# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៧១

បាលីប្រែ ៨៤ - ៨៥

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្ដីប្រែជាភាសាខ្មែរ

## កថាវត្ថុ

## បឋមភាគ-ទុតិយភាគ

# ៧១

## បាលីប្រែ ៨៤-៨៥



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧១

# អភិធម្មបិដក

# កថាវត្ថុ បឋមភាគ

*សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## បុគ្គលកថា

[ ១ ] *( សកវាទីសួរថា ) បុគ្គល គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ ( បរវាទី ឆ្លើយថា ) អើ ។ ( សកវាទី សួរថា ) បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ ( បរវាទី ឆ្លើយថា ) អ្នកមិនគួរពោលយ៉ាងនេះទេ ។ ( សកវាទី ពោលថា ) អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើបុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ម្យ៉ាងទៀត ប្រសិនបើ អ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថ*

ដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគួរពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ។

## អនុលោមបញ្ចកៈ ចប់

# អដ្ឋកថា
# បរមត្ថទីបនី
# បញ្ចបករណ៍

## កថាវត្ថុ
## អារម្ភកថា

*ព្រះសម្មាសម្ពុទ្ធជាសាស្តានៃលោក ព្រមទាំងទេវលោក ជាបុគ្គលមិនមានបុគ្គលប្រៀប ដែលពួកទេវតាសរសើរហើយ ទ្រង់គង់ប្រថាប់ក្នុងទេវលោក ទ្រង់ជាអ្នកឈ្លាសក្នុងបញ្ញត្តិទាំងពួង ទ្រង់ជាឧត្តមបុគ្គលក្នុងលោក កាលត្រាស់គម្ពីរបុគ្គលប្បញ្ញត្តិ ដែលសម្តែងដល់បញ្ញត្តិចប់ហើយ ទ្រង់បានសម្តែងកថាវត្ថុប្បករណ៍ឯណាហើយ ដោយភាពជារឿងនៃកថាទាំងឡាយមានបុគ្គលកថាជាដើម ដោយសង្ខេប ។*

*ឥឡូវនេះ លំដាប់នៃការអធិប្បាយអត្ថនៃកថាវត្ថុប្បករណ៍នោះ ដែលព្រះមានព្រះភាគទ្រង់បានចាត់តាំងហើយ ក្នុងសុរាល័យទេវលោក ដោយការផ្តើមត្រឹមតែមាតិកានោះឯង ដែលព្រះមោគ្គល្លីបុត្តតិស្សត្ថេរចែកហើយ ក្នុងមនុស្សលោក ដល់ព្រមហើយ ព្រោះហេតុនោះ ខ្ញុំនឹងពណ៌នាកថាវត្ថុប្បករណ៍នោះ សូមអ្នកទាំងឡាយ មានចិត្តតាំងមាំ សូមត្រងត្រាប់ស្តាប់កថាវត្ថុប្បករណ៍នោះហោង ។*

# និទានកថា

មានសេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះភាគទ្រង់ចាំវស្សា នាទែនបណ្ឌុកម្ពលសិលាអាសនៈ ត្រង់គល់បារិច្ឆត្តកៈ ក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស ទ្រង់ធ្វើព្រះមាតាឲ្យជាបន្ទាល់ ត្រាស់នូវព្រះអភិធម្មកថាដល់ទេវបរិស័ទ ។ កាលទ្រង់សម្ដែងបករណ៍ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិហើយ ក្នុងគ្រាសម្ដែងកថាវត្ថុ ទ្រង់ព្រះតម្រិះថា ក្នុងអនាគត សាវ័ករបស់តថាគត ឈ្មោះមោគ្គលីបុត្តតិស្សត្ថេរ ដែលមានបញ្ញាច្រើន ជម្រះមន្ទិលក្នុងសាសនាដែលកើតឡើងហើយ ខណៈធ្វើសង្គាយនាលើកទី ៣ អង្គុយកណ្ដាលជំនុំសង្ឃ នឹងរួបរួមមាតិកា ១០០០ ចូលគ្នា គឺខាងសកវាទី ៥០០ ខាងបរវាទី ៥០០ ហើយចែកបករណ៍នេះ កាលទ្រង់ធ្វើឱកាសដល់ព្រះថេរៈនោះ ទើបទ្រង់ផ្ដើមមាតិកា ដែលត្រឹមតែជាភាណវារ ដែលមិនទាន់បរិបូណ៌គ្រប់មាតិកា ដោយផ្ដើមត្រង់វាទយុត្តិ ៨ ក្នុងបុគ្គលវាទ គឺបញ្ចកៈពីរពួក ក្នុង ៤ បញ្ហា ។ បន្ទាប់មក ទ្រង់ត្រាស់អភិធម្មកថាដ៏សេស ដោយន័យដែលពិស្ដារនោះហើយ ចេញវស្សាហើយទ្រង់យាងចុះអំពីទេវលោក មកកាន់សង្កស្សនគរ ដោយជណ្ដើរកែវមណីដែលនៅត្រង់ចន្លោះជណ្ដើរប្រាក់ និងជណ្ដើរមាស ទ្រង់ញុំាងប្រយោជន៍របស់សត្វលោកឲ្យបរិបូណ៌ ទ្រង់តាំងនៅដរាបដល់ព្រះជន្មាយុ ហើយទ្រង់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

បន្ទាប់មក គណៈសង្ឃដែលជំនាញ មានព្រះមហាកស្សបៈជាប្រធាន បានព្រះបាទអជាតសត្តុ ជាអ្នកឧបត្ថម្ភ លើកគោលនៃធម្មវិន័យឡើងកាន់

ធម្មសង្គាយនា បន្ទាប់អំពីនោះមកទៀត ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្តសម្តែងវត្ថុ ១០ ប្រការ[១] ព្រះយសត្ថេរ ជាបុត្តរបស់ព្រាហ្មណ៍ឈ្មោះកាកណ្ឌកៈ ស្តាប់វត្ថុ ១០ ប្រការនោះហើយ បានព្រះបាទអសោករាជ ជាបុត្តរបស់ព្រះបាទសុសុនាគ ជាអ្នកឧបត្ថម្ភ ជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំនួនភិក្ខុ ១ លាន ២ សែនរូប ញាំញីវត្ថុ ១០ ប្រការនោះហើយ ក៏លើកគោលធម្មវិន័យឡើងកាន់សង្គាយនា ។

ភិក្ខុវជ្ជីបុត្តមានប្រមាណ ១០០០០ រូប ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយតិះដៀលហើយ ទើបស្វែងរកពួក កាលបានពួកដ៏ទុព្វល ដែលចូលជាមួយពួកខ្លួនបាន ក៏បំបែកមកតាំងត្រកូលអាចារ្យថ្មី ឈ្មោះមហាសង្ឃិកៈ ។ បន្ទាប់មក ក៏បែកចេញជាត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺគោកុលិកៈ ១ ឯកព្យោហារិកៈ ១ ។ និកាយគោកុលិកៈ បែកចេញជាត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺបណ្ណត្តិវាទ ១ ពហុលិយៈ ១ ។ ពួកវជ្ជីបុត្តនោះឯង មានឈ្មោះថា ពហុស្សុតិកៈក៏មាន ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទកើតឡើងហើយក្នុងរវាងពួកភិក្ខុវជ្ជីបុត្តទាំងនោះឯង ។ ក្នុងសតវត្សទី ២ ត្រកូលអាចារ្យទាំង ៥ កើតឡើងអំពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។ ត្រកូលអាចារ្យទាំង ៥ នោះ រួមជាមួយនឹងមហាសង្ឃិកៈខាងដើម ១ ត្រូវជា ៦ ត្រកូល ។

ក្នុងសតវត្សទី ២ នោះឯង អាចរិយវាទទាំង ២ គឺមហិសាសកៈ និង

---

១- វិនយបិដក ចុល្លវគ្គ សត្តសតិកក្ខន្ធកៈ ។

វជ្ជីបុត្តកៈ កើតឡើងដោយបែកចេញមកអំពីថេរវាទ ។ បណ្ដាអាចរិយវាទទាំង ២ នោះ អាចរិយវាទទាំង ៤ គឺធម្មុត្តរិយៈ ១ ភទ្ទយានិកៈ ១ ឆន្នាគារិកៈ ១ សមិតិយៈ ១ កើតឡើងដោយការបែកចេញមកអំពីវជ្ជីបុត្តកវាទ ។ ក្នុងសតវត្សទី ២ នោះឯង អាចរិយវាទ ២ ពួក គឺសព្វត្ថិកវាទ ១ ធម្មគុត្តិកៈ ១ កើតឡើងដោយបែកចេញមកអំពីមហិសាសកៈវាទទៀត ។ និកាយឈ្មោះកស្សបិកៈកើតឡើង ព្រោះបែកចេញអំពីត្រកូលអាចារ្យសព្វត្ថិកវាទទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏កើតជានិកាយឈ្មោះសង្កន្តិកៈទៀត កាលពួកសង្កន្តិកៈទាំងឡាយបែកគ្នាហើយ ក៏កើតជានិកាយឈ្មោះសុត្តវាទ ។ អាចរិយវាទទាំង ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកខ្វែកគ្នាមកអំពីថេរវាទ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមជាមួយនឹងថេរវាទខាងដើម ក៏ជា ១២ និកាយ ។

ក្នុងសតវត្សទី ២ អាចរិយវាទទាំងអស់ រួមជា ១៨ និកាយ គឺទាំង ១២ និកាយនេះ និងអាចរិយវាទ ៦ នៃត្រកូលអាចារ្យមហាសង្ឃិកៈ កើតឡើងហើយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ និកាយក្ដី ត្រកូលអាចារ្យ ១៨ ត្រកូលក្ដី ជាឈ្មោះនៃនិកាយដែលពោលមកហើយទាំងនោះឯង ម្យ៉ាងទៀត បណ្ដានិកាយ ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ១៧ វាទ ជានិកាយដែលបែកចេញពីគ្នាមក ចំណែកថេរវាទ ជានិកាយដែលមិនបែកគ្នា ។

# ដើម្បីឲ្យជាក់ច្បាស់ក្នុងរឿងនេះ សូមមើលបែបផែនដូចតទៅនេះ

## សម្ដែងអំពីនិកាយសតវត្សទី ៣




សមដូចពាក្យដែលលោកពោលក្នុងគម្ពីរទីបវង្ស ដូចតទៅនេះ ថា ភិក្ខុលាមកទាំងឡាយ ដែលជាវជ្ជីបុត្ត ត្រូវព្រះថេរៈទាំងឡាយបណ្ដេញចេញហើយ បានភិក្ខុដទៃជាពួកហើយ រួមគ្នាជាអធម្មវាទី មានចំនួនច្រើននាក់ ។

ភិក្ខុទាំងនោះ ប្រមាណ ១ ម៉ឺនរូប បានប្រជុំគ្នាធ្វើការរួបរួមព្រះធម្មវិន័យ ព្រោះហេតុនោះ ទើបការរួបរួមព្រះធម្មវិន័យនេះ លោកហៅថា មហាសង្គីតិ ។

ភិក្ខុទាំងឡាយ ដែលធ្វើមហាសង្គីតិ បានធ្វើនូវការជំទាស់ក្នុងព្រះសាសនា ទម្លាយសង្គាយនាដើមហើយ ធ្វើការរួបរួមព្រះធម៌វិន័យទុកមួយបែបទៀត ។

ភិក្ខុទាំងនោះ បានចងព្រះសូត្រដែលប្រមូលទុកហើយ ឲ្យទៅជាដទៃ ទម្លាយអត្ថ និងធម៌ក្នុងធម៌វិន័យផង ក្នុងនិកាយទាំង ៥ ផង ។

ម្យ៉ាងទៀត ភិក្ខុទាំងនោះ មិនដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយត្រង់ និងដោយអមទាំងមិនដឹងអត្ថ ដែលព្រះមានព្រះភាគទ្រង់ទូន្មានហើយ និងមិនដឹងអត្ថដែលគួរទូន្មាន ។

ភិក្ខុទាំងនោះ បានកំណត់អត្ថដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកដោយសំដៅយកប្រការដទៃ ឲ្យជាអត្ថមួយបែបទៀត បានធ្វើអត្ថជាច្រើនឲ្យវិនាសទៅ ព្រោះស្រមោលនៃព្យញ្ជនៈ ។

ភិក្ខុទាំងនោះ លះបង់ព្រះសូត្រខ្លះ ព្រះវិន័យដ៏ជ្រាលជ្រៅខ្លះ ហើយចងជាសូត្រក្លែងក្លាយ ព្រះវិន័យក្លែងក្លាយ ឲ្យជាបែបផែនដទៃ ។

ភិក្ខុទាំងនោះ បែកគម្ពីរបរិវារអត្ថុទ្ធារៈ ( ធម្មសង្គណី ) អភិធម្មទាំង ៦ បករណ៍ បដិសម្ភិទានិទ្ទេស ជាតកបំណែកខ្លះ មានប្រមាណប៉ុណ្ណោះចេញហើយ ចងព្រះសូត្រឲ្យជាប្រការដទៃ និងលះភាពជាប្រក្រតី នាមក្តី លិង្គក្តី បរិក្ខារក្តី អាកប្បករណីក្តី ធ្វើឲ្យជាយ៉ាងដទៃ ។

ភិក្ខុដែលធ្វើមហាសង្គីតិទាំងនោះ ជាអ្នកមានវាទបែកខ្ញែកគ្នា ជាពួកដំបូង ។

ដោយការធ្វើតាមភិក្ខុនោះ ក៏មានលទ្ធិផ្សេងគ្នាសន្ទឹកសន្ទាប់ក្រោយមក បន្ទាប់អំពីកាលនោះ ក៏កើតបែកខ្ញែកគ្នាក្នុងមហាសង្ឃិកៈនោះ ដូច្នេះ គឺ

ភិក្ខុដែលជាមហាសង្ឃិកៈបានបែកខ្ញែកគ្នាជា ២ ពួក ជាគោកុលិកៈ ១ ពួក ឯកព្យោហារិកៈ ១ ពួក តមកទៀត និកាយគោកុលិកៈ ក៏បែកគ្នាជា ២ ទៀត គឺជានិកាយពហុស្សុតិកៈ ១ ពួក និកាយបណ្ណត្តិ ១ ពួក ម្យ៉ាងទៀត ពួកចេតិយវាទ ក៏បែកមកអំពីពួកមហាសង្គីតិ បានជាពួកមួយទៀត ។

ព្រោះពួក ៥ វាទៈទាំងអស់នេះ មានមកអំពីពួកដែលធ្វើមហាសង្គីតិ ទម្លាយអត្ថ និងធម៌ ។

ភិក្ខុទាំងនោះ លះបង់នូវការរួបរួមធម៌វិន័យមួយចំណែក និងគម្ពីរមួយចំណែក ធ្វើឲ្យទៅជាដទៃ ។

ម្យ៉ាងទៀត ភិក្ខុទាំងនេះ លះនូវភាពជាប្រក្រតី ទាំងនាមលិង្គ បរិក្ខារ និងអាកប្បករណី ធ្វើឲ្យជាយ៉ាងដទៃ ។

ក្នុងចំណែកថេរវាទដែលបរិសុទ្ធ បានកើតនូវការបែកខ្ញែកគ្នាទៀត ដូច្នេះ គឺជាមហិសាសកៈ ១ ពួក វជ្ជីបុត្តកៈ ១ ពួក

ហើយវជ្ជីបុត្តកៈនោះ បានបែកចេញជា ៤ ពួកទៀត គឺ ធម្មុត្តរិកៈ ១ ភទ្ទយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ ។ ក្នុងកាលតមក ពួកមហិសាសកៈ ក៏បែកគ្នាជា ២ ទៀត គឺ ជាពួកសព្វត្ថិកវាទ ១ ធម្មគុត្តវាទ ១ ហើយសព្វត្ថិកវាទនោះ ក៏បែកចេញជាកស្សបិកៈ ហើយពួកកស្សបិកៈនោះ ក៏បែក ជាពួកសង្កន្តិកៈ ។

តមក ពួកសង្កន្តិកៈ ក៏បែកជាសុត្តវាទ តាមលំដាប់វាទៈ គឺ និកាយទាំងនេះ ទាំង ១១ ពួក បែកចេញទៅអំពីថេរវាទ ទាំងអស់ ។

ភិក្ខុទាំងនោះ ទម្លាយអត្ថផង ធម៌ផង បោះបង់នូវការរួបរួម ធម៌វិន័យចំណែកខ្លះ និងគម្ពីរចំណែកខ្លះ ហើយធ្វើឲ្យទៅជា ប្រការដទៃ ។

លះនូវភាពជាប្រក្រតី ទាំងនាម លិង្គ បរិក្ខារ និងអាកប្ប-ករណី ហើយធ្វើឲ្យទៅជាដទៃ ។

ពួកដែលមានវាទៈបែកគ្នា មាន ១៧ ពួក ពួកដែលមិន បែកគ្នាមាន ១ រួមទាំងអស់ជា ១៨ ពួក ។

ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ជាធម៌បរិសុទ្ធ បរិបូណ៌ មិនលើស មិនខ្វះ ជាគោលមាំទាំ ឧត្តមនៃថេរវាទទាំងឡាយ ហាក់បីដូចជាដើមជ្រៃធំ ដូច្នោះ ។

វាទៈដ៏សេស ដែលកើតឡើងហើយ ដូចជាបញ្ញើក្អែក កើតត្រង់ដើមឈើ មិនមានក្នុង ១០០ ឆ្នាំដំបូង តែកើតក្នុងវវាងសតវត្សទី ២ ពួក ១៧ ដែលបែកចេញមក បានកើតឡើងហើយក្នុងសាសនារបស់ព្រះជិនស្រី ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អាចរិយវាទ ៦ ដទៃទៀត គឺហេមវតិកៈ ១ រាជគិរិកៈ ១ សិទ្ធត្ថិកៈ ១ បុព្វសេលិយៈ ១ អបរសេលិយៈ ១ វាជិរិយៈ ១ កើតឡើងហើយក្នុងកាលបន្ទាប់ៗ មក អាចរិយវាទទាំងនោះ ព្រះគន្ថរចនាចារ្យលោកមិនបំណងពោលក្នុងទីនេះ ។

ព្រះរាជាទ្រង់តាំងនៅក្នុងធម៌ ព្រះនាមព្រះបាទអសោក ជាអ្នកមានសទ្ធាមាំទាំក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តទៅដោយអំណាចនៃនិកាយអាចរិយវាទទាំង ១៨ និកាយ ដែលមានមកក្នុងកាលមុន ទើបទ្រង់លះរាជសម្បត្តិ ១ ថ្ងៃ ៥ សែន រាល់ៗ ថ្ងៃ គឺដើម្បីបូជាព្រះពុទ្ធ ១ សែន បូជាព្រះធម៌ ១ សែន បូជាព្រះសង្ឃ ១ សែន ដើម្បីព្រះនិគ្រោធត្ថេរដែលជាអាចារ្យរបស់ព្រះអង្គ ១ សែន និងដើម្បីប្រយោជន៍ដល់ការព្យាបាលរោគត្រង់ទ្វារទាំង ៤ ទៀត ១ សែន បានឲ្យលាភសក្ការៈសន្ធឹកសន្ធាប់ ប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនាហើយ ។ តិរ្ថិយ គឺអ្នកបួសក្រៅព្រះពុទ្ធសាសនាទាំងឡាយ បានជាអ្នកសាបសូន្យចាកលាភសក្ការៈទាំងពួង មិនបានអ្វីតិចតួចដោយហោចសូម្បីតែអាហារ ឬសំពត់សម្រាប់បិទបាំងរាងកាយ កាលពួកគេត្រូវការលាភសក្ការៈ ទើបនាំគ្នាទៅបួសក្នុងសម្នាក់ភិក្ខុទាំងឡាយ ហើយក៏

សម្តែងទិដ្ឋិរៀងៗ ខ្លួនថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដូច្នេះ កាលតិរ្ថិយទាំងនោះមិនបានបួសតាមបំណង ក៏នាំគ្នាកោរសក់ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រដោយខ្លួនឯង បាននាំគ្នាត្រាច់ទៅក្នុងវិហារទាំងឡាយ ហើយបានចូលទៅកាន់ជំនុំសង្ឃ ក្នុងកាលដែលធ្វើឧបោសថកម្មជាដើម ។ ពួកតិរ្ថិយទាំងនោះ សូម្បីត្រូវភិក្ខុសង្ឃតិះដៀលដោយធម៌ដោយវិន័យ ដោយសត្ថុសាសនៈ គឺពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ក៏មិនអាចតាំងនៅក្នុងបដិបទាដែលសមគួរតាមព្រះធម្មវិន័យបាន បែរជាញុំាងចម្រូងចម្រាស់ មន្ទិលឧបទ្រពជាច្រើន ឲ្យកើតក្នុងព្រះពុទ្ធសាសនា គឺពួកខ្លះ បម្រើភ្លើង ពួកខ្លះ ផ្ទើរខ្លួនដោយគំនរភ្លើង ៥ គំនរ ពួកខ្លះ ងើយមុខមើលព្រះអាទិត្យរហូតទៅ ពួកខ្លះ គិតថា យើងនឹងទម្លាយធម៌ និងវិន័យរបស់ពួកលោក ដូច្នេះ ក៏នាំគ្នាព្យាយាមហើយដោយអាការនោះៗ ។ ក្នុងកាលនោះ ភិក្ខុសង្ឃមិនធ្វើឧបោសថ និងបវារណាជាមួយពួកតិរ្ថិយទាំងនោះ ។ ក្នុងអសោការាមដាច់ឧបោសថកម្មអស់ ៧ ឆ្នាំ ព្រះរាជា ទោះបីទ្រង់ព្យាយាមដោយបំណងថា អញនឹងប្រើរាជអាជ្ញាឲ្យសង្ឃធ្វើឧបោសថកម្ម ក៏មិនអាចធ្វើបាន ។ កាលពួកភិក្ខុមិនមែនតិច ត្រូវអមាត្យជាបុគ្គលល្ងង់យល់ខុសប្រហារជីវិតហើយ ការក្តៅក្រហាយព្រះហឫទ័យ ក៏បានកើតដល់ព្រះរាជាអ្នកទ្រទ្រង់ធម៌ ។ ទ្រង់មានបំណងដើម្បីរម្ងាប់ការក្តៅក្រហាយនោះ និងចង្រៃឧបទ្រពដែលកើតក្នុងព្រះពុទ្ធសាសនានោះ ទើបត្រាស់សួរសង្ឃថា អ្នកណាហ្ន៎ អាចជម្រះរឿងនេះ ទ្រង់បានស្តាប់ថា មហាបពិត្រ ព្រះមោគ្គលីបុត្តតិស្សត្ថេរ

ទ្រង់បានត្រាស់ឲ្យព្រះមោគ្គលីបុត្តតិស្សត្ថេរ និមន្តមកអំពីអហោគង្គាបព៌ត តាមពាក្យរបស់សង្ឃ ទ្រង់ក៏អស់នូវសេចក្តីសង្ស័យ ដោយអានុភាពនៃព្រះថេរៈដែលសម្តែងឥទ្ធិប្បាដិហារ្យ ទើបត្រាស់សួរនូវកង្វល់របស់ព្រះអង្គ បានញុំាងវិប្បដិសារៈឲ្យស្ងប់រម្ងាប់ហើយ សូម្បីព្រះថេរៈក៏នៅជាមួយព្រះរាជាក្នុងព្រះរាជឧទ្យាននោះឯង បានឲ្យព្រះរាជាសិក្សាក្នុងលទ្ធិសម័យអស់ ៧ ថ្ងៃ ។

ព្រះរាជាមានលទ្ធិដែលទ្រង់សិក្សាស្រេចហើយ ក៏ត្រាស់ឲ្យភិក្ខុសង្ឃទាំងឡាយមកប្រជុំគ្នាក្នុងអសោការាមក្នុងថ្ងៃទី ៧ ហើយឲ្យបាំងវាំងននធ្វើជារបងព័ទ្ធជុំវិញ ព្រះរាជាទ្រង់ប្រថាប់ខាងក្នុងវាំងនន ទ្រង់ឲ្យភិក្ខុទាំងឡាយដែលមានលទ្ធិដូចគ្នានៅជាពួកៗ និងត្រាស់ឲ្យភិក្ខុចូលទៅគាល់ម្តងមួយពួកៗ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈដូចម្តេច ។

លំដាប់នោះ ពួកសស្សតវាទី ក៏ទូលព្រះរាជាថា ព្រះសម្មាសម្ពុទ្ធមានវាទៈថា អត្តា និងលោកទៀង ។

ពួកឯកច្ចសស្សតទិដ្ឋិ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធមានវាទៈថា ទៀងដោយចំណែកខ្លះ ។ ពួកដែលជាអន្តានន្តិកទិដ្ឋិ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា លោកមានទីបំផុតក៏មាន មិនមានទីបំផុតក៏មាន ។

ពួកអមរាវិក្ខេបិកាទិដ្ឋិ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈដែលកែក្រឡះមិនឲ្យស្លាប់ខ្លួន ។

ពួកអធិច្ចសមុប្បន្និកទិដ្ឋិ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា

អត្តា និងលោកកើតឡើងឯង ។

ពួកអសញ្ញីវាទ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា អត្តាមានសញ្ញា ។

ពួកអសញ្ញីវាទ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា អត្តាមិនមានសញ្ញា ។

ពួកនេវសញ្ញីនាសញ្ញីវាទ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា អត្តាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ពួកឧច្ឆេទវាទ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថាដាច់សូន្យ ។

ពួកទិដ្ឋធម្មនិព្វានវាទ ក៏ទូលថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវាទៈថា និព្វានមានក្នុងទិដ្ឋធម៌ ។

ព្រះរាជាទ្រង់ជ្រាបថា ជនទាំងនេះ មិនមែនភិក្ខុ ជាអន្យតិរ្ថិយ ព្រោះទ្រង់បានសិក្សាលទ្ធិសម័យមកអំពីមុននោះឯង ទ្រង់ព្រះរាជទានសំពត់សដល់ពួកតិរ្ថិយទាំងនោះ ឲ្យសឹកទៅ ។ អន្យតិរ្ថិយទាំងអស់ ដែលសឹកទៅមានចំនួនរហូតដល់ ៦ ម៉ឺននាក់ ។

ព្រះរាជាត្រាស់ឲ្យភិក្ខុពួកដទៃចូលគាល់ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រះមានព្រះភាគ ទ្រង់មានវាទៈដូចម្តេច កាលភិក្ខុទាំងឡាយទូលយ៉ាងនេះថា សូមថ្វាយព្រះពរ ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាវិភជ្ជវាទៈ ទើបត្រាស់សួរព្រះមោគ្គល្លីបុត្តតិស្សត្ថេរថា ព្រះមានព្រះភាគទ្រង់ជាវិភជ្ជវាទីឬ ព្រះថេរៈទូលថា មហាបពិត្រ ពិតមែនហើយ ។

លំដាប់នោះ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ឥឡូវនេះ សាសនាបរិសុទ្ធហើយ សូមភិក្ខុសង្ឃធ្វើឧបោសថចុះ ទ្រង់ព្រះរាជទានការរក្សាហើយ យាងចូលកាន់ព្រះនគរ ។ ព្រះសង្ឃបានព្រមព្រៀងប្រជុំគ្នាធ្វើឧបោសថហើយ ក្នុងសន្និបាតនោះ មានភិក្ខុ ៦ លានរូប ។

ក្នុងសមាគមនោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ដើម្បីការពារវត្ថុទាំងឡាយដែលកើតឡើងហើយក្នុងកាលនោះ និងវត្ថុដែលនឹងកើតឡើងក្នុងកាលតទៅទាំងអស់ កាលចែកមាតិកា ដែលព្រះតថាគតទ្រង់តាំងទុកហើយ ដោយអំណាចន័យដែលព្រះសាស្តាទ្រង់បានប្រទានហើយ ទើបនាំព្រះសូត្រ ១០០០ គឺព្រះសូត្រ ៥០០ ខាងសកវាទ គឺវាទៈរបស់ខ្លួន និងព្រះសូត្រ ៥០០ ខាងបរវាទ គឺវាទៈរបស់អ្នកដទៃមក ហើយបានពោល **កថាវត្ថុប្បករណ៍** នេះ ដែលមានលក្ខណៈដ៏ធំទូលាយ ញាំញីបរមប្បវាទ គឺការជំទាស់ ឬការប្រកែករបស់អ្នកដទៃបាន ។

លំដាប់នោះ ព្រះថេរៈបានជ្រើសរើសភិក្ខុក្នុងចំនួន ៦ លាន យកតែភិក្ខុទាំងឡាយដែលទ្រទ្រង់បរិយត្តិ គឺព្រះត្រៃបិដក ដែលជាអ្នកឈ្លាសក្នុងបដិសម្ភិទាញាណ ចំនួន ១ ពាន់រូប ធ្វើតតិយសង្គីតិ ជម្រះមន្ទិលក្នុងសាសនា ដូចព្រះមហាកស្សបត្ថេរ និងព្រះយសត្ថេរសង្គាយនាព្រះធម្មវិន័យដូច្នោះ ។

ក្នុងបិដកទាំង ៣ នោះ កាលលោកសង្គាយនាព្រះអភិធម្មបិដក លោកបានលើកកថាវត្ថុប្បករណ៍ តាមដែលលោកបានពោលហើយ ឡើងកាន់សង្គាយនា ដោយហេតុនោះ ទើបគន្ថរចនាចារ្យពោលថា

ព្រះសម្មាសម្ពុទ្ធ សម្តែងកថាវត្ថុប្បករណ៍ឯណាហើយ ដោយភាពជារឿងនៃកថាទាំងឡាយ មានបុគ្គលប្បកថាជាដើម ដោយសង្ខេប ឥឡូវនេះ លំដាប់នៃការពណ៌នាកថាវត្ថុប្បករណ៍ ដែលព្រះមានព្រះភាគទ្រង់ប្រតិស្ឋានហើយ សុភាលយទេវលោក ដោយការផ្តើមតាំងទុកត្រឹមតែមាតិកានោះឯង ដែលព្រះមោគ្គលីបុត្តតិស្សត្ថេរ ចែកហើយក្នុងមនុស្សលោកដល់ព្រមហើយ ព្រោះហេតុនោះ ខ្ញុំនឹងអធិប្បាយកថាវត្ថុប្បករណ៍នោះ សូមអ្នកទាំងឡាយ មានចិត្តតាំងមាំ ចូរស្តាប់កថាវត្ថុប្បករណ៍នោះឯងហោង ៕

**និទានកថា ចប់**

# អដ្ឋកថា

## មហាវគ្គ

## បុគ្គលកថា

### សុទ្ធសច្ចិកដ្ឋៈ

### អនុលោមបច្ចនីកៈ

*នឹងពោលពាក្យអធិប្បាយបទថា* **សច្ចិកដ្ឋ** *មុន ដូចតទៅ*

*[ ១ ] បណ្ដាបទទាំងនោះ បទថា* **បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋ-បរមដ្ឋេន** *នេះ ជាពាក្យសួរ ។*

*បទថា* **អាមន្តា** *នេះ ជាពាក្យឆ្លើយទទួល ។*

*សួរថា ពាក្យដែលសួរថា បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដម*[១] *ឬនឹងឆ្លើយទទួលថា អើ នេះ ជារបស់អ្នកណា ឆ្លើយថា ពាក្យសួរ និងពាក្យឆ្លើយនេះ បុគ្គលណាមួយ មិនគួរពោលថា ជារបស់បុគ្គលឈ្មោះនោះ ព្រោះថា ក្នុងបករណ៍នេះ ព្រះមានព្រះភាគទ្រង់តាំងមាតិកាសម្រាប់ជាបែបផែន ដើម្បីជម្រះលទ្ធិដែលយល់ខុសទាំងឡាយ មានប្រការផ្សេងៗ ។ ព្រះមោគ្គលីបុត្តតិស្សត្ថេរ លោកតាំងមាតិកានេះ តាមន័យដែលព្រះសាស្ដាទ្រង់ប្រទាន ហើយចែកតាមបែបផែន ដែលព្រះមានព្រះភាគទ្រង់*

---

**១- *អត្ថដ៏ពិត និងអត្ថដ៏ឧត្តម បានដល់ ចិត្ត ចេតនា រូប និព្វាន ។***

សម្តែងនោះ ។ម្យ៉ាងទៀត វាទមគ្គ គឺគន្លងនៃវាទ ដែលព្រះសាស្តាទ្រង់សម្តែងក្នុងបករណ៍នេះ មានប្រមាណប៉ុនណា ព្រះថេរៈមិនបានសម្តែងវាទមគ្គ ដែលជាវាទឆ្លើយឆ្លងគ្នា ដោយវាទមានប្រមាណប៉ុណ្ណោះ ។ កាលបើយ៉ាងនេះ ដើម្បីកំណត់អត្ថនៃពាក្យទាំងនោះបានដោយងាយ ខ្ញុំ ( ពុទ្ធ-ឃោសាចារ្យ ) នឹងសម្តែងការចែកសេចក្តីយ៉ាងនេះ គឺជាពាក្យសួររបស់សកវាទី ១ ជាពាក្យឆ្លើយរបស់បរវាទី ១ ជាពាក្យសួររបស់បរវាទី ១ ជាពាក្យឆ្លើយរបស់សកវាទី ១ ហើយនឹងពណ៌នាសេចក្តីតទៅ

បទថា **បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន** នេះ ជាពាក្យសួររបស់សកវាទី ។ ដោយពាក្យសួរនោះ លោកសម្តែងថា ជនពួកណា ជាបុគ្គលវាទី មានការយល់ឃើញយ៉ាងនេះថា បុគ្គលមាន បណ្ឌិតគួរសួរជនទាំងនោះយ៉ាងនេះ ។ សួរថា ជនពួកណាជាបុគ្គលវាទី ឆ្លើយថា ពួកភិក្ខុដែលជានិកាយវជ្ជីបុត្តកៈ ពួកភិក្ខុដែលជានិកាយសមិតិយៈ ក្នុងព្រះពុទ្ធ-សាសនា និងអញ្ញតិត្ថិយជាច្រើន ខាងក្រៅព្រះពុទ្ធសាសនា ។

បណ្តាបទទាំងនោះ បទថា **បុគ្គលោ** បានដល់ អត្តា សត្វ និងជីវៈ ។ បទថា **ឧបលព្ភតិ** មានអធិប្បាយថា បុគ្គលចូលដល់ហើយ រមែងបានដោយបញ្ញា គឺរមែងដឹងបាន ។ បទថា **សច្ចិកដ្ឋោ** ក្នុងបទថា **សច្ចិកដ្ឋ-បរមដ្ឋេន** នេះ បានដល់ អត្ថដែលពិត ដែលមិនគប្បីកាន់យកដោយការដែលមិនពិត ដូចថ្ងៃបណ្តើរកូនដែលជាមាយាជាដើម ។ បទថា **បរមដ្ឋោ** បានដល់ អត្ថដ៏ឧត្តមដែលមិនគប្បីកាន់យក ដោយអំណាចនៃពាក្យដែល

ឮតៗ គ្នាមកជាដើម ។ ដោយអត្ថទាំងពីរ ( សច្ចិកដ្ឋ និងបរមដ្ឋ ) ប្រភេទនៃធម៌ ៥៧ ឯណា ព្រះមានព្រះភាគទ្រង់សម្ដែងខាងមុខដោយអំណាចខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ និងឥន្ទ្រិយ ២២ ( រួមជា ៥៧ ) ដោយន័យជាដើមថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដមឬ[១] សកវាទីសួរថា ប្រភេទនៃធម៌នោះដែលបណ្ឌិតរមែងដឹងបាន ដោយសេចក្ដីពិត ដោយអត្ថដែលពិតយ៉ាងណា លោកដឹងបុគ្គលបានយ៉ាងនោះឬ បរវាទីឆ្លើយទទួលថា **អាមន្តា** ។ ពាក្យទទួលដែលមកក្នុងកាលខ្លះ លោកប្រើពាក្យថា **អាមភន្តេ** និងក្នុងកាលខ្លះប្រើពាក្យថា **អាមោ** ។ តែក្នុងកថាវត្ថុនេះ លោកប្រើពាក្យថា **អាមន្តា** ។ អធិប្បាយក្នុងពាក្យថា **អាមន្តា** មានដូច្នេះ

បរវាទីបុគ្គល កាន់យកព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ខាងមុខថា បុគ្គលដែលបដិបត្តិដើម្បីប្រយោជន៍ខ្លួនមានហើយ ទើបកាន់យកលទ្ធិថា ព្រោះព្រះមានព្រះភាគជាសច្ចវាទី ទ្រង់មិនជាបុគ្គលមានចេតនាពោលឲ្យយៀងឃ្លាត ទ្រង់មិនសម្ដែងធម៌ដោយអំណាចនៃពាក្យដែលបានស្ដាប់តៗ គ្នាជាដើម តែទ្រង់ធ្វើលោកនេះ និងទេវលោកឲ្យជាក់ច្បាស់ ដោយព្រះអង្គឯង ហើយប្រកាសសាសនា ហេតុនោះ បុគ្គលណា ដែលព្រះមានព្រះភាគត្រាស់ថា បុគ្គលដែលបដិបត្តិដើម្បីប្រយោជន៍ខ្លួនមាន បុគ្គលនោះ ត្រូវមានដោយ **សច្ចិកដ្ឋ** និង **បរមដ្ឋ** ទើបត្រូវទទួលថា អើ ។

---

១- បិដកខ្មែរ ឃ្នាប ១៧ ។

ពេលនោះ សកវាទី កាលមិនឲ្យឱកាសដល់បរវាទីនោះ ដែលមានពាក្យជាលេស មានពាក្យជាកល ទើបពោលពាក្យថា **យោ សច្ចិកដ្ឋោ បរមដ្ឋោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន** បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ដូច្នេះ ។

គប្បីជ្រាបពាក្យអធិប្បាយក្នុងពាក្យនោះដូចតទៅ ប្រភេទនៃធម៌ ៥៧ មានរូបជាដើមឯណា ដែលព្រះមានព្រះភាគទ្រង់សម្ដែងខាងមុខយ៉ាងនេះថា មានបច្ច័យ មិនមានបច្ច័យ ជាសង្ខតៈ ជាអសង្ខតៈ ជារបស់ទៀង ជារបស់មិនទៀង មាននិមិត្ត មិនមាននិមិត្ត ប្រភេទនៃធម៌នោះ បណ្ឌិតមិនគប្បីកាន់យកដោយសម្មតិសច្ចៈ និងមិនគប្បីកាន់យកតាមការឮតៗ គ្នាជាដើម ។ ប្រភេទនៃធម៌ ៥៧ យ៉ាងនេះឯង ឈ្មោះថា **សច្ចិកដ្ឋ** ព្រោះភាពដែលខ្លួនជាសភាវៈមានពិតនោះឯង និងឈ្មោះថា **បរមដ្ឋ** ព្រោះភាពប្រចក្សច្បាស់ដល់ខ្លួនឯង សកវាទីសំដៅយកអត្ថទាំងពីរយ៉ាងនេះ ទើបសួរថា **យោ សច្ចិកដ្ឋោ បរមដ្ឋោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន** បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ដូច្នេះ ។

បទថា **តតោ** ជាតតិយាវិភត្តិ ព្រោះហេតុនោះ ទើបក្នុងទីនេះ មានសេចក្ដីអធិប្បាយថា លោកដឹងបុគ្គលនោះបាន ដោយសច្ចិកដ្ឋបរមដ្ឋនោះឬ ពាក្យនេះ លោកអធិប្បាយថា សកវាទីសួរថា សភាវធម៌ណា ដែលជា

**សច្ចិកដ្ឋបរមដ្ឋ** ដែលបណ្ឌិតស្ទង់ដឹងបាន ដោយអាការ ដោយលក្ខណៈមានរុប្បនលក្ខណៈជាដើម ឬដោយសភាវធម៌ មានសង្ខតៈជាដើម អ្នកស្ទង់ដឹងបុគ្គលនោះបាន ដោយអាការនោះឬ ។

បទថា **ន ហេវំ វត្តព្វេ** ជាពាក្យបដិសេធរបស់បរវាទី ។ បរវាទីនោះមិនគាប់ចិត្តបុគ្គលបែបនោះ ទើបបដិសេធ ។ បទថា **ន ឃវំ វត្តព្វេ** នេះ កាត់បទជា **ន ហិ ឃវំ វត្តព្វេ** ឬកាត់បទជា **ន ហ ឃវំ** ដូច្នេះ ក៏សមគួរទោះជាយ៉ាងនោះ បទទាំង ២ នោះក៏មានអត្ថថា មិនគប្បីពោលយ៉ាងនោះ ។

បទថា **អាជានាហិ និគ្គហំ** ជាពាក្យរបស់សកវាទី អធិប្បាយថា សកវាទីពោលថា ព្រោះពាក្យប្តេជ្ញាបដិសេធពាក្យក្រោយរបស់អ្នក មិនសមគ្នានឹងពាក្យប្តេជ្ញាទទួលដើម និងពាក្យប្តេជ្ញាទទួលខាងដើម មិនសមគួរគ្នានឹងពាក្យប្តេជ្ញាបដិសេធខាងចុង ហេតុនោះ លោកដល់នូវនិគ្គហៈ គឺចូរទទួលនិគ្គហៈ គឺទោស បានដល់ កំហុសនោះ ។ កាលសកវាទីឲ្យបរវាទីទទួលនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ កាលធ្វើនិគ្គហៈនោះឲ្យប្រាកដដោយអំណាចនៃ **ឋបនា** គឺការតាំង **ចាបនា** គឺការឲ្យដល់ **អារោបនា** គឺការលើកឡើងដោយអនុលោម និងបដិលោម ទើបពោលពាក្យថា **ហញ្ចិ បុគ្គលោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ហញ្ចិ បុគ្គលោ** បានដល់ បើបុគ្គលត្រូវស្ទង់ដឹងបាន អធិប្បាយថា បើលោកស្ទង់ដឹងបុគ្គលបាន ដោយអត្ថដ៏ពិតនិងអត្ថដ៏ឧត្តមសោត ។ បទថា **ហញ្ចិ បុគ្គលោ** នេះ ឈ្មោះថា អនុ-

លោមឋបនា ព្រោះជាលក្ខណៈនៃការឲ្យដល់ និងការលើកឡើងនូវនិគ្គហៈ ដោយការតាំងទុករបស់បរវាទី ។ បទថា **តេន វត រេ** ជាដើម ឈ្មោះថា អនុលោមបាបនា ព្រោះភាពដែលមាននិគ្គហៈ ដែលសកវាទីឲ្យដល់ហើយ ក្នុងចំណែកនៃអនុលោម ។ បណ្ដាបទទាំងនោះ បទថា **តេន** ជាពាក្យសម្ដែងដល់ហេតុ ។ បទថា **វត** ជាបទសម្ដែងដល់ការជឿមាំ ។ បទថា **រេ** ជាពាក្យសម្រាប់ហៅ លោកអធិប្បាយបទថា **តេន វត រេ វត្តព្វេ** នេះថា នៃអ្នកមានមុខស្រស់ដ៏ចម្រើន ព្រោះហេតុនោះ ទើបអ្នកគួរពោលនោះឯង ។ បទថា **យំ តត្ថ វទេសិ** ជាដើម ឈ្មោះថា អនុលោមរោបនា ( ការលើកឡើងដោយអនុលោម ) ព្រោះភាពដែលនិគ្គហៈ ដែលសកវាទីលើកឡើងហើយ ក្នុងចំណែកនៃអនុលោម ។ម្យ៉ាងទៀត បទថា **មិច្ឆា** ក្នុងទីបំផុតនៃអនុលោមនោះ អ្នកសិក្សាគប្បីនាំបទថា **ឥទន្តេ** មកប្រកបខាងមុខនៃបទថា **មិច្ឆា** នោះ ។ ក្នុងពាក្យនេះ លោកអធិប្បាយថា ការឃើញរបស់អ្នកនេះខុស សេចក្ដីនេះ មានក្នុងព្រះបាលីខាងមុខនោះឯង ។

បទថា **នោ ចេ បន វត្តព្វេ** ជាដើម ឈ្មោះថា បដិលោមឋបនា ( ការតាំងទុកដោយបដិលោម ) ព្រោះជាលក្ខណៈនៃការឲ្យដល់ និងការលើកឡើងនូវនិគ្គហៈ ដោយបដិលោម ព្រោះលោកតាំងទុកក្នុងចំណែកបដិសេធថា អ្នកមិនគួរពោលយ៉ាងនេះទេ ។ បទថា **នោ វត រេ** ជាដើម ឈ្មោះថា បដិលោមបាបនា ( ការឲ្យដល់ដោយបដិលោម ) ព្រោះភាពដែលនិគ្គហៈ ដែលសកវាទីឲ្យដល់ហើយ ក្នុងចំណែកបដិលោម ។ បទថា **យំ**

**តត្ថ វាទេសិ** ជាដើម ឈ្មោះថា បដិលោមពេបនា ( ការលើកឡើងខាងបដិលោម ) ព្រោះសកវាទីលើកនិគ្គហៈក្នុងចំណែកនៃបដិលោមឡើង ។ បទថា **មិច្ឆា** ក្នុងទីបំផុតនេះ គប្បីនាំពាក្យថា **តេនហេ** មកដាក់ខាងមុខដូចគ្នា ។ ក្នុងឋានៈទាំងឡាយដែលមានសភាពយ៉ាងនេះ ខាងមុខក៏មានន័យនេះឯង ។

បណ្ឌិតគប្បីជ្រាបអត្ថសង្ខេបតាំងអំពីដើម ក្នុងបទថា **ហញ្ចិ បុគ្គលោ ។បេ។ សច្ចិកដ្ឋបរមដ្ឋេន** នោះ ដូចតទៅនេះថា បើអ្នកស្គាល់ដឹងបុគ្គលបាន ដោយសច្ចិកដ្ឋៈ និងបរមដ្ឋៈសោត ដោយហេតុនោះឯង ទើបគប្បីពោលថា ខ្ញុំស្គាល់ដឹងបុគ្គលបាន ។ អ្នកពោលពាក្យណា ក្នុងបញ្ហានោះថា គប្បីពោលក្នុងបញ្ហាដំបូងថា ខ្ញុំស្គាល់ដឹងបុគ្គលបានដោយសច្ចិកដ្ឋបរមដ្ឋៈ តែមិនគប្បីពោលក្នុងបញ្ហាទី ២ ថា ខ្ញុំស្គាល់ដឹងបុគ្គលនោះបាន តាមសភាវៈនោះ ដូច្នេះ ពាក្យនេះ របស់អ្នកខុស ព្រោះហេតុនោះ ទើបមានការតាំងការឲ្យដល់ និងការលើកឡើង ដោយអនុលោម ដូចពណ៌នាមកដូច្នេះសិន ។

ម្យ៉ាងទៀត កាលមិនគប្បីពោលក្នុងបញ្ហាទី ២ ថា ខ្ញុំស្គាល់ដឹងបុគ្គលនោះបានតាមសភាវៈនោះ សូម្បីក្នុងបញ្ហាដំបូង ក៏មិនគប្បីពោលទទួលបែបនោះ ។ លោកពោលពាក្យណាក្នុងបញ្ហានោះថា គប្បីពោលក្នុងបញ្ហាដំបូងថា ខ្ញុំឃើញបុគ្គលដោយសច្ចិកដ្ឋៈ និងបរមដ្ឋៈ តែក្នុងបញ្ហាទី ២ មិនពោលថា ខ្ញុំស្គាល់ដឹងបុគ្គលបាន ដោយសច្ចិកដ្ឋបរមដ្ឋៈ តែមិនគប្បីពោលក្នុងបញ្ហាទី ២ ថា ខ្ញុំស្គាល់ដឹងបុគ្គលនោះបាន ... តាមសភាវៈនោះ ដូច្នេះ ពាក្យនេះ របស់អ្នកខុស ព្រោះហេតុនោះ ទើបមានការតាំងការឲ្យដល់ ការលើកឡើង

ដោយបដិលោមដូចពណ៌នាមកនេះ ។

បទថា **ឧបលព្ភតិ** ជាដើមនោះ ឈ្មោះថា **អនុលោមបញ្ចក** ព្រោះជាពាក្យដែលលោកពោលដល់និគ្គហៈ និងពោលដល់ឋាបនា និងរោបនា ៤ ដោយអនុលោម និងបដិលោម ( រួមជា ៥ ) ដោយប្រការដូច្នេះ ។ ក្នុងធម៌ទាំងនោះ លោកធ្វើនិគ្គហៈ ២ យ៉ាង គឺនិគ្គហៈ ១ ធ្វើដោយឋាបនា និងរោបនាដោយអនុលោម និគ្គហៈមួយទៀត ធ្វើដោយឋាបនា និងរោបនាដោយបដិលោមក៏ពិត តែក្នុងនិគ្គហៈទាំង ២ នេះ ក៏មាននិគ្គហៈនេះ ត្រឹមតែមួយ ព្រោះនិគ្គហៈទី ១ នេះឯងថា **អាជានាហិ និគ្គហំ** ចូរអ្នកដឹងនូវកំហុសចុះ អាស្រ័យវាទៈដំបូងថា **សោ បុគ្គលោ ឧបលព្ភតិ** បុគ្គលនោះ គេដឹងបាន ... ហើយត្រូវលើកឡើងដោយអាការ ២ យ៉ាង និគ្គហៈនេះ ឈ្មោះថា ជានិគ្គហៈទី ១ ដោយប្រការដូច្នេះ ។៚

# អភិធម្មបិដក

## បដិកម្មចតុក្កៈ

[ ២ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើបុគ្គលគេមិនដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថក៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគួរពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះ

ដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគួរពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ។

បដិកម្មចតុក្កៈ ចប់

# អដ្ឋកថា

## បដិកម្មចតុក្កៈ

[ ២ ] ឥឡូវនេះ ជានយ័ដែលជាសូត្រ ។ ក្នុងន័យនេះ ពាក្យសួរជាពាក្យរបស់បរវាទី ព្រោះថា បរវាទីនោះ មិនព្រមទទួលថា **ឆ្វបលព្ភតិ** ព្រោះប្រកាន់ថា មានបុគ្គលដែលបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯង ទើបសួរយ៉ាងនេះ ។ សកវាទីរមែងទទួលថា **អាមន្តា** ព្រោះមិនគប្បីស្គាល់ដឹងបានដូចដែលឃើញធម៌មានរូបជាដើម ។ បរវាទីពោលពាក្យថា **យោ សច្ចិកដ្ឋោ** ជាដើមទៀត សំដៅយកសភាវៈដែលពិត ( សច្ចិកដ្ឋៈ ) ដែលសំដៅយកថាជាខ្លួន ។ ម្យ៉ាងទៀត បរវាទីពោលហើយយ៉ាងនេះ ដោយធ្វើសម្មតិសច្ចៈនិងបរមត្ថសច្ចៈឲ្យជារបស់តែមួយ ។ សកវាទីបដិសេធថា **ឆ ហេវំ** ព្រោះសភាវៈដែលពិត ដោយបញ្ញត្តិដែលចូលទៅកាន់យកថា បុគ្គល ព្រោះសច្ចៈទាំង ២ ត្រូវសួរធ្វើឲ្យជារបស់តែមួយ ។

ឥឡូវនេះ សកវាទីនោះ ទទួលការស្គាល់ដឹងបុគ្គលមិនបានដោយអំណាចបរមត្ថសច្ចៈមុនហើយ ខាងក្រោយ ត្រឡប់បដិសេធដោយអំណាចសម្មតិ-សច្ចៈ ឬដោយអំណាចសច្ចៈទាំង ២ លាយឡំក៏ពិត តែបរវាទី អាស្រ័យវាទៈដែលមានលេស ត្រឹមតែពាក្យទូទៅថា **ឆ្វបលព្ភតិ** ដូច្នេះ កាលធ្វើតបនូវនិគ្គហកម្ម ដែលសកវាទីធ្វើហើយដល់ខ្លួន ដូចធ្វើនូវជម្លោះតប ដល់ការឈ្មោះថា អ្នកទទួលពាក្យណាមុនហើយ ខាងក្រោយ ត្រឡប់បដិសេធពាក្យនោះ ទើបពោលពាក្យថា **អាជានាហិ បដិកម្មំ** ។ ឥឡូវនេះ សកវាទីធ្វើនូវ

ការតាំងវាទៈ ហើយធ្វើនូវនិគ្គហៈឲ្យប្រាកដដោយបាបនា និងរោបនា ដោយអនុលោម និងបដិលោម ក្នុងអនុលោមបញ្ចកៈ ដល់បរវាទីនោះ ដោយវិធីណា បរវាទីកាលធ្វើបដិកម្មឲ្យប្រាកដដោយវិធីនោះ ទើបពោលពាក្យថា **ហាញ្ចិ បុគ្គលោ** ជាដើម ។ សេចក្ដីនោះ បណ្ឌិតគប្បីជ្រាបដោយអត្ថតាមន័យដែលពោលហើយខាងដើមនោះឯង តែព្រោះក្នុងសេចក្ដីនេះ ឈ្មោះថា **ឋបនា** រមែងត្រឹមតែជាការតាំងប៉ុណ្ណោះ ដើម្បីសម្ដែងថា នេះជាទោសរបស់អ្នក ដោយការតាំងទុកនៃចំណែកបរវាទី ។ មិនបានជាការធ្វើនិគ្គហៈ ឬបដិកម្មឲ្យប្រាកដ តែជាការធ្វើឲ្យប្រាកដដល់សកវាទីនោះ ដោយបាបនា និងរោបនា ព្រោះហេតុនោះ ទើបសេចក្ដីនេះ ឈ្មោះថា **បដិកម្មចតុក្ក** ព្រោះភាពនៃបដិកម្ម ដែលបរវាទីធ្វើហើយដោយអាការ ៤ យ៉ាង ដោយអំណាចបាបនា និងរោបនា ដោយអនុលោម និងបដិលោម ដោយប្រការដូច្នេះ ។ គប្បីជ្រាបចតុក្កៈដូចពណ៌នាមក ដូច្នេះ ៕

## អដ្ឋកថាបដិកម្មចតុក្កៈ ចប់

# អភិធម្មបិដក

## និគ្គហចតុក្កៈ

[ ៣ ] ប្រសិនបើ អ្នកសម្គាល់ថា អ្នកគួរពោលថា បុគ្គលគេមិនដឹង បានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មាន អត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយ អត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះហេតុនោះ កាលអ្នកប្ដេជ្ញាយ៉ាងនេះ ដោយពាក្យប្ដេជ្ញានេះ ក្នុងចំណែកនៃពាក្យថា គេមិនដឹងនោះ ត្រូវយើងសង្កត់ សង្កិនយ៉ាងនេះឯង កាលបើយើងសង្កត់សង្កិនអ្នក អ្នក ឈ្មោះថា យើងសង្កត់ សង្កិនត្រឹមត្រូវហើយ ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យ ណា គួរពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគួរពោលថា

បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះពាក្យរបស់អ្នកនេះ ជាពាក្យខុស ។

**និគ្គហចតុក្កៈ ចប់**

# អដ្ឋកថា

## និគ្គហចតុក្កៈ

[ ៣ ] កាលបរវាទីណា ដែលសកវាទី ធ្វើនិគ្គហៈ ក្នុងអនុលោមបញ្ចកៈ កាលធ្វើបដិកម្មយ៉ាងនេះហើយ ឥឡូវនេះ បានអាស្រ័យវាទៈដែលមានលេសនោះៗ សម្តែងការធ្វើដែលមិនប្រពៃ របស់សកវាទីនោះ ទើបពោលពាក្យថា **ត្វញ្ចេ បន មញ្ញសិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ត្វញ្ចេ បន មញ្ញសិ** បានដល់ បើអ្នកនៅអះអាង ។

បទថា **វត្តព្វេ ខោ** នេះ លោកពោលសំដៅយកពាក្យទទួលថា អើ ក្នុងគន្លងនៃការយល់ជំទាស់ ។ បទថា **នោ ច វត្តព្វេ** នេះ លោកពោលសំដៅយកពាក្យបដិសេធថា **ន ហេវំ** ។ បទថា **តេន តំ តត្ថ** បានដល់ ដោយហេតុនោះ អ្នកនោះឯង រមែងមានក្នុងចំណែកនោះថា **បុគ្គលោ នូបលព្ភតិ** ។ បទថា **ហេវំ បដិជានន្តំ** បានដល់ ទទួលយ៉ាងនេះថា **អាមន្តា** ។ បទថា **ហេវំ និគ្គហេតព្វេ** សេចក្តីថា កាលអ្នកបដិសេធដោយពាក្យថា **ន ហេវំ** គប្បីត្រូវនិគ្គហៈយ៉ាងនេះទៀត ។ បទថា **អថ តំ និគ្គណ្ហាម** សេចក្តីថា ពេលនោះ ពួកយើងរមែងនិគ្គហៈនូវអ្នកដែលគួរដល់ការនិគ្គហៈ

ដោយអាការយ៉ាងនេះ ។ បទថា **សុនិគ្គហិតោ ច ហោសិ** សេចក្ដីថា អ្នកឈ្មោះថា ជាបុគ្គលត្រូវខ្ញុំនិគ្គហៈដោយប្រពៃហើយ ព្រោះត្រូវនិគ្គហៈ ដឹ្បតមតិរបស់ខ្លួន ។

បរវាទីនោះ កាលសម្ដែងនូវការៈដែលសកវាទី គប្បីត្រូវនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងនិគ្គហៈសកវាទីនោះ ទើបពោលពាក្យថា **ហញ្ចិ** ជាដើម ។

បណ្ដាបទទាំងនោះ បណ្ឌិតគប្បីជ្រាបបទថា **ឋបនា ឲាបនា** និង **រោបនា** ដោយន័យដែលពោលហើយខាងដើមនោះឯង ។ បទថា **តេន តេ មិច្ឆា** ក្នុងខាងចុង មានអធិប្បាយថា ពាក្យរបស់អ្នកនេះខុស ។ សេចក្ដីនេះ ឈ្មោះថា និគ្គហចតុក្កៈ ព្រោះបរវាទីធ្វើនិគ្គហៈ ដោយអាការ ៤ យ៉ាង ដោយវាទៈដែលមានលេស ។៚

**អដ្ឋកថានិគ្គហចតុក្កៈ ចប់**

# អភិធម្មបិដក

## ឧបនយនចតុក្កៈ

[ ៤ ] បើវាទៈរបស់អ្នកនុ៎ះ យើងសង្កត់សង្កិនបានដោយលំបាក អ្នកចូរឃើញក្នុងពាក្យសង្កត់សង្កិនយើងនោះ យ៉ាងនេះថា អ្នកគួរពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណាមានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះឡើយ តែយើងកាលប្តេជ្ញាយ៉ាងនេះ ដោយពាក្យប្តេជ្ញានេះ ក្នុងពាក្យថា អើ ក្នុងអនុលោមបញ្ចកៈនោះ អ្នកមិនត្រូវសង្កត់សង្កិនយ៉ាងនេះទេ កាលបើអ្នកសង្កត់សង្កិនយើង យើង ឈ្មោះថា អ្នកសង្កត់សង្កិន មិនត្រឹមត្រូវឡើយ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគួរពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថ

ដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគួរពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះពាក្យរបស់អ្នកនេះ ជាពាក្យខុស ។

**ឧបនយនចតុក្កៈ ចប់**

# អដ្ឋកថា

## ឧបនយនចតុក្កៈ

[ ៤ ] កាលបរវាទីធ្វើនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងថា បើនិគ្គហៈនេះ ដែលខ្ញុំធ្វើព្រោះមតិរបស់អ្នក ជានិគ្គហៈខុសភ្លាំងភ្លាត់សោត និគ្គហៈឯណា ដែលអ្នកធ្វើហើយដល់ខ្ញុំ ក្នុងអនុលោមបញ្ចកៈ និគ្គហៈនោះ ក៏ជានិគ្គហៈខុសភ្លាំងភ្លាត់ ទើបពោលពាក្យថា **ឯសេ ចេ ទុន្និគ្គហិតេ** ។ បណ្តាបទទាំងនោះ បទថា **ឯសេ ចេ ទុន្និគ្គហិតេ** សេចក្តីថា បើវាទៈរបស់អ្នកនេះ ជាវាទៈដែលខ្ញុំនិគ្គហៈខុសភ្លាំងភ្លាត់សោត ។ ម្យ៉ាងទៀត បើនិគ្គហៈដែលខ្ញុំធ្វើដល់អ្នកនេះ ជានិគ្គហៈភ្លាំងភ្លាត់សោត ។ បទថា **ហេវមេវំ តត្ថ ទក្ខ** សេចក្តីថា ចូរអ្នកឃើញយ៉ាងនេះៗ ក្នុងនិគ្គហៈ ដែលអ្នកធ្វើហើយដល់ខ្ញុំខាងដើមនោះ ។ ឥឡូវនេះ និគ្គហៈឯណា ដែលសកវាទីធ្វើហើយដល់បរវាទីនោះខាងដើម បរវាទីនោះ កាលសម្តែងនូវនិគ្គហៈនោះ ដោយពាក្យថា **វត្តព្វេ ខោ** ជាដើមដូច្នេះហើយ កាលបង្អោននូវនិគ្គហៈនោះ ទៅកាន់ភាពមិនជានិគ្គហៈទៀត ទើបពោលពាក្យថា **នោ ច មយំ តយា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **នោ ច មយំ តយា តត្ថ ហេតាយ បដិញ្ញាយ** ជាដើម មានអធិប្បាយថា ព្រោះនិគ្គហៈនោះ ដែលអ្នកធ្វើហើយ

ដល់ខ្ញុំ ជានិគ្គហៈខុសក្លាំងក្លាត់ ព្រោះហេតុនោះ ពួកខ្ញុំកាលទទួលយ៉ាងនេះ ដោយពាក្យប្ដេជ្ញានោះថា **អាមន្តា** កាលពាក្យបដិសេធ ខ្ញុំធ្វើទៀតហើយថា **ន ហេវំ** ក្នុងអនុលោមបញ្ចកៈនោះ ក៏ត្រូវអ្នកធ្វើនិគ្គហៈយ៉ាងនោះថា **អាជានាហិ និគ្គហំ** អ្នកនិគ្គហៈខ្ញុំ ដែលមិនគួរនិគ្គហៈយ៉ាងនេះ ពួកខ្ញុំត្រូវអ្នកនិគ្គហៈខុសក្លាំងក្លាត់ហើយ ដោយនិគ្គហៈបែបនេះ ។

ឥឡូវនេះ បរវាទីនោះ សំដៅដល់និគ្គហៈឯណា បានពោលហើយថា **ទុន្និគ្គហិតា ច ហោម** ដើម្បីសម្ដែងនិគ្គហៈនោះ ទើបពោលពាក្យថា **ហញ្ចិ បុគ្គលោ ។បេ។ ឥទំ តេ មិច្ឆា** ជាដើម ។

នេះ ឈ្មោះថា **ឧបនយនចតុក្ក** ព្រោះនិគ្គហៈដែលបរវាទីនោះបង្អោនទៅហើយដោយបាបនា និងរោបនា ៤ ដោយអនុលោម និងបដិលោមដូចពណ៌នាមក ដូច្នេះ ។

**អដ្ឋកថាឧបនយនចតុក្កៈ ចប់**

# អភិធម្មបិដក

## និគ្គមចតុក្កៈ

[ ៥ ] ខ្ញុំមិនត្រូវអ្នកសង្កត់សង្កិន យ៉ាងនេះទេ ព្រោះហេតុនោះ អ្នកសង្កត់សង្កិនខ្ញុំថា ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដោយហេតុណា ម្នាលអ្នកដ៏ចម្រើន ហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា

បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ដ្បិតពាក្យរបស់អ្នកនេះ ជាពាក្យខុស ព្រោះហេតុនោះ សេចក្តីសង្កត់សង្កិនណា ដែលអ្នកធ្វើហើយ សេចក្តីសង្កត់សង្កិននោះ គឺអ្នកធ្វើមិនត្រឹមត្រូវទេ អំពើផ្ទុយ ខ្ញុំធ្វើល្អហើយ ការញ៉ាំងរបៀបពាក្យឲ្យសម្រេច ខ្ញុំបានធ្វើល្អហើយ ។

**និគ្គមចតុក្កៈ ចប់**

**និគ្គហៈទី ១ ចប់**

# អដ្ឋកថា

## និគ្គមនចតុក្កៈ

[ ៥ ] ឥឡូវនេះ ពាក្យថា **ន ហោវំ និគ្គហោតព្វេ** ឈ្មោះថា **និគ្គមនចតុក្កៈ** ក្នុងបទទាំងនោះ បទថា **ន ហោវំ និគ្គហោតព្វេ** សេចក្តីថា ខ្ញុំត្រូវអ្នកនិគ្គហៈហើយយ៉ាងណា ខ្ញុំមិនគួរត្រូវនិគ្គហៈយ៉ាងនោះ ព្រោះថា ភាពដែលនិគ្គហៈនេះ ជានិគ្គហៈខុសក្បាំងក្បាត់ ដែលខ្ញុំឲ្យសម្រេចហើយ ។ បទថា **តេន ហិ** សេចក្តីថា ដោយហេតុនោះ គឺព្រោះហេតុណា និគ្គហៈនេះ ជានិគ្គហៈខុសក្បាំងក្បាត់ ព្រោះហេតុនោះ អ្នកដាក់និគ្គហៈឯណាជាមួយខ្ញុំថា បើបុគ្គលគេដឹងបាន ។បេ។ ដ្បិតពាក្យរបស់អ្នកនេះ ជាពាក្យខុស ដូច្នេះ និគ្គហៈរបស់អ្នកនេះខុស ។ បទថា **តេន ហិ យេ កតេ និគ្គហោ** សេចក្តីថា និគ្គហៈនេះ ខុសដោយហេតុណា ដោយហេតុនោះ និគ្គហៈណា ដែលអ្នកធ្វើហើយ និគ្គហៈនោះ ជាការធ្វើមិនត្រឹមត្រូវ ។ បដិកម្មណាដែលខ្ញុំធ្វើហើយ បដិកម្មនោះ ខ្ញុំធ្វើត្រឹមត្រូវហើយ ។ ការញ៉ាំងកថាមគ្គឲ្យសម្រេចនេះ ដែលខ្ញុំធ្វើហើយ ដោយអំណាចនៃបដិកម្មចតុក្កៈជាដើម ជាវត្ថុដែលខ្ញុំធ្វើបានល្អហើយ ។ គប្បីជ្រាបថា ឈ្មោះថា អនុលោមបច្ចនិកបញ្ចកៈនេះ ដែលលោកចង្អុលបង្ហាញហើយ ដោយអំណាចអនុលោមបញ្ចកៈ មានបទថា

**ឧបលព្ភតិ** *ជាដើម ដោយអំណាចនៃបដិកម្ម និគ្គហៈ ឧបនយនៈ និងនិគ្គម-នចតុក្កៈទាំងឡាយ មានពាក្យថា* **ន្នុបលព្ភតិ** *ជាដើម ដោយប្រការដូច្នេះ ។ តទៅជានិគ្គហទី ២ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ កាលសកវាទីជាអ្នកផ្តើមមុន ទើបបរវាទីឈ្នះ ដោយវាទៈដែលជាលេស ត្រឹមតែជាពាក្យទូទៅ ។ល។*

## អដ្ឋកថានិគ្គមនចតុក្កៈ ចប់
## និគ្គហៈទី ១ ចប់

# អភិធម្មបិដក

## បច្ចនីកបញ្ហា:

[ ៦ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អ្នកមិនត្រូវពោលយ៉ាងនេះទេ ។ អ្នកចូរដឹង នូវកំហុសចុះ ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និង

អត្ថដ៏ឧត្តមដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ។

**បច្ចនីកបញ្ចកៈ ចប់**

# អដ្ឋកថា

## បច្ចនីកានុលោម

[ ៦ ] ឥឡូវនេះ កាលបរវាទីជាអ្នកផ្តើមមុន ទើបសកវាទីឈ្នះដោយធម៌ តាមសេចក្តីពិតដោយប្រការណា ដើម្បីសម្តែងនូវការកើតឡើងនៃវាទៈ ដោយប្រការនោះ ទើបលោកផ្តើមបច្ចនីកានុលោមបញ្ចកៈ ដោយពាក្យថា **បុគ្គលោ នុបលព្ភតិ** បុគ្គលគេមិនដឹងបានជាដើម ។ ក្នុងបច្ចនីកៈនោះ ពាក្យសួរជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល សំដៅយកសច្ចិកដ្ឋបរមដ្ឋៈ មានរូបជាដើមជាពាក្យរបស់សកវាទី ។ ពាក្យសួរបន្តទៀតថា **យោ សច្ចិកដ្ឋោ** សំដៅយកសម្មតិសច្ចៈសុទ្ធ ឬសម្មតិសច្ចៈដែលលាយដោយបរមត្ថ ជាពាក្យរបស់បរវាទី ។ ពាក្យបដិសេធថា **ន ហេវំ** ព្រោះសច្ចិកដ្ឋបរមត្ថនោះ ដែលបុគ្គលណាមួយមិនគប្បីពោលថា **នុបលព្ភតិ** ដោយអំណាចនៃសម្មតិសច្ចៈ ឬព្រោះការសាកសួរ ដែលលាយឡំហើយដោយសច្ចៈទាំង ២ ជាពាក្យរបស់សកវាទី ។ បទថា **អាជានាហិ និគ្គហំ** ជាដើម ដោយត្រឹមតែជាពាក្យទូទៅ ដើម្បីឲ្យដឹងថា បរវាទីបដិសេធនូវពាក្យដែលសកវាទីទទួលហើយ ជាពាក្យរបស់បរវាទី ។ គប្បីជ្រាបថា បទថា **បុគ្គលោ នុបលព្ភតិ** នេះ ជានិគ្គហៈទី ២ អាស្រ័យវាទៈទី ២ ដោយប្រការដូច្នេះ ។ បរវាទីលើកនិគ្គហៈឡើងហើយ ដោយលេសនោះ ដូចពណ៌នាមកដូច្នេះ ៕៚

**អដ្ឋកថាបច្ចនីកានុលោម ចប់**

# អភិធម្មបិដក

## បដិកម្មចតុក្កៈ

[ ៧ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹង

បាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ។

**បដិកម្មចតុក្កៈ ចប់**

[ ៨ ] ប្រសិនបើ អ្នកសម្គាល់ថា អ្នកគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះហេតុនោះ កាលអ្នកប្តេជ្ញាយ៉ាងនេះ ដោយពាក្យប្តេជ្ញានេះ ក្នុងចំណែកនៃពាក្យថា គេមិនដឹងនោះ ត្រូវយើងសង្កត់សង្កិនយ៉ាងនេះឯង កាលបើយើងសង្កត់សង្កិនអ្នក អ្នក ឈ្មោះថា យើងសង្កត់សង្កិនត្រឹមត្រូវហើយ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម

ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះពាក្យរបស់អ្នកនេះ ជាពាក្យខុស ។

## និគ្គហចតុក្កៈ ចប់

[ ៩ ] បើវាទៈរបស់អ្នកនុ៎ះ យើងសង្កត់សង្កិនបានដោយលំបាក អ្នកចូរឃើញ ក្នុងពាក្យសង្កត់សង្កិន របស់យើងនោះ យ៉ាងនេះចុះថា អ្នកគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ តែយើងកាលប្តេជ្ញាយ៉ាងនេះ ដោយពាក្យប្តេជ្ញានេះ ក្នុងពាក្យថា អើ ក្នុងអនុលោមបញ្ចកៈនោះ អ្នកមិនត្រូវសង្កត់សង្កិនយ៉ាងនេះទេ កាលបើអ្នកសង្កត់សង្កិនយើង យើង ឈ្មោះថា អ្នកសង្កត់សង្កិនមិនត្រឹមត្រូវឡើយ ប្រសិនបើបុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោល

ថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះពាក្យរបស់អ្នកនេះ ជាពាក្យខុស ។

## ឧបនយនចតុក្កៈ ចប់

[ ១០ ] ខ្ញុំមិនត្រូវសង្កត់សង្កិនយ៉ាងនេះទេ ព្រោះហេតុនោះ អ្នកសង្កត់សង្កិនខ្ញុំថា ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដោយហេតុណា ម្នាលអ្នកដ៏ចម្រើន ហេតុនោះ អ្នកគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មាន

អត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បី ពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គល នោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថ ដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោល តែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នក មិនគប្បីពោលថា បុគ្គលណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះពាក្យ របស់អ្នកនេះ ជាពាក្យខុស ព្រោះហេតុនោះ សេចក្តីសន្និដ្ឋានណា ដែល អ្នកធ្វើហើយ សេចក្តីសន្និដ្ឋាននោះ គឺអ្នកធ្វើមិនត្រឹមត្រូវទេ អំពើផ្ទុយ ខ្ញុំធ្វើល្អហើយ ការញ៉ាំងរបៀបពាក្យឲ្យសម្រេច ខ្ញុំបានធ្វើល្អហើយ ។

**និគ្គមចតុក្កៈ ចប់**

**និគ្គហៈទី ២ ចប់**

# អដ្ឋកថា

## បដិកម្មចតុក្កៈជាដើម

[ ៧-១០ ] ឥឡូវនេះ ពាក្យសួរក្នុងន័យរបស់អនុលោម ជាពាក្យរបស់សកវាទី ដើម្បីសម្តែងដល់ការឈ្នះ ក្នុងវាទៈរបស់ខ្លួនដោយធម៌ស្មើ តាមពាក្យឆ្លើយទទួលរបស់បរវាទីនោះ ។ ពាក្យឆ្លើយទទួល អាស្រ័យលទ្ធិរបស់ខ្លួន ជាពាក្យរបស់បរវាទី ។ ការសោកសួរបន្ត ដោយមិនឲ្យឱកាសដល់លទ្ធិរបស់បរវាទី ដោយអំណាចនៃបរមត្ថ ជាពាក្យរបស់សកវាទី ។ ការបដិសេធ ព្រោះភាពដែលបុគ្គលជាសភាវៈ មិនមានដោយអំណាចនៃបរមត្ថ ជាពាក្យរបស់បរវាទី ។ ខាងមុខអំពីនេះ ពាក្យទាំងពួង មានបទថា **អាជានាហិ បដិកម្មំ** ជាដើម ជាពាក្យរបស់សកវាទីនោះឯង ដើម្បីសម្តែងការឈ្នះរបស់ខ្លួន ដោយធម៌ស្មើ ។ ក្នុងទីនេះ គប្បីជ្រាបអត្ថរបស់បដិកម្ម និគ្គហៈ ឧបនយនៈ និងនិគ្គមនចតុក្កៈទាំងពួង ដោយន័យដែលពោលហើយខាងដើមនោះឯង ។ ឈ្មោះថា **បច្ចនីកានុលោមបញ្ចកៈ** នេះ ឈ្មោះថា លោកចង្អុលបង្ហាញហើយ ដោយអំណាចនៃបដិកម្ម និគ្គហៈ ឧបនយនៈ និងនិគ្គមនចតុក្កៈ ដែលមានបទថា **ឧបលព្ភតិ** ជាដើម ដល់បច្ចនីកបញ្ចកៈដែលមានបទថា **នុបលព្ភតិ** ជាដើម ដោយប្រការដូច្នេះ ។ បញ្ចកៈ គឺពួក ៥ ទាំង ២ ក្នុងបឋមសច្ចិកដ្ឋៈទាំងនេះ ឈ្មោះថា លោកចង្អុលបង្ហាញហើយ ដោយប្រការដូច្នេះ ។ ក្នុងបញ្ចកៈទាំង ២ នោះ បញ្ចកៈដំបូង និគ្គហៈដែលសកវាទីធ្វើដល់បរវាទី ឈ្មោះថា ជានិគ្គហៈត្រឹមត្រូវហើយ តែការឈ្នះដែល

បរវាទីអាស្រ័យវាទៈដែលជាលេស ធ្វើតបដល់សកវាទីដែលខ្ជួនឲ្យសម្រេច ហើយ ជាការឈ្នះដែលមិនត្រឹមត្រូវ ។ ក្នុងបញ្ចកៈទី ២ និគ្គហៈដែលបរវាទីធ្វើដល់សកវាទី ជានិគ្គហៈមិនត្រឹមត្រូវ ។ តែការឈ្នះដែលសកវាទីអាស្រ័យវាទៈដែលជាធម៌ ធ្វើតបដល់បរវាទីដែលខ្ជួនឲ្យសម្រេចហើយ ជាការឈ្នះដែលត្រឹមត្រូវ ។ នេះជាបឋមសច្ចិកដ្ឋៈ ។

ក្នុងបឋមសច្ចិកដ្ឋៈនោះ លោកពោលថា

ក្នុងបឋមបញ្ចកៈ សកវាទីធ្វើនិគ្គហៈដែលបរិសុទ្ធដល់បរវាទី តែការឈ្នះក្នុងការធ្វើតបរបស់បរវាទីនោះឯង ក្នុងបញ្ហានោះ មិនបរិសុទ្ធ ។ ក្នុងទុតិយបញ្ចកៈ បរវាទីធ្វើនិគ្គហៈ ដែលមិនបរិសុទ្ធដល់សកវាទី តែការឈ្នះក្នុងការធ្វើតបរបស់សកវាទីនោះឯង ក្នុងបញ្ហានោះ បរិ-សុទ្ធវិសេសហើយ ព្រោះហេតុនោះ ក្នុងឋានៈទាំង ២ ការឈ្នះរបស់សកវាទី ឈ្មោះថា ឈ្នះដោយធម៌ ការឈ្នះដោយអធម៌នឹងមានមកអំពីទីណា ។ ការឈ្នះ និងការចាញ់ ក្នុងសច្ចិកដ្ឋៈដែលប្រដាប់ដោយពួក ២ នៃបញ្ចកៈនេះ លោកពោលហើយ ដោយអំណាចនៃធម៌ និងអធម៌ យ៉ាងណា ក្នុងសច្ចិកដ្ឋៈទាំងពួង ក្រៅអំពីនេះ បណ្ឌិតគប្បីញុំាងនូវការឈ្នះ និងការចាញ់ទាំង ២ ឲ្យជាក់ច្បាស់ដូច្នោះឯង ។៚

**អដ្ឋកថាបដិកម្មចតុក្កៈជាដើម ចប់**

**និគ្គហៈទី ២ ចប់**

# អភិធម្មបិដក

# ឱកាសសច្ចិកដ្ឋ:

## អនុលោមបច្ចនីកៈ

[ ១១ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះ

ដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះ ថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដម តែអ្នកមិនគប្បីពោល ថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្ដម ក្នុងទីទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

## និគ្គហៈទី ៣ ចប់

# អដ្ឋកថា

## ឱកាសសច្ចិកដ្ឋៈ

## អនុលោមបច្ចនីកៈ

[ ១១ ] កាលញ៉ាំងសច្ចិកដ្ឋៈសុទ្ធៗ ឲ្យពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីញ៉ាំងសច្ចិកដ្ឋៈនោះឯងឲ្យពិស្តារ ដោយន័យដទៃ មានឱកាសជាដើម ទើបលោកផ្តើមបទថា **បុគ្គលោ ឧបលព្ភតិ** ទៀតជាដើម ។ ក្នុងនិគ្គហៈទី ៣ នេះ ពាក្យសួរជាពាក្យរបស់សកវាទី ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ ពាក្យសួរតទៅ សំដៅយកសរីរៈក្នុងបទថា **សព្វត្ថ** ជាពាក្យរបស់សកវាទី ។ ពាក្យបដិសេធ ព្រោះឃើញកំហុស ក្នុងការពិចារណាឃើញខ្ទួនក្នុងរូប និងព្រោះឃើញកំហុស ដែលនឹងកាន់យកថា ជីវៈម្យ៉ាងសរីរៈម្យ៉ាង ដូច្នេះ ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ក្នុងអនុលោមបច្ចនីកបញ្ចកៈ ។ ក្នុងទីនេះ លោកសង្ខេបនូវព្រះបាលី ។

កាលលោកពោលសំដៅយកសរីរៈ ក្នុងនិគ្គហៈទី ៦ ថា **សព្វត្ថ ឧបលព្ភតិ** ដូច្នេះ រមែងកាន់យកបានថា រមែងស្គាល់ដឹងបុគ្គលបានខាងក្រៅ អំពីសរីរៈ ព្រោះហេតុណា ព្រោះហេតុនោះ ទើបពាក្យបដិសេធក្នុងបច្ចនីកៈ ជាពាក្យរបស់សកវាទី ។ បដិកម្ម គឺការឆ្លើយតបដោយអំណាចវាទៈ ដែលជាលេសថា អ្នកទទួលពាក្យដំបូងហើយ ខាងក្រោយ រមែងបដិសេធ ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ជាក់ច្បាស់ហើយនោះឯង ។ល។

# អភិធម្មបិដក

## កាលសច្ចិកដ្ឋៈ

## អនុលោមបច្ចនីកៈ

[ ១២ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏

ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

# អដ្ឋកថា
## កាលសច្ចិកដ្ឋៈ

### អនុលោមបច្ចនីកៈ

[ ១២ ] ក្នុងន័យទី ២ ពាក្យសួរថា **សព្វទា** សំដៅដល់កាល គឺជាតិដែលមានមកអំពីមុន និងមានក្នុងកាលជាខាងក្រោយ និងកាលដែលព្រះសម្ពុទ្ធគង់ព្រះជន្មនៅ និងបរិនិព្វានហើយ ជាពាក្យរបស់សកវាទី ។ ពាក្យបដិសេធ ព្រោះឃើញការខុស ដែលមានពាក្យថា ជាក្សត្រ ក៏ជាមនុស្សនោះឯង ជាព្រាហ្មណ៍ ក៏ជាមនុស្សនោះឯងជាដើម និងព្រោះឃើញការខុស ព្រោះមិនមានអ្វីប្លែកគ្នានៃកាល ដែលព្រះសម្ពុទ្ធនៅគង់ព្រះជន្មនៅឡើយ ឬបរិនិព្វានហើយ ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលពោលហើយ ក្នុងន័យដំបូងនោះឯង ៕

# អភិធម្មបិដក

## អាវយវសច្ចិកដ្ឋៈ

### អនុលោមបច្ចនីកៈ

[ ១៣ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួង ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងទេ ព្រោះជាពាក្យខុស ។បេ។

# អដ្ឋកថា

## អាយវសច្ចិកដ្ឋៈ

## អនុលោមបច្ចនីកៈ

[ ១៣ ] ក្នុងន័យទី ៣ ពាក្យសាកសួរថា **សព្វេសុ** សំដៅដល់ខន្ធ និងអាយតនៈទាំងឡាយជាដើម ជាពាក្យរបស់សកវាទី ។ ពាក្យបដិសេធ ព្រោះខ្លាចខុសក្នុងពាក្យថា អត្តាក្នុងរូប អត្តាក្នុងចក្ខុជាដើម ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានោះឯង ដោយប្រការដូច្នេះ ៕

# អភិធម្មបិដក

## ឱកាសនិសប្តិកដ្ឋានិ

### បច្ចនីកានុលោម

[ ១៤ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងទីទាំងពួងដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ១៥ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងកាលទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ១៦ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុ

នោះ អ្នកគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ក្នុងធម៌ទាំងពួងដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

**អដ្ឋកនិគ្គហៈ ចប់**

# អដ្ឋកថា
## ឱកាសនិសប្តិកដ្ឋានិ

## បច្ចនីកានុលោម

[ ១៤-១៦ ] កាលលោកចែកមាតិកាទាំង ៣ ពួកនេះ ក្នុងអនុលោមបច្ចនីកបញ្ចកៈ តាមលំដាប់មុន ដោយអំណាចចំពោះអនុលោមប៉ុណ្ណោះ ឥឡូវនេះ ដើម្បីចែកក្នុងបច្ចនីកានុលោមបញ្ចកៈទៀត ដោយអំណាចចំពោះបច្ចនីកៈប៉ុណ្ណោះ ទើបផ្តើមពាក្យថា **បុគ្គលោ នូបលព្ភតិ** ជាដើម ។ ក្នុងពាក្យទាំងនោះ បណ្ឌិតគប្បីជ្រាបអត្ថ ដោយន័យដែលបានពោលហើយក្នុងបច្ចនីកៈ តាមដែលសង្ខេបហើយ ក្នុងព្រះបាលីនៃអនុលោមបញ្ចកៈនោះឯង និងដោយន័យដែលពោលហើយក្នុងអនុលោម តាមដែលសង្ខេបហើយ ក្នុងព្រះបាលីនៃបច្ចនីកៈនោះឯង ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ការប្រកបវាទៈ ឈ្មោះថា **អដ្ឋមុខ** ( មាតិកា ៨ ) នេះ ឈ្មោះថា បានបង្អួលបង្ហាញហើយ ដោយអំណាចនៃបច្ចនីកៈនីមួយៗ ២ គឺ អនុលោមបច្ចនីកៈ និងបច្ចនីកានុលោម ក្នុងសច្ចិកដ្ឋៈនីមួយៗ នៃសច្ចិកដ្ឋៈទាំង ៤ គឺសុទ្ធិកសច្ចិកដ្ឋៈ ១ និងសច្ចិកដ្ឋៈទាំង ៣ នេះ ។ ការប្រកបវាទៈ ឈ្មោះថា **អដ្ឋមុខ** ឯណា ដែលលោកបានចារឹកក្នុងព្រះបាលីថា និគ្គហៈ ៨ ដោយអំណាចនិគ្គហៈនីមួយៗ ក្នុងមាតិកានីមួយៗ លោកពោលការប្រកប

វាទៈនោះ ក្នុងទីនេះថា

ការប្រកបវាទៈ ឈ្មោះថា អដ្ឋមុខៈនេះ ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ដោយប្រភេទនៃបញ្ចកៈទាំង ២ ក្នុងបញ្ហា ៤ យ៉ាង ដោយប្រការដូច្នេះ ។ ក្នុងការប្រកបវាទៈនោះ និគ្គហៈ ៨ នោះឯង បណ្ដានិគ្គហៈទាំងនោះ និគ្គហៈដែលប្រកបដោយធម៌ ៤ ដែលមិនប្រកបដោយធម៌ ៤ ការមានជ័យជម្នះផង ការចាញ់ផង នៃសកវាទី និង បរវាទី មាននៅក្នុងទីទាំងពួង ដូច្នេះ ។ល។

**អដ្ឋកថាសច្ចិកដ្ឋៈ ចប់**

# អភិធម្មបិដក

## សុទ្ធិកសំសន្ទន:

[ ១៧ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ រូបដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ១៨ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសញ្ញាគេដឹងបាន ។បេ។

ទាំងសង្ខារគេដឹងបាន ។បេ។ ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ វិញ្ញាណដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ម្នាលអ្នកដ៏ចម្រើន អ្នកគប្បីពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ១៩ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខាយតនៈគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសោតាយតនៈគេដឹងបាន ។បេ។ ទាំងឃានាយតនៈគេដឹងបាន ។បេ។ ទាំងជិវ្ហាយតនៈគេដឹងបាន ។បេ។ ទាំងកាយាយតនៈ គេដឹងបាន ។បេ។ ទាំងរូបាយតនៈ គេ

ដឹងបាន ។បេ។ ទាំងសទ្ទាយតនៈគេដឹងបាន ។បេ។ ទាំងគន្ធាយតនៈគេដឹងបាន ។បេ។ ទាំងរសាយតនៈគេដឹងបាន ។បេ។ ទាំងផោដ្ឋព្វាយតនៈគេដឹងបាន ។បេ។ ទាំងមនាយតនៈគេដឹងបាន ។បេ។ ទាំងធម្មាយតនៈគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ២០ ] ចក្ខុធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសោតធាតុគេដឹងបាន ។បេ។ ទាំងឃានធាតុគេដឹងបាន ។បេ។ ទាំងជិវ្ហាធាតុគេដឹងបាន ។បេ។ ទាំងកាយធាតុ គេដឹងបាន ។បេ។ ទាំងរូបធាតុ គេដឹងបាន ។បេ។ ទាំងសទ្ទធាតុ គេដឹងបាន ។បេ។ ទាំងគន្ធធាតុ គេដឹងបាន ។បេ។ ទាំងរសធាតុ គេដឹងបាន ។បេ។ ទាំងផោដ្ឋព្វធាតុ គេដឹងបាន ។បេ។ ទាំងចក្ខុ-វិញ្ញាណធាតុគេដឹងបាន ។បេ។ ទាំងសោតវិញ្ញាណធាតុគេដឹងបាន ។បេ។ ទាំងឃានវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងជិវ្ហាវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងកាយវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងមនោធាតុ គេដឹងបាន ។បេ។ ទាំងមនោវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ២១ ] ចក្ខុន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសោតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងឃានិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងជិវ្ហិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងកាយិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងមនិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងជីវិតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងឥត្ថិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងបុរិសិន្ទ្រិយគេដឹងបាន ។បេ។ ទាំងសុខិន្ទ្រិយគេដឹងបាន ។បេ។ ទាំង

ទុក្ខិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងសោមនស្សិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងទោមនស្សិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងឧបេក្ខិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងសទ្ធិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងវិរិយិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងសតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងសមាធិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងបញ្ញិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា អញ្ញា-តាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និង

អត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ២២ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ រូបដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូបគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏

ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងវេទនាគេដឹងបាន ។បេ។ ទាំងសញ្ញាគេដឹងបាន ។បេ។ ទាំងសង្ខារទាំងឡាយគេដឹងបាន ។បេ។ ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ វិញ្ញាណដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងវិញ្ញាណគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែ

អ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ២៣ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងចក្ខាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសោតាយតនៈ គេដឹងបាន ។បេ។ ទាំងធម្មាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ២៤ ] ចក្ខុធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងកាយធាតុ គេដឹងបាន ។បេ។ ទាំងរូបធាតុ គេដឹងបាន ។បេ។ ទាំងផោដ្ឋព្វធាតុ គេដឹងបាន ។បេ។ ទាំងចក្ខុវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងមនោវិញ្ញាណធាតុ គេដឹងបាន ។បេ។ ទាំងធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ២៥ ] ចក្ខុន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងសោតិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ចុយចុះ ប្រសិន

បើព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា អញ្ញាតាវិន្ទ្រិយជាទេ បុគ្គលជាទេ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយជាទេ បុគ្គលជាទេ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយជាទេ បុគ្គលជាទេទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយជាទេ បុគ្គលជាទេ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

**សុទ្ធិកសំសន្ទនា ចប់**

# អដ្ឋកថា

## សុទ្ធិកសំសន្ទនៈ

[ ១៧-២៥ ] ឥឡូវនេះ ជាការប្រៀបធៀបសច្ចិកដ្ឋៈ និងរូបជាដើម ។ ក្នុងបទទាំងនោះ បទថា **រូបញ្ច** ជាពាក្យសួររបស់សកវាទី ដោយសំដៅយកថា អ្នកស្គាល់ដឹងរូបបានដោយបរមត្ថយ៉ាងណា អ្នកស្គាល់ដឹងបុគ្គលយ៉ាងនោះឬ ។ ពាក្យឆ្លើយទទួល ដែលកាន់យកត្រឹមតែពាក្យថា **អត្ថិ បុគ្គលោ** ជាពាក្យរបស់បរវាទី ។ ការសួរថា បើបុគ្គលមានដោយបរមត្ថដល់អ្នក ដូចរូប មានដោយបរមត្ថសោត ភាពដែលបុគ្គលជាយ៉ាងដទៃអំពីរូប ដូចដែលវេទនាជាដើម ជាយ៉ាងដទៃអំពីរូប រមែងត្រឹមត្រូវ ជាពាក្យរបស់សកវាទី ។ ការបដិសេធ ព្រោះឃើញថា ខុសចាកលទ្ធិ និងព្រះសូត្រ ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយដោយអត្ថនោះឯង ក្នុងទីនេះ កាលពោលដោយធម៌ លោកសម្តែងអនុលោមបញ្ចកៈ ៥៧ ប្រភេទ ក្នុងអនុលោមបញ្ចកៈដែលជាមូលក្នុងចំណែកសកវាទី ដោយអំណាចនៃសច្ចិ-កដ្ឋបរមដ្ឋៈ ៥៧ ប្រភេទ ។ លោកសង្ខេបពួក ៤ នៃបដិកម្មជាដើម ។ លោកសម្តែងបដិលោមបញ្ចកៈ ៥៧ ប្រភេទ ក្នុងបច្ចនីកានុលោម ដែលជាមូលខាងបរវាទីទៀត ។ លោកសង្ខេបពួក ៤ នៃបដិកម្មជាដើម ។ ពាក្យសួរ

ថា **វុត្តំ ភគវតា** ជាដើម ដើម្បីសម្ដែងដល់ភាពដែលបុគ្គលជារបស់មាន ដោយត្រឹមតែព្រះតម្រាស់ថា ព្រះមានព្រះភាគត្រាស់ថា ដូច្នេះផង ដល់នូវភាពដែលរូបជាសភាវៈ ដែលស្ទង់ដឹងបាន ដោយអំណាចនៃសច្ចិកដ្ឋបរមដ្ឋៈផង ហើយទើបឲ្យសកវាទីទទួលនូវភាពដែលធម៌ទាំង ២ ជាយ៉ាងដទៃ ជាពាក្យរបស់បរវាទី ។ ពាក្យបដិសេធព្រោះបញ្ហាថា សម្មុតិសច្ច និងបរមត្ថ-សច្ចទាំងឡាយ មានអត្ថដូចគ្នា ឬមានអត្ថផ្សេងគ្នា គួរវៀរតប ជាពាក្យរបស់សកវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ ប្រាកដជាក់ច្បាស់ហើយ ដោយអត្ថទាំងអស់នោះឯង ដូច្នេះ ។៙

**អដ្ឋកថាសុទ្ធិកសំសន្ទនា ចប់**

# អភិធម្មបិដក

## ឱបម្មសំសន្ទនៈ

[ ២៦ ] រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃឬ ។ អើ ។ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ រូបដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត

និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ២៧ ] រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វិញ្ញាណដទៃឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម និងអត្ថដ៏ឧត្តមឬ ។ អើ ។ រូបដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ រូប គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វិញ្ញាណដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វិញ្ញាណដទៃ បុគ្គល

គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វិញ្ញាណដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វិញ្ញាណដទៃ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ២៨ ] វេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ២៩ ] សញ្ញា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹងបាន ។បេ។ ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣០ ] សង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹងបាន ។បេ។ ទាំងវេទនា គេដឹងបាន ។បេ។ ទាំងសញ្ញា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣១ ] វិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ។បេ។ ទាំងវេទនា គេដឹងបាន ។បេ។ ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែវិញ្ញាណដទៃ សង្ខារដទៃឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ វិញ្ញាណដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែវិញ្ញាណដទៃ សង្ខារដទៃ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា វិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែវិញ្ញាណដទៃ សង្ខារដទៃ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយ

ទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា វិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែវិញ្ញាណដទៃ សង្ខារដទៃ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា វិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែវិញ្ញាណដទៃ សង្ខារដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៣២ ] ចក្ខាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតាយតនៈ គេដឹងបាន ។បេ។ ទាំងធម្មាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣៣ ] សោតាយតនៈ គេដឹងបាន ។បេ។ ធម្មាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខាយតនៈ គេដឹងបាន ។បេ។ ទាំងមនាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣៤ ] ចក្ខុធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតធាតុ គេដឹងបាន ។បេ។ ទាំងធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និង

អត្ថដ៏ឧត្តមឬ ។បេ។

[ ៣៥ ] សោតធាតុ គេដឹងបាន ។បេ។ ធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខុធាតុ គេដឹងបាន ។បេ។ ទាំងមនោវិញ្ញាណធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣៦ ] ចក្ខុន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៣៧ ] សោតិន្ទ្រិយ គេដឹងបាន ។បេ។ អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខុន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃឬ ។ អើ ។ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញា-តាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ អញ្ញាតា-វិន្ទ្រិយដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញា-តាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែ

ពាក្យនោះថា អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំង អញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម អញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញា-តាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោល ថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយ អត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថ ដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោល តែពាក្យនោះថា អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយ ដទៃ អញ្ញិន្ទ្រិយដទៃ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំង អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បី ពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៣៨ ] រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេ ដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប

គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ រូបដទៃ បុគ្គលដទៃ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និង

អត្ថដ៏ឧត្តម តែរូបដទៃ វេទនាដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គល ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថ ដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជា ពាក្យខុស ។បេ។

[ ៣៩ ] រូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤០ ] វេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤១ ] សញ្ញា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំង សង្ខារ គេដឹងបាន ។បេ។ ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹង បាន ។បេ។ ទាំងវេទនា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤២ ] សង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងវិញ្ញាណ គេដឹងបាន ។បេ។ ទាំងរូប គេដឹងបាន ។បេ។ ទាំងវេទនា គេដឹងបាន ។បេ។ ទាំងសញ្ញា គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៣ ] វិញ្ញាណ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងរូប គេដឹងបាន ។បេ។ ទាំងវេទនា គេដឹងបាន ។បេ។ ទាំងសញ្ញា គេដឹងបាន ។បេ។ ទាំងសង្ខារ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៤ ] ចក្ខាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតាយតនៈ គេដឹងបាន ។បេ។ ទាំងធម្មាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៥ ] សោតាយតនៈ គេដឹងបាន ។បេ។ ធម្មាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខាយតនៈ គេដឹងបាន ។បេ។ ទាំងមនាយតនៈ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៦ ] ចក្ខុធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតធាតុ គេដឹងបាន ។បេ។ ទាំងធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៧ ] សោតធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។ ធម្មធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខុធាតុ គេដឹងបាន ។បេ។ ទាំងមនោវិញ្ញាណធាតុ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៨ ] ចក្ខុន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងសោតិន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។បេ។

[ ៤៩ ] សោតិន្ទ្រិយ គេដឹងបាន ។បេ។ អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងចក្ខុន្ទ្រិយ គេដឹងបាន ។បេ។ ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម អញ្ញាតាវិន្ទ្រិយដទៃ

អញ្ញិន្ទ្រិយដទៃឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើ អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា អញ្ញា-តាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុសមួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ទាំងអញ្ញិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ ព្រះមានព្រះភាគ

ត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា អញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអញ្ញាតាវិន្ទ្រិយដទៃ អញ្ញិន្ទ្រិយដទៃ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ទាំងអញ្ញាតាវិន្ទ្រិយ គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយដទៃ បុគ្គលដទៃដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

## ឱបម្មសំសន្ទនា ចប់

# អដ្ឋកថា

## ឱបម្មសំសន្ទនា

[ ២៦-៤៩ ] ឥឡូវនេះ ជាការប្រៀបធៀបនូវសច្ចិកដ្ឋៈ ជាមួយធម៌ទាំងឡាយ មានរូបជាដើមនោះឯង ដោយអំណាចនៃឧបមា ។ បណ្ដាបទទាំងនោះ ទាំង ២ បទ ពាក្យសួរ គឺពាក្យសួរដល់ភាពដែលរូប និងវេទនាមួយបែបម្យ៉ាង ដោយស្ទង់ដឹងបានទូទៅម្យ៉ាង ពាក្យសួរ ដោយការស្ទង់ដឹងបានទូទៅនៃបុគ្គល និងរូបម្យ៉ាង ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួលទាំង ២ បញ្ហា ជាពាក្យរបស់បរវាទី ។ ពាក្យសួរដល់ភាពដែលរូប និងបុគ្គលមួយបែបម្យ៉ាង ដូចរូប និងវេទនាមួយបែបម្យ៉ាង ដោយការដឹងទូទៅដែលបរវាទីរមែងទទួលហើយ ជាពាក្យរបស់សកវាទី ។ ពាក្យបដិសេធជារបស់បរវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ ប្រាកដជាក់ច្បាស់ហើយ ដោយអត្ថនោះឯង ។ បើពោលដោយធម៌ហើយ ក្នុងសេចក្ដីនេះ ក្នុងចំណែកសកវាទី លោកសម្ដែងនិគ្គហបញ្ចកៈចំនួន ៩២០ ន័យ ដោយអំណាចរបស់ន័យដែលមានរូបជាមូលជាដើមនោះឯង នៃការវិលទៅ ។ សួរថា សម្ដែងដូចម្ដេច ឆ្លើយថា ក្នុងខន្ធទាំងឡាយ គឺន័យដែលមានរូបជាមូល វិលទៅបាន ៤ ន័យ ក្នុងន័យដែលមានវេទនាជាមូលជាដើមក៏ដូចគ្នា ទើបរួមជា ២០ ន័យ ។ ក្នុងអាយតនៈទាំងឡាយ ន័យដែលមានចក្ខាយតនៈជាមូល វិលទៅបាន ១១ ន័យ ក្នុងអាយតនៈដ៏សេសក៏យ៉ាងនោះ ទើបរួមជា ១៣២ ន័យ ។ ក្នុងធាតុទាំងឡាយ ន័យដែលមានចក្ខុធាតុជាមូល វិលទៅបាន ១៧

ន័យ ក្នុងធាតុដ៏សេសក៏យ៉ាងនោះ ទើបរួមជា ៣០៦ ន័យ ។ ក្នុងឥន្ទ្រិយទាំងឡាយ ន័យដែលមានចក្ខុន្ទ្រិយជាមូល រិលទៅបាន ២១ ន័យ ក្នុងឥន្ទ្រិយដ៏សេសក៏យ៉ាងនោះ ទើបរួមជា ៤៦២ ន័យ រួមទាំងអស់ ជានិគ្គហបញ្ចកៈ ៩២០ ន័យ ដោយប្រការដូច្នេះ ។ ក្នុងចំណែកបរវាទី លោកក៏ធ្វើឲ្យសកវាទីព្រមទទួល ដល់ភាពដែលធម៌ទាំងឡាយ មានរូប និងវេទនាជាដើមមួយបែបម្យ៉ាង ដោយអំណាចនៃអនុលោមថា **រូបំ ឧបលព្ភតិ** ជាដើម ហើយទើបលើកយកការដឹងនូវទៅឡើង ធ្វើការសាកសួរទៀត ដល់ភាពដែលបុគ្គលមួយបែបម្យ៉ាង ជាមួយរូបជាដើម ដោយអំណាចនៃពាក្យដែលមានលេស ដោយអាស្រ័យព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ថា មានបុគ្គល ... ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ដោយអត្ថជារបស់ងាយយល់ហើយ ។ កាលពោលដោយធម៌ លោកសម្ដែងបដិកម្មបញ្ចកៈ ៩២០ ន័យ ដោយន័យដែលបានពោលហើយក្នុងចំណែកសកវាទី ការប្រៀបធៀបសច្ចិកដ្ឋៈ និងរូបជាដើម ដោយអំណាចនៃការឧបមា មានប្រមាណប៉ុណ្ណោះ ។ល។

## អដ្ឋកថាឱបម្មសំសន្ទនា ចប់

# អភិធម្មបិដក

## ចតុក្កនយសំសន្ទនា

[ ៥០ ] បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គល គឺរូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គល គឺរូប ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥១ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលមានក្នុងរូប ។បេ។ បុគ្គលវៀរចាករូប ។បេ។ រូបមានក្នុងបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា រូបមានក្នុងបុគ្គល ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នក

ពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា រូបមានក្នុងបុគ្គល ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា រូបមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥២ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គល គឺវេទនា ។បេ។ បុគ្គលមានក្នុងវេទនា ។បេ។ បុគ្គលវៀរចាកវេទនា ។បេ។ វេទនាមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺសញ្ញា ។បេ។ បុគ្គលមានក្នុងសញ្ញា ។បេ។ បុគ្គលវៀរចាកសញ្ញា ។បេ។ សញ្ញាមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺសង្ខារទាំងឡាយ ។បេ។ បុគ្គលមានក្នុងសង្ខារទាំងឡាយ ។បេ។ បុគ្គលវៀរចាកសង្ខារទាំងឡាយ ។បេ។ សង្ខារទាំងឡាយ មានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺវិញ្ញាណ ។បេ។ បុគ្គលមានក្នុងវិញ្ញាណ ។បេ។ បុគ្គលវៀរចាកវិញ្ញាណ ។បេ។ វិញ្ញាណមានក្នុងបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា

គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥៣ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គល គឺចក្ខាយតនៈ ។បេ។ បុគ្គលមានក្នុងចក្ខាយតនៈ ។បេ។ បុគ្គលវៀរចាកចក្ខាយតនៈ ។បេ។ ចក្ខាយតនៈមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺធម្មាយតនៈ ។បេ។ បុគ្គលមានក្នុងធម្មាយតនៈ ។បេ។ បុគ្គលវៀរចាកធម្មាយតនៈ ។បេ។ ធម្មាយតនៈមានក្នុងបុគ្គលឬ ។បេ។

[ ៥៤ ] បុគ្គល គឺចក្ខុធាតុ ។បេ។ បុគ្គលមានក្នុងចក្ខុធាតុ ។បេ។ បុគ្គលវៀរចាកចក្ខុធាតុ ។បេ។ ចក្ខុធាតុមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺធម្មធាតុ ។បេ។ បុគ្គលមានក្នុងធម្មធាតុ ។បេ។ បុគ្គលវៀរចាកធម្មធាតុ ។បេ។ ធម្មធាតុមានក្នុងបុគ្គលឬ ។បេ។

[ ៥៥ ] បុគ្គល គឺចក្ខុន្ទ្រិយ ។បេ។ បុគ្គលមានក្នុងចក្ខុន្ទ្រិយ ។បេ។ បុគ្គលវៀរចាកចក្ខុន្ទ្រិយ ។បេ។ ចក្ខុន្ទ្រិយមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺ

អញ្ញាតាវិន្ទ្រិយ ។បេ។ បុគ្គលមានក្នុងអញ្ញាតាវិន្ទ្រិយ ។បេ។ បុគ្គលវៀរចាក អញ្ញាតាវិន្ទ្រិយ ។បេ។ អញ្ញាតាវិន្ទ្រិយមានក្នុងបុគ្គលឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើ បុគ្គលគេដឹងបាន ដោយ អត្ថដ៏ពិត និងអត្ថដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោល ថា អញ្ញាតាវិន្ទ្រិយមានក្នុងបុគ្គល ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នក ពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គល គេដឹងបាន ដោយ អត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយ មានក្នុង បុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បី ពោលថា អញ្ញាតាវិន្ទ្រិយមានក្នុងបុគ្គល ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិន គប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះ ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម តែអ្នកមិនគប្បីពោល ថា អញ្ញាតាវិន្ទ្រិយមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥៦ ] បុគ្គលគេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឬ ។ អើ ។ បុគ្គល គឺរូបឬ ។ អ្នកមិនគប្បីពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្សយ ចុះ ប្រសិនបើ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បី ប្រយោជន៍ខ្លួន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គល គឺរូប ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បី

ពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា បុគ្គល គឺរូប ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥៧ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនឬ ។ អើ ។ បុគ្គលមានក្នុងរូប ។បេ។ បុគ្គលវៀរចាករូប ។បេ។ រូបមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺវេទនា ។បេ។ បុគ្គលមានក្នុងវេទនា ។បេ។ បុគ្គលវៀរចាកវេទនា ។បេ។ វេទនាមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺសញ្ញា ។បេ។ បុគ្គលមានក្នុងសញ្ញា ។បេ។ បុគ្គលវៀរចាកសញ្ញា ។បេ។ សញ្ញា មានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺសង្ខារទាំងឡាយ ។បេ។ បុគ្គល មានក្នុងសង្ខារទាំងឡាយ ។បេ។ បុគ្គលវៀរចាកសង្ខារទាំងឡាយ ។បេ។ សង្ខារទាំងឡាយ មានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺវិញ្ញាណ ។បេ។ បុគ្គលមានក្នុងវិញ្ញាណ ។បេ។ បុគ្គលវៀរចាកវិញ្ញាណ ។បេ។ វិញ្ញាណ មានក្នុងបុគ្គលឬ ។ អ្នកមិនគប្បីពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផុយចុះ ប្រសិនបើ ព្រះមាន

ព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា វិញ្ញាណមានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៥៨ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឬ ។ អើ ។ បុគ្គល គឺចក្ខាយតនៈ ។បេ។ បុគ្គលមានក្នុងចក្ខាយតនៈ ។បេ។ បុគ្គលវៀរចាកចក្ខាយតនៈ ។បេ។ ចក្ខាយតនៈមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺធម្មាយតនៈ ។បេ។ បុគ្គលមានក្នុងធម្មាយតនៈ ។បេ។ បុគ្គលវៀរចាកធម្មាយតនៈ ។បេ។ ធម្មាយតនៈមានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺចក្ខុធាតុ ។បេ។ បុគ្គលមានក្នុងចក្ខុធាតុ ។បេ។ បុគ្គលវៀរចាកចក្ខុធាតុ ។បេ។ ចក្ខុធាតុ មានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺធម្មធាតុ ។បេ។ បុគ្គល មានក្នុងធម្មធាតុ ។បេ។

បុគ្គលវៀរចាកធម្មធាតុ ។បេ។ ធម្មធាតុ មានក្នុងបុគ្គលឬ ។បេ។

[ ៥៩ ] បុគ្គល គឺចក្ខុន្ទ្រិយ ។បេ។ បុគ្គល មានក្នុងចក្ខុន្ទ្រិយ ។បេ។ បុគ្គលវៀរចាកចក្ខុន្ទ្រិយ ។បេ។ ចក្ខុន្ទ្រិយ មានក្នុងបុគ្គលឬ ។បេ។ បុគ្គល គឺអញ្ញាតាវិន្ទ្រិយ ។បេ។ បុគ្គលមានក្នុងអញ្ញាតាវិន្ទ្រិយ ។បេ។ បុគ្គលវៀរចាកអញ្ញាតាវិន្ទ្រិយ ។បេ។ អញ្ញាតាវិន្ទ្រិយ មានក្នុងបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផុយចុះ ប្រសិនបើ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា អញ្ញាតាវិន្ទ្រិយ មានក្នុងបុគ្គល ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយ មានក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុសមួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយ មានក្នុងបុគ្គល ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ដូច្នេះដែរ បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា អញ្ញាតាវិន្ទ្រិយមាន ក្នុងបុគ្គល ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

**ចតុក្កនយសំសន្ទនា ចប់**

# អដ្ឋកថា

## ចតុក្កនយសំសន្ទនា

[ ៥០-៥៩ ] ឥឡូវនេះ វត្ថុណាដែលបរវាទីសួនដីងដោយសច្ចិកដ្ឋ-បរមដ្ឋៈ ព្រោះហេតុដែលវត្ថុនោះ គប្បីជាវត្ថុណាមួយ ក្នុងសច្ចិកដ្ឋបរមដ្ឋៈ ៥៧ យ៉ាង មានរូបជាដើម ឬគប្បីមានដោយអាស្រ័យនូវរូបជាដើម ឬវៀរចាករូបជាដើម ឬជាទីអាស្រ័យនៃរូបជាដើម ហេតុនោះ ទើបលោកផ្ដើមការប្រៀបធៀបសច្ចិកដ្ឋៈ ដោយចតុក្កន័យនេះ ។

បណ្ដាបទទាំងនោះ បទថា **រូបំ បុគ្គលោ** ជាពាក្យសួររបស់សកវាទី ។ ពាក្យបដិសេធថា **ន ហេវំ** ព្រោះខ្លាចនឹងត្រូវពោលចោទថា ជាឧច្ឆេទទិដ្ឋិ ជាពាក្យរបស់បរវាទី ។ ការលើកនិគ្គហៈឡើងជាពាក្យរបស់សកវាទី ។ បើមានពាក្យសួរថា ពាក្យបដិសេធរបស់បរវាទីថា បុគ្គល គឺរូប ត្រឹមត្រូវហើយ ឬ ពាក្យដែលពោលថា រូប ជាវេទនា ក៏គប្បីបដិសេធទាំងអស់ មិនមែនឬ ឆ្លើយថា មែន បដិសេធ ។ ពាក្យនោះ គប្បីបដិសេធ ព្រោះវេទនា មានសភាវៈដោយសភាវៈដទៃអំពីរូប មិនមែនគប្បីបដិសេធ ព្រោះមិនមានដោយសភាវៈដទៃ ។ បរវាទីនេះ រមែងមិនប្រាថ្នាភាពដែលបុគ្គលជាយ៉ាងដទៃដោយធម៌ឯណានីមួយ ក្នុងធម៌ទាំងឡាយ មានរូបជាដើម ព្រោះហេតុនោះ ពាក្យបដិសេធរបស់បរវាទីថា រូប ជាបុគ្គល ទើបត្រឹមត្រូវ ។ ពាក្យសួរនេះថា រូប គឺបុគ្គល ។បេ។ បុគ្គល គឺអញ្ញាតាវិន្ទ្រិយ សកវាទីប្រារព្ធសំដៅយកបរមត្ថសច្ចទាំងអស់ តែបុគ្គលណាមួយ មិនអាចពោលបរមត្ថធម៌ទាំងអស់

ដោយភាពតែមួយបាន ដោយអំណាចនៃបច្ចត្តលក្ខណៈ គឺលក្ខណៈដែលមានចំពោះខ្លួន ព្រោះហេតុនោះ ពាក្យនេះ លោកតាំងទុកហើយ ត្រឹមតែជាលក្ខណៈនៃការសួរ ដោយអំណាចនៃបែបផែន ។ ដោយហេតុនោះ វិញ្ញូជនទាំងឡាយ គួរញុំាងអត្ថនេះឲ្យជាក់ច្បាស់ ។ ឯសកវាទីដែលប្រាថ្នានឹងពោលកាន់យកលក្ខណៈនេះហើយ គប្បីពោលដោយប្រការដែលមិនឲ្យឱកាសដល់បរវាទី ។ ពាក្យនេះ ជាការដែលត្រឹមត្រូវហើយនោះឯង ព្រោះលក្ខណៈនៃការសាកសួរ លោកតាំងទុកហើយ ដោយអំណាចនៃបែបផែន ដោយប្រការដូច្នេះ ។ គប្បីជ្រាបអត្ថក្នុងការសួរទាំងពួង ដោយន័យនេះ ។

តែអត្ថដែលប្លែកគ្នាមានដូចតទៅ ពាក្យទាំងឡាយថា **រូបស្មឹ បុគ្គលោ** ជាដើមនេះ សួរថា ការពោលថា មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ វិញ្ញាណអាស្រ័យវត្ថុរូប រមែងមានក្នុងរូប ដូច្នេះ រមែងគួរ យ៉ាងណា អ្នកស្ទង់ដឹងបុគ្គលដែលមានរូបយ៉ាងនោះឬ ការពោលថា ធម៌ទាំងពួង មានវេទនាជាដើម ខន្ធ ៤ ដែលជាអរូប ឬព្រះនិព្វាននោះឯង ដទៃអំពីរូប ព្រោះការញែកគ្នាដោយសភាវៈ ដូច្នេះ រមែងគួរ យ៉ាងណា អ្នកស្ទង់ដឹងបុគ្គលយ៉ាងនោះឬ ការពោលថា រូបមានក្នុងវេទនា ។បេ។ រូបមានក្នុងវិញ្ញាណ ដោយអំណាចនៃធម៌ដែលជាទីអាស្រ័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដូច្នេះ រមែងគួរ យ៉ាងណា អ្នកស្ទង់ដឹងបុគ្គលយ៉ាងនោះឬ ដូច្នេះ ។ ក្នុងពាក្យសួរទាំងពួង បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចអំពីឧច្ឆេទទិដ្ឋិ និងព្រោះខុសចាកលទ្ធិ ។ ពាក្យដ៏សេសក្នុងទីនេះ ប្រាកដហើយ ដោយអត្ថទាំង

នោះ ។ បើពោលដោយធម៌ ក្នុងចំណែកសកវាទីនេះ លោកសម្តែងពួក ៥ ជា ២២៨ ដោយអំណាចនៃនិគ្គហៈ ដោយការធ្វើឲ្យជានីមួយៗ ៤ ក្នុងអត្ថនីមួយៗ ក្នុងសច្ចិកដ្ឋៈ ៥៧ ប្រភេទ ( ៥៧ × ៤ = ២២៨ ) ។ ក្នុងចំណែកបរវាទី ក៏មានប្រមាណប៉ុណ្ណោះឯង ដោយអំណាចនៃបដិកម្ម ។ម្យ៉ាងទៀត ក្នុងអធិការនេះ កាលបរវាទីពោលថា **អត្ថិ បុគ្គលោ** ជាពាក្យបដិញ្ញាដែលសកវាទីទទួល រមែងមានដោយអំណាចនៃសម្មតិ ដែលមកហើយក្នុងព្រះសូត្រ ។ ក្នុងពាក្យទាំងឡាយ ( របស់បរវាទី ) ថា **រូបំ បុគ្គលោ** ជាដើម សកវាទីធ្វើយបដិសេធ ព្រោះភាពដែលបញ្ហាពោលដោយសក្កាយទិដ្ឋិជាបញ្ហាមិនគួរធ្លើយ ។ បដិកម្មរបស់បរវាទី រមែងមានដោយអំណាចនៃពាក្យដែលមានលេសនោះឯង ដូច្នេះ ។ល។

**អដ្ឋកថាចតុក្កនយសំសន្ទនា ចប់**

**សំសន្ទនកថា ចប់**

# អភិធម្មបិដក

## លក្ខណាយុត្តិកថា

[ ៦០ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គលប្រកបដោយបច្ច័យ ។បេ។ បុគ្គលមិនមានបច្ច័យ ។បេ។ បុគ្គលមានបច្ច័យតាក់តែង ។បេ។ បុគ្គលមិនមានបច្ច័យតាក់តែង ។បេ។ បុគ្គលទៀង ។បេ។ បុគ្គលមិនទៀង ។បេ។ បុគ្គលប្រកបដោយនិមិត្ត ។បេ។ បុគ្គលមិនមាននិមិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីបង្រួញ ។

[ ៦១ ] បុគ្គល គេមិនដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឬ ។ អើ ។ បុគ្គលប្រកបដោយបច្ច័យ ។បេ។ បុគ្គលមិនមានបច្ច័យ ។បេ។ បុគ្គលមានបច្ច័យតាក់តែង ។បេ។ បុគ្គលមិនមានបច្ច័យតាក់តែង ។បេ។ បុគ្គលទៀង ។បេ។ បុគ្គលមិនទៀង ។បេ។ បុគ្គលប្រកបដោយនិមិត្ត ។បេ។ បុគ្គលមិនមាននិមិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីបង្រួញ ។

លក្ខណាយុត្តិកថា ចប់

# អដ្ឋកថា

## លក្ខណាយុត្តិ

[ ៦០-៦១ ] ឥឡូវនេះ ឈ្មោះថា **លក្ខណាយុត្តិ** ។ ក្នុងបញ្ហានោះ ពាក្យសួរទាំង ៨ ជាពាក្យសួររបស់សកវាទី មានបទថា **ពុគ្គលោ សប្បច្ចយោ** ជាដើម សំដៅសេចក្តីថា ព្រោះហេតុដែលវៀរព្រះនិព្វានហើយ សច្ចិកដ្ឋបរមដ្ឋៈដ៏សេស ឈ្មោះថា **សប្បច្ចយោ** ព្រោះជាសភាវៈទាក់ទង ដោយបច្ច័យ ឈ្មោះថា **សង្ខតោ** ព្រោះបច្ច័យទាំងនោះប្រជុំគ្នាតាក់តែងឡើង ឈ្មោះថា **អសស្សតោ** ព្រោះកើតហើយរលត់ទៅ ព្រោះមិនមានសព្វកាល ឈ្មោះថា **និមិត្តោ** ព្រោះភាពដែលនិមិត្តរាប់ព្រមហើយថា ជាហេតុនៃការ កើតឡើងមាន ឯព្រះនិព្វាន មានលក្ខណៈនៃសច្ចិកដ្ឋៈ ដូច្នេះ គឺមិនមាន បច្ច័យ ជាអសង្ខតៈ ទៀង មិនមាននិមិត្ត ព្រោះប្រការដូចពោលហើយមិន មាន ព្រោះហេតុនោះ បើបុគ្គលជាសច្ចិកដ្ឋបរមដ្ឋៈសោត បុគ្គលនោះ ក៏គប្បី មានលក្ខណៈដូចពោលនេះ ។ ពាក្យបដិសេធ ជាពាក្យរបស់បរវាទី ។ ក្នុង ពាក្យថា **អាជានាហិ និគ្គហំ** ជាដើម លោកសង្ខេបក្នុងទីនេះ ។ ក្នុងចំណែក សកវាទី បណ្ឌិតគប្បីជ្រាបបញ្ចកៈ ៨ ពួក ដោយអំណាចត្រឹមតែអនុលោម ក្នុងអនុលោមបច្ចនីកៈ ដោយប្រការដូច្នេះ ។ ក្នុងចំណែកបរវាទី ក៏គប្បីជ្រាប

បញ្ចក: ៨ ពួកដូចគ្នា ដោយអំណាចត្រឹមតែបច្ចនីក: ក្នុងបច្ចិកានុលោម នោះឯង ។ ក្នុងបច្ចិកានុលោមនោះ ព្រោះហេតុដែលបរវាទីធ្វើសម្មតិសច្ច: ឲ្យសម្រេចដោយអំណាចនៃព្រះសូត្រ និងសភាវធម៌ដែលមានបច្ច័យជាដើម នៃសម្មតិសច្ច:មិនមាន ព្រោះហេតុនោះ ទើបសកវាទីបដិសេធតាមសេចក្តីពិត ។ម្យ៉ាងទៀត ពាក្យទាំងឡាយ មានពាក្យថា **អាជានាហិ បដិកម្មំ** ជាដើម ដែលបរវាទីពោលដោយអំណាចពាក្យដែលមានលេស លោកសន្និបនោះឯង ក្នុងទីនេះ ។៚

## អដ្ឋកថាលក្ខណយុត្តិ ចប់

# អភិធម្មបិដក

## វចនសោធនៈ

[ ៦២ ] បុគ្គលគេដឹង ឈ្មោះថា គេដឹងបុគ្គលឬ ។ បុគ្គលគេដឹង តែបុគ្គលខ្លះ គេដឹង បុគ្គលខ្លះ គេមិនដឹងឬ ។ បុគ្គលខ្លះ គេដឹង បុគ្គលខ្លះ គេមិនដឹងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣ ] បុគ្គល មានអត្តដ៏ពិត ឈ្មោះថា បុគ្គលមានអត្តដ៏ពិតឬ ។ បុគ្គលមានអត្តដ៏ពិត តែបុគ្គលខ្លះ មានអត្តដ៏ពិត បុគ្គលខ្លះ មិនមានអត្តដ៏ពិតឬ ។ បុគ្គលខ្លះ មានអត្តដ៏ពិត បុគ្គលខ្លះ មិនមានអត្តដ៏ពិតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤ ] បុគ្គល កំពុងមាន ឈ្មោះថា បុគ្គល កំពុងមានឬ ។ បុគ្គល កំពុងមាន តែបុគ្គលខ្លះ កំពុងមាន បុគ្គលខ្លះ មិនកំពុងមានឬ ។ បុគ្គលខ្លះ កំពុងមាន បុគ្គលខ្លះ មិនកំពុងមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥ ] បុគ្គល កំពុងមានព្រម ឈ្មោះថា បុគ្គល កំពុងមានព្រមឬ ។ បុគ្គល កំពុងមានព្រម តែបុគ្គលខ្លះ កំពុងមានព្រម បុគ្គលខ្លះ មិនកំពុងមានព្រមឬ ។ បុគ្គលខ្លះ កំពុងមានព្រម បុគ្គលខ្លះ មិនកំពុងមានព្រមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦ ] បុគ្គលមាន ឈ្មោះថា មានបុគ្គលឬ ។ បុគ្គលមាន តែបុគ្គលខ្លះ មាន បុគ្គលខ្លះ មិនមានឬ ។ បុគ្គលខ្លះ មាន បុគ្គលខ្លះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧ ] បុគ្គលមាន តែមិនមែនមានសុទ្ធតែបុគ្គលទាំងអស់ឬ ។ អើ ។ បុគ្គលមិនមាន តែមិនមែនគ្មានបុគ្គលទាំងអស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីបង្រួញ ។

**វចនសោធនៈ ចប់**

# អដ្ឋកថា

## វចនសោធនៈ

[ ៦២-៦៧ ] ឥឡូវនេះ ជាការជម្រះពាក្យ ។ ក្នុងបញ្ហានោះ ពាក្យណាថា បុគ្គល ដែលគេដឹង ដូច្នេះ ពាក្យសួរថា **បុគ្គលោ ឧបលព្ភតិ ឧបលព្ភតិ បុគ្គលោ** ដើម្បីជម្រះពាក្យនោះ ជាពាក្យរបស់សកវាទី ។

អត្ថនៃបញ្ហានោះ គប្បីជ្រាបដូចតទៅនេះ បទថា **បុគ្គលោ ឧបលព្ភតិ** នេះ មាន ២ បទ ទាំង ២ បទនេះ គប្បីមានអត្ថដូចគ្នា ឬគប្បីមានអត្ថផ្សេងគ្នា បើគប្បីមានអត្ថផ្សេងគ្នាសោត ពាក្យនេះ ក៏រមែងប្រាកដដូចពាក្យដែលឧបមាថា រូបម្យ៉ាង វេទនាម្យ៉ាង យ៉ាងណា បុគ្គលក៏ម្យ៉ាង សភាវៈដែលឃើញបានក៏ម្យ៉ាង ក៏យ៉ាងនោះ ដូច្នេះ បើមានអត្ថដូចគ្នាសោត ពាក្យនេះ រមែងប្រាកដដូចពាក្យឧបមាថា ចិត្តយ៉ាងណា មនោក៏យ៉ាងនោះ យ៉ាងណា បុគ្គលនោះឯង ជាសភាវៈដែលស្ទង់ដឹងបានយ៉ាងនោះ ដូច្នេះ ដោយហេតុនេះ ខ្ញុំនឹងពោលជាមួយអ្នកថា បើបុគ្គលណាតាមលទ្ធិរបស់អ្នក បុគ្គលនោះជាសភាវៈដែលស្ទង់ដឹងបាន កាលបើយ៉ាងនោះ សភាវៈណាមួយដែលស្ទង់ដឹងបាន សភាវៈនោះៗ រមែងប្រាកដជាបុគ្គល អ្នកទទួលពាក្យនោះឬ បន្ទាប់អំពីនោះ សកវាទីត្រូវការនូវភាពដែលបុគ្គលជាសភាវៈដែលស្ទង់ដឹងបាន មិនបានត្រូវការនូវសភាវៈនៃធម៌ មានរូបជាដើម ដែលស្ទង់ដឹងបានថាជាបុគ្គល ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **បុគ្គលោ ឧបលព្ភតិ ឧបលព្ភតិ កេ ហិ ចិ បុគ្គលោ កេ ហិ ចិ ន បុគ្គលោ** ជាដើម ។ គប្បីជ្រាបអត្ថនៃពាក្យនោះដូចតទៅ បុគ្គលរបស់ខ្ញុំ ជាសភាវៈដែលស្ទង់ដឹងបាន

ដោយព្រះតម្រាស់របស់ព្រះសាស្តាថា **អត្ថិ បុគ្គលោ** ដូច្នេះ សភាវៈដែលស្ទង់ដឹងបានណា សភាវៈដែលស្ទង់ដឹងបាននោះ មិនជាបុគ្គលទាំងអស់ដោយពិត ជាបុគ្គលខ្លះ មិនមែនជាបុគ្គលខ្លះ ។ ក្នុងបទនេះ **កេ** អក្ខរៈ មានអត្ថជា **កោ** អក្ខរៈ **ហិ** អក្ខរៈ និង **ចិ** អក្ខរៈ ត្រឹមតែជានិបាត ។ គប្បីជ្រាបអត្ថក្នុងទីនេះថា ខ្លះជាបុគ្គល ខ្លះមិនមែនបុគ្គល ដូច្នេះ ។ ពាក្យថា ខ្លះជាបុគ្គល ខ្លះមិនមែនបុគ្គលនេះ លោកអធិប្បាយថា បុគ្គលជាសភាវៈដែលស្ទង់ដឹងបាននោះឯង ថាជាធម៌ណាមួយ ក្នុងធម៌ទាំងឡាយ មានរូបជាដើមក្នុងសេចក្តីនេះ បុគ្គលនោះឯង គឺធម៌ណាមួយនោះឯងជាបុគ្គល ឯក្នុងធម៌ទាំងឡាយ មានរូបជាដើម ធម៌ខ្លះ មិនមែនបុគ្គល ដូច្នេះ ។ លំដាប់នោះទើបសកវាទីពោលនឹងបរវាទីនោះថា **បុគ្គលោ កេហិចិ ឧបលព្ភតិ កេហិចិ ន ឧបលព្ភតិ** ដូច្នេះ ។ អត្ថនៃពាក្យសួរនោះ គប្បីជ្រាបដូចតទៅ កាលបទទាំង ២ គឺ **បុគ្គលោ ឧបលព្ភតិ** ដូចគ្នាដោយអត្ថ បើធម៌ដែលទទួលហើយថា ជាសភាវៈដែលស្ទង់ដឹងបានសោត ធម៌ដែលមិនមែនដទៃអំពីបុគ្គល ខ្លះជាបុគ្គល ខ្លះមិនជាបុគ្គល បុគ្គលរមែងប្រាកដដល់អ្នកថា ខ្លះជាសភាវៈដែលស្ទង់ដឹងបាន ខ្លះជាសភាវៈដែលស្ទង់ដឹងមិនបាន អ្នកទទួលពាក្យនោះឬ បរវាទីនោះ កាលមិនប្រាថ្នាថា បុគ្គលជាសភាវៈ ស្ទង់ដឹងមិនបាន ទើបបដិសេធថា **ន ហេវំ** ។ ខាងមុខអំពីនេះទៅ បទថា **អាជានាហិ និគ្គហំ** ជាដើម លោកសង្ខេប ។ បណ្ឌិតគប្បីជ្រាបដោយពិស្តារ ។ ក្នុងបទថា **បុគ្គលោ សច្ចិកដ្ឋោ** ជាដើម ក៏ន័យនេះឯង ។ ពាក្យទាំងពួងនេះ គឺ

**សច្ចិកដ្ឋ វិជ្ជមាន សំវិជ្ជមាន អត្ថិ** ជាវេវចនៈរបស់បទថា **ឧបលព្ភតិ** នោះឯង ។

ម្យ៉ាងទៀត ព្រោះហេតុដែលពាក្យនេះថា បុគ្គលគេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ជាពាក្យប្តេជ្ញារបស់បុគ្គលវាទី ( បរវាទី ) ព្រោះហេតុនោះ លទ្ធិរបស់បរវាទីថា បុគ្គលជាសភាវៈដែលសួង់ដឹងបាន យ៉ាងណា បុគ្គលក៏រមែងប្រាកដថាជាសច្ចិកដ្ឋៈ ក៏យ៉ាងនោះដូចគ្នា ។ លទ្ធិណារបស់បរវាទីនោះថា បុគ្គលកំពុងមាន ( **បុគ្គលោ អត្ថិ** ) ដូច្នេះ លទ្ធិនោះក៏ជាវេវចនៈនឹងពាក្យថា បុគ្គលកំពុងវិជ្ជមាន ដូច្នេះ ក៏ដូចគ្នា ព្រោះហេតុនោះ ពាក្យវេវចនៈទាំងពួងនេះ ជម្រះរៀបរយហើយ ។

ក្នុងបញ្ហាទាំងនោះ ពាក្យណា ដែលសកវាទីពោលក្នុងទីបំផុតថា **បុគ្គលោ អត្ថិ អត្ថិ ន សព្វោ បុគ្គលោ** គប្បីជ្រាបអធិប្បាយក្នុងពាក្យនោះដូចតទៅ

ពិតហើយ បរវាទីពោលពាក្យណាថា **បុគ្គលោ អត្ថិ អត្ថិ កោហិចិ បុគ្គលោ កោហិចិ ន បុគ្គលោ** ដូច្នេះ ពាក្យនោះ ព្រោះហេតុដែលកាលពោលដោយអត្ថហើយ ក៏មានពាក្យត្រឹមតែប៉ុណ្ណេះថា **បុគ្គលោ អត្ថិ អត្ថិ ន សព្វោ បុគ្គលោ** ហេតុនោះ ទើបសកវាទីឲ្យបរវាទីទទួលពាក្យនោះហើយ ទើបសាកសួរបរវាទីនោះ ក្នុងឥឡូវនេះថា អ្នកកាន់យកលទ្ធិថា បុគ្គលមាន ព្រោះអាស្រ័យត្រឹមតែព្រះតម្រាស់ថា មានបុគ្គលបដិបត្តិ ដើម្បីប្រយោជន៍ខ្លួន ក៏ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នោះ យ៉ាងណា ទ្រង់ក៏ត្រាស់

ព្រះតម្រាស់ថា បុគ្គលមិនមាន ដោយន័យជាដើមថា ម្នាលមោឃរាជ ចូរអ្នកជាអ្នកមានសតិសព្វកាល ចូរពិចារណាលោក ដោយសភាពជារបស់សូន្យ ដូច្នេះ ។ ព្រោះហេតុនោះ លទ្ធិរបស់អ្នកដែលសម្តែងថា បុគ្គលជាសភាវៈដែលមាន តែសភាវៈដែលមាន មិនជាបុគ្គលទាំងអស់ យ៉ាងណា បុគ្គលរមែងប្រាកដថា ជាសភាវៈដែលមិនមាន តែសភាវៈដែលមិនមាន មិនជាបុគ្គលទាំងអស់ យ៉ាងនោះ ដូច្នេះ អ្នកទទួលពាក្យនោះឬ លំដាប់នោះ បរវាទីកាលមិនទទួលពាក្យនោះ ទើបបដិសេធថា **ន ហេវំ** ។ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបវិធី មាននិគ្គហៈជាដើមដ៏សេស ដោយន័យដែលពោលហើយនោះឯង ៕

**អដ្ឋកថាវចនសោធនៈ ចប់**

# អភិធម្មបិដក

## បញ្ញត្តានុយោគ

[ ៦៨ ] បុគ្គល មានរូប ព្រោះរូបធាតុឬ ។ អើ ។ បុគ្គលមានកាម ព្រោះ កាមធាតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៩ ] សត្វទាំងឡាយ មានរូប ព្រោះរូបធាតុឬ ។ អើ ។ សត្វទាំងឡាយ មានកាម ព្រោះកាមធាតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧០ ] បុគ្គល មិនមានរូប ព្រោះអរូបធាតុឬ ។ អើ ។ បុគ្គលមានកាម ព្រោះកាមធាតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១ ] សត្វទាំងឡាយ មិនមានរូប ព្រោះអរូបធាតុឬ ។ អើ ។ សត្វទាំងឡាយ មានកាម ព្រោះកាមធាតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧២ ] បុគ្គល មានរូប ព្រោះរូបធាតុ បុគ្គល មិនមានរូប ព្រោះអរូប-ធាតុ ចុះបុគ្គលខ្លះ ច្យុតចាករូបធាតុ ចូលទៅកើតក្នុងអរូបធាតុ មានដែរឬ ។ អើ ។ បុគ្គលមានរូប តែបែរជាសូន្យ បុគ្គលមិនមានរូប ត្រឡប់ជាកើតទៀត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៣ ] សត្វទាំងឡាយ មានរូប ព្រោះរូបធាតុ សត្វទាំងឡាយ មិនមានរូប ព្រោះអរូបធាតុ ចុះសត្វខ្លះ ច្យុតចាករូបធាតុ ចូលទៅកើតក្នុងអរូប-ធាតុ មានដែរឬ ។ អើ ។ ចុះសត្វ មានរូប តែបែរជាសូន្យ សត្វ មិនមានរូប ត្រឡប់ជាកើតទៀត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៤ ] ( ខ្ញុំ ) ធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយនុ៎ះ តាំងនៅក្នុងទីជាមួយ

គ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នាឬ ។ អើ ។ ( ខ្ញុំ ) ធ្វើបុគ្គលឲ្យជាប់គ្នា រួម ហៅថា បុគ្គលក្តី ថាជីវិតក្តី ឬថា ជីវិតក្តី ថាបុគ្គលក្តី ( ហើយសួរថា ) បុគ្គលទាំង៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នាឬ ។ អើ ។ កាយដទៃ បុគ្គលដទៃឬ ។ អើ ។ ជីវិតដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយទាំង៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ឬខ្ញុំធ្វើបុគ្គលឲ្យជាប់គ្នា រួម ហៅថា បុគ្គលក្តី ថាជីវិតក្តី ឬថា ជីវិតក្តី ថាបុគ្គលក្តី ( ហើយសួរថា ) បុគ្គលទាំង៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា កាយដទៃ បុគ្គលដទៃ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ជីវិតដទៃ សរីរៈដទៃដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយទាំង៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ឬខ្ញុំធ្វើបុគ្គលឲ្យជាប់គ្នា រួម ហៅថា បុគ្គលក្តី ថាជីវិតក្តី ឬថា ជីវិតក្តី ថាបុគ្គលក្តី ( ហើយសួរថា ) បុគ្គលទាំង៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា កាយដទៃ បុគ្គលដទៃ តែអ្នកមិនគប្បីពោលថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះ

ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយទ៉ុះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ឬខ្ញុំធ្វើបុគ្គលឲ្យជាប់គ្នា រួម ហៅថា បុគ្គលក្តី ថាជីវិតក្តី ឬថា ជីវិតក្តី ថាបុគ្គលក្តី ( ហើយសួរថា ) បុគ្គលទ៉ុះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា កាយដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយទ៉ុះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ឬខ្ញុំធ្វើបុគ្គលឲ្យជាប់គ្នា រួម ហៅថា បុគ្គលក្តី ថាជីវិតក្តី ឬថា ជីវិតក្តី ថាបុគ្គលក្តី ( ហើយសួរថា ) បុគ្គលទ៉ុះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា កាយដទៃ បុគ្គលដទៃ តែអ្នកមិនគប្បីពោលថា ជីវិតដទៃ សរីរៈដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។

[ ៧៥ ] ( ខ្ញុំ ) ធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយទ៉ុះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នាឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្ទប្ប ។ កាយដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវអំពើផ្ទុយចុះ ប្រសិនបើខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថា

កាយក្តី ( ហើយសួរថា ) កាយនុ៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា កាយដទៃ បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយនុ៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគប្បីពោលថា កាយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស មួយទៀត ប្រសិនបើ អ្នកមិនគប្បីពោលថា កាយដទៃ បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថា ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថាកាយក្តី ( ហើយសួរថា ) កាយនុ៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា

ខ្ញុំធ្វើកាយឲ្យជាប់គ្នា រួម ហៅថា កាយក្តី ថាសរីរៈក្តី ឬថា សរីរៈក្តី ថា កាយក្តី ( ហើយសួរថា ) កាយនុ៎ះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា មានជាតិដូចគ្នា ព្រះមានព្រះភាគត្រាស់ថា មានបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែអ្នកមិនគួរពោលថា កាយដទៃ បុគ្គលដទៃ ដូច្នេះទេ ព្រោះជាពាក្យខុស ។បេ។ សេចក្តីបង្រួញ ។

## បញ្ញត្តានុយោគ ចប់

# អដ្ឋកថា

## បញ្ញត្តានុយោគ

[ ៦៨-៧៥ ] ឥឡូវនេះ ឈ្មោះថា ជាការសួររឿងបញ្ញត្តិដូចតទៅ

បុគ្គលវាទី ( បរវាទី ) រមែងបញ្ញត្តបុគ្គល ដែលមានរូបព្រោះរូបធាតុ ។ ដោយទំនងដូចគ្នា រមែងបញ្ញត្តបុគ្គលដែលមិនមានព្រោះអរូបធាតុ ។ ពាក្យសួរទាំងពួង ដើម្បីទម្លាយលទ្ធិរបស់បុគ្គលវាទីជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួលផង ពាក្យបដិសេធផង ជាពាក្យរបស់បរវាទី ។ កាលសកវាទីសួរថា **រូបី** ជាដើម បរវាទីក៏ឆ្លើយទទួល ព្រោះសភាពមានរូបកាយ និងព្រោះបញ្ញត្តិបែបនោះមាន ។ កាលសកវាទីសួរថា **កាមី** បរវាទីឆ្លើយបដិសេធ ព្រោះមានសភាវៈដែលរាគៈទៅប្រាសហើយ និងព្រោះបញ្ញត្តិបែបនោះមិនមាន ។ កាលសកវាទីសួរថា **អរូបី** បរវាទីក៏ឆ្លើយទទួល ព្រោះសភាពមានអរូបក្ខន្ធ និងព្រោះបញ្ញត្តិបែបនោះមាន ។ ក្នុងន័យទាំង ២ ពាក្យថា សត្វ លោកពោលហើយ ដោយអំណាចនៃពាក្យជាវេវចនៈរបស់បុគ្គល ។

ឥឡូវនេះ បរវាទីគាប់ចិត្តថា **អញ្ញោ កាយោ អញ្ញោ បុគ្គលោ** ព្រោះបាលីដែលមកហើយថា ពិចារណាឃើញកាយក្នុងកាយ ព្រោះហេតុនោះ ដើម្បីទម្លាយលទ្ធិនោះ ទើបសកវាទីសួរថា **កាយោតិ វា សរីរន្តិ វា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **កាយំ អប្បិយំ ករិត្វា** មាន អធិប្បាយថា ខ្ញុំសួរ ធ្វើកាយឲ្យជាដុំ ឲ្យស្អិតជាប់គ្នា បង្អោនទៅកាន់ឯកីភាវៈ មិនគប្បីបែក ។ បទថា **ឃសេ សេ** បានដល់ **ឃសោ សោ** នោះឯង ។ ព្រះបាលីថា

**ឃដេ ឃដេ** ដូច្នេះក៏មាន អធិប្បាយថា **ឃដេ ឃដោ** នោះឯង ។ បទថា **ឃកាដ្ឋេ** បានដល់ **ឃកាដ្ឋោ** ។ បទថា **សមេ សមភាគេ តជ្ជាតេ** បានដល់ **សមោ សមភាគោ តជ្ជាតិកោ** ។ ក្នុងទីនេះ ផ្សេងគ្នាត្រឹមតែពាក្យប៉ុណ្ណោះ ។ បើពោលដោយអត្ថហើយ សកវាទីសួរថា នុ៎ះ គឺកាយឬ ។ បរវាទីកាលមិនឃើញការប្លែកគ្នា ទើបឆ្លើយទទួលថា **អាមន្តា** ។ ក្នុងពាក្យសួរថា **បុគ្គលោ វា ជីវោ វា** ក៏ន័យនេះឯង ។ ម្យ៉ាងទៀត បរវាទី ត្រូវសកវាទីសួរថា **អញ្ញោ កាយោ** ក៏ឆ្លើយទទួល ព្រោះជាអ្នកមានលទ្ធិយ៉ាងនេះក្នុងកាយានុបស្សនា តែកាលត្រូវសួរថា **អញ្ញំ ជីវំ** បរវាទីកាលមិនអាចបដិសេធព្រះសូត្រ ដែលប្រកាន់សម្រាប់ពោល ទើបត្រូវពោលបដិសេធ ។ ខាងមុខអំពីនេះ បទថា **អាជានាហិ និគ្គហំ** ជាដើម មានអត្ថងាយយល់ហើយ ។

ចំណែកបរវាទី កាលត្រូវសកវាទីសួរថា **អញ្ញោ កាយោ អញ្ញោ បុគ្គលោ** រមែងបដិសេធ ព្រោះភាពជាបញ្ហា ដែលគួរវៀរមិនឆ្លើយ ទើបបរវាទីធ្វើបដិកម្ម ដោយអំណាចនៃពាក្យដែលមានលេស ។ សូម្បីពាក្យនោះ ក៏មានអត្ថងាយយល់ហើយ ៕

អដ្ឋកថាបញ្ញត្តានុយោគ ចប់

# អភិធម្មបិដក

## គតិអនុយោគ

[ ៧៦ ] បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលនោះ ប្រាកដជាអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៧ ] បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលដទៃ អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨ ] បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលនោះផង បុគ្គលដទៃផង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៩ ] បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលនោះ មិនអន្ទោល បុគ្គលដទៃ ក៏មិនអន្ទោល ចាកលោកនេះ ទៅកាន់លោកខាងមុខទេ មិនអន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០ ] បុគ្គល អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលនោះអន្ទោល បុគ្គល

ដទៃអន្ទោល បុគ្គលនោះផង បុគ្គលដទៃផង អន្ទោល បុគ្គលនោះ មិនអន្ទោល បុគ្គលដទៃ មិនអន្ទោល ចាកលោកនេះ ទៅកាន់លោកខាងមុខ មិនអន្ទោល ចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១ ] អ្នកមិនគួរពោលថា បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា

បុគ្គលនោះ អន្ទោល កំណត់ត្រឹមតែ ៧ ជាតិ ជាអ្នកបាន
ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់សញ្ញោជនៈទាំងពួង ពាក្យ
ដូច្នេះ មានក្នុងព្រះសូត្រឬ ។

អើ ។ បើដូច្នោះ មានតែបុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះ ។

[ ៨២ ] អ្នកមិនគួរពោលថា បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំសារនេះ មានទីបំផុតគេមិនអាចដឹងបានទេ ទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង កាលស្ទុះទៅ កាលអន្ទោលទៅ មិនប្រាកដឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ មានតែបុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះ ។

[ ៨៣ ] បុគ្គលអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ សត្វខ្លះ ជាមនុស្ស បានទៅកើតជាទេវតា មានមែនឬ ។ អើ ។ មនុស្សនោះឯង គឺទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនុស្សនោះឯង គឺទេវតានោះឬ ។ អើ ។ សត្វដែលកើតជាមនុស្ស ហើយបានទៅកើតជាទេវតា ដែលកើតជាទេវតា ហើយទៅកើតជាមនុស្ស សត្វដែលកើតជាមនុស្ស ហើយទៅកើតជាទេវតាដទៃ ទៅកើតជាមនុស្សដទៃ សត្វនោះឯង រមែងអន្ទោលទៅ ពាក្យនេះជាពាក្យខុស ។បេ។ ប្រសិនបើ បុគ្គលនោះឯង ច្យុតចាកលោកនេះ អន្ទោលទៅកាន់លោកខាងមុខ មិនមែនជាបុគ្គលដទៃទេ កាលបើយ៉ាងនេះ សេចក្ដីស្លាប់នឹងមិនមាន សូម្បីបាណាតិបាតក៏មិនមាន តែកម្មមាន កម្មវិបាកមាន វិបាកនៃកម្មទាំងឡាយ ដែលសត្វធ្វើហើយក៏មាន កាលកុសល និងអកុសលកំពុងឲ្យផល សត្វនោះឯង តែងអន្ទោលទៅ ពាក្យដូច្នេះនេះ ជាពាក្យខុស ។បេ។ បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ សត្វខ្លះ ដែលកើតជាមនុស្ស ហើយទៅកើតជាយក្ស ទៅកើតជាប្រេត ជាសត្វនរក ជាសត្វតិរច្ឆាន ជាឱដ្ឋ ជាគោ ជាលា ជាជ្រូក ជាក្របី មានមែនឬ ។

អើ ។ មនុស្សនោះឯង គឺក្របីនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មនុស្សនោះឯង គឺក្របីនោះឬ ។ អើ ។ សត្វដែលកើតជាមនុស្ស ហើយទៅកើតជាក្របី សត្វដែលកើតជាក្របី ហើយទៅកើតជាមនុស្ស សត្វដែលកើតជាមនុស្ស ហើយទៅកើតជាក្របីដទៃ ទៅកើតជាមនុស្សដទៃ សត្វនោះឯងតែងអន្ទោលទៅ ពាក្យដូច្នេះនេះ ជាពាក្យខុស ។បេ។ ប្រសិនបើ បុគ្គលនោះឯង ច្យុតចាកលោកនេះ អន្ទោលទៅកាន់លោកខាងមុខ មិនមែនជាបុគ្គលដទៃឡើយ កាលបើយ៉ាងនេះ សេចក្តីស្លាប់នឹងមិនមាន សូម្បីបាណាតិបាតក៏មិនមាន តែកម្មមាន កម្មវិបាកមាន វិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើហើយក៏មាន កាលបើកុសល និងអកុសលកំពុងឲ្យផល សត្វនោះឯង តែងអន្ទោលទៅ ពាក្យដូច្នេះនេះ ជាពាក្យខុស ។បេ។ បុគ្គលនោះឯងអន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខមកកាន់លោកនេះឬ ។ អើ ។ សត្វខ្លះ ដែលកើតជាក្សត្រ ហើយទៅកើតជាព្រាហ្មណ៍ មានមែនឬ ។ អើ ។ ក្សត្រនោះឯង គឺព្រាហ្មណ៍នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វខ្លះ ដែលកើតជាក្សត្រ ហើយទៅកើតជាអ្នកជំនួញ ទៅកើតជាអ្នកគ្រួ មានមែនឬ ។ អើ ។ ក្សត្រនោះឯង គឺអ្នកគ្រួនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វខ្លះ ដែលកើតជាព្រាហ្មណ៍ ហើយទៅកើតជាអ្នកជំនួញ ជាអ្នកគ្រួ ជាក្សត្រ មានមែនឬ ។ អើ ។ ព្រាហ្មណ៍នោះឯង គឺក្សត្រនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វខ្លះ ដែលកើតជាអ្នកជំនួញ ហើយទៅកើតជាអ្នកគ្រួ ជាក្សត្រ ជាព្រាហ្មណ៍ មាន

មែនឬ ។ អើ ។ អ្នកជំនួញនោះឯង គឺជាព្រាហ្មណ៍នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វខ្លះ ដែលកើតជាអ្នកគ្រួ ហើយទៅកើតជាក្សត្រ ជាព្រាហ្មណ៍ ជាអ្នកជំនួញ មានមែនឬ ។ អើ ។ អ្នកគ្រួនោះឯង គឺអ្នកជំនួញនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលកំបុតដៃ នៅតែកំបុតដៃដដែល បុគ្គលកំបុតជើង នៅតែកំបុតជើងដដែល បុគ្គលកំបុតទាំងដៃទាំងជើង នៅតែកំបុតទាំងដៃទាំងជើងដដែល បុគ្គលកំបុតស្លឹកត្រចៀក បុគ្គលកំបុតច្រមុះ បុគ្គលកំបុតទាំងត្រចៀកទាំងច្រមុះ បុគ្គលកំបុតម្រាមដៃ បុគ្គលកំបុតមេដៃមេជើង បុគ្គលដាច់សរសៃធំ បុគ្គលមានដៃក្ងែង បុគ្គលមានដៃព្រែក បុគ្គលមានរោគឃ្លង់ បុគ្គលមានបូស បុគ្គលមានរោគស្រែង បុគ្គលមានរោគហឺត បុគ្គលធ្លួតជ្រូក សត្វឱដ្ឋ គោ លា ជ្រូក ក្របីនៅជាក្របីដដែលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤ ] អ្នកមិនគួរពោលថា បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ ក្រែងបុគ្គលបានដល់នូវសោតៈ ច្យុតចាកមនុស្សលោក ហើយចូលទៅកាន់ទេវលោក នៅតែជាអ្នកដល់សោតៈ ក្នុងទេវលោកនោះដដែលឬ ។ អើ ។ ប្រសិនបើ បុគ្គលបានដល់នូវសោតៈ ច្យុតចាកមនុស្សលោក ហើយចូលទៅកាន់ទេវលោក ជាអ្នកនៅតែដល់នូវសោតៈ ក្នុងទេវលោកនោះដដែល ម្នាល

អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលនោះឯង អន្ទោលចាក លោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោក នេះដែរ ។

[ ៨៥ ] សកវាទី ធ្វើ ( នូវការប្តេជ្ញាឲ្យមាំ ) ថា បុគ្គលបានដល់នូវ សោតៈ ច្យុតចាកមនុស្សលោក ហើយចូលទៅកាន់ទេវលោក ក៏នៅតែបាន ដល់នូវសោតៈ ក្នុងទេវលោកនោះដដែល ( ហើយសួរថា ) ព្រោះហេតុនោះ ឯង បុគ្គលនោះ អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាក លោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ សកវាទី ធ្វើ ( នូវការប្តេជ្ញា ឲ្យមាំ ) ថា បុគ្គលបានដល់នូវសោតៈ ច្យុតចាកមនុស្សលោក ហើយចូល ទៅកាន់ទេវលោក ក៏នៅជាមនុស្សក្នុងទេវលោកនោះដដែលឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។

[ ៨៦ ] បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលមិនមែនដទៃ មិនមែនទៅប្រាស តែងអន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៧ ] បុគ្គលមិនមែនដទៃ មិនទាន់ទៅប្រាស តែងអន្ទោលទៅឬ ។ អើ ។ បុគ្គលកំបុតដៃ នៅតែកំបុតដៃដដែល បុគ្គលកំបុតជើង នៅតែកំបុត ជើងដដែល បុគ្គលកំបុតទាំងដៃទាំងជើង ក៏នៅតែកំបុតទាំងដៃទាំងជើងដដែល បុគ្គលកំបុតត្រចៀក បុគ្គលកំបុតច្រមុះ បុគ្គលកំបុតទាំងត្រចៀក ទាំងច្រមុះ បុគ្គលកំបុតម្រាមដៃ បុគ្គលកំបុតមេដៃមេជើង បុគ្គលដាច់សរសៃធំ បុគ្គល

មានដៃក្ងែង បុគ្គលមានដៃព្រែក បុគ្គលមានរោគឃ្លង់ បុគ្គលមានរោគបូស បុគ្គលមានរោគស្រែង បុគ្គលមានរោគហឺត បុគ្គលធ្លុតជ្រូក សត្វឱដ្ឋ គោ លា ជ្រូក ក្របី ក៏នៅតែជាក្របីដដែលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៨ ] បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលមានរូប តែង អន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមានរូប តែង អន្ទោលទៅឬ ។ អើ ។ ជីវិតនោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ បុគ្គលមានវេទនា ។បេ។ បុគ្គលមានសញ្ញា ។បេ។ បុគ្គលមាន សង្ខារ ។បេ។ បុគ្គលមានវិញ្ញាណ តែងអន្ទោលទៅឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ បុគ្គលមានវិញ្ញាណ តែងអន្ទោលទៅឬ ។ អើ ។ ជីវិត នោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩ ] បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ បុគ្គលមិនមានរូប អន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមិនមានរូប អន្ទោលទៅឬ ។ អើ ។ ជីវិតដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ បុគ្គលមិនមានវេទនា ។បេ។ បុគ្គលមិនមានសញ្ញា ។បេ។ បុគ្គលមិនមានសង្ខារ ។បេ។ បុគ្គលមិនមានវិញ្ញាណ អន្ទោលទៅឬ ។ អ្នកមិន គួរពោលយ៉ាងនេះទេ ។ បុគ្គលមិនមានវិញ្ញាណ តែងអន្ទោលទៅឬ ។ អើ ។ ជីវិតដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩០ ] បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ រូបអន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបអន្ទោលទៅឬ ។ អើ ។ ជីវិតនោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណអន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណ អន្ទោលទៅឬ ។ អើ ។ ជីវិតនោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩១ ] បុគ្គលនោះឯង អន្ទោលចាកលោកនេះ ទៅកាន់លោកខាងមុខ អន្ទោលចាកលោកខាងមុខ មកកាន់លោកនេះឬ ។ អើ ។ រូបមិនអន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបមិនអន្ទោលទៅឬ ។ អើ ។ ជីវិតដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណមិនអន្ទោលទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណមិនអន្ទោលទៅឬ ។ អើ ។ ជីវិតដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីបង្រួញ ។

កាលបើខន្ធទាំងឡាយ បែកធ្លាយ ប្រសិនបើ បុគ្គលនោះ
បែកធ្លាយដែរ ទិដ្ឋិ ( របស់អ្នក ) ទៅជាឧច្ឆេទទិដ្ឋិ ជាទិដ្ឋិ
ដែលព្រះពុទ្ធ ទ្រង់វៀរហើយ កាលបើខន្ធទាំងឡាយបែកធ្លាយ
ប្រសិនបើ បុគ្គលមិនបែកធ្លាយទេ បុគ្គលទៅជាទៀង ស្មើ
នឹងព្រះនិព្វានដែរ ។

**គតិអនុយោគ ចប់**

# អដ្ឋកថា

## គតិអនុយោគ

[ ៧៦-៨១ ] ឥឡូវនេះ ជាការសួរដល់ចុតិ និងបដិសន្ធិ ក្នុងការផ្លាស់ប្តូរគតិដូចតទៅ

ក្នុងបញ្ហានោះ ព្រោះបុគ្គលវាទីអាស្រ័យព្រះសូត្រទាំងឡាយថា បុគ្គលនោះ អន្ទោល កំណត់ត្រឹមតែ ៧ ជាតិ ដូច្នេះជាដើម ហើយកាន់យកលទ្ធិពោលថា **បុគ្គលោ សន្ធាវតិ** ហេតុនោះ ដើម្បីទម្លាយលទ្ធិរបស់បុគ្គលវាទីនោះ ទើបសកវាទីសួរថា **សន្ធាវតិ** ។ បណ្តាពាក្យទាំងនោះ ពាក្យថា **សន្ធាវតិ** បានដល់ រមែងស្ទុះទៅ គឺធ្វើការអន្ទោលទៅមកៗ ។ ពាក្យឆ្លើយទទួលដោយអំណាចនៃលទ្ធិរបស់ខ្លួន ជាពាក្យរបស់បរវាទី ។ ពាក្យសួរថា **សោ បុគ្គលោ** ជាដើម ជាពាក្យជារបស់សកវាទី ។ ពាក្យឆ្លើយបដិសេធជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហានោះ បទថា **សោ** អធិប្បាយថា បុគ្គលនោះឯង ។ បរវាទី ត្រូវសួរយ៉ាងនេះហើយ ទើបឆ្លើយបដិសេធ ព្រោះខ្លាចត្រូវចោទថា ជាសស្សតទិដ្ឋិ ។ ត្រូវសួរថា **អញ្ញោ** ក៏ឆ្លើយបដិសេធ ព្រោះខ្លាចត្រូវចោទថា ជាឧច្ឆេទទិដ្ឋិ ។ ត្រូវសួរថា **សោ អញ្ញោ ច** ក៏ឆ្លើយបដិសេធ ព្រោះខ្លាចត្រូវតិះដៀលថា ជាឯកច្ចសស្សតទិដ្ឋិ ។ ត្រូវសួរថា **នេវ សោ ន អញ្ញោ** ក៏ឆ្លើយបដិសេធ ព្រោះខ្លាចត្រូវតិះដៀលថា ជាអមរាវិក្ខេបទិដ្ឋិ ។ ត្រូវសួរបញ្ហាទាំង ៤ រួមគ្នាទៀត ក៏បដិសេធ ព្រោះខ្លាចត្រូវតិះដៀលថា ជាទិដ្ឋិទាំង ៤ ។ ម្យ៉ាងទៀត លទ្ធិរបស់បរវាទីនោះ អាស្រ័យព្រះសូត្រទាំងឡាយ

ឯណាកើតឡើង បរវាទីនោះ កាលសម្តែងព្រះសូត្រទាំងនោះ ទើបពោលពាក្យថា **តេន ហិ បុគ្គលោ សន្ធាវតិ** ជាដើម ។

[ ៨៣ ] សកវាទីកំណត់ពាក្យថា **ស្វេវ** ហើយសួរទៀត ដោយបំណងថា បុគ្គលនេះ អន្ទោលទៅតាមលទ្ធិរបស់អ្នក បុគ្គលនោះជាមនុស្សដូចគ្នាក្នុងលោកនេះផង ក្នុងលោកដទៃផងឬ បរវាទីបដិសេធ ព្រោះខ្លាចគេថាជាសស្សតទិដ្ឋិ កាលត្រូវសួរដដែល ធ្វើឲ្យមាំទាំយ៉ាងនោះឯងទៀត ត្រឡប់ជាឆ្លើយទទួល ព្រោះមានព្រះសូត្រថា តថាគតលុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ដូច្នេះជាដើម ។ បរវាទីត្រូវសួរថា **ស្វេវ មនុស្សោ** ក៏ឆ្លើយបដិសេធ ព្រោះមនុស្សនោះឯង មិនមែនទេវតា ។

ត្រូវសួរដដែលទៀត ក៏ឆ្លើយទទួលដោយអំណាចនៃព្រះសូត្រថា **អហំ តេន សមយេន សុនេត្តោ នាម សត្ថា អហោសិ** សម័យនោះ តថាគតជាគ្រូឈ្មោះសុនេត្ត ដូច្នេះជាដើម ។ ពេលនោះ សកវាទីកាលនឹងប្រកាសពាក្យនោះថា ខុស ព្រោះការផ្សេងគ្នានៃការកើតឡើងនៃទេវតា និងមនុស្សទើបពោលពាក្យថា **មនុស្សោ ហុត្វា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ហេវំ មរណំ ន ហេហិតិ** មានអធិប្បាយថា កាលភាពបែបនោះមាន ការស្លាប់ក៏នឹងមិនមាន ។ បន្ទាប់អំពីនេះទៅ បទថា **យក្ខោ បេតោ** ជាដើម បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃការសួរ ដោយអំណាចនៃការផ្សេងគ្នាដោយអត្តភាព ។

បទថា **ខត្តិយោ** ជាដើម សកវាទីពោលដោយអំណាចនៃជាតិ និង

ដោយអំណាចនៃការខ្វះខាតនៃអវយវៈជាដើម ។

[ ៨៤ ] ដោយពាក្យដែលត្រូវបរវាទីសួរថា **ន វត្តព្វំ** ដូច្នេះជាដើម ពាក្យឆ្លើយទទួល ព្រោះភាពដែលបុគ្គលតាំងនៅក្នុងភពនេះ ទៅកាន់បរលោក ដោយអំណាចនៃការកើតមិនមាន ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួលលើកទី ២ ព្រោះព្រះសោតាបន្នមិនលះនូវភាពជាព្រះសោតាបន្ន ក្នុងវវាងនៃភព ជាពាក្យរបស់សកវាទី ។ ពាក្យថា ប្រសិនបើជាដើម ជាពាក្យរបស់បរវាទី ។

[ ៨៥ ] កាលសួរទៀត ដោយការសម្ដែងដល់ការមិនមានភាពជាមនុស្សរបស់បុគ្គលដែលកើតក្នុងទេវលោក ជាពាក្យរបស់សកវាទី ។

[ ៨៦ ] ខាងមុខអំពីនេះ បទថា **អញ្ញោ** ក្នុងបទថា **អញ្ញោ អវិគតោ** បានដល់ ដូចគ្នាដោយអាការទាំងពួង ។ បទថា **អវិគតោ** មានអធិប្បាយថា មិនប្រែប្រួលដោយអាការណាមួយ ។ បរវាទីពោលយ៉ាងនេះថា **ន ហេវំ** ដោយភាពជារបស់មនុស្ស របស់បុគ្គលដែលកើតឡើងក្នុងទេវលោក ( មិនមាន )។

[ ៨៧ ] សកវាទី សួរបញ្ហានោះធ្វើឲ្យមាំទៀត បរវាទី ក៏ឆ្លើយទទួលតាមលទ្ធិថា បុគ្គលនោះៗ ឯងត្រាច់ទៅ ។ បទថា **ហត្ថច្ឆិន្នោ** ជាដើម សកវាទីពោលដើម្បីទម្លាយលទ្ធិថា **សន្ធាវតិ** ដោយការសម្ដែងដល់ការប្រែប្រួលលក្ខណៈ ។ ក្នុងបទទាំងនោះ បទថា **អង្គុលិច្ឆិន្នោ** បានដល់ ម្រាមមេដៃ ម្រាមមេជើង នៃបុគ្គលណាដាច់ហើយ ។ បទថា **កណ្ណច្ឆិន្នោ** បាន

ដល់ សារសែធំរបស់បុគ្គលណាដាច់ហើយ ។

[ ៨៨ ] ក្នុងបទទាំងឡាយ បទថា **សរូបោ** ជាដើម បរវាទីឆ្លើយបដិសេធ ក្នុងបញ្ហាដំបូង សំដៅយកការមិនត្រាច់ទៅជាមួយរូបកាយនេះ ។ ឆ្លើយទទួលក្នុងបញ្ហាទី ២ សំដៅយកបុគ្គលដែលមានភពក្នុងចន្លោះ ។ ពិតហើយ ក្នុងលទ្ធិនៃបុគ្គលនោះ បុគ្គលដែលមានរូបនោះឯងត្រាច់ទៅ ហើយចូលទៅកាន់ផ្ទៃរបស់មាតា បន្ទាប់អំពីនោះ រូបរបស់បុគ្គលនោះចូលកាន់ផ្ទៃមាតានោះ រមែងបែកធ្លាយទៅ ( នេះហៅថា មានភពក្នុងចន្លោះរបស់បុគ្គលនោះ ) ។ បទថា **តំ ជីវំ** សេចក្តីថា សកវាទីសួរថា បុគ្គលរមែងទៅព្រមជាមួយសរីរៈ ពោល គឺរូបឯណា ជីវៈក៏របស់បុគ្គលនោះ សរីរៈក៏របស់បុគ្គលនោះឬ ។ បរវាទីឆ្លើយបដិសេធ ព្រោះត្រូវលះបង់សរីរៈក្នុងលោកនេះនិងព្រោះខុសចាកព្រះសូត្រ ។

ក្នុងបទទាំងឡាយ មានបទថា **សវេទនោ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកការកើតឡើងនៃអសញ្ញសត្វ ។ ឆ្លើយទទួលព្រោះសំដៅយកការកើតឡើង ក្រៅអំពីអសញ្ញសត្តនោះ ។ បទថា **តំ ជីវំ** សេចក្តីថា សកវាទីរមែងសួរថា បុគ្គលរមែងទៅជាមួយសរីរៈ ពោល គឺវេទនាជាដើម យ៉ាងណា ជីវៈក៏យ៉ាងនោះឯង សរីរៈក៏យ៉ាងនោះឯងឬ ។ ពិតហើយ ពាក្យថា សរីរៈ តាមលទ្ធិនេះថា ជីវៈនោះ សរីរៈក៏នោះ ជីវៈដទៃសរីរៈក៏ដទៃនេះ សំដៅយកខន្ធទាំង ៥ ។ បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។

[ ៨៩ ] ក្នុងបទទាំងឡាយ មានបទថា **អរូបោ** ក្នុងបញ្ហាទី ១ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកភព មានក្នុងចន្លោះតាមលទ្ធិ ។ ក្នុងបញ្ហាទី ២ ឆ្លើយទទួល ព្រោះសំដៅយកអរូបដែលចូលដល់អំពីអរូប ។ បទថា **អញ្ញំ ជីវំ** សេចក្តីថា សកវាទីសួរថា បុគ្គលមិនមានរូប លះសរីរៈ ពោល គឺរូបឯណា ត្រាច់ទៅ សរីរៈនោះម្យ៉ាង ជីវៈនោះក៏ម្យ៉ាង តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។

ក្នុងបទថា **អវេទនោ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកភពដែលមានសញ្ញា ។ ឆ្លើយទទួល ព្រោះសំដៅយកឧបបត្តិភពដទៃ ក្រៅអំពីសញ្ញីភពនោះ ។ ពាក្យសួរថា **អញ្ញំ ជីវំ** សេចក្តីថា សកវាទីសួរថា បុគ្គលមិនមានវេទនា មិនមានវិញ្ញាណ លះសរីរៈ ពោល គឺវេទនាជាដើមឯណា រមែងត្រាច់ទៅ សរីរៈនោះក៏ម្យ៉ាង ជីវៈនោះក៏ម្យ៉ាង តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។

[ ៩០ ] ក្នុងបទថា **រូបំ សន្ធាវតិ** ជាដើម សេចក្តីថា សកវាទីសួរថា ព្រោះអាស្រ័យខន្ធទាំងឡាយ មានរូបជាដើមឯណា រមែងបញ្ញត្តនូវបុគ្គល កាលបុគ្គលនោះត្រាច់ទៅ រូបនោះ ក៏រមែងត្រាច់ទៅតាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធ ព្រោះការត្រាច់ទៅរបស់សត្វនោះឯង ដោយព្រះសូត្រដែលកាន់យកជាលទ្ធិថា ការត្រាច់ទៅនៃសត្វទាំងឡាយ មានអវិជ្ជាជាគ្រឿងរារាំង មានតណ្ហាជាគ្រឿងចង អន្ទោលទៅមក កាលត្រូវសួរទៀត ក៏ពោលទទួលថា រូបអន្ទោលទៅ ដោយការសម្គាល់ថា ព្រោះបុគ្គលវៀរនូវធម៌ទាំង

ឡាយ មានរូបជាដើម រមែងមិនមាន ព្រោះហេតុនោះ កាលបុគ្គលនោះអន្ទោលទៅ រូបនោះ ក៏ត្រូវអន្ទោលទៅ ។ ក្នុងធម៌ទាំងឡាយ មានវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

[ ៩១ ] ក្នុងបទថា **រូបំ ឆ សន្ធាវតិ** ជាដើម មានអធិប្បាយថា ព្រោះតាមលទ្ធិរបស់អ្នក អ្នកពោលថា រូបមិនមែនបុគ្គល បុគ្គលនោះឯងរមែងត្រាច់ទៅ ហេតុនោះ ខ្ញុំសូមសួរអ្នកថា តាមលទ្ធិរបស់អ្នក រូបមិនត្រាច់ទៅឬ បរវាទីឆ្លើយបដិសេធ ដោយការសម្គាល់ថា អ្នកដែលត្រាច់ទៅមិនអាចត្រាច់ទៅដោយរូបដែលជាឧបាទានរបស់បុគ្គលនោះ ។ កាលត្រូវសួរដដែលទៀត ក៏ឆ្លើយទទួល ព្រោះការត្រាច់ទៅរបស់សត្វទាំងឡាយនោះឯង ។ ពាក្យដ៏សេស ក្នុងសេចក្តីនេះ មានអត្ថងាយយល់ហើយ ។

ចំណែកអត្ថនៃគាថាទាំងឡាយ គប្បីជ្រាបដូច្នេះថា ពោលដោយមតិរបស់អ្នកមានអាយុ បុគ្គលអាស្រ័យខន្ធទាំងឡាយ ដូចស្រមោលដើមឈើអាស្រ័យដើមឈើ និងដូចភ្លើងអាស្រ័យកំញម កាលការអន្ទោលទៅនៃខន្ធទាំងឡាយ មានរូបជាដើមមិនមាន កាលខន្ធទាំងឡាយនោះ បែកធ្លាយទៅ បើបុគ្គលនោះរបស់អ្នករមែងបែកធ្លាយសោត កាលបើយ៉ាងនេះ ការឃើញថា ដាច់សូន្យ រមែងកើត ឧច្ឆេទទិដ្ឋិ រមែងប្រាកដដល់អ្នក ។ សួរថា ឧច្ឆេទ-ទិដ្ឋិដូចម្តេច សកវាទីរមែងសម្តែងថា គឺអកុសលទិដ្ឋិ ដែលព្រះសម្ពុទ្ធទ្រង់វៀរដាច់ហើយ តែបរិយាយកាសិតឯណាដែលថា ព្រះសមណគោតម ជាឧច្ឆេទវាទី ដូច្នេះ ពួកយើងទាំងឡាយ រមែងមិនពោលដល់ទិដ្ឋិនោះ ។

ម្យ៉ាងទៀត កាលខន្ធទាំងនោះ បែកធ្លាយទៅ បុគ្គលនោះ រមែងមិនបែកធ្លាយទៅសោត កាលបើយ៉ាងនោះ បុគ្គលក៏ទៀង ។ បុគ្គលនោះ ក៏នឹងដល់នូវភាពស្មើគ្នា ជាមួយព្រះនិព្វានតាមទិដ្ឋិនោះ ។ បទថា **សមសមោ** បានដល់ ស្មើក្រៃលែង ឬស្មើដោយការស្មើ ឬស្មើដោយភាវៈដែលស្មើនោះឯង ដូចព្រះនិព្វានមិនកើត មិនរលត់ យ៉ាងណា បុគ្គលនោះ ក៏មិនរលត់យ៉ាងនោះ ។ បុគ្គលស្មើដោយព្រះនិព្វាននោះ ( តាមលទ្ធិនោះ ) ដោយប្រការដូច្នេះឯង ។ល។

**អដ្ឋកថាគតិអនុយោគ ចប់**

# អភិធម្មបិដក

## ឧទានាបញ្ញត្តានុយោគ

[ ៩២ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូបឬ ។ អើ ។ រូបមិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អើ ។ សូម្បីបុគ្គលក៏មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវេទនា ។បេ។ ព្រោះអាស្រ័យសញ្ញា ។បេ។ ព្រោះអាស្រ័យសង្ខារ ។បេ។ ព្រោះអាស្រ័យវិញ្ញាណឬ ។ អើ ។ វិញ្ញាណមិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អើ ។ សូម្បីបុគ្គលក៏មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូបឬ ។ អើ ។ ការបញ្ញត្តិ

នូវបុគ្គល មានសម្បុរខៀវ ព្រោះអាស្រ័យរូបខៀវឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។ ព្រោះអាស្រ័យរូបលឿង ។បេ។ ព្រោះអាស្រ័យរូបក្រហម ។បេ។ ព្រោះអាស្រ័យរូប-ស ។បេ។ ព្រោះអាស្រ័យរូប ប្រកបដោយការឃើញ ។បេ។ ព្រោះអាស្រ័យរូប មិនប្រកបដោយការឃើញ ។បេ។ ព្រោះអាស្រ័យរូប ប្រកបដោយការប៉ះពាល់ ។បេ។ ការបញ្ញត្តិនូវបុគ្គល មិនប្រកបដោយការប៉ះពាល់ ព្រោះអាស្រ័យរូប មិនប្រកបដោយការប៉ះពាល់ឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៩៤ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវេទនាឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ដែលមានកុសល ព្រោះអាស្រ័យវេទនា ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល មានកុសល ព្រោះអាស្រ័យវេទនា ជាកុសលឬ ។ អើ ។ វេទនាជាកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលគួរប្រាថ្នា មានផលគួរត្រេកអរ មានផលគួរពេញចិត្ត មានផលមិនប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយសេចក្ដីសុខ មានសុខជាវិបាកឬ ។ អើ ។ សូម្បីបុគ្គល មានកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលគួរប្រាថ្នា មានផលគួរត្រេកអរ មានផលគួរពេញចិត្ត មានផលមិនប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយសេចក្ដីសុខ មានសុខជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៩៥ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវេទនាឬ ។ អើ ។ ការ

បញ្ញត្តិនូវបុគ្គល ជាអកុសល ព្រោះអាស្រ័យវេទនា ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ជាអកុសល ព្រោះអាស្រ័យវេទនា ជាអកុសលឬ ។ អើ ។ វេទនាជាអកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលមិនគួរប្រាថ្នា មានផលមិនគួរត្រេកអរ មានផលមិនគួរពេញចិត្ត មានផលប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយទុក្ខ មានទុក្ខជាវិបាកឬ ។ អើ ។ សូម្បីបុគ្គលជាអកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលមិនគួរប្រាថ្នា មានផលមិនគួរត្រេកអរ មានផលមិនគួរពេញចិត្ត មានផលប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយទុក្ខ មានទុក្ខជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៦ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវេទនាឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ជាអព្យាក្រឹត ព្រោះអាស្រ័យវេទនា ជាអព្យាក្រឹតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ជាអព្យាក្រឹត ព្រោះអាស្រ័យវេទនា ជាអព្យាក្រឹតឬ ។ អើ ។ វេទនាជាអព្យាក្រឹត មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អើ ។ សូម្បីបុគ្គល ជាអព្យាក្រឹត មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យសញ្ញា ។បេ។ ព្រោះអាស្រ័យសង្ខារ ។បេ។ ព្រោះអាស្រ័យវិញ្ញាណឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ជាកុសល ព្រោះអាស្រ័យវិញ្ញាណ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ជាកុសល ព្រោះអាស្រ័យវិញ្ញាណ ជាកុសលឬ ។ អើ ។ វិញ្ញាណជាកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលគួរប្រាថ្នា មានផលគួរត្រេកអរ មានផលគួរពេញចិត្ត មានផលមិនប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយសេចក្ដីសុខ មានសុខជាវិបាកឬ ។ អើ ។ សូម្បីបុគ្គលជាកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលគួរប្រាថ្នា មានផលគួរត្រេកអរ មានផលគួរពេញចិត្ត មានផលមិនប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយសុខ មានសុខជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៧ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវិញ្ញាណឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ជាអកុសល ព្រោះអាស្រ័យវិញ្ញាណ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ជាអកុសល ព្រោះអាស្រ័យវិញ្ញាណ ជាអកុសលឬ ។ អើ ។ វិញ្ញាណជាអកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលមិនគួរប្រាថ្នា មានផលមិនគួរត្រេកអរ មានផលមិនគួរពេញចិត្ត មានផលប្រឡូកប្រឡំ ( ដោយតណ្ហា និងឧបាទាន ) ចម្រើនដោយទុក្ខ មានទុក្ខជាវិបាកឬ ។ អើ ។ សូម្បីបុគ្គល ជាអកុសល ប្រកបដោយផល ប្រកបដោយវិបាក មានផលមិនគួរប្រាថ្នា មានផលមិនគួរ

ត្រេកអរ មានផលមិនគួរពេញចិត្ត មានផលប្រឡូកប្រឡំ ( ដោយតណ្ហា និង ឧបាទាន ) ចម្រើនដោយទុក្ខ មានទុក្ខជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៩៨ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យវិញ្ញាណឬ ។ អើ ។ ការ បញ្ញត្តិនូវបុគ្គល ជាអព្យាក្រឹត ព្រោះអាស្រ័យវិញ្ញាណជាអព្យាក្រឹតឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ជាអព្យាក្រឹត ព្រោះ អាស្រ័យវិញ្ញាណជាអព្យាក្រឹតឬ ។ អើ ។ វិញ្ញាណជាអព្យាក្រឹត មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អើ ។ សូម្បីបុគ្គល ជាអព្យាក្រឹត មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៩ ] បុគ្គលអាស្រ័យចក្ខុ គេត្រូវហៅថា បុគ្គលមានចក្ខុឬ ។ អើ ។ កាលបើចក្ខុរលត់ហើយ គេត្រូវហៅថា បុគ្គលមានចក្ខុរលត់ហើយឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល អាស្រ័យត្រចៀក ។បេ។ អាស្រ័យ ច្រមុះ ។បេ។ អាស្រ័យអណ្តាត ។បេ។ អាស្រ័យកាយ ។បេ។ បុគ្គលអាស្រ័យ ចិត្ត គេត្រូវហៅថា បុគ្គលមានចិត្តឬ ។ អើ ។ កាលបើចិត្តរលត់ហើយ គេ ត្រូវហៅថា បុគ្គលមានចិត្តរលត់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០០ ] បុគ្គលអាស្រ័យនូវមិច្ឆាទិដ្ឋិ គេត្រូវហៅថា បុគ្គលមានមិច្ឆាទិដ្ឋិ ឬ ។ អើ ។ កាលបើមិច្ឆាទិដ្ឋិរលត់ហើយ គេត្រូវហៅថា បុគ្គលមានមិច្ឆាទិដ្ឋិរលត់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០១ ] បុគ្គលអាស្រ័យមិច្ឆាសង្កប្ប ។បេ។ អាស្រ័យមិច្ឆាវាចា ។បេ។ អាស្រ័យមិច្ឆាកម្មន្តៈ ។បេ។ អាស្រ័យមិច្ឆាអាជីវៈ ។បេ។ អាស្រ័យមិច្ឆាវាយាមៈ ។បេ។ អាស្រ័យមិច្ឆាសតិ ។បេ។ អាស្រ័យមិច្ឆាសមាធិ គេត្រូវហៅថា បុគ្គលមានមិច្ឆាសមាធិឬ ។ អើ ។ កាលបើមិច្ឆាសមាធិរលត់ហើយ គេត្រូវហៅថា បុគ្គលមានមិច្ឆាសមាធិរលត់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០២ ] បុគ្គលអាស្រ័យសម្មាទិដ្ឋិ គេត្រូវហៅថា បុគ្គលមានសម្មាទិដ្ឋិ ឬ ។ អើ ។ កាលបើសម្មាទិដ្ឋិរលត់ហើយ គេត្រូវហៅថា បុគ្គលមានសម្មាទិដ្ឋិរលត់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអាស្រ័យសម្មាសង្កប្ប ។បេ។ អាស្រ័យសម្មាវាចា ។បេ។ អាស្រ័យសម្មាកម្មន្តៈ ។បេ។ អាស្រ័យសម្មាអាជីវៈ ។បេ។ អាស្រ័យសម្មាវាយាមៈ ។បេ។ អាស្រ័យសម្មាសតិ ។បេ។ អាស្រ័យសម្មាសមាធិ គេត្រូវហៅថា បុគ្គលមានសម្មាសមាធិឬ ។ អើ ។ កាលបើសម្មាសមាធិរលត់ហើយ គេត្រូវហៅថា បុគ្គលមានសម្មាសមាធិរលត់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៣ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប ព្រោះអាស្រ័យវេទនា ឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ២ នាក់ ព្រោះអាស្រ័យខន្ធ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប ព្រោះ

អាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារ ព្រោះអាស្រ័យវិញ្ញាណឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ៥ នាក់ ព្រោះអាស្រ័យខន្ធ ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៤ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខាយតនៈ ព្រោះអាស្រ័យសោតាយតនៈឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ២ នាក់ ព្រោះអាស្រ័យអាយតនៈ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៥ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខាយតនៈ ព្រោះអាស្រ័យសោតាយតនៈ ។បេ។ ព្រោះអាស្រ័យធម្មាយតនៈឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ១២ នាក់ ព្រោះអាស្រ័យអាយតនៈ ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៦ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខុធាតុ ព្រោះអាស្រ័យសោតធាតុឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ២ នាក់ ព្រោះអាស្រ័យធាតុ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៧ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខុធាតុ ព្រោះអាស្រ័យសោតធាតុឬ ។បេ។ ព្រោះអាស្រ័យធម្មធាតុឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ១៨ នាក់ ព្រោះអាស្រ័យធាតុ ១៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៨ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខុន្ទ្រិយ ព្រោះអាស្រ័យសោតិន្ទ្រិយឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ២ នាក់ ព្រោះអាស្រ័យឥន្ទ្រិយ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៩ ] ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យចក្ខុន្ទ្រិយ ព្រោះអាស្រ័យសោតិន្ទ្រិយ ។បេ។ ព្រោះអាស្រ័យអញ្ញាតាវិន្ទ្រិយឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ២២ នាក់ ព្រោះអាស្រ័យឥន្ទ្រិយ ២២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១០ ] ការបញ្ញត្តិនូវបុគ្គលម្នាក់ ព្រោះអាស្រ័យភពមានខន្ធ ១ ឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ៤ នាក់ ព្រោះអាស្រ័យភពមានខន្ធ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១១ ] ការបញ្ញត្តិនូវបុគ្គលម្នាក់ ព្រោះអាស្រ័យភពមានខន្ធ ១ ឬ ។ អើ ។ ការបញ្ញត្តិនូវបុគ្គល ៥ នាក់ ព្រោះអាស្រ័យភពមានខន្ធ ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១២ ] បុគ្គលតែម្នាក់ នៅក្នុងភពមានខន្ធ ១ ឬ ។ អើ ។ បុគ្គល ៤ នាក់ នៅក្នុងភពមានខន្ធ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៣ ] បុគ្គលតែម្នាក់ នៅក្នុងភពមានខន្ធ ១ ឬ ។ អើ ។ បុគ្គល ៥ នាក់ នៅក្នុងភពមានខន្ធ ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៤ ] ការបញ្ញត្តិនូវម្លប់ ព្រោះអាស្រ័យដើមឈើ យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប ក៏យ៉ាងនោះដែរឬ ។ ការបញ្ញត្តិនូវម្លប់ ព្រោះអាស្រ័យដើមឈើ ដើមឈើក្តីមិនទៀង ម្លប់ក្តីក៏មិនទៀង យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប រូបក្តី មិនទៀង បុគ្គលក្តី មិនទៀង យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវម្លប់

ព្រោះអាស្រ័យដើមឈើ ដើមឈើដទៃ មួបដទៃ យ៉ាងណាមិញ ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប រូបដទៃ បុគ្គលដទៃ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវបុគ្គល អ្នកនៅក្នុងស្រុក ព្រោះអាស្រ័យស្រុក យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប ក៏យ៉ាងនោះដែរឬ ។ ការបញ្ញត្តិនូវបុគ្គល អ្នកនៅក្នុងស្រុក ព្រោះអាស្រ័យស្រុក ស្រុកដទៃ បុគ្គលអ្នកនៅក្នុងស្រុកដទៃ យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប រូបដទៃ បុគ្គលដទៃ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការបញ្ញត្តិនូវស្តេច ព្រោះអាស្រ័យដែន យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប ក៏យ៉ាងនោះដែរឬ ។ ការបញ្ញត្តិនូវស្តេច ព្រោះអាស្រ័យដែន ដែនដទៃ ស្តេចដទៃ យ៉ាងណា ការបញ្ញត្តិនូវបុគ្គល ព្រោះអាស្រ័យរូប រូបដទៃ បុគ្គលដទៃ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ប្រវាក់ មិនមាន បុគ្គលជាប់ប្រវាក់ ប្រវាក់នៃបុគ្គលណា បុគ្គលនោះ ឈ្មោះថា ជាប់ប្រវាក់ យ៉ាងណា បុគ្គលមិនមានរូប បុគ្គលមានរូប រូបនៃបុគ្គលណា បុគ្គលនោះ ឈ្មោះថា មានរូប ក៏យ៉ាងនោះដែរឬ ។ ប្រវាក់មិនមាន បុគ្គលជាប់ប្រវាក់ ប្រវាក់នៃបុគ្គលណា បុគ្គលនោះ ឈ្មោះថា ជាប់ប្រវាក់ ប្រវាក់ដទៃ បុគ្គលជាប់ប្រវាក់ដទៃ យ៉ាងណា រូបមិនមាន បុគ្គលមានរូប រូបនៃបុគ្គលណា បុគ្គលនោះ ឈ្មោះថា មានរូប រូបដទៃ បុគ្គលមានរូបដទៃ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៥ ] ការបញ្ញត្តិនូវបុគ្គលរាល់ៗ ចិត្តឬ ។ អើ ។ ចុះបុគ្គលកើត

ចាស់ ស្លាប់ ច្យុត បដិសន្ធិ រលាយ ចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះកាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះឬ ។ អើ ។ ចុះកាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា ក្មេងប្រុស ឬថា ក្មេងស្រី ដូច្នេះដែរឬ ។ អ្នកគួរពោលបាន ។ អ្នកចូរដឹងនូវកំហុស ( របស់អ្នកចុះ ) ប្រសិនបើ កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា ក្មេងប្រុស ឬថា ក្មេងស្រី ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះទេ កាលបើចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ក្មេងប្រុសឬ ឬថា ក្មេងស្រី ពាក្យដូច្នេះនេះ ជាពាក្យខុស មួយទៀត ប្រសិនបើ កាលចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ក្មេងប្រុសឬ ឬថា ក្មេងស្រី ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាលចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា បុគ្គលនោះឬ ឬថា បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះទេ កាលបើចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ក្មេងប្រុស ឬថា ក្មេងស្រី ដូច្នេះដែរ ពាក្យដូច្នេះនេះ ក៏ជាពាក្យខុស ។

[ ១១៦ ] ចុះកាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គល នោះ ឬថា បុគ្គលដទៃឬ ។ អើ ។ ចុះកាលចិត្តទី ២ កើតឡើងហើយ អ្នក មិនគួរពោលថា ស្រី ថាប្រុស ថាគ្រហស្ថ ថាបព្វជិត ថាទេវតា ថាមនុស្ស ដែរឬ ។ អ្នកគួរពោលបាន ។ អ្នកចូរដឹងនូវកំហុស ( របស់អ្នកចុះ ) ប្រសិនបើ កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា ទេវតា ឬថា មនុស្ស ដូច្នេះដែរ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យ នោះថា កាលចិត្តទី ២ កើតឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬ ថា បុគ្គលដទៃ ដូច្នេះទេ កាលបើចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ទេវតា ឬថា មនុស្ស ពាក្យដូច្នេះនេះ ជាពាក្យខុស ម្យ៉ាងទៀត ប្រសិនបើ កាលចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ទេវតា ឬថា មនុស្ស ម្នាល អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាលចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះដែរ បណ្តាពាក្យទាំងពីរ នោះ អ្នកពោលនូវពាក្យណា គួរពោលតែពាក្យនោះថា កាលចិត្តទី ២ កើត ឡើងហើយ អ្នកមិនគួរពោលថា បុគ្គលនោះ ឬថា បុគ្គលដទៃ ដូច្នេះទេ កាល ចិត្តទី ២ កើតឡើងហើយ អ្នកគួរពោលថា ទេវតា ឬថា មនុស្ស ពាក្យដូច្នេះ នេះ ជាពាក្យខុស ។បេ។

[ ១១៧ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបុគ្គលណាឃើញ ឃើញនូវរូបណា ឃើញដោយភ្នែកណា បុគ្គលនោះ ឈ្មោះថា ឃើញ ឃើញនូវរូបនោះ ឃើញដោយភ្នែកនោះឬ ។ អើ ។ ប្រសិនបើ បុគ្គលណាឃើញ ឃើញនូវរូបណា ឃើញដោយភ្នែកណា បុគ្គលនោះ ឈ្មោះថា ឃើញ ឃើញនូវរូបនោះ ឃើញដោយភ្នែកនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ ។

[ ១១៨ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបុគ្គលណាឮ ។បេ។ បុគ្គលណាធុំ ។បេ។ បុគ្គលណាលិទ្ធភក្ស ។បេ។ បុគ្គលណាប៉ះពាល់ ។បេ។ បុគ្គលដឹងច្បាស់ ដឹងច្បាស់នូវធម្មារម្មណ៍ណា ដឹងច្បាស់ដោយមនោវិញ្ញាណណា បុគ្គលនោះ ឈ្មោះថា ដឹងច្បាស់ ដឹងច្បាស់នូវធម្មារម្មណ៍នោះ ដឹងច្បាស់ដោយមនោវិញ្ញាណនោះឬ ។ អើ ។ ប្រសិនបើ បុគ្គលណាដឹងច្បាស់ ដឹងច្បាស់នូវធម្មារម្មណ៍ណា ដឹងច្បាស់ដោយមនោវិញ្ញាណណា បុគ្គលនោះ ឈ្មោះថា ដឹងច្បាស់ ដឹងច្បាស់ នូវធម្មារម្មណ៍នោះ ដឹងច្បាស់ដោយមនោវិញ្ញាណនោះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ ។

[ ១១៩ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបុគ្គលណា មិនឃើញ មិនឃើញនូវរូបណា មិនឃើញដោយភ្នែកណា

បុគ្គលនោះ ឈ្មោះថា មិនឃើញ មិនឃើញនូវរូបនោះ មិនឃើញដោយភ្នែកនោះឬ ។ អើ ។ ប្រសិនបើ បុគ្គលណា មិនឃើញ មិនឃើញនូវរូបណា មិនឃើញដោយភ្នែកណា បុគ្គលនោះ ឈ្មោះថា មិនឃើញ មិនឃើញនូវរូបនោះ មិនឃើញដោយភ្នែកនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១២០ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបុគ្គលណា មិនឮ ។បេ។ បុគ្គលណា មិនធុំ ។បេ។ បុគ្គលណា មិនលិទ្ធភ្លក្ស ។បេ។ បុគ្គលណា មិនប៉ះពាល់ ។បេ។ បុគ្គលណា មិនដឹងច្បាស់ មិនដឹងច្បាស់ នូវធម្មារម្មណ៍ណា មិនដឹងច្បាស់ ដោយមនោវិញ្ញាណណា បុគ្គលនោះ ឈ្មោះថា មិនដឹងច្បាស់ មិនដឹងច្បាស់ នូវធម្មារម្មណ៍នោះ មិនដឹងច្បាស់ដោយមនោវិញ្ញាណនោះឬ ។ អើ ។ ប្រសិនបើ បុគ្គលណា មិនដឹងច្បាស់ មិនដឹងច្បាស់ នូវធម្មារម្មណ៍ណា មិនដឹងច្បាស់ ដោយមនោ-វិញ្ញាណណា បុគ្គលនោះ ឈ្មោះថា មិនដឹងច្បាស់ មិនដឹងច្បាស់នូវ ធម្មា-រម្មណ៍នោះ មិនដឹងច្បាស់ ដោយមនោវិញ្ញាណនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១២១ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា រមែងមើលឃើញនូវពួកសត្វ កាលច្យុត កាលកើត ថោកទាប ថ្លៃថ្លា មាន

សម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ មានតែបុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដូច្នេះដែរ ។ ( សកវាទី ) ធ្វើ ( នូវពាក្យប្ដេជ្ញាឲ្យមាំថា ) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា មើលឃើញពួកសត្វ កាលច្យុត កាលកើត ថោកទាប ថ្លៃថ្លា មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ព្រោះហេតុនោះ ( ទើបសួរថា ) បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ព្រះមានព្រះភាគ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញរូប ទ្រង់ឃើញបុគ្គលឬ ។ ទ្រង់ឃើញរូប ។ បុគ្គល គឺរូប រូបច្យុត រូបកើត រូបអន្ទោលទៅតាមយថាកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញរូប ទ្រង់ឃើញបុគ្គលឬ ។ ទ្រង់ឃើញបុគ្គល ។ រូប គឺបុគ្គល ជារូបាយតនៈ ជារូបធាតុ ជារូបខៀវ រូបលឿង រូបក្រហម រូបស រូបដែលគប្បីដឹងដោយចក្ខុ រមែងប៉ះមកក្នុងចក្ខុ មកកាន់រន្ធចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញរូប ទ្រង់ឃើញបុគ្គលឬ ។ ទ្រង់ឃើញរបស់ទាំងពីរ ។ រូប គឺរបស់ទាំងពីរ ជារូបាយតនៈ ជារូបធាតុ របស់ទាំងពីរ

មានពណ៌ខៀវ របស់ទាំងពីរ មានពណ៌លឿង របស់ទាំងពីរ មានពណ៌ក្រហម របស់ទាំងពីរ មានពណ៌ស របស់ទាំងពីរ ដែលគួរដឹងដោយចក្ខុ របស់ទាំងពីរ ប៉ះមកក្នុងចក្ខុ របស់ទាំងពីរ មកកាន់វង្វង់ចក្ខុ របស់ទាំងពីរ ច្យុត របស់ទាំងពីរ កើត របស់ទាំងពីរ អន្ទោលទៅតាមយថាកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ឧបាទាបញ្ញត្តានុយោគ ចប់

# អដ្ឋកថា

## ឧបាទាបញ្ញត្តានុយោគ

[ ៩២ ] ឥឡូវនេះ ជាការសួរដល់ឧបាទាបញ្ញត្តិ គឺបញ្ញត្តិដែលអាស្រ័យវត្ថុនោះៗ ។ ក្នុងរឿងនោះ ពាក្យសួរជាពាក្យរបស់សកវាទី ពាក្យឆ្លើយទទួល និងពាក្យឆ្លើយបដិសេធ ជាពាក្យរបស់បរវាទី ។ ពិតហើយព្រោះអាស្រ័យចក្ខុ និងរូបជាដើម ទើបបញ្ញត្តិបុគ្គល ដូចការបញ្ញត្តិស្រមោលព្រោះអាស្រ័យដើមឈើ ដូចការបញ្ញត្តិភ្លើង ព្រោះអាស្រ័យកំញម ( ឧស ) បរវាទីនោះ ត្រូវប្រកាសឲ្យដឹង ឲ្យយល់ ព្រោះហេតុនោះ កាលត្រូវសកវាទីសួរថា **រូបំ ឧបាទាយ** ទើបបរវាទីឆ្លើយទទួល ។ កាលត្រូវសួរសេចក្តីនេះតទៅទៀតថា ប្រៀបដូចស្រមោល អាស្រ័យដើមឈើ មានសភាពមិនទៀងជាដើម ដូចដើមឈើ និងភ្លើង ដែលអាស្រ័យកំញម មានសភាពមិនទៀងជាដើម ដូចកំញមនៃភ្លើង យ៉ាងណា បុគ្គលអ្នកអាស្រ័យរូបជាដើម មានសភាពមិនទៀង ដូចរូបជាដើម ក៏យ៉ាងនោះឬ ដូច្នេះ បរវាទីតាំងនៅក្នុងលទ្ធិរបស់ខ្លួន ទើបឆ្លើយបដិសេធ ។

[ ៩៣ ] ក្នុងបទទាំងឡាយ មានបទថា **នីលំ រូបំ ឧបាទាយ នីលោ** ជាដើម បរវាទីកាលមិនប្រាថ្នានូវភាពដែលបុគ្គលដូចគ្នានឹងរូបខៀវផង នូវភាវៈច្រើនយ៉ាងនៃបុគ្គល ដោយអំណាចនៃភាវៈច្រើនយ៉ាង មានពណ៌ខៀវជាដើម ក្នុងសរីរៈមួយផង ទើបឆ្លើយបដិសេធ ។

[ ៩៤ ] ក្នុងពាក្យសួរនេះថា **កុសលំ វេទនំ** បរវាទីកាលមិនប្រាថ្នានូវភាពដែលបុគ្គល និងវេទនាដូចគ្នាតែមួយ និងនូវភាវៈច្រើនយ៉ាងនៃបុគ្គល

ដោយអំណាចនៃកុសលវេទនា ជាច្រើនក្នុងសន្តានមួយ ទើបឆ្លើយបដិសេធ ។ ក្នុងន័យទី ២ បរវាទីឆ្លើយទទួល សំដៅយកបុគ្គលដែលតាំងនៅក្នុងការឈ្លាសវៃ ដោយពាក្យថា ជាអ្នកឈ្លាសក្នុងផ្លូវជាដើម ។ ត្រូវសួរថា **សជលោ** ជាដើម ក៏ឆ្លើយបដិសេធ ព្រោះមិនមានវោហារបែបនោះ ។

[ ៩៥ ] ក្នុងចំណែកអកុសល បរវាទីឆ្លើយទទួល សំដៅយកបុគ្គលដែលតាំងនៅក្នុងភាពមិនឈ្លាស ។

[ ៩៦ ] ក្នុងចំណែកអព្យាកត បរវាទីក៏ឆ្លើយទទួល សំដៅយកការៈនៃអព្យាកត ដោយអំណាចនៃការទៀនជាដើម ។ ពាក្យដ៏សេស ក្នុងទីនេះគប្បីជ្រាបដោយន័យរបស់ពាក្យដែលពោលហើយខាងដើមនោះឯង ។

[ ៩៩ ] ក្នុងពាក្យសួរទាំងឡាយថា **ចក្ខុំ ឧចានាយ** ជាដើម បរវាទីរមែងឆ្លើយទទួល ព្រោះមានវោហារថា បណ្ឌិតគប្បីវៀរស្រឡះ កម្មដ៏លាមក ... ដូចបុរសមានចក្ខុ វៀរស្រឡះទីមិនស្មើ ដូច្នេះជាដើម ការមិនកាន់យក ការរលត់របស់បុគ្គល ព្រោះការរលត់នៃចក្ខុជាដើម ទើបបដិសេធ ។

[ ១០៣-១១៣ ] ក្នុងពាក្យសួរនេះថា **រូបំ ឧចានាយ វេទនំ ឧចានាយ** បណ្ឌិតគប្បីជ្រាបធម៌ដទៃ ដែលជាពួក ២ ពួក ៣ និងពួក ៤ ដែលមានរូបជាមូល ព្រោះមានការបញ្ញត្តិបុគ្គលអាស្រ័យខន្ធទាំងឡាយ ហេតុនោះ ទើបបរវាទីឆ្លើយទទួលនូវបញ្ញត្តិ ព្រោះអាស្រ័យខន្ធ ២ ខ្លះ ខន្ធ ៣ ខ្លះ ខន្ធ ៤ ខ្លះ ខន្ធ ៥ ខ្លះ តែរមែងឆ្លើយបដិសេធ ព្រោះការមិនមានបុគ្គល ២ ឬបុគ្គល ៥ ក្នុងសន្តានមួយ សូម្បីក្នុងអាយតនៈជាដើម ក៏មានន័យនេះដូចគ្នា ។

[ ១១៤ ] ឥឡូវនេះ ដើម្បីសម្តែងថា ការបញ្ញត្តិបុគ្គលណា ព្រោះអាស្រ័យខន្ធណា រមែងមានការបញ្ញត្តិ សូម្បីបុគ្គលនោះ ដូចការមិនទៀងនៃបុគ្គលនោះ ក៏ព្រោះការមិនទៀងនៃខន្ធនោះ និងដូចភាពដែលបុគ្គលដទៃជំអំពីខន្ធនោះក៏មានឬ ដូច្នេះ ទើបពោលថា **យថា រុក្ខំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧបាទាយ** បានដល់ អាស្រ័យ គឺមកដល់ អធិប្បាយថា មិនវៀរវត្ថុនោះ ។ បរវាទីកាលមិនប្រាថ្នាបែបនោះ តាំងមាំនៅក្នុងលទ្ធិរបស់ខ្លួន ទើបឆ្លើយបដិសេធ ។

បទថា **ឆិគល្លោ** បានដល់ ចំណង គឺប្រវាក់ ។ បទថា **ឆេគឡិកោ** បានដល់ បុគ្គលដែលត្រូវចងដោយចំណងនោះ ។ បទថា **យស្ស រូបំ សោ រូបវា** អធិប្បាយថា ព្រោះហេតុដែលរូប មានដល់បុគ្គលណា បុគ្គលនោះទេតើ ឈ្មោះថា ជាអ្នកមានរូប ព្រោះហេតុនោះ ដូចប្រវាក់ មិនមែនបុគ្គលត្រូវចងរូបដទៃ បុគ្គលមានរូបក៏ដទៃ ព្រោះហេតុនោះៗ ឯង ។

[ ១១៥-១១៦ ] ក្នុងពាក្យសួរថា **ចិត្តេ ចិត្តេ** ជាដើម បរវាទីសំដៅយកភាពដែលបុគ្គលមានរាគៈជាដើម ដោយអំណាចនៃចិត្តមានរាគៈជាដើម ទើបឆ្លើយទទួល ដោយអំណាចចិត្តានុបស្សនា ។ បរវាទី ត្រូវសកវាទីសួរដោយន័យថា **ជាយតិ** ជាដើម កាលមិនប្រាថ្នានូវភាពដែលបុគ្គល ជាខណៈ ( ដូចចិត្ត ) ទើបបដិសេធ ។ ត្រូវសកវាទីសួរថា **សោតិ វា អញ្ញោតិ វា** ព្រោះខ្លាចត្រូវតិះដៀលថាជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ទើបបដិសេធ ។ ត្រូវសកវាទីសួរទៀតថា **ន វត្តព្វំ កុមារិកោតិ វា កុមារិកាតិ វា** ព្រោះ

ខ្លាចអំពីការត្រូវកាត់ផ្តាច់អំពីលោកវោហារ ទើបទទួលថា **វត្តព្វំ** ។ ពាក្យដ៏សេស ក្នុងទីនេះ ប្រាកដច្បាស់ហើយនោះឯង ។

[ ១១៧-១១៨ ] ឥឡូវនេះ បរវាទី ជាបុគ្គលប្រាថ្នាដើម្បីតាំងលទ្ធិរបស់ខ្លួនដោយអាការដទៃ ទើបពោលពាក្យថា **ន វត្តព្វំ បុគ្គលោ ឧបលព្ភតិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **នវត្តព្វំ** អធិប្បាយថា ប្រយោជន៍អ្វីដល់អ្នកដោយការសួរដល់ឧបាទាបញ្ញត្តិច្រើនយ៉ាងនេះ ចូរអ្នកពោលពាក្យនេះមុនថា មិនគប្បីពោលថា ខ្ញុំស្ទង់ដឹងបុគ្គល បានដោយសច្ចិកដ្ឋបរមត្ថឬ ។ បន្ទាប់អំពីនោះ កាលសកវាទីឆ្លើយទទួលហើយថា **អមន្តា** ទើបបរវាទីពោលថា **ននុ យោ បស្សតិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យោ** បានដល់ បុគ្គលណា ។ បទថា **យំ** បានដល់ រូប ។ បទថា **យេន** បានដល់ ដោយចក្ខុ ។ បទថា **សោ** បានដល់ បុគ្គល ។ បទថា **តំ** បានដល់ រូប ។ បទថា **តេន** បានដល់ ដោយចក្ខុ លោកអធិប្បាយថា បុគ្គលណា ឃើញរូបណា ឃើញដោយចក្ខុណា បុគ្គលនោះ ឃើញរូបនោះ ដោយចក្ខុនោះ មិនមែនឬ ចក្ខុដែលដល់នូវភាពជានិស្សយប្បច្ច័យដល់ចក្ខុវិញ្ញាណនោះឯង រមែងឃើញនូវរូបដូចគ្នាសោតនោះឯង រមែងបានឮសំឡេង ។បេ។ មនោវិញ្ញាណនោះឯង រមែងដឹងច្បាស់នូវធម៌ក៏ពិត តែសកវាទីក៏ឆ្លើយទទួលថា **អាមន្តា** ដោយអំណាចនៃពាក្យសន្មត ដោយពាក្យថា ចក្ខុរបស់ព្រះអរហន្តមាន ព្រះអរហន្តរមែងឃើញរូបនោះ ដោយចក្ខុ ដូច្នេះជាដើម ។

[ ១១៩-១២០ ] លំដាប់នោះ បរវាទី អាស្រ័យវាទៈដែលមានលេស ធ្វើភាពដែលគប្បីពោលថា ជាបុគ្គលឲ្យសម្រេចហើយ ទើបសកវាទីប្តូរវាទៈនោះឯង ហើយពោលពាក្យថា **បុគ្គលោ ឧបលព្ភតិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **យោ ច បស្សតិ** អធិប្បាយថា អសញ្ញីសត្វដទៃ ដែលខ្វាក់និងដែលមិនខ្វាក់ ចូលដល់អរូបភព ចូលនិរោធសមាបត្តិហើយ វៀរចាកសម័យជាទីឃើញ ឈ្មោះថា រមែងមិនឃើញ ។ ក្នុងវារៈទាំងឡាយដ៏សេសក៏ន័យនេះឯង ។ ពោលដោយអត្ថ បណ្ឌិតគប្បីជ្រាបពាក្យដ៏សេស ដោយអំណាចនៃព្រះបាលី ។

[ ១២១ ] ក្នុងការប្រៀបធៀបព្រះសូត្រ បរវាទីពោលថា **រូបំ បស្សតិ** ព្រោះរូបជាអារម្មណ៍ដល់ទិព្វចក្ខុ ។ ក្នុងវារៈទី ២ បរវាទីពោលថា **បុគ្គលំ បស្សតិ** ព្រោះព្រះបាលីថា តថាគតរមែងឃើញសត្វទាំងឡាយ ដូច្នេះ ។ ក្នុងវារៈទី ៣ បរវាទីពោលថា **ឧភយំ បស្សតិ** ព្រោះលទ្ធិថា ព្រះមានព្រះភាគទ្រង់ឃើញរូបហើយ ទើបដឹងច្បាស់នូវបុគ្គល ។ ព្រោះរូបាយតនៈនោះឯងលោករួបរួមក្នុងរូបសង្គហៈ ៤ ថា **ទិដ្ឋំ ១ សុតំ ១ មុតំ ១ វិញ្ញាតំ ១** ឈ្មោះថា ជាធម៌គប្បីឃើញ ព្រោះហេតុនោះ ទើបសកវាទីសួរថា **រូបំ បុគ្គលោ បុគ្គលោ រូបំ ឧភោ រូបំ** ជាដើម ។ អត្ថរបស់ពាក្យនោះ ប្រាកដជាក់ច្បាស់ហើយនោះឯង ។៚

**អដ្ឋកថាឧទាហរណបញ្ញត្តានុយោគ ចប់**

# អភិធម្មបិដក

## កល្យាណវគ្គ

[ ១២២ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៣ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈ មិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៤ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលគេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវបុគ្គល គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៥ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួន

ឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវព្រះនិព្វាន គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៦ ] កម្មល្អ និងអាក្រក់ គួរដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវមហាប្រឹថពី គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៧ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ មហាសមុទ្រ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវមហាសមុទ្រ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៨ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ស្តេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវស្តេចភ្នំ ឈ្មោះសិនេរុ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២៩ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ទឹក គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវទឹក គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣០ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ភ្លើង គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវភ្លើង គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣១ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ខ្យល់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើនូវខ្យល់ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣២ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៣ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ កម្មល្អ និងអាក្រក់ដទៃ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ នូវកម្មល្អ និងអាក្រក់ដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៤ ] វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។ វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នករងកម្មនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នករងកម្មនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈ មិនមាន អនុបាទាបរិនិព្វានមិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលគេដឹងបានឬ ។ បុគ្គលអ្នករងនូវបុគ្គលគេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកទទួលនូវព្រះនិព្វានគេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នករងវិបាក នៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។ មហាសមុទ្រ គេដឹងបានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ ។ ទឹក គេដឹងបានឬ ។ ភ្លើង គេដឹងបានឬ ។ ខ្យល់ គេដឹងបានឬ ។បេ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ បុគ្គលអ្នករងនូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ វិបាកនៃកម្មល្អ និងអាក្រក់ដទៃ បុគ្គលអ្នករងវិបាកនៃកម្មល្អ និងអាក្រក់ដទៃឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។

[ ១៣៥ ] សុខជាទិព្វ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៦ ] សុខជាទិព្វ គេដឹងបានឬ ។ បុគ្គលអ្នករងសុខជាទិព្វ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកទទួលសុខនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកទទួលសុខនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្ដៈ មិនមាន អនុបាទាបរិ-និព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៧ ] សុខជាទិព្វ គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ ។ អើ ។ បុគ្គល គេដឹងបានឬ ។ បុគ្គលអ្នករងនូវបុគ្គល គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៨ ] សុខជាទិព្វ គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកទទួលនូវព្រះនិព្វាន គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៩ ] សុខជាទិព្វ គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។បេ។ មហាសមុទ្រ គេដឹងបានឬ ។ ស្ដេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ ។បេ។ ទឹក គេដឹងបានឬ ។ ភ្លើង គេដឹងបានឬ ។ ខ្យល់ គេដឹងបានឬ ។បេ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។បេ។ បុគ្គលអ្នករងនូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤០ ] សុខជាទិព្វ គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ ។ អើ ។ សុខជាទិព្វដទៃ បុគ្គលទទួលសុខជាទិព្វដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤១ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤២ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកទទួលសុខនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកទទួលសុខនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈមិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៣ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ បុគ្គល គេដឹងបានឬ ។ បុគ្គលអ្នករងនូវបុគ្គល គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៤ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកទទួលព្រះនិព្វាន គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៥ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។បេ។

មហាសមុទ្ទ គេដឹងបានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ ។ ទឹក គេដឹងបានឬ ។ ភ្លើង គេដឹងបានឬ ។ ខ្យល់ គេដឹងបានឬ ។បេ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ បុគ្គលអ្នករងនូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៦ ] សុខជារបស់មនុស្ស គេដឹងបានឬ ។ បុគ្គលអ្នកទទួលសុខជារបស់មនុស្ស គេដឹងបានឬ ។ អើ ។ សុខជារបស់មនុស្សដទៃ បុគ្គលអ្នកទទួលសុខជារបស់មនុស្សដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៧ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នករងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៨ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ បុគ្គលអ្នករងទុក្ខនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នករងទុក្ខនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៩ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ បុគ្គល គេដឹងបានឬ ។ បុគ្គលអ្នករងនូវបុគ្គល គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥០ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកទទួលនូវព្រះ

និព្វាន គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥១ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ បុគ្គលអ្នកវេងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។បេ។ មហាសមុទ្ទ គេដឹងបានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ។ ទឹក គេដឹងបានឬ ។ ភ្លើង គេដឹងបានឬ ។ ខ្យល់ គេដឹងបានឬ ។បេ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ បុគ្គលអ្នកវេងនូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥២ ] ទុក្ខក្នុងអបាយ គេដឹងបានឬ ។ បុគ្គលអ្នកវេងទុក្ខក្នុងអបាយ គេដឹងបានឬ ។ អើ ។ ទុក្ខក្នុងអបាយដទៃ បុគ្គលអ្នកវេងទុក្ខ ក្នុងអបាយដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៣ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកវេងទុក្ខ ក្នុងនរក គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៤ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ បុគ្គលអ្នកវេងទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ បុគ្គលអ្នកវេងទុក្ខនោះ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកវេងទុក្ខនោះ គេដឹងបានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈ មិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៥ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ បុគ្គលអ្នកវេងទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ បុគ្គល គេដឹងបានឬ ។ បុគ្គលអ្នកវេងនូវបុគ្គល គេ

ដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៦ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ ព្រះនិព្វាន គេដឹងបានឬ ។ បុគ្គលអ្នកទទួលព្រះនិព្វាន គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៧ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ មហាប្រឹថពី គេដឹងបានឬ ។បេ។ មហាសមុទ្រ គេដឹងបានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ គេដឹងបានឬ ។ ទឹក គេដឹងបានឬ ។ ភ្លើង គេដឹងបានឬ ។ ខ្យល់ គេដឹងបានឬ ។ ស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ បុគ្គលអ្នករងនូវស្មៅ ឈើតូច និងឈើធំ គេដឹងបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៨ ] ទុក្ខក្នុងនរក គេដឹងបានឬ ។ បុគ្គលអ្នករងទុក្ខក្នុងនរក គេដឹងបានឬ ។ អើ ។ ទុក្ខក្នុងនរកដទៃ បុគ្គលអ្នករងទុក្ខ ក្នុងនរកដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៩ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ អ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលនោះធ្វើ បុគ្គលនោះទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះធ្វើ បុគ្គលនោះទទួលឬ ។ អើ ។ សុខ និងទុក្ខ គេធ្វើដោយខ្លួនឯងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦០ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួន

ឯង អ្នកប្រើគេឲ្យធ្វើ អ្នកទទួលវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដទៃធ្វើ បុគ្គលដទៃទទួលឬ ។ អើ ។ សុខ និងទុក្ខ បុគ្គលដទៃធ្វើឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦១ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ អ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលនោះផង បុគ្គលដទៃផងធ្វើ បុគ្គលនោះផង បុគ្គលដទៃផង ទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះផង បុគ្គលដទៃផងធ្វើ បុគ្គលនោះផង បុគ្គលដទៃផង ទទួលឬ ។ អើ ។ សុខ និងទុក្ខដែលគេធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦២ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួនឯង អ្នកប្រើគេឲ្យធ្វើ អ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលនោះមិនមែនធ្វើ បុគ្គលនោះមិនមែនទទួល បុគ្គលដទៃមិនមែនធ្វើ បុគ្គលដទៃមិនមែនទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះមិនមែនធ្វើ បុគ្គលនោះមិនមែនទទួល បុគ្គលដទៃ ក៏មិនមែនធ្វើ បុគ្គលដទៃ ក៏មិនមែនទទួលឬ ។ អើ ។ សុខ និងទុក្ខ កើតឡើង ព្រោះអាស្រ័យហេតុមិនមែន ធ្វើដោយខ្លួនឯង មិនមែន បុគ្គលដទៃធ្វើឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៣ ] កម្មល្អ និងអាក្រក់ គេដឹងបានឬ ។ បុគ្គលអ្នកធ្វើដោយខ្លួន

ឯង អ្នកប្រើគេឲ្យធ្វើ អ្នករងវិបាកនៃកម្មល្អ និងអាក្រក់ គេដឹងបានឬ ។ អើ ។ បុគ្គលនោះធ្វើ បុគ្គលនោះទទួល បុគ្គលដទៃធ្វើ បុគ្គលដទៃទទួល បុគ្គលនោះផង បុគ្គលដទៃផងធ្វើ បុគ្គលនោះផង បុគ្គលដទៃផង ទទួល បុគ្គលនោះមិនមែនធ្វើ បុគ្គលនោះមិនមែនទទួល បុគ្គលដទៃមិនមែនធ្វើ បុគ្គលដទៃមិនមែនទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលនោះធ្វើ បុគ្គលនោះទទួល បុគ្គលដទៃធ្វើ បុគ្គលដទៃទទួល បុគ្គលនោះផង បុគ្គលដទៃផងធ្វើ បុគ្គលនោះផង បុគ្គលដទៃផងទទួល បុគ្គលនោះមិនមែនធ្វើ បុគ្គលនោះមិនមែនទទួល បុគ្គលដទៃក៏មិនមែនធ្វើ បុគ្គលដទៃក៏មិនមែនទទួលឬ ។ អើ ។ សុខ និងទុក្ខ គេធ្វើដោយខ្លួនឯង សុខ និងទុក្ខ បុគ្គលដទៃធ្វើ សុខ និងទុក្ខ គេធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើផង សុខ និងទុក្ខ កើតឡើង ព្រោះអាស្រ័យហេតុ មិនមែនគេធ្វើដោយខ្លួនឯង មិនមែនបុគ្គលដទៃធ្វើឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៤ ] កម្ម មានឬ ។ អើ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម មានឬ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អើ ។ បុគ្គលអ្នកធ្វើកម្មនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកធ្វើកម្មនោះ មានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម មានឬ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អើ ។ បុគ្គលមានឬ ។ បុគ្គលអ្នកធ្វើបុគ្គល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម

មានឬ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អើ ។ ព្រះនិព្វាន មានឬ ។ បុគ្គលអ្នកធ្វើព្រះនិព្វាន មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម មានឬ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អើ ។ មហាប្រឹថពី មានឬ ។បេ។ មហាសមុទ្ទ មានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ មានឬ ។ ទឹក មានឬ ។ ភ្លើង មានឬ ។ ខ្យល់ មានឬ ។ ស្មៅ ឈើតូច និងឈើធំ មានឬ ។ បុគ្គលអ្នកធ្វើនូវស្មៅឈើតូច និងឈើធំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្ម មានឬ ។ បុគ្គលអ្នកធ្វើកម្ម មានឬ ។ អើ ។ កម្មដទៃ បុគ្គលអ្នកធ្វើកម្មដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។ អើ ។ បុគ្គលអ្នករងវិបាក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។ បុគ្គលអ្នករងវិបាក មានឬ ។ អើ ។ បុគ្គលអ្នករងវិបាកនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នករងវិបាកនោះ មានឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។ បុគ្គលអ្នករងវិបាក មានឬ ។ អើ ។ បុគ្គល មានឬ ។ បុគ្គលអ្នករងនូវបុគ្គល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។ បុគ្គលអ្នករងវិបាកមានឬ ។ អើ ។ ព្រះនិព្វាន មានឬ ។ បុគ្គលអ្នករងព្រះនិព្វាន មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។ បុគ្គលអ្នករងវិបាក មានឬ ។ អើ ។ មហាប្រឹថពី មានឬ ។បេ។ មហាសមុទ្ទ មានឬ ។ ស្តេចភ្នំឈ្មោះសិនេរុ មានឬ ។ ទឹក មានឬ ។ ភ្លើង មានឬ ។ ខ្យល់ មានឬ ។

ស្មៅ ឈើតូច និងឈើធំ មានឬ ។ បុគ្គលអ្នករផនូវស្មៅ ឈើតូច និងឈើធំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបាក មានឬ ។បេ។ បុគ្គលអ្នករងវិបាក មានឬ ។ អើ ។ វិបាកជទៃ បុគ្គលអ្នករងវិបាកជទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីបម្រួញ ។

## កល្យាណវគ្គទី ១ ចប់

# អដ្ឋកថា

## បុរិសការានុយោគ

[ ១២២ ] ឥឡូវនេះ ជាការសួរដល់ការធ្វើរបស់បុគ្គល ។ ក្នុងបញ្ហានោះ ពាក្យសួរដោយលទ្ធិថា កាលកម្មមាន បុគ្គលធ្វើកម្មនោះ ក៏ត្រូវមានពិតប្រាកដ ដូច្នេះ ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ព្រោះភាពដែលកម្មទាំងឡាយនោះមាន ជាពាក្យរបស់សកវាទី ។ ពាក្យសួរទៀតថា **កត្តា ការេតា** ជាពាក្យរបស់បរវាទី ។

បណ្ដាបទទាំងនោះ បទថា **កត្តា** បានដល់ អ្នកធ្វើកម្មទាំងឡាយនោះ ។ បទថា **ការេតា** បានដល់ អ្នកប្រើឲ្យធ្វើកម្មដោយឧបាយទាំងឡាយ មានការប្រើ និងការបង្ហាញឲ្យដឹងជាដើម ។ ឥឡូវនេះ បរវាទីសំដៅយកបុគ្គល ទើបសួរដល់អ្នកធ្វើ មិនសួរដល់ត្រឹមតែការធ្វើ ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធ ។

[ ១២៣ ] ក្នុងបទនេះថា **តស្ស កត្តា ការេតា** មានអធិប្បាយថា សកវាទីសួរថា បើអ្នកស្គាល់ដឹងកម្មណាមួយ អ្នកក៏ស្គាល់ដឹងបុគ្គល ដែលធ្វើកម្មនោះៗ បាន អ្នកនោះឯង រមែងស្គាល់ដឹងបុគ្គលបានសោត អ្នកស្គាល់ដឹងបុគ្គលដទៃដែលធ្វើផង ដែលប្រើឲ្យធ្វើផង នូវកម្មនោះឬ ។ បរវាទី កាលមិនប្រាថ្នាបែបនោះ ទើបឆ្លើយបដិសេធ ព្រោះខ្លាចត្រូវតិះដៀលថា ជាលទ្ធិរបស់ព្រះអាទិទេព ។ កាលត្រូវសួរដដែលទៀត បរវាទីក៏ឆ្លើយទទួល ព្រោះសំដៅយកអត្ថនេះថា មាតាបិតារមែងឲ្យបុគ្គលកើត រមែងដាក់ឈ្មោះ រមែងចិញ្ចឹម ព្រោះហេតុនោះ ទើបមាតាបិតាទាំងនោះ ឈ្មោះថា អ្នកធ្វើ ចំណែក

កល្យាណមិត្ត ឬអាចារ្យទាំងឡាយណា រមែងឲ្យសិស្សសិក្សាវិជ្ជា និងរៀនសិប្បៈទាំងឡាយនោះៗ កល្យាណមិត្ត ឬអាចារ្យទាំងនោះ ឈ្មោះថា អ្នកប្រើឲ្យធ្វើ ។ កម្មចាស់ប៉ុណ្ណោះ សកវាទីបំណងថា ជាអ្នកធ្វើ និងអ្នកប្រើឲ្យធ្វើនូវកម្មនោះ ។

ដោយបទនេះថា **តស្ស តស្សេវ** សកវាទីសួរថា បើអ្នកធ្វើនូវអ្នកធ្វើកម្មទាំងឡាយមាន អ្នកធ្វើនូវបុគ្គលនោះតៗ គ្នាមក ក៏មាននោះឯងសោតកាលបើភាពយ៉ាងនោះមាន បុគ្គលមុនៗ ក៏គប្បីធ្វើបុគ្គលក្រោយៗ ដោយពិត ព្រោះហេតុនោះ ដោយពាក្យនេះ បុគ្គលអ្នកធ្វើកម្មទាំងនោះ គប្បីធ្វើបុគ្គលដទៃតទៅ បុគ្គលដទៃនោះ ក៏គប្បីធ្វើបុគ្គលដទៃទៀត ព្រោះហេតុនោះការធ្វើនូវទីបំផុតនៃទុក្ខ រមែងមិនមាន ការកាត់វដ្ដៈ រមែងមិនមាន ការរលត់ដោយជុំវិញ ដែលមិនមានបច្ច័យ រមែងមិនមាន និព្វានណា ព្រោះការមិនមានទុក្ខដទៃ ទាក់ទងដោយបច្ច័យ ដែលអ្នកពោល ដោយការមិនមានបច្ច័យនិព្វាននោះ របស់អ្នកមិនមានឬ ម្យ៉ាងទៀត បទថា **តស្ស តស្សេវ** មានអធិប្បាយថា បើកម្មមិនមែនត្រឹមតែកម្ម តែមានការបន្តគ្នាមកនៃបុគ្គលយ៉ាងនេះថា បុគ្គលដែលធ្វើនូវកម្មនោះ បុគ្គលធ្វើនូវបុគ្គលនោះៗ តៗ គ្នាមកដូច្នេះសោត កាលភាពយ៉ាងនោះមាន ការធ្វើនូវទីបំផុតនៃទុក្ខ ព្រោះធ្វើឲ្យកម្មវដ្ដៈ មិនប្រព្រឹត្តទៅ ដែលពោលនោះ ក៏រមែងមិនមាន ។ បរវាទី កាលមិនប្រាថ្នាពាក្យនោះ ក៏បដិសេធ ។ ក្នុងពាក្យសួរដល់ការកៈ តាមធម្មតាដែលស្ទង់ដឹងបានដទៃអំពីនេះ លោកក៏ពោលថា **កត្តា ការេតា** សំដៅយក

ចំពោះបុគ្គលប៉ុណ្ណោះ មិនបានពោលសំដៅយកបច្ច័យទាំងឡាយឡើយ ។ ពិត ហើយ បច្ច័យនៃវត្ថុទាំងពួង ដូចជាមហាប្រឹថពីជាដើម មិនមានក៏មិនមែន ។

[ ១៣៣ ] បញ្ហាដែលសកវាទីសួរថា **អញ្ញោ កល្យាណាចាបកានំ កម្មានំ កត្តា** ដែលបរវាទីឆ្លើយបដិសេធហើយ ព្រោះខ្លាចត្រូវតិះដៀលជា មិច្ឆាទិដ្ឋិថា ឬឃើញនូវខ្លួនថា មានសង្ខារ ដូច្នេះជាដើម ។

[ ១៣៤ ] បទថា **វិចាកោ ឧបលព្ភតិ** ពោលដើម្បីទម្លាយលទ្ធិរបស់ បុគ្គល ដែលសម្តែងនូវបុគ្គលដោយអំណាចនៃបុគ្គលដែលសោយវិបាក ។

បណ្តាបទទាំងនោះ បទថា **វិចាកបដិសំវេទី** ជាពាក្យសួររបស់ បរវាទី ។ ពាក្យបដិសេធ ព្រោះការមិនមានអ្នកសោយ ដទៃក្រៅអំពីការ ប្រព្រឹត្តទៅនៃវិបាក ជាពាក្យរបស់សកវាទី ។ ពាក្យសួរក្រោយទៀត ជា ពាក្យរបស់សកវាទី ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

បទថា **តស្ស បដិសំវេទី** បានដល់ បុគ្គលសោយនូវបុគ្គលនោះៗ ដែលសោយវិបាក ។ វិបាក ឈ្មោះថា ធម្មជាតដែលបុគ្គលគប្បីសោយ តែ បុគ្គលមិនមែនវិបាក ព្រោះហេតុនោះ ទើបបរវាទីបដិសេធ ។ បរវាទី ត្រូវ សកវាទីសួរដដែលទៀត ព្រោះហេតុដែលបុគ្គល ឈ្មោះថា អ្នកសោយវិបាក ព្រោះការតាំងនៅក្នុងវិបាកនៃបុណ្យ ទោះជាមាតាក៏ឱបក្រសោប ថែទាំបុត្ត ទោះជាកិរិយា ក៏ឱបក្រសោបបដិបត្តិប្តី ហេតុនោះ ទើបឆ្លើយទទួល ដោយ សំដៅយកភាពជាអ្នកសោយបែបនោះ ។

ពាក្យសួរថា **តស្ស តស្សេវ** មានអធិប្បាយថា បើវិបាកមិនបានត្រឹម

តែវិបាក តែមានការបន្តគ្នានៃបុគ្គលយ៉ាងនេះ គឺមានបុគ្គលដែលសោយវិបាកនោះ ហើយមានបុគ្គលសោយបុគ្គលដែលសោយវិបាកនោះតៗ គ្នាទៀត ដូច្នេះសោត កាលបើកាពយ៉ាងនោះមាន ការធ្វើទីបំផុតនៃទុក្ខ ព្រោះធ្វើឲ្យវិបាកវដ្តមិនប្រព្រឹត្តទៅ ដែលពោលនេះ ក៏រមែងមិនមាន ។ បន្ទាប់អំពីនេះទៅ គប្បីជ្រាបអត្ថក្នុងពាក្យសួរដល់អ្នកសោយ ដោយពាក្យសាមញ្ញ ដែលសួង់ដឹងបាន ដោយន័យដូចពោលហើយខាងដើមនោះឯង ។

បញ្ហាដែលសកវាទីសួរថា **អញ្ញោ កលហ្យាណាចាបកាធំ កម្មាធំ វិចាកបដិសំវេទី** បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចត្រូវតិះដៀលថា ជាមិច្ឆាទិដ្ឋិ ឬឃើញនូវខ្ជួនថា មានវេទនាជាដើម ។

[ ១៣៥ ] បទថា **ធិត្តំ សុខំ** ជាដើម ប្រារព្ធដោយអំណាចការបែកនិងសម្តែងវិបាក នៃកម្មល្អ និងកម្មអាក្រក់ ។ ពាក្យទាំងអស់នោះ គប្បីជ្រាបដោយន័យដែលធ្លាប់ពោលហើយនោះឯង ។ ម្យ៉ាងទៀត ក្នុងពាក្យសួររបស់បរវាទីនេះថា បុគ្គលអ្នកទទួលសុខជាទិព្វ គេដឹងបានឬ និងពាក្យបដិសេធបុគ្គល ដែលសោយរបស់សកវាទី គប្បីជ្រាបដោយអំណាចនៃបុគ្គលប៉ុណ្ណោះ មិនមែនដោយអំណាចការសោយ ព្រោះថា លោកមិនបដិសេធការកើតឡើងនៃការសោយទាំងឡាយ ព្រោះធ្វើមហាប្រឹថពីជាដើមឲ្យជាអារម្មណ៍ ។

[ ១៥៩ ] បទថា **កត្តា ការេតា វិចាកប្បដិសំវេទី** ជាដើម ប្រារព្ធន័យដែលលាយឡំគ្នា ។ ក្នុងបទទាំងនោះ បទថា **សោ ករោតិ** បានដល់

អ្នកពោលដល់បុគ្គលណាថា បុគ្គលនោះធ្វើ បុគ្គលនោះទទួលឬ ពាក្យសាកសួរ ជាពាក្យរបស់សកវាទី ពាក្យបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ ជាពាក្យរបស់បរវាទី ។

បរវាទីត្រូវសួរជាដដែលទៀត ក៏ឆ្លើយទទួលដោយអំណាចនៃព្រះសូត្រថា ត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ ដូច្នេះជាដើម ។ លំដាប់នោះ សកវាទី កាលនឹងរារាំងឱកាសនៃពាក្យដែលពោលរបស់បរវាទីនោះ ទើបពោលពាក្យថា **សយំកតំ សុខទុក្ខំ** ដូច្នេះ ។

[ ១៦០ ] ក្នុងបទទាំងនោះ បទថា **អញ្ញោ ករោតិ** សកវាទីពោលដោយអំណាចនៃពាក្យសួរ ដល់ភាពដែលអ្នកធ្វើ និងអ្នកសោយ ម្នាក់មួយបែប ។ បន្ទាប់អំពីនោះ ទើបបរវាទីបដិសេធឱកាសនៃពាក្យដែលពោល ព្រោះខ្លាចខុសអំពីព្រះសូត្រ ។ ត្រូវសួរជាដដែលទៀត កាលមានសេចក្តីសម្គាល់ថា បុគ្គលដែលកើតជាមនុស្សធ្វើហើយ កើតជាទេវតា ទើបសោយ ទើបឆ្លើយទទួល តែសុខ និងទុក្ខ ដែលបុគ្គលដទៃធ្វើឲ្យ រមែងធ្លាក់ដល់បុគ្គលដែលពោលយ៉ាងនេះ ព្រោះហេតុនោះ បរវាទីត្រូវសួរដោយអំណាចនៃវាទៈនោះ ទើបបដិសេធទៀត

[ ១៦១ ] បទថា **សោ ច អញ្ញោ ច** សកវាទីពោលដោយអំណាចនៃពាក្យសួរដល់ភាពដែលបុគ្គលធ្វើ និងសោយជាបុគ្គលតែមួយ និងជាបុគ្គលដទៃអំពីគ្នា ។ លំដាប់នោះ បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រនោះឯង ត្រូវសួរទៀត ក៏ឆ្លើយទទួល ព្រោះរួមន័យទាំង ២ មុនៗ ចូលជា

មួយគ្នា ។ តែសុខទុក្ខដែលខ្លួនឯងធ្វើផង ដែលអ្នកដទៃធ្វើផង រមែងធ្លាក់ដល់បុគ្គលដែលពោលយ៉ាងនេះ ព្រោះហេតុនោះ បរវាទីត្រូវសួរដោយអំណាចនៃវាទៈ ទើបឆ្លើយបដិសេធទៀត ។

[ ១៦២ ] បទថា **សេវ សោ ករោតិ** ជាពាក្យដែលសកវាទីពោលដោយអំណាចនៃការបដិសេធ នូវភាពដែលអ្នកធ្វើ និងអ្នកសោយជាបុគ្គលតែមួយ ។ លំដាប់នោះ បរវាទីឆ្លើយបដិសេធ ដោយអំណាចនៃការខុសអំពីព្រះសូត្រនោះឯង ត្រូវសួរទៀត កាលមានសេចក្ដីសម្គាល់ថា ព្រោះហេតុដែលមនុស្សធ្វើកម្ម ដើម្បីចូលដល់ទេវលោក នៅជាមនុស្សនៅឡើយ រមែងមិនបានសោយ បុគ្គលណាធ្វើកម្មណា បុគ្គលដទៃអំពីបុគ្គលនោះសោយក៏មិនមែន ព្រោះហេតុនោះ ពោលដោយអ្នកធ្វើ អ្នកសោយ ក៏មិនមែន ទាំងបុគ្គលនោះៗ ឯង ទាំងមិនមែនបុគ្គលដទៃ ទើបឆ្លើយទទួល ។ ពាក្យនោះ ត្រឹមតែជាលទ្ធិប៉ុណ្ណោះ ។ តែសុខទុក្ខ ដែលមិនបានអាស្រ័យការធ្វើរបស់ខ្លួនឯង មិនបានអាស្រ័យការធ្វើរបស់អ្នកដទៃ ហើយកើតឡើងបានរមែងធ្លាក់ដល់អ្នកពោលយ៉ាងនេះ ព្រោះហេតុនោះ បរវាទីត្រូវសួរដោយអំណាចនៃវាទៈនោះ ទើបឆ្លើយបដិសេធទៀត ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថក្នុងមិស្សកន័យនេះ តាំងអំពីដើមដោយន័យនេះ ។ ពិតហើយព្រោះបុគ្គលវាទីនេះ គាប់ចិត្តកាន់យកបុគ្គលដែលធ្វើកម្មទាំងឡាយផង បុគ្គលអ្នកសោយផង ព្រោះហេតុនោះ ទើបសេចក្ដីនេះ ប្រាកដយ៉ាងនេះថា បុគ្គលណាជាអ្នកធ្វើកម្ម បុគ្គលនោះប៉ុណ្ណោះ គប្បីជាអ្នកសោយ ឬអ្នកដទៃសោយ

ឬទាំង ២ ជាអ្នកសោយ ឬទាំង ២ មិនជាអ្នកសោយ សកវាទីប្រកប ពាក្យសួរបញ្ហាដែលប្រាកដយ៉ាងនេះឯងហើយ ទើបពោលដល់បញ្ហាដែលគួរ កំណត់ទាំង ៤ យ៉ាង មានពាក្យថា បុគ្គលនោះ មិនមែនធ្វើជាដើម ។ ពាក្យ ដ៏សេស មានប្រការដូចពោលហើយនោះឯង ។

[ ១៦៣ ] ក្នុងទីបំផុត សកវាទី បានសួរបញ្ហាទាំង ៤ រួមគ្នា ។ ក្នុង បញ្ហានោះ ការបដិសេធ ការឆ្លើយទទួល និងការដល់ទោស មានពាក្យថា បុគ្គលអ្នកធ្វើដោយខ្លួនឯងជាដើម បណ្ឌិតគប្បីជ្រាបដោយន័យមុននោះឯង ។

[ ១៦៤ ] ខាងមុខអំពីនេះ មិនពោលថា កម្មល្អ កម្មអាក្រក់ តែ សម្តែងន័យដែលធ្លាប់ពោលហើយនោះឯង ដោយកំណត់ថា **កម្មំ ឆត្តិ** ជាដើម ។ បណ្ឌិតគប្បីជ្រាបអត្ថនៃពាក្យទាំងឡាយនោះ ដោយន័យដែល ពោលហើយខាងដើមនោះឯង ។៚

## អដ្ឋកថាបុរិសការានុយោគ ចប់

ពាក្យថា កល្យាណវគ្គ ជាឈ្មោះរបស់បុរិសការានុយោគនោះឯង

# អភិធម្មបិដក

## អភិញ្ញានុយោគ

[ ១៦៥ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងជនណាមួយ ប្រែងឫទ្ធិបាន មានឬ ។ អើ ។ ប្រសិនបើ ជនណាមួយ ប្រែងឫទ្ធិបាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងជនណាមួយ ឮសំឡេង ដោយទិព្វសោតធាតុបាន មានឬ ។បេ។ ដឹងនូវចិត្តរបស់បុគ្គលដទៃ ។បេ។ រឭកឃើញនូវបុព្វេនិវាស ។បេ។ ឃើញរូបដោយទិព្វចក្ខុ ។បេ។ ធ្វើឲ្យជាក់ច្បាស់នូវធម៌ ជាគ្រឿងអស់ទៅនៃអាសវៈ មានឬ ។ អើ ។ ប្រសិនបើ ជនណាមួយ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈបាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ បរវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា ជនណាមួយ ប្រែងឫទ្ធិបាន មាន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ជនណា ប្រែងឫទ្ធិបាន ជននោះ ទើបឈ្មោះថា បុគ្គល ជនណា មិនប្រែងឫទ្ធិបាន ជននោះ មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។ ជនណា ឮសំឡេង ដោយទិព្វសោតធាតុ ។បេ។ ជនណា ដឹងចិត្ត របស់បុគ្គលដទៃ ។បេ។ ជនណា រឭកឃើញនូវបុព្វេនិវាស ។បេ។ ជនណា ឃើញរូបដោយទិព្វចក្ខុ ។បេ។ ជនណា ធ្វើឲ្យជាក់ច្បាស់ នូវធម៌ជាគ្រឿង អស់ទៅនៃអាសវៈ ជននោះ ទើបឈ្មោះថា បុគ្គល ជនណា មិនធ្វើឲ្យជាក់ ច្បាស់ នូវធម៌ជាគ្រឿងអស់ទៅអាសវៈ ជននោះ មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## អភិញ្ញានុយោគ ចប់

# អដ្ឋកថា

## អភិញ្ញានុយោគ

[ ១៦៥ ] *ខាងមុខអំពីនេះ ជាការពិសោធព្រះអរហន្ត ដោយអំណាចនៃពាក្យសួរដល់អភិញ្ញាជាដើម ។ ក្នុងបញ្ហានោះ កាលសកវាទីឆ្លើយទទួលថា* **អាមន្តា** *បរវាទីមានសេចក្តីសម្គាល់ថា បុគ្គលដែលសម្រេចគុណ-វិសេស មានឫទ្ធិជាដើម មិនមានក្នុងអនិន្ទ្រិយពទ្ធរូប ( រូបដែលទាក់ទងដោយអនិន្ទ្រិយ ) ខាងក្រៅ មានតែខាងក្នុងបុគ្គល ព្រោះហេតុនោះ បុគ្គលដែលឲ្យឫទ្ធិជាដើមកើតឡើង គប្បីមាន ទើបពោលពាក្យថា* **ឆន្ទុ អត្ថិ កោចិ ឥទ្ធឹ វិកុព្វតិ** *ជាដើម ។ ពាក្យទាំងនោះ មានអត្ថងាយយល់ហើយនោះឯង ។* ៚

**អដ្ឋកថាអភិញ្ញានុយោគ ចប់**

# អភិធម្មបិដក

## ញាតកានុយោគ

[ ១៦៦ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងមាតា មានឬ ។ អើ ។ បើមាតា មាន ម្នាល អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថ ដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថ ដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបិតា មានឬ ។បេ។ បងប្អូនប្រុស មាន បងប្អូនស្រី មាន ក្សត្រ មាន ព្រាហ្មណ៍ មាន អ្នកជំនួញ មាន អ្នកគ្រួ មាន គ្រហស្ថ មាន បព្វជិត មាន ទេវតា មាន មនុស្ស មានឬ ។ អើ ។ ប្រសិន បើ មនុស្សមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះដែរ ។

[ ១៦៧ ] បរវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា មាតា មាន ព្រោះ ហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ឬ ។ អើ ។ បុគ្គលណាមួយ មិនធ្លាប់កើតជាមាតា តើកើតជាមាតា មានឬ ។ អើ ។ ជនណាមួយ មិនធ្លាប់កើតជាបុគ្គល តើកើតជាបុគ្គល មានឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណាមួយ មិនធ្លាប់កើតជាបិតា ។បេ។ មិន ធ្លាប់កើតជាបងប្អូនប្រុស មិនធ្លាប់កើតជាបងប្អូនស្រី មិនធ្លាប់កើតជាក្សត្រ មិន ធ្លាប់កើតជាព្រាហ្មណ៍ មិនធ្លាប់កើតជាអ្នកជំនួញ មិនធ្លាប់កើតជាអ្នកគ្រួ មិន ធ្លាប់កើតជាគ្រហស្ថ មិនធ្លាប់កើតជាបព្វជិត មិនធ្លាប់កើតជាទេវតា មិនធ្លាប់

កើតជាមនុស្ស តើកើតជាមនុស្ស មានឬ ។ អើ ។ ជនណាមួយ មិនធ្លាប់កើតជាបុគ្គល តើកើតជាបុគ្គល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៨ ] បរវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា មាតា មាន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ឬ ។ អើ ។ ជនណាមួយ ធ្លាប់កើតជាមាតាមកហើយ បែរជាមិនកើតជាមាតាវិញ មានឬ ។ អើ ។ ជនណាមួយ ធ្លាប់កើតជាបុគ្គលមកហើយ បែរជាមិនកើតជាបុគ្គលវិញ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណាមួយធ្លាប់កើតជាបិតា ធ្លាប់កើតជាបងប្អូនប្រុស ធ្លាប់កើតជាបងប្អូនស្រី ធ្លាប់កើតជាក្សត្រ ធ្លាប់កើតជាព្រាហ្មណ៍ ធ្លាប់កើតជាអ្នកជំនួញ ធ្លាប់កើតជាអ្នកគ្រួធ្លាប់កើតជាគ្រហស្ថ ធ្លាប់កើតជាបព្វជិត ធ្លាប់កើតជាទេវតា ធ្លាប់កើតជាមនុស្សមកហើយ បែរជាមិនកើតជាមនុស្សវិញ មានឬ ។ អើ ។ ជនណាមួយធ្លាប់កើតជាបុគ្គលមកហើយ បែរជាមិនកើតជាបុគ្គលវិញ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៩ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងសោតាបន្នបុគ្គល មានឬ ។ អើ ។ ប្រសិនបើសោតាបន្នបុគ្គល មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថាបុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថាបុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល មានឬ ។បេ។ អនាគាមិបុគ្គល មានឬ ។បេ។ ព្រះអរហន្ត មាន

ឬ ។បេ។ ឧភតោភាគវិមុត្តបុគ្គល មានឬ បញ្ញាវិមុត្តបុគ្គល មានឬ កាយ-សក្ខិបុគ្គល មានឬ ទិដ្ឋិប្បត្តបុគ្គល មានឬ សទ្ធាវិមុត្តបុគ្គល មានឬ ធម្មា-នុសារិបុគ្គល មានឬ សទ្ធានុសារិបុគ្គល មានឬ ។ អើ ។ ប្រសិនបើ សទ្ធា-នុសារិបុគ្គល មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោល ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។

[ ១៧០ ] បរវាទីធ្វើ ( នូវពាក្យប្ដេជ្ញាឲ្យមាំ ) ថា សោតាបន្នបុគ្គល មាន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ជនណាមួយ មិនធ្លាប់កើតជាសោតាបន្នបុគ្គល បែរជាកើតជាសោតាបន្នបុគ្គល មានឬ ។ អើ ។ ជនណាមួយ មិនធ្លាប់កើតជាបុគ្គល បែរជាកើតជាបុគ្គល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណាមួយ មិនធ្លាប់កើតជាសកទាគាមិបុគ្គល មិនធ្លាប់កើតជាអនាគាមិបុគ្គល មិនធ្លាប់កើតជាព្រះអរហន្ត មិនធ្លាប់កើតជាឧភតោភាគវិមុត្តបុគ្គល មិនធ្លាប់កើតជាបញ្ញាវិមុត្តបុគ្គល មិនធ្លាប់កើតជាកាយសក្ខិបុគ្គល មិនធ្លាប់កើតជាទិដ្ឋិប្បត្តបុគ្គល មិនធ្លាប់កើតជាសទ្ធាវិមុត្តបុគ្គល មិនធ្លាប់កើតជាធម្មានុសារិ-បុគ្គល មិនធ្លាប់កើតជាសទ្ធានុសារិបុគ្គល តើកើតជាសទ្ធានុសារិបុគ្គល មាន ឬ ។ អើ ។ ជនណាមួយ មិនធ្លាប់កើតជាបុគ្គល បែរជាកើតជាបុគ្គល មាន ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧១ ] បរវាទីធ្វើ ( នូវពាក្យប្ដេជ្ញាឲ្យមាំ ) ថា សោតាបន្នបុគ្គល មាន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត

និងអត្ថដ៏ឧត្តមឬ ។ អើ ។ ជនណាមួយ ជាសោតាបន្នបុគ្គលហើយ ត្រឡប់ជាមិនមែនសោតាបន្នបុគ្គលវិញ មានឬ ។ អើ ។ ជនណាមួយ កើតជាបុគ្គលហើយ បែរជាមិនកើតជាបុគ្គលវិញ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណាមួយ ជាសកទាគាមិបុគ្គលហើយ ជាអនាគាមិបុគ្គលហើយ ត្រឡប់ជាមិនមែនអនាគាមិបុគ្គលវិញ មានឬ ។ អើ ។ ជនណាមួយ កើតជាបុគ្គលហើយ បែរជាមិនកើតជាបុគ្គលវិញ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧២ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងគូនៃបុរស មាន ៤ គូ បុរសបុគ្គល ៨ រូប មានឬ ។ អើ ។ ប្រសិនបើ គូនៃបុរស មាន ៤ គូ បុរសបុគ្គល ៨ រូប មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។

[ ១៧៣ ] បរវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា គូនៃបុរស មាន ៤ គូ បុរសបុគ្គល ៨ រូប មានមែន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ គូនៃបុរស មាន ៤ គូ បុរសបុគ្គល ៨ រូប មានប្រាកដ ព្រោះការកើតប្រាកដនៃព្រះពុទ្ធឬ ។ អើ ។ បុគ្គលកើតប្រាកដ ព្រោះការកើតប្រាកដនៃព្រះពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកើតប្រាកដ ព្រោះការកើតប្រាកដនៃព្រះពុទ្ធឬ ។ អើ ។ បុគ្គលដាច់សូន្យ ឈ្មោះថា បុគ្គលមិនមាន ក្នុងកាលដែលព្រះពុទ្ធមានព្រះភាគ ទ្រង់បរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៤ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ បុគ្គល មានបច្ច័យតាក់តែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល មិនមានបច្ច័យតាក់តែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល មិនមានបច្ច័យតាក់តែង មិនមែនមិនមានបច្ច័យតាក់តែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលមានបច្ច័យតាក់តែង ក៏មិនមែន មិនមានបច្ច័យតាក់តែង ក៏មិនមែនឬ ។ អើ ។ ទីបំផុតទី ៣ ដទៃទៀត វៀរលែងតែសង្ខតៈ និងអសង្ខតៈចេញ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទីបំផុតទី ៣ ដទៃទៀត វៀរលែងសង្ខតៈ និងអសង្ខតៈចេញ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធាតុនេះ មាន ២ ប្រការ ធាតុ ២ ប្រការ តើដូចម្តេចខ្លះ គឺសង្ខតធាតុ ១ អសង្ខតធាតុ ១ ម្នាលភិក្ខុទាំងឡាយ ធាតុ ២ ប្រការនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ទីបំផុតទី ៣ ដទៃទៀត វៀរលែងតែសង្ខតៈ និងអសង្ខតៈចេញ មាន ដូច្នេះទេ ។ បុគ្គល មានបច្ច័យតាក់តែង ក៏មិនមែន មិនមានបច្ច័យតាក់តែង ក៏មិនមែនឬ ។ អើ ។ សង្ខតៈដទៃ អសង្ខតៈដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ មានបច្ច័យតាក់តែង ព្រះនិព្វាន មិនមានបច្ច័យតាក់តែង បុគ្គល មិនមែនមានបច្ច័យតាក់តែង មិនមែនជាមិនមានបច្ច័យតាក់តែងឬ ។ អើ ។ ខន្ធដទៃ ព្រះនិព្វានដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប មានបច្ច័យតាក់តែង ព្រះនិព្វាន មិនមានបច្ច័យតាក់តែង បុគ្គល មិនមែនមានបច្ច័យតាក់តែង មិនមែនជាមិនមានបច្ច័យ

តាក់តែងឬ ។ អើ ។ រូបដទៃ ព្រះនិព្វានដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ វិញ្ញាណ មានបច្ច័យតាក់តែង ព្រះនិព្វាន មិនមានបច្ច័យតាក់តែង បុគ្គល មិនមែនមាន បច្ច័យតាក់តែង មិនមែនជាមិនមានបច្ច័យតាក់តែងឬ ។ អើ ។ វិញ្ញាណដទៃ ព្រះនិព្វានដទៃ បុគ្គលដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៥ ] បុគ្គល មានការកើតឡើងប្រាកដ មានការសូន្យទៅប្រាកដ ការប្រែប្រួល នៃបុគ្គលកំពុងស្ថិតនៅប្រាកដឬ ។ អើ ។ បុគ្គល មានបច្ច័យ តាក់តែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខតលក្ខណៈ នៃសង្ខតធម៌នេះ មាន ៣ ប្រការ ម្នាលភិក្ខុទាំងឡាយ សង្ខតធម៌ទាំងឡាយ មានការកើតឡើងប្រាកដ មានការសូន្យទៅប្រាកដ ការប្រែប្រួលនៃសង្ខតធម៌ ក៏កំពុងស្ថិតនៅប្រាកដ ដែរ បុគ្គល មានការកើតឡើងប្រាកដ មានការសូន្យទៅប្រាកដ ការប្រែ ប្រួលនៃបុគ្គល កំពុងស្ថិតនៅប្រាកដដែរ ព្រោះហេតុនោះ បុគ្គលមានបច្ច័យ តាក់តែងដែរ ។ បុគ្គល មិនមានការកើតឡើងប្រាកដ មិនមានការសូន្យទៅ ប្រាកដ ការប្រែប្រួលនៃបុគ្គល កំពុងស្ថិតនៅមិនប្រាកដឬ ។ អើ ។ បុគ្គល មិនមានបច្ច័យតាក់តែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមាន ព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អសង្ខតលក្ខណៈ នៃអសង្ខត-ធម៌នេះ មាន ៣ ប្រការ ម្នាលភិក្ខុទាំងឡាយ អសង្ខតធម៌ទាំងឡាយ មិន មានការកើតឡើងប្រាកដ មិនមានការសូន្យទៅប្រាកដ ការប្រែប្រួលនៃ

អសង្ខតធម៌ ដែលកំពុងស្ថិតនៅ ក៏មិនប្រាកដដែរ បុគ្គល មិនមានការកើតឡើងប្រាកដ មិនមានការសូន្យទៅប្រាកដ ការប្រែប្រួលនៃបុគ្គល កំពុងស្ថិតនៅ ក៏មិនប្រាកដដែរ ព្រោះហេតុនោះ បុគ្គល មិនមានបច្ច័យតាក់តែងដែរ ។

[ ១៧៦ ] បុគ្គលរលត់ហើយ មានក្នុងប្រយោជន៍ គឺព្រះនិព្វានឬ ឬមិនមានក្នុងប្រយោជន៍ គឺព្រះនិព្វានទេ ។ មានក្នុងប្រយោជន៍ គឺព្រះនិព្វាន ។ បុគ្គលរលត់ហើយ ជាបុគ្គលទៀងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល មិនមានក្នុងប្រយោជន៍ គឺព្រះនិព្វានឬ ។ បុគ្គលរលត់ហើយ ជាបុគ្គលដាច់សូន្យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ញាតកានុយោគ ចប់

# អដ្ឋកថា

## ញាតកានុយោគ

[ ១៦៦ ] ឥឡូវនេះ ពាក្យសួរថា **មាតា** ជាដើម ជាការសួរដល់ពួកញាតិ ។ បទថា **ខត្តិយោ** ជាដើម ជាការសួរដល់ជាតិ ។ ពាក្យសួរថា **គហដ្ឋោ បព្វជិតោ** ជាការសួរដល់បដិបទា ។ ពាក្យសួរថា **ទេវោ មនុស្សោ** ជាការសួរដល់ការកើតឡើង ។

[ ១៦៩ ] ពាក្យសួរថា **សោតាបន្នោ** ជាដើម ជាការសួរដល់បដិវេធ សេចក្តីនេះ លោកពោលថា ជាការសួរដល់ព្រះអរិយៈក៏មាន ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។

[ ១៧១ ] ក្នុងពាក្យថា ជនណាមួយ ជាអរហន្តបុគ្គលហើយ ត្រឡប់ជាមិនមែនជាអរហន្តបុគ្គលវិញនេះ លោកមិនពោល ព្រោះជាមោឃបញ្ហា ។

[ ១៧២ ] ពាក្យសួរថា **ចត្តារោ បុរិសយុគា** ជាដើម ជាការសួរដល់ព្រះសង្ឃ ការសួរនោះ ក៏មានអត្ថងាយយល់ដូចគ្នា ។

[ ១៧៤ ] បទថា **សន្តតោ** ជាដើម ជាការសួរដល់សភាវៈនៃសច្ចិកដ្ឋៈ ។

បណ្តាបទទាំងនោះ បទថា **តតិយា កោដិ** ជាពាក្យសួររបស់សកវាទី ពាក្យបដិសេធ ព្រោះការមិនមានសច្ចិកដ្ឋៈបែបនោះ ជាពាក្យរបស់បរវាទី កាលត្រូវសួរដដែលទៀត បរវាទីក៏ឆ្លើយទទួលដោយសំដៅយកបុគ្គល ។

ក្នុងបញ្ហាថា **អញ្ញោ បុគ្គលោ** ពាក្យបដិសេធ ជាពាក្យរបស់បរវាទី នោះឯង ដែលមិនគាប់ចិត្ត ភាពជាយ៉ាងដទៃអំពីសង្ខតក្ខន្ធទាំងឡាយ ។

បទថា **ឧភ្យា សង្ខតា** ជាដើម ជាពាក្យដែលសកវាទីសម្តែងសង្ខតៈ និងអសង្ខតៈទាំងឡាយដោយសង្ខេប ពោលហើយ ដើម្បីសួរភាពជាយ៉ាងដទៃ ។

ពាក្យសួរថា **រូបំ សង្ខតំ** ជាដើម ជាពាក្យដែលសកវាទីសម្តែងខន្ធទាំងឡាយ ដោយចែក ហើយពោលដើម្បីសួរភាពដទៃ ។

[ ១៧៥ ] ពាក្យសួរថា **បុគ្គលស្ស ឧប្បាទោ** ជាពាក្យសួររបស់សកវាទី ពាក្យឆ្លើយទទួលជារបស់បរវាទី ដោយអំណាចនៃព្រះសូត្រដែលលោកពោលក្នុងទីទាំងឡាយ មានពាក្យថា សត្វទាំងឡាយ មានការកើតជាធម្មតា មានការចាស់ជាធម្មតា និងមានការស្លាប់ជាធម្មតា ដូច្នេះជាដើម តែបរវាទីនោះ មិនគាប់ចិត្តនូវភាពដែលបុគ្គលជាសង្ខតធម៌ ហេតុនោះ ទើបបដិសេធ ។ ត្រូវសួរទៀតដោយន័យជាដើមថា **ន ឧប្បាទោ បញ្ញាយតិ** ក៏ឆ្លើយទទួលដោយគិតថា ឈ្មោះថា ការកើតឡើងជាដើមនៃបុគ្គល រមែងមិនគួរ ព្រោះពាក្យថា សេចក្តីទុក្ខ រមែងកើតឡើង សេចក្តីទុក្ខ រមែងស្ថិតនៅផង វិនាសទៅផង ដូច្នេះជាដើម ។

[ ១៧៦ ] ពាក្យសួរថា **អន្តត្តម្ហិ** លោកហៅព្រះនិព្វានថា **អន្តំ** គឺធម៌ដែលមិនមានទីតាំង ។ ក្នុងបញ្ហានោះ សកវាទីសួរថា **អត្ថិ** អធិប្បាយថា បុគ្គល ឈ្មោះថា ទៀង ព្រោះភាពដែលបុគ្គលនោះមាន ឬឈ្មោះថា ដាច់សូន្យ ព្រោះភាពដែលបុគ្គលនោះមិនមាន ទើបត្រឹមត្រូវ បរវាទី កាលមិនគាប់ចិត្តនូវភាពដែលបុគ្គលទៀង ឬដាច់សូន្យទាំងពីរយ៉ាងនោះ ទើបបដិសេធ ។៚

## អដ្ឋកថាញាតកានុយោគ ចប់

# អភិធម្មបិដក

## បកិណ្ណកៈ

[ ១៧៧ ] បុគ្គលស្ថិតនៅ ព្រោះអាស្រ័យអ្វី ។ បុគ្គលស្ថិតនៅ ព្រោះអាស្រ័យភព ។ ភព មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អើ ។ សូម្បីបុគ្គល ក៏មិនទៀង មានបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការរលត់ជាធម្មតា មានការប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៨ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងជនណាមួយ កាលវេទនាសុខវេទនា រមែងដឹងច្បាស់ថា អញវេទនាសុខវេទនា មានឬ ។ អើ ។ ប្រសិនបើ ជនណាមួយ កាលវេទនាសុខវេទនា ដឹងច្បាស់ថា អញវេទនាសុខវេទនា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងជនណាមួយ កាលវេទនាទុក្ខវេទនា ។បេ។ កាលវេទនាអទុក្ខមសុខវេទនា ដឹងច្បាស់ថា អញវេទនាអទុក្ខមសុខវេទនា មានឬ ។ អើ ។ ប្រសិនបើ ជនណាមួយ កាលវេទនាអទុក្ខមសុខវេទនា ដឹងច្បាស់ថា អញវេទនាអទុក្ខមសុខវេទនា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថ

ដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ សកវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា ជនណា កាលរងសុខវេទនា ដឹងច្បាស់ថា អញរងសុខវេទនា ដូច្នេះ ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ជនណា កាលរងសុខវេទនា ដឹងច្បាស់ថា អញរងសុខវេទនា ជននោះឯង ឈ្មោះថា បុគ្គល ជនណា កាលរងសុខវេទនា មិនដឹងច្បាស់ថា អញរងសុខវេទនា ជននោះឯង មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណា កាលរងទុក្ខវេទនា ។បេ។ ជនណា កាលរងអទុក្ខមសុខវេទនា ដឹងច្បាស់ថា អញរងអទុក្ខមសុខវេទនា ជននោះឯង ឈ្មោះថា បុគ្គល ជនណា កាលរងអទុក្ខមសុខវេទនា មិនដឹងច្បាស់ថា អញរងអទុក្ខមសុខវេទនា ជននោះឯង មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា ជនណាមួយ កាលរងសុខវេទនា ដឹងច្បាស់ថា អញរងសុខវេទនា ដូច្នេះ ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ សុខវេទនាដទៃ បុគ្គល កាលរងសុខវេទនា ដឹងច្បាស់ថា អញរងសុខវេទនា ក៏ដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខវេទនាដទៃ ។បេ។ អទុក្ខមសុខវេទនាដទៃ បុគ្គលកាលរងអទុក្ខមសុខវេទនា ដឹងច្បាស់ថា អញរងអទុក្ខមសុខវេទនា ក៏ដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៩ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងបុគ្គលណាមួយ ពិចារណាឃើញនូវកាយ

ក្នុងកាយ មានឬ ។ អើ ។ ប្រសិនបើ ជនណាមួយ ពិចារណាឃើញ នូវកាយក្នុងកាយ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងជនណាមួយ ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ។បេ។ នូវចិត្តក្នុងចិត្ត ។បេ។ ពិចារណាឃើញធម្មារម្មណ៍ ក្នុងធម្មារម្មណ៍ទាំងឡាយ មានមែនឬ ។ អើ ។ ប្រសិនបើ បុគ្គលណាមួយ ពិចារណាឃើញធម្មារម្មណ៍ ក្នុងធម្មារម្មណ៍ទាំងឡាយ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ សកវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា ជនណាមួយ ពិចារណាឃើញ នូវកាយក្នុងកាយ មាន ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ជនណា ពិចារណាឃើញនូវកាយក្នុងកាយ ជននោះ ឈ្មោះថា បុគ្គល ជនណា មិនពិចារណាឃើញនូវកាយក្នុងកាយ ជននោះ មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនណាពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ។បេ។ នូវចិត្តក្នុងចិត្ត ។បេ។ ពិចារណាឃើញនូវធម្មារម្មណ៍ ក្នុងធម្មារម្មណ៍ទាំងឡាយ ជននោះឯង ឈ្មោះថា បុគ្គល ជនណា មិនពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ជននោះ មិនឈ្មោះថា បុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកវាទីធ្វើ ( នូវពាក្យប្តេជ្ញាឲ្យមាំ ) ថា ជនណាមួយ ពិចារណាឃើញនូវ

កាយក្នុងកាយ មាន ដូច្នេះ ព្រោះហេតុនោះ ( ទើបសួរ ) ថា បុគ្គល គេដឹង បាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ កាយដទៃ បុគ្គលអ្នក ពិចារណាឃើញនូវកាយ ក្នុងកាយ ដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនាដទៃ ។បេ។ ចិត្តដទៃ ។បេ។ ធម្មារម្មណ៍ដទៃ បុគ្គលអ្នកពិចារណា ឃើញ នូវធម៌ក្នុងធម៌ទាំងឡាយដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨០ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា

> ម្នាលមោឃរាជ អ្នកចូរមានស្មារតីសព្វកាល រមិលមើល
> នូវខន្ធលោក ដោយសេចក្តីថា សូន្យចុះ ( ព្រោះថា ) បុគ្គល
> លះបង់នូវអត្តានុទិដ្ឋិ គប្បីជាអ្នកឆ្លងចាកមច្ចុ ដោយវិធី
> យ៉ាងនេះ ( មួយទៀត ) មច្ចុរាជ រមែងរកមិនឃើញ នូវ
> បុគ្គលអ្នកសម្លឹងមើលខន្ធលោក ដោយវិធីយ៉ាងនេះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ មានតែអ្នក មិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។

[ ១៨១ ] បុគ្គលក្រឡេកមើលឬ ។ អើ ។ បុគ្គលក្រឡេកមើល ព្រម ទាំងរូបឬ ឬវៀរចាករូប ទើបក្រឡេកមើល ។ បុគ្គលក្រឡេកមើល ព្រមទាំង រូប ។ ជីវៈនោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល វៀរចាករូប ទើបក្រឡេកមើលឬ ។ ជីវៈដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ បុគ្គលក្រឡេកមើលឬ ។ អើ ។ បុគ្គលតាំងនៅខាងក្នុង

នៃរូប ក្រឡេកមើលឬ ឬចេញមកខាងក្រៅ ទើបក្រឡេកមើល ។ បុគ្គលតាំងនៅខាងក្នុង ក្រឡេកមើល ។ ជីវៈនោះ គឺសរីរៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចេញមកខាងក្រៅ ទើបក្រឡេកមើលឬ ។ ជីវៈដទៃ សរីរៈដទៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨២ ] អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃ្លៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានបុគ្គលប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ពិតឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃ្លៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់ កាលកើតឡើងក្នុងលោក រមែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ពិតឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល គេដឹងបាន

ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមដែរ ។

[ ១៨៣ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ធម៌ទាំងពួងជាអនត្តា ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៤ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា បុគ្គលរមែងមិនសង្ស័យ មិនងឿងឆ្ងល់ថា ទុក្ខហ្នឹងឯង កាលកើត ក៏កើតឡើង ទុក្ខហ្នឹងឯង កាលរលត់ ក៏រលត់ទៅ ការដឹងដោយមិនជឿស្តាប់បុគ្គលដទៃ នៃបុគ្គលនោះ ហ្នឹងឯង រមែងមានក្នុងសម្មាទិដ្ឋិនុ៎ះ ម្នាលកច្ចានៈ សម្មាទិដ្ឋិ រមែងមាន ដោយហេតុប៉ុណ្ណោះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៥ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងវជិរាភិក្ខុនី បានពោលពាក្យនេះ ចំពោះមារមានចិត្តបាបថា

ម្នាលមារ អ្នកជឿថា សត្វ ដូច្នេះឬ ( មួយទៀត ) អ្នកមាន ទិដ្ឋិ ( យ៉ាងនេះ ) ឬ នេះជាគំនរសង្ខារសុទ្ធទេតើ សត្វមិន មានក្នុងទីនេះទេ ដូចយ៉ាងសព្ទថា រថ ព្រោះការបរិបូណ៌ ដោយអង្គ យ៉ាងណា កាលខន្ធទាំងឡាយមាន ការសន្មតិថា សត្វ រមែងមាន ក៏យ៉ាងនោះដែរ ព្រោះថា ទុក្ខ តែងកើត ឡើងផង ទុក្ខ តែងតាំងនៅផង តែងវិនាសទៅវិញផង ធម្មជាតដទៃ ក្រៅអំពីទុក្ខ មិនកើតមានទេ ធម្មជាតដទៃ ក្រៅអំពីទុក្ខ មិនរលត់ទៅវិញទេ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិន គួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៦ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគថា បពិត្រព្រះ អង្គដ៏ចម្រើន ព្រះអង្គតែងត្រាស់ថា លោកសូន្យ លោកសូន្យ បពិត្រព្រះអង្គ ដ៏ចម្រើន ដែលព្រះអង្គត្រាស់ថា លោកសូន្យ តើដោយហេតុដូចម្តេច ព្រះ មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ធម្មជាតសូន្យចាកខ្លួន ឬចាករបស់ដែល អាស្រ័យនឹងខ្លួន ព្រោះហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ម្នាល អានន្ទ ចុះធម្មជាតអ្វីដែលសូន្យចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួន ម្នាលអានន្ទ ភ្នែកសូន្យចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួន រូបសូន្យ ។បេ។ ចក្ខុវិញ្ញាណសូន្យ ។បេ។ ចក្ខុសម្ផស្សសូន្យ ។បេ។ វេទនាណា ជា

សុខក្តី ជាទុក្ខក្តី ជាអទុក្ខមសុខក្តី តែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏សូន្យចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួន ត្រចៀក សូន្យ ។បេ។ សំឡេង សូន្យ ។បេ។ ច្រមុះ សូន្យ ... ក្លិន សូន្យ ។បេ។ អណ្តាត សូន្យ ... រស សូន្យ ... ។បេ។ កាយ សូន្យ ... ផោដ្ឋព្វៈ សូន្យ ។បេ។ ចិត្ត សូន្យ ... ធម្មារម្មណ៍ សូន្យ ... មនោវិញ្ញាណ សូន្យ ... មនោសម្ផស្ស សូន្យ ។បេ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី ជាអទុក្ខមសុខក្តី កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះ ក៏សូន្យចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួន ម្នាលអានន្ទ ធម្មជាតសូន្យចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួន ព្រោះហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៧ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃ្លៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលខ្លួនមានសេចក្តីប្រកាន់ថា អញមានរបស់ដែលអាស្រ័យនឹងខ្លួន ដូច្នេះ ក៏គប្បីមានដែរឬ ព្រះករុណាព្រះអង្គ ម្នាលភិក្ខុទាំងឡាយ កាលរបស់ដែលអាស្រ័យនឹងខ្លួនមាន សេចក្តីប្រកាន់ថា អញមានខ្លួន ដូច្នេះ ក៏គប្បីមានដែរឬ ព្រះករុណា ព្រះអង្គ ម្នាលភិក្ខុទាំងឡាយ កាលខ្លួនក្តី

កាលរបស់ដែលអាស្រ័យនឹងខ្ទនក្តី គេមិនបានដឹងថាទៀងត្រង់ ថាទៀងទាត់ទេ ហេតុនៃទិដ្ឋិណាថា ទុំះលោក ទុំះខ្ទន ខ្ទនអញនោះ លុះលះបង់លោកនេះហើយ នឹងជាបុគ្គលទៀងទាត់ ស្ថិតស្ថេរ មិនប្រែប្រួលជាធម្មតា នឹងស្ថិតនៅនឹងថ្កល់ ស្មើដោយសស្សតិវត្ថុ ដោយប្រការនោះ ម្នាលភិក្ខុទាំងឡាយ ហេតុនៃទិដ្ឋិនេះ ជាពាលធម៌ ដ៏បរិបូណ៌ទាំងអស់ មិនដូច្នោះឬ បពិត្រព្រះអង្គដ៏ចម្រើន ពាលធម៌ដ៏បរិបូណ៌ទាំងអស់ មិនគប្បីមានតែបន្តិចបន្តួចទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលគេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៨ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃ្លៀងឃ្លាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសេនិយៈ គ្រូ ៣ ពួកនេះ មានប្រាកដក្នុងលោក គ្រូ ៣ ពួក តើដូចម្តេចខ្លះ ម្នាលសេនិយៈ គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តខ្ទនក្នុងបច្ចុប្បន្នថា ទៀងទាត់ ថាស្ថិតស្ថេរផង បញ្ញត្តខ្ទនក្នុងបរលោកថា ទៀងទាត់ ថាស្ថិតស្ថេរផង ម្នាលសេនិយៈ មួយទៀត គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តខ្ទនក្នុងបច្ចុប្បន្នថា ទៀងទាត់ ថាស្ថិតស្ថេរ តែមិនបញ្ញត្តខ្ទនក្នុងបរលោក ថាទៀងទាត់ ថាស្ថិតស្ថេរទេ ម្នាលសេនិយៈ មួយវិញទៀត គ្រូខ្លះ ក្នុងលោកនេះ មិនបញ្ញត្តខ្ទន ក្នុងបច្ចុប្បន្ន ថាទៀងទាត់ ថាស្ថិតស្ថេរផង មិនបញ្ញត្តខ្ទនក្នុងបរលោក

ជាទៀងទាត់ ជាស្ថិតស្ថេរផង ម្នាលសេនិយៈ បណ្តាគ្រូទាំង ៣ ពួកនោះ គ្រូណា បញ្ញត្តខន្ធក្នុងបច្ចុប្បន្ន ជាទៀងទាត់ ជាស្ថិតស្ថេរផង បញ្ញត្តខន្ធក្នុងបរលោក ជាទៀងទាត់ ជាស្ថិតស្ថេរផង ម្នាលសេនិយៈ នេះហៅថា គ្រូជាសស្សតវាទ ម្នាលសេនិយៈ បណ្តាគ្រូទាំង ៣ ពួកនោះ គ្រូណា បញ្ញត្តខន្ធក្នុងបច្ចុប្បន្ន ជាទៀងទាត់ ជាស្ថិតស្ថេរ តែមិនបញ្ញត្តខន្ធក្នុងបរលោក ជាទៀងទាត់ ជាស្ថិតស្ថេរទេ ម្នាលសេនិយៈ នេះហៅថា គ្រូជាឧច្ឆេទវាទ ម្នាលសេនិយៈ បណ្តាគ្រូទាំង ៣ ពួកនោះ គ្រូណា មិនបញ្ញត្តខន្ធក្នុងបច្ចុប្បន្ន ជាទៀងទាត់ ជាស្ថិតស្ថេរផង មិនបញ្ញត្តខន្ធក្នុងបរលោក ជាទៀងទាត់ ជាស្ថិតស្ថេរផង ម្នាលសេនិយៈ នេះហៅថា គ្រូ គឺព្រះសម្មាសម្ពុទ្ធ ម្នាលសេនិយៈ គ្រូទាំង ៣ ពួកនេះ តែងមានប្រាកដក្នុងលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៨៩ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃៀងឃាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ថ្នាំងទឹកដោះថ្លាឬ ។ អើ ។ ជនណាមួយ ធ្វើថ្នាំងទឹកដោះថ្លា មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ដូច្នេះទេ ។

[ ១៩០ ] បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គជាអ្នកសម្តែងពាក្យទៀងត្រង់ សម្តែងតាមកាល សម្តែងពាក្យពិត សម្តែងពាក្យប្រាកដ សម្តែងពាក្យមិនឃៀងឃាត សម្តែងពាក្យមិនប្រែប្រួលឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា ថ្នាំងប្រេង ថ្នាំងទឹកឃ្មុំ ថ្នាំងទឹកអំពៅ ថ្នាំងទឹកដោះស្រស់ ថ្នាំងទឹកផឹក សៀនដាក់ទឹកផឹក កំសៀវដាំទឹកផឹក ផ្តិលខាត់ដាក់ទឹកផឹក បាយទៀងទាត់ បបរពិតប្រាកដឬ ។ អើ ។ បបរណាមួយ ទៀងទាត់ ពិតប្រាកដ ស្ថិតស្ថេរ មិនប្រែប្រួលជាធម្មតា មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល គេដឹងបាន ដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមទេ ។ សេចក្តីបង្រួញ ។

និយាយអំពីការសង្កត់សង្កិន ៨ លើក អំពីសេចក្តីបង្រួញ អំពីបុគ្គលអន្ទោលទៅ អំពីបញ្ញត្តិបុគ្គល ព្រោះអាស្រ័យរូប អំពីចិត្ត អំពីអំពើល្អជាគម្រប់ ៥ អំពីការប្ដូរឫទ្ធិ អំពីការសម្តែងអាង ដោយការនាំមកនូវព្រះសូត្រ ជាគម្រប់ ៨ ។

**បកិណ្ណកៈ ចប់**

# អដ្ឋកថា

## បដិវេធានុយោគជាដើម

[ ១៧៧ ] *គប្បីជ្រាបវិនិច្ឆ័យ ក្នុងបញ្ហាអាស្រ័យភពដូចតទៅនេះ បទថា* **ភវំ** *បានដល់ ឧបបត្តិភព ។*

[ ១៧៨-១៧៩ ] *ក្នុងបញ្ហារបស់បុគ្គលអ្នកសោយវេទនា អធិប្បាយថា ព្រះយោគាវចរដែលសោយនូវវេទនា កំណត់វេទនាហើយ ឈ្មោះថា រមែងដឹងច្បាស់ ។ ឯពាលបុថុជ្ជន រមែងមិនដឹង ។ បញ្ហាក្នុងរឿងពិចារណាឃើញកាយជាដើម មានអត្ថងាយយល់ហើយ ។*

[ ១៨០ ] *បទថា* **សុញ្ញតោ លោកំ អវេក្ខស្សុ** *ជាដើម ក្នុងបរាយណវគ្គ មានអធិប្បាយថា ចូរអ្នកពិចារណាលោក គឺខន្ធ ដោយអំណាចភាពជារបស់ទទេចាកសត្វ ។*

[ ១៨១ ] *បទថា* **បុគ្គលោ អវេក្ខតិ** *ជាពាក្យសួររបស់សកវាទី ពិតហើយ លទ្ធិរបស់បរវាទីថា បុគ្គលណាស្ទង់ដឹង បុគ្គលនោះ ជាបុគ្គល ព្រោះគាថាថា ចូរអ្នកដឹងនូវលោក ដោយភាពជារបស់សូន្យ ព្រោះហេតុនោះ ទើបសកវាទីសួរបញ្ហានោះឯង ។ បទថា* **សហ រូបេន** *បានដល់ រួមជាមួយនឹងរូបកាយ អធិប្បាយថា មិនមែនជាបុគ្គលអាស្រ័យរូបកាយនោះ ។ បរវាទីទទួលពាក្យនេះ ដោយអំណាចនៃបញ្ចវោការភូមិ ត្រូវសកវាទីសួរទៀតថា* **តំ ជីវំ** *រមែងបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រនោះឯង ។ បទថា* **វិនា រូបេន** *សេចក្ដីថា បរវាទីទទួលពាក្យនេះ ដោយអំណាចនៃចតុវោការភូមិ ត្រូវសកវាទីសួរទៀតថា* **អញ្ញំ ជីវំ** *រមែងបដិសេធ ព្រោះខ្លាចខុសចាកអំពី*

ព្រះសូត្រនោះឯង ។ បទថា **អត្តន្តរគតោ** និងបទថា **ពហិទ្ធា និក្ខមិត្វា** នេះ ជាពាក្យដែលមានលក្ខណៈ នៃពាក្យដែលសកវាទីធ្លាប់ពោលមកហើយថា **សហា រូបេន** ឬ **វិនា រូបេន** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អត្តន្តរគតោ** បានដល់ នៅខាងក្នុងនៃរូប អធិប្បាយថា ជាសភាវៈមិនចេញទៅក្នុងទីផ្សេងៗ នេះ តាំងនៅដោយអំណាចនៃរូបបរិច្ឆេទនោះឯង ។ បទថា **និក្ខមិត្វា** បានដល់ ការឈានកន្លងរូបបរិច្ឆេទ អធិប្បាយថា មិនបានអាស្រ័យរូប ។

[ ១៨៣ ] បទថា **អនត្តា** បានដល់ វៀរចាកខ្លួន វៀរចាកជីវៈ វៀរចាកបុគ្គល អធិប្បាយថា មិនមានបុគ្គល សូម្បីក្នុងធម៌ត្រឹមតែមួយ ។ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យដែលពោលហើយក្នុងអដ្ឋកថា ដែលជាទីមកនៃព្រះសូត្រទាំងពួងនោះឯង ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ខ្ញុំសំដៅយកពាក្យអធិប្បាយនេះ នឹងពោលពាក្យដែលជាភាសិតនោះឯង ។

[ ១៨៩-១៩០ ] បទថា **វុត្តំ ភគវតា សប្បិកុម្ភោ** ជាដើម ជាពាក្យដែលសកវាទីនាំមកដើម្បីសម្ដែងថា ទេសនាទាំងពួង ដែលបណ្ឌិតមិនគប្បីកាន់យកតែអត្ថដោយអំណាចនៃពាក្យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ប៉ុណ្ណោះឡើយ ។ ដូចថ្នាំងដែលជាវិការនៃមាស ដែលគេយកមាសមកធ្វើ សត្វលោកទាំងឡាយ រមែងហៅថា ថ្នាំងមាស យ៉ាងណា ដែលឈ្មោះថា ថ្នាំងសប្បិ ជាវិការនៃសប្បិ ដែលគេយកសប្បិមកធ្វើដូច្នោះ ក៏មិនមែន ។ ក្នុងពាក្យនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា សប្បិដែលបុគ្គលណាដាក់ក្នុងថ្នាំង

ណា ឆ្នាំងនោះ ក៏បានឈ្មោះថា ឆ្នាំងសប្បិ ក៏យ៉ាងនោះ ។ ក្នុងពាក្យថា ឆ្នាំងប្រេងជាដើមក៏មានន័យនេះដូចគ្នា ។ ដូចព្រះនិព្វានជាធម្មជាតទៀង ស្ថិតស្ថេរ យ៉ាងណា កត្ត ឬបបរ រមែងជាធម្មជាតទៀង ស្ថិតស្ថេរយ៉ាងនោះ ក៏មិនមែន ។ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថដូចតទៅនេះថា និច្ចកត្ត គឺកត្តដែលគេឲ្យប្រចាំ ធុវយាគូ គឺបបរដែលស្ថិតស្ថេរ លោកហៅដោយអំណាចពាក្យដែលជាបញ្ញត្តិថា ពួកយើងទាំងឡាយ មិនកំណត់កាល នឹងប្រគេននិច្ចកត្ត និងធុវយាគូរាល់ៗ ថ្ងៃ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អត្ថិ បុគ្គលោ អត្តហិតាយ បដិបន្នោ** ជាដើម ដូចតទៅនេះថា ធម៌ទាំងឡាយ មានរូបជាដើមមាន ដោយអំណាចនៃបច្ចត្តលក្ខណៈ គឺលក្ខណៈដែលមានចំពោះខ្លួន និងសាមញ្ញលក្ខណៈ យ៉ាងណា បុគ្គលរមែងមានយ៉ាងនោះក៏មិនមែន ។ កាលធម៌ទាំងឡាយ មានរូបជាដើម មាន ការហៅថា ឈ្មោះយ៉ាងនេះ គោត្តយ៉ាងនេះជាដើម ក៏មាន ។ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា បុគ្គល ឈ្មោះថា មាន ព្រោះជាវោហាររបស់លោក ព្រោះការសន្មតរបស់លោក ព្រោះជាភាសារបស់លោក ដោយប្រការដូច្នេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា ម្នាលចិត្ត សម្តីទាំងនេះឯង ជាឈ្មោះសម្រាប់លោក ជាភាសាសម្រាប់លោក ជាវោហាររបស់លោក ជាបញ្ញត្តិក្នុងលោក ដូច្នេះ ក្នុងសេចក្តីនេះ លោកអធិប្បាយថា ធម៌ទាំងឡាយ មានរូបជាដើម សូម្បីវៀរនូវការសន្មតរបស់សត្វលោក ក៏នៅតែឈ្មោះថា មាន ព្រោះមាន

សភាវៈឲ្យដឹងបាន ដោយអំណាចនៃបច្ចត្តលក្ខណៈ និងសាមញ្ញលក្ខណៈ ។

ម្យ៉ាងទៀត កថា គឺពាក្យរបស់ព្រះពុទ្ធទាំងឡាយ មាន ២ យ៉ាង គឺ សម្មតិកថា និងបរមត្ថកថា ក្នុងកថាទាំង ២ នោះ ពាក្យថា សត្វ បុគ្គល ទេវតា ព្រហ្មជាដើម ឈ្មោះថា សម្មតិកថា ពាក្យថា អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន សម្មប្បធានជាដើម ឈ្មោះថា បរមត្ថ-កថា ។ បណ្ដាកថាទាំង ២ នោះ បុគ្គលណា កាលពាក្យថា សត្វ ។បេ។ ឬ ព្រហ្មជាដើម ដែលទ្រង់ត្រាស់ហើយដោយសម្មតិទេសនា អាចត្រាស់ដឹង ចាក់ធ្លុះ ចេញទៅអំពីសង្សារវដ្ដ កាន់យកជ័យជម្នះ គឺអរហត្តបាន ព្រះមានព្រះភាគត្រាស់ពាក្យថា សត្វ ឬបុគ្គល ឬបុរស ឬទេវតា ឬព្រហ្ម ចាប់តាំងអំពីដើមនោះឯងដល់បុគ្គលនោះ ។ ឯបុគ្គលណា ស្ដាប់ពាក្យណាមួយ ក្នុងពាក្យថា អនិច្ចំ ទុក្ខំ ជាដើម ដោយបរមត្ថទេសនាហើយ ក៏អាចត្រាស់ដឹង ចាក់ធ្លុះ ចេញទៅអំពីសង្សារវដ្ដ កាន់យកជ័យជម្នះ គឺអរហត្តបាន ព្រះមានព្រះភាគត្រាស់ពាក្យឯណានីមួយ ក្នុងពាក្យថា អនិច្ចំ ជាដើម ដល់បុគ្គលនោះ ដោយទំនងដូចគ្នា ព្រះមានព្រះភាគមិនត្រាស់បរមត្ថកថាមុន ដល់សត្វដែលនឹងត្រាស់ដឹងដោយសម្មតិកថា តែទ្រង់ឲ្យត្រាស់ដឹងដោយសម្មតិកថាហើយ ទើបទ្រង់ត្រាស់បរមត្ថកថាក្នុងកាលជាខាងក្រោយ ។ ព្រះអង្គមិនត្រាស់សម្មតិកថាមុន ដល់សត្វដែលគួរត្រាស់ដឹង ដោយបរមត្ថកថា តែទ្រង់ឲ្យត្រាស់ដឹងដោយបរមត្ថកថាហើយ ទើបត្រាស់សម្មតិកថា ក្នុងកាលជាខាងក្រោយ ។ ម្យ៉ាងទៀត ដោយប្រក្រតី កាលទ្រង់ត្រាស់សម្មតិកថាមុននោះ

ឯងហើយ ទើបត្រាស់បរមត្ថកថាជាខាងក្រោយ ទេសនា នឹងជារបស់យល់បានងាយ ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយទ្រង់សម្តែងសម្មតិកថាមុនហើយ ត្រាស់បរមត្ថកថាក្នុងកាលជាខាងក្រោយ ។ ព្រះសម្ពុទ្ធទាំងឡាយនោះ សូម្បីត្រាស់ដឹងនូវសម្មតិកថា រមែងត្រាស់នូវសច្ចៈនោះឯង នូវសភាវៈនោះឯង មិនត្រាស់កុហកឡើយ សូម្បីត្រាស់នូវបរមត្ថកថា រមែងត្រាស់នូវសច្ចៈនោះឯង នូវសភាវៈនោះឯង មិនត្រាស់កុហកឡើយ ។ ពិតហើយ បណ្ឌិតគប្បីជ្រាបសេចក្តីនេះថា

បណ្តាអ្នកពោលកថាទាំងឡាយ ព្រះសម្ពុទ្ធដ៏ប្រសើរ
បានត្រាស់ហើយនូវសច្ចៈ ២ គឺសម្មតិសច្ចៈ និងបរមត្ថ-
សច្ចៈ មិនមានសច្ចៈទី ៣ ដូច្នេះ ។

បណ្តាសច្ចៈទាំង ២ នោះ

សម្មតិសច្ចៈ ជាពាក្យសម្រាប់កំណត់ និងជាហេតុនៃការ
សន្មតរបស់លោក ឯបរមត្ថសច្ចៈ ជាពាក្យបរមត្ថ ជា
លក្ខណៈពិតនៃធម៌ទាំងឡាយ ដូច្នេះ ។

ម្យ៉ាងទៀត ទេសនារបស់ព្រះមានព្រះភាគមាន ២ គឺជាបរមត្ថទេសនា ដោយអំណាចនៃ **១ដ្ឋ** ជាដើម និងជាសម្មតិទេសនា ដោយអំណាចនៃថ្នាំងសប្បិជាដើម ដ្បិតថា ព្រះមានព្រះភាគទ្រង់មិនលះបង់លោកសម្មតិ ព្រោះហេតុនោះ បណ្ឌិតមិនគប្បីធ្វើនូវការកាន់យកពាក្យត្រឹមតែថា បុគ្គល មាន ។

ពិតហើយ

ព្រះបរមសាស្តា ទ្រង់មិនលះបង់បញ្ញត្តិ ហើយប្រកាសបរមត្ថ និងមិនបានរំលងនូវវត្ថុ ដែលសត្វលោកសម្មតិ ព្រោះហេតុនោះ បណ្ឌិតដទៃៗ កាលប្រកាសបរមត្ថ ក៏មិនគប្បីរំលងវត្ថុដែលសត្វលោកសន្មត ដូច្នេះ ។

ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាបដិវេធានុយោគ ចប់**

**អដ្ឋកថាបុគ្គលកថា ចប់**

# អភិធម្មបិដក

## បរិហានិកថា

[ ១៩១ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត សាបសូន្យចាកអរហត្ត ក្នុងទីទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្ត ក្នុងទីទាំងពួងឬ ។ អើ ។ សេចក្តីសាបសូន្យ របស់ព្រះអរហន្តក្នុងទីទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត សាបសូន្យចាកអរហត្ត ក្នុងកាលទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្ត ក្នុងកាលទាំងពួងឬ ។ អើ ។ សេចក្តីសាបសូន្យរបស់ព្រះអរហន្ត ក្នុងកាលទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តទាំងអស់ សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តទាំងអស់ សាបសូន្យចាកអរហត្តឬ ។ អើ ។ សេចក្តីសាបសូន្យរបស់ព្រះអរហន្តទាំងអស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩២ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត កាលបើសាបសូន្យចាកអរហត្ត តើសាបសូន្យចាកផលទាំង ៤ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( បើដូច្នេះ ខ្ញុំសួរអ្នកវិញ ) សេដ្ឋីកាលទទួល

នូវភាពជាសេដ្ឋី ព្រោះតែទ្រព្យ ៤ សែន កាលបើទ្រព្យ ១ សែន សាបសូន្យហើយ តើជាអ្នកសាបសូន្យ ចាកភាពជាសេដ្ឋីដែរឬ ។ អើ ។ ( ចុះសេដ្ឋី ) ឈ្មោះថា សាបសូន្យចាកសម្បត្តិទាំងអស់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ សេដ្ឋី កាលទទួលនូវភាពជាសេដ្ឋី ព្រោះតែទ្រព្យ ៤ សែន កាលបើទ្រព្យ ១ សែន សាបសូន្យហើយ តើគួរដើម្បីសាបសូន្យចាកសម្បត្តិទាំងអស់ឬ ។ អើ ។ ( អើ បើដូច្នេះ ) ព្រះអរហន្ត កាលសាបសូន្យចាកអរហត្ត គួរដើម្បីសាបសូន្យចាកផលទាំង ៤ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៣ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៤ ] អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល សាបសូន្យ ចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៥ ] សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។

សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៦ ] សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៧ ] សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគា-មិផលទេឬ ។ អើ ។ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៨ ] សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៩ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត កាលបើសាបសូន្យចាកអរហត្តហើយ នឹងតាំងនៅក្នុងទីណាវិញ ។ ( នឹងតាំងនៅ ) ក្នុងអនាគាមិផល ។ អនាគាមិបុគ្គល កាលបើសាបសូន្យចាកអនាគា-

មិផលហើយ នឹងតាំងនៅក្នុងទីណាវិញ ។ ( នឹងតាំងនៅ ) ក្នុងសកទាគាមិ-ផល ។ សកទាគាមិបុគ្គល កាលបើសាបសូន្យចាកសកទាគាមិផលហើយ នឹងតាំងនៅក្នុងទីណាវិញ ។ ( នឹងតាំងនៅ ) ក្នុងសោតាបត្តិផល ។ សោតា-បន្នបុគ្គល កាលបើសាបសូន្យចាកសោតាបត្តិផល នឹងតាំងនៅក្នុងបុថុជ្ជនភូមិវិញឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរដឹងនូវកំហុស ( របស់អ្នក ) ចុះ ព្រះអរហន្ត កាលបើសាបសូន្យចាកអរហត្តហើយ នឹងតាំងនៅក្នុងអនា-គាមិផលវិញ អនាគាមិបុគ្គល កាលបើសាបសូន្យចាកអនាគាមិផលហើយ នឹងតាំងនៅក្នុងសកទាគាមិផលវិញ សកទាគាមិបុគ្គល កាលបើសាបសូន្យចាកសកទាគាមិផលហើយ នឹងតាំងនៅក្នុងសោតាបត្តិផលវិញ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល កាលបើសាបសូន្យចាកសោតាបត្តិផលហើយ នឹងតាំងនៅក្នុងបុថុជ្ជនភូមិវិញ ដូច្នេះដែរ ។

[ ២០០ ] ព្រះអរហន្ត កាលបើសាបសូន្យចាកអរហត្ត នឹងតាំងនៅក្នុងសោតាបត្តិផលវិញឬ ។ អើ ។ ( ព្រះអរហន្ត ) ធ្វើឲ្យជាក់ច្បាស់នូវអរហត្តក្នុងលំដាប់នៃសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី សោតាបន្ន-បុគ្គលក្តី លោកណាលះកិលេសបានច្រើនជាង ។ ព្រះអរហន្ត ( លះកិលេសបានច្រើនជាង ) ។ បើព្រះអរហន្ត លះកិលេសបានច្រើនជាង ហើយព្រះអរហន្តសាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោល

ថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២០១ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី សកទាគាមិបុគ្គលក្តី លោកណា លះកិលេសបានច្រើនជាង ។ ព្រះអរហន្ត ( លះកិលេសបានច្រើនជាង ) ។ បើព្រះអរហន្ត លះកិលេសបានច្រើនជាង ហើយព្រះអរហន្ត សាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផល ដូច្នេះដែរ ។

[ ២០២ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី អនាគាមិបុគ្គលក្តី លោកណា លះកិលេសបានច្រើនជាង ។ ព្រះអរហន្ត ( លះកិលេសបានច្រើនជាង ) ។ បើព្រះអរហន្ត លះកិលេសបានច្រើនជាង ហើយព្រះអរហន្ត សាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផល ដូច្នេះដែរ ។

[ ២០៣ ] អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គលក្តី សោតាបន្នបុគ្គលក្តី លោកណាលះកិលេសបានច្រើនជាង ។ អនាគាមិបុគ្គល ( លះកិលេសបានច្រើនជាង ) ។ បើអនាគា-

មិបុគ្គល លះកិលេសបានច្រើនជាង ហើយអនាគាមិបុគ្គល សាបសូន្យចាក អនាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២០៤ ] អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គលក្តី សកទាគាមិបុគ្គលក្តី លោកណាលះកិលេសបានច្រើនជាង ។ អនាគាមិបុគ្គល ( លះកិលេសបានច្រើនជាង ) ។ បើអនាគាមិបុគ្គល លះកិលេសបានច្រើនជាង ហើយអនាគាមិបុគ្គល សាបសូន្យចាក អនាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផល ដូច្នេះដែរ ។

[ ២០៥ ] សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ សកទាគាមិបុគ្គលក្តី សោតាបន្នបុគ្គលក្តី លោកណាលះកិលេសបានច្រើនជាង ។ សកទាគាមិបុគ្គល ( លះកិលេសបានច្រើនជាង ) ។ បើសកទាគាមិបុគ្គល លះកិលេសបានច្រើនជាង ហើយសកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២០៦ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

ព្រះអរហន្តក្តី សោតាបន្នបុគ្គលក្តី លោកណា ចម្រើនមគ្គច្រើនជាង ។ ព្រះអរហន្ត ( ចម្រើនមគ្គច្រើនជាង ) ។ បើព្រះអរហន្ត ចម្រើនមគ្គច្រើនជាង ហើយព្រះអរហន្តសាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២០៧ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី សោតាបន្នបុគ្គលក្តី លោកណា ចម្រើនសតិប្បដ្ឋានបានច្រើនជាង ។បេ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពល ចម្រើនពោជ្ឈង្គច្រើនជាង ។ ព្រះអរហន្ត ( ចម្រើនច្រើនជាង ) ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គច្រើនជាង ហើយព្រះអរហន្ត សាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២០៨ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី សកទាគាមិបុគ្គលក្តី លោកណា ចម្រើនមគ្គច្រើនជាង ។បេ។ ចម្រើនពោជ្ឈង្គច្រើនជាង ។ ព្រះអរហន្ត ( ចម្រើនច្រើនជាង ) ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គច្រើនជាង ហើយព្រះអរហន្តសាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គលសាប

សុទ្ធប្រាកសកទាគាមិផល ដូច្នេះដែរ ។

[ ២០៩ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តក្តី អនាគាមិបុគ្គលក្តី លោកណាចម្រើនមគ្គច្រើនជាង ។បេ។ ចម្រើនពោជ្ឈង្គច្រើនជាង ។ ព្រះអរហន្ត ( ចម្រើនច្រើនជាង ) ។ បើព្រះអរហន្តចម្រើនពោជ្ឈង្គច្រើនជាង ហើយព្រះអរហន្ត សាបសូន្យចាកអរហត្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផល ដូច្នេះដែរ ។

[ ២១០ ] អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គលក្តី សោតាបន្នបុគ្គលក្តី លោកណាចម្រើនមគ្គច្រើនជាង ។បេ។ ចម្រើនពោជ្ឈង្គច្រើនជាង ។ អនាគាមិបុគ្គល ( ចម្រើនច្រើនជាង ) ។ បើអនាគាមិបុគ្គល ចម្រើនពោជ្ឈង្គច្រើនជាង ហើយអនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២១១ ] អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គលក្តី សកទាគាមិបុគ្គលក្តី លោកណាចម្រើនមគ្គច្រើនជាង ។បេ។ ចម្រើនពោជ្ឈង្គច្រើនជាង ។ អនាគាមិបុគ្គល ( ចម្រើន

ច្រើនជាង ) ។ បើអនាគាមិបុគ្គល ចម្រើនពោជ្ឈង្គច្រើនជាង ហើយអនាគាមិបុគ្គលសាបសូន្យចាកអនាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផល ដូច្នេះដែរ ។

[ ២១២ ] សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ សកទាគាមិបុគ្គលក្តី សោតាបន្នបុគ្គលក្តី លោកណាចម្រើនមគ្គច្រើនជាង ។បេ។ ចម្រើនពោជ្ឈង្គច្រើនជាង ។ សកទាគាមិបុគ្គល ( ចម្រើនច្រើនជាង ) ។ បើសកទាគាមិបុគ្គល ចម្រើនពោជ្ឈង្គច្រើនជាង ហើយសកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផល ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផល ដូច្នេះដែរ ។

[ ២១៣ ] ព្រះអរហន្តឃើញនូវទុក្ខសច្ច ហើយព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវទុក្ខសច្ច ហើយសោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ឃើញនូវសមុទយសច្ច ហើយព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវសមុទយសច្ច ហើយសោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តឃើញនូវនិរោធសច្ច ហើយព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវនិរោធសច្ច ហើយ

សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ឃើញនូវមគ្គហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវមគ្គហើយ សោតាបន្នបុគ្គលសាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ឃើញនូវសច្ចៈ ៤ ហើយព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវសច្ចៈ ៤ ហើយសោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៤ ] ព្រះអរហន្តឃើញទុក្ខសច្ចហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល ឃើញនូវទុក្ខសច្ចហើយ សកទាគាមិបុគ្គលសាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធសច្ច ។បេ។ ឃើញនូវមគ្គ ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គលសាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៥ ] ព្រះអរហន្តឃើញនូវទុក្ខសច្ចហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ចហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធសច្ច ។បេ។ ឃើញនូវមគ្គ ។បេ។ ឃើញនូវសច្ចៈ ៤ ហើយព្រះអរហន្ត សាបសូន្យចាកអរហត្ត

ឬ ។ អើ ។ អនាគាមិបុគ្គល ឃើញនូវសច្ចៈ ៤ ហើយ អនាគាមិបុគ្គលសាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៦ ] អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ចហើយ អនាគាមិបុគ្គលសាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវទុក្ខសច្ចហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល ឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធ-សច្ច ។បេ។ ឃើញនូវមគ្គ ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ អនាគាមិបុគ្គលសាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវសច្ចៈ ៤ ហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ចហើយ អនាគា-មិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គលឃើញនូវទុក្ខសច្ចហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល ឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធសច្ច ។បេ។ ឃើញនូវមគ្គ ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគា-មិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៧ ] សកទាគាមិបុគ្គល ឃើញនូវទុក្ខសច្ចហើយ សកទាគាមិបុគ្គលសាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវទុក្ខ-

សច្ចហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល ឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធសច្ច ។បេ។ ឃើញនូវមគ្គ ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល ឃើញនូវសច្ចៈ ៤ ហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៨ ] សោតាបន្នបុគ្គល ឃើញនូវទុក្ខសច្ចហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្ត ឃើញនូវទុក្ខសច្ចហើយ ព្រះអរហន្តមិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល ឃើញនូវសមុទយសច្ច ។បេ។ ឃើញនូវនិរោធសច្ច ។បេ។ ឃើញនូវមគ្គសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្តឃើញនូវសច្ចៈ ៤ ហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៩ ] សកទាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត ឃើញនូវសច្ចៈ ៤ ហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២០ ] អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤

ហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត ឃើញនូវសច្ចៈ ៤ ហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២១ ] សោតាបន្នបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២២ ] សកទាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ អនាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៣ ] សោតាបន្នបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ សកទាគាមិបុគ្គល ឃើញនូវទុក្ខសច្ច ។បេ។ ឃើញនូវសច្ចៈ ៤ ហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៤ ] ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្ត សាបសូន្យចាក

អរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា ។បេ។ លះសីលព្វតបរាមាសៈ ។បេ។ លះរាគៈ ដែលជាដំណើរទៅកាន់អបាយ ។បេ។ លះទោសៈដែលជាដំណើរទៅកាន់អបាយ ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ លះមានះ លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈ លះអហិរិកៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះអនោត្តប្បៈហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា ។បេ។ លះសីលព្វតបរាមាសៈ ។បេ។ លះរាគៈ ដែលជាដំណើរទៅកាន់អបាយ ។បេ។ លះទោសៈ ដែលជាដំណើរទៅកាន់អបាយ ។បេ។ លះមោហៈដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៥ ] ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិ-

បុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះសីលព្វតបរាមាសៈ ។បេ។ លះកាមរាគដ៏គ្រោតគ្រាត ។បេ។ លះព្យាបាទដ៏គ្រោតគ្រាតហើយ សកទា-គាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទា-គាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៦ ] ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះរាគៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនា-គាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះសីលព្វតបរាមាសៈ លះកាមរាគដ៏ស្រាលស្តើង លះព្យាបាទដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ អនាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។

[ ២២៧ ] អនាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គលសាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះព្យាបាទ ដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៨ ] អនាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល លះសក្កាយទិដ្ឋិ ហើយអនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះសីលព្វតបរាមាសៈ លះកាមរាគដ៏គ្រោតគ្រាត លះព្យាបាទ ដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះព្យាបាទដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល សាបសូន្យចាកអនាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៩ ] សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិ-បុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្ន-បុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះកាមរាគដ៏គ្រោតគ្រាត លះព្យាបាទដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល សាបសូន្យចាកសកទាគាមិផលឬ ។ អើ ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល សាបសូន្យចាកសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣០ ] សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈហើយ

ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣១ ] សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះព្យាបាទដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣២ ] អនាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះព្យាបាទ ដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អើ ។ ព្រះអរហន្ត លះរាគៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៣ ] សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ អនាគាមិបុគ្គល លះសក្កាយ-ទិដ្ឋិ ។បេ។ លះព្យាបាទ ដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្ន-បុគ្គល លះវិចិកិច្ឆា ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ អនាគា-មិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទដ៏ស្រាលស្តើងហើយ អនាគា-មិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៤ ] សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ អនាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល លះវិចិកិច្ឆា ។បេ។ លះព្យាបាទ ដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អើ ។ អនាគា-

មិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទ ដ៏ស្រាលស្តើងហើយ អនាគាមិបុគ្គល មិនសាបសូន្យចាកអនាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៥ ] សោតាបន្នបុគ្គល លះសក្កាយទិដ្ឋិហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទ ដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល លះវិចិកិច្ឆា ។បេ។ លះមោហៈ ដែលជាដំណើរទៅកាន់អបាយហើយ សោតាបន្នបុគ្គល មិនសាបសូន្យចាកសោតាបត្តិផលទេឬ ។ អើ ។ សកទាគាមិបុគ្គល លះសក្កាយទិដ្ឋិ ។បេ។ លះព្យាបាទ ដ៏គ្រោតគ្រាតហើយ សកទាគាមិបុគ្គល មិនសាបសូន្យចាកសកទាគាមិផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៦ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត លះរាគៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៣៧ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ លះមានះ លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈ លះអហិរិកៈ លះអនោត្តប្បៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាពឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៣៨ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនមគ្គដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៣៩ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។បេ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពល ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៤០ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះអនោត្តប្បៈ ។បេ។

ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះអនាគតប្បរ: ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៤១ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ មានមោហៈទៅប្រាសហើយ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ ដោយលំដាប់ មានភវ សំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារគឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកហើយ មិនមានគន្លឹះទ្វារ ជាព្រះអរិយៈ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជ័យជម្នះ ឈ្នះល្អហើយ ព្រះអរហន្តនោះ បានកំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ធម៌ដែលគួរត្រាស់ដឹង ព្រះអរហន្តនោះ បានត្រាស់ដឹងហើយ ធម៌ដែលគួរកំណត់ដឹង ព្រះអរហន្តនោះ បានកំណត់ដឹងហើយ ធម៌ដែលគួរលះ ព្រះអរហន្តនោះ បានលះហើយ ធម៌ដែលគួរចម្រើន ព្រះអរហន្តនោះបានចម្រើនហើយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។បេ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះដែរ ។

[ ២៨២ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ ព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្ត ព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ ព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៨៣ ] ព្រះអរហន្ត ជាសមយវិមុត្ត លះរាគៈហើយ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត លះរាគៈហើយ ព្រះអរហន្តជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាសមយវិមុត្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្តជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះរាគៈហើយ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះរាគៈហើយ ព្រះអរហន្តជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្ត

ជាសមយវិមុត្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។បេ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពល ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាសមយវិមុត្ត ចម្រើនមគ្គដើម្បីលះទោសៈ ។បេ។ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៤ ] ព្រះអរហន្តជាសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ មានមោហៈទៅប្រាសហើយ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ ដោយលំដាប់ មានភពនិងសញ្ញោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារ គឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកហើយ មិនមានគន្លឹះទ្វារ ជាព្រះអរិយៈ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជ័យជម្នះ ឈ្នះល្អហើយ ព្រះអរហន្តនោះ បានកំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ធម៌ដែលគួរត្រាស់ដឹង

ព្រះអរហន្តនោះ បានត្រាស់ដឹងហើយ ធម៌ដែលគួរកំណត់ដឹង ព្រះអរហន្តនោះ បានកំណត់ដឹងហើយ ធម៌ដែលគួរលះ ព្រះអរហន្តនោះ បានលះហើយ ធម៌ដែលគួរចម្រើន ព្រះអរហន្តនោះ បានចម្រើនហើយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះអរហន្តជាសមយ-វិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តជាអសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។បេ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្តជាអសមយវិមុត្ត សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៥ ] ព្រះអរហន្តជាអសមយវិមុត្ត លះរាគៈហើយ ព្រះអរហន្តជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្តជាសមយ-វិមុត្ត លះរាគៈហើយ ព្រះអរហន្តជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាអសមយវិមុត្ត លះទោសៈ ។បេ។ លះអនោត្តប្បៈហើយ ព្រះអរហន្តជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្តជាសមយវិមុត្ត លះអនោត្តប្បៈហើយ ព្រះអរហន្តជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាអសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្តជាសមយវិមុត្ត ចម្រើនមគ្គ

ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាអសមយវិមុត្ត ចម្រើនមគ្គដើម្បីលះទោសៈ ។បេ។ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្តជាសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គហើយ ព្រះអរហន្តជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្តជាអសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។បេ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្តជាសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។បេ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៦ ] ព្រះអរហន្តសាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះសារីបុត្តត្ថេរសាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ព្រះមហាបណ្ឌកត្ថេរ សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះសារីបុត្តត្ថេរ មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។

បើព្រះសារីបុត្តត្ថេរ មិនសាបសូន្យចាកអរហត្តទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្តដូច្នេះទេ ។ ព្រះមហាមោគ្គ-ល្លានត្ថេរ ... ព្រះមហាកស្សបត្ថេរ ... ព្រះមហាកច្ចាយនត្ថេរ ... មហាកោដ្ឋិកត្ថេរ ... ព្រះមហាបណ្ណកត្ថេរ មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ បើព្រះមហា-មោគ្គល្លានត្ថេរ ... ។បេ។ ព្រះមហាបណ្ណកត្ថេរ មិនសាបសូន្យចាកអរហត្តទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៤៧ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគបានត្រាស់ថា

សេចក្ដីប្រតិបត្តិខ្ពស់ និងទាប ព្រះសមណៈប្រកាស
ហើយ ( សត្វទាំងឡាយ ) មិនដល់នូវត្រើយ គឺព្រះ
និព្វានពីរដងទេ ត្រើយ គឺព្រះនិព្វាននេះ ពួកសត្វ មិន
ដែលពាល់ត្រូវអស់វារៈម្ដងឡើយ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[ ២៤៨ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្តដែលមានកិលេសវដ្ដៈកាត់ហើយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្ត ដែលមានកិលេសវដ្ដៈកាត់ហើយ មានឬ ។ អើ ។ ក្រែង

ព្រះមានព្រះភាគបានត្រាស់ថា

កិច្ចនៃបុគ្គលណា មិនមាន ( បុគ្គលនោះ ) មានតណ្ហា
ទៅប្រាសហើយ មិនមានសេចក្តីប្រកាន់ទេ ធម្មជាតតិច
តួចដែលគេគប្បីកាត់ របស់បុគ្គលដែលមានកិលេសវដ្ដៈ
កាត់ហើយ មិនមានឡើយ ( ព្រោះ ) បុគ្គលនោះ
បានដកចោលហើយ នូវអន្ទង់ និងអន្ទាក់ គឺកិលេស ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្ត ដែលមានកិលេសវដ្ដៈកាត់ហើយ មានដូច្នេះទេ ។

[ ២៤៩ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ការចម្រើនមគ្គ ដែលបុគ្គលបានចម្រើនរួចហើយ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ការចម្រើនមគ្គ ដែលបុគ្គលបានចម្រើនរួចហើយ មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា

ភិក្ខុ អ្នកមានចិត្តរួចស្រឡះ អ្នកមានចិត្តស្ងប់រម្ងាប់នោះ
រមែងមិនមានការចម្រើនមគ្គ ដែលបានចម្រើនរួចហើយ
ទេ ទាំងកិច្ចដែលគួរធ្វើ ក៏មិនមានឡើយ ថ្មតាន់មួយដុំ
រមែងមិនកម្រើកញាប់ញ័រដោយខ្យល់ យ៉ាងណា រូប រស
សំឡេង ក្លិន ផស្សៈទាំងអស់ ទាំងពួកធម៌ដែលគួរប្រាថ្នា
និងមិនគួរប្រាថ្នា ក៏រមែងមិនញ៉ាំងចិត្តដែលរួចស្រឡះ ជា

ចិត្តនឹងធឹង របស់តាទិបុគ្គល ឲ្យញាប់ញ័រ យ៉ាងនោះ
ដែរ ម្យ៉ាងទៀត ( តាទិបុគ្គលនោះ ) ឃើញរឿយៗ នូវ
ការសូន្យនៃចិត្តនោះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ការចម្រើនមគ្គ ដែលបុគ្គលបានចម្រើនហើយ មានដូច្នេះទេ ។

[ ២៥០ ] អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្តទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសមយ-វិមុត្ត មានធម៌ ៥ នេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ ធម៌ ៥ នោះដូចម្ដេចខ្លះ សេចក្ដីត្រេកអរ ក្នុងការងារ ១ សេចក្ដីត្រេកអរ ក្នុងតិរច្ឆានកថា ១ សេចក្ដីត្រេកអរ ក្នុងការដេកលក់ ១ សេចក្ដីត្រេកអរ ក្នុងពួកបន ១ ភិក្ខុជាសមយវិមុត្ត មិនពិចារណានូវចិត្តដែលរួចស្រឡះហើយ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសមយវិមុត្ត មានធម៌ទាំង ៥ នេះឯង ប្រព្រឹត្តដើម្បីសេចក្ដីសាបសូន្យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ ព្រះអរហន្ត សាបសូន្យចាកអរហត្តដែរឬ ។

[ ២៥១ ] ព្រះអរហន្ត មានសេចក្ដីត្រេកអរក្នុងការងារដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្ដីត្រេកអរក្នុងការងារឬ ។ អើ ។ ព្រះអរហន្ត មានរាគៈ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្ដីត្រេកអរក្នុងតិរច្ឆានកថា ព្រះអរហន្ត មាន

សេចក្តីត្រេកអរក្នុងការដេកលក់ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងពួកបទ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងពួកបទឬ ។ អើ ។ ព្រះអរហន្ត មានរាគៈ កាមរាគៈ កាមរាគបរិយុដ្ឋាន កាម-រាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥២ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត កាលសាបសូន្យចាកអរហត្ត តើគ្របសង្កត់អ្វី ទើបបានសាបសូន្យ ។ ព្រះអរហន្ត គ្របសង្កត់រាគៈ ទើបបានសាបសូន្យ ។ បរិយុដ្ឋានក្កិលេស អាស្រ័យអ្វី ទើបកើតឡើងបាន ។ អាស្រ័យនូវអនុស័យ ទើបកើតឡើងបាន ។ ព្រះអរហន្ត មានអនុស័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអនុស័យឬ ។ អើ ។ ព្រះអរហន្ត មានកាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ អវិជ្ជានុស័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត គ្របសង្កត់ទោសៈ ទើបបានសាបសូន្យឬ ។បេ។ គ្របសង្កត់មោហៈ ទើបបានសាបសូន្យឬ ។ បរិ-យុដ្ឋានក្កិលេស អាស្រ័យអ្វី ទើបកើតឡើងបាន ។ អាស្រ័យអនុស័យ ទើបកើតឡើងបាន ។ ព្រះអរហន្ត មានអនុស័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអនុស័យឬ ។ អើ ។ ព្រះអរហន្ត មានកាមរាគា-នុស័យ ។បេ។ អវិជ្ជានុស័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៣ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ កាលព្រះ

អរហន្តសាបសូន្យចាកអរហត្ត តើអ្វីដល់នូវការដុះដាលឡើង ។ រាគៈដល់នូវការដុះដាលឡើង ។ សក្កាយទិដ្ឋិ ដល់នូវការដុះដាលឡើងឬ ។ វិចិកិច្ឆា ដល់នូវការដុះដាលឡើងឬ ។ សីលព្វតបរាមាសៈ ដល់នូវការដុះដាលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទោសៈដល់នូវការដុះដាលឡើងឬ ។បេ។ មោហៈដល់នូវការដុះដាលឡើងឬ ។ សក្កាយទិដ្ឋិ ដល់នូវការដុះដាលឡើងឬ ។ វិចិកិច្ឆា ដល់នូវការដុះដាលឡើងឬ ។ សីលព្វតបរាមាសៈ ដល់នូវការដុះដាលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៨ ] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្តសន្សំឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រាសចាកការសន្សំឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត លះបង់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រកាន់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត កកាយចេញឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត កៀរគរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត កម្ចាត់ចេញឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រមូលមកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះអរហន្ត មិនសន្សំ មិនប្រាសចាកការសន្សំ ស្ថិតនៅនឹង ព្រោះប្រាសចាកការសន្សំឬ ។ អើ ។ បើព្រះអរហន្ត មិនសន្សំ មិនប្រាសចាកការសន្សំ ស្ថិតនៅនឹង ព្រោះប្រាសចាកការសន្សំ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្តសាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់

ស្ថិតនៅនឹង ព្រោះលះបង់ឬ ។ អើ ។ បើព្រះអរហន្ត មិនលះបង់ មិនប្រកាន់ ស្ថិតនៅនឹង ព្រោះលះបង់ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនកកាយចេញ មិនកៀរគរ ស្ថិតនៅនឹង ព្រោះកកាយចេញឬ ។ អើ ។ បើព្រះអរហន្ត មិនកកាយចេញ មិនកៀរគរ ស្ថិតនៅនឹង ព្រោះកកាយចេញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក ស្ថិតនៅនឹង ព្រោះកម្ចាត់ចេញឬ ។ អើ ។ បើព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក ស្ថិតនៅនឹង ព្រោះកម្ចាត់ចេញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

**បរិហានិកថា ចប់**

# អដ្ឋកថា

# បរិហានិកថា

## វាទយុត្តិបរិហានិ

[ ១៩១ ] ឥឡូវនេះ នឹងពោលអំពីការសាបសូន្យដូចតទៅ

បរិហានិធម៌ក៏មាន អបរិហានិធម៌ក៏មាន និកាយសមិតិយៈ និកាយវជ្ជីបុត្តកៈ និកាយសព្វត្ថិកវាទី និងនិកាយមហាសង្ឃិកៈពួកខ្លះ អាស្រ័យព្រះសូត្រទាំងឡាយ ( ក្នុងអង្គុត្តរនិកាយ ទុកនិបាត ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យ នៃសេក្ខភិក្ខុ ដូច្នេះជាដើម និងព្រះសូត្រ ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសមយវិមុត្ត ដូច្នេះជាដើម រមែងប្រកាន់ថា សូម្បីព្រះអរហន្តក៏សាបសូន្យបាន ព្រោះហេតុនោះ និកាយទាំងនោះក្តី និកាយដទៃនោះឯងក្តី លទ្ធិ គឺការប្រកាន់ខុសនេះ រមែងមានដល់ជនពួកណា សកវាទីដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសួរបរវាទីថា **បរិហាយតិ អរហា អរហត្តា** ដូច្នេះ ។ ក្នុងពាក្យសួរទាំងនោះ បទថា **បរិហាយតិ** បានដល់ ការវិនាស ២ យ៉ាង គឺ **បត្តបរិហានិ** ការវិនាសចាកធម៌ដែលធ្លាប់សម្រេចហើយ និង **អប្បត្តបរិហានិ** ការវិនាសចាកធម៌ដែលមិនទាន់សម្រេច ។ ក្នុងការវិនាសទាំងនោះ ការវិនាសនេះថា ព្រះគោធិកៈមានអាយុ សាបសូន្យចាកចេតោវិមុត្តិ

ប្រកបតាមកាលវេលានោះ អស់វារៈជាគម្រប់ពីរដងទៀត[១] ដូច្នេះ ហៅថា **បត្តបរិហានិ** ។ សេចក្ដីវិនាសនេះថា កាលបើអ្នកទាំងឡាយត្រូវការនូវភាពជាសមណៈ កុំលះបង់ប្រយោជន៍ជារបស់សមណៈឡើយ[២] ហៅថា **អប្បត្តបរិហានិ** ។ ក្នុងការវិនាសទាំង ២ នោះ ក្នុងទីនេះ លោកបំណងយក **បត្តបរិហានិ** ។ ពាក្យឆ្លើយទទួលថា **អាមន្តា** ដោយសំដៅយកការវិនាសចាកធម៌ដែលបានសម្រេចហើយ នេះជាពាក្យរបស់បរវាទី ។ តែក្នុងលទ្ធិរបស់សកវាទី លោករមែងកាន់យកការវិនាសចាកធម៌ ដែលសម្រេចហើយនេះ ដោយលោកិយសមាបត្តិប៉ុណ្ណោះ មិនមែនដោយសាមញ្ញផលទាំងឡាយ មានអរហត្តផលជាដើម ។ ក្នុងលទ្ធិរបស់បរវាទី ពួកលោកក៏មិនកាន់យកការវិនាសនោះ ក្នុងសាមញ្ញផលទាំងពួង ក្នុងភពទាំងពួង ក្នុងកាលទាំងពួង និងដល់បុគ្គលទាំងពួង ពិតហើយ លទ្ធិនោះ ក៏ត្រឹមតែជាលទ្ធិនៃពួកលោកប៉ុណ្ណោះ ព្រោះហេតុនោះ ដើម្បីទម្លាយសំណាញ់ គឺលទ្ធិដែលខុសទាំងពួង ទើបសកវាទីពង្រីករឿងតទៅទៀត ដោយន័យជាដើមថា **សព្វត្ថ** ។ ក្នុងបញ្ហាទាំងនោះ ព្រោះបរវាទីមិនកាន់យកសេចក្ដីវិនាសចាកអរហត្តផល របស់ព្រះអរហន្តដែលវិនាសមកដោយលំដាប់ ហើយក៏ឈប់នៅក្នុងសោតាបត្តិផល តែកាន់យកសេចក្ដីវិនាសរបស់ព្រះអរិយៈ ដែលតាំងនៅក្នុងផលទាំងឡាយខាងលើប៉ុណ្ណោះ ម្យ៉ាងទៀត ព្រោះមិនកាន់យកសេចក្ដីវិនាសរបស់ព្រះអរហន្តដែលតាំងនៅក្នុងរូបភព និងអរូបភពទាំងឡាយ តែកាន់យកសេចក្ដីវិនាស

---

១- សំយុត្តនិកាយ សគាថវគ្គ ។ ២- មជ្ឈិមនិកាយ មូលបណ្ណាសក ។

របស់ព្រះអរហន្តដែលតាំងនៅក្នុងកាមភពប៉ុណ្ណោះ ព្រោះមានធម៌ទាំងឡាយដែលជាទីតាំងនៃសេចក្ដីវិនាស មានការត្រេកអរក្នុងការងារជាដើម ព្រោះហេតុនោះ កាលត្រូវសកវាទីសួរថា **សព្វត្ថ** ទើបលោកបដិសេធ កាលត្រូវសួរធ្វើឲ្យមាំដដែលទៀត លោកក៏ឆ្លើយទទួល ដោយសំដៅយកកាមភព ។ ពិតហើយ មានកាមគុណ ដែលធ្វើនូវការវិនាសក្នុងកាមភពទាំងអស់ ព្រោះហេតុនោះ ទើបសកវាទីមានលទ្ធិថា វិនាសបាន ក្នុងពាក្យសួរនេះ ។

ក្នុងពាក្យសួរទី ៣ ដោយពាក្យថា **បរិហានិ** សកវាទី សួរដល់ធម៌ដែលធ្វើសេចក្ដីវិនាស ក្នុងពាក្យទាំងនោះ ព្រោះធម៌ មានសេចក្ដីត្រេកអរក្នុងការងារជាដើម ឈ្មោះថា ហេតុវិនាស ឬពោលដោយពិសេស ក៏គឺកាមរាគៈ និងព្យាបាទនោះឯង ធម៌ទាំងនោះ រមែងមិនមានក្នុងរូបភព និងអរូបភព ហេតុនោះ ទើបបរវាទីបដិសេធថា **ន ហេវំ** ។

បទថា **សព្វទា** ជាពាក្យសួរដល់កាល ។ ក្នុងបទទាំងនោះ បញ្ហាទី ១ បរវាទីបដិសេធ ព្រោះមិនមានសេចក្ដីវិនាស ក្នុងវេលាធ្វើទុកក្នុងចិត្តដោយឧបាយ ។ ក្នុងបញ្ហាទី ២ បរវាទីឆ្លើយទទួល ព្រោះមានសេចក្ដីវិនាសក្នុងកាលទាំងពួង មិនថាជាពេលយប់ ឬជាពេលថ្ងៃ ដល់បុគ្គលដែលមិនធ្វើទុកក្នុងចិត្តដោយឧបាយ ។ ក្នុងបញ្ហាទី ៣ បរវាទីឆ្លើយបដិសេធ ដោយគិតថា កាលមានការជួបជាមួយធម៌ ដែលធ្វើសេចក្ដីវិនាស រមែងមានសេចក្ដីវិនាសត្រឹមមួយស្របក់ប៉ុណ្ណោះ បន្ទាប់អំពីនោះ ឈ្មោះថា សេចក្ដីវិនាសរបស់ព្រះអរហន្ត ដែលមិនវិនាសក្នុងពេលដំបូង ឬដែលវិនាសហើយ ក្នុងពេលក្រោយ

រមែងមិនមាន ។

ក្នុងបញ្ហាដំបូងថា **សព្វេ អរហន្តា** បរវាទីឆ្លើយបដិសេធ ដោយសំដៅដល់ លោកដែលមានឥន្ទ្រិយចាស់ក្លា ។ ក្នុងបញ្ហាទី ២ ឆ្លើយទទួល ដោយសំដៅដល់ លោកអ្នកដែលមានឥន្ទ្រិយទន់ខ្សោយ ។ ក្នុងបញ្ហាទី ៣ ក៏បំណងយក លោកអ្នកដែលមានឥន្ទ្រិយចាស់ក្លានោះឯង ។ បរវាទីនោះ មានលទ្ធិថា ហេតុវិនាស រមែងមានដល់ព្រះអរហន្តទាំងពួងនោះ ។

[ ១៩២ ] ក្នុងការលើករឿងសេដ្ឋីឡើងពោល ពាក្យដំបូង ជាពាក្យរបស់បរវាទី ពាក្យសួរទី ២ ជាពាក្យរបស់សកវាទី ។ ក្នុងរឿងនេះ មានពាក្យអធិប្បាយដូចតទៅ បរវាទីពោលថា អ្នកសួរខ្ញុំ ដល់បញ្ហាណាថា ព្រះអរហន្ត កាលបើសាបសូន្យចាកអរហត្តផល តើសាបសូន្យចាកផលទាំង ៤ ដែរឬ ក្នុងបញ្ហានោះ ខ្ញុំសូមសាកសួរជាមួយអ្នកថា សេដ្ឋី កាលទទួលនូវភាពជាសេដ្ឋី ដោយទ្រព្យ ៤ សែន កាលបើទ្រព្យ ១ សែន សាបសូន្យហើយ តើជាអ្នកសាបសូន្យចាកភាពជាសេដ្ឋីដែរឬ ដូច្នេះ ។ លំដាប់នោះ សកវាទីសំដៅដល់ការវិនាសដោយចំណែកមួយ ទើបឆ្លើយទទួលថា **អាមន្តា** ទើបបរវាទីសួរថា **សព្វសាបតេយ្យា បរិហីនោ ហោតិ** ។ សកវាទីពោលថា **ន ហេវំ** ព្រោះមិនមានការវិនាសយ៉ាងនោះ ទើបពេលនោះ សួរបរវាទីនោះដល់បញ្ហាទី ២ ដែលជាបញ្ហាសមគួរសួរ ដែលជាលទ្ធិកើតឡើងថា សូម្បីតែព្រះអរហន្តរមែងវិនាសបានយ៉ាងនេះឯង តែមិនវិនាសអស់ចាកផលទាំង ៤ បរវាទី កាលមិនឃើញភាពពិតប្រាកដ ព្រោះភាពដែលមិនគួរជាសេដ្ឋី

ទើបឆ្លើយទទួល ត្រូវសកវាទីសាកសួរដល់ភាពដែលព្រះអរហន្ត ជាអ្នកគួរវិនាសចាកផលទាំង ៤ ជាអ្នកកាន់យកអត្ថដោយមិនពិចារណាហើយ តាំងនៅក្នុងលទ្ធិនៃពាក្យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា ជាបុគ្គលទៀងទាត់ មានកិរិយាត្រាស់ដឹងទៅខាងមុខ ដូច្នេះ ទើបបដិសេធ ដោយសំដៅយកភាពមិនគួរវិនាសចាកសោតាបត្តិផល ។ ពាក្យនោះ ត្រឹមតែជាលទ្ធិរបស់បរវាទីប៉ុណ្ណោះ ៕៚

ឈ្មោះថា វាទយុត្តិ គឺការប្រកបវាទៈ ចប់ហើយ
ដោយពាក្យមានប្រមាណប៉ុណ្ណោះឯង

# អដ្ឋកថា

## អរិយបុគ្គលសំសន្ទនបរិហានិ

[ ១៩៣ ] ឥឡូវនេះ ជាការប្រារព្ធការប្រៀបធៀបរវាងព្រះអរិយបុគ្គល ។ ក្នុងបញ្ហានោះ និកាយខ្លះប្រកាន់ថា ព្រះអរហន្តប៉ុណ្ណោះ វិនាសបាន និកាយខ្លះប្រកាន់ថា សូម្បីព្រះអនាគាមីក៏វិនាសបាន និកាយខ្លះប្រកាន់ថា សូម្បីព្រះសកទាគាមីក៏វិនាសបាន តែនិកាយទាំងអស់ រមែងប្រកាន់ថា ព្រះសោតាបន្ន មិនវិនាសឡើយ ។ និកាយខ្លះ រមែងកាន់យកការវិនាសរបស់ព្រះអរហន្ត ដែលវិនាសចាកភាពជាព្រះអរហន្ត ហើយតាំងនៅក្នុងភាវៈជាភូមិនៃព្រះអនាគាមី និងព្រះសកទាគាមី រមែងមិនកាន់យកការវិនាសរបស់ព្រះអនាគាមី និងព្រះសកទាគាមីក្រៅអំពីព្រះអរហន្តនេះ តែនិកាយទាំងនោះ រមែងមិនកាន់យកការវិនាសរបស់ព្រះសោតបន្ន ក្នុងកាលទាំងពួងឡើយ ព្រោះហេតុនោះ ទើបលោកធ្វើពាក្យសួរដោយមាតិកា ទំនងដូចគ្នា ជាបែបផែន ។ ក្នុងបញ្ហាទាំងនោះ បណ្ឌិតគប្បីជ្រាបនូវពាក្យទទួល និងពាក្យបដិសេធ ដោយអំណាចនៃលទ្ធិរបស់លោកទាំងអស់នោះ ។ ក្នុងបញ្ហាថា ព្រះអនាគាមី សាបសូន្យចាកអនាគាមិផលឬ ជនដែលមិនកាន់យកថា ព្រះអនាគាមីវិនាសបាន រមែងបដិសេធ ជនដែលកាន់យកថា ព្រះអនាគាមីប្រក្រតី ឬព្រះអនាគាមីដែលសាបសូន្យចាកអរហត្តហើយ តាំងនៅក្នុងភាវៈនៃអនាគាមិភូមិ វិនាសបាន រមែងឆ្លើយទទួល ។ ក្នុងបញ្ហានេះ គប្បីជ្រាបនយមុខដូច្នេះឯង ។ បណ្ឌិតគប្បីជ្រាប បេយ្យាលទាំងពួង ដោយអត្ថតាមទំនងរបស់នយមុខនោះចុះ ។

[ ២០០ ] ម្យ៉ាងទៀត ពាក្យណា ដែលសកវាទីពោលហើយក្នុងបញ្ហានោះថា ( ព្រះអរហន្ត ) ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ក្នុងលំដាប់នៃសោតាបត្តិផលឬ ពាក្យនោះ លោកពោលសំដៅយកការកើតឡើងនៃអរហត្តរបស់ព្រះអរហន្តដែលសាបសូន្យ ហើយធ្វើនូវសេចក្ដីព្យាយាមទៀត បរវាទីឆ្លើយបដិសេធ ព្រោះមិនមានភាពជាព្រះអរហន្ត ក្នុងលំដាប់នៃសោតាបត្តិផល ។ ខាងមុខអំពីនេះ ដើម្បីសាកសួរដោយន័យថា ឈ្មោះថា ការសាបសូន្យនេះគប្បីមាន ព្រោះការលះកិលេសតិចតួច ឬព្រោះការមិនត្រាស់ដឹងដោយមគ្គភាវនាជាដើម ឬព្រោះមិនឃើញសច្ចៈទាំងឡាយ ទើបសកវាទីពោលថា លោកណា លះកិលេសបានច្រើនជាង ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះមានសេចក្ដីអធិប្បាយងាយយល់ហើយ ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះសូត្រទាំងឡាយ ដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាព្រះសូត្រទាំងឡាយ ដែលមកហើយនោះឯង ។

[ ២៤២ ] ក្នុងពាក្យថា ព្រះអរហន្តជាសមយវិមុត្តិ សាបសូន្យចាកអរហត្តផល នេះជាលទ្ធិរបស់និកាយទាំងនោះថា ព្រះអរហន្តដែលមានឥន្ទ្រិយទន់ខ្សោយ ឈ្មោះថា សមយវិមុត្តបុគ្គល ព្រះអរហន្តដែលមានឥន្ទ្រិយចាស់ក្លា ឈ្មោះថា អសមយវិមុត្តបុគ្គល ដូច្នេះ តែក្នុងលទ្ធិរបស់សកវាទីជាក់គោលថា

បុគ្គលដែលជាឈានលាភី មិនសម្រេចវសី ឈ្មោះថា សមយវិមុត្តបុគ្គល បុគ្គលជាឈានលាភីសម្រេចវសីហើយផង ព្រះអរិយបុគ្គលទាំងអស់ ក្នុងវិមោក្ខដែលជាអរិយៈផង ឈ្មោះថា អសមយវិមុត្តបុគ្គល ។ បរវាទីនោះកាន់យកលទ្ធិរបស់ខ្លួនពោលថា ព្រះអរហន្តដែលជាសមយវិមុត្តិ រមែងសាបសូន្យ ព្រះអរហន្តក្រៅអំពីនេះ មិនសាបសូន្យឡើយ ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ដូច្នេះ ។l៚

## អដ្ឋកថាអរិយបុគ្គលសំសន្ទនបរិហានិ ចប់

# អដ្ឋកថា

## សុត្តសាធនបរិហានិ

[ ២៤៧ ] ឥឡូវនេះ ជាការជម្រះដោយព្រះសូត្រ ក្នុងបទទាំងនោះ បទថា **ឧច្ចាវចា** បានដល់ ខ្ពស់ផង ទាបផង ដោយប្រភេទថ្លៃថ្លា និងថោកទាប ។ បទថា **បដិបទា** បានដល់ កិច្ចបដិបត្តិ ។ បទថា **សមណេន បកាសិតា** បានដល់ ដែលសមណៈ គឺព្រះពុទ្ធឲ្យរុងរឿងហើយ ។ កិច្ចបដិបត្តិងាយ ត្រាស់ដឹងឆាប់រហ័ស ឈ្មោះថា សេចក្តីប្រតិបត្តិខ្ពស់ ។ បដិបត្តិលំបាក ត្រាស់ដឹងក៏យឺតយូរ ឈ្មោះថា សេចក្តីប្រតិបត្តិទាប ។ បដិបទាដ៏សេសពីរយ៉ាងក្រៅអំពីនេះ ជាបដិបទាខ្ពស់មួយចំណែក ទាបមួយចំណែក ។ ម្យ៉ាងទៀត បដិបទាដែលពោលដំបូងប៉ុណ្ណោះជាបដិបទាខ្ពស់ ចំណែកដ៏សេសទាំង ៣ ជាបដិបទាទាប តែបុគ្គលបដិបត្តិទៅដល់ត្រើយបាន គឺនិព្វានបាន ២ ដង ដោយបដិបទាទាំងខ្ពស់ និងទាបនោះក៏មិនមែន អធិប្បាយថា រមែងមិនទៅកាន់ព្រះនិព្វានអស់វារៈ ២ ដង ដោយមគ្គ ១ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា កិលេសទាំងឡាយណា ដែលមគ្គណាលះបានហើយ មិនគប្បីលះកិលេសទាំងនោះដោយមគ្គនោះទៀត ។ លោករមែងសម្តែងភាវៈមិនជាធម៌សាបសូន្យ ដោយមគ្គនេះ ។ បទថា **ណយិទំ ឯកគុណំ មុតំ** សេចក្តីថា ត្រើយ គឺព្រះនិព្វាននេះ សូម្បីគួរដល់ការសម្រេចម្តងប៉ុណ្ណោះក៏មិនមែន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានការលះកិលេសទាំងពួងដោយមគ្គ ១ ។ លោកសម្តែងភាពជាព្រះអរហន្តមិនបានដោយមគ្គ ១ ប៉ុណ្ណោះ ។

[ ២៤៨ ] បទថា **អត្ថិ ឆិន្នស្ស ឆេទិយំ** សេចក្តីថា សកវាទីសួរថា កាលកិលេសវដ្តត្រូវកាត់ផ្តាច់ហើយ កិលេសណាមួយ ដែលព្រះអរិយៈគប្បីកាត់ទៀតមានឬ បរវាទីសំដៅយកព្រះអរហន្តដែលមានឥន្ទ្រិយចាស់ក្លា ទើបឆ្លើយបដិសេធ ត្រូវសួរជាដែលទៀត សំដៅយកបុគ្គលដែលមានឥន្ទ្រិយទន់ខ្សោយ ទើបឆ្លើយទទួល ទើបសកវាទីនាំព្រះសូត្រមកហើយ សម្តែងការមិនមានកិលេសណាមួយ ដែលព្រះអរហន្តគប្បីលះទៀត ។ ក្នុងព្រះសូត្រនោះ បទថា **ឱឃចារោ** បានដល់ អន្ទង់ គឺកិលេស និងអន្ទាក់ គឺកិលេស ។

[ ២៤៩ ] បទថា **កតស្ស បដិចយោ** បានដល់ ចម្រើនមគ្គដែលចម្រើនហើយ ឲ្យកើតឡើងទៀត ។ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបពាក្យបដិសេធ និងពាក្យឆ្លើយទទួលដោយន័យដែលពោលមកហើយក្នុងកាលមុននោះឯង ។

[ ២៥០ ] បទថា **បរិហានាយ សំវត្តន្តិ** សេចក្តីថា ធម៌ ៥ យ៉ាង មានការត្រេកអរក្នុងការងារជាដើម ក្នុងព្រះសូត្រ ដែលបរវាទីនាំមកអាងរមែងប្រព្រឹត្តទៅព្រមដើម្បីសេចក្តីសាបសូន្យ ចាកធម៌ដែលមិនទាន់សម្រេច និងដើម្បីការសាបសូន្យចាកលោកិយសមាបត្តិ តែសកវាទីនោះ កំណត់ដល់សេចក្តីសាបសូន្យនៃអរហត្តផលដែលសម្រេចហើយ ។

[ ២៥១ ] ដោយហេតុនោះឯង ទើបសកវាទីសួរថា ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងការងារដែរឬ ដូច្នេះ ។ បរវាទីសំដៅយកព្រះអរហន្តដែលជាអសមយវិមុត្ត ទើបឆ្លើយបដិសេធ សំដៅយកព្រះអរហន្តក្រៅអំពីនេះ ( សមយវិមុត្ត ) ទើបឆ្លើយទទួល ។ម្យ៉ាងទៀត បរវាទីបដិសេធសេចក្តី

ត្រេកអរនោះ ដែលប្រព្រឹត្តទៅដោយអំណាចកាមរាគៈ រមែងទទួលការត្រេកអរនោះ ដែលប្រព្រឹត្តទៅដោយប្រការដទៃអំពីកាមរាគៈ តែកាលត្រូវសួរដល់ភាពដែលព្រះអរហន្តនៅមានរាគៈជាដើម ក៏មិនអាចឆ្លើយទទួលថា មាន ។

[ ២៥២ ] បទថា **កឹ បរិយុដ្ឋិតោ** សេចក្ដីថា ដែលអ្វីចោមរោម អធិប្បាយថា ជាបុគ្គលដែលត្រូវកិលេសជាគ្រឿងចង ឬជាបុគ្គលដែលត្រូវកិលេសដែលជាជំនន់ខាងក្នុងលិចលង់ ។ ក្នុងពាក្យសួរដោយអនុសយក្កិលេស បណ្ឌិតគប្បីជ្រាបពាក្យបដិសេធ និងពាក្យឆ្លើយទទួល ដោយអំណាចនៃព្រះអរិយៈ ដែលមានឥន្ទ្រិយចាស់ក្លា និងឥន្ទ្រិយទន់ខ្សោយ ឬរមែងឆ្លើយទទួលដោយពាក្យទូទៅថា អនុស័យចំណែកល្អ ។

[ ២៥៣ ] បទថា **រាគោ ឧបចយំ គច្ឆតិ** សេចក្ដីថា បរវាទីពោលសំដៅយករាគៈ ដែលលះដោយមគ្គខាងលើទាំង ៣ ។ ក្នុងទោសៈ និងមោហៈ ខាងមុខក៏មានន័យនេះដូចគ្នា ។ តែកិលេស មានសក្កាយទិដ្ឋិជាដើម រមែងមិនកកើតឡើង ព្រោះភាពដែលកិលេសទាំងនោះដែលមគ្គខាងដើមលះហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាសុត្តសាធនៈ ចប់**

**បរិហានិកថា ចប់**

# អភិធម្មបិដក

## ព្រហ្មចរិយកថា

[ ២៥៥ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ពួកទេវតាទាំងអស់ សុទ្ធតែល្ងង់ខ្លៅ មិនចេះដឹង ប្រកបដោយការពោលដោយដៃ ( ដូចមនុស្ស-គ ) មិនអង់អាច ដើម្បីដឹងនូវសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ពួកទេវតាទាំងអស់ មិនជ្រះថ្លាក្នុងព្រះពុទ្ធ មិនជ្រះថ្លាក្នុងព្រះធម៌ មិនជ្រះថ្លាក្នុងព្រះសង្ឃ មិនចូលទៅអង្គុយជិតព្រះពុទ្ធមានព្រះភាគ មិនសួរនូវប្រស្នានឹងព្រះពុទ្ធមានព្រះភាគ កាលបើប្រស្នា ដែលព្រះពុទ្ធមានព្រះភាគដោះស្រាយហើយ មិនរីករាយ ពួកទេវតាទាំងអស់ ប្រកបដោយកម្មជារនាំង ប្រកបដោយកិលេសជារនាំង ប្រកបដោយវិបាកជារនាំង មិនមានសទ្ធា មិនមានឆន្ទៈ មិនមានប្រាជ្ញា មិនគួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត ជាអ្នកធ្វើព្រះលោហិតរបស់ព្រះពុទ្ធ ឲ្យកើតឡើង ជាអ្នកបំបែកសង្ឃ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់សត្វ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាស៊កសៀត ជាអ្នកមានវាចាអាក្រក់ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានអភិជ្ឈាជាប្រក្រតី ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមិច្ឆាទិដ្ឋិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងពួកទេវតា មិនល្ងង់ មិនខ្លៅ ចេះដឹង មិនប្រកបដោយការពោលដោយដៃ ( ដូចមនុស្ស-គទេ ) អាចដើម្បីដឹង នូវសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ពួកទេវតាជ្រះថ្លាក្នុងព្រះពុទ្ធ ជ្រះថ្លាក្នុងព្រះធម៌

ជ្រះថ្លាក្នុងព្រះសង្ឃ តែងចូលទៅអង្គុយជិតព្រះពុទ្ធមានព្រះភាគ សួរនូវប្រស្នានឹងព្រះពុទ្ធមានព្រះភាគ កាលបើប្រស្នា ដែលព្រះពុទ្ធមានព្រះភាគដោះស្រាយហើយ ក៏មានចិត្តរីករាយ ពួកទេវតា មិនប្រកបដោយកម្មជារនាំង មិនប្រកបដោយកិលេសជារនាំង មិនប្រកបដោយវិបាកជារនាំង មានសទ្ធា មានឆន្ទៈ មានបញ្ញា គួរដើម្បីចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកទេវតាមិនសម្លាប់មាតា មិនសម្លាប់បិតា មិនសម្លាប់ព្រះអរហន្ត មិនធ្វើព្រះលោហិតរបស់ព្រះពុទ្ធឲ្យកើតឡើង មិនបំបែកសង្ឃ ពួកទេវតា មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនពោលពាក្យកុហក មិនមានវាចាស៊កសៀត មិនមានវាចាអាក្រក់ មិនពោលពាក្យរោយរាយឥតប្រយោជន៍ មិនមានអភិជ្ឈាជាប្រក្រតី មានចិត្តមិនព្យាបាទ ជាសម្មាទិដ្ឋិឬ ។ អើ ។ បើពួកទេវតា មិនល្ងង់ មិនខ្លៅ ចេះដឹង មិនប្រកបដោយការពោលដោយដៃ ( ដូចជាមនុស្ស-គទេ ) អាចដើម្បីដឹងនូវសេចក្តីនៃសុភាសិតនិងទុព្ភាសិត ។បេ។ ពួកទេវតា ជ្រះថ្លាក្នុងព្រះពុទ្ធ ។បេ។ ជាសម្មាទិដ្ឋិ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងទេវលោកមិនមាន ដូច្នេះឡើយ ។

[ ២៥៦ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ អើ ។ បព្វជ្ជា ភាពនៃបុគ្គលមានក្បាលត្រងោល ការទ្រទ្រង់សំពត់កាសាវៈ ការទ្រទ្រង់បាត្រ ក្នុងពួកទេវតានោះ មានឬ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ គូនៃសាវក កើតក្នុងពួកទេវតា មានឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។

[ ២៥៧ ] បព្វជ្ជា ក្នុងពួកទេវតា មិនមានទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ បព្វជ្ជា មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ បព្វជ្ជា មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បព្វជ្ជា មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ បព្វជ្ជា មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណាបួស ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះមាន បុគ្គលណា មិនបួស ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះមិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៨ ] ភាពនៃបុគ្គលមានក្បាលត្រងោល មិនមានក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ភាពនៃបុគ្គលមានក្បាលត្រងោល មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ភាពនៃបុគ្គលមានក្បាលត្រងោល មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភាពនៃបុគ្គលមានក្បាលត្រងោល មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ភាពនៃបុគ្គលមានក្បាលត្រងោល មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណា មានក្បាលត្រងោល ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ

ក៏មានដែរ បុគ្គលណា មិនមានក្បាលត្រងោល ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៩ ] ការទ្រទ្រង់នូវសំពត់កាសាវៈ ក្នុងពួកទេវតា មិនមានទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ការទ្រទ្រង់សំពត់កាសាវៈ មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ការទ្រទ្រង់សំពត់កាសាវៈ មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការទ្រទ្រង់សំពត់កាសាវៈ មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ការទ្រទ្រង់សំពត់កាសាវៈ មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណា ទ្រទ្រង់សំពត់កាសាវៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មាន បុគ្គលណា មិនទ្រទ្រង់សំពត់កាសាវៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦០ ] ការទ្រទ្រង់បាត្រ មិនមាន ក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនមាន ក្នុងពួកទេវតាឬ ។ អើ ។ ការទ្រទ្រង់បាត្រ មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ការទ្រទ្រង់បាត្រ មិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការទ្រទ្រង់បាត្រ មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ការទ្រទ្រង់បាត្រ មិនមានក្នុងទីណា

ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ បុគ្គល ណា ទ្រទ្រង់បាត្រ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មាន បុគ្គល ណា មិនទ្រទ្រង់បាត្រ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមាន ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦១ ] ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើតក្នុងពួកទេវតាទេឬ ។ ការ ប្រព្រឹត្តព្រហ្មចរិយធម៌ មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ព្រះសម្មាសម្ពុទ្ធ ទាំងឡាយ កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាននៅក្នុងទីនោះដែរ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏ មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះសម្មា-សម្ពុទ្ធទាំងឡាយ កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះ ដែរ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ ព្រះមានព្រះភាគ ប្រសូតក្នុងលុម្ពិនីវ័ន ( ព្រៃរាំង ) ហើយត្រាស់ដឹងទៀបគល់ពោធិព្រឹក្ស ព្រះមានព្រះភាគ ( អង្គ នោះ ) ទ្រង់ញុំាងធម្មចក្ក ឲ្យប្រព្រឹត្តទៅក្នុងក្រុងពារាណសី ការប្រព្រឹត្តព្រហ្ម-ចរិយធម៌ ក៏មានក្នុងទីនោះៗ ដែរ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងទីដទៃ មិន មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦២ ] ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើតក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ព្រះបច្ចេក-សម្ពុទ្ធទាំងឡាយ កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះ

ដែរ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយ-ធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្ម-ចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតក្នុងមជ្ឈិមជនបទ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានតែក្នុងទីនោះឯង ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងទីឯទៀត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៣ ] គូនៃសាវក មិនកើតក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្ម-ចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ គូនៃសាវក កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ គូនៃសាវកមិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ គូនៃសាវក កើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ គូនៃសាវក មិនកើតក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ គូនៃសាវក កើតក្នុងដែនមគធៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានតែក្នុងដែនមគធៈនោះឯង ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងទីឯទៀត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៤ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងពួកទេវតាទាំងអស់ឬ ។ អ្នកមិនគួរពោល

យ៉ាងនេះទេ ។បេ។

[ ២៦៥ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងពួកមនុស្សឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងមនុស្សទាំងអស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៦ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងពួកទេវតាឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងពួកទេវតា ឈ្មោះថា អសញ្ញសត្វដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៧ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងពួកមនុស្សឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខុជន ជាអ្នកមិនចេះដឹង ក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទេ តើមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៨ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ ប្រទេសដែលពួកទេវតាប្រព្រឹត្តព្រហ្មចរិយធម៌ក៏មាន ប្រទេសដែលពួកទេវតាមិនប្រព្រឹត្តព្រហ្មចរិយធម៌ក៏មានឬ ។ ទេវតាជាន់អសញ្ញសត្វ មានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ ពួកទេវតាជាន់សញ្ញសត្វ មានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្នុងពួកទេវតា មានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះឬ ។ អើ ។ ចុះមានក្នុងទីណា មិនមានក្នុងទីណា ។ ទេវតាជាន់អសញ្ញសត្វ មិនមានការប្រព្រឹត្តព្រហ្ម-

ចរិយធម៌ ទេវតាជាន់សញ្ញសត្វ មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ ទេវតាជាន់អសញ្ញសត្វ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អើ ។ ទេវតាជាន់សញ្ញ-សត្វ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ទេវតាជាន់សញ្ញសត្វ មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អើ ។ ទេវតាជាន់អសញ្ញសត្វ មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៩ ] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកមនុស្ស មានឬ ។ ប្រទេសដែលពួកមនុស្ស ប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ប្រទេសដែលពួកមនុស្ស មិនប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខុ-ជន ជាអ្នកមិនចេះដឹង មិនមានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មួយទៀត ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៧០ ] ក្នុងពួកមនុស្ស មានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ខ្លះឬ ។ អើ ។ ចុះមានក្នុងទីណា មិនមានក្នុងទីណា ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខុជន ជាអ្នកមិនចេះដឹង មិនមានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិរបស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ ការប្រព្រឹត្តព្រហ្មចរិយ-ធម៌ ក្នុងពួកមិលក្ខុជន ជាអ្នកមិនចេះដឹង មិនមានក្នុងបច្ចន្តិមជនបទ ដែលជា

ជនបទមិនមានគតិ របស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឬ ។ អើ ។ ក្នុងមជ្ឈិមជនបទ មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខុជន ជាអ្នកមិនចេះដឹង មានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិ របស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧១ ] ក្នុងពួកទេវតា មានការប្រព្រឹត្តព្រហ្មចរិយធម៌ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងជម្ពូទ្វីបគ្របសង្កត់នូវពួកមនុស្ស នៅក្នុងឧត្តរកុរុទ្វីបផង នូវពួកទេវតាជាន់តាវត្តិង្សផង ដោយហេតុ ៣ យ៉ាង ។ ហេតុទាំង ៣ នោះ តើដូចម្តេច ។ ក្នុងជម្ពូទ្វីបនេះ ពួកមនុស្សជាអ្នកក្លៀវក្លា ១ មានសតិ ១ ការប្រព្រឹត្តព្រហ្មចរិយធម៌ ១ ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ ក្នុងពួកទេវតា មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ទេឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ក្នុងក្រុងសាវត្ថីថា ការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងក្រុងសាវត្ថីនេះ ដូច្នេះមែនឬ ។ អើ ។ ចុះការប្រព្រឹត្តព្រហ្មចរិយធម៌ មានក្នុងក្រុងសាវត្ថីតែប៉ុណ្ណោះ ក្នុងទីឯទៀត មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះ ទៅកើតក្នុងជាន់សុទ្ធាវាសនោះ ចុះការកើតឡើងនៃផលក្នុងទីណា ។ ការកើតឡើងនៃផល

ក្នុងសុទ្ធាវាសនោះឯង ។ បើអនាគាមិបុគ្គល បានលះសញ្ញោជនៈជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ការកើតឡើងនៃផល ក៏ក្នុងសុទ្ធាវាសនោះឯង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនមានក្នុងពួកទេវតា ដូច្នេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ចុះការដាក់ចុះនូវភារៈក្នុងទីណា ការកំណត់ដឹងនូវទុក្ខក្នុងទីណា ការលះកិលេសក្នុងទីណា ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក្នុងទីណា ការចាក់ធ្លុះនូវធម៌មិនកម្រើក ក្នុងទីណា ។ ក្នុងសុទ្ធាវាសនោះឯង ។ បើអនាគាមិបុគ្គល បានលះសញ្ញោជនៈជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ការត្រាស់ដឹងនូវធម៌មិនកម្រើក ក្នុងជាន់សុទ្ធាវាសនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនមានក្នុងពួកទេវតា ដូច្នេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ការកើតឡើងនៃផល ក៏ក្នុងទីនោះ ការដាក់ចុះនូវភារៈក្នុងទីនោះ ការកំណត់ដឹងនូវទុក្ខ ក្នុងទីនោះ ការលះកិលេស ក្នុងទីនោះ ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក្នុងទីនោះ ការចាក់ធ្លុះនូវធម៌មិនកម្រើក ក្នុងទីនោះ

អ្នកនិយាយថា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតាមិនមាន ដូច្នេះ តើដោយសេចក្តីដូចម្តេច ។ បើដូច្នោះ មានតែអនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះ ។

[ ២៧២ ] អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ សោតាបន្នបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ សកទាគាមិបុគ្គល ជាបុគ្គលបរិនិព្វាន ក្នុងលោកនេះ មានមគ្គចម្រើនហើយ ក្នុងលោកនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អើ ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងជាន់សុទ្ធាវាសនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល ជាបុគ្គលបរិនិព្វាន ក្នុងលោកនេះ មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អើ ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងជាន់សុទ្ធាវាសនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៣ ] បុគ្គលដែលសម្រេចដោយការលះ ក្នុងលោកនេះ គ្រាន់តែ

ចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលសម្រេចដោយការលះ ក្នុងលោកនេះ គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ។បេ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៤ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អើ ។ បុគ្គលសម្រេចដោយការលះ ក្នុងលោកនេះ ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ។បេ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អើ ។ បុគ្គលសម្រេចដោយការលះ ក្នុងលោកនេះ ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៥ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ កើតឡើងក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ ព្រះអរហន្តកើតទៀតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តកើតទៀតឬ ។ អើ ។ ភពថ្មីនៃព្រះអរហន្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភពថ្មីនៃ

ព្រះអរហន្ត មានឬ ។ អើ ។ ព្រះអរហន្ត ទៅកាន់ភពដោយភព ទៅកាន់គតិដោយគតិ ទៅកាន់សំសារដោយសំសារ ទៅកាន់ឧបបត្តិដោយឧបបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៦ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានភារៈមិនទាន់ដាក់ចុះ ទៅកើតក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ អនាគាមិបុគ្គល ចម្រើនមគ្គទៀត ដើម្បីដាក់ចុះនូវភារៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៧ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានទុក្ខមិនទាន់កំណត់ដឹង មានកិលេសមិនទាន់លះ មាននិរោធមិនទាន់ធ្វើឲ្យជាក់ច្បាស់ មានអកុប្បធម៌មិនទាន់ចាក់ធ្លុះ រមែងកើតឡើងក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ អនាគាមិបុគ្គល ចម្រើនមគ្គទៀត ដើម្បីចាក់ធ្លុះនូវអកុប្បធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៨ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានភារៈមិនទាន់ដាក់ចុះ កើតឡើងក្នុងជាន់សុទ្ធាវាសនោះ តែមិនទាន់ចម្រើនមគ្គទៀត ដើម្បីដាក់ចុះនូវភារៈទេឬ ។ អើ ។ ចុះអនាគាមិបុគ្គល មានភារៈមិនទាន់ដាក់ចុះ តើបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានទុក្ខមិនទាន់កំណត់ដឹង មានកិលេសមិនទាន់លះ មាននិរោធមិនទាន់ធ្វើឲ្យជាក់ច្បាស់ មានអកុប្បធម៌មិនទាន់ចាក់ធ្លុះ រមែងទៅកើតក្នុងជាន់

សុទ្ធាវាសនោះ តែមិនបានចម្រើនមគ្គទៀត ដើម្បីត្រាស់ដឹងនូវអកុប្បធម៌ឬ ។ អើ ។ ចុះអនាគាមិបុគ្គល មានអកុប្បធម៌មិនទាន់ត្រាស់ដឹង តើបរិនិព្វាន ក្នុងជាន់សុទ្ធាវាសនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សត្វម្រឹគដែលត្រូវសរមុត បោលទៅកាន់ទីឆ្ងាយ ហើយស្លាប់ទៅ យ៉ាងណា អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះ ក៏យ៉ាងនេះដែរ ។ សត្វម្រឹគ ដែលត្រូវសរមុត បោលទៅកាន់ទីឆ្ងាយ ហើយស្លាប់ទាំងសរ យ៉ាងណា អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ហើយបរិនិព្វាន ក្នុងជាន់សុទ្ធាវាស ដូចជាម្រឹគស្លាប់ទាំងសរ យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ព្រហ្មចរិយកថា ចប់

# អដ្ឋកថា

## ព្រហ្មចរិយកថា

### សុទ្ធព្រហ្មចរិយកថា

[ ២៥៥ ] ឥឡូវនេះ នឹងពោលរឿងប្រព្រឹត្តព្រហ្មចរិយៈដូចតទៅ

ក្នុងរឿងនោះ ការនៅប្រព្រឹត្តព្រហ្មចរិយៈមាន ២ យ៉ាង គឺការចម្រើនមគ្គ ១ បព្វជ្ជា ១ បព្វជ្ជា មិនមានក្នុងទេវតាទាំងឡាយ ។ វៀរអសញ្ញីសត្វហើយ ការចម្រើនមគ្គ លោកមិនបដិសេធក្នុងទេវតាទាំងឡាយដ៏សេស ។ ក្នុងការចម្រើនមគ្គនោះ ជនទាំងឡាយណា មានការយល់ខុស ដូចនិកាយសមិតិយៈ រមែងប្រកាន់ថា ទេវតាជាន់ខ្ពស់ តាំងអំពីជាន់បរនិម្មិតវសវត្តីឡើងទៅ មិនមានការចម្រើនមគ្គ ពាក្យសួររបស់សកវាទីថា **នត្ថិ ទេវេសុ** សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិដែលកើតឡើងហើយថា ការប្រព្រឹត្តព្រហ្មចរិយៈទាំង ២ យ៉ាង មិនមានក្នុងទេវតាទាំងឡាយ ព្រោះអាស្រ័យព្រះសូត្រ ( អង្គុត្តរនិកាយ នវកនិបាត ) នេះថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបខ្ពង់ខ្ពស់ហួសពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាង ។ ស្ថាន ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺមានសេចក្តីក្លៀវក្លា ១ មានស្មារតី ( ខ្ជាប់ខ្ជួន ) ១ មានការបំពេញព្រហ្មចរិយធម៌ដ៏វិសេស ១ ដូច្នេះ ។ ពាក្យសួរទៀតថា **សព្វេ ទេវា ជឡា** ដោយអំណាច

នៃធម៌ដែលជាអន្តរាយ ដល់ការប្រព្រឹត្តព្រហ្មចរិយៈទាំង ២ យ៉ាង ជាពាក្យរបស់សកវាទី ។ ក្នុងបទទាំងនោះ បទថា **ហត្ថសំវាចិកា** បានដល់និយាយដោយដៃ និងក្បាល ដូចមនុស្ស-គ ។

[ ២៥៦ ] ពាក្យសួរខាងមុខថា **ទេវេសុ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល សំដៅយកការចម្រើនមគ្គ ជាពាក្យរបស់សកវាទី ។ ពាក្យសួរដោយអំណាចនៃបព្វជ្ជា ព្រោះមិនកំណត់គោលបំណង នៃពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។

[ ២៥៧ ] ក្នុងបញ្ហាថា **យត្ថ នត្ថិ បព្វជ្ជា** ពាក្យបដិសេធថា មិនគប្បីពោលយ៉ាងនោះ ជាពាក្យរបស់បរវាទីនោះឯង ព្រោះសំដៅយកការបានចំពោះនូវមគ្គរបស់គ្រហស្ថទាំងឡាយ និងរបស់ទេវតាទាំងឡាយពួកខ្លះ ។ កាលត្រូវសួរជដែលទៀត បរវាទីនោះក៏ឆ្លើយទទួល សំដៅយកមនុស្សដែលនៅក្នុងបច្ចន្តិមជនបទ និងអសញ្ញីសត្វ ។ ក្នុងពាក្យសួរទាំងឡាយ មានបទថា **យោ បព្វជ្ជតិ** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ២៦៤ ] ក្នុងបញ្ហាទៀតថា **អត្ថិ ទេវេសុ** ពាក្យឆ្លើយទទួលថា អើ ជាពាក្យរបស់សកវាទី ព្រោះសំដៅយកការចម្រើនមគ្គប៉ុណ្ណោះ ។ កាលបរវាទីសួរថា **សព្វទេវេសុ** សកវាទីនោះឯង ក៏ឆ្លើយបដិសេធ ព្រោះសំដៅយកអសញ្ញីសត្វ ។

[ ២៦៥-២៦៧ ] ក្នុងបញ្ហាទាំងពីរថា **មនុស្សេសុ** គប្បីជ្រាបពាក្យឆ្លើយទទួល សំដៅយកអ្នកជម្ពូទ្វីប គប្បីជ្រាបពាក្យបដិសេធ សំដៅយក

មនុស្ស ដែលនៅក្នុងបច្ចន្តិមជនបទ ។

[ ២៦៨ ] បទថា **អត្ថិ យត្ថ អត្ថិ** ពាក្យវិសជ្ជនា ដោយមាតិកាដែលចែក គឺសត្វ និងប្រទេសយ៉ាងនេះថា ការប្រព្រឹត្តព្រហ្មចរិយៈ មានក្នុងទេវតាពួកណា ឬក្នុងប្រទេសណា ទេវតាទាំងនោះមាន ឬប្រទេសនោះក៏មានដូច្នេះ ជាពាក្យរបស់សកវាទី ។ ដោយន័យនេះ បណ្ឌិតគប្បីជ្រាបបញ្ហាទាំងពួងថា ជាឯកន្តរិកបញ្ហា គឺជាបញ្ហាដែលសួរឆ្លាស់គ្នា ។

[ ២៧១ ] ក្នុងការសួរព្រះសូត្រថា **កុហឹ ជលុប្បត្តិ** ជាពាក្យសួររបស់សកវាទីថា ការកើតឡើងនៃអរហត្តផលរបស់ព្រះអនាគាមីនោះ មានក្នុងទីណា ពាក្យឆ្លើយថា **តត្ថេវ** បានដល់ ក្នុងជាន់សុទ្ធាវាសទាំងឡាយ ។

បទថា **ហន្ទ ហិ** ជានិបាត ចុះក្នុងអត្ថនៃហេតុ ។ មានពាក្យអធិប្បាយថា ព្រោះព្រះអនាគាមិបុគ្គល ធ្វើឲ្យច្បាស់នូវផលក្នុងសុទ្ធាវាសទាំងនោះ ដោយមគ្គដែលលោកចម្រើនឲ្យកើតឡើងហើយ ក្នុងលោកនេះ មិនបានចម្រើនមគ្គដទៃ ក្នុងសុទ្ធាវាសនោះ ព្រោះហេតុនោះ ទើបការប្រព្រឹត្តព្រហ្មចរិយៈ មិនមានក្នុងពួកទេវតា ។៙

# អដ្ឋកថា

## សំសន្ទនព្រហ្មចរិយៈ

[ ២៧២ ] ឥឡូវនេះ ពាក្យសួរប្រៀបធៀបនៃពាក្យទាំងឡាយថា **អនាគាមី** ជាដើមទៀត ជាពាក្យរបស់សកវាទី ដើម្បីសម្តែងអត្ថនេះថា បើការធ្វើឲ្យជាក់ច្បាស់នូវផលមានក្នុងទីដទៃ ដោយមគ្គដែលធ្លាប់អប់រំហើយក្នុងទីដទៃសោត ព្រោះហេតុនោះ ការធ្វើឲ្យជាក់ច្បាស់នូវផលដោយមគ្គ ដែលធ្លាប់អប់រំហើយក្នុងទីដទៃ ក៏គប្បីមានដល់ព្រះសោតាបន្នជាដើមដូច្នេះ ។ ក្នុងបញ្ហានោះ ពាក្យឆ្លើយទទួលការដែលព្រះអនាគាមី ធ្វើឲ្យជាក់ច្បាស់នូវផល តែបដិសេធការដែលព្រះអរិយៈដ៏សេស ធ្វើឲ្យជាក់ច្បាស់នូវផល ជាពាក្យរបស់បរវាទី ។ លទ្ធិរបស់លោកថា ព្រះអនាគាមី វៀរការចម្រើនមគ្គរមែងធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលបាន ដោយអំណាចនៃការចូលដល់ ( សុទ្ធាវាស ) នោះឯង ព្រោះពាក្យថា ព្រះអនាគាមី ដែលចម្រើនមគ្គហើយក្នុងលោកនេះ ឈ្មោះថា ជាអ្នកលះលោកនេះទៅហើយ ទើបសម្រេច ព្រះអនាគាមីនោះ ចម្រើនអនាគាមិមគ្គ ក្នុងលោកនេះហើយ ជាឱបបាតិកៈ បរិ-និព្វានក្នុងសុទ្ធាវាសនោះ ចំណែកព្រះសោតាបន្ន និងព្រះសកទាគាមី ចម្រើនមគ្គឲ្យកើតក្នុងទីនោះហើយ ជាបុគ្គលឈ្មោះថា មានការចូលដល់ក្នុងទីនោះទៀត ការមកក្នុងសុទ្ធាវាសនេះ របស់ព្រះអរិយៈទាំងនោះ មិនមានឡើយ ដោយប្រការដូច្នេះ ហេតុនោះ បរវាទី កាលត្រូវសួរដល់ការដែលព្រះអនាគាមីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ក៏ឆ្លើយទទួល តែបដិសេធការធ្វើឲ្យជាក់ច្បាស់របស់ព្រះអរិយៈទាំងឡាយក្រៅអំពីនេះ ។

ក្នុងបញ្ហាថា **អនាគាមី បុគ្គលោ តត្ថ ភាវិតេន មគ្គេន** បរវាទី ឆ្លើយបដិសេធ ព្រោះលទ្ធិថា ការចម្រើនមគ្គរបស់ព្រះអនាគាមី ក្នុងទេវលោកមិនមាន ។

[ ២៧៣ ] ពាក្យសួរថា **មគ្គោ ច ភាវិយតិ ឆ ច កិលេសា បហីយន្តិ** ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី សំដៅយករូបាវចរមគ្គ ។ ពិតហើយ ព្រះអនាគាមីនោះ ឈ្មោះថា ជាអ្នកលះលោកនេះទៅហើយ ទើបសម្រេចដោយរូបាវចរមគ្គ ។

[ ២៧៥ ] ក្នុងបញ្ហាថា **អនាគាមី បុគ្គលោ កតករណីយោ** បរវាទីឆ្លើយទទួលថា **អាមន្តា** សំដៅយកភាវៈមានករណីយកិច្ចដែលព្រះអនាគាមីនោះធ្វើហើយជាដើម ដើម្បីការកើតឡើង ព្រោះកាន់យកពាក្យថា ជាឱបបាតិកៈបរិនិព្វានក្នុងសុទ្ធាវាសនោះ ។ ក្នុងបញ្ហាថា **អរហា** បរវាទីឆ្លើយបដិសេធដោយអំណាចនៃព្រះអរហន្តដែលបរិនិព្វានក្នុងលោកនេះ ។ ត្រូវសួរជដែលទៀត ក៏ឆ្លើយទទួលថា **អាមន្តា** ដោយអំណាចនៃព្រះអរហន្តទាំងនោះ ដែលបរិនិព្វានហើយក្នុងទេវលោក ។

ក្នុងបទទាំងឡាយ មានបទថា **អត្ថិ អរហតោ បុនព្ភវោ** ដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយអំណាចនៃព្រះអរហន្តទាំងឡាយ ដែលបរិនិព្វានហើយ ក្នុងទេវលោកនោះ ឬដែលបរិនិព្វានហើយក្នុងលោកនេះឯង ។

[ ២៧៨ ] *បរវាទីត្រូវសកវាទីសួរថា* **អប្បដិវិទ្ធាកុប្បោវ តត្ថ បរិ-ធិព្វាយតិ** *កាលមិនឃើញដោយការចាក់ធ្លុះនូវអកុប្បធម៌ របស់ព្រះអរហន្ត ដោយមគ្គដែលចម្រើនហើយ ក្នុងលោកនេះឯង ទើបឆ្លើយបដិសេធថា* **ឆ ហេវំ** ។

*ឧទាហរណ៍ដំបូងថា* **យថា មិគោ** *ជាពាក្យរបស់បរវាទី ឧទាហរណ៍ទី ២ ជាពាក្យរបស់សកវាទី ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕*

## អដ្ឋកថាព្រហ្មចរិយកថា ចប់

# អភិធម្មបិដក

## ខុទ្ទិសោកថា

[ ២៧៩ ] បុគ្គលលះកិលេសដោយចំណែកៗ ឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល តើលះអ្វី ដោយការឃើញនូវទុក្ខ ។ លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងកិលេសដែលជាចំណែកមួយ តាំងនៅក្នុងទីជាមួយនឹងសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈនោះ ។ សោតាបន្នបុគ្គលចំណែកមួយ មិនមែនសោតាបន្នបុគ្គលចំណែកមួយ បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯក-ពីជីបុគ្គល ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ប្រកបដោយអរិយកន្តសីលចំណែកមួយ មិនប្រកបដោយអរិយកន្តសីលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវសមុទយសច្ច ។ លះសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ទាំងលះពួកកិលេស ដែលជាចំណែកមួយ តាំងនៅជាមួយនឹងសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈនោះ ។ សោតាបន្ន-បុគ្គលចំណែកមួយ មិនមែនសោតាបន្នបុគ្គលចំណែកមួយ ។បេ។ បុគ្គលប្រកបដោយអរិយកន្តសីលចំណែកមួយ បុគ្គលមិនប្រកបដោយអរិយកន្ត-សីលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវនិរោធសច្ច ។ លះវិចិកិច្ឆា និងសីលព្វតបរាមាសៈ ទាំងលះ

កិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងវិចិកិច្ឆា និងសីលព្វតបរាមាសៈនោះ ។ សោតាបន្នបុគ្គលចំណែកមួយ មិនមែនសោតាបន្នបុគ្គលចំណែកមួយ ។បេ។ បុគ្គលប្រកបដោយអរិយកន្តសីលចំណែកមួយ បុគ្គលមិនប្រកបដោយអរិយកន្តសីលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវមគ្គសច្ច ។ លះសីលព្វតបរាមាសៈ ទាំងលះពួកកិលេស ដែលតាំងនៅជាមួយនឹងសីលព្វតបរាមាសៈនោះ ។ សោតាបន្នបុគ្គលចំណែកមួយ មិនមែនសោតាបន្នបុគ្គលចំណែកមួយ បុគ្គលបានដល់នូវសោតាបត្តិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជីបុគ្គល ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ដែលប្រកបដោយអរិយកន្តសីលចំណែកមួយ បុគ្គលមិនប្រកបដោយអរិយកន្តសីលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨០ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល តើលះអ្វី ដោយការឃើញនូវទុក្ខសច្ច ។ លះកាមរាគដ៏គ្រោតគ្រាត លះព្យាបាទដ៏គ្រោតគ្រាត ទាំងលះពួកកិលេស ដែលជាចំណែកមួយ តាំងនៅជាមួយនឹងកាមរាគ និងព្យាបាទនោះ ។ សកទាគាមិបុគ្គលចំណែកមួយ មិនមែនជាសកទាគាមិបុគ្គលចំណែកមួយ បុគ្គលបានដល់នូវសកទាគាមិផល បានចំពោះ

បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវ ដោយនាមកាយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវសមុទយសច្ច ។ លះកាមរាគដ៏គ្រោតគ្រាត លះព្យាបាទដ៏គ្រោតគ្រាត ទាំងលះពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងកាមរាគ និងព្យាបាទនោះ ។ សកទាគាមិបុគ្គលចំណែកមួយ មិនមែនសកទាគាមិបុគ្គលចំណែកមួយ បុគ្គលដល់នូវសកទាគាមិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវនិរោធសច្ច ។ លះព្យាបាទដ៏គ្រោតគ្រាត ទាំងលះពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងព្យាបាទនោះ ។ សកទាគាមិបុគ្គលចំណែកមួយ មិនមែនសកទាគាមិបុគ្គលចំណែកមួយ បុគ្គលបានដល់នូវសកទាគាមិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយចំណែកមួយ មិនពាល់ត្រូវដោយនាមកាយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវមគ្គសច្ច ។ លះព្យាបាទដ៏គ្រោតគ្រាត ទាំងលះពួកកិលេសដែលតាំងនៅជាមួយនឹងព្យាបាទនោះ ។ សកទាគាមិបុគ្គលចំណែកមួយ មិនមែនសកទាគាមិបុគ្គលចំណែកមួយ បុគ្គលបានដល់នូវសកទាគាមិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយចំណែកមួយ ដែលមិន

ពាល់ត្រូវ ដោយនាមកាយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨១ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល តើលះអ្វី ដោយការឃើញនូវទុក្ខសច្ច ។ លះកាមរាគ ដ៏ស្រោលស្តើង លះព្យាបាទដ៏ស្រោលស្តើង ទាំងលះពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងកាមរាគ និងព្យាបាទនោះ ។ អនាគាមិបុគ្គលចំណែកមួយ មិនមែនអនាគាមិបុគ្គលចំណែកមួយ បុគ្គលបានដល់នូវអនាគាមិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយចំណែកមួយដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយ អន្តរាបរិនិព្វាយិបុគ្គល ឧបហច្ចបរិនិព្វាយិបុគ្គល អសង្ខារបរិនិព្វាយិបុគ្គល សសង្ខារបរិនិព្វាយិបុគ្គល ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយ ដែលមិនមែនជាឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវសមុទយសច្ច ។ លះកាមរាគដ៏ស្រោលស្តើង លះព្យាបាទដ៏ស្រោលស្តើង ទាំងលះពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងកាមរាគ និងព្យាបាទនោះ ។ អនាគាមិបុគ្គលចំណែកមួយ មិនមែនអនាគាមិបុគ្គលចំណែកមួយ ។បេ។ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយ មិនមែនឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវនិរោធសច្ច ។ លះព្យាបាទដ៏ស្រោលស្តើង ទាំងលះពួកកិលេស ដែលជាចំណែកមួយ តាំងនៅជាមួយនឹងព្យាបាទនោះ ។ អនាគាមិបុគ្គល ចំណែកមួយ មិនមែនអនាគាមិបុគ្គល ចំណែកមួយ ។បេ។

អកនិដ្ឋគាមិបុគ្គលចំណែកមួយ មិនមែនឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវមគ្គសច្ច ។ លះពួកកិលេស ដែលតាំងនៅជាមួយនឹងព្យាបាទនោះ ។ អនាគាមិបុគ្គលចំណែកមួយ មិនមែនអនាគាមិបុគ្គលចំណែកមួយ បុគ្គលបានដល់នូវអនាគាមិផល បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេចពាល់ត្រូវ ដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយ អន្តរាបរិនិព្វាយិបុគ្គល ឧបហច្ចបរិនិព្វាយិបុគ្គល អសង្ខារបរិនិព្វាយិបុគ្គល សសង្ខារបរិនិព្វាយិបុគ្គល ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយ មិនមែនឧទ្ធំសោតអកនិដ្ឋគាមិបុគ្គលចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨២ ] បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត តើលះអ្វី ដោយការឃើញនូវទុក្ខសច្ច ។ លះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងធម៌ទាំងនោះ ។ ព្រះអរហន្តចំណែកមួយ មិនមែនព្រះអរហន្តចំណែកមួយ បុគ្គលបានដល់នូវអរហត្ត បានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយចំណែកមួយ ដែលមិនពាល់ត្រូវដោយនាមកាយចំណែកមួយ បុគ្គលមានរាគៈទៅប្រាស មានទោសៈទៅប្រាស មានមោហៈទៅប្រាស

មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ ដោយលំដាប់ មានភព និងសញ្ញោជនៈអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារ គឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកឡើងហើយ មិនមានគន្លឹះទ្វារ ជាព្រះអរិយៈមានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជម្នះឈ្នះដោយប្រពៃហើយ បុគ្គលនោះ បានកំណត់ដឹងនូវទុក្ខសច្ចហើយ លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ធម្មជាតដែលគួរត្រាស់ដឹង បុគ្គលនោះ បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង បុគ្គលនោះ បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះបង់ បុគ្គលនោះបានលះបង់ហើយ ធម្មជាតដែលគួរអប់រំ បុគ្គលនោះ បានអប់រំហើយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវសមុទយសច្ច ។ លះរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជានិងពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងធម៌ទាំងនោះ ។ ព្រះអរហន្តចំណែកមួយ មិនមែនព្រះអរហន្តចំណែកមួយ ។បេ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ ធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយ

ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវនិរោធ-សច្ច ។ លះមានះ ឧទ្ធច្ចៈ និងអវិជ្ជា ទាំងលះពួកកិលេសដែលជាចំណែកមួយ តាំងនៅជាមួយនឹងធម៌នោះ ។ ព្រះអរហន្តចំណែកមួយ មិនមែនព្រះអរហន្ត ចំណែកមួយ ។បេ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យ ជាក់ច្បាស់ហើយចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តើលះអ្វី ដោយការឃើញនូវមគ្គសច្ច លះឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែល តាំងនៅជាមួយនឹងធម៌នោះ ។ ព្រះអរហន្ត ចំណែកមួយ មិនមែនព្រះអរហន្ត ចំណែកមួយ បុគ្គលបានដល់នូវអរហត្ត បានចំពោះ បានត្រាស់ដឹង បានធ្វើ ឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយ ចំណែកមួយ មិនពាល់ ត្រូវដោយនាមកាយ ចំណែកមួយ បុគ្គលមានរាគៈទៅប្រាស មានទោសៈ ទៅប្រាស មានមោហៈទៅប្រាស មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះ ហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយដោយលំដាប់ មានភព និងសញ្ញោជនៈ អស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារ គឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកឡើងហើយ មិន មានគន្លឹះទ្វារ ជាព្រះអរិយៈ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិន ប្រកបដោយកិលេស មានជម្នះ ឈ្នះហើយដោយប្រពៃ បុគ្គលនោះ បាន កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ធម្មជាតដែលគួរត្រាស់ដឹង បុគ្គលនោះ បានត្រាស់ដឹងហើយ

ធម្មជាតដែលគួរកំណត់ដឹង បុគ្គលនោះ កំណត់ដឹងហើយ ធម្មជាតដែលគួរលះបង់ បុគ្គលនោះ បានលះបង់ហើយ ធម្មជាតដែលគួរអប់រំ បុគ្គលនោះ បានអប់រំ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ហើយចំណែកមួយ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនបានធ្វើឲ្យជាក់ច្បាស់ហើយ ចំណែកមួយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៣ ] អ្នកមិនគួរពោលថា បុគ្គលលះពួកកិលេសជាចំណែកៗ ដូច្នេះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

អ្នកប្រាជ្ញ គប្បីកម្ចាត់បង់ នូវមន្ទិលរបស់ខ្លួន បន្តិចម្តងៗ
រាល់ៗ ខណៈ តាមលំដាប់ ដូចជាងមាស កាលដេញ
បោលនូវមន្ទិលនៃមាស ដូច្នោះដែរ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ បុគ្គលមិនគួរពោលថា បុគ្គលលះពួកកិលេសជាចំណែកៗ ដូច្នេះឡើយ ។

[ ២៨៤ ] បុគ្គលលះពួកកិលេស ជាចំណែកៗ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

ធម៌ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វត-
បរាមាសៈណាមួយ គឺសោតាបន្នបុគ្គលនោះ បានលះ
ហើយ ជាមួយនឹងទស្សនសម្បទ គឺសោតាបត្តិមគ្គ ម្យ៉ាង

ទៀត សោតាបន្នបុគ្គល ផុតស្រឡះហើយ ចាកអបាយ
ទាំង ៤ ហើយ មិនគួរធ្វើនូវហេតុ ដ៏អាក្រក់ទាំង ៦ ( គឺ
អនន្តរិយកម្ម៥និងការរើសកចិត្តទៅកាន់សាសនាដទៃឡើយ )

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ បុគ្គលមិនគួរពោលថា បុគ្គលលះពួកកិលេសជាចំណែកៗ ដូច្នេះឡើយ ។

[ ២៨៥ ] បុគ្គលលះពួកកិលេសជាចំណែកៗ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវកមានធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើង ក្នុងសម័យនោះធម្មជាតណាមួយ ដែលមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ព្រះអរិយសាវកបានលះបង់ហើយ ជាមួយនឹងការកើតឡើងនៃទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បុគ្គលលះពួកកិលេសជាចំណែកៗ ដូច្នេះឡើយ ។

**ឱធិសោកថា ចប់**

# អដ្ឋកថា

## ឱធិសោកថា

[ ២៧៩ ] ឥឡូវនេះ នឹងពោលរឿងនៃការបែងចែកជាចំណែកៗ តទៅ ក្នុងរឿងនោះ ជនទាំងឡាយណាកាន់យកថា មានការលះកិលេសបាន ចំណែកខ្លះៗ គឺដោយចំណែកនីមួយៗ ចាកការឃើញទុក្ខជាដើម ដោយអំណាច នៃការត្រាស់ដឹងផ្សេងៗ នៃព្រះសោតាបន្នជាដើម ដូចនិកាយសមិតិយៈទាំង ឡាយក្នុងខណៈនេះ ដើម្បីទម្លាយលទ្ធិនោះ របស់ជនទាំងនោះ ទើបសកវាទី សួរថា **ឱធិសោ** ( បុគ្គលលះកិលេសបានជាចំណែកៗ ឬ ) ។ ពាក្យឆ្លើយ ទទួល ជាពាក្យរបស់បរវាទី ។ ការសាកសួរទៀត ជាពាក្យរបស់សកវាទី ។ ពាក្យបដិសេធ ជាពាក្យរបស់បរវាទី ព្រោះមិនមានភាពជាព្រះសោតាបន្ន ជាដើម ដោយឯកទេស គឺចំណែកខ្លះ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងវារៈទាំង ពួង ដោយឧបាយនេះឯង ៕

**អដ្ឋកថាឱធិសោកថា ចប់**

# អភិធម្មបិដក

## ជហាតិកថា

[ ២៨៦ ] បុថុជ្ជនលះកាមរាគ និងព្យាបាទឬ ។ អើ ។ ចុះលះជ្រះស្រឡះ លះមិនឲ្យមានសេសសល់ លះមិនឲ្យមានបដិសន្ធិ លះព្រមទាំងឫស លះព្រមទាំងតណ្ហា លះព្រមទាំងអនុស័យ លះដោយអរិយញ្ញាណ លះដោយអរិយមគ្គ កាលត្រាស់ដឹងនូវអកុប្បធម៌ទើបលះ កាលធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ទើបលះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៧ ] បុថុជ្ជនសង្កត់សង្កិនកាមរាគ និងព្យាបាទឬ ។ អើ ។ សង្កត់សង្កិនជ្រះស្រឡះ សង្កត់សង្កិនមិនឲ្យមានសេសសល់ សង្កត់សង្កិនមិនឲ្យមានបដិសន្ធិ សង្កត់សង្កិនព្រមទាំងឫស សង្កត់សង្កិនព្រមទាំងតណ្ហា សង្កត់សង្កិនព្រមទាំងអនុស័យ សង្កត់សង្កិនដោយអរិយញ្ញាណ សង្កត់សង្កិនដោយអរិយ-មគ្គ កាលត្រាស់ដឹងនូវអកុប្បធម៌ ទើបសង្កត់សង្កិន កាលធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ទើបសង្កត់សង្កិនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៨ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល លះកាមរាគ និងព្យាបាទ បុគ្គលនោះ លះជ្រះស្រឡះ លះមិនឲ្យមានសេសសល់ ។បេ។ កាលធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ទើបលះឬ ។ អើ ។ បុថុជ្ជនលះកាមរាគ និងព្យាបាទ បុថុជ្ជននោះ លះជ្រះស្រឡះ លះមិនឲ្យមានសេសសល់ ។បេ។ កាលធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ទើបលះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៩ ] បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល សង្កត់សង្កិនកាមរាគ និងព្យាបាទ បុគ្គលនោះ សង្កត់សង្កិនជ្រះស្រឡះ សង្កត់សង្កិនមិនឲ្យមានសេសសល់ ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ទើបសង្កត់សង្កិនឬ ។ អើ ។ បុថុជ្ជនសង្កត់សង្កិនកាមរាគ និងព្យាបាទ បុថុជ្ជននោះ សង្កត់សង្កិនជ្រះស្រឡះ សង្កត់សង្កិន មិនឲ្យមានសេសសល់ ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ទើបសង្កត់សង្កិនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩០ ] បុថុជ្ជនលះកាមរាគ និងព្យាបាទ តែបុថុជ្ជននោះ មិនលះជ្រះស្រឡះ មិនលះមិនឲ្យមានសេសសល់ មិនលះមិនឲ្យមានបដិសន្ធិ មិនលះព្រមទាំងឫស មិនលះព្រមទាំងតណ្ហា មិនលះព្រមទាំងអនុស័យ មិនលះដោយអរិយញ្ញាណ មិនលះដោយអរិយមគ្គ កាលមិនត្រាស់ដឹងនូវអកុប្បធម៌ហើយលះទេ កាលមិនធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលហើយ លះទេឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល លះកាមរាគ និងព្យាបាទ តែបុគ្គលនោះ មិនលះជ្រះស្រឡះ ។បេ។ មិនធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិ-ផល ទើបលះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩១ ] បុថុជ្ជនសង្កត់សង្កិនកាមរាគ និងព្យាបាទ តែបុថុជ្ជនោះ មិនសង្កត់សង្កិនជ្រះស្រឡះ មិនសង្កត់សង្កិនមិនឲ្យមានសេសសល់ ។បេ។ មិនធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ហើយសង្កត់សង្កិនទេឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល សង្កត់សង្កិនកាមរាគ និង

ព្យាបាទ តែបុគ្គលនោះ មិនសង្កត់សង្កិនជ្រះស្រឡះ មិនសង្កត់សង្កិនមិនឲ្យមានសេសសល់ ។បេ។ មិនធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ហើយសង្កត់សង្កិនទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩២ ] បុថុជ្ជនលះកាមរាគ និងព្យាបាទឬ ។ អើ ។ បុថុជ្ជនលះដោយមគ្គដូចម្តេច ។ លះដោយរូបាវចរមគ្គ ។ រូបាវចរមគ្គ ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំកពូនឡើង មិនមានអាសវៈ មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ ជាធម៌ដែលគន្ថៈមិនគប្បីដោតក្រង ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង មិនជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈមិនស្ទាបអង្អែល មិនជាប្រយោជន៍ដល់ឧបាទាន មិនប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបាវចរមគ្គ មិនមែនជាគ្រឿងចេញចាកវដ្ដៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំកពូនឡើង ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បើរូបាវចរមគ្គ មិនមែនជាគ្រឿងចេញចាកវដ្ដៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំកពូនឡើង ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុថុជ្ជនលះកាមរាគ និងព្យាបាទ ដោយរូបាវចរមគ្គ ដូច្នេះឡើយ ។

[ ២៩៣ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល

រមែងលះកាមរាគ និងព្យាបាទ ដោយអនាគាមិមគ្គ មគ្គនោះ ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំកពូនឡើង មិនមានអាសវៈ មិនជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ មិនប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បុថុជ្ជនលះកាមរាគ និងព្យាបាទ ដោយរូបាវចរមគ្គ មគ្គនោះ ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំកពូនឡើង មិនមានអាសវៈ មិនជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ មិនប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៤ ] បុថុជ្ជនលះកាមរាគ និងព្យាបាទ ដោយរូបាវចរមគ្គ តែមគ្គនោះ មិនមែនជាគ្រឿងចេញចាកវដ្តៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំកពូនឡើង ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ហើយលះកាមរាគ និងព្យាបាទ ដោយអនាគាមិមគ្គ តែមគ្គនោះ មិនមែនជាគ្រឿងចេញចាកវដ្តៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំកពូនឡើង ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៥ ] បុថុជ្ជនប្រាសចាករាគៈ ក្នុងកាមទាំងឡាយ តាំងនៅមាំ ក្នុងអនាគាមិផល ដំណាលនឹងការត្រាស់ដឹងធម៌ឬ ។ អើ ។ បុថុជ្ជនតាំងនៅស៊ប់

ក្នុងអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៦ ] បុថុជ្ជនប្រាសចាករាគៈ ក្នុងកាមទាំងឡាយ តាំងនៅមាំ ក្នុងអនាគាមិផល ជំណាលនឹងការត្រាស់ដឹងធម៌ឬ ។ អើ ។ បុថុជ្ជនអប់រំមគ្គទាំង ៣ ជំណាលគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជនអប់រំមគ្គទាំង ៣ ជំណាលគ្នាឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផលទាំង ៣ ជំណាលគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផលទាំង ៣ ជំណាលគ្នាឬ ។ អើ ។ ការប្រជុំនៃផស្សៈ ៣ វេទនា ៣ សញ្ញា ៣ ចេតនា ៣ ចិត្ត ៣ សទ្ធា ៣ វិរិយៈ ៣ សតិ ៣ សមាធិ ៣ បញ្ញា ៣ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៧ ] បុថុជ្ជនប្រាសចាករាគៈ ក្នុងកាមទាំងឡាយ តាំងនៅមាំ ក្នុងអនាគាមិផល ជំណាលនឹងការត្រាស់ដឹងធម៌ឬ ។ អើ ។ បុគ្គលលះកិលេសដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះកិលេសដោយសកទាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ចុះលះដោយមគ្គណា ។ លះដោយអនាគាមិមគ្គ ។ បុគ្គលលះសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ដោយអនាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ដោយអនាគាមិមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់សម្តែងនូវសោតាបត្តិផល ព្រោះការលះសំយោជនៈទាំង ៣ យ៉ាងឬ ។ អើ ។ បើព្រះមានព្រះភាគទ្រង់សម្តែងនូវសោតាបត្តិផល ព្រោះការលះសំយោជនៈទាំង ៣ យ៉ាង ម្នាលអ្នក

ដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ដោយអនាគាមិមគ្គទេ ។បេ។ បុគ្គលលះកាមរាគ ដ៏គ្រោតគ្រាត ព្យាបាទ ដ៏គ្រោតគ្រាត ដោយអនាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលលះកាមរាគដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអនាគាមិមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់សម្តែងនូវសកទាគាមិផល ព្រោះភាពនៃកាមរាគ និងព្យាបាទដ៏ស្រាលស្តើងឬ ។ អើ ។ បើព្រះមានព្រះភាគទ្រង់សម្តែងនូវសកទាគាមិផល ព្រោះភាពនៃកាមរាគ និងព្យាបាទដ៏ស្រាលស្តើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលលះកាមរាគដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអនាគាមិមគ្គ ដូច្នេះឡើយ ។

[ ២៩៨ ] បុថុជ្ជនប្រាសចាករាគៈ ក្នុងកាមទាំងឡាយ តាំងនៅស៊ប់ក្នុងអនាគាមិផល ដំណាលនឹងការត្រាស់ដឹងធម៌ឬ ។ អើ ។ ជនណាមួយ ត្រាស់ដឹងធម៌ ជនទាំងអស់នោះ រមែងតាំងនៅស៊ប់ ក្នុងអនាគាមិផល ដំណាលនឹងការត្រាស់ដឹងធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៩ ] អ្នកមិនគួរពោលថា បុថុជ្ជនលះកាមរាគ និងព្យាបាទឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា

ក្នុងចំណែកដែលកន្លងទៅហើយ ពួកគ្រូទាំង ៦ នោះ ជា
អ្នកមានយស មិនមានក្លិនឆ្អាប ជាអ្នករួចស្រឡះចាក
កាមសំយោជនៈ ព្រោះករុណា នឿយណាយនឹងកាមរាគ
ហើយចូលទៅកើត ក្នុងព្រហ្មលោក ពួកសាវករបស់គ្រូ

ទាំង ៦ នោះ មានចំនួនច្រើនរយ មិនមានក្ងិនធ្លាប ជា
អ្នករួចស្រឡះ ចាកកាមសំយោជនៈ ព្រោះករុណា នឿយ
ណាយនឹងកាមរាគ ហើយចូលទៅកើត ក្នុងព្រហ្មលោក។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ បុថុជ្ជនលះកាមរាគ និងព្យាបាទបានដែរឬ ។

[ ៣០០ ] បុថុជ្ជនលះកាមរាគ និងព្យាបាទបានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អំបាលយ៉ាងគ្រូឈ្មោះសុនេត្តនោះ ដែលមានអាយុវែងយ៉ាងនេះ ស្ថិតនៅអស់កាលយូរយ៉ាងនេះ គង់មិនរួចចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស តថាគតពោលថា មិនរួចចាកទុក្ខឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះមិនត្រាស់ដឹង ព្រោះមិនចាក់ធ្លុះ នូវធម៌ទាំង ៤ ។ ធម៌ទាំង ៤ តើដូចម្តេច ។ ព្រោះមិនត្រាស់ដឹង មិនចាក់ធ្លុះនូវសីលដ៏ប្រសើរ ១ ព្រោះមិនត្រាស់ដឹង មិនចាក់ធ្លុះនូវសមាធិដ៏ប្រសើរ ១ ព្រោះមិនត្រាស់ដឹង មិនចាក់ធ្លុះនូវបញ្ញាដ៏ប្រសើរ ១ ព្រោះមិនត្រាស់ដឹង មិនចាក់ធ្លុះនូវវិមុត្តិដ៏ប្រសើរ ១ ម្នាលភិក្ខុទាំងឡាយ បើអរិយសីលនោះ បុគ្គលបានត្រាស់ដឹង ចាក់ធ្លុះហើយ អរិយសមាធិនោះ បុគ្គលបានត្រាស់ដឹង ចាក់ធ្លុះហើយ អរិយបញ្ញានោះ បុគ្គលបានត្រាស់ដឹង ចាក់ធ្លុះហើយ អរិយវិមុត្តិនោះ បុគ្គលបានត្រាស់ដឹង ចាក់ធ្លុះហើយ ភវតណ្ហា ក៏បុគ្គលនោះ បានផ្តាច់ផ្តិល តណ្ហាជាគ្រឿងនាំសត្វឲ្យទៅកើតក្នុងភព នៃបុគ្គលនោះ ក៏អស់រលីង ភពថ្មីនៃបុគ្គលនោះ ក៏មិនមាន ក្នុងកាលឥឡូវនេះទៀតឡើយ ។

ធម៌ទាំងនេះ គឺសីល ១ សមាធិ ១ បញ្ញា ១ វិមុត្តិ ១
ជាធម៌ដ៏ប្រសើរ ព្រះគោតម ព្រះអង្គមានយស បាន
ត្រាស់ដឹងហើយ ព្រោះហេតុនោះ ព្រះពុទ្ធទ្រង់ជ្រាប
ច្បាស់ ទើបទ្រង់ត្រាស់ប្រាប់ធម៌នោះ ដល់ភិក្ខុទាំងឡាយ
ថា ព្រះសាស្ដា ទ្រង់អ្នកធ្វើនូវទីបំផុតនៃទុក្ខ មានបញ្ញាចក្ខុ
បរិនិព្វានហើយ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បុថុជ្ជនលះកាមរាគ និងព្យាបាទបាន ដូច្នេះឡើយ ។

ជហាតិកថា ចប់

# អដ្ឋកថា

## ជហាតិកថា

### ឆសុត្តាហរណកថា

[ ២៨៦ ] ឥឡូវនេះ នឹងពោលអំពីការលះកិលេសដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិរបស់សមិតិយៈជាដើម ក្នុងខណៈនេះថា បុថុជ្ជនដែលបានឈាន ព្រមគ្នានឹងការត្រាស់ដឹងសច្ចៈ រមែងជាបុគ្គលឈ្មោះថា ព្រះអនាគាមី និងក្នុងកាលដែលលោកនៅជាបុថុជ្ជននោះឯង ជាអ្នកលះកាមរាគៈ និងព្យាបាទបានហើយ ដូច្នេះ ដើម្បីទម្លាយលទ្ធិនោះរបស់ជនទាំងនោះ ទើបសកវាទីសួរថា **ជហាតិ បុថុជ្ជនោ** ។ កាលបរវាទីមិនឃើញនូវការចោមរោមនៃកិលេសទាំងនោះ ដែលត្រូវឈានសង្កត់សង្កិន ទើបឆ្លើយទទួល ។ ព្រោះការលះកិលេសទាំងនោះ ដែលត្រូវសង្កត់សង្កិនហើយ ដោយឈានបានដោយឥតសេសសល់ ដោយអនាគាមិមគ្គនោះឯងមាន ព្រោះហេតុនោះ ទើបសកវាទីសួរទៀតថា **អច្ចន្តំ** ។ ពាក្យបដិសេធ ជាពាក្យរបស់បរវាទី ព្រោះមិនមានការលះបែបនោះ ។

[ ២៨៧ ] បទថា **វិក្ខម្ភេតិ** ជាពាក្យសួររបស់សកវាទី សំដៅយកការសង្កត់កិលេសដោយមិនអស់រលីងប៉ុណ្ណោះ ។ បន្ទាប់អំពីនោះទៅ ជាការប្រៀបធៀបបុថុជ្ជន និងព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអនាគាមិមគ្គ ។ ពាក្យ

នោះ មានអត្ថងាយយល់ហើយ ។

[ ២៩៥ ] ខាងមុខអំពីនេះ បរវាទី ត្រូវសកវាទីសួរថា **អនាគាមិជលេសណ្ឋាតិ** ក៏ឆ្លើយទទួល ព្រោះសំដៅយកបុថុជ្ជនដែលបានឈាន ហើយជាព្រះអនាគាមី ។ ត្រូវសួរថា **អរហាត្តេសណ្ឋាតិ** ក៏ឆ្លើយបដិសេធ ព្រោះមិនមានការលះឧទ្ធម្ភាគិយសំយោជនៈ ដោយទស្សនមគ្គ ( សោតាបត្តិមគ្គ ) ។

[ ២៩៦ ] បរវាទីត្រូវសួរថា **អបុញ្ញំ អចរិមំ តយោ មគ្គេ** ក៏ឆ្លើយបដិសេធ ព្រោះមិនមានការចម្រើនបែបនោះ ។ ត្រូវសួរដដែលទៀត ក៏ឆ្លើយទទួល ព្រោះសំដៅយកសភាវកិច្ចនៃមគ្គទាំង ៣ ។ ក្នុងពាក្យសួរដល់សាមញ្ញ-ផលទាំងឡាយ ក៏ន័យនេះដូចគ្នា ។

[ ២៩៧ ] បរវាទីត្រូវសួរថា **កតមេន មគ្គេន** ក៏ឆ្លើយថា **អនាគាមិ-មគ្គេន** ព្រោះសំដៅយកបុថុជ្ជនដែលបានឈាន ហើយជាព្រះអនាគាមី ។ ត្រូវសួរដល់ការលះសំយោជនៈ មានសក្កាយទិដ្ឋិជាដើមទៀត បរវាទីក៏បដិសេធ ព្រោះកិលេសទាំង ៣ នោះ ដែលអនាគាមិមគ្គ មិនបានលះ ។ ត្រូវសួរជាលើកទី ២ ក៏ឆ្លើយទទួល ព្រោះសំដៅយកភាពដែលបឋមមគ្គនោះ មកជាអនាគាមិមគ្គ របស់អ្នកបានឈាន ។ ពាក្យដ៏សេស ក្នុងទីនេះមានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាជហាតិកថា ចប់**

# អភិធម្មបិដក

## សព្វមត្តីតិកថា

[ ៣០១ ] ធម្មជាតទាំងពួង ( មានរូបក្ខន្ធជាដើម ) មានឬ ។ អើ ។ ធម្មជាតទាំងពួង មានក្នុងសរីរៈទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួង មានឬ ។ អើ ។ ធម្មជាតទាំងពួង មានសព្វកាលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួង មានឬ ។ អើ ។ ធម្មជាតទាំងពួង មានដោយអាការទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួងមានឬ ។ អើ ។ ធម្មជាតទាំងពួង មានក្នុងធម៌ទាំងពួងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួង មានឬ ។ អើ ។ ធម្មជាតទាំងពួងមាន ព្រោះធ្វើនូវពាក្យថា មិនគួរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួង មានឬ ។ អើ ។ ធម្មជាតណាមិនមាន ធម្មជាតនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ធម្មជាតទាំងពួងមានឬ ។ អើ ។ ទិដ្ឋិណា ( របស់អ្នក ) ថា ធម្មជាតទាំងពួងមាន ទិដ្ឋិនោះ ជាមិច្ឆាទិដ្ឋិ ទិដ្ឋិណា ( របស់យើង ) ថា ជាមិច្ឆាទិដ្ឋិ ទិដ្ឋិនោះ ជាសម្មាទិដ្ឋិ យ៉ាងនេះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០២ ] រូបជាអតីត មានឬ ។ អើ ។ ក្រែងរូបជាអតីត រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីវិនាសក្រៃលែងឬ ។ អើ ។ បើរូបជាអតីត រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីវិនាសក្រៃលែងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

រូបជាអតីត មាន ដូច្នេះទេ ។

[ ៣០៣ ] រូបជាអនាគត មានឬ ។ អើ ។ ក្រែងរូបជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដទេឬ ។ អើ ។ បើរូបជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាអនាគតមាន ដូច្នេះទេ ។

[ ៣០៤ ] រូបជាបច្ចុប្បន្នមាន រូបជាបច្ចុប្បន្នមិនទាន់រលត់ មិនទាន់ទៅប្រាស មិនទាន់ប្រែប្រួល មិនទាន់ដល់នូវសេចក្ដីវិនាស មិនទាន់ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អើ ។ រូបជាអតីតមាន រូបជាអតីតមិនទាន់រលត់ មិនទាន់ទៅប្រាស មិនទាន់ប្រែប្រួល មិនទាន់ដល់នូវសេចក្ដីវិនាស មិនទាន់ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៥ ] រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន កើតមាន ដុះដាល លូតលាស់ ចម្រុងចម្រើន កើតឡើងប្រាកដឬ ។ អើ ។ រូបជាអនាគត មាន រូបជាអនាគត កើតមាន ដុះដាល លូតលាស់ ចម្រុងចម្រើន កើតឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៦ ] រូបជាអតីត មាន រូបជាអតីត រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អើ ។ រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្ដី

វិនាស ដល់នូវសេចក្តីវិនាសក្រៃលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៧ ] រូបជាអនាគត មាន រូបជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតប្រាកដឬ ។ អើ ។ រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៣០៨ ] រូបជាអតីត មានឬ ។ អើ ។ ក្រែងរូបជាអតីត រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីវិនាសក្រៃលែងហើយឬ ។ អើ ។ បើរូបជាអតីត រលត់ ។បេ។ ដល់នូវសេចក្តីវិនាសក្រៃលែង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាអតីត មាន ដូច្នេះទេ ។

[ ៣០៩ ] រូបជាអនាគត មានឬ ។ អើ ។ ក្រែងរូបជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដឬ ។ អើ ។ បើរូបជាអនាគត មិនទាន់កើត ។បេ។ មិនទាន់កើតឡើងប្រាកដ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអនាគត មាន ដូច្នេះទេ ។

[ ៣១០ ] រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន មិនទាន់រលត់ មិនទាន់ទៅប្រាស មិនទាន់ប្រែប្រួល មិនទាន់ដល់នូវសេចក្តីវិនាស មិនទាន់ដល់នូវសេចក្តីវិនាសក្រៃលែងឬ ។ អើ ។ រូបជាអតីត មាន រូបជាអតីត មិនទាន់រលត់ មិនទាន់ទៅប្រាស មិនទាន់ប្រែប្រួល មិនទាន់ដល់នូវសេចក្តីវិនាស មិន

ទាន់ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៣១១ ] រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន កើតមាន ជុះជាល លូតលាស់ ចម្រុងចម្រើន កើតឡើងប្រាកដឬ ។ អើ ។ រូបជាអនាគត មាន រូបជាអនាគត កើតមាន ជុះជាល លូតលាស់ ចម្រុងចម្រើន កើតឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៣១២ ] រូបជាអតីត មាន រូបជាអតីត រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អើ ។ រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន រលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៣ ] រូបជាអនាគត មាន រូបជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ជុះជាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដឬ ។ អើ ។ រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន មិនទាន់កើត មិនទាន់មាន មិនទាន់ជុះជាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៤ ] វេទនាជាអតីត មាន ។បេ។ សញ្ញា មាន សង្ខារ មាន ។បេ។ វិញ្ញាណ មានឬ ។ អើ ។ ក្រែងវិញ្ញាណជាអតីតរលត់ ទៅប្រាស ប្រែប្រួល ដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីវិនាសក្រៃលែងឬ ។ អើ ។ បើវិញ្ញាណជាអតីតរលត់ ។បេ។ ដល់នូវសេចក្ដីវិនាសក្រៃលែងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិញ្ញាណជាអតីត មាន ដូច្នេះទេ ។

[ ៣១៥ ] វិញ្ញាណជាអនាគតមានឬ ។ អើ ។ ក្រែងវិញ្ញាណជាអនាគត មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់លូតលាស់ មិនទាន់ចម្រុងចម្រើន មិនទាន់កើតប្រាកដឬ ។ អើ ។ បើវិញ្ញាណជាអនាគត មិនទាន់កើត ។បេ។ មិនទាន់កើតប្រាកដទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិញ្ញាណជាអនាគត មាន ដូច្នេះទេ ។

[ ៣១៦ ] វិញ្ញាណជាបច្ចុប្បន្ន មាន វិញ្ញាណជាបច្ចុប្បន្ន មិនទាន់រលត់ ។បេ។ មិនទាន់ដល់នូវសេចក្តីវិនាសក្រែលែងឬ ។ អើ ។ វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនទាន់រលត់ ។បេ។ មិនទាន់ដល់នូវសេចក្តីវិនាសក្រែលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៧ ] វិញ្ញាណជាបច្ចុប្បន្ន មាន វិញ្ញាណជាបច្ចុប្បន្នកើតមាន ។បេ។ កើតឡើងប្រាកដឬ ។ អើ ។ វិញ្ញាណជាអនាគត មាន វិញ្ញាណជាអនាគត កើត ។បេ។ កើតឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៨ ] វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត រលត់ ។បេ។ ដល់នូវសេចក្តីវិនាសក្រែលែងឬ ។ អើ ។ វិញ្ញាណជាបច្ចុប្បន្ន មាន វិញ្ញាណជាបច្ចុប្បន្ន រលត់ ។បេ។ ដល់នូវសេចក្តីវិនាសក្រែលែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៩ ] វិញ្ញាណជាអនាគត មាន វិញ្ញាណជាអនាគត មិនទាន់កើត ។បេ។ មិនទាន់កើតឡើងប្រាកដឬ ។ អើ ។ វិញ្ញាណជាបច្ចុប្បន្នមាន វិញ្ញាណជាបច្ចុប្បន្ន មិនទាន់កើត មិនទាន់មាន ។បេ។ មិនទាន់កើតឡើងប្រាកដឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២០ ] ( ខ្ញុំ ) ធ្វើនូវរូបជាបច្ចុប្បន្ន មិនឲ្យបែកគ្នា រួមហៅថា បច្ចុប្បន្ន ឬថា រូប ថារូប ឬថា បច្ចុប្បន្ន ( ហើយសួរថា ) កាយទាំងនេះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា កើតជាមួយគ្នាឬ ។ អើ ។ រូបជាបច្ចុប្បន្នកាលរលត់ តែងលះបង់ភាពជាបច្ចុប្បន្នឬ ។ អើ ។ រូបជាបច្ចុប្បន្ន តែងលះបង់ភាពជារូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២១ ] ( ខ្ញុំ ) ធ្វើនូវរូបជាបច្ចុប្បន្ន មិនឲ្យបែកគ្នា រួមហៅថា បច្ចុប្បន្ន ឬថា រូប ថារូប ឬថា បច្ចុប្បន្ន ( ហើយសួរថា ) កាយទាំងនេះ តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា កើតជាមួយគ្នាឬ ។ អើ ។ រូបជាបច្ចុប្បន្នកាលរលត់ តែងមិនលះបង់ភាពជារូបឬ ។ អើ ។ រូបជាបច្ចុប្បន្ន តែងមិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( ខ្ញុំ ) ធ្វើនូវសំពត់សមិនឲ្យបែកគ្នា រួមហៅថា ស ឬថា សំពត់ ថាសំពត់ ឬថា ស ( ហើយសួរថា ) សំពត់ទាំងឯង តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា កើតជាមួយគ្នាឬ ។ អើ ។ សំពត់ស បុគ្គលកាលជ្រលក់ រមែងលះបង់ភាព-សឬ ។ អើ ។ សំពត់តែងលះបង់ភាពជាសំពត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ( ខ្ញុំ ) ធ្វើនូវសំពត់ស មិនឲ្យបែកគ្នា រួមហៅថា ស ឬថា សំពត់ ថាសំពត់ ឬថា ស ( ហើយសួរថា ) សំពត់ទាំងឯង តាំងនៅក្នុងទីជាមួយគ្នា ស្មើគ្នា មានចំណែកស្មើគ្នា កើតជាមួយគ្នាឬ ។ អើ ។ សំពត់ស បុគ្គលកាលជ្រលក់ រមែងមិនលះបង់ភាពជាសំពត់ឬ ។ អើ ។

សំពត់តែងមិនលះបង់ភាព-សទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២២ ] រូប មិនលះបង់ភាពជារូបឬ ។ អើ ។ រូប ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបលះបង់ភាពជារូបឬ ។ រូប ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ បើរូបជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបមិនលះបង់ភាពជារូប ដូច្នេះទេ ។

[ ៣២៣ ] និព្វាន មិនលះបង់ភាពជានិព្វានឬ ។ និព្វាន ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អើ ។ រូប មិនលះបង់ភាពជារូបឬ ។ រូប ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៤ ] រូប មិនលះបង់ភាពជារូបឬ ។ រូប ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ និព្វាន មិនលះបង់ភាពជានិព្វានឬ ។ និព្វាន ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៥ ] អតីត មាន អតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ អនាគត មាន អនាគត មិនលះបង់ភាពជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អតីតមាន អតីតមិនលះបង់ភាពជាអតីតឬ ។ អើ ។ បច្ចុប្បន្ន មាន បច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៦ ] អនាគត មាន អនាគត មិនលះបង់ភាពជាអនាគតឬ ។ អើ ។ អតីត មាន អតីត មិនលះបង់ភាពជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៧ ] បច្ចុប្បន្ន មាន បច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អើ ។ អតីតមានអតីតមិនលះបង់ភាពជាអតីតឬ ។អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៨ ] អតីត មាន អតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ អតីត ទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងអតីត មិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ បើអតីត មិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អតីត មាន អតីត មិនលះបង់ភាពជាអតីត ដូច្នេះទេ ។

[ ៣២៩ ] និព្វាន មាន និព្វាន មិនលះបង់ភាពជានិព្វានឬ ។ និព្វានជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អើ ។ អតីត មាន អតីត មិនលះបង់ភាពជាអតីតឬ ។ អតីត ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣០ ] អតីត មាន អតីត មិនលះបង់ភាពជាអតីតឬ ។ អតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ និព្វាន មាន និព្វាន មិនលះបង់ភាពជានិព្វានឬ ។ និព្វាន ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣១ ] រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ រូបជាអនាគត មាន រូបជាអនាគត មិនលះបង់ភាពជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣២ ] រូបជាអនាគត មាន រូបជាអនាគត មិនលះបង់ភាពជាអនាគតឬ ។ អើ ។ រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៣ ] រូបជាបច្ចុប្បន្ន មាន រូបជាបច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អើ ។ រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៤ ] រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ រូបជាអតីត ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបជាអតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ បើរូបជាអតីត ជាធម្មជាតមិនទៀង ។បេ។ តែងប្រែប្រួលជាធម្មតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីត ដូច្នេះទេ ។

[ ៣៣៥ ] និព្វាន មាន និព្វាន មិនលះបង់ភាពជានិព្វាន និព្វានជាធម្មជាត

ទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អើ ។ រូបជាអតីត មាន រូបជាអតីតមិនលះបង់ភាពជាអតីត រូបជាអតីត ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៦ ] រូបជាអតីត មាន រូបជាអតីត មិនលះបង់ភាពជាអតីត រូបជាអតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ និព្វាន មាន និព្វានមិនលះបង់ភាពជានិព្វាន និព្វានជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៧ ] វេទនាជាអតីត មាន ។បេ។ សញ្ញាជាអតីត មាន ។បេ។ សង្ខារជាអតីត មាន ។បេ។

[ ៣៣៨ ] វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ វិញ្ញាណជាអនាគត មាន វិញ្ញាណជាអនាគត មិនលះបង់ភាពជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ វិញ្ញាណជាបច្ចុប្បន្ន មាន វិញ្ញាណជាបច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៩ ] វិញ្ញាណជាអនាគត មាន វិញ្ញាណជាអនាគត មិនលះបង់ភាពជាអនាគតឬ ។ អើ ។ វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤០ ] វិញ្ញាណជាបច្ចុប្បន្ន មាន វិញ្ញាណជាបច្ចុប្បន្ន មិនលះបង់ភាពជាបច្ចុប្បន្នឬ ។ អើ ។ វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤១ ] វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីតឬ ។ អើ ។ វិញ្ញាណជាអតីត ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងវិញ្ញាណជាអតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ បើវិញ្ញាណជាអតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិញ្ញាណជាអតីតមាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីត ដូច្នេះទេ ។

[ ៣៤២ ] និព្វាន មាន និព្វានមិនលះបង់ភាពជានិព្វាន និព្វានជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អើ ។ វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីត វិញ្ញាណជាអតីត ជាធម្មជាតទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៣ ] វិញ្ញាណជាអតីត មាន វិញ្ញាណជាអតីត មិនលះបង់ភាពជាអតីត វិញ្ញាណជាអតីត ជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួលជាធម្មតាឬ ។ អើ ។ និព្វាន មាន និព្វាន មិនលះបង់ភាពជានិព្វាន និព្វានជាធម្មជាតមិនទៀង មិនទៀងទាត់ មិនពិតប្រាកដ តែងប្រែប្រួល

ជាធម្មតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៤ ] អតីត មិនមានឬ ។ អើ ។ បើអតីតមិនមានទេ ពាក្យថា អតីតមាន ជាពាក្យខុស មួយទៀត បើអតីតមិនមាន ពាក្យថា អតីតមាន ជាពាក្យខុស ។ អនាគត មិនមានឬ ។ អើ ។ បើអនាគតមិនមាន ពាក្យថា អនាគតមាន ជាពាក្យខុស មួយទៀត បើអនាគតមិនមាន ពាក្យថា អនាគតមាន ជាពាក្យខុស ។

[ ៣៤៥ ] អនាគតកើតហើយ បច្ចុប្បន្នកំពុងកើតឬ ។ អើ ។ អនាគតនោះឯង គឺបច្ចុប្បន្ននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគតនោះឯង គឺបច្ចុប្បន្ននោះឬ ។ អើ ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ រមែងកើតឥឡូវនេះឬ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ រមែងកើតឥឡូវនេះឬ ។ អើ ។ ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះ ឈ្មោះថា ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៦ ] បច្ចុប្បន្នកើតហើយ អតីតកើតឥឡូវនេះឬ ។ អើ ។ បច្ចុប្បន្ននោះឯង គឺអតីតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បច្ចុប្បន្ននោះឯង គឺអតីតនោះឬ ។ អើ ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ រមែងកើតឥឡូវនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ

រមែងកើតឥឡូវនេះឬ ។ អើ ។ ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះ ឈ្មោះថា ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៧ ] អនាគតកើតហើយ បច្ចុប្បន្នកើតឥឡូវនេះ បច្ចុប្បន្នកើតហើយ អតីតកើតឥឡូវនេះឬ ។ អើ ។ អនាគតនោះឯង គឺបច្ចុប្បន្ននោះ បច្ចុប្បន្ននោះឬ ។ គឺអតីតនោះឬ អតីតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគតនោះឯង គឺបច្ចុប្បន្ននោះ គឺអតីតនោះឬ ។ អើ ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ រមែងកើតឥឡូវនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតកើតហើយ រមែងកើតឥឡូវនេះ ឈ្មោះថា ធម្មជាតកើតហើយ រមែងកើតឥឡូវនេះឬ ។ អើ ។ ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះ ឈ្មោះថា ធម្មជាតមិនកើតហើយ រមែងមិនកើតឥឡូវនេះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៨ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលឃើញរូបជាអតីត ដោយចក្ខុជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក សំឡេង សោតវិញ្ញាណ អាកាស មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលស្តាប់សំឡេងជាអតីត ដោយត្រចៀកជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ច្រមុះ ក្លិន ឃានវិញ្ញាណ ខ្យល់ មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលហិតក្លិនជាអតីត ដោយច្រមុះជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អណ្តាត រស ជិវ្ហាវិញ្ញាណ

ទឹក មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលលិទ្ធភ្លក្សរសជាអតីត ដោយអណ្តាតជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ផុដ្ឋ កាយ-វិញ្ញាណ ដី មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលប៉ះពាល់ផុដ្ឋ ជាអតីត ដោយកាយជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចិត្ត ធម៌ មនោវិញ្ញាណ វត្ថុ មនសិការ ជាអតីត មានឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវធម្មារម្មណ៍ជាអតីត ដោយចិត្តជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៩ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាអនាគត មានឬ ។ អើ ។ បុគ្គលឃើញរូបជាអនាគត ដោយចក្ខុជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ធម្មារម្មណ៍ មនោ-វិញ្ញាណ វត្ថុ មនសិការ ជាអនាគត មានឬ ។ អើ ។ បុគ្គលដឹងច្បាស់ នូវធម្មារម្មណ៍ជាអនាគត ដោយចិត្តជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥០ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាបច្ចុប្បន្ន បុគ្គលឃើញរូបជាបច្ចុប្បន្ន ដោយចក្ខុជាបច្ចុប្បន្នឬ ។ អើ ។ ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាអតីត បុគ្គលឃើញរូបជាអតីត ដោយចក្ខុជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ វត្ថុ មនសិការ ជាបច្ចុប្បន្នមាន បុគ្គលដឹងច្បាស់នូវធម្មារម្មណ៍ជាបច្ចុប្បន្ន ដោយចិត្តជាបច្ចុប្បន្នឬ ។ អើ ។ ចិត្ត ធម៌ មនោ-វិញ្ញាណ វត្ថុ មនសិការ ជាអតីត មាន បុគ្គលដឹងច្បាស់ នូវធម្មារម្មណ៍ជា

អតីត ដោយចិត្តជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥១ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាបច្ចុប្បន្ន មាន បុគ្គលឃើញរូបជាបច្ចុប្បន្ន ដោយចក្ខុជាបច្ចុប្បន្នឬ ។ អើ ។ ចក្ខុ រូប ចក្ខុ-វិញ្ញាណ ពន្លឺ មនសិការ ជាអនាគត មាន បុគ្គលឃើញរូបជាអនាគតដោយចក្ខុជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀកជាបច្ចុប្បន្ន ។បេ។ ច្រមុះ អណ្តាត កាយ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ វត្ថុ មនសិការ មាន បុគ្គលដឹងច្បាស់ នូវធម្មារម្មណ៍ជាបច្ចុប្បន្ន ដោយចិត្តជាបច្ចុប្បន្នឬ ។ អើ ។ ចិត្ត ធម៌ មនោវិញ្ញាណ វត្ថុ មនសិការ ជាអនាគតមាន បុគ្គលដឹងច្បាស់នូវធម្មារម្មណ៍ជាអនាគត ដោយចិត្តជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥២ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាអតីត មាន តែបុគ្គលមិនឃើញរូបជាអតីត ដោយចក្ខុជាអតីតឬ ។ អើ ។ ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាបច្ចុប្បន្នមាន តែបុគ្គលមិនឃើញរូបជាបច្ចុប្បន្ន ដោយចក្ខុជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក ជាអតីត ។បេ។ ច្រមុះ អណ្តាត កាយ ។បេ។ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ វត្ថុ មនសិការ មាន តែបុគ្គលមិនដឹងច្បាស់ នូវធម្មារម្មណ៍ជាអតីត ដោយចិត្តជាអតីតឬ ។ អើ ។ ចិត្ត ធម៌ មនោវិញ្ញាណ វត្ថុ មនសិការ ជាបច្ចុប្បន្នមាន តែបុគ្គលមិនដឹងច្បាស់ នូវធម្មារម្មណ៍ជាបច្ចុប្បន្ន ដោយចិត្តជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៣ ] ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាអនាគតមាន តែបុគ្គលមិនឃើញរូបជាអនាគត ដោយចក្ខុជាអនាគតឬ ។ អើ ។ ចក្ខុ រូប ចក្ខុវិញ្ញាណ ពន្លឺ មនសិការ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនឃើញរូប ជាបច្ចុប្បន្ន ដោយចក្ខុជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក ច្រមុះ អណ្តាត កាយ ជាអនាគតមាន ។បេ។ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ វត្ថុ មនសិការ មាន តែបុគ្គលមិនដឹងច្បាស់នូវធម្មារម្មណ៍ជាអនាគត ដោយចិត្តជាអនាគតឬ ។ អើ ។ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ វត្ថុ មនសិការ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនដឹងច្បាស់នូវធម្មារម្មណ៍ជាបច្ចុប្បន្ន ដោយចិត្តជាបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៤ ] ញាណ ជាអតីត មានឬ ។ អើ ។ បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើនូវអំពើដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អើ ។ បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៥ ] ញាណ ជាអនាគត មានឬ ។ អើ ។ បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើនូវអំពើដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អើ ។ បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៦ ] ញាណ ជាបច្ចុប្បន្ន មាន បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អើ ។ ញាណ ជាអតីត មាន បុគ្គលធ្វើនូវអំពើដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ជាបច្ចុប្បន្ន មាន បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អើ ។ ញាណ ជាអតីត មាន បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ជាបច្ចុប្បន្ន មាន បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អើ ។ ញាណ ជាអនាគត មាន បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ជាបច្ចុប្បន្ន មាន បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អើ ។ ញាណ ជាអនាគត មាន បុគ្គលកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៧ ] ញាណ ជាអតីត មាន តែបុគ្គលមិនធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះទេឬ ។ អើ ។ ញាណ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ជាអតីត មាន តែបុគ្គលមិន

កំណត់ដឹងនូវទុក្ខ មិនលះបង់នូវសមុទ័យ មិនធ្វើឲ្យជាក់ច្បាស់នូវនិរោធ មិនអប់រំនូវមគ្គ ដោយញាណនោះទេឬ ។ អើ ។ ញាណ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនកំណត់ដឹងនូវទុក្ខ មិនលះបង់នូវសមុទ័យ មិនធ្វើឲ្យជាក់ច្បាស់នូវនិរោធ មិនអប់រំនូវមគ្គ ដោយញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៨ ] ញាណ ជាអនាគត មាន តែបុគ្គលមិនធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះទេឬ ។ អើ ។ ញាណ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនធ្វើនូវអំពើ ដែលគួរធ្វើដោយញាណ ព្រោះញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ជាអនាគត មាន តែបុគ្គលមិនកំណត់ដឹងនូវទុក្ខ មិនលះបង់នូវសមុទ័យ មិនធ្វើឲ្យជាក់ច្បាស់នូវនិរោធ មិនអប់រំនូវមគ្គ ដោយញាណនោះទេឬ ។ អើ ។ ញាណ ជាបច្ចុប្បន្ន មាន តែបុគ្គលមិនកំណត់ដឹងនូវទុក្ខ មិនលះបង់នូវសមុទ័យ មិនធ្វើឲ្យជាក់ច្បាស់នូវនិរោធ មិនអប់រំនូវមគ្គ ដោយញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៩ ] ព្រះអរហន្ត មានរាគៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយរាគៈ ព្រោះរាគៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានទោសៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយទោសៈ ព្រោះទោសៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានមោហៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយមោហៈ ព្រោះមោហៈ

នោះឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានមានះជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយមានះ ព្រោះមានះនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានទិដ្ឋិជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានវិចិកិច្ឆាជាអតីតឬ ។ អើ ។ ព្រះអរហន្តប្រកបដោយវិចិកិច្ឆា ព្រោះវិចិកិច្ឆានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តមានថីនៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយថីនៈ ព្រោះថីនៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានឧទ្ធច្ចៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយឧទ្ធច្ចៈ ព្រោះឧទ្ធច្ចៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអហិរិកៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអហិរិកៈ ព្រោះអហិរិកៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអនោត្តប្បៈជាអតីតឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអនោត្តប្បៈ ព្រោះអនោត្តប្បៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦០ ] អនាគាមិបុគ្គល មានសក្កាយទិដ្ឋិ ជាអតីតឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល មានវិចិកិច្ឆា ជាអតីត មានសីលព្វតបរាមាសៈ ជាអតីត មានកាមរាគដ៏ស្រោលស្តើង ជាអតីត មានព្យាបាទដ៏ស្រោលស្តើង ជាអតីតឬ ។ អើ ។ អនាគាមិបុគ្គល មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦១ ] សកទាគាមិបុគ្គល មានសក្កាយទិដ្ឋិ ជាអតីតឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ សកទាគាមិបុគ្គល មានវិចិកិច្ឆា ជាអតីត មានសីលព្វតបរាមាសៈជាអតីត មានកាមរាគៈដ៏គ្រោតគ្រាត ជាអតីត មានព្យាបាទដ៏គ្រោតគ្រាត ជាអតីតឬ ។ អើ ។ សកទាគាមិបុគ្គល មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦២ ] សោតាបន្នបុគ្គល មានសក្កាយទិដ្ឋិ ជាអតីតឬ ។ អើ ។ សោតាបន្នបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល មានវិចិកិច្ឆាជាអតីត មានសីលព្វតបរាមាសៈជាអតីត មានរាគៈជាដំណើរទៅកាន់អបាយជាអតីត មានទោសៈជាដំណើរទៅកាន់អបាយជាអតីត មានមោហៈជាដំណើរទៅកាន់អបាយ ជាអតីតឬ ។ អើ ។ សោតាបន្នបុគ្គល ប្រកបដោយមោហៈ ព្រោះមោហៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៣ ] បុថុជ្ជន មានរាគៈជាអតីត បុថុជ្ជន ប្រកបដោយរាគៈ ព្រោះរាគៈនោះឬ ។ អើ ។ ព្រះអរហន្ត មានរាគៈជាអតីត ព្រះអរហន្ត ប្រកបដោយរាគៈ ព្រោះរាគៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជន មានទោសៈជាអតីត ។បេ។ មានអនោត្តប្បៈជាអតីត បុថុជ្ជនមានអនោត្តប្បៈ ព្រោះអនោត្តប្បៈនោះឬ ។ អើ ។ ព្រះអរហន្ត មានអនោត្តប្បៈជាអតីត ព្រះ

អរហន្ត មានអនោត្តប្បៈ ព្រោះអនោត្តប្បៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៤ ] បុថុជ្ជន មានសក្កាយទិដ្ឋិ ជាអតីត បុថុជ្ជន ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អើ ។ អនាគាមិបុគ្គល មានសក្កាយទិដ្ឋិ ជាអតីត អនាគាមិបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជន មានវិចិកិច្ឆាជាអតីត ។បេ។ មានព្យាបាទដ៏ស្រាលស្តើងជាអតីត បុថុជ្ជន មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។ អើ ។ អនាគាមិបុគ្គល មានព្យាបាទដ៏ស្រាលស្តើងជាអតីត អនាគាមិបុគ្គល មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៥ ] បុថុជ្ជន មានសក្កាយទិដ្ឋិជាអតីត បុថុជ្ជន ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អើ ។ សកទាគាមិបុគ្គល មានសក្កាយទិដ្ឋិ ជាអតីត សកទាគាមិបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជន មានវិចិកិច្ឆាជាអតីត ។បេ។ មានព្យាបាទដ៏គ្រោតគ្រាត ជាអតីត បុថុជ្ជន មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។ អើ ។ សកទាគាមិបុគ្គល មានព្យាបាទដ៏គ្រោតគ្រាត ជាអតីត សកទាគាមិបុគ្គល មានចិត្តព្យាបាទ ព្រោះព្យាបាទនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៦ ] បុថុជ្ជន មានសក្កាយទិដ្ឋិ ជាអតីត បុថុជ្ជន ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អើ ។ សោតាបន្នបុគ្គល មានសក្កាយទិដ្ឋិ ជាអតីត សោតាបន្នបុគ្គល ប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោល

យ៉ាងនេះទេ ។បេ។ បុថុជ្ជន មានវិចិកិច្ឆា ជាអតីត ។បេ។ មានមោហៈ ជាដំណើរទៅកាន់អបាយជាអតីត បុថុជ្ជន ប្រកបដោយមោហៈ ព្រោះមោហៈនោះឬ ។ អើ ។ សោតាបន្នបុគ្គល មានមោហៈជាដំណើរទៅកាន់អបាយជាអតីត សោតាបន្នបុគ្គល ប្រកបដោយមោហៈ ព្រោះមោហៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៧ ] ព្រះអរហន្ត មានរាគៈជាអតីត តែព្រះអរហន្ត មិនប្រកបដោយរាគៈ ព្រោះរាគៈនោះឬ ។ អើ ។ បុថុជ្ជន មានរាគៈជាអតីត តែបុថុជ្ជនមិនប្រកបដោយរាគៈ ព្រោះរាគៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានទោសៈជាអតីត ។បេ។ មានអនោត្តប្បៈជាអតីត តែព្រះអរហន្ត មិនមានអនោត្តប្បៈ ព្រោះអនោត្តប្បៈនោះឬ ។ អើ ។ បុថុជ្ជនមានអនោត្តប្បៈជាអតីត តែបុថុជ្ជនមិនមានអនោត្តប្បៈ ព្រោះអនោត្តប្បៈនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៨ ] អនាគាមិបុគ្គល មានសក្កាយទិដ្ឋិជាអតីត តែអនាគាមិបុគ្គល មិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អើ ។ បុថុជ្ជន មានសក្កាយទិដ្ឋិជាអតីត តែបុថុជ្ជនមិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល មានវិចិកិច្ឆាជាអតីត ។បេ។ មានព្យាបាទដ៏ស្រាលស្តើងជាអតីត តែអនាគាមិបុគ្គល មិនមានចិត្តព្យាបាទ ព្រោះព្យាបាទនោះទេឬ ។ អើ ។ បុថុជ្ជន មានព្យាបាទដ៏ស្រាលស្តើងជាអតីត តែបុថុជ្ជនមិនមានចិត្តព្យាបាទ ព្រោះព្យាបាទនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៩ ] សកទាគាមិបុគ្គល មានសក្កាយទិដ្ឋិជាអតីត តែសកទាគាមិ-បុគ្គល មិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះទេឬ ។ អើ ។ បុថុជ្ជន មានសក្កាយទិដ្ឋិជាអតីត តែបុថុជ្ជន មិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិបុគ្គល មានវិចិកិច្ឆាជាអតីត ។បេ។ មានព្យាបាទដ៏គ្រោតគ្រាតជាអតីត តែសកទាគាមិបុគ្គល មិនមានចិត្តព្យាបាទ ព្រោះព្យាបាទនោះទេឬ ។ អើ ។ បុថុជ្ជន មានព្យាបាទដ៏គ្រោតគ្រាតជាអតីត តែបុថុជ្ជនមិនមានចិត្តព្យាបាទ ព្រោះព្យាបាទនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧០ ] សោតាបន្នបុគ្គល មានសក្កាយទិដ្ឋិជាអតីត តែសោតាបន្ន-បុគ្គល មិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះទេឬ ។ អើ ។ បុថុជ្ជន មានសក្កាយទិដ្ឋិជាអតីត តែបុថុជ្ជនមិនប្រកបដោយទិដ្ឋិ ព្រោះទិដ្ឋិនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបន្នបុគ្គល មានវិចិកិច្ឆាជាអតីត ។បេ។ មានមោហៈ ជាដំណើរទៅកាន់អបាយជាអតីត តែសោតាបន្នបុគ្គលមិនប្រកបដោយមោហៈ ព្រោះមោហៈនោះទេឬ ។ អើ ។ បុថុជ្ជន មានមោហៈជាដំណើរទៅកាន់អបាយជាអតីត តែបុថុជ្ជនមិនប្រកបដោយមោហៈ ព្រោះមោហៈនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧១ ] ដៃជាអតីតឬ ។ អើ ។ កាលបើដៃជាអតីត មានការកាន់និងការដាក់ចុះ ក៏ប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជើង ជាអតីត មានឬ ។ អើ ។ កាលបើជើងជាអតីត មាន ការឈានទៅមុខ និង

ការថយក្រោយ ក៏ប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សន្ទាក់ជាអតីត មានឬ ។ អើ ។ កាលបើសន្ទាក់ជាអតីតមាន ការបត់ចូល និងការលាចេញ ក៏ប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពោះជាអតីត មានឬ ។ អើ ។ កាលបើពោះជាអតីតមាន សេចក្តីឃ្លាន និងការស្រេក ក៏ប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយជាអតីតមានឬ ។ អើ ។ កាយជាអតីត ដែលគួរដល់ការផ្គងឡើង និងសង្កត់សង្កិនគួរដល់ការដាច់ធ្លុះធ្លាយជាសាធារណ៍ ដល់ពួកសត្វក្អែក ត្មាត និងខ្លែងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ថ្នាំពិស គប្បីចូលទៅ គ្រឿងសស្ត្រាគប្បីចូលទៅ ភ្លើង គប្បីចូលទៅ ក្នុងកាយជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយ ជាអតីត គួរបានជាប់ដោយចំណង គឺខ្នោះ ជាប់ដោយចំណង គឺខ្សែ ជាប់ដោយចំណង គឺច្រវាក់ ជាប់ដោយចំណង គឺស្រុក ជាប់ដោយចំណង គឺនិគម ជាប់ដោយចំណង គឺនគរ ជាប់ដោយចំណង គឺជនបទ ជាប់ដោយចំណងទាំងឡាយ មានចំណង-កជាគម្រប់ ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧២ ] ទឹកជាអតីត មានឬ ។ អើ ។ បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយទឹក ព្រោះទឹកនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ភ្លើងជាអតីត មានឬ ។ អើ ។ បុគ្គលធ្វើនូវអំពើ ដែលគួរធ្វើដោយភ្លើង ព្រោះភ្លើងនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខ្យល់ជាអតីត មានឬ ។ អើ ។ បុគ្គលធ្វើនូវអំពើដែលគួរធ្វើដោយខ្យល់ ព្រោះខ្យល់នោះឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។

[ ៣៧៣ ] រូបក្ខន្ធ ជាអតីត មាន រូបក្ខន្ធ ជាអនាគត មាន រូបក្ខន្ធ ជាបច្ចុប្បន្ន មានឬ ។ អើ ។ រូបក្ខន្ធមាន ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ចក្ខន្ធ ជាអតីត មាន បញ្ចក្ខន្ធ ជាអនាគត មាន បញ្ចក្ខន្ធ ជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធមាន ១៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៤ ] ចក្ខាយតនៈ ជាអតីត មាន ចក្ខាយតនៈ ជាអនាគត មាន ចក្ខាយតនៈ ជាបច្ចុប្បន្ន មានឬ ។ អើ ។ ចក្ខាយតនៈ មាន ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ១២ ជាអតីត មាន អាយតនៈ ១២ ជាអនាគត មាន អាយតនៈ ១២ ជាបច្ចុប្បន្ន មានឬ ។ អើ ។ អាយតនៈ មាន ៣៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៥ ] ចក្ខុធាតុជាអតីត មាន ចក្ខុធាតុជាអនាគត មាន ចក្ខុធាតុ ជាបច្ចុប្បន្ន មានឬ ។ អើ ។ ចក្ខុធាតុមាន ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុជាអតីតមាន ១៨ ធាតុជាអនាគតមាន ១៨ ធាតុជាបច្ចុប្បន្នមាន ១៨ ឬ ។ អើ ។ ធាតុមាន ៥៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៦ ] ចក្ខុន្ទ្រិយ ជាអតីត មាន ចក្ខុន្ទ្រិយជាអនាគត មាន ចក្ខុន្ទ្រិយ ជាបច្ចុប្បន្ន មានឬ ។ អើ ។ ចក្ខុន្ទ្រិយមាន ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ឥន្ទ្រិយ ២២ ជាអតីត មាន ឥន្ទ្រិយ ២២ ជាអនាគត មាន

ឥន្រ្ទិយ ២២ ជាបច្ចុប្បន្ន មានឬ ។ អើ ។ ឥន្រ្ទិយ មាន ៦៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៧ ] ស្តេចចក្រពត្តិ ជាអតីត មាន ស្តេចចក្រពត្តិជាអនាគត មាន ស្តេចចក្រពត្តិជាបច្ចុប្បន្ន មានឬ ។ អើ ។ ស្តេចចក្រពត្តិ ៣ អង្គ មានក្នុងទីចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៨ ] ព្រះសម្មាសម្ពុទ្ធជាអតីត មាន ព្រះសម្មាសម្ពុទ្ធជាអនាគត មាន ព្រះសម្មាសម្ពុទ្ធជាបច្ចុប្បន្ន មានឬ ។ អើ ។ ព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គមានក្នុងទីចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៩ ] អតីត មានឬ ។ អើ ។ មានអតីតឬ ។ មានអតីតក៏មាន មិនមែនអតីតក៏មាន ។ ចូរអ្នកដឹងនូវកំហុសចុះ បើអតីតមាន មានអតីតក៏មាន មិនមែនអតីតក៏មាន ព្រោះហេតុនោះ អតីត ទៅជាមិនមែនអតីត មិនមែនអតីត ទៅជាអតីតវិញ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា អតីតមាន មានអតីតក៏មាន មិនមែនអតីតក៏មាន ព្រោះហេតុនោះ អតីត ទៅជាមិនមែនអតីត មិនមែនអតីត ទៅជាអតីតវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស មួយទៀត បើមិនមានអតីត ទៅជាមិនមែនអតីត មិនមែនអតីត ទៅជាអតីតវិញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អតីតមាន មានអតីតក៏មាន មិនមែនអតីតក៏មាន ដូច្នេះទេ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា អតីតមាន មានអតីតក៏មាន មិនមែនអតីតក៏មាន ព្រោះហេតុនោះ អតីត ទៅជាមិនមែនអតីត

មិនមែនអតីត ទៅជាអតីតវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស ។

[ ៣៨០ ] អនាគត មានឬ ។ អើ ។ មានអនាគតឬ ។ មានអនាគតក៏មាន មិនមែនអនាគតក៏មាន ។ អ្នកចូរដឹងនូវកំហុសចុះ បើអនាគតមាន មានអនាគតក៏មាន មិនមែនអនាគតក៏មាន ព្រោះហេតុនោះ អនាគត ទៅជាមិនមែនអនាគត មិនមែនអនាគត ទៅជាអនាគតវិញ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា អនាគតមាន មានអនាគតក៏មាន មិនមែនអនាគតក៏មាន ព្រោះហេតុនោះ អនាគតទៅជាមិនមែនអនាគត មិនមែនអនាគត ទៅជាអនាគតវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស មួយទៀត បើអនាគតមិនមាន ទៅជាមិនមែនអនាគត មិនមែនអនាគត ទៅជាអនាគតវិញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគតមាន មានអនាគតក៏មាន មិនមែនអនាគតក៏មាន ដូច្នេះទេ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា អនាគតមាន មានអនាគតក៏មាន មិនមែនអនាគតក៏មាន ព្រោះហេតុនោះ អនាគត ទៅជាមិនមែនអនាគត មិនមែនអនាគត ទៅជាអនាគតវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស ។

[ ៣៨១ ] បច្ចុប្បន្ន មានឬ ។ អើ ។ មានបច្ចុប្បន្នឬ ។ មានបច្ចុប្បន្នក៏មាន មិនមែនបច្ចុប្បន្នក៏មាន ។ អ្នកចូរដឹងនូវកំហុសចុះ បើបច្ចុប្បន្នមាន មានបច្ចុប្បន្នក៏មាន មិនមែនបច្ចុប្បន្នក៏មាន ព្រោះហេតុនោះ បច្ចុប្បន្នទៅជាមិនមែនបច្ចុប្បន្ន មិនមែនបច្ចុប្បន្ន ទៅជាបច្ចុប្បន្នវិញ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា បច្ចុប្បន្នមាន មានបច្ចុប្បន្ន

ក៏មាន មិនមែនបច្ចុប្បន្នក៏មាន ព្រោះហេតុនោះ បច្ចុប្បន្ន ទៅជាមិនមែន បច្ចុប្បន្ន មិនមែនបច្ចុប្បន្ន ទៅជាបច្ចុប្បន្នវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស មួយទៀត បើមិនមែនបច្ចុប្បន្ន ទៅជាមិនមែនបច្ចុប្បន្ន មិនមែនបច្ចុប្បន្ន ទៅ ជាបច្ចុប្បន្នវិញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បច្ចុប្បន្នមាន មាន បច្ចុប្បន្នក៏មាន មិនមែនបច្ចុប្បន្នក៏មាន ដូច្នេះទេ បណ្តាពាក្យទាំងពីរនោះ អ្នក ពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យនោះថា បច្ចុប្បន្នមាន មានបច្ចុប្បន្ន ក៏មាន មិនមែនបច្ចុប្បន្នក៏មាន ព្រោះហេតុនោះ បច្ចុប្បន្ន ទៅជាមិនមែន បច្ចុប្បន្ន មិនមែនបច្ចុប្បន្ន ទៅជាបច្ចុប្បន្នវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស ។

[ ៣៨២ ] និព្វាន មានឬ ។ អើ ។ មាននិព្វានឬ ។ មាននិព្វានក៏មាន មិនមែននិព្វានក៏មាន ។ អ្នកចូរដឹងនូវកំហុសចុះ បើនិព្វានមាន មាននិព្វាន ក៏មាន មិនមែននិព្វានក៏មាន ព្រោះហេតុនោះ និព្វាន ទៅជាមិនមែននិព្វាន មិនមែននិព្វាន ទៅជានិព្វានវិញ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យ ណា អ្នកគប្បីពោលតែពាក្យនោះថា និព្វានមាន មាននិព្វានក៏មាន មិនមែន និព្វានក៏មាន ព្រោះហេតុនោះ និព្វាន ទៅជាមិនមែននិព្វាន មិនមែននិព្វាន ទៅជានិព្វានវិញ ពាក្យដូច្នេះនេះ ជាពាក្យខុស មួយទៀត បើមិនមែននិព្វាន ទៅជាមិនមែននិព្វាន មិនមែននិព្វាន ទៅជានិព្វានវិញ ម្នាលអ្នកដ៏ចម្រើន អ្នក មិនគួរពោលថា និព្វានមាន មាននិព្វានក៏មាន មិនមែននិព្វានក៏មាន ដូច្នេះ ទេ បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា អ្នកគប្បីពោលតែពាក្យ នោះថា និព្វានមាន មាននិព្វានក៏មាន មិនមែននិព្វានក៏មាន ព្រោះហេតុនោះ

និញ្វាន ទៅជាមិនមែននិញ្វាន មិនមែននិញ្វាន ទៅជានិញ្វានវិញ ពាក្យដូច្នេះនេះជាពាក្យខុស ។

[ ៣៨៣ ] អ្នកមិនគួរពោលថា អតីត មាន អនាគត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ខ្ពង់ខ្ពស់ក្តី រូបណា ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី នេះហៅថា រូបក្ខន្ធ វេទនាណាមួយ ។បេ។ សញ្ញាណាមួយ ។បេ។ សង្ខារណាមួយ ។បេ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ខ្ពង់ខ្ពស់ក្តី វិញ្ញាណណា ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី នេះហៅថា វិញ្ញាណក្ខន្ធ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អតីតមាន អនាគតមាន ។

[ ៣៨៤ ] អតីត មាន អនាគត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ ជាគន្លងនៃពាក្យសម្រាប់និយាយគ្នា ជាគន្លងនៃពាក្យសម្រាប់ហៅ ជាគន្លងនៃពាក្យបញ្ញត្តិ ជាធម៌មិនច្រឡូកច្រឡំ មិនធ្លាប់ច្រឡូកច្រឡំ មិនច្រឡូកច្រឡំ ឥឡូវនេះ នឹងមិនច្រឡូកច្រឡំ ក្នុងអនាគត ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ ជាសមណៈ ឬព្រាហ្មណ៍ មិនតិះដៀលហើយ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបណា ដែលកន្លងទៅហើយ រលត់ទៅហើយ ទៅប្រាសហើយ ប្រែប្រួលហើយ វាចាសម្រាប់ហៅនូវរូបនោះថា មានហើយ ក្នុងអតីត ឈ្មោះនៃរូបនោះថា មាន

ហើយក្នុងអតីត បញ្ញត្តិនៃរូបនោះថា មានហើយ ក្នុងអតីត វាចាសម្រាប់ហៅនូវរូបនោះថា មិនមាន ក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវរូបនោះថា នឹងមិនមានក្នុងអនាគត វេទនាណា ។បេ។ សញ្ញាណា ។បេ។ សង្ខារទាំងឡាយណា ។បេ។ វិញ្ញាណណា ដែលកន្លងទៅហើយ រលត់ទៅហើយ ទៅប្រាសហើយ ប្រែប្រួលហើយ វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មានហើយក្នុងអតីត ឈ្មោះនៃវិញ្ញាណនោះថា មានហើយ ក្នុងអតីត បញ្ញត្តិនៃវិញ្ញាណនោះមានហើយក្នុងអតីត វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មិនមានក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា នឹងមិនមានក្នុងអនាគត ម្នាលភិក្ខុទាំងឡាយ រូបណាដែលមិនទាន់កើត មិនទាន់កើតប្រាកដ វាចាសម្រាប់ហៅនូវរូបនោះថា នឹងមានក្នុងអនាគត ឈ្មោះនៃរូបនោះថា នឹងមានក្នុងអនាគត បញ្ញត្តិនៃរូបនោះថា នឹងមានក្នុងអនាគត វាចាសម្រាប់ហៅនូវរូបនោះថា មិនមានក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវរូបនោះថា មិនមានហើយក្នុងអតីត វេទនាណា ។បេ។ សញ្ញាណា ។បេ។ សង្ខារទាំងឡាយណា ។បេ។ វិញ្ញាណណាដែលមិនទាន់កើត មិនទាន់កើតប្រាកដ វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា នឹងមានក្នុងអនាគត ឈ្មោះនៃវិញ្ញាណនោះថា នឹងមានក្នុងអនាគត បញ្ញត្តិនៃវិញ្ញាណនោះថា នឹងមានក្នុងអនាគត វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មិនមានក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មិនមានហើយក្នុងអតីត ម្នាលភិក្ខុទាំងឡាយ រូបណា ដែលកើតហើយ កើតប្រាកដហើយ វាចា សម្រាប់ហៅនូវរូបនោះថា មានក្នុងបច្ចុប្បន្ន ឈ្មោះនៃរូបនោះថា មាន

ក្នុងបច្ចុប្បន្ន បញ្ញត្តិនៃរូបនោះថា មានក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវរូបនោះថា មិនមានហើយក្នុងអតីត វាចាសម្រាប់ហៅនូវរូបនោះថា នឹងមិនមានក្នុងអនាគត វេទនាណា ។បេ។ សញ្ញាណា ។បេ។ សង្ខារទាំងឡាយណា ។បេ។ វិញ្ញាណណា ដែលកើតហើយ កើតប្រាកដហើយ វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មានក្នុងបច្ចុប្បន្ន ឈ្មោះនៃវិញ្ញាណនោះថា មានក្នុងបច្ចុប្បន្ន បញ្ញត្តិនៃវិញ្ញាណនោះថា មានក្នុងបច្ចុប្បន្ន វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា មិនមានហើយក្នុងអតីត វាចាសម្រាប់ហៅនូវវិញ្ញាណនោះថា នឹងមិនមានក្នុងអនាគត ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះឯង ជាគន្លងនៃពាក្យសម្រាប់និយាយគ្នា ជាគន្លងនៃពាក្យសម្រាប់ហៅ ជាគន្លងនៃពាក្យបញ្ញត្តិ ជាធម៌មិនប្រឡូកប្រឡំ មិនធ្លាប់ប្រឡូកប្រឡំ មិនប្រឡូកប្រឡំឥឡូវនេះ នឹងមិនប្រឡូកប្រឡំក្នុងអនាគត ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ ជាសមណៈ ឬព្រាហ្មណ៍មិនតិះដៀលហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណា ជាអ្នកលើកខ្លួន មានពាក្យដូចជាទឹកភ្លៀង ជាអហេតុកវាទ ជាអកិរិយវាទ ជានត្ថិកវាទ បុគ្គលទាំង ៣ ពួកនេះ មិនបានសម្គាល់នូវពាក្យដែលគួរតិះដៀល មិនបានសម្គាល់នូវពាក្យដែលគួរហាមឃាត់ ក្នុងគន្លងនៃពាក្យសម្រាប់និយាយ ក្នុងគន្លងនៃពាក្យសម្រាប់ហៅ ក្នុងគន្លងនៃពាក្យបញ្ញត្តិទេ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះខ្លាចអំពីការនិន្ទា ការបៀតបៀន និងការប្រណាំងប្រជែង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា អតីត មាន អនាគត មាន ដូច្នេះទេ ។

[ ៣៨៥ ] អតីត មានឬ ។ អើ ។ ក្រែងព្រះផគ្គុណមានអាយុ បានក្រាបទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះពុទ្ធជាអតីត មានដំណើរយឺតយូរកាត់បង់ហើយ មានផ្លូវកាត់បង់ហើយ មានវដ្តៈអស់ហើយ ប្រព្រឹត្តកន្លងនូវទុក្ខទាំងពួងហើយ ទ្រង់បរិនិព្វានហើយ បុគ្គលកាលបញ្ញត្តិ គប្បីបញ្ញត្តិដោយចក្ខុណា ចក្ខុនោះ មានឬ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ជិវ្ហានោះ មានឬ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះពុទ្ធជាអតីត មានដំណើរយឺតយូរកាត់បង់ហើយ មានផ្លូវកាត់បង់ហើយ មានវដ្តៈអស់ហើយ ប្រព្រឹត្តកន្លងនូវទុក្ខទាំងពួងហើយ ទ្រង់បរិនិព្វានហើយ បុគ្គលកាលបញ្ញត្តិ គប្បីបញ្ញត្តិដោយចិត្តណា ចិត្តនោះ មានឬ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលផគ្គុណ កាលព្រះពុទ្ធជាអតីត មានដំណើរយឺតយូរកាត់បង់ហើយ មានផ្លូវកាត់បង់ហើយ មានវដ្តៈអស់ហើយ ប្រព្រឹត្តកន្លងនូវទុក្ខទាំងពួងហើយ ទ្រង់បរិនិព្វានហើយ បុគ្គលកាលបញ្ញត្តិ គប្បីបញ្ញត្តិដោយចក្ខុណា ចក្ខុនោះ មិនមានទេ ។បេ។ ម្នាលផគ្គុណ ជិវ្ហានោះ មិនមានទេ ។បេ។ ម្នាលផគ្គុណ កាលព្រះពុទ្ធជាអតីត មានដំណើរយឺតយូរកាត់បង់ហើយ មានផ្លូវកាត់បង់ហើយ មានវដ្តៈអស់ហើយ ប្រព្រឹត្តកន្លងនូវទុក្ខទាំងពួងហើយ ទ្រង់បរិនិព្វានហើយ បុគ្គលកាលបញ្ញត្តិ គប្បីបញ្ញត្តិដោយចិត្តណា ចិត្តនោះ មិនមានទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា អតីតមាន ដូច្នេះទេ ។

[ ៣៨៦ ] អតីត មានឬ ។ អើ ។ ក្រែងព្រះនន្ទកៈមានអាយុបានពោល

ពាក្យនេះថា លោភៈ មានហើយក្នុងកាលមុន លោភៈនោះ ជាអកុសល លោភៈនោះ មិនមានក្នុងកាលឥឡូវនេះ នេះជាកុសល ទោសៈ មានហើយក្នុងកាលមុន ។បេ។ មោហៈ មានហើយក្នុងកាលមុន មោហៈនោះ ជាអកុសល មោហៈនោះ មិនមានក្នុងកាលឥឡូវនេះ នេះជាកុសល ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា អតីត មាន ដូច្នេះទេ ។

[ ៣៨៧ ] អ្នកមិនគួរពោលថា អនាគត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកត្រអាលមាន សេចក្តីរីករាយមាន ចំណង់មាន ក្នុងកពឡិង្ការាហារ វិញ្ញាណដែលតាំងនៅក្នុងកពឡិង្ការាហារនោះ ក៏លូតលាស់ឡើង វិញ្ញាណដែលតាំងនៅក្នុងកពឡិង្ការាហារណា លូតលាស់ហើយ ការចុះកាន់នាមរូប ក៏មានក្នុងកពឡិង្ការាហារនោះ ការចុះកាន់នាមរូប មានក្នុងកពឡិង្ការាហារណា ការចម្រើនឡើងនៃសង្ខារទាំងឡាយ ក៏មានក្នុងកពឡិង្ការាហារនោះ ការចម្រើនឡើងនៃសង្ខារទាំងឡាយ មានក្នុងកពឡិង្ការាហារណា ការកើតក្នុងកពថ្មីតទៅទៀត ក៏មានក្នុងកពឡិង្ការាហារនោះ ការកើតក្នុងភពថ្មីតទៅទៀត មានក្នុងកពឡិង្ការាហារណា ជាតិជរាមរណៈតទៅ ក៏មានក្នុងកពឡិង្ការាហារនោះ ជាតិជរាមរណៈតទៅ មានក្នុងកពឡិង្ការាហារណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកពឡិង្ការាហារនោះថា ប្រកបដោយសោក ប្រកបដោយធូលី ប្រកបដោយសេចក្តីចង្អៀតចង្អល់ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ... ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ... ម្នាលភិក្ខុទាំងឡាយ បើសេចក្តី

ត្រេកត្រអាលមាន សេចក្ដីរីករាយមាន ក្នុងវិញ្ញាណាហារ ។បេ។ តថាគត ពោលថា ប្រកបដោយធូលី ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា អនាគត មាន ដូច្នេះទេ ។

[ ៣៨៨ ] អនាគត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីត្រេកត្រអាលមិនមាន សេចក្ដីរីករាយមិនមាន ចំណង់មិនមាន ក្នុងកពឡិង្ការាហារ វិញ្ញាណដែលមិនតាំងនៅក្នុងកពឡិង្ការាហារនោះ ក៏មិនលូតលាស់ឡើង វិញ្ញាណដែលមិនតាំងនៅក្នុងកពឡិង្ការាហារណា មិនលូតលាស់ហើយ ការចុះកាន់នាមរូប ក៏មិនមានក្នុងកពឡិង្ការាហារនោះ ការចុះកាន់នាមរូប មិនមានក្នុងកពឡិង្ការាហារណា សេចក្ដីចម្រើននៃសង្ខារទាំងឡាយ ក៏មិនមានក្នុងកពឡិង្ការាហារនោះ សេចក្ដីចម្រើននៃសង្ខារទាំងឡាយ មិនមានក្នុងកពឡិង្ការាហារណា ការកើតក្នុងភពថ្មីតទៅទៀត ក៏មិនមានក្នុងកពឡិង្ការាហារនោះ ការកើតក្នុងភពថ្មីតទៅទៀត មិនមានក្នុងកពឡិង្ការាហារណា ជាតិជរាមរណៈតទៅ ក៏មិនមានក្នុងកពឡិង្ការាហារនោះ ជាតិជរាមរណៈតទៅទៀត មិនមានក្នុងកពឡិង្ការាហារ

ណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកតឡិង្គាភាហារនោះថា មិនប្រកប ដោយសោក មិនប្រកបដោយធូលី មិនប្រកបដោយសេចក្ដីចង្អៀតចង្អល់ ម្នាល ភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ... ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេ-តនាហារ ... ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីត្រេកត្រអាល មិនមានសេចក្ដី រីករាយ មិនមាន ។បេ។ ក្នុងវិញ្ញាណាហារ តថាគតពោលថា មិនប្រកបដោយ ធូលី មិនប្រកបដោយសេចក្ដីចង្អៀតចង្អល់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា អនាគត មាន ដូច្នេះទេ ។

សព្វមត្ថីតិកថា ចប់

# អដ្ឋកថា

## សព្វមត្ថីតិកថា

### វាទយុត្តិ

[ ៣០១ ] ឥឡូវនេះ នឹងពោលអំពីវាទៈថា វត្ថុទាំងពួងមានដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយសព្វមត្ថីតិវាទៈទាំងឡាយក្នុងខណៈនេះថា ធម៌ទាំងឡាយ មានអតីតជាដើម រមែងមិនវៀរនូវសភាវៈនៃខន្ធ ព្រោះព្រះបាលីថា រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ នេះហៅថា រូបក្ខន្ធ ដូច្នេះជាដើម ព្រោះហេតុនោះ ទើបវត្ថុទាំងពួង ឈ្មោះថា មាននោះឯង ដូច្នេះ ដើម្បីជម្រះលទ្ធិរបស់ជនទាំងនោះ ទើបសកវាទីសួរថា **សព្វមត្ថិ** ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ព្រោះតាំងនៅក្នុងទិដ្ឋិ មានប្រការដូចពោលហើយ ។

បទថា **សព្វត្ថ** អធិប្បាយថា សកវាទីសួរថា វត្ថុទាំងអស់ មាននៅក្នុងសរីរៈទាំងពួងឬ ។ បទថា **សព្វទា** អធិប្បាយថា សកវាទីសួរថា វត្ថុទាំងអស់ មានក្នុងកាលទាំងពួងឬ ។ បទថា **សព្វេន សព្វំ** អធិប្បាយថា សកវាទីសួរថា វត្ថុទាំងអស់ មាននៅដោយអាការទាំងពួងឬ ។ បទថា **សព្វេសុ** អធិប្បាយថា សកវាទីសួរថា វត្ថុទាំងអស់ មានក្នុងធម៌ទាំងពួងឬ ។ បទថា **អយោគំ** បានដល់ មិនប្រកបហើយ អធិប្បាយថា ការប្រកបគ្នា រមែង

មានដល់របស់ដែលមានសភាវៈច្រើនយ៉ាង តែមិនមានដល់របស់ដែលមានសភាវៈតែមួយ ហេតុនោះ ទើបក្នុងបញ្ហានេះ សកវាទីឆ្លើយរូប និងវេទនា ឬឆ្លើយវេទនា និងរូប មិនឲ្យផ្សេងគ្នា គឺឲ្យមានលក្ខណៈតែមួយជាមួយគ្នានោះឯង ហើយទើបសួរថា **សព្វមត្ថិ ។** បទថា **យម្បិ នត្ថិ តម្បិ អត្ថិ** អធិប្បាយថា សកវាទីសួរថា វត្ថុណាមួយ មានខន្ធទី ៦ ជាដើម ឬស្នែងទន្សាយជាដើម មិនមាន ព្រោះហេតុនោះ វត្ថុនោះ ក៏កើតឡើងបាន រមែងមានដល់អ្នកឬ ។ ដោយពាក្យថា **សព្វមត្ថីតិ យា ទិដ្ឋិ សា ទិដ្ឋិ មច្ឆាទិដ្ឋីតិ យា ទិដ្ឋិ សា ទិដ្ឋិ សម្មាទិដ្ឋីតិ ហេវមត្ថិ** សកវាទីសួរពាក្យនេះថា ក្នុងលទ្ធិរបស់អ្នក មានយ៉ាងនេះដែរឬទេថា ទិដ្ឋិណារបស់ពួកយើងយ៉ាងនេះ ទិដ្ឋិរបស់អ្នកដែលថា វត្ថុទាំងពួង មាន ដូច្នេះនោះ ជាមិច្ឆាទិដ្ឋិ ព្រោះប្រព្រឹត្តទៅតាមសេចក្តីពិត ទិដ្ឋិនោះ ជាសម្មាទិដ្ឋិ ព្រោះប្រព្រឹត្តទៅតាមសេចក្តីពិត ដូច្នេះ ។ បរវាទីឆ្លើយបដិសេធថា **ន ហេវំ** ព្រោះការមិនមាននៃធម៌ដែលមាន មានប្រការតាមដែលពោលហើយ ក្នុងន័យទាំងអស់នោះ ។ ក្នុងន័យទាំងអស់នេះ បណ្ឌិតគប្បីជ្រាបប្រភេទនៃកថាមគ្គទាំងពួងដោយពិស្តារ ដោយផ្តើមតាំងអំពីបទថា ចូរអ្នកដឹងនូវកំហុសចុះ ។ នេះឈ្មោះថា វាទយុត្តិ គឺពាក្យប្រកបរឿងក្នុងទីនេះ មានប្រមាណប៉ុណ្ណោះ ។៚

**អដ្ឋកថាវាទយុត្តិកថា ចប់**

# អដ្ឋកថា

## កាលសំសន្ទនៈ

[ ៣០២ ] ឥឡូវនេះ ជាការប្រៀបធៀបវេលាដោយពាក្យថា **អតីតំ អត្ថិ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អតីតំ អត្ថិ** ជាដើម ជាពាក្យប្រៀបធៀបពេលវេលាសុទ្ធៗ ។

[ ៣០៨ ] បទជាដើមថា **អតីតំ រូបំ អត្ថិ** ជាការប្រៀបធៀបកាលជាមួយខន្ធជាដើម ។

[ ៣២០ ] បទថា **បច្ចុប្បន្នំ រូបំ អប្បិយំ កាតព្វា** សេចក្ដីថា លះរូបដែលជាអតីត និងអនាគតចេញហើយ ទើបសម្ដីងរូបបច្ចុប្បន្នប៉ុណ្ណោះ មិនបែងចែក ។ ក្នុងបញ្ហាថា **រូបភាវំ ជហាតិ** បរវាទីឆ្លើយបដិសេធ ព្រោះភាពដែលរូបរលត់ទៅហើយ លោកក៏សង្គ្រោះជារូបក្ខន្ធ ។

[ ៣២១ ] ក្នុងបញ្ហាបដិលោមថា **រូបភាវំ ន ជហាតិ** បរវាទីឆ្លើយទទួលព្រោះភាពដែលរូបនោះ សង្គ្រោះចូលជារូបក្ខន្ធ ។ ក្នុងបទនេះថា **ឱទាតំ វត្ថំ អប្បិយំ កាតព្វា** សេចក្ដីថា សំពត់មិនជាពណ៌សទាំងអស់ក៏ពិត តែសកវាទីក៏ឆ្លើយទទួលភាពមានអត្ថតែមួយ កាលបរវាទីមិនពោលពាក្យថា សំពត់ តែពោលពាក្យថា រួមសម្ដីងដល់សំពត់ស ។ ក្នុងបញ្ហាថា **ឱទាតភាវំ ន ជហាតិ** ពាក្យឆ្លើយទទួលនេះ ជាពាក្យឆ្លើយរបស់សកវាទី ព្រោះសំដៅយកសំពត់ដែលមានពណ៌ដើមវិនាសទៅហើយ ។ ក្នុងបទថា **វត្ថភាវំ ជហាតិ** នេះពាក្យបដិសេធ ជាពាក្យរបស់សកវាទីនោះឯង ព្រោះពាក្យបញ្ញត្តិមិនទាន់វិនាសទៅ ។ ក្នុងបញ្ហាបដិលោម ក៏ន័យនេះដូចគ្នា ។

[ ៣២៥ ] បរវាទីនោះត្រូវសួរថា **អតីតំ អតីតភាវំ ន ជហាតិ** កាលសម្គាល់ថា បើគប្បីលះ ក៏គប្បីជាអនាគត ឬបច្ចុប្បន្ន ទើបឆ្លើយទទួលថា **អាមន្តា** ។

[ ៣២៦ ] កាលត្រូវសួរថា **អនាគតំ អនាគតភាវំ ន ជហាតិ** បរវាទីសម្គាល់ថា បើគប្បីលះអនាគតនោះឯង ក៏នឹងមិនគប្បីសម្រេចភាពជាបច្ចុប្បន្ន ទើបបដិសេធ ។ ក្នុងបញ្ហាពោលដោយបច្ចុប្បន្ន បរវាទីក៏បដិសេធ ព្រោះគិតថា គប្បីមានកំហុស ដែលបច្ចុប្បន្នមិនដល់នូវភាពជាអតីត ។ ក្នុងបញ្ហាអនុលោមទាំងឡាយ បណ្ឌិតក៏គប្បីជ្រាបដោយន័យនេះឯង ។

[ ៣៣១ ] កាលពោលសុទ្ធិកន័យយ៉ាងនេះហើយ ដើម្បីសម្តែងដោយអំណាចនៃខន្ធទៀត ទើបពោលពាក្យថា **អតីតំ រូបំ** ជាដើម ។ ពាក្យទាំងអស់ អាចដឹងបានដោយទំនងនៃព្រះបាលីនោះឯង ។ ។

# អដ្ឋកថា

## វចនសោធនៈ

[ ៣៤៤ ] ឥឡូវនេះ នឹងពណ៌នាអំពីសោធនា គឺការជម្រះនូវពាក្យដោយបទថា **អតីតំ នត្ថិ** ជាដើម ។ ក្នុងបញ្ហានោះ បទថា **ហញ្ចិ អតីតំ នត្ថិ** អធិប្បាយថា បើអតីតមិនមានសោត ។ បទថា **អតីតំ អត្ថីតិ មិច្ឆា** អធិប្បាយថា ពាក្យថា អតីតនោះផង សភាវៈដែលមានផង ដូច្នេះ ខុសនោះឯង ។

[ ៣៤៥ ] ត្រូវសួរថា **តញ្ញេវ អនាគតំ តំ បច្ចុប្បន្នំ** បរវាទីសំដៅ

*យកអនាគត ដែលកំពុងជាបច្ចុប្បន្ន មិនមានក្នុងខណៈនៃអនាគតនោះឯង ទើបឆ្លើយបដិសេធ ព្រោះការផ្សេងគ្នានៃវេលា ។*

*បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះវត្ថុដែលមិនទាន់មកដល់ក្នុងកាលមុនអំពីការកើតឡើង ជាបច្ចុប្បន្នក្នុងវេលាដែលកើតឡើងហើយ ។ បទថា* **ហុត្វា ហោតិ ហុត្វា ហោតិ** *អធិប្បាយថា អ្នកដែលពោលថា ជាអនាគតហើយ ទើបជាបច្ចុប្បន្ន ពោលពាក្យណានេះថា ជាអនាគត ឬជាបច្ចុប្បន្ន ឈ្មោះថា កើតហើយ ទើបកំពុងកើត ដោយអំណាចនៃលទ្ធិថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង ពាក្យនោះ ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើតតាមលទ្ធិរបស់អ្នកឬ បរវាទីបដិសេធថា* **ន ហេវំ** *ព្រោះមិនមានវត្ថុដែលជាអនាគតហើយ មកជាបច្ចុប្បន្នហើយ នឹងមកជាអនាគតហើយ ជាបច្ចុប្បន្នទៀត ។*

*បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះវត្ថុនោះជាអនាគតហើយ ទើបមកជាបច្ចុប្បន្ន ទើបរាប់ថា កើតហើយ ទើបកំពុងកើត ។ លំដាប់នោះ ទើបសកវាទីសួរបញ្ហានឹងបរវាទីថា* **ន ហុត្វា ន ហោតិ ន ហុត្វា ន ហោតិ** *ដូច្នេះ ដោយបំណងយកថា បើលទ្ធិរបស់អ្នកថា អនាគតនោះកើតហើយ ទើបមកជាបច្ចុប្បន្ន ដែលរាប់ថា កើតហើយ ទើបកំពុងកើត រមែងកើតហើយ ទើបកំពុងកើតទៀត អនាគតណា មិនកើតហើយ មិនមកជាបច្ចុប្បន្ន ដែលរាប់ថា មិនកើតហើយ ទើបមិនកំពុងកើត ដូចស្នែងទន្សាយ សូម្បីអនាគតនោះ ក៏ឈ្មោះថា មិនកើតហើយ តាមមិនកំពុងកើតទៀត ទើបលទ្ធិរបស់*

អ្នកឬ បរវាទីសម្គាល់ថា វត្ថុណាមិនមាន វត្ថុនោះ ព្រោះការមិនមាននោះឯង ទើបមិនជាអនាគត ហើយមិនជាបច្ចុប្បន្ន ព្រោះហេតុនោះ ឈ្មោះថា វត្ថុដែលមិនកើតហើយ ទើបមិនកំពុងកើត ចូរស្មេះសិន តែសភាវៈនៃធម៌ដែលមិនកើតហើយ ទើបមិនកំពុងកើតនៃវត្ថុនោះ នឹងមានក្នុងទីណាទៀត ដូច្នេះ ទើបឆ្លើយបដិសេធ ។

[ ៣៤៦ ] ក្នុងបញ្ហាថា **តញ្ញេវ បច្ចុប្បន្នំ តំ អតីតំ** បរវាទីសំដៅយកការមិនមាននៃបច្ចុប្បន្ននោះ ដែលជាអតីត ក្នុងខណៈនៃបច្ចុប្បន្ននោះឯង ព្រោះការផ្សេងគ្នានៃវេលា ។

បរវាទីត្រូវសួរក្នុងបញ្ហាទី ២ ក៏ឆ្លើយទទួល ព្រោះធម៌ដែលធ្លាប់ជាបច្ចុប្បន្ន មកក្នុងកាលមុន ដោយជារបស់ដែលកន្លងទៅហើយនោះឯង ក៏ជាអតីត ។ បទថា **ហុត្វា ហោតិ ហុត្វា ហោតិ** អធិប្បាយថា អ្នកពោលថា ជាបច្ចុប្បន្នហើយ ទើបជាអតីត ពោលពាក្យនេះណាថា ជាបច្ចុប្បន្ន ឬជាអតីត ឈ្មោះថា កើតហើយ ទើបកំពុងកើត ដោយអំណាចនៃលទ្ធិថា បច្ចុប្បន្ននោះក៏នោះឯង អតីតក៏នោះឯង ដូច្នេះ ពាក្យនោះ ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើត តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធថា **ន ហេវំ** ព្រោះមិនមានវត្ថុដែលជាបច្ចុប្បន្នហើយ មកជាអតីតហើយ និងមកជាបច្ចុប្បន្នហើយ ជាអតីតទៀត ។

ក្នុងបញ្ហាទី ២ បរវាទីឆ្លើយទទួល ព្រោះវត្ថុដែលជាបច្ចុប្បន្នហើយ នឹងមកជាអតីត ដល់នូវការរាប់ថា កើតហើយ ទើបកំពុងកើត ។ លំដាប់នោះ

ទើបសកវាទីសួរបញ្ហានឹងបរវាទីនោះថា **ន ហុត្វា ន ហោតិ ន ហុត្វា ន ហោតិ** ដោយបំណងយកថា បើលទ្ធិរបស់អ្នកថា បច្ចុប្បន្ននោះឯង កើតហើយ ទើបមកជាអតីត ដែលដល់នូវការរាប់ថា កើតហើយ ទើបកំពុងកើតរមែងកើតហើយ ទើបកំពុងកើតទៀត បច្ចុប្បន្នណា មិនកើតហើយ មិនមកជាអតីត ដែលដល់នូវការរាប់ថា មិនកើតហើយ ទើបមិនកំពុងកើត ដូចស្នែងទន្សាយ បច្ចុប្បន្ននោះ ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើតទៀត តាមលទ្ធិរបស់អ្នកឬ បរវាទីសម្គាល់ថា វត្ថុណាមិនមាន វត្ថុនោះ ព្រោះការមិនមាននោះឯង ទើបមិនជាបច្ចុប្បន្ន ហើយមិនជាអតីត ព្រោះហេតុនោះឈ្មោះថា វត្ថុដែលមិនកើតហើយ ទើបមិនកំពុងកើត ចូរស្វែះសិន សភាវៈនៃធម៌ដែលមិនកើតហើយ ទើបមិនកំពុងកើតនៃវត្ថុនោះ នឹងមានអំពីណាទៀត ដូច្នេះ ទើបឆ្លើយបដិសេធ ។ បណ្ឌិតគប្បីធ្វើការប្រកបដោយឧបាយនេះ សូម្បីក្នុងបញ្ហាទី ៣ ដែលមកហើយ ដោយការរួមបញ្ហាទាំង ២ ចូលជាមួយគ្នា ។

ម្យ៉ាងទៀត បើអនាគតយ៉ាងនោះ បច្ចុប្បន្នក៏យ៉ាងនោះសោត ភាវៈ គឺភាពកំពុងកើតនៃអនាគត ដែលលោកពោលក្នុងបច្ចុប្បន្ន និងភាវៈ គឺការកើតហើយនៃបច្ចុប្បន្ន ដែលលោកពោលក្នុងអនាគត ក៏រមែងត្រឹមត្រូវ ។ កាលបើភាពយ៉ាងនោះមាន សូម្បីអនាគត ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើត សូម្បីបច្ចុប្បន្ន ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើតនោះឯង ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា លទ្ធិរបស់អ្នកថា បណ្តាធម៌ទាំងនោះ ធម៌

នីមួយៗ ជាអនាគត ហើយជាបច្ចុប្បន្ន ឈ្មោះថា កើតហើយ ទើបកំពុង កើតឬ បរវាទីបដិសេធហើយ ដោយន័យដែលលោកបដិសេធហើយ ក្នុងបញ្ហាថា អនាគតនោះឯង បច្ចុប្បន្នក៏នោះឯង ត្រូវសួរទៀត ក៏ឆ្លើយទទួល ដោយន័យដែលឆ្លើយទទួលក្នុងបញ្ហាទី ២ ។ លំដាប់នោះ សកវាទីកាលនឹងប្តូរការសួរបញ្ហាដែលបរវាទីឆ្លើយទទួលថា បណ្តាធម៌ទាំងនោះ ធម៌នីមួយៗ ជាអនាគតហើយ ជាបច្ចុប្បន្ន ឈ្មោះថា កើតហើយ ទើបកំពុងកើត ដោយអំណាចនៃបញ្ហាថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង ធ្វើឲ្យជាបញ្ហាបដិសេធមុន ទើបសួរថា **ន ហុត្វា ន ហោតិ ន ហុត្វា ន ហោតិ** ។ អត្ថនៃបញ្ហានោះ គប្បីជ្រាបថា កាលពាក្យថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង ដែលខ្ញុំពោលហើយ អ្នកបដិសេធបញ្ហាដំបូង ក៏ឈ្មោះថា បដិសេធភាពកំពុងកើតនៃអនាគត និងភាពកើតហើយនៃបច្ចុប្បន្ន មិនមែនឬ ព្រោះហេតុនោះ ដោយការបដិសេធនោះ អនាគតក៏ឈ្មោះថា មិនកំពុងកើត បច្ចុប្បន្ន ក៏ឈ្មោះថា មិនកើតហើយ ។

តែក្នុងបញ្ហាទី ២ អ្នកទទួលតាមលទ្ធិរបស់អ្នកថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង កាលបើភាពយ៉ាងនោះមាន អនាគត ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើត បច្ចុប្បន្នក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើតនោះឯង ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា តាមលទ្ធិរបស់អ្នក បណ្តាធម៌ទាំងនោះ ធម៌នីមួយៗ មិនកើតហើយ ទើបមិនកំពុងកើតឬ បរវាទីកាលមិនឃើញនូវភាពដែលធម៌ទាំងនោះមិនជាអនាគត ហើយមិនជាបច្ចុប្បន្ន

ដូចបុគ្គលដែលត្រូវផនឹតគ្របដណ្ដប់ហើយ ដោយប្រការទាំងពួង ទើបឆ្លើយបដិសេធថា **ន ហេវំ ។**

ក្នុងវារៈទី ២ បើបច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯងសោត ភាវៈ គឺភាពកំពុងកើតនៃបច្ចុប្បន្ន ដែលអ្នកពោលក្នុងអតីត និងភាវៈ គឺការកើតហើយនៃអតីត ដែលអ្នកពោលក្នុងបច្ចុប្បន្ន ក៏រមែងត្រឹមត្រូវ ។ កាលបើភាពយ៉ាងនេះមាន បច្ចុប្បន្នក៏ឈ្មោះថា កើតហើយ ទើបកំពុងកើត សូម្បីអតីត ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើតនោះឯង ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ ដែលជាបច្ចុប្បន្ន ហើយជាអតីត ឈ្មោះថា កើតហើយ ទើបកំពុងកើតឬ បរវាទីបដិសេធហើយ ដោយន័យដែលលោកពោលហើយក្នុងបញ្ហាថា បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯងត្រូវសួរទៀត ក៏ឆ្លើយទទួល ដោយន័យដែលលោកទទួលហើយ ក្នុងបញ្ហាទី ២ ។ លំដាប់នោះ សកវាទីកាលប្ដូរសួរបញ្ហាដែលទទួលថា បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ ដែលជាបច្ចុប្បន្នហើយ ជាអតីត ឈ្មោះថា កើតហើយទើបកំពុងកើត ដោយអំណាចនៃបញ្ហាថា បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯងធ្វើឲ្យជាបញ្ហាបដិសេធមុន ទើបសួរថា **ន ហុត្វា ន ហោតិ ន ហុត្វា ន ហោតិ ។** អត្ថនៃបញ្ហានោះ គប្បីជ្រាបថា កាលពាក្យថា បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯង ដែលខ្ញុំពោលហើយ អ្នកបដិសេធបញ្ហាដំបូង ក៏ឈ្មោះថាបដិសេធនូវភាវៈ គឺភាពកំពុងកើតនៃបច្ចុប្បន្ន និងភាវៈ គឺការកើតហើយនៃអតីត មិនមែនឬ ព្រោះហេតុនោះ ដោយពាក្យបដិសេធនោះ បច្ចុប្បន្ន

ឈ្មោះថា មិនកំពុងកើត អតីត ក៏ឈ្មោះថា មិនកើតហើយ ។

តែក្នុងបញ្ហាទី ២ លោកឆ្លើយទទួលតាមលទ្ធិថា បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯង កាលភាពយ៉ាងនោះមាន សូម្បីបច្ចុប្បន្ន ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើត សូម្បីអតីត ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើតដូចគ្នា ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ មិនជាបច្ចុប្បន្ន ហើយមិនជាអតីត ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើត តាមលទ្ធិរបស់អ្នកឬ បរវាទីកាលមិនឃើញនូវភាពដែលធម៌ទាំងនោះមិនជាបច្ចុប្បន្ន ហើយមិនជាអតីត ដូចបុគ្គលដែលត្រូវងងឹតគ្របដណ្ដប់ហើយ ដោយប្រការទាំងពួង ទើបឆ្លើយបដិសេធថា **នហេវំ** ។

[ ៣៤៧ ] ក្នុងវារៈទី ៣ បើអនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯងសោត ភាវៈ គឺភាពកំពុងកើតនៃអនាគត និងបច្ចុប្បន្ន ដែលអ្នកពោលក្នុងបច្ចុប្បន្ន និងអតីត និងភាវៈ គឺការកើតហើយនៃបច្ចុប្បន្ន និងអតីត ដែលអ្នកពោលក្នុងអនាគត និងបច្ចុប្បន្ន ក៏រមែងត្រឹមត្រូវ ។ កាលភាពជាយ៉ាងនោះមាន អនាគត ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើត សូម្បីបច្ចុប្បន្ន សូម្បីអតីត ក៏ឈ្មោះថា កើតហើយ ទើបកំពុងកើតនោះឯង ។ ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា ក្នុងធម៌ទាំង ៣ នោះ ធម៌នីមួយៗ ជាវត្ថុដែលកើតហើយ ទើបកំពុងកើត ឈ្មោះថា កើតហើយ ទើបកំពុងកើត តាមលទ្ធិរបស់អ្នកឬ បរវាទីឆ្លើយបដិសេធដោយន័យ ដែលបដិសេធហើយនោះឯង ក្នុងបញ្ហាថា អនាគតនោះឯង គឺបច្ចុប្បន្ននោះឯង គឺអតីតនោះឯង ឬត្រូវ

សួរទៀត ក៏ឆ្លើយទទួលដោយន័យការឆ្លើយទទួលក្នុងបញ្ហាទី ២ នោះឯង ។ លំដាប់នោះ សកវាទីកាលនឹងបួរសួរបញ្ហា ដែលបរវាទីទទួលថា បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ ជាវត្ថុដែលកើតហើយ ទើបកំពុងកើត ឈ្មោះថាកើតហើយ ទើបកំពុងកើត ដោយអំណាចនៃបញ្ហាថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯងឬ ដូច្នេះ ធ្វើឲ្យជាបញ្ហាបដិសេធមុន ទើបសួរថា **ន ហុត្វា ន ហោតិ ន ហុត្វា ន ហោតិ** ។ អត្ថនៃបញ្ហានោះ គប្បីជ្រាបដូច្នេះថា កាលបើពាក្យថា អនាគតនោះឯង បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯង ដែលខ្ញុំពោលហើយ អ្នកបដិសេធបញ្ហាដំបូង ក៏ឈ្មោះថា បដិសេធនូវការៈ គឺការកំពុងកើតនៃអនាគត និងបច្ចុប្បន្នទាំងឡាយ និងនូវការៈ គឺការកើតហើយនៃបច្ចុប្បន្ន និងអតីតទាំងឡាយ មិនមែនឬ ព្រោះហេតុនោះដោយពាក្យបដិសេធនោះ អនាគត និងបច្ចុប្បន្ន ក៏ឈ្មោះថា មិនកំពុងកើត បច្ចុប្បន្ន និងអតីត ក៏ឈ្មោះថា មិនកើតហើយ ។

តែក្នុងបញ្ហាទី ២ អ្នកឆ្លើយទទួលតាមលទ្ធិថា អនាគតក៏នោះឯង បច្ចុប្បន្នក៏នោះឯង អតីតក៏នោះឯង កាលបើភាពដូច្នោះមាន អនាគត ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើត បច្ចុប្បន្នក្តី អតីតក្តី ក៏ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើតដូចគ្នា ដោយហេតុនោះ ខ្ញុំសូមសួរអ្នកថា ក្នុងធម៌ទាំងនោះ ធម៌នីមួយៗ មិនជាអនាគត ហើយមិនជាបច្ចុប្បន្ន ឈ្មោះថា មិនកើតហើយ ទើបមិនកំពុងកើត តាមលទ្ធិរបស់អ្នកឬ បរវាទីកាលមិនឃើញនូវភាពដែលធម៌ទាំងនោះមិនជាអនាគត ហើយមិនជាបច្ចុប្បន្ន

ដូចបុគ្គលត្រូវងងឹតគ្របដណ្តប់ហើយ ដោយប្រការទាំងពួង ទើបឆ្លើយ បដិសេធថា **នហេវំ** ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យនិគ្គហៈក្នុងទីនេះជាដើម បណ្ឌិតគប្បីប្រកបសេចក្តី ដោយន័យដែលពោលហើយ ខាងដើមនោះឯង ។ល។

**អដ្ឋកថាវចនសោធនៈ ចប់**

# អដ្ឋកថា

## អតីតចក្ខុរថាទិកថា

[ ៣៤៨ ] ក្នុបញ្ហាថា **អតីតំ ចក្ខុ អត្ថិ** ជាដើម បរវាទីឆ្លើយទទួល នូវភាពមាន ព្រោះការមិនវៀរចាកភាពជាចក្ខុជាដើម ។ ត្រូវសួរថា **បស្សតិ** ជាដើម ក៏ឆ្លើយបដិសេធដោយអំណាចនៃការមិនមានកិច្ចរបស់វិញ្ញាណទាំង នោះទៀត ។ល។

# អដ្ឋកថា

## អតីតញ្ញាណាទិកថា

[ ៣៥៤ ] ក្នុងបញ្ហាថា **តេន ញាណេន ញាណករណីយំ ករោតិ** បរវាទីកាលមិនឃើញនូវភាពដែលញាណនោះ មានកិច្ចបានព្រោះភាពដែល ញាណនោះរលត់ទៅហើយ ទើបឆ្លើយបដិសេធ ។ បរវាទីត្រូវសួរទៀត ក៏ធ្វើ បច្ចុប្បន្នញ្ញាណ ដែលមានអតីតជាអារម្មណ៍ដែលជាបច្ចុប្បន្ននោះឯង ឲ្យជា អតីតញ្ញាណ ដោយលេសន័យ របស់បុគ្គលដែលមានអតីតញ្ញាណ ព្រោះ

ដឹងធម៌ដែលជាអតីតារម្មណ៍ទាំងឡាយហើយ ទើបឆ្លើយទទួល ព្រោះភាព ដែលកិច្ចនោះ ដែលបុគ្គលគប្បីធ្វើដោយញាណ មានដោយញាណនោះ ។ លំដាប់នោះ សកវាទីមិនឲ្យឱកាស ដែលមានលេសន័យដល់បរវាទីនោះ ទើបពោលពាក្យថា **តេន ញាណេន ទុក្ខំ បរិជានាតិ** ជាដើម បរវាទី ឆ្លើយបដិសេធ ព្រោះភាពមិនមានកិច្ចទាំង ៤ នេះ ដោយញាណដែលមាន អតីតជាអារម្មណ៍ឡើយ ។ ក្នុងបញ្ហារបស់អនាគតក៏មានន័យនេះឯង ។ បញ្ហា ពោលដោយបច្ចុប្បន្ន និងបញ្ហាពោលដោយការប្រៀបធៀប មានអត្ថងាយ យល់ហើយ ៕

# អដ្ឋកថា

## អរហន្តាទិកថា

[ ៣៥៩ ] ក្នុងបញ្ហាថា **អរហតោ អតីតោ រាគោ អត្ថិ** ជាដើម បរវាទីឆ្លើយទទួលយ៉ាងនោះ ព្រោះមិនទាន់លះនូវភាពមានរាគៈជាដើម ។ ក្នុង បញ្ហាថា **សរាគោ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពី ព្រះសូត្រ និងព្រោះខ្លាចខុសអំពីភាពដែលត្រឹមត្រូវ ៕

# អដ្ឋកថា

## បទសោធនកថា

[ ៣៧៩ ] កាលដឹងពាក្យទាំងពួង តាមទំនងព្រះបាលីនោះឯង យ៉ាង នេះហើយ គប្បីជ្រាបអត្ថយ៉ាងនេះ ក្នុងពាក្យនេះថា **អត្ថិ សិយា អតីតំ**

**សិយា ឆ្នាតីតំ** ខាងមុខដូចតទៅនេះថា វត្ថុណាជាអតីតនោះឯង ជាវត្ថុមាន វត្ថុនោះ ក៏ជាអតីត វត្ថុណា ជាបច្ចុប្បន្ននោះឯង អនាគតជាវត្ថុមាន វត្ថុនោះ មិនមែនជាវត្ថុមាន វត្ថុនោះ មិនមែនជាអតីត ។ បទថា **តេនាតីតំ ឆ្នាតីតំ ឆ្នាតីតំ អតីតំ** អធិប្បាយថា ដោយហេតុនោះ អតីតក៏ជាសភាវៈដែលមិនមែនអតីត តែសភាវៈដែលមិនមែនអតីតក៏ជាអតីត ដូច្នេះ ។ ក្នុងពាក្យសួរដោយអនាគត និងបច្ចុប្បន្ន ក៏ន័យនេះឯង ។ល។

# អដ្ឋកថា

## សុត្តសោធនៈ

[ ៣៨៣ ] ពាក្យសួរ ដើម្បីអះអាងដោយព្រះសូត្រថា **ន វត្តព្វំ អតីតំ អត្ថិ អនាគតំ អត្ថិ** ជាពាក្យរបស់បរវាទី ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ។ ការសួរអាស្រ័យលទ្ធិរបស់ខ្លួន តាមព្រះសូត្រទៀតថា **យំ កិញ្ចិ ភិក្ខវេ រូបំ** ជាដើម ជាពាក្យរបស់បរវាទី ។

[ ៣៨៤ ] ក្នុងន័យទី ២ ពាក្យសួរជាពាក្យរបស់សកវាទី ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យសួរក្តី ពាក្យឆ្លើយទទួលក្តី ក្នុងឋានៈទាំងពួង បណ្ឌិតគប្បីជ្រាបដោយប្រការដូច្នេះ ។

[ ៣៨៧ ] ម្យ៉ាងទៀត បរវាទីសម្តែងពាក្យណាថា **អត្ថិ តត្ថ អាយតី បុនព្ភវា ភិនិព្វត្តិ** ជាដើម ក្នុងទីបំផុតរបស់ព្រះសូត្រថា ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីត្រេកត្រអាលមាន សេចក្តី

រីករាយមាន ចំណង់មាន ក្នុងកពឡិង្គារហារ ដូច្នេះ ជាសូត្រដែលមានពិត មិនមែនឬ ក៏ដើម្បីអះអាងសភាពដែលអនាគតមាន ពាក្យនោះ អះអាងមិនបាន ដល់សភាវៈដែលអនាគតមាន ។ ពិតហើយ ពាក្យដែលព្រះមានព្រះភាគត្រាស់ក្នុងព្រះសូត្រនោះ សំដៅយកធម៌ដែលបុគ្គលចម្រើនហើយពិត ព្រោះភាពដែលហេតុទាំងឡាយ ជាសភាវៈដល់នូវការសម្រេចហើយ ។ នេះជាការអធិប្បាយព្រះសូត្រ ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយហើយ ។៚

## អដ្ឋកថាសព្វមត្តិតិកថា ចប់

# អភិធម្មបិដក

## អតីតត្តនិកថា

[ ៣៨៩ ] ខន្ធទាំងឡាយ ជាអតីតឬ ។ អើ ។ អតីតមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាអតីតឬ ។ អើ ។ អតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ជាអតីតឬ ។ អើ ។ អតីតមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ ជាអតីតឬ ។ អើ ។ អតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩០ ] ខន្ធទាំងឡាយ ជាអនាគតឬ ។ អើ ។ អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាអនាគតឬ ។ អើ ។ អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ជាអនាគតឬ ។ អើ ។ អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ ជាអនាគតឬ ។ អើ ។ អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩១ ] ខន្ធទាំងឡាយ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធទាំងឡាយ ជាអតីត អតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ អាយតនៈ ជាអតីត អតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ។ អើ។ ធាតុ ជាអតីត អតីត មានឬ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ ជាអតីត អតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩២ ] ខន្ធទាំងឡាយ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធទាំងឡាយ ជាអនាគត អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ អាយតនៈ ជាអនាគត អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ ធាតុ ជាអនាគត អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ ជាអនាគត អនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៣ ] ខន្ធទាំងឡាយ ជាអតីត អតីត មិនមានឬ ។ អើ ។ ខន្ធទាំងឡាយ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាអតីត អតីត មិនមានឬ ។ អើ ។ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ ជាអតីត អតីត មិនមានឬ ។ អើ ។ ធាតុ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ ជាអតីត អតីត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៤ ] ខន្ធទាំងឡាយ ជាអនាគត អនាគត មិនមានឬ ។ អើ ។ ខន្ធទាំងឡាយ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ ជាអនាគត ។បេ។ ធាតុ ជាអនាគត ។បេ។ ខន្ធ ធាតុ អាយតនៈ

ជាអនាគត អនាគត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ ជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៥ ] ខន្ធ គឺរូប ជាអតីតឬ ។ អើ ។ រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺរូប ជាអតីតឬ ។ អើ ។ រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធាតុ គឺរូប ជាអតីតឬ ។ អើ ។ រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអតីតឬ ។ អើ ។ រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៦ ] ខន្ធ គឺរូប ជាអនាគតឬ ។ អើ ។ រូប ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺរូប ជាអនាគតឬ ។បេ។ ធាតុ គឺរូប ជាអនាគត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអនាគតឬ ។ អើ ។ រូប ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៧ ] ខន្ធ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ គឺរូប ជាអតីត រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺរូប ជាបច្ចុប្បន្ន ។បេ។ ធាតុ គឺរូប ជាបច្ចុប្បន្ន ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអតីត រូប ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៨ ] ខន្ធ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ

គឺរូប ជាអនាគត រូប ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺរូប ជាបច្ចុប្បន្ន ។បេ។ ធាតុ គឺរូប ជាបច្ចុប្បន្ន ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអនាគត រូប ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។បេ។

[ ៣៩៩ ] ខន្ធ គឺរូប ជាអតីត រូប ជាអតីត មិនមានឬ ។ អើ ។ ខន្ធ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។បេ។ អាយតនៈ គឺរូប ជាអតីត ។បេ។ ធាតុ គឺរូប ជាអតីត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអតីត រូប ជាអតីត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាបច្ចុប្បន្ន រូបជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ខន្ធ គឺរូប ជាអនាគត រូប ជាអនាគត មិនមានឬ ។ អើ ។ ខន្ធ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ អាយតនៈ គឺរូប ជាអនាគត ។បេ។ ធាតុ គឺរូប ជា អនាគត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាអនាគត រូប ជាអនាគត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺរូប ជាបច្ចុប្បន្ន រូប ជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ជាអតីត ។បេ។ សញ្ញា ជាអតីត ។បេ។ សង្ខារទាំងឡាយ ជាអតីត ។បេ។

[ ៤០០ ] ខន្ធ គឺវិញ្ញាណ ជាអតីតឬ ។ អើ ។ វិញ្ញាណ ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណ ជា

អតីត ។បេ។ ធាតុ គឺវិញ្ញាណ ជាអតីត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណ ជាអតីតឬ ។ អើ ។ វិញ្ញាណ ជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០១ ] ខន្ធ គឺវិញ្ញាណ ជាអនាគតឬ ។ អើ ។ វិញ្ញាណ ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណ ជាអនាគត ។បេ។ ធាតុ គឺវិញ្ញាណ ជាអនាគត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណ ជាអនាគតឬ ។ អើ ។ វិញ្ញាណ ជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០២ ] ខន្ធ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ គឺវិញ្ញាណជាអតីត វិញ្ញាណជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន ។បេ។ ធាតុ គឺវិញ្ញាណជាបច្ចុប្បន្ន ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាអតីត វិញ្ញាណជាអតីត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៣ ] ខន្ធ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ គឺវិញ្ញាណជាអនាគត វិញ្ញាណជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន ។បេ។ ធាតុ គឺវិញ្ញាណជាបច្ចុប្បន្ន ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាអនាគត

វិញ្ញាណជាអនាគត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៤ ] ខន្ធ គឺវិញ្ញាណជាអតីត វិញ្ញាណជាអតីត មិនមានឬ ។ អើ ។ ខន្ធ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណជាអតីត ។បេ។ ធាតុ គឺវិញ្ញាណជាអតីត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាអតីត វិញ្ញាណជាអតីត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៥ ] ខន្ធ គឺវិញ្ញាណជាអនាគត វិញ្ញាណជាអនាគត មិនមានឬ ។ អើ ។ ខន្ធ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាយតនៈ គឺវិញ្ញាណជាអនាគត ។បេ។ ធាតុ គឺវិញ្ញាណជាអនាគត ។បេ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាអនាគត វិញ្ញាណជាអនាគត មិនមានឬ ។ អើ ។ ខន្ធ ធាតុ អាយតនៈ គឺវិញ្ញាណជាបច្ចុប្បន្ន វិញ្ញាណជាបច្ចុប្បន្ន មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៦ ] អ្នកមិនគួរពោលថា ខន្ធ ធាតុ អាយតនៈទាំងនេះ ជាអតីត អនាគត មិនមានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ ជាគន្លងនៃពាក្យសម្រាប់និយាយគ្នា ជាគន្លងនៃពាក្យសម្រាប់ហៅ ជាគន្លងនៃបញ្ញត្តិ ។បេ។ ដែលអ្នកប្រាជ្ញទាំងឡាយ មិនតិះដៀលហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ខន្ធ ធាតុ អាយតនៈទាំងនេះ ជាអតីត អនាគត មិន

មាន ដូច្នេះឡើយ ។

[ ៤០៧ ] ខន្ធ ធាតុ អាយតនៈ ទាំងនេះ ជាអតីត អនាគត មិនមាន ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ នេះហៅថា រូបក្ខន្ធ វេទនាណាមួយ ។បេ។ សញ្ញាណាមួយ ។បេ។ សង្ខារទាំងឡាយណាមួយ ។បេ។ វិញ្ញាណណាមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ នេះហៅថា វិញ្ញាណក្ខន្ធ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ខន្ធ ធាតុ អាយតនៈ ទាំងនេះ ជាអតីត អនាគត មិនមាន ដូច្នេះឡើយ ។

**អតីតក្ខន្ធាទិកថា ចប់**

# អដ្ឋកថា

# អតីតក្ខន្ធាទិកថា

## ឆសុត្តសាធកកថា

[ ៣៨៩ ] ឥឡូវនេះ នឹងពោលរឿងអតីតជាខន្ធជាដើមដូចតទៅ

ក្នុងរឿងនោះ ពាក្យសួរថា **អតីតំ ខន្ធា** ជាដើម ជាពាក្យរបស់បរវាទី ដែលកាន់យកនូវការមាននៃខន្ធទាំងឡាយ ទាំងដែលជាអតីត និងអនាគត ព្រោះការមិនវៀរចាកភាពជាខន្ធជាដើម ។ ពាក្យឆ្លើយទទួលថា **អាមន្តា** ជាពាក្យរបស់សកវាទី ព្រោះភាពដែលខន្ធក្នុងអតីតក៏សង្គ្រោះជាខន្ធ ។ ពាក្យសួរទៀតថា **អតីតំ អត្ថិ** ជាពាក្យរបស់បរវាទី ។ ពាក្យបដិសេធ ជាពាក្យរបស់សកវាទី ព្រោះភាពដែលអតីតក្ខន្ធមាននោះ លោកបដិសេធ ដោយព្រះសូត្រដែលជាគន្លងនៃភាសា ។ ក្នុងពាក្យសួរពោលដោយអាយតនៈ និងធាតុក្តី ក្នុងបញ្ហាពោលដោយអនាគតក្តី ក្នុងបញ្ហាពោលដោយអនាគត ដោយអនុលោម និងបដិលោមដែលប្រៀបធៀបជាមួយបច្ចុប្បន្នក្តី ក្នុងបញ្ហាពោលដោយពាក្យជាដើមថា រូបអតីតជាខន្ធក្តី បណ្ឌិតគប្បីជ្រាបអត្ថដោយឧបាយនេះឯង ៕៚

# អដ្ឋកថា

## សុត្តសាធនៈ

[ ៤០៦ ] មួយវិញទៀត ក្នុងការអះអាងដោយព្រះសូត្រ ពាក្យសួរថា **ន វត្តព្វំ** ជាពាក្យរបស់សកវាទី ។ បណ្តាបទទាំងនោះ បទថា **នត្ថិ ចេតេ** អធិប្បាយថា ធម៌ទាំងឡាយនោះ មិនមានឬ ។ កាលភាពជាខន្ធជាដើមមាន បរវាទីមិនកាន់យកនូវការមិនមាននៃអតីត និងអនាគតទាំងនោះ ទើបឆ្លើយទទួលថា **អាមន្តា ។** លំដាប់នោះ ការនាំព្រះសូត្រមក ដើម្បីអះអាងភាពដែលខន្ធជាអតីត និងអនាគតទាំងនោះ ជាសភាវៈដែលមិនមាន ជាពាក្យរបស់សកវាទី ។ ពាក្យសួរទី ២ ក៏ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ។ ការនាំព្រះសូត្រមក ជាពាក្យរបស់បរវាទី ។ ការនាំព្រះសូត្រមកនោះ រមែងអះអាងនូវភាពដែលអតីតក្ខន្ធ និងអនាគតជាដើមទាំងនោះជាខន្ធជាដើមប៉ុណ្ណោះ មិនបានអះអាងនូវភាពដែលខន្ធជាដើមនោះមាន ព្រោះហេតុនោះ សូម្បីបរវាទីនាំព្រះសូត្រមកហើយ ក៏ហាក់ដូចជាមិននាំមកនោះឯង ដូច្នេះ ៕ ចប់

**អដ្ឋកថាអតីតក្ខន្ធាទិកថា ចប់**

# អភិធម្មបិដក

## ឯកច្ចមត្ថីតិកថា

[ ៤០៨ ] អតីត មានឬ ។ មានខ្លះ មិនមានខ្លះ ។ អតីត រលត់ខ្លះ មិនរលត់ខ្លះ ទៅប្រាសខ្លះ មិនទៅប្រាសខ្លះ វិនាសខ្លះ មិនវិនាសខ្លះ សូន្យខ្លះ មិនសូន្យខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៩ ] អតីត មានខ្លះ មិនមានខ្លះឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត មានខ្លះ មិនមានខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១០ ] អតីត មានខ្លះ មិនមានខ្លះឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត មានខ្លះ មិនមានខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១១ ] អតីត មានខ្លះ មិនមានខ្លះឬ ។ អើ ។ ធម៌ទាំងឡាយ មិនមានវិបាក ជាអតីត មានខ្លះ មិនមានខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១២ ] អតីត មានខ្លះ មិនមានខ្លះឬ ។ អើ ។ អ្វីមាន អ្វីមិនមាន ។ ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ តែងមាន ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត ធម៌ទាំងនោះ តែងមិនមាន ។

[ ៤១៣ ] ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត ធម៌ទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៤ ] ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ មិនមានវិបាក ជាអតីត ធម៌ទាំងនោះ មាន

ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៥ ] ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ មិនមានវិបាក ជាអតីត ធម៌ទាំងនោះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៦ ] ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មានឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយឬ ។ អើ ។ បើធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មាន ដូច្នេះឡើយ ។

[ ៤១៧ ] ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ មិនមានវិបាក ជាអតីត រលត់ហើយ ធម៌ទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ

មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ មិនមានវិបាក ជាអតីត រលត់ហើយ ធម៌ទាំងនោះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៨ ] ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកចាស់ ជាអតីត រលត់ហើយ ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ មានវិបាកចាស់ចំណែកមួយ ជាអតីត ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ចំណែកមួយ រលត់ហើយ ធម៌ទាំងនោះ មានខ្លះ មិនមានខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៩ ] អ្នកមិនគប្បីពោលថា ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មាន ដូច្នេះឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត នឹងឲ្យផលក្នុងអនាគតឬ ។ អើ ។ បើធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត នឹងឲ្យផលក្នុងអនាគត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត ធម៌ទាំងនោះ មាន ដូច្នេះដែរ ។ ធម៌ទាំងឡាយនោះមាន ព្រោះអាងថា ធម៌ទាំងឡាយ មានវិបាកមិនទាន់ចាស់ ជាអតីត នឹងឲ្យផលក្នុងអនាគត ដូច្នេះឬ ។ អើ ។ ធម៌ទាំងឡាយ ជាបច្ចុប្បន្ន ព្រោះអាងថា នឹងឲ្យផលក្នុងអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ

ជាបច្ចុប្បន្ន ព្រោះអាងថា នឹងឲ្យផលក្នុងអនាគតឬ ។ អើ ។ ធម៌ទាំងឡាយនោះ មិនមាន ព្រោះអាងថា ធម៌ទាំងឡាយ ជាបច្ចុប្បន្ន នឹងរលត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២០ ] អនាគត មានឬ ។ មានខ្លះ មិនមានខ្លះ ។ កើតខ្លះ មិនកើតខ្លះ ជុះជាលខ្លះ មិនជុះជាលខ្លះ លូតលាស់ខ្លះ មិនលូតលាស់ខ្លះ កើតប្រាកដខ្លះ មិនកើតប្រាកដខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២១ ] អនាគតមានខ្លះ មិនមានខ្លះឬ ។ អើ ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត មានខ្លះ មិនមានខ្លះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគតមានខ្លះ ។បេ។ ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ។បេ។

[ ៤២២ ] អនាគតមានខ្លះ មិនមានខ្លះឬ ។ អើ ។ អ្វីមាន អ្វីមិនមាន ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មាន ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មិនមាន ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងឡាយនោះ មានឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត មិនកើតឬ ។ អើ ។

បើធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត មិនកើតទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មាន ដូច្នេះទេ ។

[ ៤២៣ ] ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត មិនកើតទេ ធម៌ទាំងនោះ មានឬ ។ អើ ។ ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ជាអនាគត មិនកើតទេ ធម៌ទាំងនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ ដែលមិនប្រុងនឹងកើត ជាអនាគត មិនកើតទេ ធម៌ទាំងនោះ មិនមានឬ ។ អើ ។ ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត មិនកើតទេ ធម៌ទាំងនោះ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៤ ] អ្នកមិនគួរពោលថា ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មាន ដូច្នេះឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត នឹងកើតឬ ។ អើ ។ បើធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត នឹងកើត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត ធម៌ទាំងនោះ មានដូច្នេះដែរ ។

[ ៤២៥ ] ធម៌ទាំងនោះ មាន ព្រោះអាងថា ធម៌ទាំងឡាយ ដែលប្រុងនឹងកើត ជាអនាគត នឹងកើតឬ ។ អើ ។ ធម៌ទាំងឡាយ ជាបច្ចុប្បន្ន ព្រោះអាងថា នឹងកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងឡាយ ជាបច្ចុប្បន្ន ព្រោះអាងថា នឹងកើត មានឬ ។ អើ ។ ធម៌ទាំងនោះ មិនមាន ព្រោះអាងថា ធម៌ទាំងឡាយ ជាបច្ចុប្បន្ន នឹងរលត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ឯកច្ចមត្ថីតិកថា ចប់

# អដ្ឋកថា

## ឯកច្ចំអត្ថីតិកថា

### អតីតាទិឯកច្ចកថា

[ ៤០៨ ] ឥឡូវនេះ នឹងពោលរឿងខ្លះៗ ដែលមានដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា រមែងសម្គាល់ថា អតីតខ្លះមាន ដូច និកាយកស្សបិកៈទាំងឡាយ ដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសកវាទី សួរថា **អតីតំ អត្ថិ** ពាក្យវិសជ្ជនាថា **ឯកច្ចំ អត្ថិ** ជាដើម ជាពាក្យរបស់ បរវាទី ។ គប្បីជ្រាបអត្ថនៃពាក្យវិសជ្ជនារបស់បរវាទីនោះថា វិបាកធម៌ដែល មិនទាន់ឲ្យផល មាន វិបាកធម៌ដែលឲ្យផលហើយ មិនមាន ។ ពាក្យសួរថា **ឯកច្ចំ និរុទ្ធំ** ជាពាក្យរបស់សកវាទី ។ អធិប្បាយអត្ថនៃបញ្ហានោះថា បើ អតីតធម៌ខ្លះមាន ខ្លះមិនមាន តាមលទ្ធិរបស់អ្នកសោត កាលបើភាពយ៉ាង នោះ មានអតីតធម៌ខ្លះ រលត់ទៅ និងអតីតធម៌ខ្លះ មិនទាន់រលត់ទៅ គង់តាំង នៅយ៉ាងនោះឯង ។ ក្នុងបទទាំងឡាយថា **វិគតំ** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ៤០៩ ] បទនេះថា **អវិបក្កវិបាកធម្មា ឯកច្ចេ** ព្រោះបរវាទី កាន់ យកភាពមាននៃវិបាក ដែលមិនទាន់ឲ្យផលទាំងឡាយ ធម៌ទាំងនោះ ក៏ជា អតីតធម៌ទាំងអស់ ព្រោះហេតុនោះ សកវាទីពោលដើម្បីចោទសួរថា តាម លទ្ធិរបស់អ្នក អតីតធម៌ ខ្លះមាន យ៉ាងណា ធម៌ទាំងឡាយ សូម្បីជាវិបាក ដែលមិនឲ្យផល ខ្លះមាន ខ្លះមិនមាន យ៉ាងនោះឬ ។

[ ៤១០ ] បទថា **វិបក្កវិបាកា** នេះ សកវាទីពោលដើម្បីចោទសួរ ដោយអំណាចនៃវិបាកធម៌ ដែលបរវាទីនោះកាន់យកថា មិនមាន ។

[ ៤១១ ] បទថា **អវិបាកា** នេះ សកវាទីពោលដើម្បីចោទសួរ ដោយអំណាចធម៌ដែលជាអព្យាកតៈទាំងឡាយ ។ ពាក្យឆ្លើយទទួល និងពាក្យបដិសេធ ក្នុងអនុលោម និងបដិលោមទាំងពួង បណ្ឌិតគប្បីជ្រាបដោយអំណាចនៃគំនរធម៌ទាំង ៣ នេះ ដោយប្រការដូច្នេះ ។ ធម៌ មានវិបាកដែលឲ្យផលហើយចំណែកមួយ មិនទាន់ឲ្យផលចំណែកមួយ ដែលជាអតីត ធម៌ទាំងនោះ លោកហៅថា វិបាកដែលឲ្យផលមិនទាន់អស់ ។ ពិតហើយ បដិសន្ធិកើតហើយដោយកម្មណា ភវង្គចិត្តក្តី ចុតិចិត្តក្តី ជាវិបាករបស់កម្មនោះឯង ព្រោះហេតុនោះ វិបាកនោះ តាំងពីបដិសន្ធិ រហូតដល់ចុតិ ទើបឈ្មោះថា ជាវិបាកដែលឲ្យផលមិនទាន់អស់ ។ លោកពោលពាក្យនេះ សំដៅយកធម៌បែបនោះ ។

[ ៤១៩ ] ពាក្យសួរថា **វិបច្ចិស្សន្តីតិ កត្វា តេ អត្ថិ** ជាពាក្យរបស់សកវាទី ។ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅដោយច្រើន លោករមែងពោលថា មានដល់បុគ្គលដែលទ្រទ្រង់នូវធម៌ បុគ្គលដេកលក់ យ៉ាងណា ពាក្យឆ្លើយ

ទទួល ជាពាក្យរបស់បរវាទី សំដៅយកការមាននៃធម៌ទាំងនោះ ដោយអំណាចនៃលោកវោហារយ៉ាងនោះ ។ ក្នុងបញ្ហាទី ២ ថា **វិបច្ចិស្សន្តីតិ កត្វា បច្ចុប្បន្នា** ពាក្យឆ្លើយទទួលដែលតាំងនៅក្នុងលទ្ធិថា ឈ្មោះថា កម្មប្បច្ច័យឯណានីមួយ ពោល គឺការមិនវិនាសទៅនៃកម្មទាំងឡាយ រមែងមាន ជាពាក្យរបស់បរវាទី ។ល។

## អដ្ឋកថា

## អនាគតាធិឃកច្ចកថា

[ ៤២០ ] ក្នុងបទថា **អនាគតំ អត្ថិ** ជាដើម សកវាទីពោលសំដៅយកធម៌ទាំងឡាយដែលនឹងកើតឡើងថា **ឃកច្ចំ អត្ថិ** ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។ល។

**អដ្ឋកថាឃកច្ចំអត្ថីតិកថា ចប់**

# អភិធម្មបិដក

## សតិប្បដ្ឋានកថា

[ ៤២៦ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ធម៌ទាំងអស់ ឈ្មោះថា សតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ដែលជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំកពូនឡើង មិនមានអាសវៈ មិនជាប្រយោជន៍ដល់សញ្ញោជនៈ ជាធម៌ដែលគន្ថៈ មិនគប្បីជោតក្រង ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង មិនជាប្រយោជន៍ដល់នីវរណៈ ជាធម៌ដែលបរាមាសៈមិនស្ទាបអង្អែល មិនជាប្រយោជន៍ដល់ឧបាទាន មិនគួរដល់សេចក្តីសៅហ្មង ធម៌ទាំងអស់ ឈ្មោះថា ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ អានាបានស្សតិ មរណានុស្សតិ កាយគតាសតិ ឧបសមានុស្សតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៧ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថា សតិប្បដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខាយតនៈ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថា សតិ សតិន្ទ្រិយ សតិពល សម្មាសតិ សតិសម្ពោជ្ឈង្គ ដែលជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំកពូនឡើង មិនមានអាសវៈ មិនជាប្រយោជន៍ដល់សំយោជនៈ ។បេ។ មិនគួរដល់សេចក្តី

សៅហ្មង ចក្ខាយតនៈ ឈ្មោះថា ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ អានាបានស្សតិ មរណានុស្សតិ កាយគតាសតិ ឧបសមានុស្សតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាយតនៈ ។បេ។ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ ។បេ។ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ។បេ។ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។បេ។ អនោត្តប្បៈ ឈ្មោះថា សតិប្បដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនោត្តប្បៈ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ អនោត្តប្បៈ ឈ្មោះថា សតិ សតិន្ទ្រិយ សតិពល សម្មាសតិ ។បេ។ កាយគតាសតិ ឧបសមានុស្សតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៨ ] សតិ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ ឈ្មោះថា សតិឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ ឈ្មោះថា សតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សតិ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ ឈ្មោះថា សតិឬ ។ អើ ។ សោតាយតនៈ ។បេ។ កាយាយតនៈ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ រាគៈ ទោសៈ មោហៈ មានះ ។បេ។ អនោត្តប្បៈ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ ឈ្មោះថា សតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៩ ] ចក្ខាយតនៈ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ មិនឈ្មោះថា សតិទេឬ ។ អើ ។ សតិ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាន

នោះ មិនឈ្មោះថា សតិទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាយតនៈ ។បេ។ កាយាយតនៈ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ រាគៈ ទោសៈ មោហៈ ។បេ។ អនោត្តប្បៈ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ មិនឈ្មោះថា សតិទេឬ ។ អើ ។ សតិ ឈ្មោះថា សតិប្បដ្ឋាន ទាំងសតិប្បដ្ឋាននោះ មិនឈ្មោះថា សតិទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣០ ] អ្នកមិនគួរពោលថា ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានទេឬ ។ អើ ។ ក្រែងសតិតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ឬ ។ អើ ។ បើសតិតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋាន ដូច្នេះដែរ ។

[ ៤៣១ ] សតិតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ ព្រោះហេតុនោះ ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ផស្សៈតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ ព្រោះហេតុនោះ ធម៌ទាំងអស់ ឈ្មោះថា ជាទីតាំងនៅនៃផស្សៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣២ ] សតិតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ ព្រោះហេតុនោះ ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ វេទនាតាំងនៅនឹង ព្រោះប្រារព្ធនូវធម៌ទាំងអស់ ។បេ។ សញ្ញាតាំងនៅនឹង ។បេ។ ចេតនាតាំងនៅនឹង ។បេ។ ចិត្តតាំងនៅនឹង ព្រោះហេតុនោះ ធម៌ទាំងអស់ ឈ្មោះថា ជាទីតាំងនៃចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៣ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ សត្វ

ទាំងអស់ មានសតិតាំងមាំ ប្រកបដោយសតិ ខ្ជាប់ខ្ជួនដោយសតិ សតិរបស់សត្វទាំងអស់ ឈ្មោះថា តាំងមាំឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៤ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា មិនបរិភោគកាយគតាសតិ ពួកសត្វនោះ ឈ្មោះថា មិនបរិភោគអមតៈ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា បរិភោគកាយគតាសតិ ពួកសត្វនោះ ឈ្មោះថា បរិភោគអមតៈ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ សត្វទាំងអស់ បរិភោគ បានចំពោះ សេពគប់ អប់រំ ធ្វើឲ្យច្រើន នូវកាយគតាសតិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៥ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះឯង សម្រាប់ជាទីទៅនៃបុគ្គលម្នាក់ ដើម្បីសេចក្តីបរិសុទ្ធដោយវិសេស នៃសត្វទាំងឡាយ ដើម្បីកន្លងនូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរម្ងត់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ផ្លូវនេះ គឺសតិប្បដ្ឋាន ៤ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អើ ។ ធម៌ទាំងអស់ ឈ្មោះថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៤៣៦ ] ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃរតនៈ ៧ ប្រការ ព្រោះការកើតប្រាកដនៃស្តេចចក្កពត្តិ ។ រតនៈ ៧ ប្រការ តើដូចម្តេច ។ ការកើតប្រាកដនៃចក្ករតនៈ ១ ការកើតប្រាកដនៃហត្ថិរតនៈ ១ ការកើតប្រាកដនៃអស្សរតនៈ ១ ការកើតប្រាកដនៃមណិរតនៈ ១ ការកើតប្រាកដនៃឥត្ថីរតនៈ ១ ការកើតប្រាកដនៃគហបតិរតនៈ ១ ការកើតប្រាកដនៃបរិណាយករតនៈ ១ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃរតនៈ ៧ ប្រការនេះឯង ព្រោះការកើតប្រាកដនៃព្រះរាជាចក្កពត្តិ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃពោជ្ឈង្គរតនៈ ៧ ព្រោះការកើតប្រាកដនៃព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ការកើតប្រាកដនៃពោជ្ឈង្គ ៧ តើដូចម្តេច ។ ការកើតប្រាកដនៃសតិសម្ពោជ្ឈង្គរតនៈ ១ ការកើតប្រាកដនៃធម្មវិចយសម្ពោជ្ឈង្គរតនៈ ១ ការកើតប្រាកដនៃវិរិយសម្ពោជ្ឈង្គរតនៈ ១ ការកើតប្រាកដនៃបីតិសម្ពោជ្ឈង្គរតនៈ ១ ការកើតប្រាកដនៃបស្សទ្ធិសម្ពោជ្ឈង្គរតនៈ ១ ការកើតប្រាកដនៃសមាធិសម្ពោជ្ឈង្គរតនៈ

១ ការកើតប្រាកដនៃឧបេក្ខាសម្ពោជ្ឈង្គរតនៈ ១ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃពោជ្ឈង្គរតនៈ ៧ នេះ ព្រោះការកើតប្រាកដនៃព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ធម៌ទាំងអស់ ឈ្មោះថា សតិសម្ពោជ្ឈង្គរតនៈ ព្រោះការកើតប្រាកដនៃព្រះតថាគត អរហន្តសម្មាសម្ពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ទាំងអស់ ឈ្មោះថា សតិប្បដ្ឋានឬ ។ អើ ។ ធម៌ទាំងអស់ ឈ្មោះថា សម្មប្បធាន ។បេ។ ឥទ្ធិបាទ ។បេ។ ឥន្ទ្រិយ ។បេ។ ពល ។បេ។ ពោជ្ឈង្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

## សតិប្បដ្ឋានកថា ចប់

# អដ្ឋកថា

## សតិប្បដ្ឋានកថា

[ ៤២៦ ] ឥឡូវនេះ នឹងពោលសតិប្បដ្ឋានដូចតទៅ

ក្នុងរឿងនោះ ជនពួកណា មានលទ្ធិដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា ធម៌ទាំងពួងជាសតិប្បដ្ឋាន ព្រោះកាន់យកធម៌ទាំងឡាយ មានកាយជាដើម ជាអារម្មណ៍ដោយសតិ ដោយន័យដែលព្រះមានព្រះភាគត្រាស់ក្នុងសតិប្បដ្ឋានសំយុត្តថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើង និងសូន្យទៅនៃសតិប្បដ្ឋាន ៤ ដូច្នេះជាដើម ។ និកាយដែលកើតឡើងខាងក្រោយទាំងនេះ គឺបុព្វសេលិយៈ អបរសេលិយៈ រាជគិរិយៈ និងសិទ្ធត្ថិកៈ ឈ្មោះថា និកាយអន្ធកៈ ។ ពាក្យសួរដើម្បីសង្កត់សង្កិនលទ្ធិរបស់ជនទាំងនោះ ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សតិប្បដ្ឋាន ដូចតទៅនេះ

ព្រោះហេតុដែលឈ្មោះថា បដ្ឋាន ព្រោះអត្ថថា រមែងតាំងមាំក្នុងធម៌ទាំងឡាយ ។ សួរថា អ្វីតាំងមាំ ឆ្លើយថា សតិ ។ សូម្បីមានសតិជាអារម្មណ៍ក៏ឈ្មោះថា សតិប្បដ្ឋាន ដោយអត្ថនេះថា ការតាំងមាំនៃសតិ ឈ្មោះថា សតិប្បដ្ឋាន ។ ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា រមែងតាំងមាំ ។ សួរថា អ្វីរមែងតាំងមាំ ឆ្លើយថា សតិរមែងតាំងមាំ ។ **បដ្ឋាន** គឺ **សតិ** ឈ្មោះថា **សតិប្បដ្ឋាន** ដោយអត្ថនេះថា ទីតាំង គឺសតិ ឈ្មោះថា **សតិប្បដ្ឋាន**

ហេតុនោះ វាទៈទាំង ២ រមែងត្រឹមត្រូវដោយបរិយាយ ។

ម្យ៉ាងទៀត ជនទាំងឡាយណា លះបរិយាយនេះហើយ រមែងពោលថា ធម៌ទាំងពួងជាសតិប្បដ្ឋានដោយចំណែកមួយប៉ុណ្ណោះ ពាក្យសួរសំដៅដល់ជនទាំងនោះ ជាពាក្យរបស់សកវាទី ពាក្យឆ្លើយទទួលដោយអំណាចនៃអារម្មណ៍ ជាពាក្យរបស់បរវាទី ។ តែកាលសកវាទីសួរថា **សព្វេ ធម្មា សតិ** ជាដើម បរវាទីក៏ឆ្លើយបដិសេធ ព្រោះភាពដែលធម៌ទាំងពួង មិនជាសតិទាំងអស់ ។

បណ្ដាបទទាំងនោះ បទថា **ឯកាយនោ** ជាដើម ជាឈ្មោះពិសេសនៃមគ្គ ។ ពិតហើយ ឯកាយនមគ្គ ឈ្មោះថា **ឯកាយនោ** ព្រោះអត្ថថា សម្រេចព្រះនិព្វាន ជាទីអស់ទៅនៃកិលេសទាំងឡាយ ។ ឈ្មោះថា **ខេមគាមី** ព្រោះអត្ថថា ដល់នូវការត្រាស់ដឹងសច្ចៈ ៤ ។ ឈ្មោះថា **អបចយគាមី** ព្រោះអត្ថថា ដល់នូវការមិនសន្សំវដ្ដៈ ។ សកវាទីសួរដោយបទទាំងនេះយ៉ាងនេះដោយសំដៅយកថា ធម៌ទាំងពួងជាឯកាយនមគ្គ មានតាមលទ្ធិរបស់អ្នកយ៉ាងនេះឬ ពាក្យទាំងឡាយ មានពាក្យថា **អនាសវា អសំយោជនិយា** ជាដើម សកវាទីពោលដើម្បីសួរដោយភាពជាលោកុត្តរ ។ ពាក្យទាំងឡាយ

ថា **ពុទ្ធានុស្សតិ** ជាដើម លោកពោលដោយអំណាចពាក្យសួរបែកប្រភេទ ។

[ ៤២៧ ] បទថា **ចក្ខាយតនំ សតិប្បដ្ឋានំ** ជាដើម លោកពោលដោយអំណាចពាក្យសួរបែកប្រភេទនៃធម៌ទាំងពួង ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបញ្ហាទាំងពួងយ៉ាងនេះថា ពាក្យឆ្លើយបដិសេធមានដោយអំណាចនៃសតិ ពាក្យឆ្លើយទទួលមានដោយអំណាចនៃអារម្មណ៍ ។ ការអះអាង ដោយព្រះសូត្រ មានអត្ថងាយយល់ហើយ ដោយប្រការដូច្នេះ ៗ។

**អដ្ឋកថាសតិប្បដ្ឋានកថា ចប់**

# អភិធម្មបិដក

## ហេវត្ថិកថា

[ ៤៣៧ ] អតីត មានឬ ។ អតីត មានយ៉ាងនេះ មិនមានយ៉ាងនេះ ។ អតីតនោះមាន អតីតនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អតីតនោះមាន អតីតនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន អត្ថថា មិនមាន ឈ្មោះអត្ថថា មាន ភាពមាន ឈ្មោះថា ភាពមិនមាន ភាពមិនមាន ឈ្មោះថា ភាពមាន ពាក្យថា មានក្តី ថាមិនមានក្តី ឬថា មិនមានក្តី ថាមានក្តី សភាវៈទាំងនេះ មានអត្ថតែមួយស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៨ ] អនាគត មានឬ ។ អនាគត មានយ៉ាងនេះ មិនមានយ៉ាងនេះ ។ អនាគតនោះមាន អនាគតនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគតនោះមាន អនាគតនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន អត្ថថា មិនមាន ឈ្មោះអត្ថថា មាន ភាពមាន ឈ្មោះថា ភាពមិនមាន ភាពមិនមាន ឈ្មោះថា ភាពមាន ពាក្យថា មានក្តី ថាមិនមានក្តី ឬថា មិនមានក្តី ថាមានក្តី សភាវៈទាំងនេះ មានអត្ថតែមួយ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៩ ] បច្ចុប្បន្ន មានឬ ។ បច្ចុប្បន្ន មានយ៉ាងនេះ មិនមានយ៉ាង

នេះ ។ បច្ចុប្បន្ននោះ មាន បច្ចុប្បន្ននោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិន គួរពោលយ៉ាងនេះទេ ។បេ។ បច្ចុប្បន្ននោះ មាន បច្ចុប្បន្ននោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន ។បេ។ ស្មើគ្នា មាន ចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤០ ] អតីត មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ អតីត មានដូចម្ដេច មិនមានដូចម្ដេច ។ អតីត មានយ៉ាងនេះ គឺអតីត នៅជាអតីត អតីត មិនមានយ៉ាងនេះ គឺអតីត ជាអនាគត អតីត មិនមានយ៉ាងនេះ គឺ អតីត ជាបច្ចុប្បន្ន ។ អតីតនោះ មាន អតីតនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អតីតនោះ មាន អតីតនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន អត្ថថា មិនមាន ឈ្មោះអត្ថថា មាន ភាពមាន ឈ្មោះថា ភាពមិនមាន ភាពមិនមាន ឈ្មោះ ថា ភាពមាន ពាក្យថា មានក្តី ថាមិនមានក្តី ឬថា មិនមានក្តី ថាមានក្តី សភាវៈទាំងនេះ មានអត្ថតែមួយ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជា មួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤១ ] អនាគត មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ អនាគត មានដូចម្ដេច មិនមានដូចម្ដេច ។ អនាគត មានយ៉ាងនេះ គឺអនាគត នៅជាអនាគត អនាគត មិនមានយ៉ាងនេះ គឺអនាគត ជាអតីត អនាគត មិន មានយ៉ាងនេះ គឺអនាគត ជាបច្ចុប្បន្ន ។ អនាគតនោះ មាន អនាគតនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគតនោះ

មាន អនាគតនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន អត្ថថា មិនមាន ឈ្មោះអត្ថថា មាន ។បេ។ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤២ ] បច្ចុប្បន្ន មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ បច្ចុប្បន្ន មានដូចម្តេច មិនមានដូចម្តេច ។ បច្ចុប្បន្ន មានយ៉ាងនេះ គឺបច្ចុប្បន្ន នៅជាបច្ចុប្បន្ន បច្ចុប្បន្ន មិនមានយ៉ាងនេះ គឺបច្ចុប្បន្ន ជាអតីត បច្ចុប្បន្ន មិនមានយ៉ាងនេះ គឺបច្ចុប្បន្ន ជាអនាគត ។ បច្ចុប្បន្ននោះ មាន បច្ចុប្បន្ននោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បច្ចុប្បន្ននោះ មាន បច្ចុប្បន្ននោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន ។បេ។ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៣ ] អ្នកមិនគួរពោលថា អតីត មានយ៉ាងនេះ មិនមានយ៉ាងនេះ អនាគត មានយ៉ាងនេះ មិនមានយ៉ាងនេះ បច្ចុប្បន្ន មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ អតីត មានយ៉ាងនេះ គឺអតីត ជាអនាគត អតីត មានយ៉ាងនេះ គឺអតីត ជាបច្ចុប្បន្ន អនាគត មានយ៉ាងនេះ គឺអនាគត ជាអតីត អនាគត មានយ៉ាងនេះ គឺអនាគត ជាបច្ចុប្បន្ន បច្ចុប្បន្ន មានយ៉ាងនេះ គឺបច្ចុប្បន្ន ជាអតីត បច្ចុប្បន្ន មានយ៉ាងនេះ គឺបច្ចុប្បន្ន ជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បើដូច្នោះ អតីត មានយ៉ាងនេះ មិនមានយ៉ាងនេះ អនាគត មានយ៉ាងនេះ មិនមានយ៉ាងនេះ បច្ចុប្បន្ន មានយ៉ាងនេះ មិន

មានយ៉ាងនេះ ។

[ ៤៤៤ ] រូប មានឬ ។ រូប មានយ៉ាងនេះ មិនមានយ៉ាងនេះ ។ រូបនោះ មាន រូបនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបនោះ មាន រូបនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន អត្ថថា មិនមាន ឈ្មោះអត្ថថា មាន ភាពមាន ឈ្មោះថា ភាពមិនមាន ភាពមិនមាន ឈ្មោះថា ភាពមាន ពាក្យថា មានក្តី ថាមិនមានក្តី ឬថា មិនមានក្តី ថាមានក្តី សភាវៈទាំងនេះ មានអត្ថតែមួយ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នា ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ មានឬ ។ វិញ្ញាណ មានយ៉ាងនេះ មិនមានយ៉ាងនេះ ។ វិញ្ញាណនោះ មាន វិញ្ញាណនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណនោះមាន វិញ្ញាណនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះអត្ថថា មិនមាន ។បេ។ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ រូប មានដូចម្តេច មិនមានដូចម្តេច ។ រូប មានយ៉ាងនេះ គឺរូបនៅជារូប រូប មិនមានយ៉ាងនេះ គឺរូប ជាវេទនា ។បេ។ រូប មិនមានយ៉ាងនេះ គឺរូប ជាសញ្ញា ។បេ។ រូប មិនមានយ៉ាងនេះ គឺរូប ជាសង្ខារ ។បេ។ រូប មិនមានយ៉ាងនេះ គឺរូប ជាវិញ្ញាណ ។ រូបនោះ មាន រូបនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូប

នោះ មាន រូបនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះ អត្ថថា មិនមាន ។បេ។ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ វិញ្ញាណ មានដូចម្ដេច មិនមានដូចម្ដេច ។ វិញ្ញាណ មានយ៉ាងនេះ គឺវិញ្ញាណ នៅជាវិញ្ញាណ វិញ្ញាណ មិនមានយ៉ាងនេះ គឺវិញ្ញាណ ជារូប ។បេ។ វិញ្ញាណ មិនមានយ៉ាងនេះ គឺវិញ្ញាណ ជាវេទនា ។បេ។ វិញ្ញាណ មិនមានយ៉ាងនេះ គឺវិញ្ញាណ ជាសញ្ញា ។បេ។ វិញ្ញាណមិនមានយ៉ាងនេះ គឺវិញ្ញាណ ជាសង្ខារ ។ វិញ្ញាណនោះ មាន វិញ្ញាណនោះឯង ឈ្មោះថា មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណនោះ មាន វិញ្ញាណនោះឯង ឈ្មោះថា មិនមានឬ ។ អើ ។ អត្ថថា មាន ឈ្មោះ អត្ថថា មិនមាន ។បេ។ ស្មើគ្នា មានចំណែកស្មើគ្នា មានកំណើតជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៥ ] អ្នកមិនគួរពោលថា រូប មានយ៉ាងនេះ មិនមានយ៉ាងនេះ ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ វិញ្ញាណ មានយ៉ាងនេះ មិនមានយ៉ាងនេះឬ ។ អើ ។ រូប មានយ៉ាងនេះ គឺរូប ជាវេទនា ។បេ។ រូប មានយ៉ាងនេះ គឺរូប ជាសញ្ញា ។បេ។ រូប មានយ៉ាងនេះ គឺរូប ជាសង្ខារ ។បេ។ រូប មានយ៉ាងនេះ គឺរូប ជាវិញ្ញាណ វេទនា មានយ៉ាងនេះ គឺវេទនា ជាសញ្ញា ជាសង្ខារ ជាវិញ្ញាណ ជារូប វិញ្ញាណ មានយ៉ាងនេះ គឺវិញ្ញាណ ជាវេទនា ។បេ។ វិញ្ញាណ មានយ៉ាងនេះ គឺវិញ្ញាណ ជាសង្ខារឬ ។ អ្នកមិន

គួរពោលយ៉ាងនេះទេ ។បេ។ បើដូច្នោះ រូប មានយ៉ាងនេះ មិនមានយ៉ាងនេះ វេទនា សញ្ញា សង្ខារ វិញ្ញាណ មានយ៉ាងនេះ មិនមានយ៉ាងនេះ ។

ហេវត្ថិតិកថា ចប់

មហាវគ្គទី ១ ចប់

## ឧទានកថា នៃមហាវគ្គទី ១

ពោលអំពីបុគ្គល ១ ការសាបសូន្យ ១ ការនៅដោយព្រហ្មចរិយៈ ១ ការលះកាមរាគៈ ដោយការកំណត់ដឹងដោយចំណែក ១ វាទៈទាំងអស់ មាន ១ អាយតនៈជាចំណែក ក្នុងអតីត អនាគត ១ ធម៌ទាំងអស់ឈ្មោះថា សតិប្បដ្ឋាន ១ សភាវៈមានយ៉ាងនេះ មិនមានយ៉ាងនេះ ១ ។

# អដ្ឋកថា

## ហោវត្ថីកថា

[ ៤៣៧ ] ឥឡូវនេះ នឹងពណ៌នាអំពីការមានដោយភាវៈយ៉ាងនេះដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ដែលមានប្រភេទតាមដែលពោលមកហើយក្នុងខណៈនេះថា ធម៌ទាំងឡាយ មានអតីតធម៌ទាំងពួងជាដើម មានដោយអំណាចនៃធម៌ មានរូបជាដើម ឬអតីតធម៌មិនមានដោយអំណាចនៃអនាគត និងបច្ចុប្បន្ន ឬអនាគតនិងបច្ចុប្បន្ន មិនមានដោយអំណាចនៃអតីតធម៌ជាដើម ព្រោះហេតុនោះ វត្ថុទាំងពួងនោះ យ៉ាងនេះ មាន យ៉ាងនេះ មិនមាន ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា **អតីតំ អត្ថិ** ដូច្នេះ ៗ ពាក្យវិសជ្ជនាថា **ហេវត្ថិ ហេវ នត្ថិ** ជាពាក្យរបស់បរវាទី ៗ

បណ្តាបទទាំងនោះ បទថា **ហេវ** បានដល់ **ឯវំ** ប្រែថា យ៉ាងនេះ ឬដោយសភាវៈយ៉ាងនេះ ៗ លំដាប់នោះ សកវាទីកាលនឹងសួរបរវាទីនោះថា បើអតីតធម៌យ៉ាងនេះមាន យ៉ាងនេះមិនមានសោត កាលបើមានសេចក្តីយ៉ាងនោះមាន អតីតធម៌នោះឯង ឈ្មោះថា មាន អតីតធម៌នោះឯង ឈ្មោះថាមិនមាន ទើបពោលថា **សេវត្ថិ សេវ នត្ថិ** ដូច្នេះ ៗ បរវាទីសំដៅយកការមាននៃធម៌នោះដោយសភាវៈនោះប៉ុណ្ណោះ និងសំដៅយកការមិនមាននៃធម៌ទាំង

នោះ ដោយសភាវៈនោះប៉ុណ្ណោះ ទើបឆ្លើយបដិសេធ ។ បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល សំដៅយកការមាន ដោយសភាវៈរបស់ខ្លួននោះឯង និងការមិនមាន ដោយសភាវៈដទៃ ។ ខាងមុខអំពីនេះទៅ ពាក្យថា **អត្តត្ថោ ឧត្តត្ថោ** អធិប្បាយថា សកវាទីសួរថា ភាវៈដែលជារបស់ខ្លួនមានឈ្មោះថា រមែងជាភាវៈដែលជារបស់ខ្លួន ដែលមិនមានឬ ។ បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងវារៈទាំងពួង ដោយឧបាយនេះ ។

[ ៤៤៣-៤៤៥ ] ក្នុងទីបំផុត ទើបបរវាទីពោលពាក្យថា **តេន ហិ អតីតំ ហោវត្តិ ហោវ ឧត្តិ** និងពាក្យថា **តេន ហិ រូបំ ហោវត្តិ ហោវ ឧត្តិ** ជាដើម ហើយតាំងនូវលទ្ធិក៏ពិត តែលទ្ធិនោះ ក៏ជាលទ្ធិដែលតាំងទៅមិនបាននោះឯង ព្រោះជាលទ្ធិដែលតាំងទុកដោយប្រាសចាកយោនិមនសិការដូច្នេះឯង ។l៚

**អដ្ឋកថាហោវត្តិកថា ចប់**

**មហាវគ្គទី ១ ចប់**

# អភិធម្មបិដក

## កថាវត្ថុ ទុតិយភាគ

### បរូបហារកថា

[ ១ ] ( សកវាទីសួរថា ) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ ( បរវាទីឆ្លើយថា ) អើ ។ រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈរបស់ព្រះអរហន្តមានដែរឬ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២ ] រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ សញ្ញោជនៈ គឺកាម-រាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើរាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តមានទេ ។

[ ៣ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជនមាន រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ សញ្ញោជនៈ គឺកាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាតរបស់ព្រះអរហន្តមាន រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ ។បេ។

កាមច្ឆន្ទនីវរណៈរបស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ ។បេ។ កាមច្ឆន្ទនីវរណៈរបស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន រាគៈ កាមរាគៈ បរិយុដ្ឋាន គឺកាមរាគៈ ។បេ។ កាមច្ឆន្ទនីវរណៈរបស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ។បេ។

[ ៥ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ( ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ) មាន ដោយអត្ថដូចម្តេច ។ ទំនងជាទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ។

[ ៦ ] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតា ជាពួកនៃមារ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៧ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតា ជាពួកនៃមារ មិនមានទេឬ ។ អើ ។ បើការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតា ជាពួកនៃមារ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តទេ ។

[ ៨ ] ទេវតាជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត

របស់ព្រះអរហន្តឬ ។ អើ ។ ទេវតាជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកជនដទៃ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩ ] ទេវតាជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់អ្នកដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះទេឬ ។ អើ ។ បើទេវតាជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់ពួកជនដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តទេ ។

[ ១០ ] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ទេវតាជាពួកនៃមារ នាំយកតាមរណ្តៅនៃរោមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១ ] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ព្រោះហេតុអ្វី ។ ព្រោះទេវតា ( មានគំនិតថា ) យើងនឹងញុំាងអ្នកដទៃឲ្យកាន់យកមតិខុស ។ ព្រះអរហន្ត មានមតិខុសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២ ] មតិខុស របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ មតិខុស

របស់ព្រះអរហន្ត ក្នុងព្រះសាស្តា មតិខុសក្នុងព្រះធម៌ មតិខុសក្នុព្រះសង្ឃ មតិខុសក្នុងសិក្ខា មតិខុសក្នុងចំណែកខាងដើម មតិខុសក្នុងចំណែកខាងចុង មតិខុសក្នុងចំណែកខាងដើម និងខាងចុង មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣ ] មតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា មិនមានមតិខុសក្នុងព្រះធម៌ មិនមានមតិខុសក្នុងព្រះសង្ឃ មិនមានមតិខុសក្នុងសិក្ខា មិនមានមតិខុសក្នុងចំណែកខាងដើម មិនមានមតិខុសក្នុងចំណែកខាងចុង មិនមានមតិខុសក្នុងចំណែកខាងដើម និងខាងចុង មិនមានក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យទេឬ ។ អើ ។ បើមតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា ។បេ។ មិនមានមតិខុសក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មតិខុសរបស់ព្រះអរហន្ត មានទេ ។

[ ១៤ ] មតិខុស របស់បុថុជ្ជន មាន មតិខុសរបស់បុថុជ្ជននោះ ក្នុងព្រះសាស្តា ។បេ។ មតិខុស ក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ មតិខុសរបស់ព្រះអរហន្ត មានមតិខុសរបស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា ។បេ។ មតិខុសក្នុងធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥ ] មតិខុស របស់ព្រះអរហន្ត មាន មតិខុស របស់ព្រះអរហន្ត នោះ មិនមានក្នុងព្រះសាស្តា ។បេ។ មិនមានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យឬ ។ អើ ។ មតិខុសរបស់ បុថុជ្ជន មាន មតិខុសរបស់បុថុជ្ជននោះ មិនមានក្នុងព្រះសាស្តា ។បេ។ មិន មានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជា បច្ច័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរ ឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃរបស់អ្វី ។ ការបញ្ចេញទឹកសុក្កៈ របស់ព្រះអរហន្ត ជាអានិសង្សនៃបាយ ដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ។ ការបញ្ចេញ ទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែល ផឹក វត្ថុដែលទំពាស៊ី និងរសដែលលិទ្ធភក្សដែរឬ ។ អើ ។ ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ជនទាំង អស់នោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ១៧ ] ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹក សុក្កៈ មិនស្អាត របស់ជនទាំងអស់នោះ មានដែរឬ ។ អើ ។ ពួកទារក ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទារក មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨ ] ពួកបណ្ឌកៈ ( មនុស្សខ្ទើយ ) ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស

ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកបណ្ឌកៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩ ] ពួកទេវតា ស៊ី ផឹក ទំពាស៊ី លិទ្ធភក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាតរបស់ពួកទេវតា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ឬ ។ អើ ។ ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរនិយាយយ៉ាងនេះទេ ។បេ។

[ ២១ ] ឧច្ចារៈ និងបស្សាវៈ របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ឧច្ចារៈ និងបស្សាវៈ របស់ព្រះអរហន្ត ជាអានិសង្សនៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង គប្បីនៅគ្រប់គ្រងនូវទីដេក ដ៏ចង្អៀតដោយកូន គប្បីប្រដាប់នូវខ្លឹមចន្ទន៍ក្នុងដែនកាសិកៈ គប្បីទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គប្បីត្រេកអរចំពោះមាស និងប្រាក់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៤ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន បុថុជ្ជនគប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង ។បេ។ គប្បីត្រេកអរចំពោះមាស និងប្រាក់ដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង ។បេ។ គប្បីត្រេកអរចំពោះមាស និងប្រាក់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តមាន តែព្រះអរហន្ត មិនសេពមេថុនធម្ម មិនញុំាងមេថុនធម្មឲ្យកើតឡើងទេ ។បេ។ មិនត្រេកអរចំពោះមាស និងប្រាក់ទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាតរបស់បុថុជ្ជន មាន តែបុថុជ្ជន មិនសេពមេថុនធម្ម មិនញុំាងមេថុនធម្មឲ្យកើតឡើង មិនគប្បីអាស្រ័យនូវទីដេកដ៏ចង្អៀតដោយកូន មិនប្រដាប់នូវខ្លឹមចន្ទន៍ ក្នុងដែនកាសិកៈ មិនទ្រទ្រង់នូវកម្រផ្កា គ្រឿងក្រអូប គ្រឿងលាប មិនត្រេកអរចំពោះមាស និងប្រាក់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាទីធម៌លែងកើតតទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ២៧ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ លះមានះ លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈ លះអហិរិកៈ ។បេ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ២៨ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តមានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោល

ថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ២៩ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរ ឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។បេ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពល ។បេ។ ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ៣០ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរ ឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះមោហៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ៣១ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរ ឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួន ដល់ហើយ មានសញ្ញោជនៈ ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះបើកឡើងហើយ មានគូទម្លាយហើយ មានសសរខឿនដកឡើងហើយ មិនមានគន្ទឹះទ្វារ ជាអរិយ-

បុគ្គល មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជម្នះ ឈ្នះល្អហើយ ព្រះអរហន្តនោះ កំណត់ដឹងនូវទុក្ខ លះនូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើនមគ្គ ត្រាស់ដឹងនូវអភិញ្ញេយ្យកិច្ច កំណត់ដឹងនូវបរិញ្ញេយ្យកិច្ច លះនូវបហាតព្វកិច្ច ចម្រើននូវភាវេតព្វកិច្ច ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វកិច្ចឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ ។បេ។ ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វកិច្ច ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[ ៣២ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានឬ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួនមាន ការបញ្ចេញទឹកសុក្កៈ មិនស្អាតរបស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តអ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈហើយ លះមោហៈហើយ ។បេ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្តអ្នកឈ្លាសក្នុងធម៌ដទៃ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះមោហៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះ

អរហន្តអ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះទោសៈហើយ លះមោហៈហើយ ។បេ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ដើម្បីលះមោហៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ

ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២ ] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាបុថុជ្ជន បរិបូណ៌ដោយសីល មានសតិ និងសម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាដេកលក់ អសុចិរបស់ភិក្ខុទាំងនោះ មិនឃ្លាតចេញទេ ម្នាលភិក្ខុទាំងឡាយ ពួកឥសី ជាខាងក្រៅណា ប្រាសចាករាគៈ ក្នុងកាមទាំងឡាយ អសុចិរបស់ឥសីទាំងនោះ មិនឃ្លាតចេញទេ អសុចិរបស់ព្រះអរហន្ត គប្បីឃ្លាតចេញ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ រមែងមិនមានមិនមែនជាឱកាសទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តមានទេ ។

[ ៤៣ ] អ្នកមិនគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌ-បាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរឬ ។ អើ ។ បើពួកជនដទៃ គប្បីនាំមកនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្តមានដែរ ។

[ ៤៤ ] ពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរឬ ។ ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ពួកជនដទៃគប្បីនាំមកនូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ដើម្បីព្រះអរហន្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

### បរូបហារកថា ចប់

# អដ្ឋកថា

## បរូបហារកថា

[ ១ ] ឥឡូវនេះ នឹងពណ៌នាអំពីអ្នកដទៃនាំមកឲ្យដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា ដូចនិកាយបុព្វសេលិយៈ និងនិកាយអបរសេលិយៈទាំងឡាយ ក្នុងខណៈនេះ រមែងសម្គាល់ថា ទេវតាដែលទាក់ទងក្នុងពួកមារ បង្អោននាំទឹកសុក្កៈ គឺទឹកអសុចិចូលទៅដល់ព្រះអរហន្តបាន ព្រោះឃើញការហូរទឹកសុក្កៈ គឺអសុចិរបស់ជនទាំងឡាយ ដែលសម្គាល់ខុស មានការសម្គាល់ក្នុងធម៌ ដែលខ្លួនមិនសម្រេចថា សម្រេច ហើយប្ដេជ្ញាខ្លួនថាជាព្រះអរហន្ត ឬបុគ្គលអ្នកបោកបញ្ឆោត ដែលប្ដេជ្ញាខ្លួនថា ជាព្រះអរហន្ត សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា **អត្ថិ អរហតោ** ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

ឈ្មោះថា ការហូរទឹកសុក្កៈ រមែងមាន ព្រោះរាគៈជាសមុដ្ឋាន ព្រោះហេតុនោះ ឥឡូវនេះ ទើបសកវាទីសួរថា **អត្ថិ អរហតោ រាគោ** ដូច្នេះ អត្ថទាំងពួងនោះ ងាយយល់ហើយ ។

[ ៧ ] ក្នុងបញ្ហាថា **មារកាយិកា ទេវតា អត្តនោ** ជាដើម សេចក្ដីថា ឈ្មោះថា ការបញ្ចេញទឹកសុក្កៈរបស់ទេវតាទាំងនោះ រមែងមិនមាន ទាំងទេវតាទាំងនោះ ក៏មិនកាន់យកទឹកសុក្កៈ ហើយបង្អោនចូលទៅដល់ជនពួក

ដទៃ ទាំងទឹកសុក្កៈរបស់ព្រះអរហន្តនោះឯង ក៏មិនមាន ព្រោះហេតុនោះ ទើបបរវាទីបដិសេធថា **ន ហេវំ** ។

[ ៩ ] ក្នុងបញ្ហាថា **នេវ អត្តនោ** សេចក្តីថា បរវាទីនោះ រមែងឆ្លើយទទួល ព្រោះលទ្ធិថា ទេវតានិម្មិតហើយ នាំចូលទៅ ។

[ ១០ ] ក្នុងបញ្ហាថា **លោមកូបេហិ** បរវាទីបដិសេធ ព្រោះឃើញថា មិនមានការនាំចូលទៅតាមរន្ធរោមទាំងឡាយ ដូចការនាំសប្បិ និងប្រេងទាំងឡាយចូលទៅ ។

[ ១១ ] បទថា **ហន្ទ ហិ** ជានិបាត ចុះក្នុងអត្ថនៃការសម្រេចចិត្ត ។ អធិប្បាយថា ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកមារ បង្អោននាំសុក្កៈចូលទៅ ដោយធ្វើនូវការសម្រេចចិត្តយ៉ាងនេះថា យើងនឹងធ្វើព្រះអរហន្ត ឲ្យសង្ស័យយ៉ាងនេះថា អញជាព្រះអរហន្ត ឬមិនមែនជាព្រះអរហន្តហ្ន៎ ដូច្នេះ ។

[ ១២ ] ត្រូវសកវាទីសួរថា **អត្ថិ អរហតោ វិមតិ** បរវាទីសំដៅយកការសង្ស័យ មានវត្ថុ ៨ ប្រការ ទើបឆ្លើយបដិសេធ ។ ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះសំដៅយកការដាក់ចិត្តមិនបានក្នុងនាម និងគោត្តជាដើមនៃស្ត្រី និងបុរសជាដើម ។

*[ ២១ ] បទថា* **អត្ថិ តស្ស អាសយោ** *សេចក្តីថា សកវាទីសួរថា ឱកាសជាទីតាំងនៅនៃទឹកស្អុះនោះមាន ដូចឱកាសជាទីតាំងនៅរបស់ឧច្ចារ-បស្សាវៈឬ ។*

*[ ៣២ ] បទថា* **សធម្មកុសលស្ស** *បានដល់ អ្នកឈ្លាសត្រឹមតែធម៌គឺព្រះអរហត្តរបស់ខ្លួនប៉ុណ្ណោះ ។ បរវាទីសំដៅយកព្រះអរហន្តដែលរួចផុតដោយបញ្ញា ទើបពោលបែបនោះ ។ បទថា* **បរធម្មកុសលស្ស** *បានដល់ ដែលឈ្លាសក្នុងធម៌ដែលជាសមាបត្តិ ៨ ក្រៅអំពីព្រះអរហត្តធម៌ ។ បរវាទីសំដៅយកព្រះអរហន្តដែលជាឧភតោភាគវិមុត្ត ទើបពោលយ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយទំនងដែលពោលហើយ ក្នុងព្រះបាលីនោះឯង ដូច្នេះ ។៚*

**អដ្ឋកថាបរូបហារកថា ចប់**

# អភិធម្មបិដក

## អញ្ញាណកថា

[ ៤៥ ] ការមិនដឹងរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជារបស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦ ] អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើអវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៤៧ ] ការមិនដឹងរបស់បុថុជ្ជន មាន អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨ ] ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា

នីវរណៈ គឺអវិជ្ជា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់បុថុជ្ជន មាន អវិជ្ជា ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា បរិយុដ្ឋាន គឺអវិជ្ជា សញ្ញោជនៈ គឺអវិជ្ជា នីវរណៈ គឺអវិជ្ជា របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យ ដែលគេមិនឲ្យ គប្បីពោលពាក្យកុហក គប្បីពោលពាក្យញុះញង់ គប្បីពោលពាក្យអាក្រក់ គប្បីពោលពាក្យឥតប្រយោជន៍ គប្បីកាត់ទីត គប្បីពួនចាំ ឆក់ គប្បីប្លន់តែផ្ទះ ១ គប្បីឈរស្ទាក់ត្រង់ផ្លូវ គប្បីគប់រកប្រពន្ធបុគ្គលដទៃ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០ ] ការមិនដឹង របស់បុថុជ្ជន មាន បុថុជ្ជន ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យ ដែលគេមិនឲ្យ ។បេ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អើ ។ ការមិនដឹងរបស់ព្រះអរហន្ត មាន ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។បេ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១ ] ការមិនដឹង របស់ព្រះអរហន្ត មាន ប៉ុន្តែព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យដែលគេមិន

ឲ្យ ។បេ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគមទេឬ ។ អើ ។ ការមិនដឹងរបស់បុថុជ្ជន មាន ប៉ុន្តែ បុថុជ្ជនដែលការមិនដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។បេ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២ ] ការមិនដឹងរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការមិនដឹងរបស់ព្រះអរហន្ត ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាងដើម មិនដឹងក្នុងចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើម និងចំណែកខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣ ] ការមិនដឹងរបស់ព្រះអរហន្ត ក្នុងព្រះសាស្តា ការមិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាងដើម មិនដឹងក្នុងចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើម និងចំណែកខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ បើការមិនដឹងរបស់ព្រះអរហន្ត ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។បេ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៥៤ ] ការមិនដឹងរបស់បុថុជ្ជន មាន ការមិនដឹងរបស់បុថុជ្ជននោះ

ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។បេ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ ការមិនដឹងរបស់ព្រះអរហន្ត មាន ការមិនដឹងរបស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។បេ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥ ] ការមិនដឹងរបស់ព្រះអរហន្ត មាន ការមិនដឹងរបស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។បេ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។អើ ។ ការមិនដឹងរបស់ព្រះបុថុជ្ជន មាន ការមិនដឹងរបស់បុថុជ្ជននោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។បេ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦ ] ការមិនដឹងរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។បេ។ ក្រែង

ព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៥៧ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៥៨ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៥៩ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ឆិកាតព្វកិច្ច ( កិច្ចដែលគួរធ្វើឲ្យជាក់ច្បាស់ ) លោកធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ។បេ។ សច្ឆិកាតព្វកិច្ច លោក

ធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៦០ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ ការមិនដឹងរបស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មាន ការមិនដឹងរបស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ ការមិនដឹងរបស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានដែរឬ ។ អ្នកមិគួរពោលយ៉ាងនេះទេ ។បេ។

[ ៦១ ] ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈ លះមោហៈ ។បេ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បី

លះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្តអ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៨ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ។បេ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៩ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧០ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧១ ] ការមិនដឹងរបស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃ

អាសវៈរបស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងដូចម្ដេច កាលឃើញដូចម្ដេច ( ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញយ៉ាងនេះថា ) រូប ដូច្នេះ ការកើតឡើងនៃរូប ដូច្នេះ សេចក្ដីវិនាសទៅនៃរូប ដូច្នេះ វេទនា ដូច្នេះ ។បេ។ សញ្ញា ដូច្នេះ ។បេ។ សង្ខារទាំងឡាយ ដូច្នេះ ។បេ។ វិញ្ញាណ ដូច្នេះ ការកើតឡើងនៃវិញ្ញាណ ដូច្នេះ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះ ដូច្នេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៧២ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងដូចម្ដេច កាលឃើញដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះ ជាទុក្ខ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងថា នេះជាទុក្ខសមុទ័យ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធ ការអស់

ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធគាមិនីបដិបទា ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មាន ក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹងរបស់ព្រះអរហន្ត មានទេ ។

[ ៧៣ ] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិនបន្ទោបង់ មិនលះបង់ នូវធម៌ទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹងច្បាស់ កំណត់ដឹង បន្ទោបង់ លះបង់ នូវធម៌ទាំងពួង គួរដើម្បីអស់ទៅនៃទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៧៤ ] ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

> ធម៌ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ណាមួយ ដែលព្រះសោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះ ចាកអបាយទាំង ៤ ហើយ មិនគួរធ្វើនូវឋានៈដ៏អាក្រក់ ៦ យ៉ាង គឺអនន្តរិយកម្ម ៥ និងកិរិយាផាកចិត្តទៅកាន់សាសនាដទៃ ពាក្យដូច្នេះ មានក្នុង

ព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៧៥ ] ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវកមានធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណាមួយ កើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ( ក្នុងសម័យនោះ ) អរិយសាវក លះបង់នូវសញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ជាមួយនឹងការកើតឡើងនៃទស្សនៈ គឺសោតាបត្តិមគ្គ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[ ៧៦ ] អ្នកមិនគប្បីពោលថា ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនគប្បីដឹងនូវនាម និងគោត្ត របស់ស្ត្រី និងបុរស មិនគប្បីដឹងនូវផ្លូវ និងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំឬ ។ អើ ។ បើព្រះអរហន្ត មិនគប្បីដឹងនូវនាម និងគោត្ត របស់ស្ត្រី និងបុរស មិនគប្បីដឹងនូវផ្លូវ និងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ការមិនដឹង របស់ព្រះអរហន្ត មាន ។ ព្រះអរហន្ត មិនគប្បីដឹងនូវនាម និងគោត្តនៃស្ត្រី និងបុរស មិនគប្បីដឹងនូវផ្លូវ និងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ព្រោះហេតុនោះ ការមិនដឹង របស់ព្រះ

អរហន្ត មានឬ ។ អើ ។ ព្រះអរហន្ត មិនគប្បីដឹង នូវសោតាបត្តិផលក្តី នូវសកទាគាមិផលក្តី នូវអនាគាមិផលក្តី នូវអរហត្តផលក្តី ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អញ្ញាណកថា ចប់

## កង្ខាកថា

[ ៧៧ ] កង្ខា ( ការងឿងឆ្ងល់ ) របស់ព្រះអរហន្ត មានឬ ។ អើ ។ វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់ព្រះអរហន្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៧៨ ] វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើវិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កង្ខារបស់ព្រះអរហន្ត មានទេ ។

[ ៧៩ ] កង្ខារបស់បុថុជ្ជន មាន វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ កង្ខារបស់ព្រះអរហន្ត មាន វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨០ ] កង្ខារបស់ព្រះអរហន្ត មាន វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា

សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ កង្ខារបស់បុថុជ្ជន មាន វិចិកិច្ឆា បរិយុដ្ឋាន គឺវិចិកិច្ឆា សញ្ញោជនៈ គឺវិចិកិច្ឆា នីវរណៈ គឺវិចិកិច្ឆា របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨១ ] កង្ខា របស់ព្រះអរហន្ត មានឬ ។ អើ ។ កង្ខា របស់ព្រះអរហន្ត ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ កង្ខាក្នុងព្រះសង្ឃ កង្ខាក្នុងសិក្ខា កង្ខាក្នុងខន្ធជាចំណែកខាងដើម កង្ខាក្នុងខន្ធជាចំណែកខាងចុង កង្ខាក្នុងខន្ធជាចំណែកខាងដើម និងចំណែកខាងចុង កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះ ជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨២ ] កង្ខា របស់ព្រះអរហន្ត ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ កង្ខាក្នុងព្រះសង្ឃ ។បេ។ កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះ ជាបច្ច័យ មិនមានទេឬ ។ អើ ។ បើកង្ខារបស់ព្រះអរហន្ត ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ ។បេ។ កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះ ជាបច្ច័យ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កង្ខារបស់ព្រះអរហន្ត មានទេ ។

[ ៨៣ ] កង្ខា របស់បុថុជ្ជន មាន កង្ខា របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ ។បេ។ កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អើ ។ កង្ខារបស់ព្រះអរហន្ត មាន

កង្ខា របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ ។បេ។ កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៤ ] កង្ខា របស់ព្រះអរហន្ត មាន កង្ខា របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ ។បេ។ កង្ខា ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះ ជាបច្ច័យ មិនមានទេឬ ។ អើ ។ កង្ខា របស់បុថុជ្ជន មាន កង្ខារបស់បុថុជ្ជននោះ ក្នុងព្រះសាស្តា កង្ខាក្នុងព្រះធម៌ ។បេ។ កង្ខាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះ ជាបច្ច័យ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៥ ] កង្ខា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កង្ខារបស់ព្រះអរហន្ត មានទេ ។

[ ៨៦ ] កង្ខា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ក្រែងព្រះអរហន្ត

ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ៨៧ ] កង្ខា របស់ព្រះអរហន្ត មានឬ ។ កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មាន កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានឬ ។ អើ ។ កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ។បេ។

[ ៨៨ ] កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ កង្ខា របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៨៩ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះបង់រាគៈ កង្ខា របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះបង់រាគៈ កង្ខា របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៩០ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះបង់ទោសៈ ។បេ។ លះបង់មោហៈ ។បេ។ លះបង់អនោត្តប្បៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បី

លះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។

[ ៩១ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ កង្ខា របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ កង្ខា របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩២ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ កង្ខា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ កង្ខា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៩៣ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។

[ ៩៤ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ កង្ខា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់

ច្បាស់ហើយ កង្ខា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៩៥ ] កង្ខា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ( ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា ) រូប ដូច្នេះ ។បេ។ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ៩៦ ] កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខ ។បេ។ ថា

នេះជាសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ៩៧ ] កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនដឹងច្បាស់ កាលមិនកំណត់ដឹង កាលមិនបន្ទោបង់ កាលមិនលះបង់នូវធម៌ទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខទេ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹងច្បាស់ កាលកំណត់ដឹង កាលបន្ទោបង់ កាលលះបង់នូវធម៌ទាំងពួង ទើបគួរដើម្បីអស់ទៅនៃទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ៩៨ ] កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ( សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ) ជាមួយនឹងទស្សនសម្បទ ។បេ។ មិនគួរធ្វើនូវឋានៈអាក្រក់ ៦ យ៉ាង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ៩៩ ] កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវក មានធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណាមួយ

កើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ម្នាលភិក្ខុទាំងឡាយ ( សម័យនោះ ) អរិយសាវ័ក បានលះបង់សញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ជាមួយនឹងការកើតឡើងនៃទស្សនៈ គឺសោតាបត្តិមគ្គ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ១០០ ] កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រះខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា កង្ខា ( ការងឿងឆ្ងល់ ) ទាំងពួង របស់ព្រះខីណាសវព្រាហ្មណ៍នោះ ក៏រម្ងាប់អស់ទៅ ក្នុងកាលនោះ ព្រោះថា ព្រះខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ ព្រមទាំងហេតុ ធម៌ទាំងឡាយ ប្រាកដដល់ព្រះខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា កង្ខាទាំងពួង របស់ព្រះខីណាសវព្រាហ្មណ៍នោះ តែងរម្ងាប់អស់ទៅ ក្នុងកាលនោះ ព្រោះថា ព្រះខីណាសវ-ព្រាហ្មណ៍នោះ បានដឹងច្បាស់ នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យ ធម៌ទាំងឡាយ ប្រាកដដល់ព្រះខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុង

កាលណា ព្រះខីណាស្រវព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារ ព្រមសេនានៃមារ ហើយស្ថិតនៅ ក្នុងកាលនោះ ដូចព្រះអាទិត្យ កាលរះឡើង ធ្វើអាកាសឲ្យរុងរឿង ដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹត ស្ថិតនៅ ដូច្នោះឯង កង្ខាណាមួយ ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី ដែលបុគ្គលដឹងដោយខ្លួនឯង ឬដែលបុគ្គលដទៃដឹងហើយ ព្រះខីណាស្រវព្រាហ្មណ៍ទាំងឡាយនោះ អ្នកមានព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ប្រព្រឹត្តព្រហ្មចរិយៈ តែងលះបង់នូវកង្ខាទាំងពួងនោះ ពួកជនណា កន្លងកង្ខាបានហើយ មិនមានសេចក្តីសង្ស័យ ប្រាសចាកសេចក្តីសង្ស័យ ក្នុងពួកសត្វដែលមានសេចក្តីសង្ស័យកើតហើយ ទានដែលបុគ្គលឲ្យហើយ ចំពោះពួកជននោះ តែងមានផលច្រើន ការប្រកាសនូវធម៌ ក្នុងសាសនានេះ ប្រាកដដូច្នេះ សាវកណាមួយ សង្ស័យដូចម្តេច ក្នុងការប្រកាសនូវធម៌នោះ បពិត្រព្រះអង្គជាធំជាងជន យើងទាំងឡាយ សូមថ្វាយបង្គំ នូវព្រះជិនស្រី ជាព្រះពុទ្ធ ព្រះអង្គឆ្លងនូវអន្លង់ កាត់បង់វិចិកិច្ឆាហើយ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេ ។

[ ១០១ ] អ្នកមិនគួរពោលថា កង្ខា របស់ព្រះអរហន្ត មានទេឬ ។

អើ ។ ក្រែងព្រះអរហន្ត គប្បីងឿងឆ្ងល់ ក្នុងនាម និងគោត្ត របស់ស្ត្រី និងបុរស គប្បីងឿងឆ្ងល់ ក្នុងផ្លូវ និងមិនមែនផ្លូវ គប្បីងឿងឆ្ងល់ ក្នុងឈ្មោះនៃស្មៅ ឈើតូច និងឈើធំឬ ។ អើ ។ បើព្រះអរហន្ត គប្បីងឿងឆ្ងល់ក្នុងនាម និងគោត្តរបស់ស្ត្រី និងបុរស គប្បីងឿងឆ្ងល់ក្នុងផ្លូវ និងមិនមែនផ្លូវ គប្បីងឿងឆ្ងល់ ក្នុងឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា កង្ខា របស់ព្រះអរហន្ត មានដែរ ។ ព្រះអរហន្ត គប្បីងឿងឆ្ងល់ក្នុងនាម និងគោត្តនៃស្ត្រី និងបុរស គប្បីងឿងឆ្ងល់ ក្នុងផ្លូវ និងមិនមែនផ្លូវ គប្បីងឿងឆ្ងល់ ក្នុងឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ព្រោះហេតុនោះ កង្ខា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត គប្បីងឿងឆ្ងល់ ក្នុងសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

កង្ខាកថា ចប់

## បរវិតារណាកថា

[ ១០២ ] បរវិតារណា ( ការឆ្លងផុតដោយបុគ្គលដទៃ ) របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត មានបុគ្គលណែនាំ សម្រេចដោយបុគ្គលដទៃ មានបុគ្គលដទៃជាបច្ច័យ រស់នៅជាប់ដោយបុគ្គលដទៃ រមែងមិនដឹង មិនឃើញ ជាអ្នកវង្វេង ជាអ្នកមិនដឹងខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៣ ] ក្រែងព្រះអរហន្ត មិនមានបុគ្គលដទៃណែនាំ មិនសម្រេចដោយបុគ្គលដទៃ មិនមានបុគ្គលដទៃជាបច្ច័យ មិនរស់នៅជាប់ដោយបុគ្គលដទៃ រមែងដឹង ឃើញ ជាអ្នកមិនវង្វេង ជាអ្នកដឹងខ្លួនឬ ។ អើ ។ បើព្រះអរហន្ត មិនមានបុគ្គលដទៃណែនាំ មិនសម្រេចដោយបុគ្គលដទៃ មិនមានបុគ្គលដទៃជាបច្ច័យ មិនរស់នៅជាប់ដោយបុគ្គលដទៃ រមែងដឹង ឃើញ ជាអ្នកមិនវង្វេង ជាអ្នកដឹងខ្លួន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការឆ្លងផុតដោយបុគ្គលដទៃ របស់ព្រះអរហន្ត មានទេ ។

[ ១០៤ ] ការឆ្លងផុតដោយបុគ្គលដទៃ របស់បុថុជ្ជន មាន បុថុជ្ជននោះ មានបុគ្គលណែនាំ សម្រេចដោយបុគ្គលដទៃ មានបុគ្គលដទៃជាបច្ច័យ រស់នៅជាប់ដោយបុគ្គលដទៃ រមែងមិនដឹង មិនឃើញ ជាអ្នកវង្វេង ជាអ្នកមិនដឹងខ្លួនឬ ។ អើ ។ ការឆ្លងផុតដោយបុគ្គលដទៃ របស់ព្រះអរហន្ត មាន ព្រះអរហន្តនោះ មានបុគ្គលដទៃណែនាំ សម្រេចដោយបុគ្គលដទៃ មានបុគ្គលដទៃជាបច្ច័យ រស់នៅជាប់ដោយបុគ្គលដទៃ រមែងមិនដឹង មិនឃើញ ជាអ្នកវង្វេង ជាអ្នកមិនដឹងខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៥ ] ការឆ្លងផុតដោយបុគ្គលដទៃ របស់ព្រះអរហន្ត មាន តែព្រះអរហន្តនោះ មិនមានបុគ្គលដទៃណែនាំ មិនសម្រេចដោយបុគ្គលដទៃ មិនមានបុគ្គលដទៃជាបច្ច័យ មិនរស់នៅជាប់ដោយបុគ្គល រមែងដឹង ឃើញ ជាអ្នកមិនវង្វេង ជាអ្នកដឹងខ្លួនឬ ។អើ។ ការឆ្លងផុតដោយបុគ្គលដទៃ របស់បុថុជ្ជន មាន តែបុថុជ្ជននោះ មិនមានបុគ្គលដទៃណែនាំ មិនសម្រេចដោយ

បុគ្គលដទៃ មិនមានបុគ្គលដទៃជាបច្ច័យ មិនរស់នៅជាប់ដោយបុគ្គលដទៃ រមែងដឹង ឃើញ ជាអ្នកមិនវង្វេង ជាអ្នកដឹងខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៦ ] ការច្នេងផុតដោយបុគ្គលដទៃ របស់ព្រះអរហន្ត មានឬ ។ អើ ។ បរវិតារណា ( ការច្នេងផុតដោយបុគ្គលដទៃ ) របស់ព្រះអរហន្ត ក្នុងព្រះសាស្តា បរវិតារណាក្នុងព្រះធម៌ បរវិតារណាក្នុងព្រះសង្ឃ បរវិតារណាក្នុងសិក្ខា បរវិតារណាក្នុងខន្ធជាចំណែកខាងដើម បរវិរតាណាក្នុងខន្ធជាចំណែកខាងចុង បរវិតារណាក្នុងខន្ធជាចំណែកខាងដើម និងខាងចុង បរ-វិតារណាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៧ ] បរវិតារណារបស់ព្រះអរហន្ត ក្នុងព្រះសាស្តា បរវិតារណាក្នុងព្រះធម៌ ។បេ។ បរវិតារណាក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ បើបរវិតារណារបស់ព្រះអរហន្ត ក្នុងព្រះសាស្តា បរវិតារណាក្នុងព្រះធម៌ ។បេ។ បរវិតារណាក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរវិតារណារបស់ព្រះអរហន្ត មានទេ ។

[ ១០៨ ] បរវិតារណារបស់បុថុជ្ជន មាន បរវិតារណារបស់បុថុជ្ជននោះ ក្នុងព្រះសាស្តា បរវិតារណា ក្នុងព្រះធម៌ ។បេ។ បរវិតារណា ក្នុង

ពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មាន ឬ ។ អើ ។ បរិវិតារណា របស់ព្រះអរហន្ត មាន បរិវិតារណា របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្ដា បរិវិតារណា ក្នុងព្រះធម៌ ។បេ។ បរិវិតារណា ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១០៩ ] បរិវិតារណា របស់ព្រះអរហន្ត មាន បរិវិតារណា របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្ដា បរិវិតារណា ក្នុងព្រះធម៌ ។បេ។ បរិវិតារណា ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេ ។ អើ ។ បរិវិតារណា របស់បុថុជ្ជន មាន បរិវិតារណា របស់បុថុជ្ជននោះ ក្នុងព្រះសាស្ដា បរិវិតារណា ក្នុងព្រះធម៌ ។បេ។ បរិវិតារណា ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១០ ] បរិវិតារណា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត លះរាគៈ ផ្ដាច់ផ្ដិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ផ្ដាច់ផ្ដិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរិវិតារណា របស់ព្រះអរហន្ត មានទេ ។បេ។ ក្រែងព្រះអរហន្ត លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ។បេ។

[ ១១១ ] ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។

[ ១១២ ] ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរិហានិ របស់ព្រះអរហន្ត មានទេ ។

[ ១១៣ ] បរិហានិ របស់ព្រះអរហន្ត មានឬ ។ បរិហានិ របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មាន បរិហានិ របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ បរិហានិ របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានឬ ។ អើ ។ បរិហានិរបស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៤ ] បរិហានិ របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ បរិហានិ របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៥ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ បរិហានិ របស់ព្រះអរហន្តនោះ មានឬ ។អើ ។ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ បរិហានិ របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។

[ ១១៦ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ។បេ។

[ ១១៧ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។

[ ១១៨ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ បរិហានិ-តារណា របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ បរិហានិតារណា របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១១៩ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ បរិហានិតារណា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ បរិហានិតារណា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះទោសៈ ។បេ។ លះមោហៈ ។បេ។ លះអនោត្តប្បៈ ។បេ។

[ ១២០ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។ ដើម្បីលះទោសៈ ។បេ។ ចម្រើនមគ្គ

ដើម្បីលះអនោត្តប្បៈ ។បេ។ ចម្រើនពោជ្ឈង្គ ។បេ។

[ ១២១ ] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ បរិតារណា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។បេ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ បរិតារណា របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១២២ ] បរិតារណា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ( ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញថា ) រូបដូច្នេះ ។បេ។ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បរិតារណា របស់ព្រះអរហន្ត មានទេ ។

[ ១២៣ ] បរិតារណា របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះ

មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈរបស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញថា នេះទុក្ខ ថានេះហេតុកើតឡើងនៃទុក្ខ ។បេ។ ថានេះទីរលត់ទុក្ខ ។បេ។ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹង កាលឃើញថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈរបស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បរិហានិ របស់ព្រះអរហន្ត មានទេ ។

[ ១២៤ ] បរិហានិ របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនដឹងច្បាស់ កាលមិនកំណត់ដឹង កាលមិនបន្ទោបង់ កាលមិនលះបង់ នូវអាសវៈទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខទេ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹង កាលកំណត់ដឹង កាលបន្ទោបង់ កាលលះបង់ នូវអាសវៈទាំងពួង ទើបគួរដើម្បីអស់ទៅនៃទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បរិហានិ របស់ព្រះអរហន្ត មានទេ ។

[ ១២៥ ] បរិហានិ របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ( សោតាបន្នបុគ្គលនោះ លះបង់ហើយ ) ជាមួយនឹងទស្សនសម្បទ គឺសោតាបត្តិមគ្គ ។បេ។ មិនគួរធ្វើឋានៈដ៏អាក្រក់ទាំង ៦ យ៉ាង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បរិហានិ របស់ព្រះអរហន្ត មានទេ ។

[ ១២៦ ] បរិហានិ របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវកមានធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ( សម័យនោះ ) អរិយសាវក លះបង់សញ្ញោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ជាមួយនឹងការកើតឡើងនៃទស្សនៈ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា បរិហានិ របស់ព្រះអរហន្ត មានទេ ។

[ ១២៧ ] បរិហានិ របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

ម្នាលធោតកៈ តថាគត នឹងមិនទៅដើម្បីដោះនូវបុគ្គលណា
មួយ អ្នកមានសេចក្តីសង្ស័យក្នុងលោកទេ អ្នកកាលដឹងនូវ
ធម៌ដ៏ប្រសើរ រមែងឆ្លងនូវអន្លង់បាន ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា

បរិតារណា របស់ព្រះអរហន្ត មានទេ ។

[ ១២៨ ] អ្នកមិនគួរពោលថា បរិតារណា របស់ព្រះអរហន្ត មានទេឬ ។ អើ ។ ក្រែងពួកជនដទៃ គប្បីប្រាប់នូវនាម និងគោត្ត របស់ស្ត្រីនិងបុរស ពួកជនដទៃ គប្បីប្រាប់នូវផ្លូវ និងមិនមែនផ្លូវ ពួកជនដទៃ គប្បីប្រាប់នូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ចំពោះព្រះអរហន្តឬ ។ អើ ។ បើជនដទៃ គប្បីប្រាប់នូវនាម និងគោត្ត របស់ស្ត្រី និងបុរស ពួកជនដទៃ គប្បីប្រាប់នូវផ្លូវ និងមិនមែនផ្លូវ ពួកជនដទៃ គប្បីប្រាប់នូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ចំពោះព្រះអរហន្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បរិតារណា របស់ព្រះអរហន្ត មានដែរ ។

[ ១២៩ ] ពួកជនដទៃ គប្បីប្រាប់នូវនាម និងគោត្ត របស់ស្ត្រី និងបុរស ពួកជនដទៃ គប្បីប្រាប់នូវផ្លូវ និងមិនមែនផ្លូវ ពួកជនដទៃ គប្បីប្រាប់នូវឈ្មោះនៃស្មៅ ឈើតូច និងឈើធំ ចំពោះព្រះអរហន្ត ព្រោះហេតុនោះ បរិតារណា របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ពួកជនដទៃ គប្បីប្រាប់នូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តក្តី ចំពោះព្រះអរហន្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**បរិតារណាកថា ចប់**

# អដ្ឋកថា

## អញ្ញាណកថាជាដើម

[ ៤៥-១៩២ ] ឥឡូវនេះ នឹងពណ៌នាអំពីរឿងទាំង ៣ គឺការមិនដឹង ការសង្ស័យ និងការច្ឆេងផុត ដោយបុគ្គលដទៃដូចតទៅ

ក្នុងរឿងទាំងនោះ ជនទាំងឡាយណាមានលទ្ធិ ដូចលទ្ធិរបស់និកាយទាំងឡាយ មាននិកាយបុព្វសេលិយៈជាដើម ក្នុងខណៈនេះថា អញ្ញាណ គឺការមិនដឹងរបស់ព្រះអរហន្ត មាន ព្រោះមិនមានញាណកើតឡើងក្នុងឈ្មោះ និងគោត្តនៃជនទាំងឡាយជាដើម មានស្ត្រី និងបុរសផងជាដើម ដោយកង្ខា គឺការសង្ស័យរបស់ព្រះអរហន្ត មាន ព្រោះការមិនមានសន្និដ្ឋាន គឺការដាក់ចិត្តក្នុងរឿងនោះឯងផង ។ ម្យ៉ាងទៀត ជនពួកដទៃ រមែងណែនាំ រមែងប្រកាស រមែងប្រាប់រឿងទាំងឡាយដល់ព្រះអរហន្តទាំងនោះ ព្រោះហេតុនោះ ទើបការណែនាំ ( បរវិតារណា ) ដល់ព្រះអរហន្តទាំងនោះ មាន ដូច្នេះ ។ ពាក្យសួរក្នុងរឿងទាំង ៣ ដើម្បីទម្លាយលទ្ធិរបស់ជនទាំងនោះ ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួល និងពាក្យបដិសេធជាពាក្យរបស់បរវាទី ។ ក្នុងពាក្យសួរ និងពាក្យវិសជ្ជនាទាំងពួង បណ្ឌិតគប្បីជ្រាបអត្ថ តាមព្រះបាលី ដែលមកហើយតាមលំដាប់ហោង ៕

**អដ្ឋកថាអញ្ញាណកថាជាដើម ចប់**

# អភិធម្មបិដក

## វចីភេទកថា

[ ១៣០ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទរបស់បុគ្គលទាំងឡាយ ចូលកាន់សមាបត្តិក្នុងទីទាំងពួង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣១ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលទាំងឡាយ ចូលកាន់សមាបត្តិសព្វកាល មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣២ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់ពួកបុគ្គលទាំងអស់ ចូលកាន់សមាបត្តិ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៣ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទក្នុងសមាបត្តិទាំងពួង មានដែរឬ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៤ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ កាយភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៥ ] កាយភេទ របស់បុគ្គលចូលកាន់សមាបត្តិ មិនមានទេឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៦ ] វាចារបស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ វចីភេទ មានដែរឬ ។ អើ ។ កាយរបស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ កាយ-ភេទ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៧ ] កាយ របស់បុគ្គលចូលកាន់សមាបត្តិ មាន កាយភេទ មិនមានទេឬ ។ អើ ។ វាចា របស់បុគ្គលចូលកាន់សមាបត្តិ មានឬ វចីភេទ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៨ ] បុគ្គល កាលដឹងថា ទុក្ខ ហើយពោលវាចាថា ទុក្ខឬ ។ អើ ។ បុគ្គល កាលដឹងថា ហេតុនាំឲ្យកើតទុក្ខ ហើយពោលវាចាថា ហេតុនាំឲ្យកើតទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៣៩ ] បុគ្គល កាលដឹងថា ទុក្ខ ហើយពោលវាចាថា ទុក្ខឬ ។ អើ ។ បុគ្គល កាលដឹងថា ធម៌ជាទីរលត់ទុក្ខ ហើយពោលវាចាថា ធម៌ជាទីរលត់ទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤០ ] បុគ្គល កាលដឹងថា ទុក្ខ ហើយពោលថា ទុក្ខឬ ។ អើ ។ បុគ្គល កាលដឹងថា មគ្គ ហើយពោលវាចាថា មគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤១ ] បុគ្គល កាលដឹងថា ហេតុនាំឲ្យកើតទុក្ខ តែមិនពោលវាចាថា ហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ បុគ្គល កាលដឹងថា ទុក្ខ តែមិនពោលវាចាថា ទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤២ ] បុគ្គល កាលដឹងថា ធម៌ជាទីរលត់ទុក្ខ តែមិនពោលវាចាថា

ធម៌ជាទីរលត់ទុក្ខឬ ។ អើ ។ បុគ្គល កាលដឹងថា ទុក្ខ តែមិនពោលវាចាថា ទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៣ ] បុគ្គល កាលដឹងថា មគ្គ តែមិនពោលវាចាថា មគ្គឬ ។ អើ ។ បុគ្គល កាលដឹងថា ទុក្ខ តែមិនពោលវាចាថា ទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៤ ] វិធីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ ចក្ខុវិញ្ញាណ មានអ្វីជាអារម្មណ៍ ។ ចក្ខុវិញ្ញាណ មានរូបជាអារម្មណ៍ ។ សោតវិញ្ញាណ មានរូបជាអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៥ ] វិធីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ សោតវិញ្ញាណ មានអ្វីជាអារម្មណ៍ ។ សោតវិញ្ញាណ មានសំឡេងជាអារម្មណ៍ ។ ចក្ខុវិញ្ញាណ មានសំឡេងជាអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៦ ] វិធីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានចក្ខុវិញ្ញាណ មានរូបជាអារម្មណ៍ សោតវិញ្ញាណ មានសំឡេងជាអារម្មណ៍ឬ ។ អើ ។ ប្រសិនណាបើ ចក្ខុវិញ្ញាណ មានរូបជាអារម្មណ៍ សោតវិញ្ញាណ មានសំឡេងជាអារម្មណ៍ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិធីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេ ។

[ ១៤៧ ] វិធីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ចក្ខុវិញ្ញាណ

មានសទ្ទៈជាអារម្មណ៍ សោតវិញ្ញាណ មានសំឡេងជាអារម្មណ៍ឬ ។ អើ ។ ការប្រជុំប្រមូលផស្សៈទាំង ២ វេទនាទាំង ២ សញ្ញាទាំង ២ ចេតនាទាំង ២ ចិត្តទាំង ២ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៨ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់បឋវីកសិណសមាបត្តិ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៤៩ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់អាបោកសិណសមាបត្តិ ។បេ។ តេជោកសិណសមាបត្តិ វាយោកសិណសមាបត្តិ នីលកសិណសមាបត្តិ បីតកសិណសមាបត្តិ លោហិតកសិណសមាបត្តិ ឱទាតកសិណសមាបត្តិ ។បេ។ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ។បេ។ នេវសញ្ញានាសញ្ញាយតនៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥០ ] វចីភេទ របស់បុគ្គលចូលកាន់បឋវីកសិណសមាបត្តិ មិនមានទេឬ ។អើ។ ប្រសិនណាបើ វចីភេទ របស់បុគ្គលចូលកាន់បឋវីកសិណសមាបត្តិ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេ ។

[ ១៥១ ] វចីភេទ របស់បុគ្គលចូលកាន់អាបោកសិណសមាបត្តិ ។បេ។ ឱទាតកសិណសមាបត្តិ ។បេ។ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ។បេ។ នេវសញ្ញានាសញ្ញាយតនៈ មិនមានទេឬ ។ អើ ។

ប្រសិនណាបើ វចីភេទ របស់បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនៈ មិន មានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វចីភេទ របស់បុគ្គលចូល កាន់សមាបត្តិ មានទេ ។

[ ១៥២ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់លោកិយសមាបត្តិ មានដែរឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៣ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់លោកិយបឋមជ្ឈាន មានដែរឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរ ឬ ។ អើ ។ វចីភេទរបស់បុគ្គលចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ចតុត្ថជ្ឈានជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៤ ] វចីភេទ របស់បុគ្គលចូលកាន់លោកិយសមាបត្តិ មិនមាន ទេឬ ។ អើ ។ ប្រសិនណាបើ វចីភេទ របស់បុគ្គលចូលកាន់លោកិយ-សមាបត្តិ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេ ។

[ ១៥៥ ] វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកិយ មិន មានទេឬ ។ អើ ។ បើវចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកិយ មិនមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វចីភេទ របស់បុគ្គលចូល កាន់សមាបត្តិ មានទេ ។

[ ១៥៦ ] វិចីភេទ របស់បុគ្គលចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈានជាលោកិយ មិនមានទេឬ ។ អើ ។ ប្រសិនបើ វិចីភេទ របស់បុគ្គលចូលកាន់ចតុត្ថជ្ឈានជាលោកិយ មិនមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេ ។

[ ១៥៧ ] វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មានដែរឬ ។ អើ ។ វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៨ ] វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មានដែរឬ ។ អើ ។ វិចីភេទ របស់បុគ្គលចូលកាន់ទុតិយជ្ឈាន តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈានជាលោកិយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៥៩ ] វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកិយ មិនមានទេឬ ។ អើ ។ វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦០ ] វិចីភេទ របស់បុគ្គលចូលកាន់ទុតិយជ្ឈាន តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈានជាលោកិយ មិនមានទេឬ ។អើ ។ វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦១ ] វិចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មានដែរឬ ។ អើ ។ វិចីភេទ របស់បុគ្គលចូលកាន់ទុតិយជ្ឈានជាលោកុត្តរ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦២ ] វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មានដែរឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈានជាលោកុត្តរ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៣ ] វចីភេទ របស់បុគ្គលចូលកាន់ទុតិយជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៤ ] វចីភេទ របស់បុគ្គលចូលកាន់តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អើ ។ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈានជាលោកុត្តរ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៥ ] បុគ្គលមិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេឬ ។ អើ ។ ក្រែងវិតក្ក វិចារ ព្រះមានព្រះភាគត្រាស់ហៅថា វចីសង្ខារឬ ( បើដូច្នោះ ) វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈានមានដែរឬ ។ អើ ។ បើវិតក្ក វិចារ ព្រះមានព្រះភាគត្រាស់ហៅថា វចីសង្ខារ វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ។

[ ១៦៦ ] វិតក្ក វិចារ ព្រះមានព្រះភាគ ត្រាស់ហៅថា វចីសង្ខារ វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ចុះវចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន ចម្រើនបឋវីកសិណ មាន ចុះវចីភេទ របស់បុគ្គលចូលកាន់

បឋមជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៧ ] វិតក្ក វិចារ ព្រះមានព្រះភាគ ត្រាស់ហៅថា វចីសង្ខារ វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ចុះវចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន ចម្រើនអាបោកសិណ ។បេ។ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ។បេ។ ឱទាតកសិណ មាន ចុះវចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៦៨ ] បុគ្គល មិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេឬ ។ អើ ។ ក្រែងការតាំងឡើងនៃវិតក្ក ព្រះមានព្រះភាគត្រាស់ហៅថា វាចា ( បើដូច្នោះ ) វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មានដែរឬ ។ អើ ។ បើការតាំងឡើងនៃវិតក្ក ព្រះមានព្រះភាគត្រាស់ហៅថា វាចា វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ។

[ ១៦៩ ] ការតាំងឡើងនៃវិតក្ក ព្រះមានព្រះភាគត្រាស់ហៅថា វាចា វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ ការតាំងឡើងនៃសញ្ញា ព្រះមានព្រះភាគត្រាស់ហៅថា វាចា សញ្ញា របស់បុគ្គលចូលកាន់

ទុតិយជ្ឈាន មាន ចុះវិតក្ក វិចារ របស់បុគ្គលចូលកាន់ទុតិយជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧០ ] ការតាំងឡើងនៃវិតក្ក ព្រះមានព្រះភាគត្រាស់ហៅថា វាចា វិតក្ក វិចារ របស់បុគ្គលចូលកាន់បឋមជ្ឈាន មាន ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ ការតាំងឡើង នៃសញ្ញា ព្រះមានព្រះភាគត្រាស់ហៅថា វាចា សញ្ញា របស់បុគ្គលចូលកាន់ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយត-នជ្ឈាន ។បេ។ អាកិញ្ចញ្ញាយតនជ្ឈាន មាន ចុះវិតក្ក វិចារ របស់បុគ្គលចូល កាន់តតិយជ្ឈានជាដើមនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧១ ] វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ ក្រែងវាចារបស់បុគ្គលចូលកាន់បឋមជ្ឈាន រលត់ហើយ ពាក្យដូច្នេះ មានក្នុង ព្រះសូត្រឬ ។ អើ ។ បើវាចារបស់បុគ្គលចូលកាន់បឋមជ្ឈាន រលត់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកមិន គួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេ ។

[ ១៧២ ] វាចា របស់បុគ្គលចូលកាន់បឋមជ្ឈាន រលត់ហើយ ពាក្យ ដូច្នេះ មានក្នុងព្រះសូត្រ ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់ បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ វិតក្ក វិចារ របស់បុគ្គលចូលកាន់ ទុតិយជ្ឈាន រលត់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ព្រោះហេតុនោះ វិតក្ក វិចារ របស់បុគ្គលចូលកាន់ទុតិយជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។

[ ១៧៣ ] វាចា របស់បុគ្គលចូលកាន់បឋមជ្ឈាន រលត់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ បីតិ របស់បុគ្គលកាន់តតិយជ្ឈាន រលត់ហើយ ។បេ។ អស្សាសបស្សាសៈ របស់បុគ្គលចូលកាន់ចតុត្ថជ្ឈាន រលត់ហើយ រូបសញ្ញា របស់បុគ្គលចូលកាន់អាកាសានញ្ចាយតនជ្ឈាន រលត់ហើយ អាកាសានញ្ចាយតនសញ្ញា របស់បុគ្គលចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន រលត់ហើយ វិញ្ញាណញ្ចាយតនសញ្ញា របស់បុគ្គលចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន រលត់ហើយ ។បេ។ អាកិញ្ចញ្ញាយតនសញ្ញា របស់បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន រលត់ហើយ សញ្ញា និងវេទនា របស់បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធសមាបត្តិ រលត់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ព្រោះហេតុនោះ សញ្ញា និងវេទនា របស់បុគ្គលចូលកាន់តតិយជ្ឈានជាដើមនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៤ ] បុគ្គលមិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា សំឡេង ជាសត្រូវដល់បឋមជ្ឈានឬ ។ អើ ។ បើព្រះមានព្រះភាគត្រាស់ថា សំឡេងជាសត្រូវដល់បឋមជ្ឈានហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ។

[ ១៧៥ ] ព្រះមានព្រះភាគត្រាស់ថា សំឡេង ជាសត្រូវដល់បឋមជ្ឈាន

ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា វិតក្ក វិចារ ជាសត្រូវដល់ទុតិយជ្ឈាន ។បេ។ ព្រះមានព្រះភាគត្រាស់ថា បីតិជាសត្រូវដល់តតិយជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អស្សាសបស្សាសៈ ជាសត្រូវដល់ចតុត្ថជ្ឈាន ព្រះមានព្រះភាគត្រាស់ថា រូបសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់អាកាសានញ្ចាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អាកាសានញ្ចាយតនសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា វិញ្ញាណញ្ចាយតន-សញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អាកិញ្ចញ្ញាយតនសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់នេវសញ្ញា-នាសញ្ញាយតនជ្ឈាន ។បេ។ ព្រះមានព្រះភាគត្រាស់ថា សញ្ញា និងវេទនា ជាសត្រូវដល់បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចុះសញ្ញា និងវេទនា របស់បុគ្គលចូលកាន់ទុតិយជ្ឈានជាដើមនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៦ ] បុគ្គលមិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ សាវកឈ្មោះអភិភូ របស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគ ទ្រង់ព្រះនាមសិខី ស្ថិតនៅក្នុងព្រហ្មលោក ហើយញុំាងពាន់នៃលោកធាតុឲ្យដឹងច្បាស់ ដោយសំឡេងថា

អ្នកទាំងឡាយ ចូរប្រុងប្រៀប ឈានទៅ ប្រកប ក្នុងពុទ្ធ-
សាសនា ចូរកម្ចាត់បង់នូវសេនានៃមច្ចុ ដូចជាដំរីកម្ចាត់បង់នូវ
ផ្ទះ ជាវិការនៃដើមបបុស បុគ្គលណា ជាអ្នកមិនប្រមាទ នៅ
ក្នុងធម៌វិន័យនេះ បុគ្គលនោះ នឹងលះនូវជាតិសំសារៈ ធ្វើនូវ
ទីបំផុតនៃសេចក្តីទុក្ខបាន ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ វចីភេទ របស់បុគ្គល ចូលកាន់សមាបត្តិ មាន ។

វចីភេទកថា ចប់

# អដ្ឋកថា

## វចីភេទកថា

[ ១៣០ ] ឥឡូវនេះ នឹងពោលអំពីការបន្លឺវាចាដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណាមានលទ្ធិ ដូចលទ្ធិរបស់និកាយទាំងឡាយ មាននិកាយបុព្វសេលិយៈជាដើម ក្នុងខណៈនេះថា កាលបុគ្គលចូលបឋមជ្ឈានក្នុងខណៈនៃសោតាបត្តិមគ្គ បុគ្គលរមែងបន្លឺវាចាថា ទុក្ខ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **សមាបន្នស្ស អត្ថិ វចីភេទោ** ដូច្នេះ ។ ពាក្យឆ្លើយទទួលដែលតាំងនៅក្នុងលទ្ធិ ជាពាក្យរបស់បរវាទី ។ ត្រូវសកវាទីសួរសំដៅយកកពទាំង ៣ ដោយបទថា **សព្វត្ថ** ទៀត បរវាទីបដិសេធ ព្រោះសំដៅយកអរូបកព ។

[ ១៣១ ] ត្រូវសួរដល់កាលដោយបទថា **សព្វទា** បរវាទីបដិសេធ ព្រោះសំដៅយកកាលនៃសមាបត្តិទាំងពួង ដទៃចាកសមាបត្តិ របស់អ្នកបានបឋមជ្ឈាន ក្នុងខណៈនៃសោតាបត្តិមគ្គ ។

[ ១៣២ ] ត្រូវសួរដោយបទថា **សព្វេសំ សមាបន្នានំ** បរវាទីបដិសេធ ព្រោះសំដៅយកអ្នកចូលលោកិយសមាបត្តិ ។

[ ១៣៣ ] ត្រូវសួរថា **សព្វសមាបត្តីសុ** បរវាទីក៏ឆ្លើយបដិសេធ ព្រោះសំដៅយកលោកុត្តរ ដែលសម្បយុត្តដោយទុតិយជ្ឈាន និងលោកិយ-សមាបត្តិទាំងពួង ។

[ ១៣៤ ] បទថា **កាយភេទោ** បានដល់ កាយវិញ្ញត្តិ ដែលប្រព្រឹត្ត

ទៅដោយអំណាចនៃឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ។ សកវាទីនោះរមែងសួរពាក្យនេះ ដើម្បីចោទសួរថា ចិត្តពួកណា រមែងញុំាងវចីវិញ្ញត្តិឲ្យកើតឡើង ចិត្តទាំងនោះឯង រមែងញុំាងកាយវិញ្ញត្តិឲ្យកើតឡើងដូចគ្នា កាលបើភាពយ៉ាងនោះមាន ព្រោះហេតុអ្វី សូម្បីការកម្រើកកាយទើបមិនមាន ។ បរវាទីឆ្លើយបដិសេធផង ឆ្លើយទទួលផង ដោយអំណាចនៃលទ្ធិ ។

[ ១៣៨ ] ឥឡូវនេះ លោកពោលបញ្ហាទាំងឡាយ មានបទថា **ទុក្ខន្តិ ជានន្តោ** ជាដើម ដើម្បីចោទសួរថា បើបុគ្គលនោះ រមែងពោលវាចា ក្នុងខណៈនៃមគ្គថា ទុក្ខ ដូច្នេះសោត បុគ្គលនោះ ក៏គប្បីពោលនូវពាក្យថា សមុទយៈជាដើម ឬបើបុគ្គលនោះមិនពោលពាក្យថា ទុក្ខនោះសោត បុគ្គលនោះ ក៏មិនគប្បីពោលពាក្យក្រៅអំពីនេះ ។ ឯបរវាទីឆ្លើយទទួលផង ឆ្លើយបដិសេធផង ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពិតហើយ លទ្ធិនៃបុគ្គលនោះថា បុគ្គលចូលលោកុត្តរបឋមជ្ឈានហើយ រមែងឃើញច្បាស់នូវទុក្ខថាជាទុក្ខ ដូច្នេះ ។

[ ១៤៥ ] បទថា **ញាណំ** បានដល់ សច្ចញ្ញាណទាំង ៤ ដែលជាលោកុត្តរ ។ បទថា **សោតំ** លោកបំណងយកសោតវិញ្ញាណ ដែលជាធម្មជាតស្តាប់សំឡេង ។

[ ១៤៧ ] បទថា **ទិដ្ឋំ ជស្សាធំ** បានដល់ នៃសោតសម្ផស្ស និងមនោសម្ផស្ស ។

[ ១៥០ ] បទថា **នោ វត វេ វត្តព្វេ** អធិប្បាយថា បើការបន្ទឹវាចា មិនមានដល់អ្នកចូលឈានណាមួយ ដោយមិនប្លែកគ្នាសោត ក៏ត្រូវមិនពោលថា ការបន្ទឹវាចារបស់បុគ្គលចូលឈានណាមួយ មានដោយមិនប្លែកគ្នា ។ ពាក្យដ៏សេសក្នុងទីនេះ ព្រមទាំងការអះអាងដោយព្រះសូត្រ មានអត្ថងាយយល់ហើយ ។

[ ១៧៦ ] ម្យ៉ាងទៀត ព្រះសូត្រដែលបរវាទីនាំមកក្នុងទីបំផុតនៃបញ្ហាថា ម្នាលអានន្ទ សាវកឈ្មោះអភិភូ របស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគដូច្នេះជាដើម ក្នុងព្រះសូត្រនោះ កាលបន្ទឹវាចានោះ រមែងកើតឡើងដោយសមាបត្តិចិត្តណា សូម្បីការកម្រើកកាយ ក៏រមែងកើតឡើងដោយសមាបត្តិ-ចិត្តនោះឯង តែចិត្តដែលធ្វើឲ្យវចីវិញ្ញត្តិ និងកាយវិញ្ញត្តិកើតនោះ មិនមែនបឋមជ្ឈានចិត្តដែលជាលោកុត្តរ ព្រោះហេតុនោះ ទើបសូត្រដែលបរវាទីនាំមកនោះ មិនមែនជាគោលអះអាង ដូច្នេះ ។៚

**អដ្ឋកថាវចីភេទកថា ចប់**

# អភិធម្មបិដក

## ទុក្ខាហារកថា

[ ១៧៧ ] ការនាំមកនូវញាណ ( ការដឹង ) ក្នុងទុក្ខ ជាអង្គនៃមគ្គ ដែលរាប់បញ្ចូលក្នុងមគ្គឬ ។ អើ ។ ពួកជនណាមួយ ពោលវាចាថា ទុក្ខ ជនទាំងអស់នោះ តែងចម្រើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៧៨ ] ពួកជនណាមួយ ពោលវាចាថា ទុក្ខ ជនទាំងអស់នោះ តែងចម្រើននូវមគ្គឬ ។ អើ ។ ពួកពាលបុថុជ្ជន ពោលវាចាថា ទុក្ខ ពួកពាល-បុថុជ្ជន តែងចម្រើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជនអ្នកសម្លាប់មាតា ។បេ។ ជនអ្នកសម្លាប់បិតា ជនអ្នកសម្លាប់ព្រះអរហន្ត ជនអ្នកធ្វើព្រះលោហិតឲ្យពុះពោរឡើង ។បេ។ ជនអ្នកបំបែកសង្ឃ ពោលវាចាថា ទុក្ខ ជនអ្នកបំបែកសង្ឃ តែងចម្រើនមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ទុក្ខាហារកថា ចប់

# អដ្ឋកថា

## ទុក្ខាហារកថា

[ ១៧៧ ] ឥឡូវនេះ នឹងពណ៌នាអំពីការពោលថា ទុក្ខ ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់ពួកនិកាយបុព្វសេលិយៈជាដើម ក្នុងខណៈនេះថា កាលបុគ្គលណា ពោលវាចាថា ទុក្ខ ទុក្ខ ដូច្នេះ បុគ្គលនោះ ឈ្មោះថា នាំមកនូវញាណក្នុងទុក្ខ វាចានោះ លោកហៅថា **ទុក្ខាហារ** ទុក្ខាហារនោះឯង ជាអង្គនៃមគ្គ និងរាប់បញ្ចូលក្នុងមគ្គ ដូច្នេះ ។ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា **ទុក្ខាហារោ** ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាជំបូងថា **យេ កេចិ** បរវាទីសំដៅយកបុគ្គលដែលមិនឃើញច្បាស់ ទើបឆ្លើយបដិសេធ ។

[ ១៧៨ ] ក្នុងបញ្ហាទី ២ បរវាទីឆ្លើយទទួល សំដៅយកបុគ្គលឃើញច្បាស់ ។ ការឃើញច្បាស់ ឬការមិនឃើញច្បាស់នោះ ត្រឹមតែជាលទ្ធិរបស់បរវាទីប៉ុណ្ណោះ ព្រោះហេតុនោះ ដើម្បីទម្លាយវាទៈរបស់បរវាទីនោះថា **សព្វេ តេ** ទើបសកវាទីសួរថា **ពាលបុថុជ្ជនា** ជាដើម ។ សេចក្តីនោះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាទុក្ខាហារកថា ចប់**

# អភិធម្មបិដក

## ចិត្តដ្ឋិតិកថា

[ ១៧៩ ] ចិត្តមួយ ស្ថិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ កន្លះថ្ងៃ ជាឧប្បាទក្ខណៈ កន្លះថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨០ ] ចិត្តមួយ ស្ថិតនៅអស់ ២ ថ្ងៃឬ ។ អើ ។ ១ ថ្ងៃ ជាឧប្បាទក្ខណៈ ១ ថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨១ ] ចិត្តមួយ ស្ថិតនៅអស់ ៤ ថ្ងៃ ។បេ។ ស្ថិតនៅអស់ ៨ ថ្ងៃ ស្ថិតនៅអស់ ១០ ថ្ងៃ ស្ថិតនៅអស់ ២០ ថ្ងៃ ស្ថិតនៅអស់ ១ ខែ ស្ថិតនៅអស់ ២ ខែ ស្ថិតនៅអស់ ៤ ខែ ស្ថិតនៅអស់ ៨ ខែ ស្ថិតនៅអស់ ១០ ខែ ស្ថិតនៅអស់ ១ ឆ្នាំ ស្ថិតនៅអស់ ២ ឆ្នាំ ស្ថិតនៅអស់ ៤ ឆ្នាំ ស្ថិតនៅអស់ ៨ ឆ្នាំ ស្ថិតនៅអស់ ១០ ឆ្នាំ ស្ថិតនៅអស់ ២០ ឆ្នាំ ស្ថិតនៅអស់ ៣០ ឆ្នាំ ស្ថិតនៅអស់ ៤០ ឆ្នាំ ស្ថិតនៅអស់ ៥០ ឆ្នាំ ស្ថិតនៅអស់ ១០០ ស្ថិតនៅអស់ ២០០ ឆ្នាំ ស្ថិតនៅអស់ ៤០០ ឆ្នាំ ស្ថិតនៅអស់ ៥០០ ឆ្នាំ ស្ថិតនៅអស់ ១០០០ ឆ្នាំ ស្ថិតនៅអស់ ២០០០ ឆ្នាំ ស្ថិតនៅអស់ ៤០០០ ឆ្នាំ ស្ថិតនៅអស់ ៨០០០ ឆ្នាំ ស្ថិតនៅអស់ ១៦០០០ ឆ្នាំ ស្ថិតនៅអស់ ១ កប្ប ស្ថិតនៅអស់ ២ កប្ប ស្ថិតនៅអស់ ៤ កប្ប ស្ថិតនៅអស់ ៨ កប្ប ស្ថិតនៅអស់ ១៦ កប្ប ស្ថិតនៅអស់ ៣២ កប្ប ស្ថិតនៅអស់ ៦៤ កប្ប ស្ថិតនៅអស់ ៥០០ កប្ប ស្ថិតនៅអស់ ១០០០ កប្ប ស្ថិតនៅអស់ ២០០០ កប្ប ស្ថិតនៅអស់ ៤០០០ កប្ប ស្ថិតនៅអស់

៨០០០ កប្ប ស្ថិតនៅអស់ ១៦ ពាន់កប្ប ស្ថិតនៅអស់ ២០ ពាន់កប្ប ស្ថិតនៅអស់ ៤០ ពាន់កប្ប ស្ថិតនៅអស់ ៦០ ពាន់កប្ប ។បេ។ ស្ថិតនៅអស់ ៨៤ ពាន់កប្បឬ ។ អើ ។ ៤២ ពាន់កប្ប ជាឧប្បាទក្ខណៈ ៤២ ពាន់កប្ប ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨២ ] ចិត្តមួយ ស្ថិតនៅអស់ ១ ថ្ងៃ ។ អើ ។ ពួកធម៌ដទៃ ដែលកើតឡើងអស់ ១ ថ្ងៃ ឬច្រើនថ្ងៃ ហើយរលត់ទៅវិញ មានដែរឬ ។ អើ ។ ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។ មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៣ ] ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពិចារណារកមិនឃើញនូវធម៌ដទៃ សូម្បីតែមួយ ដែលប្រព្រឹត្តទៅរហ័សយ៉ាងនេះ ដូចជាចិត្តនេះទេ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ ប្រព្រឹត្តទៅរហ័ស មិនងាយបុគ្គលនឹងធ្វើសេចក្តីប្រៀបបានឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តទេ ។

[ ១៨៤ ] ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វស្វា ត្រាច់ទៅក្នុងព្រៃតូច ព្រៃធំ ចាប់កាន់មែកឈើ លែងមែកឈើនោះ ហើយចាប់មែកដទៃ លែងមែកនោះហើយ ចាប់មែកដទៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ

ធម្មជាតណា ហៅថា ចិត្ត ដូច្នេះក្តី ហៅថា មនោ ដូច្នេះក្តី ហៅថា វិញ្ញាណ ដូច្នេះក្តី ធម្មជាតនោះ ជាធម្មជាតដទៃមែនពិត កើតឡើងក្នុងវេលាយប់ផង ក្នុងវេលាថ្ងៃផង ធម្មជាតដទៃរលត់ទៅវិញផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័សដោយចិត្តទេ ។

[ ១៨៥ ] ចិត្តមួយ ស្ថិតនៅអស់មួយថ្ងៃឬ ។ អើ ។ ចក្ខុវិញ្ញាណ ស្ថិតនៅអស់១ថ្ងៃឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតវិញ្ញាណ ។បេ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ អកុសលចិត្ត ចិត្តដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានៈ ប្រកបដោយទិដ្ឋិ ប្រកបដោយវិចិកិច្ឆា ប្រកបដោយថីនៈ ប្រកបដោយឧទ្ធច្ចៈ ប្រកបដោយអហិរិកៈ ប្រកបដោយអនោត្តប្បៈ ស្ថិតនៅអស់ ១ ថ្ងៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៦ ] ចិត្តមួយ ស្ថិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ បុគ្គលឃើញរូបដោយភ្នែក ដោយចិត្តណា ក៏ឮសំឡេងដោយត្រចៀក ដោយចិត្តនោះដែរ ។បេ។ ធុំក្លិនដោយច្រមុះ លិទ្ធភក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ។បេ។ បុគ្គលដឹងច្បាស់ធម្មា-រម្មណ៍ដោយចិត្ត ដោយចិត្តណា ក៏ឃើញរូបដោយភ្នែក ដោយចិត្តនោះដែរ ។បេ។ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ( ដោយចិត្តនោះ ) ដែរឬ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៧ ] ចិត្តមួយ ស្ថិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ បុគ្គលឈានទៅមុខដោយចិត្តណា ឈានបែរមកក្រោយ ដោយចិត្តនោះដែរ ឈានបែរមកក្រោយដោយចិត្តណា ឈានទៅមុខ ដោយចិត្តនោះដែរ មើលទៅមុខដោយចិត្តណា មើលចំហៀង ដោយចិត្តនោះដែរ មើលចំហៀងដោយចិត្តណា មើលទៅមុខ ដោយចិត្តនោះដែរ បត់អវយវៈចូលដោយចិត្តណា លាអវយវៈចេញ ដោយចិត្តនោះដែរ លាអវយវៈចេញដោយចិត្តណា បត់អវយវៈចូលដោយចិត្តនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៨ ] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ស្ថិតនៅជាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយរបស់មនុស្សទាំងឡាយ ស្ថិតនៅជាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៨៩ ] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើត ក្នុងជាន់អាកានញ្ញាយតនៈ ស្ថិតនៅជាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយរបស់ពួកទេវតា ដែលស្ថិតនៅក្នុងឋានចាតុម្មហារាជិកា ។បេ។ របស់ពួកទេវតា ដែលស្ថិតនៅក្នុងឋានតាវត្តិង្ស ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានយាមៈ ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានតុសិត ... ពួកទេវតា ដែលស្ថិតនៅ ក្នុងឋាននិម្មានរតី ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានបរនិម្មិតវសវត្តី ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានព្រហ្មបារិសជ្ជា ... ពួកទេវតា ដែលស្ថិតនៅ

ក្នុងឋានព្រហ្មបុរោហិតា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានមហាព្រហ្ម ... ពួកទេវតាដែលស្ថិតនៅក្នុងឋានបរិត្តាភា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានអប្បមាណាភា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានអាភស្សរៈ ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានបរិត្តសុភា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានអប្បមាណសុភា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានសុភកណ្ហា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានវេហប្ផលា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានអវិហា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានអតប្បា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានសុទស្សា ... ពួកទេវតា ដែលស្ថិតនៅក្នុងឋានសុទស្សី ។បេ។ ពួកទេវតា ដែលស្ថិតនៅក្នុងឋានអកនិដ្ឋៈ ស្ថិតនៅជាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩០ ] ២០ ពាន់កប្ប ជាប្រមាណនៃអាយុរបស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ( នោះ ) ស្ថិតនៅអស់ ២០ ពាន់កប្ប ដែរឬ ។ អើ ។ មួយរយឆ្នាំ ជាប្រមាណនៃអាយុរបស់មនុស្សទាំងឡាយ ចិត្តមួយ របស់ពួកមនុស្ស ស្ថិតនៅអស់មួយរយឆ្នាំ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩១ ] ២០ ពាន់កប្ប ជាប្រមាណនៃអាយុរបស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ស្ថិតនៅអស់ ២០ ពាន់កប្ប ដែរ

ឬ ។ អើ ។ ប្រាំរយឆ្នាំ ជាប្រមាណនៃអាយុរបស់ពួកទេវតា ដែលស្ថិតនៅក្នុងជាន់ចាតុម្មហារាជិកា ចិត្តមួយ របស់ពួកទេវតា ក្នុងឋានចាតុម្មហារាជិកា ( នោះ ) ស្ថិតនៅអស់ប្រាំរយឆ្នាំ ដែរឬ ។បេ។ ស្ថិតនៅអស់ ១ ពាន់ឆ្នាំ ស្ថិតនៅអស់ ២ ពាន់ឆ្នាំ ស្ថិតនៅអស់ ៤ ពាន់ឆ្នាំ ស្ថិតនៅអស់ ៨ ពាន់ឆ្នាំ ស្ថិតនៅអស់ ១៦ ពាន់ឆ្នាំ ស្ថិតនៅអស់ភាគជាគម្រប់បីនៃកប្ប ស្ថិតនៅអស់កន្លះកប្ប ស្ថិតនៅអស់ ១ កប្ប ស្ថិតនៅអស់ ២ កប្ប ស្ថិតនៅអស់ ៤ កប្ប ស្ថិតនៅអស់ ៨ កប្ប ស្ថិតនៅអស់ ១៦ កប្ប ស្ថិតនៅអស់ ៣២ កប្ប ស្ថិតនៅអស់ ៦៤ កប្ប ស្ថិតនៅអស់ប្រាំរយកប្ប ស្ថិតនៅអស់ ១ ពាន់កប្ប ស្ថិតនៅអស់ ២ ពាន់កប្ប ស្ថិតនៅអស់ ៤ ពាន់កប្ប ស្ថិតនៅអស់ ៨ ពាន់កប្ប ។បេ។ ១៦ ពាន់កប្ប ជាប្រមាណនៃអាយុរបស់ទេវតាក្នុងឋានអកនិដ្ឋៈ ចិត្តមួយ របស់ពួកទេវតា ដែលស្ថិតនៅក្នុងឋានអកនិដ្ឋៈ ស្ថិតនៅអស់ ១៦ ពាន់កប្ប ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩២ ] ចិត្តរបស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ កើតឡើងមួយស្របក់ៗ រលត់ទៅមួយស្របក់ៗ ឬ ។ អើ ។

ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ច្យុតមួយស្របក់ៗ កើតឡើងមួយស្របក់ៗ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៣ ] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកា-សានញ្ចាយតនៈ ស្ថិតនៅដរាបដល់អស់អាយុឬ ។ អើ ។ ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ កើតឡើងដោយចិត្តណា ច្យុតទៅវិញ ដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**ចិត្តដ្ឋិតិកថា ចប់**

# អដ្ឋកថា

## ចិត្តដ្ឋិតិកថា

[ ១៧៩ ] ឥឡូវនេះ នឹងពោលអំពីការតាំងនៅនៃចិត្តដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ដែលមានប្រភេទតាមដែលពោលហើយខាងដើម ក្នុងខណៈនេះថា ចិត្ត ១ ដួងប៉ុណ្ណោះ រមែងតាំងនៅអស់កាលយូរ ព្រោះឃើញចិត្តនៃសមាបត្តិ និងភវង្គចិត្ត ដែលប្រព្រឹត្តទៅជាប់តគ្នាដោយលំដាប់ ពាក្យសួរដើម្បីជម្រះលទ្ធិនោះថា **ឯកំ ចិត្តំ ទិវសំ តិដ្ឋតិ** ជាដើម ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

ក្នុងបញ្ហាថា **ឧបន្នទិវសោ ឧប្បាទក្ខណោ** លោកធ្វើពាក្យសួរដោយអំណាចនៃការកើត និងការរលត់ដោយទេសនាន័យ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា សង្ខារទាំងឡាយ មិនទៀងទេហ្ន៎ មានការកើតឡើង និងការសូន្យទៅវិញជាធម្មតា ដូច្នេះជាដើម ដោយមិនកាន់យកខណៈតាំងនៅនៃចិត្ត ។

[ ១៨៣ ] បរវាទីនោះ ត្រូវសកវាទីសួរថា **តេ ធម្មា ចិត្តេន លហុ-បរិវត្តា** កាលមិនឃើញធម៌ទាំងឡាយ ដែលកើតរលត់រហ័សជាងចិត្ត ទើបឆ្លើយបដិសេធ ។

[ ១៨៤ ] ត្រូវសួរលើកទី ២ លោកប្រាប្ធាការតាំងនៅអស់កាលយូរនៃចិត្តណា ក៏ឆ្លើយទទួល ដោយសំដៅយកចិត្តនោះ ។

[ ១៨៨ ] ក្នុងបញ្ហាទាំងឡាយថា **យាវតាយុកំ តិដ្ឋតិ** សេចក្តីថា បរវាទីឆ្លើយបដិសេធដោយវៀរអរូប និងឆ្លើយទទួល បុគ្គលដែលកើតក្នុងអរូប ដោយអំណាចនៃព្រះបាលីថា ពួកទេវតាណា ស្ថិតនៅអស់ ៨៤០០០ កប្ប ដូច្នេះជាដើម ។

[ ១៩២ ] ក្នុងបញ្ហារបស់បរវាទីថា **មុហុត្តំ មុហុត្តំ ឧប្បជ្ជតិ** សកវាទីឆ្លើយទទួល ព្រោះខ្លាចខុសអំពីព្រះសូត្រថា សង្ខារទាំងឡាយ មិនទៀងទេហ្ន៎ មានការកើតឡើង និងការសូន្យទៅវិញជាធម្មតា ដូច្នេះជាដើម តែបរវាទីនោះ ពេញចិត្តការតាំងនៅនៃចិត្ត ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថាចិត្តដ្ឋិតិកថា ចប់

# អភិធម្មបិដក

## កុក្កុឡកថា

[ ១៩៤ ] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ វេទនាជាសុខ គឺសុខប្រព្រឹត្តទៅក្នុងកាយ សុខប្រព្រឹត្តទៅក្នុងចិត្ត សុខជាទិព្វ សុខជារបស់មនុស្ស សុខដោយលាភ សុខដោយសក្ការៈ សុខដោយយាន សុខដោយដំណេក សុខដោយភាពនៃខ្លួនជាធំ សុខដោយភាពនៃខ្លួនជាអធិបតី សុខរបស់គ្រហស្ថ សុខរបស់សមណៈ សុខប្រកបដោយអាសវៈ សុខមិនមានអាសវៈ សុខប្រកបដោយឧបធិក្កិលេស សុខមិនមានឧបធិក្កិលេស សុខប្រកបដោយអាមិសៈ សុខមិនមានអាមិសៈ សុខប្រកបដោយបីតិ សុខមិនមានបីតិ សុខដោយឈាន សុខដោយវិមុត្តិ សុខក្នុងកាម សុខដោយការចេញចាកកាម សុខដោយការស្ងប់ស្ងាត់ សុខដោយការរម្ងាប់ សុខដោយការត្រាស់ដឹង ក្រែងមានដែរឬ ។ អើ ។ បើវេទនាជាសុខ ។បេ។ សុខកើតអំពីការត្រាស់ដឹង មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[ ១៩៥ ] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ សង្ខារទាំងពួង មានវេទនាជាទុក្ខ គឺទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីសង្រេងសង្រៃ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ១៩៦ ] បុគ្គលមិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើ

ឲ្យមិនមានព្រំដែនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ គឺអ្វីជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ រូបជារបស់ក្តៅ ចក្ខុ-វិញ្ញាណជារបស់ក្តៅ ចក្ខុសម្ផស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខ មិនមែនជាសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ ជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើង គឺរាគៈ ក្តៅដោយភ្លើង គឺទោសៈ ក្តៅដោយភ្លើង គឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស តថាគតពោលថា ក្តៅ ត្រចៀក ជារបស់ក្តៅ សំឡេង ជារបស់ក្តៅ ។បេ។ ច្រមុះ ជារបស់ក្តៅ ក្លិនជារបស់ក្តៅ ។បេ។ អណ្តាត ជារបស់ក្តៅ រស ជារបស់ក្តៅ ។បេ។ កាយ ជារបស់ក្តៅ ផោដ្ឋព្វៈ ជារបស់ក្តៅ ។បេ។ ចិត្ត ជារបស់ក្តៅ ធម្មារម្មណ៍ ជារបស់ក្តៅ មនោវិញ្ញាណ ជារបស់ក្តៅ មនោសម្ផស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខ មិនមែនជាសុខក្តី កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ ជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើង គឺរាគៈ ក្តៅដោយភ្លើង គឺទោសៈ ក្តៅដោយភ្លើង គឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស តថាគតពោលថា ក្តៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផ្ទះក្តៅធ្វើមិនឲ្យមានព្រំដែន ។

[ ១៩៧ ] សង្ខារទាំងពួងដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាតម្រេក ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ១ ។បេ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ ។បេ។ រសដែលគប្បីដឹងដោយអណ្តាត ១ ។បេ។ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាតម្រេក ១ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[ ១៩៨ ] បុគ្គលមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពេញហៅមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយ ពេញជាបានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ធ្លុះហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ នរកឈ្មោះឆផស្សាយតនិកៈ តថាគត បានឃើញហើយ បណ្តាធម៌ទាំងនោះ បុគ្គលឃើញរូបណាមួយ ដោយភ្នែក តែងឃើញរូបមិនជាទីប្រាថ្នាតែម្យ៉ាង មិនឃើញរូបជាទីប្រាថ្នា តែងឃើញរូបមិនជាទីត្រេកអរ មិនឃើញរូបជាទីត្រេកអរ តែង

ឃើញរូបមិនជាទីគាប់ចិត្ត មិនឃើញរូបជាទីគាប់ចិត្ត បុគ្គល ឮសំឡេងណាមួយដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភ្លក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបមិនជាទីប្រាថ្នា មិនដឹងច្បាស់នូវរូបជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបមិនជាទីត្រេកអរ មិនដឹងច្បាស់នូវរូបជាទីត្រេកអរ តែងដឹងច្បាស់នូវរូបមិនជាទីពេញចិត្ត មិនដឹងច្បាស់នូវរូបជាទីពេញចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែន ។

[ ១៩៩ ] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពេញហៅមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយ ពេញជាបានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ធ្លុះហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ ស្ថានសួគ៌ឈ្មោះឆផស្សាយតនិកៈ តថាគតបានឃើញហើយ បណ្តាធម៌ទាំងនោះ បុគ្គល ឃើញរូបណាមួយដោយភ្នែក តែងឃើញរូបជាទីប្រាថ្នា មិនឃើញរូបមិនជាទីប្រាថ្នា តែងឃើញរូបជាទីត្រេកអរ មិនឃើញរូបមិនជាទីត្រេកអរ តែងឃើញរូបជាទីពេញចិត្ត មិនឃើញរូបមិនជាទីពេញចិត្ត ឮសំឡេងណាមួយដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភ្លក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបជាទីប្រាថ្នា

មិនដឹងច្បាស់នូវរូបមិនជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបជាទីត្រេកអរ មិនដឹងច្បាស់នូវរូបមិនជាទីត្រេកអរ តែងដឹងច្បាស់នូវរូបជាទីពេញចិត្ត មិនដឹងច្បាស់នូវរូបមិនជាទីពេញចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[ ២០០ ] បុគ្គល មិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា របស់ណាមិនទៀង របស់នោះ ជាទុក្ខ ចុះសង្ខារទាំងពួង មិនទៀងឬ ។ អើ ។ បើព្រះមានព្រះភាគត្រាស់ថា របស់ណា មិនទៀង របស់នោះ ជាទុក្ខ សង្ខារទាំងពួង មិនទៀង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[ ២០១ ] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ទានមានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល ។បេ។ ឧបោសថ ។បេ។ ភាវនា ។បេ។ ព្រហ្មចរិយៈ មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជា

កម្រៃ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។ ក្រែងសីល ។បេ។ ឧបោសថ ។បេ។ ភាវនា ។បេ។ ព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខឬ ។ អើ ។ បើព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[ ២០២ ] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

វិវេករបស់បុគ្គល អ្នកត្រេកអរ ជាអ្នកមានធម៌បានស្តាប់ហើយ
ឃើញ ( ធម៌ ) រមែងនាំនូវសេចក្តីសុខ ការមិនបៀតបៀន
គឺការសង្រួមក្នុងសត្វទាំងឡាយ នាំមកនូវសេចក្តីសុខ ក្នុង

លោក ការៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខ ក្នុងលោក ការបន្ទោបង់នូវអស្មិមានះ ណា នេះឯង ជាសេចក្តីសុខដ៏ក្រៃលែង សេចក្តីសុខនោះ បុគ្គល បានដល់ហើយ ដោយងាយ សេចក្តីសុខនោះឯង មានទីបំផុតដ៏ក្រៃលែង វិជ្ជា ៣ ដែលគេបានដល់ហើយនេះ ជាសេចក្តីសុខដ៏ក្រៃលែង ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោល ថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

កុក្កុឡកថា ចប់

# អដ្ឋកថា

## កុក្កុឡកថា

[ ១៩៤-២០២ ] ឥឡូវនេះ នឹងពណ៌នាអំពីផេះក្តៅដូចតទៅ

ក្នុងរឿងនោះ ជនពួកណា មានលទ្ធិ ដូចលទ្ធិរបស់និកាយគោកុលិកៈទាំងឡាយ ក្នុងខណៈនេះថា សង្ខារទាំងពួង ដូចផេះក្តៅ គឺដូចគ្នានឹងឆារិក-នរក ដែលលាយឡំដោយរងើកភ្លើង ដែលប្រាសចាកអណ្តាតដោយពិតប៉ុណ្ណោះ ព្រោះមិនពិចារណាកាន់យកព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ ជារបស់ក្តៅ និងព្រះតម្រាស់ថា សង្ខារទាំងពួង នាំមកនូវសេចក្តីទុក្ខ ដូច្នេះជាដើម ។ ពាក្យសួរ ជាពាក្យរបស់សកវាទី ដើម្បីញ៉ាំញីលទ្ធិនោះ របស់ជនទាំងនោះ ដោយការបង្អុលបង្ហាញដល់សេចក្តីសុខ មានប្រការផ្សេងៗ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហានោះ បទថា **អនោធិកត្វា** បានដល់ មិនធ្វើការបែងចែកឲ្យជាព្រំដែនចំណែកមួយ អធិប្បាយថា មិនធ្វើវត្ថុទាំងពួងនោះឯងឲ្យប្លែកគ្នា ។ ពាក្យដ៏សេសក្នុងទីទាំងពួង គប្បីជ្រាបដោយន័យដែលសម្តែងហើយក្នុងព្រះបាលី ព្រមទាំងការអះអាង ដោយព្រះសូត្រនោះឯង ៕

**អដ្ឋកថាកុក្កុឡកថា ចប់**

# អភិធម្មបិដក

## អនុបុព្វាភិសមយកថា

[ ២០៣ ] ការត្រាស់ដឹងជាលំដាប់ មានដែរឬ ។ អើ ។ បុគ្គលចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៤ ] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គលចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៥ ] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គលចម្រើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៦ ] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គល ចម្រើនអរហត្តមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលចម្រើនអរហត្តមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៧ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល

ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងពួកកិលេស ដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ ( មានចំណែកជា ៤ ) ។ សោតាបន្នបុគ្គល ជាចតុក្កាគ មិនមែនសោតាបន្នបុគ្គល ជាចតុក្កាគ បុគ្គល ដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ប្រកបដោយសីលជាទីត្រេកអរ របស់អរិយៈទាំងឡាយ ជាចតុក្កាគ មិនប្រកបដោយសីល ជាទីត្រេកអរ របស់ព្រះអរិយៈទាំងឡាយ ជាចតុក្កាគ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយការឃើញសមុទយសច្ច ។បេ។ ដោយការឃើញនិរោធសច្ច ។បេ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងពួកកិលេស ដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ សោតាបន្នបុគ្គល ជាចតុក្កាគ មិនមែនសោតាបន្នបុគ្គល ជាចតុក្កាគ បុគ្គល ដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាម-កាយ ជាចតុក្កាគ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ប្រកបដោយសីលជាទីត្រេកអរ របស់អរិយៈទាំងឡាយ ជា

ចតុព្ពាគ មិនប្រកបដោយសីល ជាទីត្រេកអរ របស់អរិយៈទាំងឡាយ ជាចតុព្ពាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៨ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ពាគ ។ សកទាគាមិបុគ្គល ជាចតុព្ពាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ពាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយការឃើញសមុទយសច្ច ។បេ។ ដោយការឃើញនិរោធសច្ច ។បេ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គលលះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ពាគ ។ សកទាគាមិបុគ្គល ជាចតុព្ពាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ពាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២០៩ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគស្រាលស្តើង ព្យាបាទស្រាលស្តើង និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ពាគ ។

អនាគាមិបុគ្គល ជាចតុព្ពាគ មិនមែនអនាគាមិបុគ្គល ជាចតុព្ពាគ បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ អន្តរាបរិនិព្វាយិបុគ្គល ។បេ។ ឧបហច្ចបរិនិព្វាយិបុគ្គល ។បេ។ អសង្ខារបរិនិព្វាយិបុគ្គល ។បេ។ សសង្ខារបរិនិព្វាយិបុគ្គល ។បេ។ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ជាចតុព្ពាគ មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុព្ពាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយការឃើញសមុទយៈ ។បេ។ ដោយការឃើញនិរោធសច្ច ។បេ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគស្រាលស្តើង ព្យាបាទស្រាលស្តើង និងពួកកិលេស ដែលដូចគ្នានឹងពួកធម៌ទាំងនោះ ជាចតុព្ពាគ ។ អនាគាមិបុគ្គល ជាចតុព្ពាគ មិនមែនអនាគាមិបុគ្គល ជាចតុព្ពាគ បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ពាគ អន្តរាបរិនិព្វាយិបុគ្គល ។បេ។ ឧបហច្ចបរិនិព្វាយិបុគ្គល ។បេ។ អសង្ខារបរិនិព្វាយិបុគ្គល ។បេ។ សសង្ខារបរិនិព្វាយិបុគ្គល ។បេ។ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ជាចតុព្ពាគ មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុព្ពាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១០ ] បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ

អវិជ្ជា និងពួកកិលេស ដែលដូចគ្នានឹងពួកធម៌ទាំងនោះ ជាចតុក្កាគ ។ ព្រះអរហន្ត ជាចតុក្កាគ មិនមែនព្រះអរហន្ត ជាចតុក្កាគ បុគ្គល ដល់នូវអរហត្តបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ជារបស់ខ្លួនដល់ហើយ ដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានទ្វារដើងគុល គឺអវិជ្ជាលើកឡើងហើយ មានគូ ( ស្នាមភ្លោះ ) ទម្លាយហើយ មានសសរខឿនដកចោលហើយ មិនមានសន្ទះទ្វារ ចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកធម៌ជាគ្រឿងប្រកប មានជម្នះ ឈ្នះដោយប្រពៃ ទុក្ខសច្ច បុគ្គលនោះ ក៏បានកំណត់ដឹងហើយ សមុទយសច្ច ( ហេតុដែលនាំឲ្យកើតទុក្ខ ) ក៏បានលះបង់ហើយ និរោធសច្ច ( ធម៌ជាទីរលត់ទុក្ខ ) បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែលគួរចម្រើន ក៏បានចម្រើនហើយ ។បេ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយការឃើញ

សមុទយសច្ច ។បេ។ ដោយការឃើញនិរោធសច្ច ។បេ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេស ដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ ។ អរហន្ត ជាចតុក្កាគ មិនមែនអរហន្ត ជាចតុក្កាគច បុគ្គល ដល់នូវអរហត្ត បានចំពោះត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ ដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានទ្វារជើងគុល គឺអវិជ្ជាលើកឡើងហើយ មានគូទម្លាយហើយ មានសសរខឿនដកចោលហើយ មិនមានសន្ទះទ្វារ ចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកធម៌ជាគ្រឿងប្រកប មានជម្នះ ឈ្នះហើយដោយប្រពៃ ទុក្ខសច្ច បុគ្គលនោះ បានកំណត់ដឹងហើយ សមុទយសច្ច ក៏បានលះបង់ហើយ និរោធសច្ច ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែលគួរចម្រើន ក៏បានចម្រើនហើយ ។បេ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ មិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជា

ចតុត្ថាគមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២១១ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាលបើទុក្ខ ដែលបុគ្គលបានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ឃើញសមុទយៈ ។បេ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាលបើនិរោធ បុគ្គលនោះ បានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២១២ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើមគ្គ បុគ្គលនោះ បានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ ។ អើ ។ បុគ្គលឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើទុក្ខ បុគ្គល បានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើមគ្គ បុគ្គលនោះ បានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ ។ អើ ។ បុគ្គល ឃើញសមុទយៈ ។បេ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើនិរោធ បុគ្គលនោះ បានឃើញហើយ គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានឬ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៣ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល

ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលទេឬ ។ អើ ។ បុគ្គល ឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើមគ្គ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ឃើញសមុទយៈ ។បេ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលទេឬ ។ អើ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើមគ្គ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៤ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញទុក្ខ ជាការឥតប្រយោជន៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ឃើញសមុទយៈ ។បេ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះ បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកស្ថិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញនិរោធ ជាការឥតប្រយោជន៍ឬ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៥ ] កាលបើទុក្ខ បុគ្គល បានឃើញហើយ សច្ចៈ ៤ ឈ្មោះថា

បានឃើញហើយឬ ។ អើ ។ ទុក្ខសច្ច ឈ្មោះថា សច្ចៈ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៦ ] កាលបើរូបក្ខន្ធ បុគ្គល បានឃើញហើយ ដោយសេចក្ដីថា មិនទៀង បញ្ចក្ខន្ធ ឈ្មោះថា បានឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ រូបក្ខន្ធ ឈ្មោះថា បញ្ចក្ខន្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៧ ] កាលបើចក្ខាយតនៈ បុគ្គល ឃើញហើយ ដោយសេចក្ដីថា មិនទៀង អាយតនៈ ១២ ឈ្មោះថា បុគ្គល ឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថា អាយតនៈ ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៨ ] កាលបើចក្ខុធាតុ បុគ្គលបានឃើញហើយ ដោយសេចក្ដីថា មិនទៀង ធាតុទាំង ១៨ ឈ្មោះថា បានឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ ចក្ខុធាតុ ឈ្មោះថា ធាតុ ១៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២១៩ ] កាលបើចក្ខុន្ទ្រិយ បុគ្គល បានឃើញហើយ ដោយសេចក្ដីថា មិនទៀង ឥន្ទ្រិយទាំង ២២ ឈ្មោះថា បានឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ ចក្ខុន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយ ២២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២០ ] បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៤ ឬ ។ អើ ។ សោតាបត្តិផល មាន ៤ ឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។ បុគ្គល ធ្វើជាក់ច្បាស់នូវសោតាបត្តិផល ដោយញាណទាំង ៨ ឬ ។ អើ ។ សោតាបត្តិផល មាន ៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ដោយញាណទាំង ១២ ឬ ។ អើ ។ សោតាបត្តិផលមាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៤៤ ឬ ។ អើ ។ សោតាបត្តិផល មាន ៤៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៧៧ ឬ ។ អើ ។ សោតាបត្តិផលមាន ៧៧ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២១ ] បុគ្គល មិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រទាបទៅដោយលំដាប់ ជ្រាលទៅដោយលំដាប់ ទេរទៅដោយលំដាប់ មិនមែនចោតជ្រៅស្រឡូង ដូចជាអណ្តូងទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាជាលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ក៏យ៉ាងនោះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

[ ២២២ ] បុគ្គល មិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

អ្នកមានប្រាជ្ញា គប្បីកម្ចាត់បង់ នូវមន្ទិលរបស់ខ្លួន បន្តិចម្ដងៗ
ក្នុងមួយខណៈៗ ដោយលំដាប់ ដូចជាជាងមាស ដែល
កម្ចាត់បង់នូវមន្ទិលនៃរជតវត្ថុ ដូច្នោះដែរ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

[ ២២៣ ] បុគ្គល មិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះគវម្បតិត្ថេរមានអាយុ បានពោលដូច្នេះ នឹងភិក្ខុទាំងឡាយហើយថា ម្នាលលោកមានអាយុទាំងឡាយ ពាក្យនេះ ខ្ញុំបានស្ដាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញទុក្ខ បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខសមុទយៈ បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធ បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធគាមិនីបដិបទា បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរនិយាយថា ការត្រាស់ជាលំដាប់ មានទេ ។

[ ២២៤ ] ការត្រាស់ជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមាន

ព្រះភាគ ទ្រង់ត្រាស់ថា ជាមួយនឹងទស្សនសម្បទា ( គឺសោតាបត្តិមគ្គ ) ។បេ។ សោតាបន្នបុគ្គល មិនគួរធ្វើនូវហេតុជាទីតាំងនៃសេចក្តីអាក្រក់ទាំង ៦ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

[ ២២៥ ] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យណា ធម្មចក្ខុ ដែលមានធូលី ទៅប្រាសហើយ មានមន្ទិល ទៅប្រាសហើយ របស់អរិយសាវ័ក កើតឡើងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ម្នាលភិក្ខុទាំងឡាយ សម័យនោះ សញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឈ្មោះថា អរិយសាវ័ក បានលះបង់ជាមួយនឹងការកើតឡើងនៃទស្សនសម្បទា ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល មិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

អនុបុព្វាភិសមយកថា ចប់

# អដ្ឋកថា

## អនុព្វាភិសមយកថា

[ ២០៣ ] ឥឡូវនេះ នឹងពណ៌នាអំពីការត្រាស់ដឹងដោយលំដាប់តទៅ ក្នុងរឿងនោះ ជនទាំងឡាយណា កើតមានលទ្ធិ នៃការត្រាស់ដឹងផ្សេងៗ ដូចលទ្ធិរបស់និកាយអន្ធកៈ និកាយសព្វត្ថិកវាទ និកាយសមិតិយៈ និង និកាយភទ្រយានិកទាំងឡាយ ក្នុងខណៈនេះយ៉ាងនេះថា ការសម្រេចអរហត្តផលមាន ព្រោះការលះកិលេសដោយលំដាប់ ១៦ ចំណែកយ៉ាងនេះ គឺ បុគ្គល ដែលបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល រមែងលះកិលេសទាំងឡាយបានខ្លះ ដោយការឃើញនូវទុក្ខ រមែងលះកិលេសខ្លះ បានដោយការឃើញសមុទយៈ ... និរោធ ... មគ្គ បុគ្គល ដែលបដិបត្តិដ៏សេស ក៏ដូចគ្នាដូច្នេះ ព្រោះកាន់យកដោយមិនពិចារណានូវព្រះសូត្រទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ
ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬប្រែះ
របស់មាស ដូច្នេះ ។

ដើម្បីញ៉ាំញីលទ្ធិនៃជនទាំងនោះ ទើបសកវាទីសួរថា **អនុបុព្វាភិសមយោ** ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បរវាទីត្រូវសួរថា **អនុបុព្វេន សោតាបត្តិមគ្គំ** ក៏ឆ្លើយបដិសេធ ព្រោះខ្លាចចំពោះការត្រាស់ដឹងចំនួនច្រើន របស់មគ្គមួយ ។ ត្រូវសួរលើកទី ២ ឆ្លើយទទួល ដោយអំណាច

នៃការឃើញទុក្ខជាដើម ។ ម្យ៉ាងទៀត បរវាទីឆ្លើយទទួល ដោយការគិតថា ញាណទាំង ៤ នោះ ជាសោតាបត្តិមគ្គ ១ ប៉ុណ្ណោះ តែរមែងប្រាថ្នាផល ត្រឹមតែ ១ ព្រោះហេតុនោះ ទើបបដិសេធ ក្នុងសកទាគាមិមគ្គជាដើម ក៏ន័យនេះដូចគ្នា ។

[ ២១២ ] ក្នុងបញ្ហាថា **មគ្គេ ទិដ្ឋេ ផលេ ឋិតោ** អធិប្បាយថា ព្រោះការឃើញ មានការឃើញទុក្ខជាដើម មិនទាន់ជាការសម្រេច និងឈ្មោះថា សម្រេចបាន ដោយការឃើញមគ្គហើយ ក្នុងវេលានោះ ទើបបុគ្គលនោះ ដល់នូវការរាប់ថា តាំងនៅក្នុងផល ហេតុនោះ ទើបបរវាទីឆ្លើយទទួលថា **អាមន្តា ។**

[ ២១៥ ] ពាក្យសួររបស់បរវាទីថា **ទុក្ខេ ទិដ្ឋេ ចត្តារិ សច្ចានិ** សកវាទីឆ្លើយទទួល ដោយអំណាចនៃការត្រាស់ដឹងសច្ចៈទាំង ៤ នោះព្រមគ្នា ។ កាលត្រូវសួរជាដែលទៀតថា **ទុក្ខសច្ចំ ចត្តារិ សច្ចានិ** សកវាទីនោះឯង ឆ្លើយបដិសេធ ព្រោះសច្ចៈទាំង ៤ មានសភាវៈផ្សេងគ្នា ។

[ ២១៦ ] ពាក្យសួរថា **រូបក្ខន្ធេ អនិច្ចតោ ទិដ្ឋេ** ជាពាក្យរបស់សកវាទី ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយលទ្ធិរបស់លោកថា កាលបុគ្គលចាក់ធ្លុះធម៌ ១ ដោយភាពជារបស់មិនទៀងហើយ រមែង ឈ្មោះថា ជាអ្នកចាក់ធ្លុះធម៌ទាំងពួង ដូចបុគ្គលដឹងរសនៃទឹក ត្រឹមតែមួយតំណក់អំពីសមុទ្រ រមែងជាអ្នកឈ្មោះថា ដឹងនូវរសនៃទឹកសមុទ្រដ៏សេស ដូច្នេះ ។

*[ ២២០ ] បទថា* **ចតូហិ ញាណេហិ** *បានដល់ ដោយញាណក្នុងទុក្ខជាដើម ។ បទថា* **អដ្ឋហិ ញាណេហិ** *បានដល់ ដោយសច្ចញ្ញាណ ៤ ដែលទូទៅដល់សាវកទាំងឡាយ និងដោយបដិសម្ភិទាញាណ ៤ ។ បទថា* **ទ្វាទសហិ ញាណេហិ** *បានដល់ ដោយញាណក្នុងបដិច្ចសមុប្បាទ ដែលមានអង្គ ១២ ។ បទថា* **ចតុចត្តារីសាយ ញាណេហិ** *បានដល់ ដោយញាណ ដែលលោកពោលក្នុង ( សំយុត្តនិកាយ និទានវគ្គ ) យ៉ាងនេះថា សេចក្ដីដឹងក្នុងជរា និងមរណៈ ១ សេចក្ដីដឹងក្នុងហេតុជាទីកើតឡើងនៃជរា និងមរណៈ ១ ដូច្នេះ ។ បទថា* **សត្តសត្តតិយា ញាណេហិ** *បានដល់ ដោយញាណដែលលោកពោលក្នុងនិទានវគ្គនោះឯង យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ជរា មរណៈ មិនទៀង ជាធម្មជាតដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ជាធម្មជាតតែងអស់ជាធម្មតា សូន្យជាធម្មតា វិនាសជាធម្មតា រលត់ជាធម្មតា ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យព្រះបាលី មួយអន្លើដោយការអេះអាងដោយព្រះសូត្រនោះឯង ។*

**អដ្ឋកថាអនុបុព្វាភិសមយកថា ចប់**

# អភិធម្មបិដក

## វោហារកថា

[ ២២៦ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។ អើ ។ វោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀក ជាលោកុត្តរ មិនប៉ះទង្គិចត្រចៀក ជាលោកិយ ជនទាំងឡាយ ដឹងច្បាស់ដោយវិញ្ញាណ ជាលោកុត្តរ មិនដឹងច្បាស់ដោយវិញ្ញាណ ជាលោកិយ សាវកទាំងឡាយ ដឹងច្បាស់ បុថុជ្ជនទាំងឡាយ មិនដឹងច្បាស់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២២៧ ] ក្រែងវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀក ជាលោកិយឬ ។ អើ ។ បើវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀក ជាលោកិយដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរទេ ។

[ ២២៨ ] ក្រែងពួកសាវក ដឹងច្បាស់នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគដោយវិញ្ញាណ ជាលោកិយឬ ។ អើ ។ បើពួកសាវកដឹងច្បាស់នូវវោហាររបស់ព្រះពុទ្ធមានព្រះភាគ ដោយវិញ្ញាណជាលោកិយដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធ មានព្រះភាគ ជាលោកុត្តរទេ ។

[ ២២៩ ] ក្រែងពួកបុថុជ្ជន ដឹងច្បាស់នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគឬ ។ អើ ។ បើពួកបុថុជ្ជនដឹងច្បាស់នូវវោហារ របស់ព្រះពុទ្ធមាន

ព្រះភាគដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរទេ ។

[ ២៣០ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។អើ ។ ចុះមគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ( ជាលោកុត្តរ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣១ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។អើ ។ សាវកពួកខ្លះ ស្តាប់វោហាររបស់ព្រះពុទ្ធ មានព្រះភាគមានឬ ។ អើ ។ លោកុត្តរធម៌ បុគ្គលគប្បីដឹងដោយត្រចៀក ប៉ះទង្គិចត្រចៀក មកកាន់វង្វង់នៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣២ ] ក្រែងលោកុត្តរធម៌ បុគ្គលមិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់វង្វង់នៃត្រចៀកទេឬ ។ អើ ។ បើលោកុត្តរធម៌ បុគ្គល មិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់វង្វង់នៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរទេ ។

[ ២៣៣ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។អើ ។ សាវកពួកខ្លះ ត្រេកអរនឹងវោហាររបស់ព្រះពុទ្ធមានព្រះភាគ មានឬ ។ អើ ។ លោកុត្តរធម៌ជាទីតាំងនៃរាគៈ ជាទីត្រេកអរ ជាទីប្រាថ្នា ជាទីស្រវឹង ជាទីចង

ជាទីជ្រប់ចុះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៤ ] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃរាគៈ មិនជាទីត្រេកអរ មិនជាទីប្រាថ្នា មិនជាទីស្រវឹង មិនជាទីចង មិនជាទីជ្រប់ចុះទេឬ ។ អើ ។ បើលោកុត្តរធម៌ មិនជាទីតាំងនៃរាគៈ មិនជាទីត្រេកអរ មិនជាទីប្រាថ្នា មិនជាទីស្រវឹង មិនជាទីចង មិនជាទីជ្រប់ចុះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរទេ ។

[ ២៣៥ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។ អើ ។ សាវ័កពួកខ្លះ ប្រទូស្តនឹងវោហារ របស់ព្រះពុទ្ធមានព្រះភាគមានឬ ។អើ។ លោកុត្តរធម៌ ជាទីតាំងនៃសេចក្តីប្រទូស្ត ជាទីតាំងនៃសេចក្តីក្រោធ ជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៦ ] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីប្រទូស្ត មិនមែនជាទីតាំងនៃសេចក្តីក្រោធ មិនមែនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេឬ ។ អើ ។ បើលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីប្រទូស្ត មិនមែនជាទីតាំងនៃសេចក្តីក្រោធ មិនមែនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរទេ ។

[ ២៣៧ ] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។ អើ ។ សាវ័កពួកខ្លះ វង្វេងក្នុងវោហាររបស់ព្រះពុទ្ធ មានព្រះភាគឬ ។ អើ ។ លោកុត្តរធម៌ ជាទីតាំងនៃសេចក្តីវង្វេង ធ្វើមិនឲ្យមានញាណ ធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការរលត់ទៅនៃបញ្ញា ជាពួកនៃសេចក្តីចង្អៀតចង្អល់ មិន

ប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៣៨ ] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីវង្វេង មិនមែនធ្វើមិនឲ្យមានញាណ មិនមែនធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការចម្រើននៃបញ្ញា មិនមែនជាពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វានឬ ។ អើ ។ បើលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីវង្វេង មិនមែនធ្វើមិនឲ្យមានញាណ មិនមែនធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការចម្រើននៃបញ្ញា មិនមែនជាពួកនៃសេចក្តីអង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធ មានព្រះភាគ ជាលោកុត្តរទេ ។

[ ២៣៩ ] វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរឬ ។ អើ ។ ពួកសាវកណាមួយ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ សាវកទាំងអស់នោះ ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤០ ] ពួកសាវកណាមួយ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ សាវកទាំងអស់នោះ ចម្រើនមគ្គឬ ។ អើ ។ ពួកពាលបុថុជ្ជន ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ ពួកពាលបុថុជ្ជន ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកសម្លាប់មាតា ។បេ។ បុគ្គលអ្នកសម្លាប់បិតា ... បុគ្គលអ្នកសម្លាប់ព្រះអរហន្ត ... បុគ្គលអ្នកធ្វើព្រះលោហិតឲ្យពុះពោរ ។បេ។ បុគ្គលអ្នកបំបែកសង្ឃ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ បុគ្គលអ្នកបំបែកសង្ឃ ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤១ ]គំនរស្រូវក្តី គំនរមាសក្តី បុគ្គលអាចដើម្បីប្រាប់ថា ជាកូនត្នោត ជាវិការនៃមាសឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ពោលនូវធម៌ ជាលោកិយក្តី ជាលោកុត្តរក្តី ដោយវោហារជាលោកុត្តរយ៉ាងនេះឯង ។

[ ២៤២ ] គំនរស្រូវក្តី គំនរមាសក្តី បុគ្គលអាចដើម្បីប្រាប់ថា ជាកូនត្នោត មានសណ្ឋានដូចដើមល្ហុងខ្វៃឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ពោលនូវធម៌ជាលោកិយក្តី ជាលោកុត្តរក្តី ដោយវោហារជាលោកិយយ៉ាងនេះឯង ។

[ ២៤៣ ] វោហារ ដែលព្រះពុទ្ធមានព្រះភាគ កាលពោលថា ជាលោកិយ ក៏ជាលោកិយមែន កាលពោលថា ជាលោកុត្តរ ក៏ជាលោកុត្តរមែនឬ ។ អើ ។ កាលព្រះពុទ្ធមានព្រះភាគ ពោលជាលោកិយ វោហារនោះប៉ះទង្គិចប្រចៀក ជាលោកិយ កាលពោលជាលោកុត្តរ ប៉ះទង្គិចត្រចៀក ជាលោកុត្តរ កាលពោលជាលោកិយ ពួកសាវករមែងដឹងច្បាស់ដោយវិញ្ញាណជាលោកិយ កាលពោលជាលោកុត្តរ ពួកសាវករមែងដឹងច្បាស់ដោយវិញ្ញាណជាលោកុត្តរ កាលពោលជាលោកិយ ពួកបុថុជ្ជនរមែងដឹងច្បាស់ កាលពោលជាលោកុត្តរ ពួកសាវករមែងដឹងច្បាស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៤ ] បុគ្គល មិនគួរនិយាយថា វោហារ ដែលព្រះពុទ្ធមានព្រះភាគ កាលពោលជាលោកិយ ក៏ជាលោកិយមែន កាលពោលជាលោកុត្តរ ក៏ជាលោកុត្តរមែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ពោលនូវធម៌ជាលោកិយផង ជាលោកុត្តរផងឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ពោល

នូវធម៌ ជាលោកិយផង ជាលោកុត្តរផង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វោហារ កាលព្រះពុទ្ធមានព្រះភាគពោល ជាលោកិយ ក៏ជាលោកិយមែន កាលពោលជាលោកុត្តរ ក៏ជាលោកុត្តរមែន ។

[ ២៤៥ ] វោហារ កាលព្រះពុទ្ធមានព្រះភាគពោល ជាលោកិយ ក៏ជាលោកិយមែន កាលពោលជាលោកុត្តរ ក៏ជាលោកុត្តរមែនឬ ។ អើ ។ ព្រះមានព្រះភាគ កាលពោលថា មគ្គ ក៏ជាមគ្គមែន កាលពោលថា មិនមែនមគ្គ ក៏មិនមែនមគ្គមែន កាលពោលថា ផល ក៏ជាផលមែន កាលពោលថា មិនមែនផល ក៏មិនមែនផលមែន កាលពោលថា និព្វាន ក៏ជានិព្វានមែន កាលពោលថា មិនមែននិព្វាន ក៏មិនមែននិព្វានមែន កាលពោលថា សង្ខតធម៌ ក៏ជាសង្ខតធម៌មែន កាលពោលថា អសង្ខតធម៌ ក៏ជាអសង្ខតធម៌មែន កាលពោលថា រូប ក៏ជារូបមែន កាលពោលថា មិនមែនរូប ក៏មិនមែនរូបមែន កាលពោលថា វេទនា ក៏ជាវេទនាមែន កាលពោលថា មិនមែនវេទនា ក៏មិនមែនវេទនាមែន កាលពោលថា សញ្ញា ក៏ជាសញ្ញាមែន កាលពោលថា មិនមែនសញ្ញា ក៏មិនមែនសញ្ញាមែន កាលពោលថា ពួកសង្ខារ ក៏ជាពួកសង្ខារមែន កាលពោលថា មិនមែនពួកសង្ខារ ក៏មិនមែនពួកសង្ខារមែន កាលពោលថា វិញ្ញាណ ក៏ជាវិញ្ញាណមែន កាលពោលថា មិនមែនវិញ្ញាណ ក៏មិនមែនវិញ្ញាណមែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

វោហារកថា ចប់

# អដ្ឋកថា

## វោហារកថា

[ ២២៦ ] ឥឡូវនេះ នឹងពណ៌នាអំពីវោហារដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា ព្រះមានព្រះភាគត្រាស់ដោយព្រះតម្រាស់ដែលជាលោកុត្តរ ដូច្នេះ ពាក្យសួរ ជាពាក្យរបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដោយអំណាចនៃលទ្ធិ ។ បទថា **លោកុត្តរេ សោតេ** ជាដើម សកវាទីពោលហើយ ដើម្បីសម្តែងភាពដែលបរវាទីនោះ ជាអ្នកមានប្រក្រតីពោលមិនត្រឹមត្រូវ ។ ក្នុងសេចក្តីនេះ លោកអធិប្បាយដូច្នេះថា សទ្ទាយតនៈនោះឯង ជាលោកុត្តរ ឬសូម្បីអាយតនៈ មានសោតៈជាដើម ក៏ជាលោកុត្តរ តាមលទ្ធិរបស់អ្នក ។

[ ២២៧ ] ក្នុងបទថា **ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារោ លោកិយេ សោតេ បដិហញ្ញតិ** នេះ សេចក្តីថា បុគ្គល មិនគប្បីកាន់យកអត្ថយ៉ាងនេះថា បើព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ គប្បីប៉ះខ្ទប់សោតៈដែលជាលោកុត្តរបានសោត ព្រះតម្រាស់នោះ គប្បីជាលោកុត្តរបាន ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ឈ្មោះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគដែលប៉ះខ្ទប់នូវសោតៈ ដែលជាលោកិយ ជាលោកុត្តរ រមែងមិនមាន ។

[ ២២៨ ] ក្នុងបទនេះថា **លោកិយេន វិញ្ញាណេន** បានដល់ ដោយលោកិយប៉ុណ្ណោះ ។ ភាពមិនមែនតែមួយ គប្បីមានដោយប្រការដទៃ ។

ពិតហើយ លោកុត្តរ រមែងដឹងបានដោយញាណដែលជាលោកិយ ។ បណ្ឌិតគប្បីជ្រាបអត្ថទាំងពួង តាមសមគួរយ៉ាងនេះ ។

[ ២៣៩ ] ក្នុងបញ្ហាទាំងឡាយថា **សព្វេ តេ មគ្គំ ភាវេន្តិ** បរវាទី រមែងបដិសេធ ព្រោះសំដៅយកចំពោះបុគ្គលដែលមិនបានមគ្គ តែឆ្លើយទទួល ព្រោះសំដៅយកបុគ្គលដែលបានមគ្គ ។

[ ២៤១ ] បទថា **សោវណ្ណមយាយ** បានដល់ ឈើច្រត់[១] សម្រេចហើយដោយមាស ។ ឧទាហរណ៍នេះ ជារបស់បរវាទី ។

[ ២៤២ ] បទថា **ឯឡណ្ឌិយាយ** បានដល់ ឈើច្រត់[២] ដែលធ្វើអំពីដើមល្ហុងខ្វៃ ។ ឧទាហរណ៍នេះ ជារបស់សកវាទី ។

ម្យ៉ាងទៀត លទ្ធិមួយរបស់និកាយអន្ធកៈ ក្នុងឥឡូវនេះ មានដូច្នេះថា កាលព្រះពុទ្ធមានព្រះភាគត្រាស់លោកិយធម៌ ក៏ជាលោកិយធម៌ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាវោហារកថា ចប់**

---

១- សេចក្តីថា គំនរស្រូវក្តី គំនរមាសក្តី បុគ្គលយកឈើច្រត់ សម្រេចអំពីមាស ចង្អុលប្រាប់បានឬ ។ ២- បិដកខ្មែរជា កូនគ្នោត ។

# អភិធម្មបិដក

## និរោធកថា

[ ២៤៦ ] និរោធ មាន ២ ឬ ។ អើ ។ ទុក្ខនិរោធ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខនិរោធ មាន ២ ឬ ។ អើ ។ និរោធសច្ច មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច មាន ២ ឬ ។ អើ ។ ទុក្ខសច្ច មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច មាន ២ ឬ ។ អើ ។ សមុទយសច្ច មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច មាន ២ ឬ ។ អើ ។ មគ្គសច្ច មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច មាន ២ ឬ ។ អើ ។ ការទីពឹង មាន ២ ។បេ។ ការជ្រកកោន មាន ២ ការរឭក មាន ២ ការប្រព្រឹត្តទៅក្នុងខាងមុខ មាន ២ ការមិនច្យុត មាន ២ ការមិនស្លាប់ មាន ២ ។បេ។ និព្វាន មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វាន មាន ២ ឬ ។ អើ ។ ភាពខ្ពស់ និងទាប ភាពថោកទាប និងឧត្តម ឧក្រិដ្ឋ និងឱនថយ ដែន ឬការបែកធ្លាយ ការប្រេះធា ឬចន្លោះ របស់និព្វានទាំង ២ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៤៧ ] និរោធ មាន ២ ឬ ។ អើ ។ ក្រែងថា កាលបើសង្ខាររលត់ ព្រោះមិនបានពិចារណា បញ្ញាជាគ្រឿងពិចារណាទាំងឡាយ រលត់ដែរឬ ។ អើ ។ បើសង្ខាររលត់ ព្រោះមិនបានពិចារណា បញ្ញាជាគ្រឿងពិចារណាទាំងឡាយ ក៏រលត់ទៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា និរោធមាន ២ ទេ ។

[ ២៤៨ ] បុគ្គល មិនគួរនិយាយថា និរោធ មាន ២ ទេឬ ។ អើ ។ ក្រែងសង្ខារទាំងឡាយ រលត់ទៅ ព្រោះមិនបានពិចារណា មានការបាក់បែកក្នុងទីបំផុត ចុះសង្ខារទាំងឡាយ រលត់ទៅ ព្រោះបានពិចារណា មានការបាក់បែកក្នុងទីបំផុតដែរឬ ។ អើ ។ បើសង្ខារទាំងឡាយ រលត់ទៅ ព្រោះមិនបានពិចារណាក្តី មានការបាក់បែកក្នុងទីបំផុត សង្ខារទាំងឡាយ រលត់ទៅ ព្រោះបានពិចារណាក្តី មានការបាក់បែកក្នុងទីបំផុត ( ដូចគ្នា ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា និរោធ មាន ២ ។

[ ២៤៩ ] និរោធ មាន ២ ឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅ ព្រោះបានពិចារណា រលត់ទៅ ព្រោះអាស្រ័យអរិយមគ្គឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅ ព្រោះមិនបានពិចារណា រលត់ទៅ ព្រោះអាស្រ័យអរិយមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥០ ] និរោធ មាន ២ ឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅ ព្រោះបានពិចារណា រមែងមិនកើតទៀតទេឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅ ព្រោះមិនបានពិចារណា រមែងមិនកើតទៀតទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា និរោធ មាន ២ ទេ ។

**និរោធកថា ចប់**

**ទុតិយវគ្គ ចប់**

## ឧទ្ទាននៃទុតិយវគ្គនោះ គឺ

បរូបហារកថា ១ អញ្ញាណកថា ១ កន្ខាកថា ១ បរវិតារណាកថា ១ វចីភេទកថា ១ ទុក្ខាហារកថា ១ ចិត្តដ្ឋិតិកថា ១ កុក្កុឡកថា ១ សន្ធារកថា ១ អនុបុព្វាភិសមយកថា ១ វោហារកថា ១ និរោធកថា ១ ។

# អដ្ឋកថា

## និរោធកថា

[ ២៤៦ ] ឥឡូវនេះ នឹងពណ៌នាអំពីនិរោធដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយមហិសាសកៈ និងនិកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា រួមនិរោធទាំង ២ គឺអប្បដិសង្ខានិរោធ ( ការរលត់ដោយមិនប្រើបញ្ញាជាគ្រឿងពិចារណា ) ១ បដិសង្ខានិរោធ ( ការរលត់ដោយប្រើបញ្ញាជាគ្រឿងពិចារណា ) ១ ទាំង ២ នេះ ចូលជាមួយគ្នា ទើបឈ្មោះថា និរោធសច្ច សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **ទ្វេនិរោធា** ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាថា **ទ្វេ ទុក្ខនិរោធា** បរវាទីមិនកាន់យកថា ទុក្ខសច្ចជា ២ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ តែប្រកាន់ថា ទុក្ខ រមែងរលត់ទៅដោយអាការ ២ យ៉ាង ព្រោះហេតុនោះ ទើបឆ្លើយទទួល ។ ក្នុងបញ្ហាថា **ទ្វេ និរោធសច្ចានិ** បរវាទី កាលមិនកាន់យកដោយអំណាចនៃការរលត់ទុក្ខសច្ចទាំង ២ យ៉ាង ទើបឆ្លើយបដិសេធ តែរមែងឆ្លើយទទួល ព្រោះការរលត់ទុក្ខដោយអាការទាំង ២ យ៉ាង ។ ក្នុងបទទាំងឡាយ មានបទថា **ទ្វេ តាណានិ** ជាដើម ក៏មានន័យនេះឯង ។

ពាក្យសួរទាំងឡាយ មានពាក្យថា **អត្ថិ ទ្វិន្នំ និព្វានានំ** ជាដើម បរវាទី កាលមិនឃើញព្រះនិព្វាន មានសភាពខ្ពស់ និងការទាបជាដើម ទើបឆ្លើយបដិសេធ ។

[ ២៤៧ ] បទថា **អប្បដិសង្ខានិរុទ្ធេ** ដូច្នេះ អធិប្បាយថា សង្ខារទាំងឡាយណា មិនរលត់ទៅ ដោយលោកុត្តរញ្ញាណ ដែលជាគ្រឿងពិចារណា លោកហៅថា រលត់ទៅហើយ ព្រោះបរិសុទ្ធហើយតាមប្រក្រតី ឬព្រោះមិនមានការផ្សាយឡើង ដោយអំណាចនៃការរៀន និងការសាកសួរជាដើម ។ សង្ខារទាំងនោះ ។ បទថា **បដិសង្ខា និរោធេន្តិ** បានដល់ ញុំាងសង្ខារទាំងនោះឲ្យរលត់ទៅ ដោយលោកុត្តរញ្ញាណ គឺរមែងឲ្យដល់នូវការមិនកើតឡើងទៀត ។

[ ២៤៨ ] ពាក្យសួរថា **ននុ អប្បដិសង្ខានិរុទ្ធា សង្ខារា** ជាពាក្យរបស់បរវាទី ។ ក្នុងពាក្យវិសជ្ជនានោះ សកវាទី រមែងឆ្លើយទទួលនូវភាពដែលសង្ខារទាំងឡាយនោះ មានការបែកធ្លាយទៅ ព្រោះការបែកធ្លាយនៃសង្ខារទាំងឡាយ ដែលត្រូវបែកធ្លាយទៅ ឬភាពដែលសង្ខារទាំងនោះ មិនទាន់រលត់ដោយបញ្ញាជាគ្រឿងពិចារណា កាលអរិយមគ្គកើតឡើងហើយ ក៏ត្រូវបែកធ្លាយទៅយ៉ាងនោះឯង ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថានិរោធកថា ចប់**

**ទុតិយវគ្គ ចប់**

# អភិធម្មបិដក

## ពលកថា

[ ២៥១ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈរបស់សាវកឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត ជាកម្លាំងរបស់សាវក កម្លាំងរបស់សាវក ជាកម្លាំងរបស់ព្រះតថាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥២ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវកឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគតនោះឯង ជាកម្លាំងរបស់សាវកនោះ កម្លាំងរបស់សាវកនោះឯង ជាកម្លាំងរបស់ព្រះតថាគតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៣ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវកឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគតដូចម្តេច កម្លាំងរបស់សាវកក៏ដូច្នោះ កម្លាំងរបស់សាវកដូចម្តេច កម្លាំងរបស់ព្រះតថាគតក៏ដូច្នោះ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនោះទេ ។បេ។

[ ២៥៤ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវកដែរឬ ។ អើ ។ សេចក្តីព្យាយាមខាងដើម ការប្រព្រឹត្តខាងដើម ការពោលធម៌ ការសម្តែងធម៌ របស់ព្រះតថាគតដូចម្តេច ។ សេចក្តីព្យាយាមខាងដើម ការប្រព្រឹត្តខាងដើម ការពោលធម៌ ការសម្តែងធម៌ របស់សាវកក៏ដូច្នោះ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៥ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវក ដែរឬ ។

អើ ។ ព្រះតថាគត ជាអ្នកឈ្នះ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹងសព្វ ឃើញសព្វ ជាម្ចាស់ធម៌ មានធម៌ជាទីពឹង ដែរឬ ។ អើ ។ សាវកជាអ្នកឈ្នះ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹងសព្វ ឃើញសព្វ ជាម្ចាស់នៃធម៌ មានធម៌ជាទីពឹងមែន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៦ ] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវក ដែរឬ ។ អើ ។ ព្រះតថាគត ជាអ្នកញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ជាអ្នកញុំាងមគ្គ ដែលមិនទាន់កើតព្រម ឲ្យកើតព្រម ជាអ្នកពោលនូវមគ្គ ដែលមិនទាន់ពោល ជាអ្នកជ្រាបនូវមគ្គ ដឹងច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ដែរឬ ។ អើ ។ សាវក ជាអ្នកញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ជាអ្នកញុំាងមគ្គ ដែលមិនទាន់កើតព្រម ឲ្យកើតព្រម ជាអ្នកពោលនូវមគ្គ ដែលមិនទាន់ពោល ជាអ្នកជ្រាបនូវមគ្គ ដឹងច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៥៧ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា ( នៃសត្វ ) ជាសាធារណៈដល់សាវក ដែរឬ ។ អើ ។ សាវកជាអ្នកដឹងសព្វ ឃើញសព្វ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៥៨ ] សាវក ជ្រាបហេតុ និងមិនមែនហេតុ ដែរឬ ។ អើ ។ ប្រសិនបើ សាវកជ្រាបហេតុ និងមិនមែនដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវហេតុ និងមិនមែនហេតុ ជាសាធារណៈដល់សាវកដែរ ។

[ ២៥៩ ] សាវ័ក ជ្រាបនូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីត អនាគត និងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីត អនាគត និងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីត អនាគត និងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុ ជាសាធារណៈដល់សាវ័កដែរ ។

[ ២៦០ ] សាវ័ក ជ្រាបនូវបដិបទា ជាដំណើរទៅរកប្រយោជន៍ទាំងអស់ដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវបដិបទា ជាដំណើរទៅរកប្រយោជន៍ទាំងអស់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវបដិបទា ជាដំណើរទៅរកប្រយោជន៍ទាំងអស់ ជាសាធារណៈ ដល់សាវ័កដែរ ។

[ ២៦១ ] សាវ័កជ្រាបនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ ដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ ជាសាធារណៈដល់សាវ័កដែរ ។

[ ២៦២ ] សាវ័ក ជ្រាបនូវអធ្យាស្រ័យផ្សេងៗ គ្នា របស់ពួកសត្វដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវអធ្យាស្រ័យផ្សេងៗ គ្នារបស់ពួក

សត្វដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវអធ្យាស្រ័យផ្សេងៗ គ្នា របស់ពួកសត្វ ជាសាធារណៈ ដល់សាវ័កដែរ ។

[ ២៦៣ ] សាវ័ក ជ្រាបនូវការសៅហ្មង ការផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបនូវការសៅហ្មង ការផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវការសៅហ្មង ការផូរផង់ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ជាសាធារណៈ ដល់សាវ័កដែរ ។

[ ២៦៤ ] សាវ័ក ជ្រាបនូវការរឭកឃើញជាតិ ដែលធ្លាប់អាស្រ័យក្នុងកាលមុនដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវការរឭកឃើញជាតិ ដែលធ្លាប់អាស្រ័យ ក្នុងកាលមុនដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវការរឭកឃើញជាតិដែលធ្លាប់អាស្រ័យក្នុងកាលមុន ជាសាធារណៈដល់សាវ័កដែរ ។

[ ២៦៥ ] សាវ័ក ជ្រាបនូវចុតិ និងបដិសន្ធិ របស់ពួកសត្វដែរឬ ។ អើ ។ ប្រសិនបើ សាវ័កជ្រាបនូវចុតិ និងបដិសន្ធិ របស់ពួកសត្វដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាសាធារណៈ ដល់

សាវ័កដែរ ។

[ ២៦៦ ] ក្រែងអាសវៈទាំងឡាយ របស់ព្រះតថាគតអស់ហើយ អាសវៈទាំងឡាយ របស់សាវ័កអស់ហើយដែរឬ ។ អើ ។ ការអស់អាសវៈ ដោយការអស់អាសវៈក្តី ការផុតស្រឡះ ដោយការផុតស្រឡះក្តី របស់ព្រះតថាគតក្តី របស់សាវ័កក្តី ធ្វើឲ្យផ្សេងៗ គ្នាបន្តិចបន្តួចមានដែរឬ ។ មិនមានទេ ។ ប្រសិនបើ ការអស់អាសវៈ ដោយការអស់អាសវៈក្តី ការផុតស្រឡះ ដោយការផុតស្រឡះក្តី របស់ព្រះតថាគតក្តី របស់សាវ័កក្តី ធ្វើឲ្យផ្សេងៗ គ្នាបន្តិចបន្តួច មិនមានទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ជាសាធារណៈ ដល់សាវ័កដែរ ។

[ ២៦៧ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាសាធារណៈ ដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៨ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាសាធារណៈ ដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៦៩ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និង

មិនមែនហេតុ មិនសាធារណៈដល់សាវកទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនសាធារណៈ ដល់សាវកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧០ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ មិនសាធារណៈដល់សាវកទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនសាធារណៈ ដល់សាវកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧១ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់ និងចាស់ក្លា មិនសាធារណៈដល់សាវកទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ មិនសាធារណៈដល់សាវកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧២ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់ និងចាស់ក្លា មិនសាធារណៈដល់សាវកទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនសាធារណៈ ដល់សាវកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៣ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និង មិនមែនហេតុ ជាសាធារណៈដល់សាវកដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់ និងចាស់ក្លា ជាសាធារណៈដល់សាវក ទេដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៤ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសធារណៈដល់សាវកដែរឬ ។ អើ ។ កម្លាំង របស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់ និងចាស់ក្លា ជា សាធារណៈ ដល់សាវកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ពលកថា ចប់

# អដ្ឋកថា

## ពលកថា

[ ២៥១ ] ឥឡូវនេះ នឹងពណ៌នាអំពីពលដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា កម្លាំងរបស់ព្រះតថាគតទូទៅដល់សាវកទាំងឡាយ ព្រោះកាន់យកព្រះសូត្រ ១០ ក្នុងអនុរុទ្ធសំយុត្ត ដោយមិនពិចារណាថា ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិត នូវហេតុដ៏គួរតាមហេតុដ៏គួរផង នូវហេតុដ៏មិនគួរ តាមហេតុដ៏មិនគួរផង ក៏ព្រោះតែចម្រើនធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ដូច្នេះ ពាក្យសួរ សំដៅដល់ជនទាំងនោះ ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ម្យ៉ាងទៀត ឈ្មោះថា កម្លាំងនៃព្រះតថាគតនេះ ទូទៅដល់សាវកទាំងឡាយក៏មាន មិនទូទៅក៏មាន ទូទៅផង មិនទូទៅផងក៏មាន ។ ក្នុងកម្លាំងទាំងនោះ ញាណក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ឈ្មោះថា សាធារណៈ គឺទូទៅដល់សាវក តែឥន្ទ្រិយបរោបរិយត្តិញ្ញាណ ជាអសាធារណញ្ញាណ ញាណដ៏សេស ជាសាធារណៈផង ជាអសាធារណៈផង ។ ពិតហើយ សាវកទាំងឡាយ រមែងដឹងនូវឋានាឋានញ្ញាណជាដើមបានដោយចំណែកខ្លះ តែព្រះតថាគតទាំងឡាយ រមែងដឹងឋានាឋានញ្ញាណជាដើមបាន ដោយឥតសេសសល់ ។ សាវកទាំងឡាយ រមែងដឹងសាធារណញ្ញាណទាំងនោះដោយឧទ្ទេស គឺដោយមាតិកា មិនដឹងដោយនិទ្ទេស គឺដោយការនាំចេញសម្ដែងដោយពិស្ដារ ដោយប្រការដូច្នេះ ។ លទ្ធិនេះពោល

ថា កម្លាំងរបស់ព្រះតថាគតទាំងឡាយ ទូទៅដល់សាវ័កដោយមិនប្លែកគ្នា ។ ដើម្បីញ៉ាំញីលទ្ធិនោះៗ អំពីពាក្យនោះ ទើបសកវាទីផ្ដើមសាកសួរទៀតថា **តថាគតពលំ សាវកពលំ** ដូច្នេះជាដើម ។

ក្នុងបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីសំដៅយកភាពដែលកម្លាំងទាំងនោះ ជាវិស័យដោយអាការទាំងអស់ ដោយនិទ្ទេស ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាទី ២ ឆ្លើយទទួល ដោយអំណាចនៃញាណ មានឋានាឋានញ្ញាណ ដោយឧទ្ទេសជាដើម ។

[ ២៥២ ] ក្នុងបញ្ហាថា **តញ្ញោវ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានការធ្វើដែលច្រើនយ៉ាង ដោយអាការទាំងពួង ។

[ ២៥៤ ] បុព្វប្បយោគ គឺការប្រកបខាងដើមក្ដី បុព្វចរិយា គឺការប្រព្រឹត្តខាងដើមក្ដី រមែងដូចគ្នាដោយអត្ថ ។ ការពោលធម៌ផង ការសម្ដែងធម៌ផង ក៏ដូចគ្នាតែមួយ ។

[ ២៥៧ ] ក្នុងបញ្ហាពោលអំពីឥន្ទ្រិយបរោបរិយត្តិញ្ញាណ បរវាទីឆ្លើយទទួលក្នុងវិស័យនៃសាវ័ក សំដៅយកភាពទូទៅដោយឯកទេស គឺចំណែកខ្លះ ។

[ ២៥៨ ] ឥឡូវនេះ ព្រោះសាវ័កដឹងនូវឋានៈ និងអឋានៈ ដោយឧទ្ទេស ព្រោះហេតុនោះ ដើម្បីប្រកាសនូវការដឹងអត្ថរបស់សាវ័កហើយ ឲ្យតាំងនូវភាពដែលញាណទាំងនោះ សាធារណញ្ញាណដល់សាវ័ក ព្រោះភាពជារបស់ទូទៅត្រឹមតែការដឹងនោះ ទើបបរវាទីមានបញ្ហា មានបទថា **សាវកោ**

**ឋានាឋានំ ជានាតិ** ជាដើម ។ ក្នុងបញ្ហានោះ បរវាទីមិនកាន់យកឥន្ទ្រិយ-បរោបរិយត្តិញ្ញាណ ថាជាញាណណាមួយ នៃអសាធារណញ្ញាណ ៦ ។

[ ២៦៦ ] បទថា **អាសវក្ខយេន វា អាសវក្ខយំ** អធិប្បាយថា ពាក្យណាដែលអាស្រ័យការអស់អាសវៈ របស់សាវក និងការអស់អាសវៈ របស់ព្រះតថាគត ដែលបុគ្គលគួរពោលពាក្យនោះ ដែលធ្វើការផ្សេងគ្នា មិនមាន ។ ក្នុងបទថា **វិមុត្តិយា វា វិមុត្តិ** ក៏ន័យនេះឯង ។ ពាក្យដ៏សេស ក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ២៦៧ ] ឥឡូវនេះ ជាបញ្ហារបស់បរវាទីនោះឯងទៀតថា **អាសវានំ ខយេ** ជាដើម ដើម្បីប្រៀបធៀបជាមួយញាណ ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ដែលជាសាធារណញ្ញាណ ដែលសកវាទីឆ្លើយទទួលហើយ ទើបសួរនូវភាពជាសាធារណញ្ញាណទាំងឡាយ នៃញាណដ៏សេស ។ ញាណនោះ ( អាសវក្ខយញ្ញាណ ) ដែលសកវាទីអ្នកឆ្លើយបញ្ហាទាំងនោះ ទទួលហើយថា ជាសាធារណញ្ញាណ ព្រោះមិនមានអ្វីប្លែកគ្នា ក្នុងការអស់នូវអាសវៈឡើយ ។ ក្នុងញាណទាំងឡាយ ក្រៅអំពីនេះ ភាពជាសាធារណញ្ញាណ ព្រោះមិនមានការផ្សេងគ្នា ដែលលោកឆ្លើយបដិសេធហើយ ។

[ ២៦៨ ] ពាក្យសួររឿងអសាធារណញ្ញាណ នៃញាណទាំងឡាយ មានឋានឋានញ្ញាណជាដើម ជាពាក្យរបស់បរវាទី ដោយប្រៀបធៀបនឹងអាសវក្ខយញ្ញាណនោះឯងទៀត ។ ក្នុងការវិសជ្ជនាបញ្ហានោះ ពាក្យបដិសេធ ក្នុងអាសវក្ខយញ្ញាណ និងពាក្យឆ្លើយទទួលក្នុងញាណដ៏សេស ជាពាក្យរបស់

សកវាទី បន្ទាប់អំពីនេះ ពាក្យសួរអំពីអសាធារណញ្ញាណ ជាពាក្យរបស់បរវាទី ដោយប្រៀបធៀបនឹងឥន្ទ្រិយបរោបរិយត្តិញ្ញាណ ។ ពាក្យសួរនោះលោកសម្ដែងដោយសង្ខេប ។ ក្នុងការវិសជ្ជនាបញ្ហា ពាក្យឆ្លើយទទួលក្នុងឥន្ទ្រិយបរោបរិយត្តិញ្ញាណ និងពាក្យឆ្លើយបដិសេធ ក្នុងញាណដ៏សេសទាំងឡាយ ជាពាក្យរបស់សកវាទី ។

[ ២៦៦ ] បន្ទាប់អំពីនោះ ពាក្យសួរអំពីអសាធារណញ្ញាណ នៃឥន្ទ្រិយបរោបរិយត្តិញ្ញាណ ដោយប្រៀបធៀបនឹងញាណទាំងឡាយ មានឋានាឋានញ្ញាណជាដើម ជាពាក្យរបស់បរវាទី ។ ពាក្យសួរនោះ លោកក៏សម្ដែងដោយសង្ខេប ។ ក្នុងការវិសជ្ជនាបញ្ហានោះ ពាក្យឆ្លើយបដិសេធក្នុងឥន្ទ្រិយបរោបរិយត្តិញ្ញាណ និងពាក្យឆ្លើយទទួល ក្នុងញាណទាំងឡាយដ៏សេស ជាពាក្យរបស់សកវាទី ដោយប្រការដូច្នេះ ៕

**អដ្ឋកថាពលកថា ចប់**

# អភិធម្មបិដក

## អរិយន្តិកថា

[ ២៧៥ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និង មិនមែនហេតុ ជាអរិយៈដែរឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគា-មិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ( ជាអរិយៈ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៦ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និង មិនមែនហេតុ ជាអរិយៈឬ ។ អើ ។ ជាសុញ្ញតារម្មណ៍ ( មានសុញ្ញតនិព្វាន ជាអារម្មណ៍ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជាសុញ្ញតារម្មណ៍ ឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវហេតុ និងមិនមែនហេតុផង ធ្វើទុកក្នុង ចិត្ត នូវសុញ្ញតៈ ( និព្វាន ) ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវហេតុ និងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈ ( និព្វាន ) ផងឬ ។ អើ ។ ( បើដូច្នោះ ) ការប្រជុំចុះនៃផស្សៈទាំងពីរ នៃ ចិត្តទាំង ២ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈឬ ។ អើ ។ ជាអនិមិត្តារម្មណ៍ ( មានអនិមិត្តនិព្វានជាអារម្មណ៍ ) ។បេ។ ជា អប្បណិហិតារម្មណ៍ ( មានអប្បណិតនិព្វានជាអារម្មណ៍ ) ឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ ( បើដូច្នោះ ) បុគ្គលធ្វើទុកក្នុងចិត្ត នូវហេតុ និង មិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវ

អប្បណិហិតៈ( និព្វាន )ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវហេតុ និងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈ ( និព្វាន ) ផងឬ ។ អើ ។ ( បើដូច្នោះ ) ការប្រជុំចុះនៃផស្សៈទាំងពីរ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៧ ] សតិប្បដ្ឋាន ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សតិប្បដ្ឋាន ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៨ ] សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពោជ្ឈង្គ ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៧៩ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ទេឬ ។ អើ ។

សតិប្បដ្ឋាន ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សតិប្បដ្ឋាន ជាអរិយៈ មិនគួរនិយាយថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សម្មប្បធាន ។បេ។ ពោជ្ឈង្គ ជាអរិយៈ មិនគួរនិយាយថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៨០ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( ជាអរិយៈ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨១ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវចុតិ និងបដិសន្ធិរបស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវចុតិ និងបដិសន្ធិ

របស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈផងឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវចុតិ និងបដិសន្ធិរបស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើទុកក្នុងចិត្ត នូវចុតិ និងបដិសន្ធិរបស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈផងឬ ។ អើ ។ ការប្រជុំចុះនៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨២ ] សតិប្បដ្ឋាន ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មប្បធាន ។បេ។ ពោជ្ឈង្គ ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៣ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និង

បដិសន្ធិរបស់ពួកសត្វ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សតិប្បដ្ឋាន ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៤ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សម្មប្បធាន ។បេ។ ពោជ្ឈង្គ ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៥ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៦ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាអរិយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៧ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ មិនគួរពោលថា ជាអរិយៈទេឬ ។ អើ ។ កម្លាំងរបស់ព្រះ

តថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនគួរពោលថា ជាអរិយៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៨៨ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ មិនគួរពោលថា ជាអរិយៈទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនគួរពោលថា ជាអរិយៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ២៨៩ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩០ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩១ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុ និង មិនមែនហេតុ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈ ទាំងឡាយ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ទេឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុង ហេតុ និងមិនមែនហេតុ ជាអរិយៈ មិនគួរពោលថា ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាប តាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩២ ] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិ និង បដិសន្ធិរបស់ពួកសត្វ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ ។បេ។ ជាអនិមិត្តារម្មណ៍ ។បេ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ កម្លាំងរបស់ ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជា អរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

**អរិយន្តិកថា ចប់**

# អដ្ឋកថា

## អរិយន្តិកថា

[ ២៧៥ ] ឥឡូវនេះ នឹងពណ៌នាអំពីអរិយៈដូចតទៅ

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា មិនមែនអាសវក្ខយញ្ញាណ ត្រឹមតែម្យ៉ាងប៉ុណ្ណោះជាអរិយៈ ដោយពិត ញាណខាងដើម ៩ យ៉ាង ដែលជាកម្លាំង ក៏ជាអរិយៈផងដែរ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **អរិយំ** ដូច្នេះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យសួរទៀត ដោយអំណាចនៃមគ្គជាដើមថា ញាណនេះ ក្នុងអរិយមគ្គជាដើម ញាណណាមួយ គប្បីជាអរិយៈឬ ជាពាក្យរបស់សកវាទី ពាក្យឆ្លើយបដិសេធ ជាពាក្យរបស់បរវាទី ។

[ ២៧៦ ] ពាក្យសួរទៀតថា ដោយសុញ្ញតារម្មណ៍ជាដើម ជាពាក្យរបស់សកវាទី ។ ក្នុងពាក្យសួរនោះ សុញ្ញតាមាន ២ យ៉ាង គឺសត្តសុញ្ញតា ការទទេចាកសត្វ ១ សង្ខារសុញ្ញតា ការទទេចាកសង្ខារ ១ ។ បញ្ចក្ខន្ធជាសភាវៈទទេចាកសត្វ ដែលសត្វលោក គប្បីកំណត់ដោយទិដ្ឋិ ឈ្មោះថាសត្តសុញ្ញតា ។ ព្រះនិព្វាន ជាសភាវៈទទេ ស្ងាត់ហើយ ជាធម្មជាតចេញទៅហើយ ចាកសង្ខារទាំងពួង ឈ្មោះថា សង្ខារសុញ្ញតា ។ ក្នុងបញ្ហានោះ បរវាទីសំដៅយកភាពទទេ ដែលជាអារម្មណ៍នៃព្រះនិព្វាន ទើបបដិសេធ តែសំដៅយកភាពទទេ ដែលជាអារម្មណ៍របស់សង្ខារ ទើបឆ្លើយទទួល ។

សូម្បីត្រូវសួរថា **មនសិករោតិ**[១] ក៏បដិសេធ ព្រោះសំដៅយកព្រះនិព្វាន ប៉ុណ្ណោះ រមែងឆ្លើយទទួល ព្រោះសំដៅយកសង្ខារទាំងឡាយ បន្ទាប់អំពីនោះ ត្រូវសកវាទីកាន់យកន័យនេះថា បុគ្គល មានមនសិការក្នុងឋានាឋានញ្ញាណជាដើម មានសង្ខារជាអារម្មណ៍ តែបុគ្គលមានមនសិការក្នុងភាពទទេ មានព្រះនិព្វានជាអារម្មណ៍ សួរថា ជាការប្រជុំនៃផស្សៈ ២ យ៉ាងនៃចិត្ត ២ ដួងឬ បរវាទីនោះ កាលមិនបានឱកាស ដែលមានលេសន័យ ទើបបដិសេធក្នុងអនិមិត្ត និងអប្បណិហិតៈ ក៏ន័យនេះឯង ។ ពិតហើយ ខន្ធទាំងឡាយ ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមាននិមិត្ត គឺសត្វ ព្រះនិព្វានឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានសង្ខារនិមិត្ត ។ ខន្ធទាំងឡាយ ឈ្មោះថា អប្បណិហិតៈ គឺមិនមានទីតាំង ដោយទីតាំងនៃសត្វ ដែលដល់នូវការរាប់ថា បណិធិ ព្រោះអត្ថថា គប្បីតាំងទុក ពោល គឺដែលគេលើកឡើងហើយ គប្បីតាំងទុកក្នុងធម៌ណាមួយ ។ ព្រះនិព្វាន ឈ្មោះថា អប្បណិហិតៈ គឺមិនមានទីតាំង ដោយការតាំងនូវតណ្ហា ឬដោយការតាំងនូវសង្ខារទាំងពួង ដែលជាអារម្មណ៍នៃតណ្ហា ។ ព្រោះហេតុនោះ ក្នុងការវិសជ្ជនានេះ ទាំងពាក្យបដិសេធ និងពាក្យឆ្លើយទទួល បណ្ឌិតគប្បីជ្រាបដោយន័យមុននោះឯង ។

[ ២៧៧ ] បន្ទាប់អំពីនេះ ជាអនុលោម និងបដិលោមបញ្ហាថា លោកុត្តរធម៌ទាំងឡាយ មានសតិប្បដ្ឋានជាដើម ជាអរិយៈផង មានសុញ្ញតៈ

---

១- បិដកខ្មែរជា មនសិករោតិ ( មិនជកឃ្វា ) ។

ជាដើមជាអារម្មណ៍ផង យ៉ាងណា ញាណជាគ្រឿងដឹងឋានៈ និងអឋានៈ ដោយលទ្ធិរបស់អ្នកក៏យ៉ាងនោះឬ ក្នុងការវិសជ្ជនាបញ្ហានោះ ការឆ្លើយទទួលទាំងពួង និងការបដិសេធទាំងពួង ជាពាក្យរបស់បរវាទីនោះឯង ។ បណ្ឌិតគប្បីជ្រាបពាក្យសួរ និងពាក្យឆ្លើយ ក្នុងញាណទាំងឡាយដ៏សេស ដោយឧបាយនេះ ។ តែក្នុងបាលី លោកសង្ខេបញាណដ៏សេស ហើយចែកចុតូបបាតញ្ញាណចុងក្រោយ ។

[ ២៨៥ ] ខាងមុខបន្ទាប់អំពីនេះ ជាពាក្យសួរដល់ភាពជាព្រះអរិយៈទាំងដោយអនុលោម និងដោយបដិលោម នៃញាណទាំងឡាយដ៏សេស ដោយប្រៀបធៀបនឹងអាសវក្ខយញ្ញាណ ដែលសម្រេចហើយថា ជាអរិយៈ ក្នុងលទ្ធិរបស់សកវាទី ។ ពាក្យសួរទាំងពួង ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួលផង ពាក្យបដិសេធផង ជាពាក្យរបស់សកវាទី ។ សេចក្តីទាំងនោះ មានអត្ថងាយយល់ហើយ ឯបាលីក្នុងទីនេះ លោកសង្ខេបញាណទាំង ៧ សម្តែងដោយន័យទី ១ នោះឯង ។

## អដ្ឋកថាអរិយន្តិកថា ចប់

# អភិធម្មបិដក

## វិមុច្ចតិកថា

[ ២៩៣ ] ចិត្តដែលប្រកបដោយរាគៈ រួចស្រឡះ ( ចាកអាសវៈ ) ឬ ។ អើ ។ ចិត្តដែលប្រព្រឹត្តទៅជាមួយនឹងរាគៈ មានកំណើតជាមួយនឹងរាគៈ ច្រឡូកច្រឡំដោយរាគៈ ប្រកបដោយរាគៈ កើតជាមួយនឹងរាគៈ ប្រព្រឹត្តទៅតាមរាគៈ ជាអកុសល ជាលោកិយ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីជោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈស្ទាបអង្អែលហើយ ជាប្រយោជន៍ដល់ឧបាទាន ប្រកបដោយសេចក្តីសៅហ្មង រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៤ ] ចិត្តប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈ និងចិត្តទាំង ២ រួចស្រឡះឬ ។ អើ ។ ចិត្តដែលប្រកបដោយរាគៈ រួចស្រឡះ ចុះរាគៈ និងចិត្តទាំង ២ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៥ ] ចិត្តដែលប្រកបដោយវេទនា ។បេ។ ប្រកបដោយសញ្ញា ។បេ។ ប្រកបដោយចេតនា ។បេ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញា និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ។ ចិត្តដែលប្រកបដោយរាគៈ រួចស្រឡះ ចុះរាគៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៦ ] ចិត្តដែលប្រកបដោយផស្សៈ ប្រកបដោយរាគៈ រួចស្រឡះ ចុះផស្សៈ និងចិត្តទាំង ២ រួចស្រឡះដែរឬ ។ អើ ។ រាគៈ និងចិត្តទាំង ២ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៧ ] ចិត្តប្រកបដោយវេទនា ប្រកបដោយរាគៈ ។បេ។ ប្រកបដោយសញ្ញា ប្រកបដោយរាគៈ ។បេ។ ប្រកបដោយចេតនា ប្រកបដោយរាគៈ ។បេ។ ប្រកបដោយបញ្ញា ប្រកបដោយរាគៈ រួចស្រឡះ ចុះបញ្ញា និងចិត្តទាំង ២ រួចស្រឡះដែរឬ ។ អើ ។ រាគៈ និងចិត្តទាំង ២ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៨ ] ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះឬ ។ អើ ។ ចិត្តដែលប្រព្រឹត្តទៅជាមួយនឹងទោសៈ មានកំណើតជាមួយនឹងទោសៈ ច្រឡូកច្រឡំដោយទោសៈ ប្រកបដោយទោសៈ កើតជាមួយនឹងទោសៈ ប្រព្រឹត្តទៅតាមទោសៈ ជាអកុសល ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្ដីសៅហ្មង រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ២៩៩ ] ចិត្តដែលប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈ និងចិត្តទាំង ២ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈ និងចិត្តទាំង ២ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០០ ] ចិត្តដែលប្រកបដោយវេទនា ។បេ។ ប្រកបដោយសញ្ញា ។បេ។ ប្រកបដោយចេតនា ។បេ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញា និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០១ ] ចិត្តដែលប្រកបដោយផស្សៈ ប្រកបដោយទោសៈ រួចស្រឡះចុះផស្សៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០២ ] ចិត្តដែលប្រកបដោយវេទនា ប្រកបដោយទោសៈ ។បេ។ ប្រកបដោយសញ្ញា ប្រកបដោយទោសៈ ។បេ។ ប្រកបដោយចេតនា ប្រកបដោយទោសៈ ។បេ។ ប្រកបដោយបញ្ញា ប្រកបដោយទោសៈ រួចស្រឡះ ចុះបញ្ញា និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ទោសៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៣ ] ចិត្តដែលប្រកបដោយមោហៈ រួចស្រឡះឬ ។ អើ ។ ចិត្តដែលប្រព្រឹត្តទៅជាមួយនឹងមោហៈ មានកំណើតជាមួយនឹងមោហៈ ច្រឡូកច្រឡំដោយមោហៈ ប្រកបដោយមោហៈ កើតជាមួយនឹងមោហៈ ប្រព្រឹត្តទៅតាមមោហៈ ជាអកុសល ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៤ ] ចិត្តដែលប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយមោហៈ រួចស្រឡះ ចុះមោហៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៥ ] ចិត្តដែលប្រកបដោយវេទនា ។បេ។ ប្រកបដោយសញ្ញា ។បេ។ ប្រកបដោយចេតនា ។បេ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញា និងចិត្ត

ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយមោហៈ រួចស្រឡះចុះមោហៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៦ ] ចិត្តដែលប្រកបដោយផស្សៈ ប្រកបដោយមោហៈ រួចស្រឡះចុះផស្សៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៧ ] ចិត្តដែលប្រកបដោយវេទនា ប្រកបដោយមោហៈ ។បេ។ ប្រកបដោយសញ្ញា ប្រកបដោយមោហៈ ។បេ។ ប្រកបដោយចេតនា ប្រកបដោយមោហៈ ។បេ។ ប្រកបដោយបញ្ញា ប្រកបដោយមោហៈ រួចស្រឡះ ចុះបញ្ញា និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈ និងចិត្តទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣០៨ ] បុគ្គលមិនគួរនិយាយថា ចិត្តដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រួចស្រឡះទេឬ ។ អើ ។ ចិត្តដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានកិលេស រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ចិត្តដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រមែងរួចស្រឡះ ( ចាកអាសវៈ ) ។

**វិមុច្ចតិកថា ចប់**

# អដ្ឋកថា

## វិមុត្តិកថា

[ ២៩៣ ] ឥឡូវនេះ នឹងពណ៌នាអំពីវិមុត្តិ គឺការរួចផុតដូចតទៅ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា ឈ្មោះថា កិច្ចបដិបត្តិដើម្បីការរួចផុតរបស់ចិត្តដែលប្រាសចាករាគៈហើយ មិនមាន ដូចសំពត់ដែលបោកគក់យកមន្ទិលចេញ រមែងផុតចាកមន្ទិលបាន យ៉ាងណា ចិត្តមានរាគៈ ក៏យ៉ាងនោះ រមែងរួចផុតចាករាគៈបាន ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា **សរាគំ** ដូច្នេះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បន្ទាប់អំពីនោះ បរវាទីត្រូវសួរដោយន័យជាដើមថា **រាគសហគតំ** ក៏បដិសេធដោយសំដៅយកថា ក្នុងខណៈនៃមគ្គចិត្ត ចិត្តនោះ ឈ្មោះថា រមែងរួចផុតតែក្នុងកាលនោះ ចិត្តបែបនេះ ( ចិត្តមានរាគៈជាដើម ) រមែងមិនមាន ។

[ ២៩៤ ] ត្រូវសួរដោយន័យថា **សផស្សំ** ជាដើម បរវាទីកាលមិនឃើញការរួចផុតចាករាគៈ ដូចធម៌ទាំង ២ គឺផស្សៈ និងចិត្តរួចផុតចាករាគៈ ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងចិត្តមានទោសៈជាដើម បណ្ឌិតគប្បីជ្រាបអត្ថ ដោយឧបាយនេះឯង ៕

**អដ្ឋកថាវិមុត្តិកថា ចប់**

# អភិធម្មបិដក

## វិមុច្ចមានកថា

[ ៣០៩ ] ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១០ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គលជាសោតាបន្ន មួយផ្នែក មិនមែនជាសោតាបន្ន មួយផ្នែក បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ប្រកបដោយសីល ជាទីត្រេកអរ នៃព្រះអរិយៈទាំងឡាយ មួយផ្នែក មិនប្រកបដោយសីល ជាទីត្រេកអរ នៃព្រះអរិយៈទាំងឡាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១១ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសកទាគាមី មួយផ្នែក មិនមែនជាសកទាគាមី មួយផ្នែក បុគ្គល ដល់នូវសកទាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។

[ ៣១២ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គលជាអនាគាមី មួយផ្នែក មិនមែនជាអនាគាមី មួយផ្នែក បុគ្គលដល់នូវអនាគាមិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក ជាអន្តរាបរិនិព្វាយី ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ជាឧទ្ធំសោតអកនិដ្ឋគាមី មួយផ្នែក មិនមែនជាឧទ្ធំសោតៈ មិនមែនជាអកនិដ្ឋគាមី មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៣ ] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាអរហន្ត មួយផ្នែក មិនមែនជាអរហន្ត មួយផ្នែក បុគ្គល ដល់នូវអរហត្ត ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក បុគ្គល ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មួយផ្នែក ។បេ។ សច្ឆិកាតព្វកិច្ច លោកបានធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក សច្ឆិកាតព្វកិច្ច លោកមិនបានធ្វើឲ្យជាក់ច្បាស់ហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេឬ ។បេ។

[ ៣១៤ ] ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តដែលរួចស្រឡះហើយ ក្នុងខណៈដែលកើតឡើង ចិត្តកំពុងរួចស្រឡះ

ក្នុងខណៈសាបសូន្យ មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៥ ] បុគ្គល មិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចស្រឡះ ចាកកាមាសវៈផង ចិត្តរួចស្រឡះ ចាកភវាសវៈផង ចិត្តរួចស្រឡះ ចាកអវិជ្ជាសវៈផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ចិត្ត ឈ្មោះថា រួចស្រឡះហើយ ឈ្មោះថា កំពុងរួចស្រឡះ ។

[ ៣១៦ ] ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ ( ឈ្មោះថា រួច ) មែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាលដែលចិត្ត ខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ បុគ្គលនោះ រមែងបង្អោនចិត្ត ដើម្បីញាណ ជាហេតុឲ្យអស់ទៅនៃអាសវៈទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរពោលថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះទេ ។

[ ៣១៧ ] ចិត្តកំពុងរួចស្រឡះ មានឬ ។ អើ ។ ចិត្តកំពុងត្រេកអរ កំពុងទឹង កំពុងវង្វេង កំពុងសៅហ្មង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងចិត្តដែលត្រេកអរផង មិនត្រេកអរផង ទឹងផង មិនទឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានឬ ។ អើ ។ ប្រសិនបើចិត្តត្រេកអរផង មិនត្រេកអរផង ទឹងផង មិនទឹងផង វង្វេងផង មិនវង្វេងផង ដាច់ផង មិនដាច់ផង បែកផង មិនបែកផង ធ្វើផង មិនធ្វើផង មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តកំពុងរួចស្រឡះ មានទេ ។

## វិមុច្ចមានកថា ចប់

# អដ្ឋកថា

## វិមុច្ចមានកថា

[ ៣០៩ ] ឥឡូវនេះ នឹងពោលអំពីចិត្តរួចស្រឡះដូចតទៅ

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិថា ចិត្តរួចផុតហើយ ដោយវិក្ខម្ភនវិមុត្តិដោយឈាន ឈ្មោះថា រួចផុតដោយសមុច្ឆេទវិមុត្តិ ក្នុងខណៈនៃមគ្គ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **វិមុត្តំ វិមុច្ចមានំ** ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ សកវាទីសួរទៀតថា **ឯកទេសំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឯកទេសំ** ជានបុំសកលិង្គសម្តែងភាវៈ ។ លោកសួរថា ចិត្តរួចផុតហើយ ជាចិត្តដែលមិនរួចផុតចំណែកមួយ ឬមិនរួចផុតក្នុងចំណែកខ្លះ យ៉ាងណា ចិត្តនោះ ចំណែកមួយ រួចផុតហើយ តែចំណែកមួយទៀត មិនរួចផុតហើយ យ៉ាងនោះឬ ។ សួរថា សកវាទីរមែងសួរយ៉ាងនេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបរវាទីនោះ ពោលដោយភាវៈដែលផ្អាកថា ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ ដូច្នេះ ដូចវត្ថុទាំងឡាយ មានបន្ទះជាដើម ជារបស់ធ្វើស្រេចហើយចំណែកខ្លះ ចំណែកខ្លះមិនទាន់សម្រេច ព្រោះភាពដែលរបស់នោះនៅផ្អាកនៅឡើយ យ៉ាងណា ចិត្តនេះ ក៏រមែងប្រាកដថា ចំណែកមួយ រួចផុតហើយ ចំណែកមួយទៀត មិនទាន់រួចផុត យ៉ាងនោះ ។

លំដាប់នោះ បរវាទីឆ្លើយបដិសេធក្នុងបញ្ហាដំបូង ព្រោះចិត្តមិនមានចំណែកខ្លះ ដូចចំណែកនៃបន្ទះជាដើម ក្នុងបញ្ហាទី ២ ឆ្លើយទទួល ព្រោះ

ចិត្តនោះ កំពុងរួចផុត មិនមែនរួចផុតស្រេចហើយ ។ ម្យ៉ាងទៀត លោក ឆ្លើយបដិសេធ សំដៅយកលក្ខណៈនៃលោកិយជ្ឈាន ។ ពិតហើយ ចិត្តនោះ មិនមែនកំពុងរួចផុតដោយសមុច្ឆេទវិមុត្តិ ក្នុងកាលនោះ ។ បរវាទីឆ្លើយ ទទួល សំដៅយកលក្ខណៈនៃលោកុត្តរជ្ឈាន ។ លទ្ធិរបស់លោកថា ក្នុង កាលនោះ ចិត្តនោះ កំពុងរួចផុតដោយសមុច្ឆេទវិមុត្តិ ដោយការរួចផុត ចំណែកខ្លះ ដូច្នេះ ។

[ ៣១០ ] លំដាប់នោះ ទើបសកវាទីពោលថា **ឯកទេសំ សោតាបន្នោ** ជាដើម ដើម្បីចោទសួរថា បើតាមលទ្ធិរបស់អ្នក ចិត្តដួងនោះឯង រួចផុត បានចំណែកមួយ មួយចំណែកទៀត មិនទាន់រួចផុតបានសោត កាលបើ ភាពយ៉ាងនោះមាន បុគ្គលណា ជាព្រះសោតាបន្នដោយចិត្ត ១ ដួងនោះឯង បុគ្គលនោះ ក៏ជាព្រះសោតាបន្នត្រឹមតែចំណែកមួយ មិនជាចំណែកមួយបាន ដោយចិត្តដួងនោះ ដូច្នេះ ។ បរវាទី កាលមិនឃើញបែបផែននោះ ទើប ឆ្លើយបដិសេធ ។ ក្នុងវារៈដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។

[ ៣១៤ ] ក្នុងបញ្ហាពោលដោយចិត្តរួចផុតហើយ ក្នុងខណៈកើតឡើង អធិប្បាយថា បើចិត្ត ១ ដួងនោះ រួចផុតហើយផង កំពុងរួចផុតផងសោត ចិត្តរួចផុតហើយក្នុងខណៈមួយ កំពុងរួចផុតក្នុងខណៈមួយ ក៏រមែងត្រឹមត្រូវ ចិត្តបែបនេះ មានតាមលទ្ធិរបស់អ្នកឬ ។

[ ៣១៥-៣១៦ ] ក្នុងការអះអាងដោយព្រះសូត្រ ព្រះសូត្រដំបូងជា របស់បរវាទី ។ ក្នុងព្រះសូត្រនោះ បំណងរបស់បរវាទីនោះ មានដូច្នេះថា

បទថា **វិមុច្ចតិ** ជាការចង្អុលបង្ហាញ ដែលនៅមានចំណែកផ្អាកនៅឡើយ ព្រោះហេតុនោះ កាលយោគីបុគ្គលនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តណា រមែងរួចផុតចាកអាសវៈទាំងនេះ ចិត្តនោះ ឈ្មោះថា កំពុងរួចផុត ។ ព្រះសូត្រទី ២ ជារបស់សកវាទី បំណងរបស់សកវាទីនោះ មានដូច្នេះថា បើចិត្តរួចផុតហើយ ឈ្មោះថា កំពុងរួចផុត ព្រោះព្រះបាលីថា រមែងរួចផុត តាមលទ្ធិរបស់អ្នកមានសោត ចិត្តនោះ ក៏គប្បីរួចផុតហើយនោះឯង មិនមែនកំពុងរួចផុត ព្រោះមិនមានពាក្យបាលី ក្នុងព្រះសូត្រនេះថា រមែងរួចផុត ដូច្នេះ ។

ឥឡូវនេះ ដើម្បីសួរថា ចិត្ត ឈ្មោះថា កំពុងរួចផុត ព្រោះការរួចផុតដែលកំពុងផ្អាកតាមលទ្ធិរបស់អ្នកមាន យ៉ាងណា សូម្បីចិត្តដែលកំពុងត្រេកត្រអាលជាដើម ក៏រមែងមាន ព្រោះរាគៈកំពុងផ្អាកជាដើមយ៉ាងនោះឬ ទើបផ្តើមពាក្យទៀតថា **អត្ថិ ចិត្តំ** ដូច្នេះជាដើម ។ បរវាទី កាលមិនឃើញចិត្តបែបនោះ ទើបបដិសេធទាំងអស់ ។ លំដាប់នោះ សកវាទី កាលញ៉ាំងបរវាទីឲ្យដឹងថា ទីបំផុតមាន ២ យ៉ាងប៉ុណ្ណោះ ចំណែកទី ៣ មិនមាន ទើបពោលពាក្យថា **ឆន្ទុ រត្តញ្ចេវ អរត្តញ្ច** ជាដើម ។ គប្បីជ្រាបអត្ថនៃបញ្ហានោះថា អ្នកមានមុខល្អ ទីបំផុតមាន ២ យ៉ាងប៉ុណ្ណោះ គឺចិត្ត សម្បយុត្តហើយដោយរាគៈ ឈ្មោះថា ចិត្តត្រេកត្រអាលហើយ ចិត្តប្រាសចាករាគៈហើយ ឈ្មោះថា ចិត្តមិនត្រេកត្រអាលហើយ មិនមែនឬ ទីបំផុតទី ៣ គឺចិត្ត ឈ្មោះថា កំពុងត្រេកត្រអាល រមែងមិនមាន ។ ក្នុងពាក្យថា ចិត្តអាក់អន់

ជាដើម ក៏ន័យនេះឯង ។ លំដាប់នោះ សកវាទី ញុំាងបរវាទីឲ្យទទួលថា **អាមន្តា** ដើម្បីសម្តែងទីបំផុតទាំង ២ នោះឯង ក្នុងចំណែកចិត្តវិមុត្តិ ទើបពោលថា **ហញ្ចិ រត្តញ្ចេវ** ជាដើម ។ អត្ថនៃបញ្ហានោះ គប្បីជ្រាបថា បើអ្នកទទួលទីបំផុតទាំង ២ នេះ ចូរអ្នកទទួលចិត្តទាំងនេះ គឺចិត្តមិនរួចផុតហើយ និងចិត្តរួចផុតហើយ ពិតហើយ ចិត្តដែលសម្បយុត្តដោយកិលេស ឈ្មោះថា មិនរួចផុតហើយ ចិត្តប្រាសចាកកិលេស ឈ្មោះថា រួចផុតហើយ កាលពោលដោយបរមត្ថទីបំផុតទី ៣ ថា ចិត្ត ឈ្មោះថា កំពុងរួចផុត ដូច្នេះ រមែងមិនមាន ដូច្នេះ ៕

## អដ្ឋកថាវិមុច្ចមានកថា ចប់

# អភិធម្មបិដក

## អដ្ឋមកកថា

[ ៣១៨ ] ទិដ្ឋិបរិយុដ្ឋាន ( ការស្មុគស្មាញដោយទិដ្ឋិ ) គឺបុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្ន ដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣១៩ ] វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ជាសោតាបន្ន ដល់នូវសោតាបត្តិផល ។បេ។ ពាល់ត្រូវដោយនាមកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២០ ] ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយ ។បេ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២១ ] វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ លះបង់ហើយឬ ។ អើ ។ ទិដ្ឋានុស័យ បុគ្គលទី ៨ លះបង់ហើយឬ ។បេ។ សីលព្វតបរាមាសៈ លោកលះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២២ ] ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទិដ្ឋានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិចិកិច្ឆានុស័យ បុគ្គលទី ៨ មិនបានលះបង់ទេ ។បេ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីលព្វតបរាមាសៈ បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ មិនបានលះបង់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៣ ] ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ បានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ បានលះបង់ទិដ្ឋិបរិយុដ្ឋានឬ ។ អើ ។ បុគ្គលទី ៨ បានចម្រើនសតិប្បដ្ឋាន ។បេ។ សម្មប្បធាន ។បេ។ បានចម្រើនពោជ្ឈង្គដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៤ ] វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ បានចម្រើនមគ្គ ។បេ។ បានចម្រើនពោជ្ឈង្គ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៥ ] បុគ្គលទី ៨ មិនបានចម្រើនមគ្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋាន

ទេឬ ។ អើ ។ បរិយុដ្ឋានក្កិលេស គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងមែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនបានចម្រើនសតិប្បដ្ឋាន ។បេ។ មិនបានចម្រើនពោជ្ឈង្គ ដើម្បីលះបង់ទិដ្ឋិបរិយុដ្ឋានទេឬ ។ អើ ។ ( បរិយុដ្ឋានក្កិលេស ) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងមែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៦ ] បុគ្គលទី ៨ មិនបានចម្រើនមគ្គ ។បេ។ សតិប្បដ្ឋាន ។បេ។ មិនបានចម្រើនពោជ្ឈង្គ ដើម្បីលះបង់វិចិកិច្ឆាបរិយុដ្ឋានទេឬ ។ អើ ។ ( បរិយុដ្ឋានក្កិលេស ) គឺលោកលះបង់ហើយ ដោយធម៌មិនមែនជាមគ្គ ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងមែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣២៧ ] បុគ្គលមិនគួរពោលថា ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ ទិដ្ឋិបរិយុដ្ឋាន នឹងកើតឡើងឬ ។ ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើងទេ ។ ប្រសិនបើ ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទិដ្ឋិបរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយ ។

[ ៣២៨ ] បុគ្គលមិនគួរពោលថា វិចិកិច្ឆាបរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយឬ ។ អើ ។ វិចិកិច្ឆាបរិយុដ្ឋាន នឹងកើតឡើងឬ ។ វិចិកិច្ឆា-

បរិយុដ្ឋាន នឹងមិនកើតឡើងទេ ។ ប្រសិនបើ វិចិកិច្ឆាបរិយុដ្ឋាន នឹងមិនកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិចិកិច្ឆា-បរិយុដ្ឋាន បុគ្គលទី ៨ បានលះបង់ហើយ ។

[ ៣២៩ ] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋានុស័យ នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣០ ] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា វិចិកិច្ឆានុស័យ ។បេ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣១ ] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា វិចិកិច្ឆាបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អើ ។ បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា វិចិកិច្ឆានុស័យ ។បេ។ សីលព្វតបរាមាសៈ នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣២ ] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អើ ។ បុគ្គលជាទីគោត្រភូ ធ្វើសេចក្តីចូលចិត្តថា ទិដ្ឋិបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៣ ] បុគ្គលទី ៨ ធ្វើសេចក្តីចូលចិត្តថា វិចិកិច្ឆានបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អើ ។ បុគ្គលជាគោត្រភូ ធ្វើសេចក្តីចូលចិត្តថា វិចិកិច្ឆាបរិយុដ្ឋាន នឹងមិនកើតឡើង ឈ្មោះថា លះបង់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**អដ្ឋមកកថា ចប់**

# អដ្ឋកថា

## អដ្ឋមកកថា

[ ៣១៨ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលទី ៨ គឺព្រះអរិយបុគ្គល ដែលតាំងនៅក្នុងសោតាបត្តិមគ្គដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈ និងនិកាយសម្មិតិយៈទាំងឡាយ ក្នុងខណៈនេះថា បុគ្គលតាំងនៅក្នុងសោតា-បត្តិមគ្គ ដែលជាបុគ្គលទី ៨ លះបរិយុដ្ឋានក្កិលេសទាំង ២ គឺទិដ្ឋិ និងវិចិកិច្ឆា បានហើយ ព្រោះមិនមានកិលេសទាំងឡាយកើតឡើង ក្នុងខណៈនៃអនុលោម គោត្រភូ និងមគ្គ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនពួកណាមួយ នៃជនទាំងនោះ ។ ពាក្យឆ្លើយទទួលរបស់បរវាទី សំដៅយកការមិនកើតឡើងនៃទិដ្ឋិ ចាប់អំពីខណៈនៃមគ្គ ។ ព្រោះធម្មតា ទិដ្ឋិនេះ ព្រះសោតាបន្ន ជាបុគ្គលលះហើយ មិនមែនបុគ្គលដែលតាំងនៅក្នុងមគ្គ ព្រោះហេតុនោះ ទើបសកវាទីសួរថា **អដ្ឋមកោ បុគ្គលោ សោតាបន្នោ** ដូច្នេះជាដើម ។

[ ៣១៩ ] ក្នុងបញ្ហាពោលអំពីវិចិកិច្ឆា ក៏ន័យនេះឯង ។

[ ៣២០ ] ក្នុងបញ្ហាពោលអំពីអនុស័យ លទ្ធិរបស់ជនទាំងនោះថា អនុស័យដទៃក្រៅអំពីបរិយុដ្ឋានក្កិលេស ព្រោះហេតុនោះ ទើបឆ្លើយបដិសេធថា **ន ហេវំ** ដូច្នេះ ។

ក្នុងបញ្ហាពោលអំពីសីលព្វតបរាមាសៈ បរវាទីមិនឃើញវោហារថា គ្រឿងបោមពោម គឺសីលព្វតបរាមាសៈ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។ លទ្ធិ

របស់បរវាទីថា បុគ្គលទី ៨ លះបរិយុដ្ឋានបានហើយប៉ុណ្ណោះ ។

[ ៣២៣ ] ក្នុងបញ្ហាថា **មគ្គោ ភាវិតោ** សេចក្តីថា ក្នុងខណៈនោះ បុគ្គលទី ៨ កំពុងចម្រើនមគ្គ មិនមែនចម្រើនស្រេចហើយ ព្រោះហេតុនោះ ទើបលោកឆ្លើយបដិសេធ ។

[ ៣២៥ ] ក្នុងពាក្យសួរថា **អមគ្គេន** ជាដើម បរវាទីឆ្លើយបដិសេធ សំដៅយកភាពដែលកិលេសទាំងនោះ ត្រូវលះបានហើយដោយមគ្គទី ១ នោះឯង ព្រោះថា លទ្ធិរបស់លោកថា បើបុគ្គលគប្បីលះកិលេសដោយធម៌ដែលមិនមែនជាមគ្គបានសោត បុគ្គលសូម្បីជាគោត្រភូបុគ្គលជាដើម ក៏គប្បីលះកិលេសបាន ។

[ ៣២៧ ] ពាក្យសួរថា **ឧប្បជ្ជិស្សតិ** ជាពាក្យរបស់បរវាទី ។ ពាក្យវិសជ្ជនា ជាពាក្យរបស់សកវាទី ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាអដ្ឋមកកថា ចប់

# អភិធម្មបិដក

## អដ្ឋមកឥន្ទ្រិយកថា

[ ៣៣៤ ] បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៥ ] បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយ ។បេ។ មិនមានសតិន្ទ្រិយ ។បេ។ មិនមានសមាធិន្ទ្រិយ ។បេ។ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មិនមានបញ្ញាទេឬ ។ អ្នកមិនគួរពោលយ៉ាងទេ ។បេ។

[ ៣៣៦ ] បុគ្គលទី ៨ មានសទ្ធាដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មានវីរិយៈ ។បេ។ មានសតិ មានសមាធិ ។បេ។ មានបញ្ញាដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៧ ] បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មានមនោ មានមនិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៣៨ ] បុគ្គលទី ៨ មានសោមនស្ស មានសោមនស្សិន្ទ្រិយ ។បេ។ មានជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៥ មានជីវិត មានជីវិតិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានវីរិយៈ ។បេ។ មាន

បញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៣៣៩] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី៨ មានតែមនោ មិនមានមនិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ។បេ។

[ ៣៤០ ] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។បេ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤១ ] បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ មានតែមនោ មិនមានមនិន្ទ្រិយ ។បេ។ មានតែសោមនស្ស មិនមានសោមនស្សិន្ទ្រិយ ។បេ។ មានតែជីវិត មិនមានជីវិតិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤២ ] បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមិនមានសទ្ធាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនមានវីរិយិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកខ្ជិលច្រអូស មិនមានព្យាយាមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនមានសតិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកភ្លេចស្មារតី មិនដឹងខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មិនមានសមាធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តរាយមាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៣៤៣ ] បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលទី ៨

ជាអ្នកឥតប្រាជ្ញា ជាមនុស្សល្ងង់ខ្លៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៤ ] បើបុគ្គលទី ៨ មានសទ្ធា ចុះសទ្ធានោះ ជាធម្មជាតនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទី ៨ មានសទ្ធា សទ្ធានោះឯង ជាធម្មជាតនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយទេ ។ បុគ្គលទី ៨ មានវិរិយៈ ចុះវិរិយៈនោះ ជាធម្មជាតនាំសត្វចេញចាកទុក្ខ ។បេ។ មានសតិ ចុះសតិនោះជាធម្មជាតនាំសត្វចេញចាកទុក្ខ ។បេ។ មានសមាធិ ចុះសមាធិនោះ ជាធម៌នាំសត្វចេញចាកទុក្ខ ។បេ។ មានបញ្ញា ចុះបញ្ញានោះ ជាធម្មជាតនាំសត្វចេញចាកទុក្ខដែរឬ ។ អើ ។ ប្រសិនបើបុគ្គលទី៨ មានបញ្ញា បញ្ញានោះឯងជាធម្មជាតនាំសត្វចេញចាកទុក្ខមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទី ៨ មិនមានបញ្ញិន្ទ្រិយទេ ។

[ ៣៤៥ ] បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៤៦ ] បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ។បេ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានសទ្ធា មាន

សទ្ធិន្ទ្រិយ ។បេ។ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អើ ។ បុគ្គលទី ៨ មានបញ្ញា មានបញ្ញិន្ទ្រិយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៧ ] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលទី ៨ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៨ ] បុគ្គលទី ៨ មានតែសទ្ធា មិនមានសទ្ធិន្ទ្រិយទេ ។បេ។ មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អើ ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ។បេ។ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត មានតែបញ្ញា មិនមានបញ្ញិន្ទ្រិយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៩ ] បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាង តើដូចម្តេច ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបានឈ្មោះថា អរហន្ត ព្រោះមានឥន្ទ្រិយទាំង ៥ នេះឯងសម្រេចបរិបូណ៌ បុគ្គលដែលបានឈ្មោះថា អ្នក

ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលជាអរហន្តនោះ បុគ្គលដែលបានឈ្មោះថា អនាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះ បុគ្គលដែលបានឈ្មោះថា អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលជាអនាគាមីនោះ បុគ្គលដែលបានឈ្មោះថា សកទាគាមី ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះ បុគ្គលដែលបានឈ្មោះថា អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលជាសកទាគាមីនោះ បុគ្គលដែលបានឈ្មោះថា សោតាបន្ន ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់អ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលនោះ បុគ្គលដែលបានឈ្មោះថា អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ព្រោះមានឥន្ទ្រិយទាំងឡាយ ទន់ជាងឥន្ទ្រិយរបស់បុគ្គលជាសោតាបន្ននោះ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មិនមានឥន្ទ្រិយទាំង ៥ នេះ សព្វគ្រប់ឥតខ្វះ ដោយប្រការទាំងពួងទេ តថាគតហៅបុគ្គលនោះថា ជាអ្នកតាំងនៅក្នុងពួកបុថុជ្ជន ជាខាងក្រៅ ពាក្យដូច្នេះ មានក្នុងប្រសូត្រឬ ។ អើ ។ បុគ្គលទី ៨ ឈ្មោះថា តាំងនៅក្នុងពួកបុថុជ្ជន ជាខាងក្រៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បុគ្គលទី ៨ ក៏មានឥន្ទ្រិយ ៥ ដែរ ។

# អដ្ឋកថា

## អដ្ឋមកស្ស ឥន្ទ្រិយកថា

[ ៣៣៤ ] ឥឡូវនេះ នឹងពណ៌នាអំពីឥន្ទ្រិយរបស់បុគ្គលទី ៨ តទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈ ក្នុងខណៈនេះថា បុគ្គលទី ៨ រមែងបាននូវឥន្ទ្រិយទាំងឡាយ ក្នុងខណៈនៃមគ្គកើត មិនមែនបានមកមុន ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **នត្ថិ សទ្ធិន្ទ្រិយំ ៗ** ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បរវាទីត្រូវសួរថា **នត្ថិ សទ្ធា** កំណត់យកភាពដែលសទ្ធាផ្សេងអំពីសទ្ធិន្ទ្រិយ ទើបឆ្លើយបដិសេធ ក្នុងបញ្ហាដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។

[ ៣៣៧ ] សកវាទីផ្ដើមពាក្យជាដើមថា **អត្ថិ សទ្ធា អត្ថិ សទ្ធិន្ទ្រិយំ** ដូច្នេះ ដើម្បីសម្ដែងថា ដូចជាចិត្តរបស់បុគ្គលណាមាន សូម្បីមនិន្ទ្រិយរបស់បុគ្គលនោះក៏មាន យ៉ាងណា សទ្ធាជាដើម របស់បុគ្គលណាមានឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម របស់បុគ្គលនោះក៏មាន ក៏យ៉ាងនោះ ។ ពាក្យទាំងអស់ ព្រមទាំងការអះអាងដោយព្រះសូត្រ មានអត្ថងាយយល់ហើយ ដូច្នេះ ។៚

**អដ្ឋកថាអដ្ឋមកស្ស ឥន្ទ្រិយកថា ចប់**

# អភិធម្មបិដក

## ធិព្វចក្ខុកថា

[ ៣៥០ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ មំសចក្ខុ គឺទិព្វចក្ខុ ឯទិព្វចក្ខុ គឺមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥១ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។អើ ។ មំសចក្ខុដូចម្តេច ទិព្វចក្ខុក៏ដូច្នោះ ទិព្វចក្ខុដូចម្តេច មំសចក្ខុក៏ដូច្នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥២ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។អើ ។ មំសចក្ខុនោះឯង គឺទិព្វចក្ខុនោះ ទិព្វចក្ខុនោះ គឺមំសចក្ខុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៣ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។អើ ។ មំសចក្ខុ មានវិស័យ មានអានុភាព មានគោចរដូចម្តេច ទិព្វចក្ខុក៏មានវិស័យ មានអានុភាព មានគោចរ ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៤ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។អើ ។ ( មំសចក្ខុ ) ជាឧបាទិន្ន ទៅជា ( ទិព្វចក្ខុ ) អនុបាទិន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៥ ] ឧបាទិន្ន ទៅជាអនុបាទិន្ន ឬ ។ អើ ។ កាមាវចរ ទៅជារូបាវចរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៦ ] កាមាវចរ ទៅជារូបាវចរឬ ។ អើ ។ រូបាវចរទៅជាអរូបាវចរ

ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៧ ] រូបាវចរ ទៅជាអរូបាវចរឬ ។ អើ ។ បរិយាបន្ន ទៅជាអបរិយាបន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៨ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៥៩ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាបញ្ញាចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦០ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ទិព្វចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាមំសចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦១ ] មំសចក្ខុ ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វចក្ខុឬ ។ អើ ។ ចក្ខុទាំងឡាយ មានតែ ២ ប៉ុណ្ណោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦២ ] ចក្ខុទាំងឡាយ មានតែ ២ ប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចក្ខុទាំងឡាយ មាន ៣ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ដូច្នេះមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុទាំងឡាយ មានតែ

២ ប៉ុណ្ណោះទេ ។

[ ៣៦៣ ] ចក្ខុទាំងឡាយ មានតែ ២ ប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ ។ ចក្ខុទាំង ៣ តើដូចម្តេច ។ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ម្នាលភិក្ខុទាំងឡាយ ចក្ខុទាំងឡាយ មាន ៣ យ៉ាងនេះឯង ។

បុរសឧត្តម បានពោលថា ចក្ខុទាំងឡាយ មាន ៣ ប៉ុណ្ណោះ
គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ជាធម្មជាតដ៏ប្រសើរ ១
ការកើតឡើងនៃមំសចក្ខុ ជាផ្លូវនាំឲ្យកើតឡើងនៃទិព្វចក្ខុ កាល
ណា បើញាណកើតឡើងហើយ បញ្ញាចក្ខុដ៏ប្រសើរ ( ក៏កើត
ឡើង កាលនោះដែរ ) បុគ្គលរួចស្រឡះ ចាកទុក្ខទាំងអស់
ព្រោះតែបានបញ្ញាចក្ខុនោះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចក្ខុទាំងឡាយ មានតែ ២ ប៉ុណ្ណោះទេ ។

**ទិព្វចក្ខុកថា ចប់**

# អដ្ឋកថា

## ទិព្វចក្ខុកថា

[ ៣៥០ ] ឥឡូវនេះ នឹងពណ៌នាអំពីទិព្វចក្ខុដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈ និងនិកាយសមិតិយៈទាំងឡាយ ក្នុងខណៈនេះថា មំសចក្ខុនោះឯង ដែលធម៌ គឺចតុត្ថជ្ឈានឧបត្ថម្ភហើយ ឈ្មោះថា ជាទិព្វចក្ខុ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **មំសចក្ខុំ** ដូច្នេះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក៏ត្រូវសួរទៀតថា **មំសចក្ខុ ទិព្វចក្ខុ ទិព្វចក្ខុ មំសចក្ខុ** បរវាទីបដិសេធថា មំសចក្ខុនោះត្រឹមតែជាមំសចក្ខុប៉ុណ្ណោះ មិនមែនដទៃ ។

[ ៣៥១ ] ក្នុងពាក្យសួរទាំងឡាយថា **យាទិសំ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះភាពដែលចក្ខុទាំង ២ នោះ មិនមានសភាពដូចគ្នា ។

[ ៣៥៣ ] ក្នុងបញ្ហា មានពាក្យថា **វិសយោ** ជាដើម សេចក្តីថា រូបាយតនៈនោះឯង ជាវិស័យនៃចក្ខុទាំង ២ អធិប្បាយថា មំសចក្ខុ រមែងឃើញរូបដែលមកកាន់គន្លងនៃចក្ខុប៉ុណ្ណោះ ឯទិព្វចក្ខុ រមែងឃើញរូបដែលមិនមកកាន់គន្លងនៃចក្ខុបាន សូម្បីរូបនោះ មានភ្នំបាំងជាដើម ។ម្យ៉ាងទៀត រូបល្អិតក្រៃលែង ក៏ជាគោចរ គឺជាអារម្មណ៍នៃទិព្វចក្ខុបាន តែរូបបែបនេះ ជាអារម្មណ៍របស់មំសចក្ខុមិនបានឡើយ ព្រោះហេតុនោះ អានុភាព គឺអំណាច និងគោចរ គឺអារម្មណ៍នៃចក្ខុទាំង ២ នេះ ទើបមិនដូចគ្នា ដោយប្រការដូច្នេះ ។

[ ៣៥៤ ] ត្រូវសួរថា **ឧបាធិគ្នំ ហុត្វា អនុបាធិគ្នំ ហោតិ** ព្រោះបរវាទីកាន់យកថា មំសចក្ខុ ជាឧបាទិន្ន ឯទិព្វចក្ខុ ជាអនុបាទិន្ន ទាំងមំសចក្ខុនោះឯង ក៏មិនជាទិព្វចក្ខុ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។

[ ៣៥៥ ] ត្រូវសួរលើកទី ២ បរវាទីកាន់យកថា ព្រោះទិព្វចក្ខុរមែងកើតឡើង ព្រោះមំសចក្ខុជាបច្ច័យ ព្រោះអាស្រ័យព្រះបាលីថា ការកើតឡើងនៃមំសចក្ខុ ជាផ្លូវនៃទិព្វចក្ខុ ដូច្នេះ ទាំងទិព្វចក្ខុនោះ ក៏ជាការផូរផង់នៃមហាភូតរូបទាំង ៤ ដែលប្រព្រឹត្តទៅក្នុងរូបាវចរ ព្រោះហេតុនោះទើបឆ្លើយទទួល ។ ត្រូវសួរថា **កាមាវចរំ** ព្រោះបរវាទីមិនកាន់យកថា មំសចក្ខុនោះឯង ជាទិព្វចក្ខុ ហេតុនោះ ទើបឆ្លើយបដិសេធ ។

[ ៣៥៦ ] ត្រូវសួរលើកទី ២ បរវាទីក៏ឆ្លើយទទួល ព្រោះគិតថា ធម្មតារូបាវចរកើត ព្រោះភាពកើតឡើងហើយ ដោយមានរូបាវចរជ្ឈានជាបច្ច័យ ។ ត្រូវសួរថា **រូបាវចរំ ហុត្វា អរូបាវចរំ** បរវាទីក៏ឆ្លើយបដិសេធ ព្រោះការមិនមានរូបាវចរចិត្តក្នុងខណៈ នៃរូបាវចរដោយការភាវនាបន្តអំពីនេះទៅ ។

[ ៣៥៧ ] ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះលទ្ធិថា អរូបាវចរជាភាពផូរផង់នៃមហាភូតរូបទាំង ៤ ដែលប្រព្រឹត្តទៅក្នុងអរូបាវចរ ហើយរមែងកើតឡើង តែបរវាទីនោះ មិនកាន់យកថា អរូបាវចរនោះ ជាអបរិយាបន្ន ព្រោះហេតុនោះ ទើបឆ្លើយបដិសេធនោះឯង ។

[ ៣៥៨ ] បទថា **ទិព្វចក្ខុំ ធម្មុបត្ថម្ភំ** បានដល់ ជាវត្ថុដែលកាមាវចរធម៌

ឧបត្ថម្ភហើយ ។

[ ៣៥៩ ] បទថា **ធម្មុបត្ថទ្ធំ** បានដល់ ដែលលោកុត្តរធម៌ឧបត្ថម្ភហើយ ។

[ ៣៦១ ] ត្រូវសួរថា **ទ្វេវ ចក្ខូនិ** បរវាទីមិនកាន់យកទិព្វចក្ខុ ដែលធម៌ឧបត្ថម្ភហើយ ជាបញ្ញាចក្ខុក៏ពិត ទើបឆ្លើយបដិសេធ ព្រោះភាពដែលបញ្ញាចក្ខុ ជាសភាវៈមាន ។

[ ៣៦២ ] ត្រូវសួរទៀត ក៏ឆ្លើយទទួល ដោយអំណាចនៃលទ្ធិថា មំសចក្ខុដែលធម៌ឧបត្ថម្ភហើយ រមែងជាទិព្វចក្ខុ ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាទិព្វចក្ខុកថា ចប់**

# អភិធម្មបិដក

## ទិដ្ឋសោតកថា

[ ៣៦៤ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត គឺទិព្វសោត ទិព្វសោត គឺមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៥ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោតដូចម្ដេច ទិព្វសោតក៏ដូច្នោះដែរ ទិព្វសោតដូចម្ដេច មំស-សោតក៏ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៦ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោតនោះឯង គឺទិព្វសោតនោះ ទិព្វសោតនោះ គឺមំសសោតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៧ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត មានវិស័យ អានុភាព គោចរដូចម្ដេច ទិព្វសោត ក៏មានវិស័យ អានុភាព គោចរដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៨ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ មំសសោត ជាឧបាទិន្ន ទៅជា ( ទិព្វសោត ) អនុបាទិន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៦៩ ] ( មំសសោត ) ជាឧបាទិន្ន ទៅជា ( ទិព្វសោត ) អនុ-បាទិន្នឬ ។ អើ ។ កាមាវចរ ទៅជារូបាវចរឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។

[ ៣៧០ ] កាមាវចរ ទៅជារូបាវចរឬ ។ អើ ។ រូបាវចរ ទៅជាអរូបាវចរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧១ ] រូបាវចរ ទៅជាអរូបាវចរឬ ។ អើ ។ បរិយាបន្ន ទៅជាអបរិយាបន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧២ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ ទិព្វសោត ដែលធម៌ទំនុកបម្រុងហើយ ជាមំសសោតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៣ ] មំសសោត ដែលធម៌ទំនុកបម្រុងហើយ ជាទិព្វសោតឬ ។ អើ ។ សោត មានតែមួយប៉ុណ្ណោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៤ ] សោត មានតែមួយប៉ុណ្ណោះឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា សោតទាំងឡាយ មាន ២ គឺមំសសោត ១ ទិព្វសោត ១ មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សោតទាំងឡាយ មាន ២ គឺមំសសោត ១ ទិព្វសោត ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សោត មានតែ ១ ប៉ុណ្ណោះទេ ។

**ទិព្វសោតកថា ចប់**

# អដ្ឋកថា

## ធិព្វសោតកថា

[ ៣៧៣ ] ឥឡូវនេះ នឹងពណ៌នាអំពីទិព្វសោតដូចតទៅ

ក្នុងរឿងនោះ បរវាទី ត្រូវសកវាទីសួរថា **ឃត៌រយេវ សោតំ** ក៏ឆ្លើយបដិសេធ ព្រោះសោត មាន ២ យ៉ាង គឺមំសសោត ១ ទិព្វសោត ១ ត្រូវសួរទៀត ក៏ឆ្លើយទទួល ព្រោះមំសសោតនោះឯង ដែលធម៌ឧបត្ថម្ភហើយ ឈ្មោះថា ជាទិព្វសោត ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថាធិព្វសោតកថា ចប់**

# អភិធម្មបិដក

## យថាកម្មូបគតញ្ញាណកថា

[ ៣៧៥ ] យថាកម្មូបគតញ្ញាណ ( ការដឹងពួកសត្វ ដែលអន្ទោលទៅតាមកម្ម ) គឺទិព្វចក្ខុឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ ( សត្វដែលអន្ទោលទៅតាមកម្ម ) ឈ្មោះថា ឃើញរូបដោយទិព្វចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៦ ] បុគ្គលធ្វើទុកក្នុងចិត្ត ចំពោះយថាកម្មូបគតៈ ឈ្មោះថា ឃើញរូបដោយទិព្វចក្ខុឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៧ ] យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយកាយទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោទុច្ចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត និងនរក ដូច្នេះខ្លះ មួយទៀត បុគ្គលធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកប

ដោយកាយសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយវចីសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វប្រកបដោយមនោសុចរិត ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកមិនតិះដៀលព្រះអរិយៈទាំងឡាយ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វជាអ្នកប្រកាន់នូវអំពើជាសម្មាទិដ្ឋិ ដូច្នេះខ្លះ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថា ឃើញរូបដោយទិព្វចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៨ ] យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ បុគ្គលធ្វើទុកក្នុងចិត្តថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងអម្បាលនេះ ដូច្នេះខ្លះ ។បេ។ ធ្វើទុកក្នុងចិត្តថា ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ដូច្នេះខ្លះ ឈ្មោះថា ឃើញរូបដោយទិព្វចក្ខុឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៧៩ ] យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ បុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានចំពោះ មិនបានត្រាស់ដឹង មិនធ្វើឲ្យជាក់ច្បាស់នូវទិព្វចក្ខុ តែងដឹងនូវយថាកម្មូបគតៈ មានដែរឬ ។ អើ ។ ប្រសិនបើបុគ្គលណាមួយ មិនមានទិព្វចក្ខុ មិនបានចំពោះ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់នូវទិព្វចក្ខុទេ តែងដឹងនូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏

ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

[ ៣៨០ ] យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុឬ ។ អើ ។ ព្រះសារីបុត្ត មានអាយុ បានជ្រាបនូវយថាកម្មូបគតៈឬ ។ អើ ។ ប្រសិនបើ ព្រះសារីបុត្ត មានអាយុ បានជ្រាបនូវយថាកម្មូបគតៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

[ ៣៨១ ] ព្រះសារីបុត្តមានអាយុ បានជ្រាបនូវយថាកម្មូបគតៈឬ ។ អើ ។ ព្រះសារីបុត្តមានអាយុ មានទិព្វចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨២ ] ព្រះសារីបុត្តមានអាយុ មានទិព្វចក្ខុឬ ។ អើ ។ ក្រែងព្រះសារីបុត្តមានអាយុ បានពោលគាថានេះថា

ការតាំងចិត្តរបស់ខ្ញុំ មិនមានដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ
មិនមានដើម្បីទិព្វចក្ខុ មិនមានដើម្បីចេតោបរិយញ្ញាណ មិន
មានដើម្បីឥទ្ធិវិធញ្ញាណ មិនមានដើម្បីសោតធាតុដ៏បរិសុទ្ធ
មិនមានដើម្បីចុតូបបាតញ្ញាណទេ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា យថាកម្មូបគតញ្ញាណ គឺទិព្វចក្ខុទេ ។

**យថាកម្មូបគតញ្ញាណកថា ចប់**

# អដ្ឋកថា

## យថាកម្មូបគតញ្ញាណកថា

[ ៣៧៥ ] ឥឡូវនេះ នឹងពណ៌នាយថាកម្មូបគតញ្ញាណ គឺញាណជាគ្រឿងដឹងភាពដែលសត្វទាំងឡាយប្រព្រឹត្តទៅតាមកម្មដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិថា យថាកម្មូបគតញ្ញាណនោះឯងជាទិព្វចក្ខុ ព្រោះកាន់យកព្រះសូត្រដោយមិនពិចារណាថា មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ។បេ។ រមែងដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ត្រូវសកវាទីសួរទៀតថា **យថាកម្មូបគតញ្ចុ មនសិករោតិ** បរវាទីឆ្លើយបដិសេធ ព្រោះចិត្ត ១ ដួង មិនមានអារម្មណ៍ ២ យ៉ាង ។

[ ៣៧៦ ] ត្រូវសួរលើកទី ២ បរវាទីត្រឡប់ឆ្លើយទទួល ដោយអំណាចនៃចិត្តដួងផ្សេងគ្នា ។ សកវាទីមិនឲ្យឱកាស ធ្វើលេសដល់បរវាទីនោះទើបសួរទៀតថា **ទ្វិន្នំ ផស្សានំ** បរវាទីក៏ឆ្លើយបដិសេធ ។

[ ៣៧៧ ] បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងការប្រកបសេចក្ដីដោយបទថា **ឥមេ វត ភោន្តោ សត្តា** ជាដើម ដូចដែលប្រកបជាមួយបទថា **យថា-កម្មូបគតំ** នោះឯង ។

[ ៣៨០ ] បទថា **អាយស្មា សារីបុត្តោ យថាកម្មូបគតំ ញាណំ ជានាតិ** នេះ អធិប្បាយថា ព្រោះជនពួកខ្លះ មិនដឹងថា ព្រះសារីបុត្តត្រេរ

រមែងមិនប្រើអភិញ្ញាញាណទាំងឡាយ ព្រោះភាពជាអ្នកប្រាថ្នាតិច រមែងសម្គាល់ថា ព្រះថេរៈមិនមានអភិញ្ញាញាណទាំងនោះ ព្រោះហេតុនោះ ទើបសកវាទីសួរបរវាទី ដែលសម្គាល់ថា ព្រះថេរៈមិនបានទិព្វចក្ខុ ដូច្នេះ ។

[ ៣៨១ ] ដោយហេតុនោះ បរវាទីត្រូវសកវាទីសួរបន្តថា **អត្ថាយស្មតោ សារិបុត្តស្ស ទិព្វចក្ខុ** ទើបឆ្លើយបដិសេធ ។

[ ៣៨២ ] ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ដោយគិតថា អភិញ្ញាញាណឯណានីមួយ ដែលសាវកគប្បីសម្រេច ព្រះថេរៈសម្រេចញាណនោះទាំងអស់ ដោយលំដាប់ ។ ឥឡូវនេះ សកវាទី កាលឲ្យបរវាទីរាយមាយចិត្ត ទើបពោលពាក្យថា **ននុ អាយស្មា សារីបុត្តោ** ជាដើម ។ ពិតហើយ ព្រះថេរៈពោលគាថានេះ ព្រោះមិនមានការប្រាថ្នានឹងប្រើអភិញ្ញាប៉ុណ្ណោះឯង មិនបានពោល ព្រោះមិនមានអភិញ្ញាញាណទាំងឡាយ តែបរវាទីកំណត់ន័យព្រះសូត្រថា ព្រះថេរៈពោលព្រោះមិនមានអភិញ្ញាញាណ ព្រោះហេតុនោះ តាមលទ្ធិនោះ ទើបព្រះថេរៈ មានត្រឹមតែយថាកម្មូបគតញ្ញាណ មិនមានទិព្វចក្ខុញ្ញាណ ដោយហេតុនោះ ទើបសកវាទីពោលថា **តេន ហិ ន វត្តព្វំ យថាកម្មូបគតញ្ញាណំ ទិព្វចក្ខុ** ដូច្នេះ ។

**អដ្ឋកថាយថាកម្មូបគតញ្ញាណកថា ចប់**

# អភិធម្មបិដក

## សំវរកថា

[ ៣៨៣ ] ការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការមិនសង្រួម មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៤ ] ការមិនសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ការសង្រួម មិនមានក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៥ ] ក្រែងការសង្រួម ជាសីល ព្រោះការមិនសង្រួម ចុះការសង្រួម មានក្នុងពួកទេវតាឬ ។ អើ ។ ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ អ្នកចូរជ្រាបនូវកំហុស ( របស់អ្នក ) ចុះ ប្រសិនបើ ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួមមានក្នុងពួកទេវតាមែន ម្នាលដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ បណ្ដាពាក្យទាំង ២ ប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ប្រសិនបើគេមិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសង្រួម

ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា ដូច្នេះ បណ្ដាពាក្យទាំងពីរប្រការនោះ អ្នកពោលពាក្យណាថា គេគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួម ការសង្រួម មានក្នុងពួកទេវតា មិនគួរពោលថា ការសង្រួម ជាសីល ព្រោះការមិនសង្រួមណា ការមិនសង្រួមនោះ មានក្នុងពួកទេវតា ដូច្នេះ ពាក្យនោះ ជាពាក្យខុសទេ ។

[ ៣៨៦ ] ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មានក្នុងពួកមនុស្សនោះដែរឬ ។ អើ ។ ការសង្រួម មានក្នុងពួកទេវតា ចុះការមិនសង្រួម មានក្នុងពួកទេវតានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៧ ] ការសង្រួម មានក្នុងទេវតា ចុះការមិនសង្រួម មិនមានក្នុងពួកទេវតានោះទេឬ ។ អើ ។ ការសង្រួម មានក្នុងពួកមនុស្ស ចុះការមិនសង្រួម មិនមានក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៨ ] ការវៀរចាកបាណាតិបាត មានក្នុងពួកទេវតាឬ ។ អើ ។ ចុះបាណាតិបាត ( ការសម្លាប់សត្វ ) មានក្នុងពួកទេវតាឬ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ( ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ) មានក្នុងពួកទេវតាឬ ។ អើ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ( ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ) មានក្នុងពួកទេវតាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៨៩ ] បាណាតិបាត មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ការវៀរ

ចាកបាណាតិបាត មិនមានក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋាន មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន មិនមានក្នុងពួកទេវតាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩០ ] ការវៀរចាកបាណាតិបាត មានក្នុងពួកមនុស្ស ចុះបាណាតិបាត មានក្នុងពួកមនុស្សនោះឬ ។ អើ ។ ការវៀរចាកបាណាតិបាត មានក្នុងពួកទេវតា ចុះបាណាតិបាត មានក្នុងពួកទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកមនុស្ស ចុះសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកមនុស្សនោះឬ ។ អើ ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកទេវតានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩១ ] ការវៀរចាកបាណាតិបាត មានក្នុងពួកទេវតា ចុះបាណាតិបាត មិនមានក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរចាកបាណាតិបាត មានក្នុងពួកមនុស្ស ចុះបាណាតិបាត មិនមានក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកទេវតា ចុះសុរាមេរយមជ្ជប្បមាទដ្ឋាន មិនមានក្នុងពួកទេវតានោះទេឬ ។ អើ ។ ការវៀរសុរាមេរយមជ្ជប្បមាទដ្ឋាន មានក្នុងពួកមនុស្ស ចុះសុរាមេរយមជ្ជប្បមាទដ្ឋាន មិនមានក្នុងពួកមនុស្សនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩២ ] ការសង្រ្គម មិនមានក្នុងពួកទេវតាទេឬ ។ អើ ។ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់សត្វ ជាអ្នកកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកប្រព្រឹត្តនូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ការសង្រ្គម មានក្នុងពួកទេវតាដែរ ។

សំវរកថា ចប់

# អដ្ឋកថា

## សំវរកថា

[ ៣៨៣ ] ឥឡូវនេះ នឹងពណ៌នាអំពីការសង្រួមដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិថា ក្នុងទេវតាទាំងឡាយខាងលើ តាំងអំពីជាន់តាវត្តិង្សឡើងទៅ ព្រោះទេវតាទាំងនោះ មិនប្រព្រឹត្តកន្លងបញ្ចវេរ ព្រោះហេតុនោះ ទើបការសង្រួមមានក្នុងទេវតាទាំងនោះ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ដែលមិនឃើញការប្រព្រឹត្តកន្លងនូវបញ្ចវេរ ។ លំដាប់នោះ ទើបសកវាទីសួរដល់ការមិនសង្រួម ព្រោះធម្មតាការសង្រួមមាន លុះណាតែ ការមិនសង្រួមក្នុងវត្ថុដែលបុគ្គលគប្បីសង្រួមមាន តែបរវាទីឆ្លើយបដិសេធ ព្រោះក្នុងទេវតាទាំងឡាយ មិនមានបាណាតិបាតជាដើម ។

[ ៣៨៦ ] បទថា **អត្ថិ មនុស្សេសុ** ជាដើម សកវាទីពោលដើម្បីសម្តែងការប្រព្រឹត្តទៅនៃការមិនសង្រួម ក្នុងកាលការសង្រួមមាន និងការប្រព្រឹត្តទៅនៃការសង្រួម ក្នុងកាលការមិនសង្រួមមាន ។

[ ៣៨៨ ] ក្នុងបញ្ហាទាំងឡាយថា **ចាណាតិចាតា វេរមណី** ជាដើម គប្បីជ្រាបពាក្យឆ្លើយទទួល ដោយអំណាចនៃការមិនប្រព្រឹត្តបាណាតិបាត

ជាដើម និងគប្បីជ្រាបពាក្យឆ្លើយបដិសេធ ព្រោះការមិនមានបាណាតិបាត ជាដើម ។ បញ្ហាពោលដោយបដិលោម មានអត្ថងាយយល់ហើយ ។

[ ៣៩២ ] ក្នុងបញ្ហាចុងបញ្ចប់ថា **ឆត្តិ ទេវេសុ សំវរោ** ពាក្យឆ្លើយ ទទួល ជាពាក្យរបស់សកវាទី សំដៅយកការមិនមានការធ្វើបាណាតិបាត ជាដើម ហើយសង្រួមចាកការធ្វើបាណាតិបាតជាដើមទៀត ។ បន្ទាប់អំពី នោះ ពាក្យសួរដោយអំណាចលេសន័យជាដើមថា បើការសង្រួមរបស់ ទេវតាទាំងឡាយមិនមាន ទេវតាទាំងឡាយ ក៏ត្រូវជាបុគ្គលផ្តាច់បង់ជីវិត ជាពាក្យរបស់បរវាទី ។ ពាក្យបដិសេធ ព្រោះមិនមានការប្រព្រឹត្តកន្លងពៀរ របស់ទេវតាទាំងឡាយ ជាពាក្យរបស់សកវាទី ។ បរវាទីឲ្យលទ្ធិតាំងទុក ព្រោះកាន់យកត្រឹមតែពាក្យថា **ឆ ហោរិ** របស់សកវាទី ។ តែលទ្ធិដែល តាំងទុកហើយយ៉ាងនេះ រមែងតាំងទុកមិនបានឡើយ ដូច្នេះ ។៚

## អដ្ឋកថាសំវរកថា ចប់

# អភិធម្មបិដក

## អសញ្ញកថា

[ ៣៩៣ ] *សញ្ញាក្នុងពួកអសញ្ញសត្វ ( សត្វមិនមានសញ្ញា ) មានដែរឬ ។ អើ ។ ភពរបស់សញ្ញសត្វ ( សត្វមានសញ្ញា ) គតិរបស់សញ្ញសត្វ លំនៅរបស់សញ្ញសត្វ សង្សាររបស់សញ្ញសត្វ កំណើតរបស់សញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់សញ្ញសត្វមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។*

[ ៣៩៤ ] *ក្រែងភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សង្សាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញសត្វ ការបានចំពោះនូវអត្តភាព របស់អសញ្ញសត្វមានដែរឬ ។ អើ ។ ប្រសិនបើភពរបស់អសញ្ញសត្វ គតិរបស់អសញ្ញសត្វ លំនៅរបស់អសញ្ញសត្វ សង្សាររបស់អសញ្ញសត្វ កំណើតរបស់អសញ្ញសត្វ ការបានចំពោះនូវអត្តភាពរបស់អសញ្ញសត្វមានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញាក្នុងពួកអសញ្ញសត្វមានទេ ។*

[ ៣៩៥ ] *សញ្ញាក្នុងពួកអសញ្ញសត្វមានដែរឬ ។ អើ ។ បញ្ចវោការភព គតិ សត្តាវាស សង្សារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងទេ ។បេ។*

[ ៣៩៦ ] *ក្រែងឯកវោការភព គតិ សត្តាវាស សង្សារ កំណើត ការបានអត្តភាពមានដែរឬ ។ អើ ។ ប្រសិនបើ ឯកវោការភព គតិ សត្តាវាស*

សង្សារ កំណើត ការបានអត្តភាពមានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញាក្នុងពួកអសញ្ញសត្វ មានទេ ។

[ ៣៩៧ ] សញ្ញាក្នុងពួកអសញ្ញសត្វ មានដែរឬ ។ អើ ។ បុគ្គលធ្វើកិច្ចគួរធ្វើដោយសញ្ញា ដោយសញ្ញានោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៨ ] សញ្ញាក្នុងពួកមនុស្សមាន ទាំងសញ្ញភពនោះ សញ្ញគតិ ( គតិរបស់សត្វមានសញ្ញា ) សញ្ញសត្តាវាស សញ្ញសង្សារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញាក្នុងពួកអសញ្ញសត្វ មានទាំងសញ្ញភពនោះ សញ្ញគតិ សញ្ញសត្តាវាស សញ្ញសង្សារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៣៩៩ ] សញ្ញា ក្នុងពួកមនុស្សមាន ទាំងបញ្ចវោការភពនោះ គតិ សត្តាវាស សង្សារ យោនិ អត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញាក្នុងពួកអសញ្ញសត្វមាន ទាំងបញ្ចវោការភពនោះ គតិ លំនៅរបស់សត្វ សង្សារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០០ ] សញ្ញា ក្នុងពួកមនុស្សមាន ទាំងបុគ្គលធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះដែរឬ ។ អើ ។ សញ្ញា ក្នុងពួកអសញ្ញសត្វមាន ទាំងបុគ្គលធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០១ ] សញ្ញា ក្នុងពួកអសញ្ញសត្វមាន ទាំងអសញ្ញភពនោះ អសញ្ញ

គតិ អសញ្ញសត្តាវាស អសញ្ញសង្សារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ សញ្ញា ក្នុងពួកមនុស្សមាន ទាំងអសញ្ញភពនោះ ។បេ។ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។

[ ៤០២ ] សញ្ញាក្នុងពួកអសញ្ញសត្វមាន ទាំងឯកវោការភពនោះ គតិលំនៅរបស់សត្វ សង្សារ កំណើត ការបានអត្តភាព មានដែរឬ ។ អើ ។ សញ្ញាក្នុងពួកមនុស្សមាន ទាំងឯកវោការភពនោះ ។បេ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៣ ] សញ្ញា ក្នុងពួកអសញ្ញសត្វមាន ប៉ុន្តែ អសញ្ញសត្វនោះ មិនធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះទេឬ ។ អើ ។ សញ្ញា ក្នុងពួកមនុស្សមាន ប៉ុន្តែ មនុស្សនោះ មិនធ្វើកិច្ចដែលគួរធ្វើដោយសញ្ញា ដោយសញ្ញានោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៤ ] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអសញ្ញសត្វមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាឈ្មោះថា អសញ្ញសត្វ ជាអ្នកញុំាងសញ្ញាឲ្យកើតឡើងមាន ប៉ុន្តែ ទេវតាទាំងនោះ រមែងច្យុតចាកកាយនោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សញ្ញា ក្នុងពួកអសញ្ញសត្វ មានមែន ។

[ ៤០៥ ] សញ្ញា ក្នុងពួកអសញ្ញសត្វ មានដែរឬ ។ សញ្ញា ក្នុងកាលខ្លះ មាន ក្នុងកាលខ្លះ មិនមាន ។ ចុះពួកសញ្ញសត្វ ក្នុងកាលខ្លះ មាន ពួក

អសញ្ញសត្វ កាលខ្លះ មាន សញ្ញភព ក្នុងកាលខ្លះ មាន អសញ្ញភព ក្នុងកាលខ្លះ មាន បញ្ចវោការភព ក្នុងកាលខ្លះ មាន ឯកវោការភព ក្នុងកាលខ្លះ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៦ ] សញ្ញា ក្នុងពួកអសញ្ញសត្វ ក្នុងកាលខ្លះ មាន ក្នុងកាលខ្លះ មិនមានឬ ។ អើ ។ កាលដូចម្ដេច សញ្ញា មាន កាលដូចម្ដេច សញ្ញា មិនមាន ។ សញ្ញាក្នុងចុតិកាល ( កាលច្យុត ) និងឧបបត្តិកាល ( កាលដែលកើត ) មាន តែក្នុងឋិតិកាល ( កាលដែលតាំងនៅ ) មិនមានទេ ។ ពួកសញ្ញសត្វ ក្នុងចុតិកាល និងឧបបត្តិកាល មាន ក្នុងអសញ្ញសត្វ ក្នុងឋិតិ-កាល មាន សញ្ញភព ក្នុងចុតិកាល និងឧបបត្តិកាល មាន អសញ្ញភព ក្នុងឋិតិកាល មាន បញ្ញវោការភព ក្នុងចុតិកាល និងឧបបត្តិកាល មាន ឯកវោការភព ក្នុងឋិតិកាល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**អសញ្ញកថា ចប់**

# អដ្ឋកថា

## អសញ្ញកថា

[ ៣៩៣ ] ឥឡូវនេះ នឹងពណ៌នាការមិនមានសញ្ញាដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា ឈ្មោះថា បដិសន្ធិ វៀរចាកវិញ្ញាណ មិនមាន ព្រោះពាក្យថា វិញ្ញាណ មាន ព្រោះសង្ខារជាបច្ច័យ ដូច្នេះ សញ្ញាក្នុងខណៈនៃចុតិ និងបដិសន្ធិរបស់អសញ្ញីសត្វទាំងឡាយ មាន ព្រោះពាក្យថា អសញ្ញីទេវតាទាំងនោះ រមែងចុតិចាកពួកនោះ ព្រោះការកើតឡើងនៃសញ្ញា ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បន្ទាប់អំពីនោះ សកវាទី ដើម្បីនឹងសួរបរវាទីដោយពាក្យជាដើមថា ឋានៈនោះ ជាភពមានសញ្ញា តាមលទ្ធិរបស់អ្នកឬ ទើបពោលពាក្យថា **សញ្ញាភវោ សញ្ញាគតិ** ដូច្នេះជាដើម ។ ពាក្យទាំងពួង និងពាក្យដទៃក្រៅពីពាក្យនោះ គប្បីជ្រាបដោយន័យរបស់ព្រះបាលីនោះឯង ។l៚

**អដ្ឋកថាអសញ្ញកថា ចប់**

# អភិធម្មបិដក

## នេវសញ្ញានាសញ្ញាយតនកថា

[ ៤០៧ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយ-តនភព មានទេឬ ។ អើ ។ អសញ្ញភព អសញ្ញគតិ អសញ្ញសត្តាវាស អសញ្ញសង្សារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤០៨ ] ក្រែងសញ្ញភព សញ្ញគតិ សញ្ញសត្តាវាស សញ្ញសង្សារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ ប្រសិនបើសញ្ញភព សញ្ញគតិ ។បេ។ សញ្ញភាវប្បដិលាភ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតន-ភព មានទេ ។

[ ៤០៩ ] បុគ្គល មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភព មានទេឬ ។ អើ ។ ឯកវោការភព គតិ ។បេ។ ការបាទអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងចតុវោការភព គតិ ។បេ។ ការបាទអត្តភាព មានដែរឬ ។ អើ ។ ប្រសិនបើ ចតុវោការភព គតិ ។បេ។ ការបាទអត្តភាព មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[ ៤១០ ] បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងអសញ្ញសត្វ មានទេ ចុះចំណែកខាងអសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាស អសញ្ញសំសារ

អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាងអសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាស អសញ្ញសំសារ អសញ្ញ-យោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មិនគួរនិយាយថា សញ្ញាក្នុងអសញ្ញសត្វ មានទេ ចុះចំណែកខាងឯកវោការភពនោះ គតិ ។បេ។ ការបានអត្តភាព មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាងឯកវោការភពនោះ គតិ លំនៅរបស់សត្វ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១១ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយ-តនភព មានទេ ចុះចំណែកខាងសញ្ញភពនោះ សញ្ញគតិ ។បេ។ សញ្ញត្ត-ភាវប្បដិលាភ មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញាក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាងសញ្ញភពនោះ សញ្ញគតិ ។បេ។ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១២ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញា-យតនភព មានទេ ចុះចំណែកខាងចតុវោការភពនោះ គតិ ។បេ។ ការបានអត្តភាព មានដែរឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាងចតុវោការភពនោះ ។បេ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៣ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ ក្រែងនេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[ ៤១៤ ] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងអាកាសានញ្ចាយតនភព មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៥ ] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ វិញ្ញាណញ្ចាយតនភព ។បេ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងអាកិញ្ចញ្ញាយតនភព មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៦ ] អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញាក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណញ្ចាយតនភព ។បេ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញាក្នុងអាកិញ្ចញ្ញាយតនភព

នោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៧ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬ មិនមានទេឬ ។ អើ ។ ក្រែងនេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មាន ឬមិនមានទេ ។

[ ៤១៨ ] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬ មិនមានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ។បេ។ វិញ្ញាណញ្ចាយតនភព ។បេ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញាក្នុងអាកិញ្ចញ្ញាយតនភព មានឬ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤១៩ ] អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញាក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណញ្ចាយតនភព ។បេ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញាក្នុងអាកិញ្ចញ្ញាយតនភព

នោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនកព ជាចតុវោការភព សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនកពនោះ មានដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៤២០ ] បុគ្គល មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញា-យតនកព មានឬ មិនមានទេឬ ។ អើ ។ ក្រែងនេវសញ្ញានាសញ្ញាយតនកព មានឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនកព មានមែន ម្នាល អ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនកព មាន ឬមិនមានទេ ។

[ ៤២១ ] បុគ្គលធ្វើសេចក្តីចូលចិត្តថា នេវសញ្ញានាសញ្ញាយតនកព ដូច្នេះហើយ មិនគួរនិយាយថា សញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនកព មាន ឬ មិនមានទេឬ ។ អើ ។ បុគ្គលធ្វើសេចក្តីចូលចិត្តថា អទុក្ខមសុខវេទនា ដូច្នេះហើយ មិនគួរនិយាយថា វេទនា ឬមិនមែនវេទនា ក្នុងអទុក្ខមសុខ-វេទនាទេ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

នេវសញ្ញានាសញ្ញាយតនកថា ចប់

តតិយវគ្គ ចប់

## ឧទ្ទាននៃតតិយវគ្គនោះ គឺ

និយាយអំពីកម្លាំងព្រះតថាគត សាធារណៈដល់សាវក ១ កម្លាំងព្រះតថាគត ជាអរិយៈ ១ ចិត្តប្រកបដោយរាគៈ រួចស្រឡះ ១ ចិត្តរួចស្រឡះហើយ កំពុងរួចស្រឡះ និងចិត្តកំពុងរួចស្រឡះ ១ បុគ្គលទី ៨ លះបង់ទិដ្ឋិបរិយុដ្ឋាន ១ បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ យ៉ាង ១ មំសចក្ខុដែលធម៌ទំនុកបម្រុង ១ មំសសោត ដែលធម៌ទំនុកបម្រុង ១ យថាកម្មូបគតញ្ញាណ ១ ការសម្រេចក្នុងពួកទេវតា ១ សញ្ញាក្នុងពួកអសញ្ញសត្វ ១ ក្នុងនេវសញ្ញានាសញ្ញាយតនភព ១ ។

# អដ្ឋកថា

## នេវសញ្ញានាសញ្ញាយតនកថា

[ ៤០៧ ] ឥឡូវនេះ នឹងពណ៌នាអំពីនេវសញ្ញានាសញ្ញាយតនៈតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា មិនគប្បីពោលថា សញ្ញាមានទៅក្នុងភពនោះ ព្រោះព្រះបាលីថា អាយតនៈនោះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីជ្រាបដោយន័យរបស់ព្រះបាលីនោះឯង ។l។

**អដ្ឋកថានេវសញ្ញានាសញ្ញាយតនកថា ចប់**

**វគ្គទី ៣ ចប់**

# អភិធម្មបិដក

## គិហិអរហាតិកថា

[ ៤២២ ] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថបានជាព្រះអរហន្តទេ ។

[ ៤២៣ ] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់ ផ្ដាច់ហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់ផ្ដាច់ហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។បេ។

[ ៤២៤ ] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន មានដែរឬ ។ មិនមានទេ ។ បើគ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[ ៤២៥ ] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងវច្ឆគោត្ត-បរិព្វាជក បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មានដែរឬ ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ម្នាលវច្ឆៈ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មិនមានទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា គ្រហស្ថបានជាព្រះអរហន្តទេ ។

[ ៤២៦ ] គ្រហស្ថ បានជាព្រះអរហន្ត ដែរឬ ។ អើ ។ ព្រះអរហន្តសេពមេថុនធម្ម ញុំាងមេថុនធម្មឲ្យកើតឡើង នៅគ្រប់គ្រងដំណេកដែលចង្អៀតដោយកូន លាបប្រោះព្រំខ្លឹមចន្ទន៍ដ៏ឧត្តម ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប ត្រេកអរចំពោះមាស និងប្រាក់ ទទួលពពែ និងចៀម ទទួលមាន់ និងជ្រូក ទទួលដំរី គោ សេះឈ្មោល សេះញី ទទួលទទា ក្រួច ក្ងោក ចបាត ទ្រទ្រង់ផ្នួងសក់ ដែលមានទង់ មានពណ៌លឿង

ទូទ្រង់សំពត់ស មានជាយវែង នៅជាគ្រហស្ថ ដរាបអស់មួយជីវិតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៧ ] បុគ្គលមិនគួរនិយាយថា គ្រហស្ថ បានជាព្រះអរហន្តទេឬ ។ អើ ។ ក្រែងយសកុលបុត្ត ឧត្តិយគហបតី និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថឬ ។ អើ ។ បើយសកុលបុត្ត ឧត្តិយគហបតី និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គ្រហស្ថបានជាព្រះអរហន្តដែរ ។

**គិហិអរហោតិកថា ចប់**

# អដ្ឋកថា

## គិហិស្ស អរហាតិកថា

[ ៤២២ ] ឥឡូវនេះ នឹងពណ៌នាអំពីគ្រហស្ថ គប្បីជាព្រះអរហន្តបាន ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយ ឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា គ្រហស្ថគប្បីជាព្រះអរហន្តបាន ព្រោះឃើញការកើតឡើង នៃព្រះអរហន្តរបស់ជនទាំងឡាយ មានយស-កុលបុត្តជាដើម ដែលតាំងនៅក្នុងភេទគ្រហស្ថ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ បណ្តាបទទាំងនោះ បទថា **គិហិស្ស** អធិប្បាយ ថា បុគ្គលណា ឈ្មោះថា គ្រហស្ថ ព្រោះប្រកបព្រមដោយសំយោជនៈ របស់គ្រហស្ថ បុគ្គលនោះ គប្បីជាព្រះអរហន្តបានឬ ឯបរវាទីមិនកំណត់ ដល់បំណង កាលឃើញត្រឹមតែភេទគ្រហស្ថប៉ុណ្ណោះ ទើបឆ្លើយទទួល ។ ឥឡូវនេះ សកវាទីក៏ផ្តើមពាក្យថា **អត្ថិ អរហតោ** ដើម្បីសម្តែងន័យនេះថា ឈ្មោះថា បុគ្គលគប្បីជាគ្រហស្ថ ក៏រមែងកើតដោយសំយោជនៈរបស់ គ្រហស្ថ មិនមែនជាគ្រហស្ថដោយត្រឹមតែភេទ សមដូចពាក្យដែលព្រះមាន ព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលទៀង ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ជាសមណៈក៏បាន ជាភិក្ខុក៏បាន ដូច្នេះ ។ ពាក្យទាំងពួង មានអត្ថងាយយល់ហើយនោះឯង ។

## អដ្ឋកថាគិហិស្សអរហាតិកថា ចប់

# អភិធម្មបិដក

## ឧបបត្តិកថា

[ ៤២៨ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាសោតាបន្ន ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤២៩ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាសកទាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៤៣០ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាអនាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣១ ] បុគ្គល បានជាសោតាបន្ន មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គលបានជាសោតាបន្ន មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣២ ] បុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គលបានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៣ ] បុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៤ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ព្រះសារីបុត្តត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមោគ្គល្លានត្ថេរ ។បេ។ ព្រះមហាកស្សបត្ថេរ ។បេ។ ព្រះមហាកច្ចាយនត្ថេរ ។បេ។ ព្រះមហាកោដ្ឋិកត្ថេរ ។បេ។ ព្រះមហាបណ្ណកត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៥ ] ព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៦ ] ព្រះមហាមោគ្គល្លានត្ថេរ ។បេ។ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ។បេ។

[ ៤៣៧ ] ព្រះមហាបណ្ណកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះមហាបណ្ណកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោល

ថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៣៨ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្ត ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ( បដិសន្ធិចិត្ត ) ជាលោកិយ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៣៩ ] បុគ្គល បានជាព្រះអរហន្ត ជាមួយនឹងការកើតឡើងឬ ។ អើ ។ ចិត្តដែលកំពុងស្វែងរកនូវការកើតឡើង ជានិយ្យានិកៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំ មិនមានអាសវៈ ។បេ។ មិនប្រកបដោយសេចក្តីសៅហ្មងទេឬ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤០ ] ក្រែងចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បើចិត្តដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[ ៤៤១ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលលះរាគៈ លះទោសៈ លះមោហៈ ។បេ។ លះអនោត្តប្បៈ ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។

[ ៤៤២ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្តដែលកំពុងស្វែងរកនូវការកើតឡើងជាមគ្គ ។បេ។ ជាសតិប្បដ្ឋាន ជាសម្មប្បធាន ជាឥទ្ធិបាទ ជាឥន្ទ្រិយ ជាពល ។បេ។ ជាពោជ្ឈង្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៣ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលកំណត់ដឹងនូវទុក្ខសច្ច លះនូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយចិត្តដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៤ ] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចុតិចិត្ត មគ្គចិត្ត ចិត្តដែលកំពុងស្វែងរកនូវការកើតឡើង ជាផលចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

**ឧបបត្តិកថា ចប់**

# អដ្ឋកថា

## ឧបបត្តិកថា

[ ៤២៨ ] ឥឡូវនេះ នឹងពណ៌នាអំពីការកើតឡើងដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិថា ព្រះអនាគាមីកើតក្នុងសុទ្ធាវាសព្រហ្ម រមែងជាព្រះអរហន្ត ជំណាលគ្នានឹងការកើតឡើង ព្រោះកាន់យកដោយមិនពិចារណានូវព្រះបាលីទាំងឡាយ មានពាក្យថា បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយបរិនិព្វានក្នុងសុទ្ធាវាសទេវលោកនោះ ដូច្នេះជាដើម ឬជនទាំងឡាយណា ដែលផ្ទាស់ប្តូរបទថា ឧបហច្ចបរិនិព្វាយី មកជាឧបបជ្ជបរិនិព្វាយី ( គ្រាន់តែកើតឡើងហើយក៏បរិនិព្វាន ) សិក្សាព្រះពុទ្ធវចនៈ មានលទ្ធិថា ព្រះអនាគាមីជាព្រះអរហន្ត ព្រមគ្នានឹងការកើតឡើង ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះ ពាក្យសួររបស់សកវាទីសំដៅយកជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហានោះ ឈ្មោះថា ចិត្តដែលកើតឡើង រមែងជាលោកិយចិត្ត ទាំងបុគ្គលទាំងឡាយជាព្រះសោតាបន្នជាដើម ដោយលោកិយចិត្តនោះ ក៏មិនមានឡើយនឹងពោលថ្វីដល់ភាពជាព្រះអរហន្តនោះ ព្រោះហេតុនោះ ដើម្បីសម្តែងន័យនេះដល់បរវាទីនោះ ទើបសកវាទីផ្តើមពាក្យថា **សហ ឧបបត្តិយា សោតាបន្នោ** ដូច្នេះ ។

[ ៤៣៤ ] សកវាទីពោលពាក្យថា **សារីបុត្តោ** ជាដើម ដើម្បីចោទសួរថា បណ្តាព្រះមហាថេរៈទាំងនេះ សូម្បីមួយអង្គ ឈ្មោះថា ជាព្រះអរហន្ត

ព្រមជាមួយការកើតមានឬ ។

[ ៤៣៨ ] បទថា **ឧបបត្តេសិយេន** បានដល់ បដិសន្ធិចិត្ត ។ ពិតហើយ បដិសន្ធិចិត្តនេះ រមែងស្វែងរកការកើត គឺបន្ត ព្រោះហេតុនោះ ទើបលោកហៅបដិសន្ធិចិត្តនេះថា ចិត្តស្វែងរកការកើតឡើង ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ដូច្នេះ ។

**អដ្ឋកថាឧបបត្តិកថា ចប់**

# អភិធម្មបិដក

## អនាសវកថា

[ ៤៤៥ ] ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ( របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៦ ] ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ ចក្ខុរបស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុរបស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀករបស់ព្រះអរហន្ត ។បេ។ ច្រមុះរបស់ព្រះអរហន្ត ។បេ។ អណ្តាត របស់ព្រះអរហន្ត ។បេ។ កាយរបស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៧ ] កាយរបស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ ពោជ្ឈង្គ ( របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៨ ] កាយរបស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។

កាយរបស់ព្រះអរហន្ត គួរដល់នូវការផ្គងឡើង និងការសង្កត់សង្កិន គួរដល់នូវការដាច់ និងការបែកធ្លាយ ជាសាធារណៈដល់ពួកក្អែក ត្មាត ខ្លែងដែរឬ ។ អើ ។ ធម៌មិនមានអាសវៈ គួរដល់នូវការផ្គងឡើង និងការសង្កត់សង្កិន គួរដល់នូវការដាច់ និងការបែកធ្លាយ ជាសាធារណៈដល់ពួកក្អែក ត្មាត ខ្លែងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៤៩ ] ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរឬ ។ អើ ។ ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះធម៌ដែលមិនមានអាសវៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥០ ] កាយរបស់ព្រះអរហន្ត គួរដើម្បីជាប់ដោយចំណង គឺខ្នោះ ដើម្បីជាប់ដោយចំណង គឺខ្សែ ដើម្បីជាប់ដោយចំណង គឺច្រវាក់ ដើម្បីជាប់ដោយចំណង គឺស្រុក ដើម្បីជាប់ដោយចំណង គឺនិគម ដើម្បីជាប់ដោយចំណង គឺនគរ ដើម្បីជាប់ដោយចំណង គឺជនបទ ដើម្បីជាប់ដោយចំណងមាន-កជាគម្រប់ ៥ ដែរឬ ។ អើ ។ ធម៌មិនមានអាសវៈ គួរដើម្បីជាប់ដោយចំណង គឺខ្នោះ ដើម្បីជាប់ដោយចំណង គឺខ្សែ ដើម្បីជាប់ដោយចំណង គឺច្រវាក់ ដោយចំណង គឺស្រុក ដោយចំណង គឺនិគម ដោយចំណង គឺនគរ ដោយចំណង គឺជនបទ ដើម្បីជាប់ដោយចំណង មាន-កជាគម្រប់ ៥ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥១ ] បើព្រះអរហន្ត ឲ្យចីវរដល់បុថុជ្ជន ( ចីវរនោះ ) ជាវត្ថុ

មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( ចីវរ ) ជាវត្ថុមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង មិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចីវរនោះមិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥២ ] បើព្រះអរហន្តឲ្យបិណ្ឌបាត ឲ្យទីសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់បុថុជ្ជន ( បច្ច័យ មានបិណ្ឌបាតជាដើមនោះ ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ( បច្ច័យ មានបិណ្ឌបាតជាដើមនោះ ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ បច្ច័យ មានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យ មានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បច្ច័យ មានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យ មានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោល

យ៉ាងនេះទេ ។បេ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៣ ] បើបុថុជ្ជន ឲ្យចីវរដល់ព្រះអរហន្ត ( ចីវរនោះ ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៤ ] ( ចីវរ ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទោសៈ មោហៈ ។បេ។ អនោត្តប្បៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៥ ] បើបុថុជ្ជន ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយ-ភេសជ្ជបរិក្ខារដល់ព្រះអរហន្ត ( បច្ច័យ មានបិណ្ឌបាតជាដើមនោះ ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៦ ] ( បច្ច័យ មានបិណ្ឌបាតជាដើមនោះ ) ជាសភាពប្រកប

ដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អើ ។ បច្ច័យ មានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ តែបច្ច័យ មានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បច្ច័យ មានបិណ្ឌបាតជាដើមនោះឯង ប្រកបដោយអាសវៈ តែបច្ច័យ មានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទោសៈ ។បេ។ មោហៈ ។បេ។ អនោត្តប្បៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៧ ] បុគ្គលមិនគួរនិយាយថា ពួកធម៌ទាំងអស់របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ បើព្រះអរហន្ត មិនមានអាសវៈទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ។

អនាសវកថា ចប់

# អដ្ឋកថា

## អនាសវកថា

[ ៤៤៥ ] ឥឡូវនេះ នឹងពណ៌នាអំពីអនាសវៈ គឺធម៌មិនជាអារម្មណ៍របស់អាសវៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា ធម៌ទាំងឡាយណា របស់ព្រះអរហន្ត ដែលមិនមានអាសវៈ ធម៌ទាំងអស់នោះ មិនជាអារម្មណ៍របស់អាសវៈ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **អរហតោ** ជាដើម ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីសួរបរវាទីនោះថា ធម៌ទាំងឡាយ មានមគ្គជាដើម ឈ្មោះថា មិនជាអារម្មណ៍របស់អាសវៈ មាន ធម៌ទាំងនោះប៉ុណ្ណោះ រមែងកើតដល់ព្រះអរហន្តឬ ទើបផ្តើមពាក្យថា **មគ្គោ ផលំ** ជាដើម ។ បរវាទីត្រូវសកវាទីសួរថា **ចក្ខុំ អនាសវំ** ក៏ឆ្លើយបដិសេធ ព្រោះចក្ខុនោះ ជាអារម្មណ៍របស់អាសវៈ ។ ត្រូវសួរលើកទី ២ បរវាទីឆ្លើយទទួល ព្រោះគិតថា ចក្ខុជារបស់បុគ្គលដែលមិនមានអាសវៈ ។

[ ៤៥១ ] ក្នុងបញ្ហាពោលអំពីការឲ្យចីវរ បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកលក្ខណៈនៃបញ្ហានេះថា ធម៌ឯណានីមួយ មិនជារម្មណ៍របស់អាសវៈផង ជាអារម្មណ៍របស់អារម្មណ៍នៃអាសវៈផង ។ ត្រូវសួរលើកទី ២ បរវាទីឆ្លើយទទួល ព្រោះគិតថា ចីវរជារបស់ព្រះអរហន្ត ដែលមិនមានអាសវៈ ហើយជារបស់បុថុជ្ជនដែលមានអាសវៈ ។ ក្នុងបញ្ហា ២ ថា **តញ្ញេវ អនាសវំ** ជាដើម ក៏ន័យនេះឯង តែសកវាទីចោទសួរ ព្រោះការទទួលរបស់បរវាទីក្នុងពាក្យថា **តញ្ញេវ** ដោយពាក្យជាដើមថា **មគ្គោ អនាសវោ ហុត្វា** ជាដើម ។ គប្បីជ្រាបអត្ថទាំងពួង ដោយឧបាយនេះឯង ៕

**អដ្ឋកថាអនាសវកថា ចប់**

# អភិធម្មបិដក

## សមន្នាគតកថា

[ ៤៥៨ ] ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤ ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៥៩ ] អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយផស្សៈ ៣ ។បេ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦០ ] សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយផស្សៈ ២ ។បេ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦១ ] ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្តជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្តប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាសកទាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាអនាគាមិបុគ្គល គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតអកនិដ្ឋគាមីឬ ។ អ្នកមិនគួរពោលយ៉ាងនេះ

ទេ ។បេ។

[ ៤៦២ ] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៣ ] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៤ ] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៥ ] បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ។

[ ៤៦៦ ] បុគ្គល ប្រកបដោយអនាគាមិផល គួរនិយាយថា អនាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។

ព្រះអរហន្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៧ ] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៨ ] បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៦៩ ] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧០ ] ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលទេ ។

[ ៤៧១ ] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកប

ដោយសោតាបត្តិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតា-បត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ រាគៈដែលជាដំណើរទៅកាន់អបាយ ទោសៈ ដែលជាដំណើរទៅកាន់អបាយ និងមោហៈដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧២ ] ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្តប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសកទាគាមិផលទេ ។

[ ៤៧៣ ] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាតហើយ ប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧៤ ] ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្តប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថាព្រះអរហន្ត ប្រកបដោយអនាគាមិផលទេ ។

[ ៤៧៥ ] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ប្រកប

ដោយអនាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិ-មគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើងហើយ ប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧៦ ] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលទេ ។

[ ៤៧៧ ] អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។បេ។ មោហៈ ដែលជាដំណើរទៅកាន់អបាយហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៧៨ ] អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលទេ ។

[ ៤៧៩ ] អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោត

គ្រាតហើយ ប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨០ ] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលទេ ។

[ ៤៨១ ] សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។បេ។ និងមោហៈដែលជាដំណើរទៅកាន់អបាយហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨២ ] បុគ្គល មិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយផល ៤ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បានចំពោះនូវផល ៤ ហើយ មិនសាបសូន្យចាកផល ៤ នោះទេឬ ។ អើ ។ បើព្រះអរហន្ត បានចំពោះនូវផល ៤ មិនសាបសូន្យចាកផល ៤ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយផល ៤ ដែរ ។

[ ៤៨៣ ] បុគ្គល មិនគួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយផល ៣ ទេឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយ មិនសាបសូន្យចាកផលនោះទេឬ ។ អើ ។ បើអនាគាមិបុគ្គល បានចំពោះនូវ

ផល ៣ ហើយ មិនសាបសូន្យចាកផល ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគាមិបុគ្គលប្រកបដោយផល ៣ ដែរ ។

[ ៤៨៤ ] បុគ្គល មិនគួរនិយាយថា សកទាគាមិបុគ្គលប្រកបដោយផល ២ ទេឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយ មិនសាបសូន្យចាកផល ២ នោះទេឬ ។ អើ ។ បើសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយ មិនសាបសូន្យចាកផល ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល ប្រកបដោយផល ២ ដែរ ។

[ ៤៨៥ ] ព្រះអរហន្ត បានចំពោះនូវផល ៤ ហើយ មិនសាបសូន្យចាកផល ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត បានចំពោះនូវមគ្គ ៤ ហើយ មិនសាបសូន្យចាកមគ្គ ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយមគ្គ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨៦ ] អនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយ មិនសាបសូន្យចាកផល ៣ នោះទេឬ ។ អនាគាមិបុគ្គលប្រកបដោយផល ៣ ឬ ។

អើ ។ អនាគាមិបុគ្គលបានចំពោះនូវមគ្គ ៣ ហើយ មិនសាបសូន្យបាកមគ្គ ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយមគ្គ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨៧ ] សកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយ មិនសាបសូន្យបាកផល ២ នោះទេឬ ។ សកទាគាមិបុគ្គលប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល បានចំពោះនូវមគ្គ ២ ហើយ មិនសាបសូន្យបាកមគ្គ ២ នោះទេឬ ។ សកទាគាមិបុគ្គលប្រកបដោយមគ្គ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**សមន្នាគតកថា ចប់**

# អដ្ឋកថា

## សមន្នាគតកថា

[ ៤៥៨ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលប្រកបដូចតទៅ

ក្នុងរឿងនោះ បុគ្គលប្រកប មាន ២ យ៉ាង គឺបុគ្គលប្រកបក្នុងភាពជាអ្នកព្រមព្រៀងគ្នា ក្នុងខណៈនៃបច្ចុប្បន្ន ១ បុគ្គលប្រកបក្នុងការបានចំពោះ ដោយសម្រេចភូមិណាមួយ មានរូបាវចរជាដើម ១ ។ បុគ្គលប្រកបនោះ មិនទាន់វិនាសចាកគុណវិសេស ដែលខ្លួនសម្រេចហើយ ដរាបណា ក៏ឈ្មោះថា ជាអ្នកបាននូវគុណវិសេសដរាបនោះឯង ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា វៀរបុគ្គលប្រកប ២ យ៉ាងនេះហើយ ឈ្មោះថា បុគ្គលប្រកបប្រភេទមួយដទៃមាន ដោយអំណាចនៃបត្តិធម៌ គឺធម៌ដែលសម្រេច ដូច្នេះ ដើម្បីឲ្យជនទាំងនោះយល់តាមថា ឈ្មោះថា បត្តិធម៌មាន អ្វីដទៃមិនមាន ទើបសកវាទីសួរថា **អរហា ចតូហិ ផលេហិ សមន្នាគតោ** ដូច្នេះ ពាក្យឆ្លើយទទួល សំដៅយកការសម្រេចផល ជាពាក្យរបស់បរវាទី ។ លំដាប់នោះទើបសកវាទីផ្ដើមពាក្យថា **អរហា ចតូហិ ផស្សេហិ** ជាដើម ដើម្បីចោទសួរថា បើព្រះអរហន្តប្រកបដោយផលទាំង ៤ ដូចដល់ព្រមដោយនាមក្ខន្ធ ៤ សោត កាលបើភាពយ៉ាងនោះមាន ធម៌ទាំងឡាយពួកណា មានផស្សៈជាដើម នីមួយៗ ៤ ក្នុងផលទាំង ៤ ធម៌ទាំងនោះ ក៏រមែងដល់ព្រមដល់ព្រះអរហន្ត តាមលទ្ធិរបស់អ្នក ។ ពាក្យទាំងពួងនោះ បរវាទីឆ្លើយបដិសេធហើយ ព្រោះមិនមានផស្សៈជាដើម នីមួយៗ ៤ ក្នុងខណៈជាមួយគ្នា ។ ក្នុង

បញ្ហាពោលអំពីព្រះអនាគាមីក៏មានន័យនេះដូចគ្នា ។

[ ៤៧១ ] បទថា **សោតាបត្តិផលំ វីតិវត្តោ** អធិប្បាយថា សកវាទី រមែងសួរថា ព្រះអរហន្តកន្លង ( សោតាបត្តិផល ) ព្រោះការមិនកើតឡើង ទៀត មិនដូចទុតិយជ្ឈានលាភីបុគ្គល ដែលឆ្លងហួសបឋមជ្ឈានទៅហើយ នោះទេ ។ បទថា **សោតាបត្តិមគ្គំ** ជាដើម ដែលសកវាទីប្រារព្ធហើយ ក៏ដើម្បីសម្តែងដល់ការមិនប្រកបទៀត ដោយមគ្គដែលបតិបត្តិ កន្លងហួស ទៅហើយ របស់ព្រះអរហន្តនោះ ។

[ ៤៨៣ ] ក្នុងបញ្ហាថា **តេហិ ច អបរិហីនោ** សេចក្តីថា ព្រោះធម៌ គឺលោកិយជ្ឈានទាំងឡាយ រមែងវិនាសដោយធម៌ដែលជាសត្រូវ យ៉ាងណា លោកុត្តរធម៌ មិនដូច្នោះឡើយ ។ ពិតហើយ កិលេសទាំងឡាយណា ដែល មគ្គលះ និងរមែងស្ងប់រម្ងាប់ទៅដោយផល កិលេសទាំងនោះ លោកក៏លះ ហើយ ជាធម្មជាតស្ងប់រម្ងាប់ទៅហើយ យ៉ាងនោះៗ ព្រោះហេតុនោះ ទើប សកវាទីឆ្លើយទទួលថា **អាមន្តា** ។

[ ៤៨៥ ] អត្ថនោះឯង លោកអធិប្បាយហើយ ក្នុងពាក្យទាំងឡាយ ខាងមុខ ដែលមានពាក្យថា **អរហតា ចត្តារោ មគ្គា បដិលទ្ធា** ជាដើម ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាសមន្នាគតកថា ចប់**

# អភិធម្មបិដក

## ឧបេក្ខាសមន្នាគតកថា

[ ៤៨៨ ] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៦ ដោយវេទនា ៦ ដោយសញ្ញា ៦ ។បេ។ ដោយបញ្ញា ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៨៩ ] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត កាលឃើញរូបដោយចក្ខុ រមែងឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ។បេ។ កាលដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងឃើញរូបដោយចក្ខុ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩០ ] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ មានចិត្តខ្ជាប់ខ្ជួន ទៀងទាត់ មិនរាយមាយ ចុះឧបេក្ខាទាំង ៦ តាំងឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩១ ] បុគ្គល មិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានឧបេក្ខា ៦ ឬ ។ អើ ។ បើព្រះអរហន្ត មានឧបេក្ខា ៦ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ។

ឧបេក្ខាសមន្នាគតកថា ចប់

# អដ្ឋកថា

## ឧបេក្ខាសមន្នាគតកថា

[ ៤៨៨ ] ក្នុងបទថា **អរហា ធម្មេហិ ឧបេក្ខាហិ** បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះ គឺន័យដែលពោលមកហើយ ។ ពិតហើយ ព្រះមានព្រះភាគរមែងហៅព្រះអរហន្តថា បុគ្គលប្រកបដោយឧបេក្ខាទាំងនោះ ព្រោះឧបេក្ខាក្នុងទ្វារទាំង ៦ គួរកើតឡើងដល់លោកបាន មិនមែនព្រោះឧបេក្ខាទាំងអស់កើតឡើងដល់លោកក្នុងខណៈតែមួយ ៕

**អដ្ឋកថាឧបេក្ខាសមន្នាគតកថា ចប់**

# អភិធម្មបិដក

## ពោធិយា ពុទ្ធោតិកថា

[ ៤៩២ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ ( ចតុម្មគ្គញ្ញាណ និងសព្វញ្ញុតញ្ញាណឬ ) ។ អើ ។ បុគ្គល កាលបើពោធិញ្ញាណរលត់ហើយ ទៅប្រាសហើយ ស្ងប់រម្ងាប់ហើយ មិនឈ្មោះថា ព្រះពុទ្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៣ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធដោយពោធិញ្ញាណជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៤ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីតឬ ។ អើ ។ ព្រះពុទ្ធធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៥ ] ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធកំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៦ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធដោយពោធិញ្ញាណជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៧ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគតឬ ។ អើ ។ ព្រះពុទ្ធធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរ

ពោលយ៉ាងនេះទេ ។បេ។

[ ៤៩៨ ] ព្រះពុទ្ធធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធកំណត់ដឹងនូវទុក្ខសច្ច ។បេ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៤៩៩ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០០ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត កំណត់ដឹងនូវទុក្ខសច្ច ។បេ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០១ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ចដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធដោយពោធិញ្ញាណជាអនាគត ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០២ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច ។បេ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។

បុគ្គលជាព្រះពុទ្ធដោយពោធិញ្ញាណជាអនាគត កំណត់ដឹងនូវទុក្ខសច្ច ។បេ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៣ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៤ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។បេ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។បេ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៥ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៦ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។បេ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់

ដឹងនូវទុក្ខសច្ច ។បេ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៧ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៨ ] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អើ ។ បុគ្គលជាព្រះពុទ្ធ ប្រកបដោយពោធិញ្ញាណទាំង ៣ មានចិត្តខ្ជាប់ខ្ជួន ទៀងទាត់ មិនរាយមាយ ចុះពោធិញ្ញាណទាំង ៣ តាំងនៅប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥០៩ ] បុគ្គលមិនគួរនិយាយថា បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណទេឬ ។ អើ ។ ក្រែងបុគ្គលជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ អើ ។ បើបុគ្គលជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណដែរ ។

[ ៥១០ ] បុគ្គលជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ ការត្រាស់ដឹង ព្រោះការបានចំពោះនូវពោធិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**ពោធិយា ពុទ្ធោតិកថា ចប់**

# អដ្ឋកថា

## ពោធិយាពុទ្ធោតិកថា

[ ៤៩២ ] ឥឡូវនេះ នឹងពណ៌នាអំពីឈ្មោះថា **ពុទ្ធ** ព្រោះពោធិ គឺបញ្ញាជាគ្រឿងត្រាស់ដឹងដូចតទៅ

ក្នុងរឿងនោះ បទថា **ពោធិ** ជាឈ្មោះនៃមគ្គញ្ញាណ ៤ ខ្លះ ជាឈ្មោះនៃសព្វញ្ញុតញ្ញាណខ្លះ ព្រោះហេតុនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយនោះឯង ក្នុងខណៈនេះថា ឈ្មោះថា ជាព្រះពុទ្ធ ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹង ដូចពាក្យថា ឈ្មោះថា មនុស្សសម្បុរ-ស ព្រោះស្បែក-ស មនុស្សសម្បុរខ្មៅ ព្រោះស្បែកខ្មៅ ដូច្នេះ ពាក្យសួរក្តី ពាក្យចោទសួរក្តីរបស់សកវាទី សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួលក្តី ពាក្យបដិសេធក្តី ជាពាក្យរបស់បរវាទី ។

[ ៤៩៣ ] ក្នុងបញ្ហាថា **អតីតាយ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានក្នុងខណៈនោះ ។

[ ៤៩៤ ] ត្រូវសួរលើកទី ២ លោកឆ្លើយទទួល សំដៅយកការបាន ដោយចំពោះ ។ ត្រូវសួរដោយអំណាចនៃកិច្ចទៀត លោកក៏ឆ្លើយបដិសេធ ព្រោះមិនមានកិច្ច ។

[ ៤៩៥ ] ត្រូវសួរលើកទី ២ លោកឆ្លើយទទួល នូវភាពមិនវង្វេង ក្នុងកិច្ចដែលគួរធ្វើ ដោយបញ្ញាជាគ្រឿងត្រាស់ដឹងនោះ ដែលបុគ្គលនោះធ្វើហើយ ។ ឯសកវាទីមិនឲ្យឱកាសដែលមានលេសន័យ ទើបសួរដោយ

ន័យថា **ឥក្កុំ បរិជានាតិ** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានកិច្ចនោះ ។

[ ៤៩៦ ] ក្នុងបញ្ហាពោលអំពីអនាគត បរវាទីឆ្លើយបដិសេធ ព្រោះមិនមានមគ្គញ្ញាណ ក្នុងខណៈនោះ ។

[ ៤៩៧ ] ត្រូវសួរលើកទី ២ បរវាទីសម្គាល់នូវភាពជាព្រះពុទ្ធ ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹងដែលជាអនាគត ដោយព្រះបាលី ( ក្នុងសុត្តនិបាត ) ថា ព្រះពុទ្ធមានលក្ខណៈ ដ៏ប្រសើរបរិបូណ៌ ទ្រង់យានទៅកាន់ក្រុងរាជគ្រឹះ ដូច្នេះជាដើម ទើបឆ្លើយទទួល ។ ត្រូវសួរថា **ពោធិករណីយំ ករោតិ** បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានកិច្ច ក្នុងខណៈនោះ ។

[ ៤៩៨ ] ត្រូវសួរលើកទី ២ លោកឆ្លើយទទួល ព្រោះគិតថា បើមិនគប្បីធ្វើ ក៏មិនគប្បីត្រូវថ្វាយព្រះនាមថា ព្រះពុទ្ធ ព្រោះនឹងធ្វើពិតប្រាកដ ហេតុនោះ ទើបឈ្មោះថា ធ្វើនោះឯង ។ ត្រូវសកវាទីសួរដោយមិនឲ្យឱកាស ដែលមានលេសន័យទៀត ក៏ឆ្លើយបដិសេធ ។

[ ៤៩៩ ] បញ្ហាពោលដោយបច្ចុប្បន្ន ព្រមទាំងការប្រៀបធៀប មានអត្ថងាយយល់ហើយ ។

[ ៥០៧ ] ត្រូវសកវាទីសួររួមបញ្ញាជាគ្រឿងត្រាស់ដឹង ៣ យ៉ាង ( ដែលជាអតីត អនាគត និងបច្ចុប្បន្ន ) ចូលគ្នាតែមួយ បរវាទីសំដៅយកសព្វញ្ញុតញ្ញាណ ទើបឆ្លើយទទួល ព្រោះភាវៈដែលបុគ្គលគប្បីពោលថា ជាព្រះពុទ្ធដោយពោធិទាំង ៣ ។ ត្រូវសួរថា **តីហិ** ទៀត បរវាទីឆ្លើយបដិសេធ

ព្រោះញាណទាំង ៣ នោះ មិនមានក្នុងខណៈជាមួយគ្នា ។

[ ៥០៨ ] ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ដោយអំណាចនៃសព្វញ្ញុតញ្ញាណដែលជាអតីត អនាគត និងបច្ចុប្បន្ន ។ សកវាទីមិនឲ្យឱកាសដែលមានលេសន័យ ទើបសួរទៀតថា **សតតំ សមិតំ** ជាដើម បរវាទីក៏ឆ្លើយបដិសេធ ។

[ ៥០៩ ] ពាក្យសួរថា **ន វត្តព្វំ ពោធិយា** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី ព្រោះមិនមានការត្រឡប់ក្លាយទៅជាមិនមែនព្រះពុទ្ធ ក្នុងខណៈមិនមានបញ្ញាជាគ្រឿងត្រាស់ដឹង ។ ម្យ៉ាងទៀត ក្នុងបញ្ហាថា **ននុ ពោធិប្បដិលាភា** សកវាទីនោះឯងឆ្លើយទទួលថា **អាមន្តា** ព្រោះសភាពនៃសម្មតិថា មគ្គញ្ញាណ ពោល គឺបញ្ញាជាគ្រឿងត្រាស់ដឹងកើតឡើងហើយក្នុងសន្តានណា ឈ្មោះថា ជាព្រះពុទ្ធ ក្នុងសន្តាននោះ ។ ព្រោះមិនជ្រាបដល់ពាក្យអធិប្បាយរបស់សកវាទី ទើបបរវាទីតាំងលទ្ធិដោយពាក្យថា **ហញ្ចិ** ដូច្នេះ ។

[ ៥១០ ] ឥឡូវនេះ ជាពាក្យសួររបស់សកវាទីថា **ពោធិប្បដិលាភា ពុទ្ធោតិ ពោធិយា ពុទ្ធោ** ដើម្បីធ្វើភាពដែលបរវាទីនោះ កំណត់មិនបានឲ្យប្រាកដ ។ បណ្ឌិតគប្បីជ្រាបអត្ថនៃបញ្ហានោះថា ព្រោះ ឈ្មោះថា **ពុទ្ធ** ព្រោះការបានចំពោះនូវបញ្ញាជាគ្រឿងត្រាស់ដឹង ព្រោះហេតុនោះ ទើបឈ្មោះថា **ពុទ្ធ** ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹង តាមលទ្ធិរបស់អ្នកឬ កាលបរវាទីមិនកំណត់វិភាគនេះថា កាលបញ្ញាជាគ្រឿងត្រាស់ដឹងកើតឡើងហើយ សូម្បី

រលត់ទៅហើយ ការៈដែលកើតឡើងហើយ ក្នុងសន្តាននោះឯង ឈ្មោះថា ការបានទូវបញ្ញាជាគ្រឿងត្រាស់ដឹង ញាណក្នុងខណៈនៃមគ្គ ឈ្មោះថា បញ្ញាជាគ្រឿងត្រាស់ដឹង ដូច្នេះ ទើបឆ្លើយទទួលទៀត ។ លំដាប់នោះ បរវាទីត្រូវសួរថា **ពោធិប្បដិលាភា ពោធិ** កាលមិនបានឱកាសនឹងពោលពាក្យណាមួយបាន ទើបលោកឆ្លើយបដិសេធ ដូច្នេះ ។ល។

## អដ្ឋកថាពោធិយាពុទ្ធោតិកថា ចប់

រឿងទាំង ៣ ដូចពណ៌នាមកនេះ ជារបស់និកាយឧត្តាបថកៈទាំងឡាយនោះឯង ។

# អភិធម្មបិដក

## លក្ខណាកថា

[ ៥១១ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ បទេសពោធិសត្វ ប្រកបដោយបទេសលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១២ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ តិភាគពោធិសត្វ ប្រកបដោយតិភាគលក្ខណៈឬ ។ អ្នកមិនពោលយ៉ាងនេះទេ ។បេ។

[ ៥១៣ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ឧបឌ្ឍពោធិសត្វ ប្រកបដោយឧបឌ្ឍលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ។បេ។

[ ៥១៤ ] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថា ពោធិសត្វឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១៥ ] ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថា ពោធិសត្វឬ ។ អើ ។ បុព្វយោគ បុព្វចរិយា ការពោលធម៌ ការសម្ដែងធម៌ របស់ពោធិសត្វ យ៉ាងណា បុព្វយោគ បុព្វចរិយា ការពោលធម៌ ការសម្ដែងធម៌របស់ចក្កវត្តិសត្វ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១៦ ] កាលពោធិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១៧ ] កាលពោធិសត្វប្រសូត ទេវបុត្តទាំង ៤ ទទួលហើយ តម្កល់ទុកក្នុងទីចំពោះមុខនៃព្រះមាតាថា បពិត្រនាងទេវី ព្រះនាងចូរត្រេកអរថា បុត្ររបស់នាង មានសក្តិធំ កើតហើយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទេវបុត្តទាំង ៤ ទទួលហើយ តម្កល់ទុកក្នុងទីចំពោះមុខនៃព្រះមាតាថា បពិត្រនាងទេវី ព្រះនាងចូរត្រេកអរថា បុត្ររបស់ព្រះនាងមានសក្តិធំ កើតហើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១៨ ] ពោធិសត្វប្រសូត ទនៃទឹកពីរ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះព្រះពោធិសត្វផង ចំពោះព្រះមាតាផង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទនៃទឹកពីរ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះចក្កវត្តិសត្វផង ចំពោះព្រះមាតាផង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥១៩ ] ព្រះពោធិសត្វប្រសូតមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលធ្វើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះជាជាតិទីបំផុត ( របស់អញ ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ យ៉ាងណា ចក្កវត្តិសត្វប្រសូតមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំង

ស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលផ្ដើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះជាជាតិទីបំផុត ( របស់អញ ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២០ ] កាលព្រះពោធិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២១ ] កាយប្រក្រតី របស់ពោធិសត្វ រមែងភ្លឺទៅ ១ ព្យាមដោយជុំវិញ យ៉ាងណា កាយប្រក្រតីរបស់ចក្កវត្តិសត្វរមែងភ្លឺទៅ ១ ព្យាមដោយជុំវិញ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២២ ] ព្រះពោធិសត្វឃើញមហាសុបិន យ៉ាងណា ចក្កវត្តិសត្វឃើញមហាសុបិន ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២៣ ] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ ប្រកបដោយលក្ខណៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាបុរស ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ នេះ រមែងមានតែគតិ ២ យ៉ាងប៉ុណ្ណោះ មិនមែនខុសអំពីគតិ ២ យ៉ាងនោះទេ គឺថា បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្កពត្តិ ជាធម្មរាជប្រកបដោយធម៌ ជាឥស្សរៈលើផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុត ឈ្នះអស់សត្រូវទាំងខាងក្នុង

ខាងក្រៅ ដល់នូវភាពមាំមួនក្នុងជនបទ ប្រកបដោយកែវ ៧ ប្រការ ឯកែវទាំង ៧ ប្រការនេះ របស់ស្តេចចក្កពត្តិនោះ គឺចក្កកែវ ១ ដំរីកែវ ១ សេះកែវ ១ មណីកែវ ១ ស្ត្រីកែវ ១ គហបតីកែវ ១ បរិនាយកកែវ ១ ទៀតជាគម្រប់ ៧ ព្រះរាជានោះ មានព្រះរាជបុត្តច្រើនជាងពាន់ ដែលជាអ្នកក្លៀវក្លា មានសភាពអង់អាច អាចញាំញីនូវសេនានៃស្តេចដទៃបាន ព្រះរាជានោះ មានជ័យជម្នះ នៅគ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌ ដោយមិនមានគ្រឿងវាយដំ ដោយមិនមានគ្រឿងកាប់ចាក់ បើចេញចាកផ្ទះចូលទៅកាន់ផ្នួសវិញ នឹងបានជាអរហន្តសម្មាសម្ពុទ្ធ មានដំបូលគឺកិលេសបើកហើយ ក្នុងលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ ប្រកបដោយលក្ខណៈ ( ដោយពិត ) ។

## លក្ខណកថា ចប់

# អដ្ឋកថា

## លក្ខណកថា

[ ៥១១ ] ឥឡូវនេះ នឹងពណ៌នាអំពីលក្ខណៈដូចតទៅ

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា ព្រះពោធិសត្វប៉ុណ្ណោះ ដល់ព្រមហើយដោយលក្ខណៈ ព្រោះកាន់យកដោយមិនពិចារណានូវព្រះសូត្រ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) នេះថា កាលបើមហាបុរស ប្រកបដោយមហាបុរិសលក្ខណៈណាហើយ គង់មានគតិជាពីរយ៉ាង ដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៥១៤ ] ក្នុងបញ្ហាទាំងឡាយថា **ចក្កវត្តិសត្តោ** សេចក្តីថា ព្រោះសត្វដែលជាចក្កពត្តិ ជាព្រះពោធិសត្វក៏មាន មិនមែនព្រះពោធិសត្វក៏មាន ព្រោះហេតុនោះ បរវាទីសំដៅយកបុគ្គលមិនមែនព្រះពោធិសត្វ ទើបឆ្លើយបដិសេធ ។ សំដៅយកបុគ្គលជាព្រះពោធិសត្វ ទើបឆ្លើយទទួល ។

[ ៥២៣ ] ព្រះសូត្រថា **ទ្វត្តឹសិមានិ** បរវាទីពោលហើយ សំដៅយកព្រះពោធិសត្វប៉ុណ្ណោះ ព្រោះថា ក្នុងកពចុងក្រោយ ព្រះពោធិសត្វនោះរមែងបានជាព្រះពុទ្ធ ។ ក្នុងជនទាំងឡាយក្រៅអំពីនេះ ជាស្តេចចក្កពត្តិ ( តែមិនជាព្រះពុទ្ធ ) ព្រោះហេតុនោះ ព្រះសូត្រដែលបរវាទីនាំមកអាងហើយ ដូចគ្នានឹងមិនទាំមកនោះឯង ដូច្នេះ ។ ល។

# អភិធម្មបិដក

## និយាមោក្កន្តិកថា

[ ៥២៤ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អើ ។ ព្រះពោធិសត្វ ជាសាវ័កនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២៥ ] ព្រះពោធិសត្វ ជាសាវ័កនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អើ ។ ( ព្រះពោធិសត្វ ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២៦ ] ( ព្រះពោធិសត្វ ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អើ ។ ( បុគ្គលជាព្រះពុទ្ធ ) ប្រកបដោយការស្តាប់តាមគេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២៧ ] ( បុគ្គលជាព្រះពុទ្ធ ) ប្រកបដោយការស្តាប់តាមគេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯងឬ ។ អើ ។ បើព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ( បុគ្គលជាព្រះពុទ្ធ ) ប្រកបដោយការស្តាប់តាមគេទេ ។

[ ៥២៨ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈដែរឬ ។ អើ ។ សាមញ្ញផល ៣ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃ

ពោធិព្រឹក្សឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥២៩ ] ក្រែងសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹងទៀបគល់នៃពោធិព្រឹក្សឬ ។ អើ ។ បើសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វមាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេ ។

[ ៥៣០ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អើ ។ ព្រះពោធិសត្វ បានធ្វើទុក្ករិយាដែរឬ ។ អើ ។ បុគ្គលបរិបូណ៌ដោយទស្សនៈ គប្បីធ្វើទុក្ករិយាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣១ ] ព្រះពោធិសត្វ បានធ្វើអំពើដែលមិនញ៉ាំងបុគ្គលដទៃ ឲ្យក្តៅក្រហាយ ហើយឧទ្ទិសចំពោះសាស្តាដទៃដែរឬ ។ អើ ។ បុគ្គលបរិបូណ៌ដោយទស្សនៈ គប្បីឧទ្ទិសចំពោះសាស្តាដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣២ ] ព្រះអានន្ទមានអាយុ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះអានន្ទមានអាយុជាសាវ័កនៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបៈ ព្រះពោធិសត្វ ជាសាវ័កនៃព្រះមានព្រះភាគ ទ្រង់ព្រះ

នាមកស្សបៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣៣ ] ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ ជាសាវកនៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ ព្រះពោធិសត្វ ជាសាវកនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣៤ ] ព្រះពោធិសត្វ មាននិយាមយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ តែមិនមែនជាសាវក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេឬ ។ អើ ។ ព្រះអានន្ទមានអាយុ មាននិយាមយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ តែមិនមែនជាសាវក នៃព្រះមានព្រះភាគទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣៥ ] ព្រះពោធិសត្វ មាននិយាមយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ តែមិនមែនជាសាវក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេឬ ។ អើ ។ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ តែមិនមែនជា

សាវ័កនៃព្រះមានព្រះភាគទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣៦ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ តែមិនមែនជាសាវ័កនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេឬ ។អើ ។ សាវ័កដែលប្រព្រឹត្តកន្លងនូវជាតិហើយ មិនមែនជាសាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៣៧ ] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតបានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ ដើម្បីត្រាស់ដឹងតទៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈដែរ ។

[ ៥៣៨ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹង
នូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេស ក្នុង

តេភូមិកធម៌ទាំងអស់ទេ លះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះការអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ ដោយខ្លួនឯង ( ចាំបាច់ ) ឧទ្ទិស បុគ្គលណា តថាគត មិនមានអាចារ្យទេ បុគ្គលដទៃស្មើនឹង តថាគតមិនមានឡើយ ក្នុងលោក ព្រមទាំងទេវលោក មិន មានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះថា តថាគត ជាអរហន្តក្នុងលោក តថាគតជាសាស្តាខ្ពង់ខ្ពស់បំផុត តថាគត ជាសម្មាសម្ពុទ្ធឯក មានសេចក្តីត្រជាក់ មានភ្លើងកិលេស រលត់ហើយ ឥឡូវនេះ តថាគត ទៅកាន់បុរី នៃពួកជនអ្នក កាសី ដើម្បីសម្តែងធម្មចក្ក ( ដោយបំណងថា ) តថាគតនឹង ទូងស្គរ គឺអមតនិព្វាន ចំពោះសត្វលោក ដែលងងឹត គឺអវិជ្ជា កំពុងគ្របសង្កត់ ។

( ឧបកាជីវកតបថា ) ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកថាយ៉ាងណា អ្នក ( គួរដើម្បីបាននូវឈ្មោះ ) ថា អនន្តជិនៈ យ៉ាងនោះឯង ( ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទៀតថា )

ជនទាំងឡាយណា បានដល់នូវការអស់ទៅនៃអាសវៈ ជន ទាំងឡាយនោះ ឈ្មោះថា ជិនៈ ( អ្នកឈ្នះកិលេស ) ប្រាកដដូចជាតថាគតដែរ តថាគតបានឈ្នះបាបធម៌ទាំងឡាយ ហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគត បាននូវ

ឈ្មោះថា ជិនៈ ( អ្នកឈ្នះបាបធម៌ ) ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោល ថា ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈ ប្រព្រឹត្ត ហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេ ។

[ ៥៣៩ ] ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈ ប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើត ឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើង ហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគត មិនធ្លាប់បានឮ ក្នុងកាលពីមុនមកថា នេះជាទុក្ខអរិយសច្ច ដូច្នេះឡើយ ម្នាល ភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទុ៎ះឯង ជាទុក្ខអរិយសច្ច ដែលបុគ្គល គួរកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។បេ។ ពន្លឺកើតឡើង ហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮ ក្នុងកាល ពីមុនមកថា ទុក្ខនោះឯង ដែលតថាគតបានកំណត់ដឹងហើយ ម្នាលភិក្ខុទាំង ឡាយ ។បេ។ ដល់តថាគតថា នេះជាទុក្ខសមុទយអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទុ៎ះឯង ជាទុក្ខសមុទយអរិយ-សច្ច ដែលបុគ្គលគួរលះបោល ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា ទុ៎ះឯង ជាទុក្ខសមុទយអរិយសច្ច ដែលតថាគតបានលះបោលហើយ ម្នាល ភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះ

ឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នុ៎ះឯង ជាទុក្ខនិរោធ-អរិយសច្ច ដែលបុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នុ៎ះឯង ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នេះជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។បេ។ ដល់តថាគតថា នុ៎ះឯង ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលបុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮ ក្នុងកាលពីមុនមកថា នុ៎ះឯង ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលតថាគតបានចម្រើនហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមយានចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនានៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈទេ ។

**និយាមោក្កន្តិកថា ចប់**

# អដ្ឋកថា

## និយាមោក្កន្តិកថា

[ ៥២៤ ] ឥឡូវនេះ នឹងពោលអំពីការឈមចុះកាន់និយាមដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា ព្រះពោធិសត្វបានឈមចុះកាន់និយាមមានព្រហ្មចរិយៈដែលប្រព្រឹត្តហើយ ក្នុងព្រះធម្មវិន័យរបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ព្រោះសំដៅយកបព្វជ្ជារបស់ជោតិបាលក្នុងឃដិការសូត្រ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរដោយពាក្យថា **ពោធិសត្តោ** ជាដើម ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ បន្ទាប់អំពីនោះ ព្រោះពាក្យថា និយាមក្តី ព្រហ្មចរិយៈក្តី ជាឈ្មោះនៃអរិយមគ្គ ។ ម្យ៉ាងទៀត វៀរការបំពេញបារមីរបស់ព្រះពោធិសត្វចេញហើយ ឈ្មោះថាការឈមចុះកាន់និយាមដទៃ រមែងមិនមាន ។ បើព្រះពោធិសត្វ គប្បីជាព្រះសោតាបន្ន គប្បីជាអរិយសាវកសោត សេចក្តីនោះ ប្រព្រឹត្តទៅមិនបាន ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់តាំងនៅក្នុងកម្លាំង គឺព្រះញាណរបស់ព្រះអង្គ រមែងទ្រង់ព្យាករព្រះពោធិសត្វនោះថា បុគ្គលនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រោះហេតុនោះ ទើបសកវាទីសួរដោយពាក្យថា **ពោធិសត្តោ** ជាដើមម្តងទៀត ។ ពាក្យឆ្លើយបដិសេធ ជាពាក្យរបស់បរវាទី ព្រោះសំដៅយកបច្ឆិមភព គឺភពចុងក្រោយ ។

[ ៥២៥ ] ក្នុងបញ្ហាទី ២ បរវាទីនោះឆ្លើយទទួល ព្រោះសំដៅយក

វេលាដែលព្រះពោធិសត្វ កាលនៅជាជោតិបាល ។ ក្នុងបទទាំងឡាយ មានបទថា **សាវកោ ហុត្វា** ជាដើម ក៏ន័យនេះឯង ។

[ ៥២៦ ] បទថា **អនុស្សវិយោ** សំដៅសេចក្តីថា បុគ្គលមានធម៌ដែលចាក់ធ្លុះហើយ ដោយការស្តាប់តៗ គ្នាមក ។ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកបច្ឆិមភព ហើយរមែងឆ្លើយទទួល ព្រោះសំដៅយកការស្តាប់តៗ គ្នាមក ក្នុងកាលនៅជាជោតិបាល ។

[ ៥៣១ ] បទថា **អញ្ញំ សត្ថារំ** សកវាទី ពោលហើយសំដៅយកអាឡារតាបស និងរាមបុត្តតាបស ។

[ ៥៣២ ] បទថា **អាយស្មា អានន្ទោ** ជាដើម សកវាទីពោលហើយដើម្បីសម្តែងថា បុគ្គលឈមចុះកាន់និយាមប៉ុណ្ណោះ ជាសាវក ក្រៅអំពីនេះមិនមែនសាវកឡើយ តែបុគ្គលឈមចុះកាន់និយាមបែបនេះ មាន ដូច្នេះ ។

[ ៥៣៦ ] បទថា **សាវកោ ជាតឹ វីតិវត្តោ** សេចក្តីថា សកវាទីរមែងសួរថា ជាព្រះសាវកដោយជាតិណា តែលុះកន្លងជាតិនោះទៅហើយ មិនជាសាវកក្នុងភពដទៃឬ ដូច្នេះ បរវាទីឆ្លើយបដិសេធ ព្រោះភាពដែលព្រះសោតាបន្នជាដើមជាសាវក ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថានិយាមោក្កន្តិកថា ចប់

# អភិធម្មបិដក

## អបរាបិ សមន្នាគតកថា

[ ៥៤០ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវិរិយៈ ៤ ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤១ ] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ ឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគមិផល ប្រកបដោយផស្សៈ ៣ ដោយវេទនា ៣ ។បេ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤២ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយផស្សៈ ២ ដោយវេទនា ២ ។បេ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៣ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលជាសោតាបន្ន គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៤ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៥ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គលជាអនាគាមី គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោត អកនិដ្ឋគាមី ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៦ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលជាសោតាបន្ន គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៧ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៨ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផលប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលជាសោតាបន្ន គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៤៩ ] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិ-ផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥០ ] គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគា-មិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥១ ] គួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥២ ] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិ-ផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥៣ ] គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគា-មិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល

ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥៤ ] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផលប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥៥ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលទេ ។

[ ៥៥៦ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ នូវវិចិកិច្ឆា នូវសីលព្វតបរាមាសៈ នូវរាគៈ ជាដំណើរទៅកាន់អបាយ នូវទោសៈ ជាដំណើរទៅកាន់អបាយ នូវ

មោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេឬ ។បេ។

[ ៥៥៧ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលទេ ។

[ ៥៥៨ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទា-គាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគដ៏គ្រោតគ្រាត នូវព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៥៩ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលទេ ។

[ ៥៦០ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តនូវកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រោលស្តើង នូវព្យាបាទដ៏ស្រោលស្តើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦១ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលទេ ។

[ ៥៦២ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។បេ។ នូវមោហៈ ជាដំណើរទៅកាន់អបាយហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦៣ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យ

ជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសកទាគាមិផលទេ ។

[ ៥៦៤ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត នូវព្យាបាទដ៏គ្រោតគ្រាតហើយ ប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦៥ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេ ។

[ ៥៦៦ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។

បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។បេ។ នូវមោហៈ ជាដំណើរទៅកាន់អបាយហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៦៧ ] បុគ្គលមិនគួរនិយាយថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ទេឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះនូវផលទាំង ៣ ហើយ មិនសាបសូន្យចាកផលទាំង ៣ នោះទេឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះនូវផលទាំង ៣ ហើយ មិនសាបសូន្យចាកផលទាំង ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ មែន ។

[ ៥៦៨ ] បុគ្គលមិនគួរនិយាយថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ ទេឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល បានចំពោះនូវផលទាំង ២ ហើយ មិនសាបសូន្យចាកផលទាំង ២ នោះទេឬ ។ អើ ។ បើបុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល បានចំពោះនូវផលទាំង ២ ហើយ មិនសាបសូន្យចាកផលទាំង ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវ

អនាគាមិផល ប្រកបដោយផល ២ មែន ។

[ ៥៦៩ ] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេឬ ។ អើ ។ ក្រែងបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល បានចំពោះនូវសោតាបត្តិផលហើយ មិនសាបសូន្យចាកសោតាបត្តិនោះទេឬ ។ អើ ។ បើបុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល បានចំពោះនូវសោតាបត្តិផលហើយ មិនសាបសូន្យចាកសោតាបត្តិផលនោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលដែរ ។

[ ៥៧០ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះនូវផល ៣ ហើយ មិនសាបសូន្យចាកផលទាំង ៣ នោះទេឬ ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផលទាំង ៣ ឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះនូវមគ្គ ៤ ហើយ មិនសាបសូន្យចាកមគ្គទាំង ៤ នោះទេឬ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយមគ្គទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧១ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល បានចំពោះនូវផល ២ ហើយ មិនសាបសូន្យចាកផលទាំង ២ នោះទេឬ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផលទាំង

២ ឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បាន ចំពោះនូវមគ្គ ៣ ហើយ មិនសាបសូន្យចាកមគ្គទាំង ៣ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយមគ្គទាំង ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧២ ] បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល បានចំពោះនូវសោតាបត្តិផលហើយ មិនសាបសូន្យចាកសោតបត្តិផលនោះទេ ឬ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ប្រកប ដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវ សកទាគាមិផល បានចំពោះនូវមគ្គ ២ ហើយ មិនសាបសូន្យចាកមគ្គទាំង ២ នោះទេឬ ។ បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ប្រកបដោយមគ្គទាំង ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**អបរាបិ សមន្នាគតកថា ចប់**

# អដ្ឋកថា

## អបរាបិ សមន្នាគតកថា

[ ៥៤០-៥៧២ ] ឥឡូវនេះ នឹងពណ៌នាអំពីបុគ្គលប្រកបដទៃទៀតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះថា បុគ្គលដែលតាំងនៅក្នុងមគ្គទី ៤ ជាបុគ្គលប្រកបដោយផល ៣ ដោយអំណាចនៃធម៌ដែលសម្រេច ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរឿងពោលអំពីបុគ្គលប្រកបដោយផល ៤ ខាងដើមនោះឯង ៕៚

**អដ្ឋកថាអបរាបិសមន្នាគតកថា ចប់**

# អភិធម្មបិដក

## សព្វសញ្ញោជនប្បហានកថា

[ ៥៧៣ ] ការលះបង់នូវសញ្ញោជនៈទាំងអស់ ឈ្មោះថា អរហត្តឬ ។ អើ ។ សញ្ញោជនៈទាំងអស់ ព្រះអរហន្តលះបង់ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧៤ ] សញ្ញោជនៈទាំងអស់ ព្រះអរហន្តលះបង់ដោយអរហត្តមគ្គឬ ។ អើ ។ ( ព្រះអរហន្ត ) លះនូវបង់នូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧៥ ] ព្រះអរហន្ត លះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់នូវសញ្ញោជនៈទាំង ៣ ឈ្មោះថា សោតាបត្តិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់នូវសញ្ញោជនៈទាំង ៣ ឈ្មោះថា សោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គទេ ។ សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយព្រះអរហត្តមគ្គឬ ។ អើ ។ ព្រះអរហន្ត លះបង់នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧៦ ] ព្រះអរហន្ត លះបង់នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់

ត្រាស់ថា ការស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ ឈ្មោះថា សកទាគាមិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ ឈ្មោះថា សកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គទេ ។

[ ៥៧៧ ] សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គឬ ។ អើ ។ ( ព្រះអរហន្ត ) លះបង់នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៧៨ ] ( ព្រះអរហន្ត ) លះបង់នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការបង់នូវកាមរាគៈ និងព្យាបាទ មិនឲ្យមានសេសសល់ ឈ្មោះថា អនាគាមិផលឬ ។ អើ ។ បើព្រះមានព្រះភាគទ្រង់ត្រាស់ថា ការលះបង់នូវកាមរាគៈ និងព្យាបាទ មិនឲ្យមានសេសសល់ ឈ្មោះថា អនាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គទេ ។

[ ៥៧៩ ] សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថា អរហត្តឬ ។ អើ ។ បើព្រះមានព្រះភាគទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ

មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថា អរហត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ដោយអរហត្តមគ្គទេ ។

[ ៥៨០ ] បុគ្គលមិនគួរនិយាយថា ការលះបង់នូវសញ្ញោជនៈទាំងអស់ ឈ្មោះថា អរហត្តទេឬ ។ អើ ។ ក្រែងសញ្ញោជនៈទាំងអស់ ព្រះអរហន្តលះបង់ហើយឬ ។ អើ ។ បើសញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការលះបង់នូវសញ្ញោជនៈទាំងអស់ ឈ្មោះថា អរហត្ត ។

សព្វសញ្ញោជនប្បហានកថា ចប់

ចតុត្ថវគ្គ ចប់

## ឧទ្ទាននៃចតុត្ថវគ្គនោះ គឺ

និយាយអំពីគ្រហស្ថ បានជាព្រះអរហន្ត ១ បានជាព្រះអរហន្តជាមួយគ្នានឹងការកើតឡើង ១ ពួកធម៌ទាំងអស់ មិនមានអាសវៈរបស់ព្រះអរហន្ត ១ ព្រះអរហន្តប្រកបដោយផលទាំងបួន ១ ព្រះអរហន្តប្រកបដោយឧបេក្ខា ៦ យ៉ាង ១ បានជាព្រះពុទ្ធដោយពោធិញ្ញាណ ១ ពោធិសត្វប្រកបព្រមដោយលក្ខណៈ ១ ព្រះពោធិសត្វមាននិយាម យាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ១ បុគ្គលអ្នកប្រតិបត្តិប្រកបដោយផល ១ ការលះបង់សញ្ញោជនៈទាំងអស់ ឈ្មោះថា អរហត្ត ១ ។

# អដ្ឋកថា

## សព្វសញ្ញោជនប្បហានកថា

[ ៥៧៣ ] ឥឡូវនេះ នឹងពណ៌នាការលះសំយោជនៈទាំងពួងដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈ ទាំងឡាយ ក្នុងខណៈនេះថា ការលះសំយោជនៈទាំងពួងបាន ដោយឥត សេសសល់ ជាអរហត្តផល ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំង នោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ បរវាទី ត្រូវសកវាទី សួរដោយពាក្យថា **សព្វេ សញ្ញោជនា** ទៀត ក៏ឆ្លើយបដិសេធ សំដៅយក ការលះកិលេសដោយមគ្គទាំង ៣ តាមដែលពោលហើយខាងដើម ។

[ ៥៧៤-៥៨០ ] បរវាទីត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះមិន មានកិលេស ដែលមិនទាន់លះបានដោយមគ្គនោះ ។ សូម្បីក្នុងបទថា **សក្កាយទិដ្ឋិ** ជាដើម បរវាទីសំដៅយកភាពដែលសក្កាយទិដ្ឋិជាដើម លះ បានហើយ ដោយបឋមមគ្គ ទើបឆ្លើយបដិសេធ ។ សំដៅយកការលះ កិលេសមិនសេសសល់ដោយមគ្គទី ៤ ទើបឆ្លើយទទួល ។ អត្ថក្នុងទីទាំង ពួង ក៏មានន័យនេះឯង ។

**អដ្ឋកថាសព្វសញ្ញោជនប្បហានកថា ចប់**

**វគ្គទី ៤ ចប់**

# អភិធម្មបិដក

## វិមុត្តកថា

[ ៥៨១ ] វិមុត្តិញាណ ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញាណណាមួយ វិមុត្តិញាណទាំងអស់នោះ ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញាណ ឈ្មោះថា វិមុត្តឬ ។ អើ ។ បច្ចវេក្ខណញាណ ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញាណ ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញាណ របស់បុគ្គលជាគោត្រភូ ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨២ ] វិមុត្តិញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា វិមុត្តឬ ។ អើ ។ ញាណរបស់សោតាបន្នបុគ្គល ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថា វិមុត្តឬ ។អើ។ ញាណរបស់សកទាគាមិបុគ្គល ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថា វិមុត្តឬ ។ អើ ។ ញាណរបស់អនាគាមិបុគ្គល ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិន

គួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឈ្មោះថា វិមុត្តឬ ។ អើ ។ ញាណរបស់ព្រះអរហន្ត ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨៣ ] វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយសោតាបត្តិផល ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលព្រមព្រៀងដោយសកទាគាមិផល ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលព្រមព្រៀងដោយអនាគាមិផល ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយអរហត្តផល ឈ្មោះថា វិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ឈ្មោះថា វិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨៤ ] វិមុត្តិញ្ញាណរបស់បុគ្គល ដែលព្រមព្រៀងដោយសោតាបត្តិផល ឈ្មោះថា វិមុត្តឬ ។ វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់

នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលព្រមព្រៀងដោយសកទាគាមិផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិ-ផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលព្រមព្រៀងដោយអនាគាមិផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិមុត្តិញ្ញាណរបស់បុគ្គល ដែលព្រមព្រៀងដោយអរហត្តផល ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឈ្មោះថា វិមុត្ត វិមុត្តនោះឯង ជាញាណរបស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

**វិមុត្តកថា ចប់**

# អដ្ឋកថា

## វិមុត្តកថា

[ ៥៨១ ] ឥឡូវនេះ នឹងពណ៌នាអំពីវិមុត្ត គឺការរួចផុតដូចតទៅ

ក្នុងរឿងនោះ បទថា **វិមុត្តិញ្ញាណំ** ជាឈ្មោះនៃញាណទាំង ៤ គឺ វិបស្សនា ១ មគ្គ ១ ផល ១ និងបច្ចវេក្ខណញ្ញាណ ១ បណ្តាញាណទាំងនោះ វិបស្សនាញាណ ឈ្មោះថា វិមុត្តិញ្ញាណ ព្រោះរួចផុតហើយចាកនិច្ចនិមិត្តជាដើម ឬព្រោះភាពជាតទង្គវិមុត្តិ មគ្គ ឈ្មោះថា សមុច្ឆេទវិមុត្ត ផល ឈ្មោះថា បដិបស្សទ្ធិវិមុត្ត បច្ចវេក្ខណញ្ញាណ រមែងដឹងនូវវិមុត្ត ព្រោះហេតុនោះ ទើបឈ្មោះថា វិមុត្តិញ្ញាណ ។ ក្នុងវិមុត្តិញ្ញាណ ៤ យ៉ាងនេះ ផលញ្ញាណប៉ុណ្ណោះ រួចផុតហើយដោយឥតសេសសល់ វិមុត្តិញ្ញាណ ៣ ដ៏សេស ដែលបុគ្គលណាមួយមិនគប្បីពោលថា រួចផុតហើយ ឬថា មិនរួចផុតហើយ ព្រោះហេតុនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា វិមុត្តិញ្ញាណ រួចផុតហើយ ដោយមិនប្លែកគ្នាឡើយ ព្រោះមិនពោលថា វិមុត្តិញ្ញាណឈ្មោះនេះ រួចផុតហើយ ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ត្រូវសួរទៀតថា **យំ កិញ្ចិ** បរវាទី ព្រោះសំដៅយកបច្ចវេក្ខណញ្ញាណជាដើម ទើបឆ្លើយបដិសេធ ។

[ ៥៨២ ] *បរវាទីត្រូវសួរថា* **បដិបន្នស្ស** *ជាដើម ក៏សំដៅយកការមិនមានអាសវៈរបស់មគ្គញ្ញាណ ទើបឆ្លើយទទួល ។ សកវាទីពោលថា* **សោតាបន្នស្ស** *ដូច្នេះជាដើមទៀត ដើម្បីចោទសួរថា ព្រោះញាណនោះមិនមែនញាណរបស់ព្រះសោតាបន្នដែលតាំងនៅក្នុងផល ព្រោះហេតុនោះ ញាណនោះ ឈ្មោះថា វិមុត្តិញ្ញាណឬ ដូច្នេះ ។ គប្បីជ្រាបអត្ថក្នុងទីទាំងពួងដោយឧបាយនេះ ដូច្នេះ ។*

## អដ្ឋកថាវិមុត្តកថា ចប់

# អភិធម្មបិដក

## អសេក្ខញាណកថា

[ ៥៨៥ ] អសេក្ខញាណ របស់អសេក្ខបុគ្គលមានដែរឬ ។ អើ ។ សេក្ខ-បុគ្គល ដឹង ឃើញនូវអសេក្ខធម៌ ( បានដល់នូវអសេក្ខធម៌ ) ដែលខ្លួនឃើញ ដឹង ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្ត នៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងសេក្ខបុគ្គល មិនដឹង មិន ឃើញ នូវអសេក្ខធម៌ ( មិនបានដល់នូវអសេក្ខធម៌ ) ដែលខ្លួនមិនឃើញ មិន ដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនបានពាល់ត្រូវ ដោយនាមកាយហើយ សម្រេច សម្រាន្តទេឬ ។ អើ ។ បើសេក្ខបុគ្គល មិនដឹង មិនឃើញនូវអសេក្ខធម៌ ( មិន បានដល់នូវអសេក្ខធម៌ ) ដែលខ្លួនមិនឃើញ មិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អសេក្ខញាណរបស់សេក្ខបុគ្គល មានទេ ។

[ ៥៨៦ ] អសេក្ខញាណ របស់អសេក្ខបុគ្គល មាន អសេក្ខបុគ្គល ដឹង ឃើញ នូវអសេក្ខធម៌ ( បានដល់នូវអសេក្ខធម៌ ) ដែលខ្លួនឃើញ ដឹង ធ្វើជាក់ច្បាស់ ពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តនៅឬ ។ អើ ។ អសេក្ខញាណ របស់សេក្ខបុគ្គល មាន សេក្ខបុគ្គល ដឹង ឃើញ នូវអសេក្ខធម៌ ( បានដល់នូវអសេក្ខធម៌ ) ដែលខ្លួនឃើញ ដឹង ធ្វើឲ្យជាក់ ច្បាស់ ពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តនៅដែរឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨៧ ] អសេក្ខញ្ញាណ របស់អសេក្ខបុគ្គល មាន សេក្ខបុគ្គលមិនដឹង មិនឃើញ នូវអសេក្ខធម៌ ( មិនបានដល់នូវអសេក្ខធម៌ ) ដែលខ្លួនមិនឃើញ មិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនពាល់ត្រូវ ដោយនាមកាយហើយសម្រេចសម្រាន្តនៅទេឬ ។ អើ ។ អសេក្ខញ្ញាណរបស់អសេក្ខបុគ្គល មានអសេក្ខបុគ្គល មិនដឹង មិនឃើញនូវអសេក្ខធម៌ ( មិនបានដល់នូវអសេក្ខធម៌ ) ដែលខ្លួនមិនឃើញ មិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនពាល់ត្រូវដោយនាមកាយហើយ សម្រេចសម្រាន្តនៅទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨៨ ] អសេក្ខញ្ញាណរបស់សេក្ខបុគ្គល មានដែរឬ ។ អើ ។ ញាណក្នុងសោតាបត្តិមគ្គ របស់បុគ្គលជាគោត្រភូ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងសោតាបត្តិផល របស់បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដើម្បីឲ្យជាក់ច្បាស់នូវសកទាគាមិផល ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។បេ។ ញាណក្នុងព្រះអរហត្ត របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៨៩ ] បុគ្គលមិនគួរនិយាយថា អសេក្ខញ្ញាណ របស់សេក្ខបុគ្គល មានទេឬ ។ អើ ។ ក្រែងព្រះអានន្ទមានអាយុ ជាសេក្ខបុគ្គល រមែងដឹងថា ព្រះមានព្រះភាគ ព្រះអង្គលើសលុប រមែងដឹងថា ព្រះថេរៈឈ្មោះសារីបុត្ត និងព្រះថេរៈឈ្មោះមហាមោគ្គល្លាន លោកលើសលុប ដូច្នេះដែរឬ ។ អើ ។ បើព្រះអានន្ទមានអាយុ ជាសេក្ខបុគ្គល រមែងដឹងថា ព្រះមានព្រះភាគ ព្រះអង្គលើសលុប រមែងដឹងថា ព្រះថេរៈឈ្មោះសារីបុត្ត និងព្រះថេរៈឈ្មោះមហាមោគ្គល្លាន លោកលើសលុប ដូច្នេះហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អសេក្ខញ្ញាណ របស់សេក្ខបុគ្គល មាន ។

អសេក្ខញ្ញាណកថា ចប់

# អដ្ឋកថា

## អសេក្ខញាណកថា

[ ៥៨៥ ] ឥឡូវនេះ នឹងពណ៌នាអំពីព្រះអសេក្ខៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា ព្រោះព្រះសេក្ខៈទាំងឡាយ មានព្រះអានន្ទត្ថេរជាដើម រមែងដឹងនូវអសេក្ខបុគ្គលទាំងឡាយ ដោយន័យជាដើមថា ព្រះមានព្រះភាគ ជាបុគ្គលមានព្រះគុណដ៏ធំក្រៃលែង ព្រោះហេតុនោះ ព្រះសេក្ខៈ រមែងមានញាណរបស់ព្រះអសេក្ខៈបាន ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **ជានាតិ បស្សតិ** នេះ សកវាទីពោលដោយអំណាចនៃការដឹងធម៌ដែលខ្លួនឯងសម្រេចហើយ ។

[ ៥៨៨ ] បទថា **គោត្រភុនោ** ជាដើម សកវាទីពោលដើម្បីសម្ដែងការមិនមាននៃញាណខាងលើរបស់ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងភូមិធម៌ខាងក្រោម ។

[ ៥៨៩ ] បទថា **ឆន្នុ អាយស្មា អានន្ទោ ។បេ។ ជានាតិ** អធិប្បាយថា បរវាទីរមែងកាន់យកថា ញាណនោះ ជាអសេក្ខញាណ ព្រោះការប្រព្រឹត្តទៅនៃញាណថា ព្រោះប្រព្រឹត្តទៅក្នុងព្រះមានព្រះភាគ ដែលជាព្រះអសេក្ខៈ តែមិនកាន់យកញាណនោះ ជាអសេក្ខៈ ព្រោះហេតុនោះ លទ្ធិសូម្បីបរវាទីតម្កល់ទុកហើយយ៉ាងនេះ ក៏មិនជាការតម្កល់ទុកនោះឯង ៕០៚

# អភិធម្មបិដក

## វិបរីតកថា

[ ៥៩០ ] វិបរីតញ្ញាណ ( ការយល់ផ្ទុយ ) របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិមានឬ ។ អើ ។ សេចក្ដីប្រកាន់ផ្ទុយថា ទៀង ក្នុងរបស់មិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្ដីប្រកាន់ផ្ទុយថា សុខ ក្នុងរបស់ជាទុក្ខ ។បេ។ ថាខ្លួន ក្នុងរបស់មិនមែនជាខ្លួន ។បេ។ ថាស្អាត ក្នុងរបស់មិនស្អាត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[ ៥៩១ ] វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានដែរឬ ។ អើ ។ ( ញាណនោះ ) ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែង ( ញាណនោះ ) ជាកុសលឬ ។ អើ ។ បើ ( ញាណនោះ ) ជាកុសល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

[ ៥៩២ ] សេចក្ដីប្រកាន់ផ្ទុយ ថាទៀង ក្នុងរបស់មិនទៀង ( មាន ) ចុះសេចក្ដីប្រកាន់ផ្ទុយនោះ ជាអកុសលឬ ។ អើ ។ វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ ( មាន ) ចុះញាណនោះ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្ដីប្រកាន់ផ្ទុយ ថាសុខ ក្នុងរបស់ជាទុក្ខ ។បេ។ ថាខ្លួន ក្នុងរបស់មិនមែនខ្លួន ។បេ។ ថាស្អាត ក្នុងរបស់មិនស្អាត ចុះសេចក្ដីប្រកាន់ផ្ទុយនោះ ជាអកុសលឬ ។ អើ ។ វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ ( មាន ) ចុះ

ញាណនោះ ជាអកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៩៣ ] វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ ( មាន ) ចុះញាណនោះ ជាកុសលឬ ។ អើ ។ សេចក្តីប្រកាន់ផ្ទុយ ថាទៀង ក្នុងរបស់មិនទៀង ចុះសេចក្តីប្រកាន់ផ្ទុយនោះ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមបត្តិ ( មាន ) ចុះញាណនោះ ជាកុសលឬ ។ អើ ។ សេចក្តីប្រកាន់ផ្ទុយ ថាសុខ ក្នុងរបស់ជាទុក្ខ ។បេ។ ថាខ្លួន ក្នុងរបស់មិនមែនខ្លួន ។បេ។ ថាស្អាត ក្នុងរបស់មិនស្អាត ចុះសេចក្តីប្រកាន់ផ្ទុយនោះ ជាកុសលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៩៤ ] វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ ( មាន ) ឬ ។ អើ ។ ព្រះអរហន្ត ចូលកាន់បឋវីកសិណ-សមាបត្តិឬ ។ អើ ។ បើព្រះអរហន្ត ចូលកាន់បឋវីកសិណសមាបត្តិ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

[ ៥៩៥ ] វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ ( មាន ) ព្រះអរហន្ត ចូលកាន់បឋវីកសិណសមាបត្តិឬ ។ អើ ។ សេចក្តីប្រកាន់ផ្ទុយ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៩៦ ] សេចក្តីប្រកាន់ផ្ទុយ របស់ព្រះអរហន្ត មានឬ ។ អើ ។

សេចក្តីប្រកាន់ផ្ទុយដោយសញ្ញា សេចក្តីប្រកាន់ផ្ទុយដោយចិត្ត សេចក្តីប្រកាន់ផ្ទុយដោយទិដ្ឋិរបស់ព្រះអរហន្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៥៩៧ ] សេចក្តីប្រកាន់ផ្ទុយដោយសញ្ញា សេចក្តីប្រកាន់ផ្ទុយដោយចិត្ត សេចក្តីប្រកាន់ផ្ទុយដោយទិដ្ឋិ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើសេចក្តីប្រកាន់ផ្ទុយដោយសញ្ញា សេចក្តីប្រកាន់ផ្ទុយដោយចិត្ត សេចក្តីប្រកាន់ផ្ទុយដោយទិដ្ឋិ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីប្រកាន់ផ្ទុយ របស់ព្រះអរហន្ត មានទេ ។

[ ៥៩៨ ] បុគ្គលមិនគួរនិយាយថា វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ ( មាន ) ទេឬ ។ អើ ។ បុគ្គលកាលចូលកាន់បឋវីកសិណសមាបត្តិ ។ ធម្មជាតទាំងអស់ ទៅជាផែនដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ។

[ ៥៩៩ ] វិបរីតញ្ញាណ របស់បុគ្គលចូលកាន់បឋវីកសិណសមាបត្តិ មានឬ ។ អើ ។ ក្រែងផែនដី មាន បុគ្គលទីមួយ ចូលកាន់ផែនដី ដោយផែនដី មានដែរឬ ។ អើ ។ បើផែនដី មាន បុគ្គលទីមួយ ចូលកាន់ផែនដី

ដោយផែនដី មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

[ ៦០០ ] ផែនដី មាន វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់ផែនដី ដោយផែនដី មានដែរឬ ។ អើ ។ និព្វាន មាន វិបរីតញ្ញាណ របស់បុគ្គល ដែលចូលកាន់និព្វាន ដោយនិព្វាន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា វិបរីតញ្ញាណ របស់បុគ្គល ដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

**វិបរីតកថា ចប់**

# អដ្ឋកថា

## វិបរីតកថា

[ ៥៩០ ] ឥឡូវនេះ នឹងពណ៌នាអំពីញាណវិបរិតដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា បុគ្គលណា មានសញ្ញាក្នុងបឋវី រមែងចូលសមាបត្តិមានបឋវីជាអារម្មណ៍ ញាណនោះរបស់បុគ្គលនោះ ជាញាណវិបរិត ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី គប្បីជ្រាបពាក្យអធិប្បាយរបស់បញ្ហានោះដូចតទៅនេះថា និមិត្តដែលអាស្រ័យបឋវីកើតឡើង មិនមែនបឋវីឡើយ តែបុគ្គលមានការសម្គាល់ក្នុងបឋវីកសិណ រមែងចូលឈាន មានបឋវីជាអារម្មណ៍ ព្រោះហេតុនោះ ញាណនោះ ឈ្មោះថា ជាញាណវិបរិត គឺខុសចាកសេចក្តីពិតដូច្នេះ ។ លំដាប់នោះ សកវាទីដើម្បីចោទសួរថា លក្ខណបឋវីក្តី សសម្ភារបឋវីក្តី និមិត្តបឋវីក្តី បឋវីទេវតាក្តី បឋវីទាំងអស់នោះឯង ក្នុងបឋវីទាំងនោះញាណថា បឋវី មិនមែនជាញាណវិបរិត ។ ចំណែកការយល់ខុសប្រក្រតីក្នុងធម៌ដែលមិនទៀង ថាទៀងជាដើម ឈ្មោះថា ញាណវិបរិត ។ ញាណដែលមានបឋវីកសិណជាអារម្មណ៍នេះ ជាញាណណាមួយ ក្នុងញាណដែលវិបរិត ក្នុងធម៌ដែលមិនទៀង ថាទៀងជាដើមទាំងឡាយ មានប្រមាណប៉ុណ្ណេះ តាមលទ្ធិរបស់អ្នកឬ ទើបពោលពាក្យថា **អនិច្ចេ និច្ចំ** ជាដើម ។ បរវាទីសំដៅយកការមិនមានលក្ខណៈដែលវិបល្លាស ទើបឆ្លើយបដិសេធ ។ សំដៅយកបឋវីនិមិត្ត ទើបឆ្លើយទទួល ។

[ ៥៩១ ] បទថា **កុសលំ** លោកពោលសំដៅយកញាណរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ។

[ ៥៩៥ ] ក្នុងបញ្ហាថា **អត្ថិ អរហតោ** បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានលក្ខណៈដែលវិបល្លាសឡើយ ។ រមែងឆ្លើយទទួល សំដៅយកបឋវីនិមិត្ត ។

[ ៥៩៨ ] បទថា **សព្វា បឋវី ហោតិ** សេចក្ដីថា បរវាទីសួរដោយគិតថា បឋវីកសិណទាំងពួងនោះជាលក្ខណៈបឋវីប៉ុណ្ណោះ ។ សកវាទីឆ្លើយបដិសេធ ព្រោះការមិនមានបែបនោះ ។

[ ៥៩៩ ] ពាក្យសួរថា **ននុ បឋវី អត្ថិ ។បេ។ សមាបជ្ជតិ** ជាពាក្យរបស់សកវាទី ។ គប្បីជ្រាបអត្ថនៃបញ្ហានោះថា និមិត្តបឋវី មាន បុគ្គលណាមួយ រមែងចូលសមាបត្តិ មានដីជានិមិត្តនោះ អំពីដីនោះឯង ក៏មានមិនបានចូលអំពីអាបោ ឬអំពីតេជោឡើយ មិនមែនឬ ដូច្នេះ ។

[ ៦០០ ] បទថា **បឋវី អត្ថិ** ជាដើម សកវាទីពោលដើម្បីសម្ដែងថាញាណរបស់បុគ្គលចូលបឋវីកសិណ ដោយប្រការដែលមាន ជាញាណ-វិបរិតសោត និព្វាន មាន កាលបុគ្គលចូលសមាបត្តិ មាននិព្វានជាអា-រម្មណ៍ក្ដី មគ្គញាណដែលជកនូវការវិបរិតទាំងពួងក្ដី ក៏រមែងវិបរិតតាមលទ្ធិរបស់អ្នក ដូច្នេះ ។៚

## អដ្ឋកថាវិបរីតកថា ចប់

# អភិធម្មបិដក

## និយាមកថា

[ ៦០១ ] ញាណ ក្នុងដំណើរទៅកាន់និយាម គឺមគ្គរបស់បុគ្គលជាអនិយត ( បុថុជ្ជន ) មានដែរឬ ។ អើ ។ ញាណ ក្នុងដំណើរទៅកាន់អនិយាម របស់បុគ្គលជានិយត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០២ ] ញាណ ក្នុងដំណើរទៅកាន់អនិយាម របស់បុគ្គលជានិយត មិនមានទេឬ ។ អើ ។ ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៣ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានដែរឬ ។ អើ ។ ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជានិយត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៤ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជានិយត មិនមានទេឬ ។ អើ ។ ញាណ ក្នុងការទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៥ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានដែរឬ ។ អើ ។ ញាណ ក្នុងដំណើរទៅកាន់អនិយាម របស់បុគ្គលជាអនិយត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៦ ] ញាណ ក្នុងដំណើរទៅកាន់អនិយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អើ ។ ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៧ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានដែរឬ ។ អើ ។ និយាម ( មគ្គ ) ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៨ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានឬ ។ អើ ។ សតិប្បដ្ឋាន ។បេ។ សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦០៩ ] និយាម ( មគ្គ ) ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អើ ។ បើនិយាម ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានទេ ។

[ ៦១០ ] សតិប្បដ្ឋាន ។បេ។ ពោជ្ឈង្គ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមានទេឬ ។ អើ ។ បើពោជ្ឈង្គ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មិនមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងដំណើរទៅកាន់និយាមរបស់បុគ្គលជាអនិយត មានទេ ។

[ ៦១១ ] ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មានឬ ។ អើ ។ ញាណ ក្នុងសោតាបត្តិមគ្គ របស់បុគ្គលជាគោត្រភូ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦១២ ] ញាណ ក្នុងសោតាបត្តិផល របស់បុគ្គលអ្នកប្រតិបត្តិដើម្បី

ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។បេ។ ញាណ ក្នុងព្រះអរហត្ត របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦១៣ ] បុគ្គលមិនគួរនិយាយថា ញាណ ក្នុងដំណើរទៅកាន់និយាមរបស់បុគ្គលជាអនិយត មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ នឹងឈានចុះកាន់សម្មត្តនិយាម បុគ្គលនេះ គួរដើម្បីត្រាស់ដឹងនូវធម៌បានឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ នឹងឈានចុះកាន់សម្មត្តនិយាម បុគ្គលនេះ គួរដើម្បីត្រាស់ដឹងនូវធម៌បាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ញាណ ក្នុងដំណើរទៅកាន់និយាម របស់បុគ្គលជាអនិយត មាន ។

**និយាមកថា ចប់**

# អដ្ឋកថា

## និយាមកថា

[ ៦០២ ] ឥឡូវនេះ នឹងពណ៌នាអំពីនិយាមដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា ព្រោះព្រះមានព្រះភាគ ទ្រង់រមែងជ្រាបថា បុគ្គលណា នឹងឈមចុះកាន់សម្មត្តនិយាម ដើម្បីភាពត្រឹមត្រូវ បុគ្គលនោះ គួរត្រាស់ដឹងធម៌នោះ ព្រោះហេតុនោះ ញាណ ដើម្បីការសម្រេចនិយាមរបស់អនិយតបុគ្គល ដែលជាបុថុជ្ជនទោះឯង រមែងមានដូច្នេះ ។ ពាក្យសួរថា **អនិយតស្ស** ជាដើម សកវាទីសំដៅដល់ជនទាំងនោះ ។ ក្នុងបញ្ហានោះ បទថា **និយាមគមនាយ** ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅមគ្គថា និយាម អធិប្បាយថា ដើម្បីការសម្រេចមគ្គ ដើម្បីការឈមចុះកាន់មគ្គ ។ ព្រះមានព្រះភាគ ទ្រង់រមែងជ្រាបថា បុគ្គលនេះ គួរដើម្បីសម្រេចនិយាម ព្រោះទ្រង់ឃើញញាណឯណារបស់បុគ្គលនោះ បរវាទីសំដៅដល់ញាណនោះ ទើបឆ្លើយទទួល ។ លំដាប់នោះ សកវាទីដើម្បីសម្តែងថា វាទៈរបស់បរវាទីនោះ មិនត្រឹមត្រូវ ទើបសួរដល់អត្ថដែលផ្ទុយគ្នាដោយពាក្យថា **និយតស្ស** ជាដើម ។ បណ្តាបញ្ហាទាំងនោះ ក្នុងបញ្ហាដំបូង បរវាទីឆ្លើយបដិសេធ ព្រោះគិតថា ឈ្មោះថា ញាណ ដើម្បីការសម្រេចនិយាមដោយមគ្គរបស់បុគ្គល ដែលពិតប្រាកដ មិនមាន ។ ក្នុងបញ្ហាទី ២ រមែងឆ្លើយទទួល ព្រោះការមិនមាន ។ ក្នុងបញ្ហាទី ៣ ព្រោះត្រូវសួរដោយពាក្យថា

បុគ្គលមិនពិតប្រាកដ មិនមានញាណដើម្បីទៅកាន់ផ្លូវ ដែលពិតប្រាកដឬ រមែងឆ្លើយបដិសេធ ព្រោះខុសអំពីលទ្ធិ ។

[ ៦០៣ ] សកវាទីធ្វើបញ្ហាដំបូងនោះឯង ឲ្យជាបញ្ហាទី ៤ ទៀត ហើយធ្វើបញ្ហា ៣ របស់និយតបុគ្គល ដោយអំណាចនៃការសម្រេចនិយាម ជាដើម ។ ក្នុងបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីឆ្លើយបដិសេធ ព្រោះញាណ ដើម្បីសម្រេចនិយាមនោះទៀត នៃនិយតបុគ្គលដោយមគ្គដើម ( សោតា-បត្តិមគ្គ ) រមែងមិនមាន ។ ក្នុងបញ្ហាទី ២ ឆ្លើយទទួល ព្រោះការមិនមាន នោះឯង ។ ក្នុងបញ្ហាទី ៣ ឆ្លើយបដិសេធ ព្រោះខុសអំពីលទ្ធិ ។

[ ៦០៥ ] សកវាទីធ្វើបញ្ហាដំបូងនោះឯង ឲ្យជាបញ្ហាទី ៨ ទៀត ហើយធ្វើបញ្ហា ៣ របស់អនិយតបុគ្គល ដោយអំណាចនៃការទៅកាន់ លោកិយធម៌ ដែលមិនមែនជាផ្លូវពិតប្រាកដជាដើម ។ បណ្ឌិតគប្បីជ្រាប អត្ថនៃបញ្ហាទាំងនោះ ដោយន័យដែលពោលហើយនោះឯង ។

[ ៦០៧ ] សកវាទីធ្វើបញ្ហាដំបូងនោះឯង ឲ្យជាបញ្ហាទី ១២ ទៀត ហើយធ្វើបញ្ហា ៣ មានពាក្យថា **អត្ថិ ឆិយាមោ** ជាដើម ដែលមានបញ្ហា ដំបូងនោះជាមូល ។ ក្នុងបញ្ហាទាំងឡាយនោះ ព្រោះមគ្គញាណប៉ុណ្ណោះ ឈ្មោះថា ញាណដើម្បីទៅកាន់ផ្លូវទៀង ព្រោះហេតុនោះ សកវាទីសំដៅដល់ ញាណនោះ ទើបពោលថា **អត្ថិ ឆិយាមោ** ដូច្នេះ ។ កាលពាក្យថា **អត្ថិ ឆិយាមោ** ដែលសកវាទីពោលហើយ បរវាទីក៏ឆ្លើយបដិសេធ ។ កាល សកវាទីពោលថា **ញាណំ** បរវាទីក៏ឆ្លើយទទួល ។ ក្នុងបទទាំងឡាយ មាន

បទថា **សតិប្បដ្ឋានា** ជាដើម ក៏ន័យនេះឯង ។ ពាក្យបច្ចុទិកៈ មានអត្ថ ងាយយល់ហើយ ។

[ ៦១១ ] បទថា **គោត្រភុនោ** ជាដើម សកវាទីពោលដើម្បីសម្តែងថា ញាណណា ដែលបុគ្គលណា មិនសម្រេចហើយ ញាណនោះ របស់បុគ្គលនោះ រមែងមិនមាន ។

[ ៦១៣ ] បទថា **ភគវា ជានាតិ** សេចក្តីថា ព្រះមានព្រះភាគ រមែងជ្រាប ដោយញាណពលរបស់ព្រះអង្គឯង មិនមែនទ្រង់ជ្រាបចាកសភាវៈនៃការសម្រេចនិយាមរបស់បុគ្គលនោះ ដោយហេតុនេះ បរវាទី សូម្បីតាំងនូវលទ្ធិហើយ ក៏តាំងនៅមិនបានឡើយ ដូច្នេះ ។៚

## អដ្ឋកថានិយាមកថា ចប់

# អភិធម្មបិដក

## បដិសម្ភិទាកថា

[ ៦១៤ ] ញាណទាំងអស់ ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ សម្មតិញ្ញាណ ( ការដឹងនូវសម្មតិ ) ឈ្មោះថា បដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មតិញ្ញាណ ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ ពួកជនណាមួយ ដឹងនូវសម្មតិ ពួកជនទាំងអស់នោះ ឈ្មោះថា ដល់នូវបដិ-សម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណទាំងអស់ ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ឈ្មោះថា បដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ ពួកជនណាមួយ ដឹងនូវចិត្តនៃបុគ្គលដទៃ ពួកជនទាំងអស់នោះ ឈ្មោះថា ដល់នូវបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦១៥ ] ញាណទាំងអស់ ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ បញ្ញាទាំងអស់ ឈ្មោះថា បដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញាទាំងអស់ ឈ្មោះថា បដិសម្ភិទាឬ ។ អើ ។ បញ្ញារបស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ចុះបញ្ញានោះ ឈ្មោះថា បដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញារបស់បុគ្គលដែលចូលកាន់អាបោ-កសិណ ។បេ។ តេជោកសិណ ។បេ។ វាយោកសិណ ។បេ។ នីលកសិណ ។បេ។ បីតកសិណ ។បេ។ លោហិតកសិណ ។បេ។ ឱទាតកសិណ ។បេ។

អាកាសានញ្ចាយតនៈ ។បេ។ វិញ្ញាណញ្ចាយតនៈ ។បេ។ អាកិញ្ចញ្ញាយតនៈ ។បេ។ នេវសញ្ញានាសញ្ញាយតនៈ ។បេ។ កាលឲ្យទាន ។បេ។ កាលឲ្យចីវរ ។បេ។ កាលឲ្យបិណ្ឌបាត ។បេ។ កាលឲ្យសេនាសនៈ ។បេ។ កាលឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ មាន ចុះបញ្ញានោះ ឈ្មោះថា បដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦១៦ ] បុគ្គលមិនគួរនិយាយថា ញាណទាំងអស់ ឈ្មោះថា បដិសម្ភិទាទេឬ ។ អើ ។ បញ្ញាជាលោកុត្តរ មាន ចុះបញ្ញានោះ មិនឈ្មោះថា បដិសម្ភិទាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ញាណទាំងអស់ ឈ្មោះថា បដិសម្ភិទាដែរ ។

## បដិសម្ភិទាកថា ចប់

# អដ្ឋកថា

## បដិសម្ភិទាកថា

[ ៦១៤ ] ឥឡូវនេះ នឹងពណ៌នាអំពីបដិសម្ភិទាដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ញាណ គឺការដឹងទាំងពួង ជាបដិសម្ភិទា ព្រោះកាន់យកព្រះបាលីថា ញាណរបស់ព្រះអរិយៈទាំងឡាយណាមួយ ជាលោកុត្តរទាំងអស់ ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ក្នុងបញ្ហាពោលដោយសម្មតិញ្ញាណទាំងឡាយ បរវាទីសំដៅយកញាណក្នុងសមាបត្តិដែលជាបរិកសិណ ដែលជាសម្មតិ ទើបឆ្លើយបដិសេធ ។ សំដៅយកនិរុត្តិញ្ញាណ ទើបឆ្លើយទទួល ។ ក្នុងបញ្ហាទាំងឡាយថា **យេ កេចិ សម្មតី** បរវាទី សំដៅយកបុថុជ្ជនទាំងឡាយ ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាពោលអំពីចេតោបរិយាយ បរវាទីសំដៅយកញាណរបស់បុថុជ្ជន ទើបឆ្លើយបដិសេធ សំដៅយកញាណរបស់ព្រះអរិយៈ ទើបឆ្លើយទទួល ។

[ ៦១៥ ] ក្នុងបញ្ហាទាំងឡាយថា **សព្វា បញ្ញា** បរវាទីឆ្លើយ សំដៅយកបញ្ញាក្នុងកសិណសមាបត្តិ ទើបឆ្លើយបដិសេធ សំដៅយកលោកុត្តរ

ទើបឆ្លើយទទួល ។ បទថា **បឋវីកសិណសមាបត្តិ** ជាដើម សកវាទីពោល ដើម្បីសួរថា បញ្ញាក្នុងទីទាំងឡាយ មានប្រមាណប៉ុណ្ណេះ បញ្ញាទាំងអស់នោះ ជាបដិសម្ភិទាឬ ។

[ ៦១៦ ] បទថា **តេន ហិ សព្វំ ញាណំ** អធិប្បាយថា ព្រោះលោកុត្តរបញ្ញាទាំងអស់ ជាបដិសម្ភិទា ព្រោះហេតុនោះ ទើបបរវាទីឲ្យពាក្យថា **សព្វំ** តាំងទុករួមជាមួយសាមញ្ញផល ដូច្នេះ ។

## អដ្ឋកថាបដិសម្ភិទាកថា ចប់

# អភិធម្មបិដក

## សម្មតិញ្ញាណកថា

[ ៦១៧ ] បុគ្គល មិនគួរនិយាយថា សម្មតិញ្ញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណរបស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ទាំងបឋវីកសិណក្នុងសម្មតិសច្ច ក៏មានឬ ។ អើ ។ បើញាណរបស់បុគ្គល ដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ទាំងបឋវីកសិណក្នុងសម្មតិសច្ចក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សម្មតិញ្ញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

[ ៦១៨ ] បុគ្គល មិនគួរនិយាយថា សម្មតិញ្ញាណ មានសច្ចៈជាអារម្មណ៍ មិនមែនធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណរបស់បុគ្គលដែលចូលកាន់អាបោកសិណ ។បេ។ តេជោកសិណ ។បេ។ កាលឲ្យគិលានប្បច្ច័យភេសជ្ជបរិក្ខារ មាន ឯគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងសម្មតិ-សច្ច ក៏មានឬ ។ អើ ។ បើញាណរបស់បុគ្គល កាលឲ្យគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ មាន ឯគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងសម្មតិសច្ចក៏មាន

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សម្មតិញ្ញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

[ ៦១៩ ] សម្មតិញ្ញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ បុគ្គលកំណត់ដឹងនូវទុក្ខ លះនូវសមុទយៈ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើននូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

សម្មតិញ្ញាណកថា ចប់

# អដ្ឋកថា

## សម្មតិញ្ញាណកថា

[ ៦១៧ ] ឥឡូវនេះ នឹងពណ៌នាអំពីសម្មតិញ្ញាណដូចតទៅ

ក្នុងរឿងនោះ សច្ចៈមាន ២ គឺសម្មតិសច្ច និងបរមត្ថសច្ច ។ បុគ្គលទាំងឡាយ ដូចនិកាយអន្ធកៈទាំងឡាយ មិនធ្វើការចែកសច្ចៈយ៉ាងនេះ រមែងពោលនូវសម្មតិញ្ញាណថា មានសច្ចៈជាអារម្មណ៍ប៉ុណ្ណោះ ដោយពាក្យទូទៅថា សច្ចៈ ទើបសកវាទីផ្ដើមពាក្យនេះ ដើម្បីជម្រះនូវវាទៈរបស់ជនទាំងនោះថា ពួកបុគ្គលទាំងនោះ មានវាទៈមិនត្រឹមត្រូវ ។ ក្នុងពាក្យទាំងនោះ ពាក្យសួរថា **ឆ វត្តព្វំ** ជាពាក្យរបស់បរវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់សកវាទី សំដៅយកបរមត្ថសច្ច ។ បទថា **សម្មតិសច្ចម្ហិ** បានដល់សច្ចៈដែលចូលទៅអាស្រ័យសម្មតិ ។ ម្យ៉ាងទៀត បទថា **សម្មតិសច្ចម្ហិ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃបឋមាវិភត្តិ អធិប្បាយថា សម្មតិសច្ច ។

[ ៦១៩ ] ពាក្យសួរថា **សម្មតិញ្ញាណំ សច្ចារម្មណញ្ញេវ** ជាពាក្យរបស់សកវាទី ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះសកវាទីដើម្បីសួរថា បើញាណក្នុងសម្មតិនោះ មានសច្ចៈជាអារម្មណ៍ប៉ុណ្ណោះដោយមិនប្លែកគ្នា ព្រោះហេតុនោះ បុគ្គលក៏គប្បីធ្វើកិច្ចទាំងឡាយមានការកំណត់ដឹងទុក្ខជាដើម ដោយញាណនោះបាន ទើបពោលពាក្យនឹងបរវាទីនោះថា **តេន ញាណេន** ជាដើម ។ល។

**អដ្ឋកថាសម្មតិញ្ញាណកថា ចប់**

# អភិធម្មបិដក

## ចិត្តារម្មណកថា

[ ៦២០ ] ញាណ ក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលប្រកបដោយរាគៈ ថាចិត្តប្រកបដោយរាគៈ ដូច្នេះឬ ។ អើ ។ បើបុគ្គលណាមួយ ដឹងច្បាស់នូវចិត្ត ដែលប្រកបដោយរាគៈ ថាចិត្តប្រកបដោយរាគៈ ដូច្នេះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។ ក្រែងបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលប្រាសចាករាគៈ ថាចិត្តប្រាសចាករាគៈ ។បេ។ នូវចិត្តដែលប្រកបដោយទោសៈ ។បេ។ នូវចិត្តដែលប្រាសចាកទោសៈ នូវចិត្តដែលប្រកបដោយមោហៈ នូវចិត្តដែលប្រាសចាកមោហៈ នូវចិត្តដែលរួញរា នូវចិត្តដែលរាយមាយ នូវចិត្តដែលដល់នូវភាវៈជាធំ ( គឺរូបាវចរ និងអរូបាវចរ ) នូវចិត្តដែលមិនដល់នូវភាវៈជាធំ ( គឺកាមាវចរនោះ ) នូវចិត្តដែលមានចិត្តដទៃប្រសើរជាង ( គឺកាមាវចរ ) នូវចិត្តដែលមិនមានចិត្តដទៃប្រសើរជាង ( គឺរូបាវចរ និងអរូបាវចរ ) នូវចិត្តដែលតាំងមាំ នូវចិត្តដែលមិនតាំងមាំ ( គឺប្រាសចាកសមាធិទាំង ២ ) នូវចិត្តដែលរួចស្រឡះ ។បេ។ នូវចិត្តដែលមិនទាន់រួចស្រឡះ ថាចិត្តមិនទាន់រួចស្រឡះ ដូច្នេះ មានដែរឬ ។ អើ ។ បើបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលមិនទាន់រួចស្រឡះ ថាចិត្តមិនទាន់រួច

ស្រឡះ ដូច្នេះ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនធម៌ដទៃជាអារម្មណ៍ទេ ។

[ ៦២១ ] ញាណក្នុងអារម្មណ៍ គឺផស្សៈ បុគ្គលគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ឬ ។ អើ ។ បើញាណក្នុងអារម្មណ៍ គឺផស្សៈ បុគ្គលគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។ ញាណក្នុងអារម្មណ៍ គឺវេទនា ។បេ។ ញាណក្នុងអារម្មណ៍ គឺសញ្ញា ញាណក្នុងអារម្មណ៍ គឺចេតនា ញាណក្នុងអារម្មណ៍ គឺចិត្ត ញាណក្នុងអារម្មណ៍ គឺសទ្ធៈ ញាណក្នុងអារម្មណ៍ គឺវិរិយៈ ញាណក្នុងអារម្មណ៍ គឺសតិ ញាណក្នុងអារម្មណ៍ គឺសមាធិ ញាណក្នុងអារម្មណ៍ គឺបញ្ញា ។បេ។ ញាណក្នុងអារម្មណ៍ គឺរាគៈ ។បេ។ ញាណក្នុងអារម្មណ៍ គឺទោសៈ ។បេ។ ញាណក្នុងអារម្មណ៍ គឺអនោត្តប្បៈ បុគ្គលគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ឬ ។ អើ ។ បើញាណក្នុងអារម្មណ៍ គឺអនោត្តប្បៈ បុគ្គលគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃ ជាអារម្មណ៍ទេ ។

[ ៦២២ ] ញាណក្នុងអារម្មណ៍ គឺផស្សៈ បុគ្គលមិនគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ទេឬ ។ អើ ។ ញាណក្នុងការកំណត់ដឹងនូវផស្សៈ ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងអារម្មណ៍ គឺវេទនា ។បេ។ ញាណក្នុងអារម្មណ៍ គឺសញ្ញា ។បេ។ ញាណក្នុងអារម្មណ៍ គឺអនោត្តប្បៈ បុគ្គលមិនគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( ក្នុងបុគ្គលដទៃ ) ទេឬ ។ អើ ។ ញាណក្នុងការកំណត់ដឹងនូវអនោត្តប្បៈ ( មាន ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២៣ ] បុគ្គលមិនគួរនិយាយថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃ ជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃមាន ) ឬ ។ អើ ។ បើញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃមាន ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃ ជាអារម្មណ៍ទេ ។

**ចិត្តារម្មណកថា ចប់**

# អដ្ឋកថា

## ចិត្តារម្មណកថា

[ ៦២០ ] ឥឡូវនេះ នឹងពណ៌នាអំពីញាណ មានចិត្តជាអារម្មណ៍ដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ ក្នុងឥឡូវនេះថា ញាណនោះ មានចិត្តជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ព្រោះកាន់យកហេតុត្រឹមតែពាក្យថា ញាណក្នុងការកំណត់ដឹងចិត្តអ្នកដទៃ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរថា បុគ្គលណា រមែងដឹងចិត្តរបស់អ្នកដទៃ ដោយអំណាចនៃចិត្ត មានរាគៈជាដើម សូម្បីរាគៈជាដើម ក៏រមែងជាអារម្មណ៍របស់បុគ្គលនោះ ព្រោះហេតុនោះ អ្នកមិនគប្បីពោលថា ញាណនោះ មានចិត្តជាអារម្មណ៍ត្រឹមតែម្យ៉ាង មិនមានធម៌ដទៃជាអារម្មណ៍ ដូច្នេះ ទើបផ្ដើមពាក្យថា **ននុ អត្ថិ កោចិ** ជាដើម ។

[ ៦២១ ] បទថា **ផស្សារម្មណោ** បានដល់ ក្នុងអារម្មណ៍ ពោលគឺផស្សៈ ។ ក្នុងបទទាំងឡាយ មានបទថា **វេទនារម្មណោ** ជាដើម ក៏ន័យនេះឯង ។

[ ៦២២ ] ត្រូវសកវាទីសួរទៀតថា **ផស្សារម្មណោ ញាណំ ន វត្តព្វំ** បរវាទីឆ្លើយទទួលដោយគិតថា កាលពិចារណានូវផុស្សនលក្ខណៈនៃផស្សៈ រមែងជាអារម្មណ៍របស់ផស្សៈ ដូច្នេះ ។ ត្រូវសកវាទីសួរថា **ករឹ បនេតំ ផស្សបរិយាយេ ញាណំ** បរវាទីឆ្លើយបដិសេធ ព្រោះការមិនមានបទព្រះសូត្របែបនោះ ។ ក្នុងវេទនាជាដើម ក៏ន័យនេះឯង ។

ឥឡូវនេះ លទ្ធិរបស់បរវាទីនោះ អាស្រ័យវត្ថុណា ដើម្បីសម្តែងវត្ថុនោះ ហើយឲ្យលទ្ធិតាំងទុក ទើបពោលពាក្យថា **ននុ ចេតោបរិយាយេ ញាណំ** ជាដើម តែលទ្ធិនេះ សូម្បីជាលទ្ធិដែលបរវាទីឲ្យតាំងទុក ដោយប្រកាន់យកត្រឹមតែពាក្យ រមែងមិនជាការតាំងទុកបានឡើយ ដូច្នេះ ៕

## អដ្ឋកថាចិត្តារម្មណាកថា ចប់

# អភិធម្មបិដក

## អនាគតញ្ញាណកថា

[ ៦២៤ ] ញាណក្នុងអនាគត មានឬ ។ អើ ។ បុគ្គលដឹងអនាគត ដោយមូល ដឹងដោយហេតុ ដឹងដោយនិទាន ដឹងដោយសម្ភវៈ ( ហេតុជាដែនកើតព្រម ) ដឹងដោយបភវៈ ( ហេតុជាដែនកើតទូទៅ ) ដឹងដោយសមុដ្ឋាន ដឹងដោយអាហារ ដឹងដោយអារម្មណ៍ ដឹងដោយបច្ច័យ ដឹង ( អនាគត ) ដោយសមុទយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២៥ ] ញាណក្នុងអនាគត មានឬ ។ អើ ។ បុគ្គល ដឹងនូវភាពនៃហេតុប្បច្ច័យ ដឹងនូវភាពនៃអារម្មណប្បច្ច័យ ដឹងនូវភាពនៃអធិបតិប្បច្ច័យ ដឹងនូវភាពនៃអនន្តរប្បច្ច័យ ដឹងនូវភាពនៃសមនន្តរប្បច្ច័យ ជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២៦ ] ញាណក្នុងអនាគត មានឬ ។ អើ ។ ញាណក្នុងសោតាបត្តិ-មគ្គ របស់បុគ្គលជាគោត្រភូ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងសោតាបត្តិផល របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-

ផល ។បេ។ ញាណក្នុងអរហត្ត របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២៧ ] បុគ្គល មិនគួរនិយាយថា ញាណក្នុងអនាគត មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ អន្តរាយទាំងឡាយ ៣ យ៉ាង គឺអន្តរាយអំពីភ្លើង ១ អន្តរាយអំពីទឹក ១ អន្តរាយអំពីការបែកបាក់គ្នានៃជន ២ នាក់ ១ នៃក្រុងបាដលិបុត្ត នឹងមាន ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ញាណក្នុងអនាគត មាន ។

អនាគតញ្ញាណកថា ចប់

# អដ្ឋកថា

## អនាគតញ្ញាណកថា

[ ៦២៤ ] ឥឡូវនេះ នឹងពណ៌នាញាណក្នុងអនាគតដូចតទៅ

ក្នុងបញ្ហានោះ ខណៈដែលជាអន្តរៈក្តី ជាអនន្តរៈក្តី ឈ្មោះថា អនាគត ។ ក្នុងខណៈទាំង ២ នោះ ញាណឈមចុះកាន់អនាគត ដែលជាអនន្តរៈតែម្យ៉ាង ប៉ុណ្ណោះមាន ម្យ៉ាងទៀត ញាណអនាគត ដែលជាអនន្តរៈ មានដោយប្រការណា សូម្បីញាណដែលឈមចុះក្នុងជវន ១ នៃវិថិ ១ ក៏មានដោយប្រការនោះ ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា ដូចនិកាយអន្ធកៈទាំងឡាយ រមែងកាន់យកញាណក្នុងអនាគត ក្នុងវត្ថុទាំងពួង ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គ្រានោះ សកវាទីដើម្បីចោទសួរថា ញាណក្នុងអនាគត តាមលទ្ធិរបស់អ្នកឯណា បុគ្គលរមែងដឹងអនាគត ដែលជាអនន្តរៈបាន ដោយអំណាចនៃមូលជាដើម ដោយញាណនោះឬ ទើបពោលនឹងបរវាទីនោះថា **អនាគតំ មូលតោ** ជាដើម ។ បណ្តាបទទាំងនោះ បទទាំងពួងថា **មូលតោ** ជាដើមនេះ ជាវេវចនៈនៃពាក្យថា **ការណា** នោះឯង ។ ពិតហើយ ការណៈឈ្មោះថា **មូល** ព្រោះអត្ថថា វត្ថុណា រមែងធ្វើផលឲ្យដល់ខ្លួន វត្ថុនោះរមែងជាមូល រមែងតាំងមាំ ព្រោះផលនោះ ។ បន្ទាប់អំពីនោះ ឈ្មោះថា **ហេតុ** ព្រោះអត្ថថា បញ្ជូនផលនោះទៅ គឺធ្វើផលនោះ ឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **និទាន** ព្រោះអត្ថថា ប្រគល់ឲ្យនូវផលនោះឯង ហាក់ដូចប្រគល់

ឲ្យ ដោយពាក្យថា សូមលោកទាំងឡាយកាន់យកវត្ថុនេះ ដូច្នេះ ។ ឈ្មោះថា **សម្ភវ** ព្រោះអត្ថថា រមែងឲ្យផលកើតព្រមអំពីហេតុនោះ ។ ឈ្មោះថា **បភវ** ព្រោះអត្ថថា ជាដែនកើតមុន ។ ឈ្មោះថា **សមុដ្ឋាន** ព្រោះអត្ថថា ផលនោះ រមែងតាំងឡើងព្រម ព្រោះធម៌ដែលជាហេតុនោះម្យ៉ាងទៀត ព្រោះអត្ថថា រមែងញ៉ាំងផលនោះៗ ឲ្យតាំងឡើងព្រម ។ ឈ្មោះថា **អាហារ** ព្រោះអត្ថថា រមែងនាំមកនូវផលនោះៗ ឯង ។ ការណៈនោះ ឈ្មោះថា **អារម្មណ** ព្រោះអត្ថថា មិនលះបង់នូវផលនោះ ។ ឈ្មោះថា **បច្ចយ** ព្រោះអត្ថថា អាស្រ័យអារម្មណ៍នោះប្រព្រឹត្តទៅ ។ សភាវៈណា រមែងញ៉ាំងផលនោះឲ្យកើតឡើងអំពីហេតុ ព្រោះហេតុនោះ ទើបសភាវៈនោះ លោកហៅថា **សមុទយ** ។ ព្រោះបុគ្គលណាមួយ មិនអាចដឹងអន្តរចិត្តបានដោយអាការទាំងនេះ ព្រោះហេតុនោះ ទើបបរវាទីឆ្លើយបដិសេធថា **ន ហេវំ** ។

[ ៦២៥ ] បទថា **អនាគតំ ហេតុប្បច្ចយតំ** សេចក្តីថា ភាពជាហេតុប្បច្ច័យ ក្នុងចិត្តដែលជាអនាគតដែលជាអន្តរៈណាមាន បុគ្គលរមែងដឹងនូវហេតុប្បច្ច័យនោះ អធិប្បាយថា ធម៌ក្នុងចិត្ត ដែលជាអនាគត ដែលជាអនន្តរៈពួកណា ជាហេតុប្បច្ច័យ រមែងដឹងនូវធម៌ទាំងនោះ ។ ក្នុងពាក្យដ៏សេសទាំងឡាយ ក៏មានន័យនេះឯង ។

[ ៦២៦ ] បទថា **គោត្រភុនោ** ជាដើម សំដៅយកវាទីពោលដើម្បីសម្តែងអនាគត ដែលជាវេលាដែលញាណនឹងកើតឡើងដោយសង្ខេប ។

[ ៦២៧ ] ព្រះសូត្រថា **ចាដលិបុត្តស្ស** បរវាទីនាំមក ក៏ដើម្បីសម្តែងអនាគត ដែលញាណកើតឡើង តែព្រោះព្រះសូត្រនោះ មិនសម្រេចប្រយោជន៍ដល់ញាណក្នុងអនាគតទាំងពួង ព្រោះហេតុនោះ ទើបព្រះសូត្រនោះ មិនជាការនាំមក ដោយប្រការដូច្នេះ ។

## អដ្ឋកថាអនាគតញ្ញាណកថា ចប់

# អភិធម្មបិដក

## បច្ចុប្បន្នញាណកថា

[ ៦២៨ ] ញាណ ក្នុងបច្ចុប្បន្ន មានឬ ។ អើ ។ បុគ្គលដឹងនូវញាណនោះ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលដឹងនូវញាណនោះ ដោយញាណនោះឬ ។ អើ ។ បុគ្គលដឹងនូវញាណនោះ ដោយញាណនោះ ជាញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បុគ្គលដឹងនូវញាណនោះ ដោយញាណនោះ ជាញាណឬ ។ អើ ។ ញាណនោះ ជាអារម្មណ៍របស់ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណនោះ ជាអារម្មណ៍របស់ញាណនោះឬ ។ អើ ។ បុគ្គលពាល់ត្រូវនូវផស្សៈនោះ ដោយផស្សៈនោះ ទទួលនូវវេទនានោះ ដោយវេទនានោះ សម្គាល់នូវសញ្ញានោះ ដោយសញ្ញានោះ ត្រិះរិះនូវចេតនានោះ ដោយចេតនានោះ គិតនូវចិត្តនោះ ដោយចិត្តនោះ ត្រិះរិះនូវវិតក្កនោះ ដោយវិតក្កនោះ ពិចារណានូវវិចារនោះ ដោយវិចារនោះ រីករាយនូវបីតិនោះ ដោយបីតិនោះ រឭកនូវសតិនោះ ដោយសតិនោះ ដឹងច្បាស់នូវបញ្ញានោះ ដោយបញ្ញានោះ កាត់នូវព្រះខ័ននោះ ដោយព្រះខ័ននោះ ប្រាសនូវប៉ូវថៅនោះ ដោយប៉ូវថៅនោះ ចាំងនូវដឹងនោះ ដោយដឹងនោះ កាប់នូវកាំបិតនោះ ដោយកាំបិតនោះ ដេរនូវម្ជុលនោះ ដោយម្ជុលនោះ ស្ទាបអង្អែលនូវចុងម្រាមនោះ ដោយចុងម្រាមនោះ ស្ទាបអង្អែលនូវចុងច្រមុះនោះ ដោយចុងច្រមុះនោះ ស្ទាបអង្អែលនូវក្បាលនោះ ដោយក្បាលនោះ លាងនូវលាមកនោះ ដោយ

លាមកនោះ លាងនូវមូត្រនោះ ដោយមូត្រនោះ លាងនូវទឹកមាត់នោះ ដោយទឹកមាត់នោះ លាងនូវខ្ទុះនោះ ដោយខ្ទុះនោះ លាងនូវឈាមនោះ ដោយឈាមនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦២៩ ] បុគ្គលមិនគួរនិយាយថា ញាណក្នុងបច្ចុប្បន្ន មានទេឬ ។ អើ ។ កាលបុគ្គលឃើញនូវសង្ខារទាំងពួង ដោយសភាពជារបស់មិនទៀង ក្រែងឃើញនូវញាណនោះ ដោយសភាពជារបស់មិនទៀងដែរឬ ។ អើ ។ បើកាលបុគ្គលឃើញនូវសង្ខារទាំងពួង ដោយសភាពជារបស់មិនទៀង ឃើញនូវញាណនោះ ដោយសភាពជារបស់មិនទៀង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ញាណក្នុងបច្ចុប្បន្ន មាន ។

បច្ចុប្បន្នញាណកថា ចប់

# អដ្ឋកថា

## បច្ចុប្បន្នញ្ញាណកថា

[ ៦២៨ ] ឥឡូវនេះ នឹងពណ៌នាញាណក្នុងបច្ចុប្បន្នដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ញាណក្នុងបច្ចុប្បន្នទាំងពួង មានដោយមិនប្លែកគ្នា ព្រោះអាស្រ័យព្រះបាលីថា កាលឃើញសង្ខារទាំងពួង ដោយភាពជារបស់មិនទៀង ញាណនោះ រមែងឈ្មោះថា ជាញាណដែលបុគ្គលនោះ ឃើញហើយ ដោយភាពជារបស់មិនទៀង ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **បច្ចុប្បន្នេ** ជាដើម ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីសួរថា **តេន** ដើម្បីចោទសួរបរវាទីនោះថា បើញាណក្នុងបច្ចុប្បន្នមាន ដោយមិនប្លែកគ្នាហើយសោត គប្បីមានញាណនោះ សូម្បីក្នុងបច្ចុប្បន្នក្ខណៈ កាលបើដូច្នេះ ញាណទាំងពីរ ក៏មិនមែនញាណដែលដូចគ្នា បុគ្គលគប្បីដឹងញាណនោះបាន ដោយញាណនោះឯង ។ ក្នុងបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីបដិសេធថា មិនអាចដឹងញាណនោះដោយញាណនោះបាន ។ ក្នុងបញ្ហាទី ២ បរវាទីឆ្លើយទទួល សំដៅយកការបន្ត ។ បញ្ហានោះ មានអធិប្បាយថា កាលបុគ្គលឃើញនូវការបែកធ្លាយ

ទៅនៃសង្ខារទាំងឡាយដោយលំដាប់ បុគ្គលនោះ ឈ្មោះថា រមែងឃើញកង្ខានុបស្សនាញាណបាន ដោយកង្ខានុបស្សនាញាណនោះឯង ។ ក្នុងបទទាំងឡាយ មានបទថា **តេន ញាណេន តំ ញាណំ ជានាតិ** ជាដើម ក៏មានន័យនេះ ។ ពាក្យទាំងឡាយដែលសកវាទីពោលថា **តេន ផស្សេន តំ ផស្សំ** ជាដើម ក៏ដើម្បីហាមឱកាស ដែលមានលេសន័យរបស់បរវាទីនោះ ។

[ ៦២៩ ] ដើម្បីឲ្យលទ្ធិតាំងទុក បរវាទីនោះពោលពាក្យណាថា **ននុ សព្វសង្ខារេ** ជាដើម ពាក្យឆ្លើយទទួលក្នុងពាក្យនោះ ជាពាក្យរបស់សកវាទី ដោយបំណងថា ញាណនោះ ឈ្មោះថា ឃើញហើយដោយន័យ តែមិនឃើញដោយអារម្មណ៍ ។ ព្រោះហេតុនោះ លទ្ធិដែលបរវាទីតាំងទុកហើយយ៉ាងនេះ ក៏មិនឈ្មោះថា តាំងទុកបានឡើយ ដូច្នេះ ។៚

**អដ្ឋកថាបច្ចុប្បន្នញាណកថា ចប់**

# អភិធម្មបិដក

## ផលញ្ញាណកថា

[ ៦៣០ ] ញាណ ក្នុងផលរបស់សាវ័ក មានឬ ។ អើ ។ សាវ័កបញ្ញត្ត នូវផលជារបស់ខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងផល របស់សាវ័ក មានឬ ។ អើ ។ការកំណត់ដឹងនូវផលដ៏ក្លា និងទន់ ការកំណត់ ដឹងនូវឥន្ទ្រិយដ៏ក្លា និងទន់ ការកំណត់ដឹងនូវបុគ្គលដ៏ក្លា និងទន់របស់សាវ័ក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងផលរបស់សាវ័ក មានឬ ។ អើ ។ ការបញ្ញត្តិនូវខន្ធ ការបញ្ញត្តិនូវអាយតនៈ ការបញ្ញត្តិនូវធាតុ ការបញ្ញត្តិនូវសច្ចៈ ការបញ្ញត្តិនូវឥន្ទ្រិយ ការបញ្ញត្តិនូវបុគ្គល របស់សាវ័ក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងផលរបស់សាវ័ក មានឬ ។ អើ ។ សាវ័ក ជាអ្នកឈ្នះមារ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹង សព្វ ឃើញសព្វ ជាម្ចាស់នៃធម៌ ជាអ្នកមានធម៌ជាទីពឹងដែរឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។បេ។ ញាណក្នុងផលរបស់សាវ័ក មានឬ ។ អើ ។ សាវ័ក ញ៉ាំងមគ្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ញ៉ាំងមគ្គដែលមិន ទាន់កើតព្រម ឲ្យកើតព្រម និយាយចំពោះមគ្គដែលគេមិនទាន់និយាយ ដឹង នូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[ ៦៣១ ] បុគ្គលមិនគួរនិយាយថា ញាណ ក្នុងផលរបស់សាវ័ក មាន ឬ ។ អើ ។ សាវ័កមិនមានញាណទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ព្រោះហេតុនោះ ញាណក្នុងផលរបស់សាវក មាន ។

ផលញ្ញាណកថា ចប់

បញ្ចមវគ្គ ចប់

## ឧទ្ទាននៃបញ្ចមវគ្គនោះ គឺ

និយាយអំពីវិមុត្តិញ្ញាណ ឈ្មោះថាវិមុត្ត ១ អសេក្ខញ្ញាណរបស់សេក្ខបុគ្គល ១ វិបរីតញ្ញាណ ១ ញាណក្នុងដំណើរទៅកាន់និយាមរបស់បុគ្គលជាអនិយតមាន ១ ញាណទាំងពួង ឈ្មោះថាបដិសម្ភិទា ១ សម្មតិញ្ញាណ ១ ញាណក្នុងការកំណត់ដឹងនូវចិត្ត ( នៃបុគ្គលដទៃ ) ១ ញាណក្នុងអនាគត ១ ញាណក្នុងបច្ចុប្បន្ន ១ ញាណក្នុងផលរបស់សាវក ១ ។

មហាបណ្ណាសក ចប់

វគ្គនិយាយពីបុគ្គលបានឈ្មោះថាសត្វជាដើម ១ វគ្គនិយាយពីទេវតាជាពួកនៃមារនាំយករបស់ដែលមិនស្អាត ឲ្យដល់ព្រះអរហន្ត ១ វគ្គនិយាយពីកម្លាំងនៃព្រះតថាគតជាដើម ១ វគ្គនិយាយពីគ្រហស្ថបានសម្រេចជាអរហន្ត ១ និងវគ្គនិយាយពីវិមុត្ត ១ ទៀត ជាគម្រប់ ៥ ។

# អដ្ឋកថា

## ផលញ្ញាណកថា

[ ៦៣០ ] ឥឡូវនេះ នឹងពណ៌នាអំពីផលញ្ញាណដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា សូម្បីសាវកទាំងឡាយ មានញាណក្នុងផល ដែលសត្វនោះៗ គប្បីសម្រេច ដូចព្រះពុទ្ធទាំងឡាយ ដោយភាពស្មើគ្នានេះថា ព្រះពុទ្ធទាំងឡាយក្តី សាវកទាំងឡាយក្តី រមែងសម្តែងធម៌ដើម្បីការកើតឡើងនៃអរិយផលរបស់សត្វទាំងឡាយ ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **សាវកស្ស** ជាដើម ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទសួរបរវាទីនោះថា បើសាវកមានញាណក្នុងផល ដូចព្រះពុទ្ធសោត ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងបញ្ញត្តគុណសម្បត្តិនៃផលក្នុងសោតាបត្តិផល សូម្បីមានដោយញាណពលរបស់ព្រះអង្គថា ព្រះសោតាបន្នរូបនេះជាឯកពីជី រូបនេះជាកោលំកោលៈ រូបនេះជាសត្តក្ខត្តុបរមៈ យ៉ាងណា សូម្បីសាវកតាមលទ្ធិរបស់អ្នក ក៏បញ្ញត្តគុណសម្បត្តិនៃផលបាន យ៉ាងនោះឬ ដូច្នេះ ទើបពោលថា **សាវកោ ផលស្ស កតំ បញ្ញបេតិ** ។ បរវាទីរមែងឆ្លើយបដិសេធ ។ បទថា **អត្ថិ សាវកស្ស**

**ផលបរោបរិយត្តិ** ជាដើម សកវាទីពោលដើម្បីសួរដល់បច្ច័យ ព្រោះផលញ្ញាណ មាន ។ ពិតហើយ ក្នុងបញ្ហានោះ មានអធិប្បាយថា ផលទាំងឡាយ ពោល គឺការដែលព្រះពុទ្ធទាំងឡាយ ទ្រង់ដឹងភាពខ្ពស់ និងទាបនៃផលទាំងឡាយ យ៉ាងនេះថា ផលនេះ ជាផលដទៃ ផលនេះ ជាផលដែលប្រាសទៅហើយ ដូច្នេះ ឈ្មោះថា **បរោបរិយត្តិ** ។ ការដឹងភាពក្រៃលែង ភាពទន់ខ្សោយនៃឥន្ទ្រិយ ការដឹងភាពក្រៃលែង ភាពទន់ខ្សោយនៃបុគ្គល ក៏មានដោយទំនងនោះ ព្រះពុទ្ធទាំងឡាយ រមែងដឹងនូវផលនោះៗ ដោយអំណាចនៃបុគ្គលនោះៗ ឬដោយអំណាចនៃឥន្ទ្រិយនោះៗ ព្រោះភាពដែលបរោបរិយត្តិញ្ញាណទាំងនោះ មាន ។ បរោបរិយត្តិញ្ញាណទាំងឡាយនេះ សូម្បីរបស់សាវ័ក ក៏មានឬ ។

ពាក្យទាំងឡាយ មានពាក្យថា **អត្ថិ សាវកស្ស ឥទ្ធិបញ្ញត្តិ** ជាដើម សកវាទីពោលហើយ ក៏ដើម្បីសួរថា បើផលញ្ញាណរបស់សាវ័កមាន ដូចរបស់ព្រះពុទ្ធ តាមលទ្ធិរបស់អ្នកសោត សាវ័កក៏គប្បីបញ្ញត្តធម៌ទាំងនេះបាន បញ្ញត្តិទាំងនេះ របស់សាវ័ក រមែងមានឬ សាវ័កអាចដឹងឬ ដើម្បីបញ្ញត្តិនូវបញ្ញត្តិទាំងនេះ ដោយកម្លាំងរបស់ខ្លួនឬ ដូច្នេះ ។ បទថា **សាវកោ ឯតោ**

សកវាទីពោលដើម្បីសួរថា បើសាវកមានផលញាណដូចព្រះពុទ្ធទាំងឡាយ សោត កាលបើភាពបែបនោះមាន សាវកនោះឯង ក៏នឹងជាព្រះជិនស្រី-សម្ពុទ្ធ ។ ក្នុងបញ្ហាថា **សាវកោ អនុប្បន្នស្ស** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ៦៣១ ] ក្នុងបញ្ហាថា **អញ្ញាណភី** សកវាទីឆ្លើយបដិសេធ ព្រោះការមិនដឹង គឺអវិជ្ជាដែលសាវកកម្ចាត់បានហើយ តែសាវកមានផលញាណដូចព្រះពុទ្ធក៏មិនមែន ព្រោះហេតុនោះ ទើបវាទៈរបស់បរវាទី មិនជាការតាំងទុកបាន ដូច្នេះ ។ល។

**អដ្ឋកថាផលញាណកថា ចប់**

**វគ្គទី ៥ ចប់**

**មហាបណ្ណាសក ចប់**

# អភិធម្មបិដក

## និយាមកថា

[ ៦៣២ ] និយាម ( អរិយមគ្គ ) ជាអសង្ខតៈឬ ។ អើ ។ ព្រះនិព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៣ ] និយាម ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ទីជ្រកកោន មាន ២ ទីការពារ មាន ២ ទីប្រព្រឹត្តទៅក្នុងខាងមុខ មាន ២ ទីមិនច្យុត មាន ២ ទីមិនស្លាប់ មាន ២ និព្វាន មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វាន មាន ២ ឬ ។ អើ ។ ភាពខ្ពស់ និងទាប ភាពថោកទាប និងឧត្តម ឧក្រិដ្ឋ និងទន់ទាប ដែនក្តី ការបែកធ្លាយក្តី ការប្រេះធាក្តី ការវិនាសទៅក្តី នៃនិព្វានទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៤ ] និយាម ជាអសង្ខតៈឬ ។ អើ ។ បុគ្គលពួកខ្លះ ឈានចុះកាន់និយាម បានចំពោះនូវនិយាម ញុំាងនិយាមឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើង មានដែរឬ ។ អើ ។ បុគ្គលពួកខ្លះ ឈានចុះកាន់អសង្ខតៈ បានចំពោះនូវអសង្ខតៈ ញុំាងអសង្ខតៈឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះ

ឡើង ឲ្យជុះជាលឡើង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៥ ] និយាម ជាអសង្ខតៈឬ ។ អើ ។ មគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ និយាម ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិនិយាម ជាអសង្ខតៈឬ ។ អើ ។ សោតាបត្តិមគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិមគ្គ ជាសង្ខតៈឬ ។ អើ ។ សោតាបត្តិ-និយាម ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិ-និយាម ។បេ។ អនាគាមិនិយាម ។បេ។ អរហត្តនិយាម ជាអសង្ខតៈឬ ។ អើ ។ អរហត្តមគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរហត្តមគ្គ ជាអសង្ខតៈឬ ។ អើ ។ អរហត្តនិយាម ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៦ ] សោតាបត្តិនិយាម ជាអសង្ខតៈឬ ។បេ។ អរហត្តនិយាម ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹង មាន ៥ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៧ ] និយាម ជាអសង្ខតៈឬ ។ អើ ។ មិច្ឆត្តនិយាម ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មិច្ឆត្តនិយាម ជាសង្ខតៈឬ ។ អើ ។ សម្មត្តនិយាម ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៣៨ ] បុគ្គលមិនគួរនិយាយថា និយាម ជាអសង្ខតៈទេឬ ។ អើ ។

កាលនិយាមកើតឡើងហើយ រលត់ទៅវិញ ឈ្មោះថា មិនទៀងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ និយាម ជាអសង្ខតៈ ។ កាលមិច្ឆត្តនិយាមកើតឡើងហើយ រលត់ទៅវិញ ឈ្មោះថា មិនទៀងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ មិច្ឆត្តនិយាម ជាអសង្ខតៈដែរ ។

**និយាមកថា ចប់**

# អដ្ឋកថា

## និយាមកថា

[ ៦៣២ ] ឥឡូវនេះ នឹងពណ៌នាអំពីនិយាមដូចតទៅ

ក្នុងបញ្ហានោះ លោកហៅអរិយមគ្គថា **និយាម** ព្រោះព្រះបាលី ( ក្នុងបុគ្គលប្បញ្ញត្តិ ) ថា ជាអ្នកគួរឈានចុះកាន់សម្មត្តនិយាមក្នុងធម៌ជាកុសលទាំងឡាយ ដូច្នេះជាដើម ។ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា ព្រោះកាលនិយាមនោះកើតឡើង និងរលត់ទៅហើយ បុគ្គលនោះ ឈ្មោះថា ជាបុគ្គលមិនទៀងក៏មិនមែន ព្រោះហេតុនោះទើបនិយាមនោះ ឈ្មោះថា ជាអសង្ខតៈ ដោយអត្ថថា ជារបស់ទៀងដូច្នេះ ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បន្ទាប់អំពីនោះ សកវាទី កាលសម្តែងថា បើនិយាមនោះជាអសង្ខតៈសោត និយាមនោះ ក៏គប្បីយ៉ាងនេះ ទើបពោលពាក្យថា **និព្វានំ** ជាដើម ។ ពាក្យសួរដើម្បីប្រៀបធៀប មានអត្ថងាយយល់ហើយ ។

[ ៦៣៤ ] បទថា **អត្ថិ កេចិ** ជាដើម សកវាទីពោលដើម្បីសម្តែងភាពជាសង្ខតៈនៃនិយាម ។

[ ៦៣៥ ] ក្នុងបញ្ហាថា **មគ្គោ អសង្ខតោ** បរវាទីឆ្លើយបដិសេធ ព្រោះមគ្គនោះមានការកើត និងការរលត់ ។ ក្នុងបញ្ហាថា **និយាមោ សង្ខតោ** បរវាទីសំដៅយកនិយាមក្នុងមគ្គដែលរលត់ទៅហើយ ក៏ជារបស់មាន ទើប

ឆ្លើយបដិសេធ ។ ក្នុងបទទាំងឡាយ មានបទថា **សោតាបត្តិនិយាមោ** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយអនុលោម និងដោយបដិលោម ដោយន័យនេះឯង ។

[ ៦៣៦ ] បរវាទី ត្រូវសកវាទីសួរថា **បញ្ច អសង្ខតានិ** កាលមិនឃើញទីមករបស់អសង្ខតៈ ៥ យ៉ាង ទើបឆ្លើយបដិសេធ ។ ត្រូវសួរលើកទី ២ ក៏ឆ្លើយទទួល ព្រោះពាក្យថា និយាម នៃសម្មត្តនិយាម ៤ យ៉ាង និងព្រោះភាពជាអសង្ខតៈរបស់ព្រះនិព្វាន ១ ។ បញ្ហាពោលអំពីមិច្ឆត្តនិយាម សកវាទីពោលហើយ ដើម្បីសម្តែងការមិនត្រឹមត្រូវនៃភាពជាអសង្ខតៈ ដោយហេតុត្រឹមតែពាក្យថា និយាម ដោយប្រការដូច្នេះឯង ។

## អដ្ឋកថានិយាមកថា ចប់

# អភិធម្មបិដក

## បដិច្ចសមុប្បាទកថា

[ ៦៣៩ ] បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិច្ចសមុប្បាទ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ទីជ្រកកោន មាន ២ ទីការពារ មាន ២ ទីប្រព្រឹត្តទៅខាងមុខ មាន ២ ទីមិនច្យុត មាន ២ ទីមិនស្លាប់ មាន ២ និព្វាន មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វាន មាន ២ ឬ ។ អើ ។ ភាពខ្ពស់ និងទាបភាពថោកទាប និងឧត្តម ឧក្រិដ្ឋ និងទន់ទាប ដែនក្តី ការបែកធ្លាយក្តី ការប្រេះធាក្តី ការវិនាសទៅក្តី នៃនិព្វានទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤០ ] បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ អវិជ្ជា ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អវិជ្ជា ជាសង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។

បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិច្ច-សមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ នាមរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ នាមរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤១ ] បុគ្គលមិនគួរនិយាយថា បដិច្ចសមុប្បាទ ជាអសង្ខតៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ការកើតឡើងនៃតថាគតទាំងឡាយក្តី ការមិនកើតឡើងនៃតថាគតទាំងឡាយក្តី ក៏ធាតុនោះ ភាពនៃការស្ថិតនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ភាពនៃឥទប្បច្ច័យនោះ រមែងតាំងនៅជាធម្មតា តថាគតត្រាស់ដឹងច្បាស់ យល់ច្បាស់នូវហេតុ មានធាតុជាដើមនោះ

លុះត្រាស់ដឹងច្បាស់ យល់ច្បាស់ហើយ ទើបប្រាប់ សម្តែង បញ្ញត្ត តែង តាំង បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសថា អ្នកទាំងឡាយ ចូរមើលចុះ ម្នាលភិក្ខុទាំងឡាយ ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ។បេ។ ម្នាល ភិក្ខុទាំងឡាយ សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ការ កើតឡើងនៃតថាគតទាំងឡាយក្តី ការមិនកើតឡើងនៃតថាគតទាំងឡាយក្តី ក៏ ធាតុនោះ រមែងតាំងនៅជាធម្មតា ។បេ។ ប្រកាសថា អ្នកទាំងឡាយ ចូរមើល ចុះ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែ ប្រួល ភាពនៃឥទប្បច្ច័យណា ក្នុងធម៌ទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សង្ខារ ទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិច្ចសមុប្បាទ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បដិច្ចសមុប្បាទ ជាអសង្ខតៈ ។

[ ៦៤២ ] បណ្តាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការ កំណត់នូវធម៌ណាថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៣ ] បណ្តាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការ កំណត់នូវធម៌ណាថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ

ជាអសង្ខតៈ បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ណាថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ៣ ឬ ។ អើ ។ ទីពឹង មាន ៣ ។បេ។ ការវិនាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៤ ] បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ណាថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈ បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ណាថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ជាអសង្ខតៈ ។បេ។ បណ្ដាធម៌ទាំងឡាយនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ណាថា ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ១២ ឬ ។ អើ ។ ទីពឹង មាន ១២ ទីជ្រកកោន មាន ១២ ។បេ។ ការវិនាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

បដិច្ចសមុប្បាទកថា ចប់

# អដ្ឋកថា

## បដិច្ចសមុប្បាទកថា

[ ៦៣៩ ] ឥឡូវនេះ នឹងពណ៌នាអំពីបដិច្ចសមុប្បាទដូចតទៅ ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងនិកាយមហិសាសកៈទាំងឡាយថា បដិច្ចសមុប្បាទ ជាអសង្ខតៈ ព្រោះព្រះបាលីក្នុងនិទានវគ្គថា ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ តែងស្ថិតនៅជាធម្មតា ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។

[ ៦៤០ ] បញ្ហាថា **អវិជ្ជា អសង្ខតា** ជាដើម សកវាទីពោលដើម្បីសម្តែងភាពដែលធម៌ទាំងឡាយ មានអវិជ្ជាជាដើមនោះឯង អាស្រ័យគ្នាកើតឡើង ។ អង្គនីមួយៗ ក្នុងធម៌ទាំងនោះ លោកហៅថា បដិច្ចសមុប្បាទដោយអត្ថឯណា អត្ថនោះឯង លោកបានពោលហើយ ក្នុងបដិច្ចសមុប្បាទវិភង្គ ។

[ ៦៤២ ] បទថា **អវិជ្ជាបច្ចយា សង្ខារាតិ យា តត្ថ ធម្មដ្ឋិតតា** ជាដើម សកវាទីពោលដើម្បីទម្លាយលទ្ធិ ដោយការសម្តែងអត្ថរបស់ព្រះសូត្រ ដែលជាហេតុ ឲ្យបរវាទីនាំលទ្ធិមកតាំងទុក ។ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថថា ធាតុណាដែលលោកពោលក្នុងកាលមុនថា ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា ដូច្នេះ ធាតុនោះ វៀរចាកអវិជ្ជា

ជាដើមមាន ចែកចេញជាចំណែកមួយក៏មិនមែន ហើយពាក្យថា ធម្មដ្ឋិតិ និង ធម្មនិយាមនេះ ជាឈ្មោះនៃបច្ច័យទាំងឡាយ មានអវិជ្ជាជាដើមនោះឯង ។ ពិតហើយ កាលព្រះតថាគតទ្រង់កើតហើយក្តី មិនទាន់បានកើតក្តី សង្ខារ ទាំងឡាយក៏រមែងកើតព្រោះអវិជ្ជាជាបច្ច័យ ទាំងធម៌ទាំងឡាយ មានវិញ្ញាណ ជាដើម រមែងកើតអំពីធម៌ទាំងឡាយ មានសង្ខារជាដើម ព្រោះហេតុនោះ ការតាំងនៅឯណា ព្រោះអត្ថថា ជាហេតុនៃសង្ខារធម៌ទាំងឡាយ ក្នុងបទ នេះថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម ព្រោះហេតុនោះ ទើបការតាំងនៅ នោះ ឈ្មោះថា ធម្មដ្ឋិតិ ម្យ៉ាងទៀត ភាពដែលធម៌ទាំងនោះឯងជានិយាម ព្រោះអត្ថថា ជាហេតុ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា ធម្មនិយាម ព្រោះហេតុនោះ ធម្មដ្ឋិតិក្តី ធម្មនិយាមក្តី លោកហៅថា អវិជ្ជា ។ សកវាទី សួរថា សភាវៈនោះ ( អវិជ្ជា ) ជាអសង្ខតៈ និព្វាន ក៏ជាអសង្ខតៈឬ បរវាទី ឆ្លើយទទួលដោយអំណាចនៃលទ្ធិហើយ ត្រូវសួរទៀតថា **ទ្វេ អសង្ខតានិ** ក៏ឆ្លើយបដិសេធ ព្រោះមិនមានក្នុងព្រះសូត្រ តែឆ្លើយទទួលដោយអំណាច នៃលទ្ធិ ។ ក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។ ម្យ៉ាងទៀត ក្នុងទី នេះ បណ្ឌិតគប្បីជ្រាបដូចពាក្យដែលពោលហើយខាងដើម ដោយន័យដែល ពោលហើយនោះឯង ។

## អដ្ឋកថាបដិច្ចសមុប្បាទកថា ចប់

# អភិធម្មបិដក

## សច្ចកថា

[ ៦៤៥ ] សច្ចៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ទីពឹង ៤ ទីជ្រកកោន ៤ ទីការពារ ៤ ទីប្រព្រឹត្តទៅខាងមុខ ៤ ទីមិនច្យុត ៤ ទីមិនស្លាប់ ៤ និព្វាន ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វាន មាន ៤ ឬ ។ អើ ។ ភាពខ្ពស់ និងទាប ភាពថោកទាប និងឧត្តម ឧក្រិដ្ឋ និងទន់ទាប ដែនក្តី ការបែកធ្លាយក្តី ការប្រេះធាក្តី ការវិនាសទៅក្តី នៃនិព្វានទាំង ៤ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៦ ] ទុក្ខសច្ច ជាអសង្ខតៈឬ ។ អើ ។ ទុក្ខ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខសច្ច ជាអសង្ខតៈឬ ។ អើ ។ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សមុទយសច្ច ជាអសង្ខតៈឬ ។ អើ ។ សមុទយៈ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សមុទយសច្ច ជាអសង្ខតៈឬ ។ អើ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គសច្ច ជាអសង្ខតៈឬ ។ អើ ។ មគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គសច្ច ជាអសង្ខតៈឬ ។ អើ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៧ ] ទុក្ខ ជាសង្ខតៈឬ ។ អើ ។ ទុក្ខសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទុក្ខ ប្រព្រឹត្តទៅក្នុងកាយ ទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត ជាសង្ខតៈឬ ។ អើ ។ ទុក្ខសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សមុទយៈ ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមតណ្ហា ភវតណ្ហា វិភវ-តណ្ហា ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៨ ] និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៤៩ ] ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាអសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាង

នេះទេ ។បេ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥០ ] បុគ្គលមិនគួរនិយាយថា សច្ចៈទាំង ៤ ជាអសង្ខតៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលនោះ មាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះជាទុក្ខ ១ ។បេ។ ថានេះ ជាទុក្ខសមុទយៈ ១ ។បេ។ ថានេះ ជាទុក្ខនិរោធ ១ ។បេ។ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះជាទុក្ខនិរោធគាមិនីបដិបទា ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល មាន ៤ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សច្ចៈទាំង ៤ ជាអសង្ខតៈ ។

## សច្ចកថា ចប់

# អដ្ឋកថា

## សច្ចកថា

[ ៦៤៥ ] ឥឡូវនេះ នឹងពណ៌នាអំពីសច្ចៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា សច្ចៈទាំង ៤ ជាអសង្ខតៈ ព្រោះអាស្រ័យព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយសច្ចៈ ៤ យ៉ាងនេះ ពិត មិនឃ្លៀងឃ្លាតមិនជាយ៉ាងដទៃជាដើម ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ គប្បីជ្រាបពាក្យអធិប្បាយបញ្ហានោះថា បណ្ដាទុក្ខ សមុទយៈ និងមគ្គទាំងឡាយ ឈ្មោះថា វត្ថុសច្ចៈជាសង្ខតៈ លក្ខណសច្ចៈ ( និព្វាន ) ជាអសង្ខតៈ ឈ្មោះថា វត្ថុសច្ចៈ មិនមានក្នុងនិរោធ និរោធសច្ចនោះ ជាអសង្ខតៈតែម្យ៉ាង ព្រោះហេតុនោះ ទើបបរវាទីឆ្លើយទទួលថា **អាមន្តា** តែការឆ្លើយទទួលនោះ ត្រឹមតែជាលទ្ធិរបស់បរវាទីប៉ុណ្ណោះ ។ ពិតហើយ បរវាទីនោះ រមែងកាន់យកថា ទុក្ខ ជាវត្ថុសច្ចៈ ទាំងសមុទយៈ និងមគ្គក៏យ៉ាងនោះ ។ ឯលក្ខណៈទាំងឡាយណា មានលក្ខណៈនាំចេញចាកទុក្ខដែលជាគ្រឿងបៀតបៀន និងចាកហេតុឲ្យកើតទុក្ខនៃសច្ចៈទាំងនោះ លក្ខណៈទាំងនោះ ឈ្មោះថា លក្ខណសច្ចៈ ។ ម្យ៉ាងទៀត ឈ្មោះថា សច្ចៈ មានទុក្ខជាដើម ដទៃអំពីលក្ខណៈបៀតបៀនជាដើមមិនមាន ។ បណ្ដាពាក្យទាំងឡាយ មានពាក្យថា **តាណានិ** ជាដើម បណ្ឌិតគប្បីជ្រាបអធិប្បាយ ដោយន័យដែលពោលហើយនោះឯង ។

[ ៦៤៦ ] ក្នុងបញ្ហាថា **ឧក្កុសច្ចំ** បរវាទីសំដៅយកលក្ខណសច្ចៈ ដោយអំណាចនៃលទ្ធិ ទើបឆ្លើយទទួល ។ ក្នុងបញ្ហាថា **ឧក្កុំ** បរវាទីសំដៅយកវត្ថុសច្ចៈ ទើបឆ្លើយបដិសេធ ។ ខាងមុខអំពីនេះ សុទ្ធិកបញ្ហាក្តី បញ្ហាពោលដោយការប្រៀបធៀបក្តី ទាំងអស់ បណ្ឌិតគប្បីជ្រាបដោយទំនងនៃព្រះបាលីនោះឯង ។ ក្នុងអវសានព្រះសូត្រ ដែលបរវាទីនាំមកដើម្បីតាំងទុកជាលទ្ធិ ដូចគ្នានឹងមិនបាននាំមកនោះឯង ព្រោះលោកកាន់យកអត្ថខុសដោយប្រការដូច្នេះឯង ៗ។

**អដ្ឋកថាសច្ចកថា ចប់**

# អភិធម្មបិដក

## អារុប្បកថា

[ ៦៥១ ] អាកាសានញ្ចាយតនៈ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈឬ ។ អើ ។ អាកាសានញ្ចាយតនៈ គឺជាភព ជាគតិ ជាសត្តាវាស ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អើ ។ អសង្ខតៈ គឺជាភព ជាគតិ ជាសត្តាវាស ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កម្មដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ កម្មដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ ពួកសត្វដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥២ ] ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៣ ] វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អាកាសានញ្ចាយតនៈ គឺចតុវោការភពឬ ។ អើ ។ អសង្ខតៈ គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៤ ] បុគ្គលមិនគួរនិយាយថា អារុប្បៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ជាធម៌មិនញាប់ញ័រ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អារុប្បៈ ៤ ជាអសង្ខតៈ ។

អារុប្បកថា ចប់

# អដ្ឋកថា

## អារុប្បកថា

[ ៦៥១ ] ឥឡូវនេះ នឹងពណ៌នាអំពីអារុប្បៈដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិថា ធម៌ទាំងពួងនោះ ជាអសង្ខតៈ ព្រោះអាស្រ័យព្រះបាលីថា ភពមិនមានរូបទាំង ៤ ជាសភាវៈមិនញាប់ញ័រ ដូច្នេះ ពាក្យសួររបស់សកវាទីថា **អាកាសានញ្ចាយតនំ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួលជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។ សូម្បីព្រះសូត្រ ដែលសាធកៈនោះ ក៏ដូចជាមិនបាននាំមកនោះឯង ព្រោះមិនដឹងអត្ថ ហើយនាំមក ដូច្នេះឯង ។ល។

**អដ្ឋកថាអារុប្បកថា ចប់**

# អភិធម្មបិដក

## និរោធសមាបត្តិកថា

[ ៦៥៥ ] និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសមាបត្តិ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធ-សមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់និរោធ បានចំពោះនូវនិរោធ ញុំាងនិរោធឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់អសង្ខតៈ បានចំពោះនូវអសង្ខតធម៌ ញុំាងអសង្ខតធម៌ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យដុះឡើង ឲ្យដុះដាលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការផ្ទូរផង់ ការចេញព្រោះនិរោធ រមែងប្រាកដឬ ។ អើ ។ ការផ្ទូរផង់ ការចេញ ព្រោះអសង្ខតៈ រមែងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលបុគ្គលចូលកាន់និរោធ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អើ ។ កាលបុគ្គលចូលកាន់អសង្ខតៈ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខារ

វេលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាលបុគ្គលចេញចាកនិរោធ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អើ ។ កាលបុគ្គលចេញចាកអសង្ខតៈ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៦ ] ផស្សៈ ៣ គឺសុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវនូវបុគ្គលដែលចេញអំពីនិរោធឬ ។ អើ ។ ផស្សៈ ៣ គឺសុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវ នូវបុគ្គលដែលចេញអំពីអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៧ ] ចិត្តរបស់បុគ្គលដែលចេញអំពីនិរោធ ឱនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អើ ។ ចិត្តរបស់បុគ្គលដែលចេញអំពីអសង្ខតៈ ឱនទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្ទាកទៅកាន់វិវេកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៥៨ ] បុគ្គលមិនគួរនិយាយថា និរោធសមាបត្តិ ជាអសង្ខតៈទេឬ ។ អើ ។ និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ និរោធសមាបត្តិជាអសង្ខតៈ ។

**និរោធសមាបត្តិកថា ចប់**

# អដ្ឋកថា

## និរោធសមាបត្តិកថា

[ ៦៥៥ ] ឥឡូវនេះ នឹងពណ៌នាអំពីនិរោធសមាបត្តិដូចតទៅ

ក្នុងរឿងនោះ ការមិនប្រព្រឹត្តទៅនៃនាមក្ខន្ធ ៤ ឈ្មោះថា **និរោធ-សមាបត្តិ** ។ ព្រោះនិរោធសមាបត្តិនោះ ដែលបុគ្គលកាលធ្វើ ឈ្មោះថា រមែងធ្វើបាន គឺកាលចូលនិរោធសមាបត្តិ រមែងចូលបាន ព្រោះហេតុនោះ ទើបលោកហៅនាមក្ខន្ធ ៤ នោះថា ជាសមាបត្តិដែលរលត់ទៅហើយ តែបុគ្គលណាមួយ មិនគប្បីពោលថា ជាសង្ខតធម៌ ឬជាអសង្ខតធម៌ ព្រោះមិនមានលក្ខណៈនៃសង្ខតធម៌ និងអសង្ខតធម៌ ។

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈ និងនិកាយឧត្តរាបថកៈទាំងឡាយថា ព្រោះនិរោធសមាបត្តិ មិនជាសង្ខតៈ ព្រោះហេតុនោះ ទើបជាអសង្ខតៈ ដូច្នេះ ពាក្យសួររបស់សកវាទីថា **និរោធសមាបត្តិ** ជាដើម សំដៅដល់ជនទាំងនោះ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ បទថា **ឧប្បាទេន្តិ** ជាដើម សកវាទីពោលហើយដោយអំណាចនៃការចូល និងការបានចំពោះនូវសមាបត្តិនោះ អធិប្បាយថា ដូចជនទាំងឡាយញុំាងសង្ខតធម៌ទាំងឡាយ មានរូបជាដើមឲ្យកើតឡើង បាន

ដោយវិធីណា តែបុគ្គលណាមួយ ឈ្មោះថា ញុំាងអសង្ខតៈឲ្យកើតឡើង បានដោយវិធីនោះបាន មិនមាន ។ បទថា **និរោធា វោទានំ វុដ្ឋានំ** បណ្ឌិត គប្បីជ្រាបថា ជាផលសមាបត្តិ តែការផូរផង់ ការចេញចាកអសង្ខតៈនោះ មិនមានឡើយ ព្រោះហេតុនោះ ទើបបរវាទីឆ្លើយបដិសេធ ។

[ ៦៥៨ ] បទថា **តេន ហិ** សេចក្ដីថា មានលទ្ធិថា ព្រោះនិរោធ សមាបត្តិមិនជាសង្ខតៈ ព្រោះហេតុនោះ ទើបត្រូវជាអសង្ខតៈ ដូច្នេះ តែ ពាក្យនេះ មិនជាហេតុ ក្នុងភាពជាអសង្ខតៈ ព្រោះហេតុនោះ សូម្បីបរវាទី ពោលហើយ ក៏ដូចជាមិនបានពោលនោះឯង ដូច្នេះ ។

## អដ្ឋកថានិរោធសមាបត្តិកថា ចប់

# អភិធម្មបិដក

## អាកាសកថា

[ ៦៥៩ ] អាកាស ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦០ ] អាកាស ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦១ ] អាកាស ជាអសង្ខតៈឬ ។ អើ ។ មានបុគ្គលពួកខ្លះ ធ្វើនូវទីមិនមែនជាអាកាស ឲ្យជាអាកាសឬ ។ អើ ។ មានបុគ្គលពួកខ្លះ ធ្វើនូវសង្ខតៈ ឲ្យជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦២ ] មានបុគ្គលពួកខ្លះ ធ្វើនូវអាកាស ឲ្យទៅជាមិនមែនអាកាសឬ ។ អើ ។ មានបុគ្គលពួកខ្លះ ធ្វើនូវអសង្ខតៈ ឲ្យជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៣ ] ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រ និងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយតែងចរទៅ ពួកជនតែងសម្តែងឫទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរទៅក្នុងអាកាសបានឬ ។ អើ ។ ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រ និង

ព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្តែងឫទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរ ទៅក្នុងអសង្ខតៈបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៤ ] ពួកជន បិទបាំងនូវអាកាស ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អើ ។ ពួកជនបិទបាំងនូវអសង្ខតៈ ហើយធ្វើផ្ទះទាំងឡាយ ធ្វើជង្រុកទាំងឡាយបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៥ ] កាលអណ្តូង កាលគេជីក អាកាសទៅជាមិនមែនអាកាសឬ ។ អើ ។ សង្ខតៈទៅជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៦ ] កាលអណ្តូងទទេ ដែលគេដាក់ទឹកពេញ កាលជង្រុកទទេ ដែលគេដាក់ឲ្យពេញ កាលក្អមទទេ ដែលគេដាក់ទឹកពេញ អាកាស រមែងបាត់ឬ ។ អើ ។ អសង្ខតៈ រមែងបាត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៧ ] បុគ្គលមិនគួរនិយាយថា អាកាស ជាអសង្ខតៈឬ ។ អើ ។ អាកាស ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អាកាស ជាអសង្ខតៈ ។

**អាកាសកថា ចប់**

# អដ្ឋកថា

## អាកាសកថា

[ ៦៥៩ ] ឥឡូវនេះ នឹងពណ៌នាអំពីអាកាសដូចតទៅ

ក្នុងរឿងនោះ អាកាស មាន ៣ យ៉ាង គឺបរិច្ឆេទាកាស ១ កសិណុគ្ឃាដិមាកាស ១ អជដាកាស ១ ។ សូម្បីបទថា **តុច្ឆាកាស** ក៏ជាឈ្មោះរបស់អជដាកាសនោះឯង ។ បណ្ដាអាកាសទាំងនោះ **បរិច្ឆេទាកាស** ជាសង្ខត: ឯអាកាសដ៏សេស ២ ទៀតនេះ ត្រឹមតែជាបញ្ញត្តិ ។

ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈ និងនិកាយមហិសាសកៈទាំងឡាយថា អាកាសទាំង ២ គឺកសិណុគ្ឃាដិមាកាស និងអជដាកាស មិនមែនសង្ខតៈ ព្រោះហេតុនោះ ទើបជាអសង្ខតៈ ដូច្នេះ ពាក្យសួររបស់សកវាទីថា **អាកាសោ** ជាដើម សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាអាកាសកថា ចប់**

# អភិធម្មបិដក

## អាកាសសនិទស្សនោតិកថា

[ ៦៦៨ ] អាកាស ជាសនិទស្សនៈ ( ប្រកបដោយការមើលឃើញ ) ឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៦៩ ] អាកាស ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧០ ] ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន

អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងទេ ។

[ ៦៧១ ] បុគ្គល មិនគួរនិយាយថា អាកាស ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញនូវចន្លោះនៃដើមឈើ ២ នូវចន្លោះនៃសសរ ២ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរឬ ។ អើ ។ បើអ្នកឃើញនូវចន្លោះនៃដើមឈើ ២ នូវចន្លោះនៃសសរ ២ នូវប្រហោងនៃកូនសោ នូវប្រហោងនៃបង្អួចដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាកាស ជាសនិទស្សនៈដែរ ។

អាកាសសនិទស្សនោតិកថា ចប់

# អដ្ឋកថា

## អាកាសសនិទស្សនោតិកថា

[ ៦៦៨ ] ឥឡូវនេះ នឹងពណ៌នាអំពីអាកាសជារបស់ឃើញបាន ដោយចក្ខុដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិនៃនិកាយអន្ធកៈទាំងឡាយថា អជដាកាសទាំងពួង ជារបស់ឃើញបាន ព្រោះអាស្រ័យការប្រព្រឹត្តទៅនៃការដឹងក្នុងទីទាំងឡាយ មានប្រហោងសោជាដើម ពាក្យសួររបស់សកវាទីថា **អាកាសោ សនិទស្សនោ** សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា **រូបំ** ជាដើម ដើម្បីចោទសួរបរវាទីនោះថា បើអាកាសជារបស់ឃើញបានសោត អាកាស ក៏គប្បីជាយ៉ាងនេះៗ ។

[ ៦៦៩-៦៧០ ] ក្នុងបញ្ហាទាំងឡាយថា **ចក្ខុញ្ច បដិច្ច** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានព្រះសូត្របែបនោះ ហើយត្រឡប់ជាឆ្លើយទទួល ព្រោះអាស្រ័យការចូលទៅឃើញទីទាំងឡាយ មានប្រហោងដែលគ្រោតគ្រាតជាដើម ។

[ ៦៧១ ] ក្នុងបទថា **ទ្វិន្នំ រុក្ខានំ អន្តរំ** នេះ អធិប្បាយថា វិញ្ញាណដែលកើតតាមមនោទ្វារ រមែងកើតថា នេះ គឺអាកាស ព្រោះឃើញដើមឈើដោយចក្ខុហើយ មិនមានរូបក្នុងចន្លោះ មិនមែនចក្ខុវិញ្ញាណកើតឡើង ។ ក្នុងពាក្យដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ព្រោះហេតុនោះ ពាក្យដែលបរវាទីនាំមកពោលហើយនោះ ទើបមិនសម្រេចប្រយោជន៍ ដូច្នេះឯង ។ល។

# អភិធម្មបិដក

## បឋវីធាតុសនិទស្សនាទិកថា

[ ៦៧២ ] បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧៣ ] បឋវីធាតុ ជានិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧៤ ] ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អើ ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីផងទេ ។

[ ៦៧៥ ] បុគ្គល មិនគួរនិយាយថា បឋវីធាតុជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញផែនដី ថ្ម ភ្នំ ដែរឬ ។ អើ ។ បើអ្នកឃើញផែនដី

ថ្ម ភ្នំដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បឋវីធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គល មិនគួរនិយាយថា អាបោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញទឹកដែរឬ ។ អើ ។ បើអ្នកឃើញទឹកដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាបោធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គល មិនគួរនិយាយថា តេជោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញភ្លើងកំពុងឆេះដែរឬ ។ អើ ។ បើអ្នកឃើញភ្លើងកំពុងឆេះដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា តេជោធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គល មិនគួរនិយាយថា វាយោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរឬ ។ អើ ។ បើអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាយោធាតុ ជាសនិទស្សនៈដែរ ។បេ។

## បឋវីធាតុសនិទស្សនាត្យាទិកថា ចប់

# អភិធម្មបិដក

## ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

[ ៦៧៦ ] ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ។បេ។ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧៧ ] ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[ ៦៧៨ ] ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យនូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អើ ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យនូវចក្ខុផង នូវចក្ខុន្ទ្រិយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងទេ ។

[ ៦៧៩ ] បុគ្គល មិនគួរនិយាយថា បញ្ចិន្ទ្រិយ ( ឥន្ទ្រិយ ៥ ) ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរឬ ។ អើ ។ បើអ្នកឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បញ្ចិន្ទ្រិយ ជា

សនិទស្សនៈដែរ ។បេ។

ចក្ខុន្ទ្រិយំ សនិទស្សនត្តិកអាទិកថា ចប់

# អភិធម្មបិដក

## កាយកម្មំ សនិទស្សនត្តិកថា

[ ៦៨០ ] កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគួរដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យនូវចក្ខុផង នូវកាយកម្មផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យនូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងទេ ។

[ ៦៨១ ] បុគ្គល មិនគួរនិយាយថា កាយកម្មជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរឬ ។ អើ ។ បើអ្នកឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្មជាសនិទស្សនៈដែរ ។

កាយកម្មសនិទស្សនទិ្ធកថា ចប់

និយាយពីបឋវីធាតុសនិស្សនៈជាដើម

និងកាយកម្មសនិទស្សនៈជាទីបំផុត

ឆដ្ឋវគ្គ ចប់

## ឧទ្ទាននៃឆដ្ឋវគ្គនោះ គឺ

និយាយអំពីនិយាមជាអសង្ខតៈ ១ បដិច្ចសមុប្បាទជាអសង្ខតៈ ១ សច្ចៈទាំង ៤ ជាអសង្ខតៈ ១ អារុប្បៈ ៤ ជាអសង្ខតៈ ១ និរោធសមាបត្តិជាអសង្ខតៈ ១ អាកាសជាអសង្ខតៈ ១ អាកាសជាសនិទស្សនៈ ១ មហាភូតរូប ៤ ជាសនិទស្សនៈ ១ បញ្ចិន្ទ្រិយជាសនិទស្សនៈ ១ កាយកម្ម ជាសនិទស្សនៈ ១ ។

# អដ្ឋកថា

## បឋវីធាតុសនិទស្សនាតិអាទិកថា

[ ៦៧២ ] ឥឡូវនេះ នឹងពណ៌នាអំពីរឿងបឋវីធាតុជាសនិទស្សនៈ ជាដើមដូចតទៅ

ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា បឋវីធាតុជាដើម ជារបស់ឃើញបានដោយភ្នែក ព្រោះឃើញវណ្ណាយតនៈ គឺពណ៌នៃដុំថ្ម ទឹក អណ្តាតភ្លើង និងការកម្រើករបស់ដើមឈើនោះឯងផង ព្រោះឃើញវណ្ណាយតនៈ នៃឱកាសដែលតាំងនៅចំពោះនៃឥន្ទ្រិយ ៥ គឺចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយផង និងព្រោះឃើញរូប មានដៃ និងជើងជាដើម ក្នុងពេលកម្រើកកាយផង ពាក្យសួរផ្តើមក្នុងរឿងទាំងអស់របស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយទទួល ជាពាក្យរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីទាំងពួង បណ្ឌិតគប្បីជ្រាបដោយទំនងនៃព្រះបាលី និងដោយន័យដែលពោលហើយខាងដើមនោះឯង ។

[ ៦៨០ ] រឿងចុងក្រោយថា **កាយកម្មំ សនិទស្សនំ** ដោយមានរឿងបឋវីធាតុ ជាសនិទស្សនៈ ជារឿងដំបូងចប់ហើយ ។ល។

**អដ្ឋកថាបឋវីធាតុសនិទស្សនាតិអាទិកថា ចប់**

**វគ្គទី ៦ ចប់**

# ក្បាលទី ៧១

# អភិធម្មបិដក-៨៤

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


អភិធម្មបិដក បុគ្គលកថា .......... .......... .......... .......... .......... ២

អារម្មកថា .......... .......... .......... .......... .......... ៤

និទានកថា .......... .......... .......... .......... .......... ៥

អដ្ឋកថាបុគ្គលកថា .......... .......... .......... .......... .......... ១៨

អនុលោមបច្ចនីកៈ .......... .......... .......... .......... .......... ១៨

អភិធម្មបិដក បដិកម្មចតុក្កៈ .......... .......... .......... .......... .......... ២៦

អដ្ឋកថាបដិកម្មចតុក្កៈ .......... .......... .......... .......... .......... ២៨

អភិធម្មបិដក និគ្គហចតុក្កៈ .......... .......... .......... .......... .......... ៣០

អដ្ឋកថានិគ្គហចតុក្កៈ .......... .......... .......... .......... .......... ៣២

អភិធម្មបិដក ឧបនយនចតុក្កៈ .......... .......... .......... .......... .......... ៣៤

អដ្ឋកថាឧបនយនចតុក្កៈ .......... .......... .......... .......... .......... ៣៦

អភិធម្មបិដក និគ្គមចតុក្កៈ .......... .......... .......... .......... .......... ៣៨

អដ្ឋកថានិគ្គមចតុក្កៈ .......... .......... .......... .......... .......... ៤០

អភិធម្មបិដក បច្ចនីកបញ្ចកៈ .......... .......... .......... .......... .......... ៤២

អដ្ឋកថាបច្ចនីកានុលោម .......... .......... .......... .......... .......... ៤៤

អភិធម្មបិដក បដិកម្មចតុក្កៈ .......... .......... .......... ៤៥

អដ្ឋកថាបដិកម្មចតុក្កៈជាដើម .......... .......... .......... ៥០

អភិធម្មបិដក ឱកាសសច្ចិកដ្ឋៈ អនុលោមបច្ចនីកៈ .......... .......... .......... ៥២

អដ្ឋកថាឱកាសសច្ចិកដ្ឋអនុលោមបច្ចនីកៈ .......... .......... .......... ៥៤

អភិធម្មបិដក កាលសច្ឆិកដ្ឋៈ អនុលោមបច្ចនីកៈ .......... .......... ....... ៥៦

អដ្ឋកថាកាលសច្ឆិកដ្ឋអនុលោមបច្ចនីកៈ .......... .......... ........ ៥៨

អភិធម្មបិដក អវយវសច្ឆិកដ្ឋៈ អនុលោមបច្ចនីកៈ .......... .......... ........ ៥៩

អដ្ឋកថាអវយវសច្ឆិកដ្ឋអនុលោមបច្ចនីកៈ .......... .......... ........ ៦០

អភិធម្មបិដក ឱកាសទិសច្ឆិកដ្ឋាទិ បច្ចនីកានុលោម.......... .......... ...... ៦១

អដ្ឋកថាឱកាសទិសច្ឆិកដ្ឋាទិ បច្ចនីកានុលោម .......... .......... ........ ៦៤

អភិធម្មបិដក សុទ្ធិកសំសន្ទនៈ .......... .......... ........ ៦៦

អដ្ឋកថាសុទ្ធិកសំសន្ទនៈ .......... .......... ...... ៧៤

អភិធម្មបិដក ឱបម្មសំសន្ទនៈ .......... .......... ........ ៧៦

អដ្ឋកថាឱបម្មសំសន្ទនៈ .......... .......... ........ ៨៨

អភិធម្មបិដក ចតុក្កនយសំសន្ទនៈ .......... .......... ........ ៩០

អដ្ឋកថាចតុក្កនយសំសន្ទនៈ .......... .......... ........ ៩៧

អភិធម្មបិដក លក្ខណយុត្តិកតា .......... .......... .... ១០០

អដ្ឋកថាលក្ខណយុត្តិ .......... .......... ..... ១០១

អភិធម្មបិដក វចនសោធនៈ .......... .......... ...... ១០៣

អដ្ឋកថាវចនសោធនៈ .......... .......... ...... ១០៥

អភិធម្មបិដក បញ្ញត្តានុយោគ .......... .......... ...... ១០៩

អដ្ឋកថាបញ្ញត្តានុយោគ .......... .......... ...... ១១៤

អភិធម្មបិដក គតិអនុយោគ .......... .......... .......... ........ ១១៦

អដ្ឋកថាគតិអនុយោគ .......... .......... .......... ........ ១២៤

អភិធម្មបិដក ឧបាទាបញ្ញត្តានុយោគ .......... .......... .......... ........ ១៣១

អដ្ឋកថាឧបាទាបញ្ញត្តានុយោគ .......... .......... .......... ........ ១៤៦

អភិធម្មបិដក កល្យាណវគ្គ .......... .......... .......... ........ ១៥១

អដ្ឋកថាបុរិសការានុយោគ .......... .......... .......... ........ ១៦៤

អភិធម្មបិដក អភិញ្ញានុយោគ .......... .......... .......... ........ ១៧១
អដ្ឋកថាអភិញ្ញានុយោគ .......... .......... .......... ........ ១៧៣
អភិធម្មបិដក ញាតកានុយោគ .......... .......... .......... ........ ១៧៤
អដ្ឋកថាញាតកានុយោគ .......... .......... .......... ........ ១៨១
អភិធម្មបិដក បកិណ្ណកៈ .......... .......... .......... ........ ១៨៤
អដ្ឋកថាបដិវេធានុយោគជាដើម .......... .......... .......... ........ ១៩៥

## បរិហានិកថា

អភិធម្មបិដក បរិហានិកថា .......... .......... .......... ........ ២០១
អដ្ឋកថាភាទយុត្តិបរិហានិ .......... .......... .......... ........ ២៣៣
អដ្ឋកថាអរិយបុគ្គលសំសន្ទនបរិហានិ .......... .......... .......... ........ ២៣៨
អដ្ឋកថាសុត្តសាធនបរិហានិ .......... .......... .......... ........ ២៤១

## ព្រហ្មចរិយកថា

អភិធម្មបិដក ព្រហ្មចរិយកថា .......... .......... .......... ........ ២៤៤
អដ្ឋកថាសុទ្ធព្រហ្មចរិយកថា .......... .......... .......... ........ ២៥៨
អដ្ឋកថាសំសន្ទនព្រហ្មចរិយៈ .......... .......... .......... ........ ២៦១
អភិធម្មបិដក ឱធិសោកថា .......... .......... .......... ........... ..... ២៦៤
អដ្ឋកថាឱធិសោកថា .......... .......... .......... ........... ..... ២៧៣
អភិធម្មបិដក ជហតិកថា .......... .......... .......... ........... ..... ២៧៤
អដ្ឋកថាជហតិកថា .......... .......... .......... ........... ..... ២៨២

## សព្វមត្តីតិកថា

អភិធម្មជិបក សព្វមត្តីតិកថា .......... .......... .......... ........... ..... ២៨៤
អដ្ឋកថាភាទយុត្តិ .......... .......... .......... ........... ..... ៣១៩

អដ្ឋកថាកាលសំសន្ទនៈ .......... .......... .......... ........... ..... ៣២១
អដ្ឋកថាវចនសោធនៈ .......... .......... .......... ........... ..... ៣២២
អដ្ឋកថាអតីតចក្ខុរូបាទិកថា .......... .......... .......... ........... ..... ៣៣០
អដ្ឋកថាអតីតញ្ញាណាទិកថា .......... .......... .......... ........... ..... ៣៣០
អដ្ឋកថាអរហន្តាទិកថា .......... .......... .......... ........... ..... ៣៣១
អដ្ឋកថាបទសោធនកថា .......... .......... .......... ........... ..... ៣៣១
អដ្ឋកថាសុទ្ធសោធនៈ .......... .......... .......... ........... ..... ៣៣២

## អតីតក្ខន្ធាតិកថា

អភិធម្មបិដក អតីតក្ខន្ធាតិកថា .......... .......... .......... ........... ..... ៣៣៤
អដ្ឋកថានសុទ្ធសោធនកថា .......... .......... .......... ........... ..... ៣៤១
អដ្ឋកថាសុទ្ធសោធនៈ .......... .......... .......... ........... ..... ៣៤២

## ឯកច្ចមត្ថីតិកថា

អភិធម្មបិដក ឯកច្ចមត្ថីតិកថា .......... .......... .......... ........... ..... ៣៤៣
អដ្ឋកថាអតីតាទិឯកច្ចកថា .......... .......... .......... ........... ..... ៣៤៩
អដ្ឋកថាអនាគតាទិឯកច្ចកថា .......... .......... .......... ............ ៣៥១
អភិធម្មបិដក សតិប្បដ្ឋានកថា .......... .......... .......... ............ ៣៥២
អដ្ឋកថាសតិប្បដ្ឋានកថា .......... .......... .......... ............ ៣៥៨
អភិធម្មបិដក ហេវត្ថីតិកថា .......... .......... .......... ............ ៣៦១
អដ្ឋកថាហេវត្ថីកថា .......... .......... .......... ............ ៣៦៧

# អភិធម្មបិដក បាលីប្រែ -៨៥

អភិធម្មបិដក បរូបហារកថា .......... .......... .......... ............ ៣៦៩
អដ្ឋកថាបរូបហារកថា .......... .......... .......... ............ ៣៨៣
អភិធម្មបិដក អញ្ញាណកថា .......... .......... .......... ............ ៣៨៦

អភិធម្មបិដក កន្ធាកថា .......... .......... .......... ............ ៣៩៧
អភិធម្មបិដក បរវិតារណាកថា .......... .......... .......... ............ ៤០៦
អដ្ឋកថាអញ្ញាណកថាជាដើម .......... .......... .......... ............ ៤១៦
អភិធម្មបិដក វចីភេទកថា .......... .......... .......... ............ ៤១៧
អដ្ឋកថាវចីភេទកថា .......... .......... .......... ............ ៤២៩
អភិធម្មបិដក ទុក្ខាហារកថា .......... .......... .......... ............ ៤៣២
អដ្ឋកថាទុក្ខាហារកថា .......... .......... .......... ............ ៤៣៣
អភិធម្មបិដក ចិត្តដ្ឋិតិកថា .......... .......... .......... ............ ៤៣៤
អដ្ឋកថាចិត្តដ្ឋិតិកថា .......... .......... .......... ............ ៤៤១
អភិធម្មបិដក កុក្កុឡកថា .......... .......... .......... ............ ៤៤៣
អដ្ឋកថាកុក្កុឡកថា .......... .......... .......... ............ ៤៥០
អភិធម្មបិដក អនុបុព្វាភិសមយកថា .......... .......... .......... ............ ៤៥១
អដ្ឋកថាអនុបុព្វាភិសមយកថា .......... .......... .......... ............ ៤៦៣
អភិធម្មបិដក វោហារកថា .......... .......... .......... ............ ៤៦៦
អដ្ឋកថាវោហារកថា .......... .......... .......... ............ ៤៧២
អភិធម្មបិដក និរោធកថា .......... .......... .......... ............ ៤៧៤
អដ្ឋកថានិរោធកថា .......... .......... .......... ............ ៤៧៧

## តតិយវគ្គ

អភិធម្មបិដក ពលកថា .......... .......... .......... ............ ៤៧៩
អដ្ឋកថាពលកថា .......... .......... .......... ............ ៤៨៦
អភិធម្មបិដក អរិយន្តិកថា .......... .......... .......... ............ ៤៩០
អដ្ឋកថាអរិយន្តិកថា .......... .......... .......... ............ ៤៩៧
អភិធម្មបិដក វិមុច្ចតិកថា .......... .......... .......... ............ ៥០០

អដ្ឋកថាវិមុត្តិកថា .......... .......... .......... ............ ៥០៤
អភិធម្មបិដក វិមុច្ចមានកថា .......... .......... .......... ............ ៥០៥
អដ្ឋកថាវិមុច្ចមានកថា ........ .......... .......... ............ ៥០៩
អភិធម្មបិដក អដ្ឋមកកថា .......... .......... .......... ............ ៥១៣
អដ្ឋកថាអដ្ឋមកកថា .......... .......... .......... ............ ៥១៨
អភិធម្មបិដក អដ្ឋមកឥន្ទ្រិយកថា .......... .......... .......... ............ ៥២០
អដ្ឋកថាអដ្ឋមកស្សឥន្ទ្រិយកថា .......... .......... .......... ........... ៥២៥
អភិធម្មបិដក ទិព្វចក្ខុកថា .......... .......... .......... ........... ៥២៦
អដ្ឋកថាទិព្វចក្ខុកថា .......... .......... .......... ........... ៥២៩
អភិធម្មបិដក ទិព្វសោតកថា .......... .......... ............. ៥៣២
អដ្ឋកថាទិព្វសោតកថា .......... .......... ............. ៥៣៤
អភិធម្មបិដក យថាកម្មូបគតញ្ញាណកថា .......... .......... ............. ៥៣៥
អដ្ឋកថាយថាកម្មូបគតញ្ញាណកថា .......... .......... ............. ៥៣៨
អភិធម្មបិដក សំវរកថា .......... .......... ............. ៥៤០
អដ្ឋកថាសំវរកថា .......... .......... ............. ៥៤៤
អភិធម្មបិដក អសញ្ញកថា .......... .......... ............. ៥៤៦
អដ្ឋកថាអសញ្ញកថា .......... .......... ............. ៥៥០
អភិធម្មបិដក នេវសញ្ញានាសញ្ញាយតនកថា .......... .......... ............. ៥៥១
អដ្ឋកថានេវសញ្ញានាសញ្ញាយតនកថា .......... .......... ............. ៥៥៧

## ចតុត្ថវគ្គ

អភិធម្មបិដក គិហិអរហោតិកថា .......... .......... ............. ៥៥៨
អដ្ឋកថាគិហិស្សអរហោតិកថា .......... .......... ............. ៥៦១
អភិធម្មបិដក ឧបបត្តិកថា .......... .......... ............. ៥៦៣
អដ្ឋកថាឧបបត្តិកថា .......... .......... ............. ៥៦៧

អភិធម្មបិដក អនាសវកថា .......... .......... ............. ៥៦៩

អដ្ឋកថាអនាសវកថា .......... .......... ............. ៥៧៤

អភិធម្មបិដក សមន្នាគតកថា .......... .......... ............. ៥៧៦

អដ្ឋកថាសមន្នាគតកថា .......... .......... ............. ៥៨៤

អភិធម្មបិដក ឧបេក្ខាសមន្នាគតកថា .......... .......... ............. ៥៨៦

អដ្ឋកថាឧបេក្ខាសមន្នាគតកថា .......... .......... ............. ៥៨៧

អភិធម្មបិដក ពោធិយា ពុទ្ធោតិកថា .......... .......... ............. ៥៨៨

អដ្ឋកថាពោធិយាពុទ្ធោតិកថា .......... .......... .......... ..... ៥៩២

អភិធម្មបិដក លក្ខណកថា .......... .......... .......... ..... ៥៩៦

អដ្ឋកថាលក្ខណកថា .......... .......... .......... ..... ៦០០

អភិធម្មបិដក និយាមោក្កន្តិកថា .......... .......... .......... ..... ៦០១

អដ្ឋកថានិយាមោក្កន្តិកថា .......... .......... .......... ..... ៦០៨

អភិធម្មបិដក អបរាបិ សមន្នាគតកថា .......... .......... .......... ..... ៦១០

អដ្ឋកថាអបរាបិសមន្នាគតកថា .......... .......... .......... ..... ៦២០

អភិធម្មបិដក សព្វសញ្ញោជនប្បហានកថា .......... .......... .......... ..... ៦២១

អដ្ឋកថាសព្វសញ្ញោជនប្បហានកថា .......... .......... .......... ..... ៦២៥

## បញ្ចមវគ្គ

អភិធម្មបិដក វិមុត្តកថា .......... .......... .......... ..... ៦២៦

អដ្ឋកថាវិមុត្តកថា .......... .......... .......... ..... ៦២៩

អភិធម្មបិដក អសេក្ខញ្ញាណកថា .......... .......... .......... ..... ៦៣១

អដ្ឋកថាអសេក្ខញ្ញាណកថា .......... .......... .......... ..... ៦៣៤

អភិធម្មបិដក វិបរីតកថា .......... .......... .......... ..... ៦៣៥

អដ្ឋកថាវិបរីតកថា .......... .......... .......... ..... ៦៣៩

អភិធម្មបិដក និយាមកថា .......... .......... .......... ..... ៦៤១

អដ្ឋកថានិយាមកថា .......... .......... .......... ..... ៦៤៤
អភិធម្មបិដក បដិសម្ភិទាកថា .......... .......... .......... ..... ៦៤៧
អដ្ឋកថាបដិសម្ភិទាកថា .......... .......... .......... ..... ៦៤៩
អភិធម្មបិដក សម្មតិញ្ញាណកថា .......... .......... .......... ..... ៦៥១
អដ្ឋកថាសម្មតិញ្ញាណកថា ......... .......... .......... ..... ៦៥៣
អភិធម្មបិដក ចិត្តារម្មណកថា .......... .......... ........ ៦៥៤
អដ្ឋកថាចិត្តារម្មណកថា .......... .......... .......... ៦៥៧
អភិធម្មបិដក អនាគតញ្ញាណកថា .......... .......... .......... ៦៥៩
អដ្ឋកថាអនាគតញ្ញាណកថា .......... .......... .......... ៦៦១
អភិធម្មបិដក បច្ចុប្បន្នញ្ញាណកថា .......... .......... .......... ៦៦៤
អដ្ឋកថាបច្ចុប្បន្នញ្ញាណកថា .......... .......... .......... ៦៦៦
អភិធម្មបិដក ផលញ្ញាណកថា .......... .......... .......... ៦៦៨
អដ្ឋកថាផលញ្ញាណកថា .......... .......... .......... ៦៧០

# ទុតិយបណ្ណាសក

## ឆដ្ឋវគ្គ

អភិធម្មបិដក និយាមកថា .......... .......... ........ ៦៧៣
អដ្ឋកថានិយាមកថា .......... .......... ........ ៦៧៦
អភិធម្មបិដក បដិច្ចសមុប្បាទកថា .......... .......... ........ ៦៧៨
អដ្ឋកថាបដិច្ចសមុប្បាទកថា .......... .......... ........ ៦៨២
អភិធម្មបិដក សច្ចកថា .......... .......... .......... ៦៨៤
អដ្ឋកថាសច្ចកថា .......... .......... .......... ៦៨៧
អភិធម្មបិដក អារុប្បកថា .......... .......... ......... ៦៨៩
អដ្ឋកថាអារុប្បកថា .......... .......... .......... ៦៩១
អភិធម្មបិដក និរោធសមាបត្តិកថា .......... .......... ........... ៦៩២

អដ្ឋកថានិរោធសមាបត្តិកថា .......... .......... .......... ៦៩៤
អភិធម្មបិដក អាកាសកថា .......... .......... .......... ៦៩៦
អដ្ឋកថាអាកាសកថា .......... .......... .......... ៦៩៨
អភិធម្មបិដក អាកាសសនិទស្សនោតិកថា .......... .......... .......... ៦៩៩
អដ្ឋកថាអាកាសសនិទស្សនោតិកថា .......... .......... .......... ៧០១
អភិធម្មបិដក បឋវីធាតុសនិទស្សនោត្យាធិកថា .......... .......... .......... ៧០២
អភិធម្មបិដក ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា .......... .......... .......... ៧០៤
អភិធម្មបិដក កាយកម្មំ សនិទស្សនន្តិកថា .......... .......... .......... ៧០៥
អដ្ឋកថាបឋវីធាតុសនិទស្សនោត្យាធិកថា .......... .......... .......... ៧០៧